គ្រោងជាតិនៃប្រពៃណីនិងស្នាដៃ
COMMISSION DES MŒURS & COUTUMES

ភាសាសង្គម

ទស្សនាវដ្តី ផ្សាយជំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ៣៥ លេខ ១ ខែ មករា


ព. ស. ២៥០៥ គ. ស. ១៩៦៣

- ភ្នំពេញ -



មន្ទីរពុទ្ធសាសនបណ្ឌិត្យ នឹងក្រសួងធម្មការ ជាកន្លែងផ្សាយទស្សនវិស្តីនេះ

ប្រជុំសាសនបណ្ឌិត្យ
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE



ភ្នំពេញសន្ទេយ្យ

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

បេញ្ញារាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
	វិចារណកថារបស់ក្រសួងធម្មការ	១
	ប្រយោជន៍នៃពុទ្ធសាសនា ព្រះគេជព្រះគុណ ព្រះមុនីកោសល សូរ-ហាយ រៀបរៀង	៤
	ព្រះអភិធម្មបិដក (គម្ពីរព្រះមហាបដ្ឋាន) លោក ប៉ូ-ប៉ូ ប្រែរៀបរៀង (តពីឆ្នាំ ១៩៦២)	១៣
	មធុរសវិហិណី សម្តេចព្រះធម្មលិខិត ល្វី-ឯម ឧត្តមប្រឹក្សាប្រែរៀបរៀង (តពីឆ្នាំ ១៩៦២)	២១
	មហោសថជាតក (តពីឆ្នាំ ១៩៦២)	១៩
ផ្នែកអក្សរសាស្ត្រ		
	វិបត្តិសតិសម្បជញ្ញៈ (វិចារណកថា) លោក ផេង-គ្រីវ តែងរៀបរៀង	៤១
	ពាក្យខ្មែរប្រែពីបរទេស ដោយគណៈកម្មការជំនាញនៃការសិក្សាផ្នែកអក្សរ «ក» (តពីឆ្នាំ (១៩៦២)	៥៥
	វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះគេជព្រះគុណ ប៉ាង-ខាត់ រៀបរៀង (តពីឆ្នាំ ១៩៦២)	៥៩
	ល្បែកប្បាហ្មុងតែន លោក ផេង-គ្រីវ ប្រែពីភាសាចាវ៉ាំង (តពីឆ្នាំ ១៩៦២)	៦១
	រឿងសាមកុក លោកឧកញ៉ា ង្ហួ-ពន ប្រែរៀបរៀង (តពីឆ្នាំ ១៩៦២)	៦៧
	រឿងព្រេងចិន លោក ភ័យ-ប៊ុក ប្រែពីភាសាចាវ៉ាំង (តពីឆ្នាំ ១៩៦២)	៧៦
	ពិធីបុណ្យទៅភ្នំព្រះវិហារ	៧៩
	សកម្មភាពទូទៅ នឹងសកម្មភាពនៅធមាសទី ២ ឆ្នាំ ១៩៦២ នៃក្រុមដំណុំទំនៀមទម្លាប់ខ្មែរ	៩៣
ផ្នែកកំណត់ទិដ្ឋប្រវត្តិការណ៍		
	ពិធីអនុស្សាវរីយ៍មហាសន្និបាតនៃមន្ត្រីសង្ឃក្នុងព្រះរាជអាណាចក្រ លើកទី ១៩ ឆ្នាំ ១៩៦២	១០៧
	សុន្ទរកថានៃលោក ម៉ែន-ឈុំ អនុរដ្ឋលេខាធិការក្រសួងធម្មការ	១១៦
	សុន្ទរកថារបស់ ព្រះគេជព្រះគុណ ភាន់-អែល មេគណខែត្រតាខ្មៅ	១២២

មួយឆ្នាំមាន ១២ លេខ តម្លៃជាវ ២៣០រៀល

ពាក្យឃាត់មិនឲ្យ	ធ្វើការអាក្រក់
ជាការលាមក	ឲ្យធ្វើល្អទៅ
ឲ្យចុះសាត់ចិត្ត	កុំឲ្យហ្មងសៅ
បីនេះលោកហៅ	ពុទ្ធសាសនា

ប.ព.

វិចារណាកថា

ស្វែងរកបុណ្យ ប្រទះបានបាប

ពុទ្ធបរិស័ទពាំនន្លាយ !

មានពុទ្ធបរិស័ទខ្លះ មានសទ្ធាជ្រះថ្លាប្រកបដោយមហាកុសលសណាស់ គឺថា កាលបើដើរទៅប្រទះឃើញសត្វអណ្តើកតូច - ធំក្តី ឬត្រីជាដើម ដែលគេចាប់យកទៅពិឃាត ឬយកទៅលក់នៅទីផ្សារ ក៏បានបរិច្ចាគធនជានបែបនេះដែរ យកទៅលែងដោយកុណាធម៌ ដើម្បីជួយរំដោះជីវិតសត្វនោះ ឲ្យរួចពីសេចក្តីស្លាប់ ដើម្បីប្រាថ្នាបានឲ្យអាយុរបស់ខ្លួនបានវែងនៅឯនយូរផង នឹងឲ្យអនាគតជាតិទៅបានទទួលការសង្គ្រោះពីអ្នកដទៃផង ដូចអស់លោក-អ្នកបានជ្រាបស្រាប់ហើយ ។ កល្យាណធម៌នេះ ជាការប្រពៃណាស់ ព្រោះការនោះតាប់ថាជាជីវិតទាន គឺការស្រង់ជីវិតដល់សត្វដទៃឲ្យរួចពីសេចក្តីស្លាប់តែក្រសួងធម្មការ បានសង្កេតឃើញជាញឹកញាប់ ព្រមទាំងបាន

ខ្លួលពតិមានតិមជ្ឈដ្ឋានឡើង ។ មានតុក្កដែរស័ខ្លះមានសទ្ធាជ្រះថ្លាដូច
គោលខាងលើនេះហើយ តែខ្លះវិចារណញ្ញាណ មិនបានតិចារណាឲ្យ
សមហេតុ - ផល កាលបើបានប្រទះឃើញ ទើញបានមច្ឆជាតិនោះមក
ហើយ មិនយកទៅលែងក្នុងទឹកទេ ឬបើងត្រាំងដែលមានទំហំធំ មាន
ទឹកត្រជាក់ត្រជុំ មានអាហារបរិបូណ៌នោះឡើយ ត្រឡប់ជាយកទៅ
លែងទៅស្រះព័ទ្ធជុំវិញព្រះសក្យមុនីចេតិយ ដែលស្ថិតនៅមុខស្ថានីយ
រថអយស្ទឹយយាន ឬនៅក្នុងបូជនីយដ្ឋានខ្លះ។ល។ មានស្រះនៅមុខ
វត្តចុមវតីជាដើម ដែលជាទីចង្អៀតចង្អល់មានទឹកតិចប្រកបដោយ កំ-
ជៅទ្បាំង ហើយអាហារបរិភោគក៏គ្មានទៀត បានបណ្តាលឲ្យមច្ឆជាតិ
នោះខ្លួលវង្វេងក្នុងវេទនារហូតដល់សេចក្តីស្លាប់ ដោយសារតែអត់អាហារ
ខ្លីងតំជៅទឹកនោះទៅវិញ ។ សមដូចសុភាសិតថា «ស្វែងរកបុណ្យ
ប្រទះបានបាប » ព្រោះមានសទ្ធាជ្រះថ្លាល្អហើយ តែខ្លះវិចារណញ្ញាណ
ត្រែរិះពិចារណាឲ្យសមហេតុ - ផល ។ ដូចជាកាលពីថ្ងៃទី ៩ កុម្ភៈ
១៩៦២ នេះ បានប្រទះឃើញនៅក្នុងស្រះព័ទ្ធជុំវិញព្រះសក្យមុនីចេតិយ
មានអណ្តើក ២ ស្ទាប់ ហើយអណ្តែតខ្លួននៅលើទឹកឯណោះ អណ្តើកខ្លះ
ទៀតដែលនៅរស់ គឺខំអើតកត្រឡែកក្បែរកំពែរកអាហារ តើជីវិតសត្វ
អណ្តើកដែលនៅរស់ខ្លះនោះ ខ្លីងប្រព្រឹត្តទៅយ៉ាងណា - គួរឲ្យមាន
សេចក្តីអាណិចអធ្យមពន់ពេក ។

ក្រសួងធម្មការ មានសេចក្តីសង្ឃឹមយ៉ាងមាំថា អំណោះតាំងពីថ្ងៃនេះតទៅ ពុទ្ធបរិស័ទដែលមានសទ្ធាជ្រះថ្លា ទីដ៏ចេះពិចារណាកងុស - ត្រូវឲ្យសមហេតុ - ផល ហើយឈប់យកមកបូជាតទៅលែងកន្លងក្នុងស្រះនៃព្រះសក្យមុនីចេតិយតទៅមុខទៀត គប្បីយកទៅលែងកន្លងទឹកទន្លេឬទៅទឹកត្រពាំងដ៏ធំដ៏ជ្រៅដែលមានទំហំធំ មានទឹកត្រជាក់ត្រជំ មានអាហារបរិបូណ៌ជាការប្រពៃ ដើម្បីឲ្យសត្វនោះបានទទួលសេចក្តីសុខ តាមចំណង់ជាកុសលដើមរបស់យើង អស់កាលជាអង្វែងតទៅ ។

សុភាសិត

បង់បានកូនរស់	ឲ្យធឹកស្លរ
បង់ចិត្តស្នេហា	គិតតែប្តាក់ប្តម
បង់សុខមិនរើរ	ទេរតាមត្រណម
បង់មានមិនត្រម	ទំប្រឹងព្យាយាម

ធើង - ជ្រើ

ប្រយោជន៍នៃព្រះពុទ្ធសាសនា

ព្រះមុនីកោសល ស្វរ - មហាយ រៀបរៀង

សាសនាទាំងអស់ក្នុងសកលលោក សុទ្ធតែមានបញ្ញត្តិ មានទ្រឹស្តី មានអត្ថបទ សម្រាប់តម្រង់ដឹកនាំប្រៀនប្រដៅមនុស្ស ដើម្បីប្រយោជន៍ឲ្យគ្រាន់តែមនុស្សជឿជាក់ចិត្តថ្កាក់ថ្កុត ទៅជាទំនៀមទម្លាប់ដោយឥតហេតុផលក៏មាន ប្រដៅមនុស្សឲ្យមានសីលធម៌ក៏មាន ប៉ុន្តែក្នុងពីរនេះ យើងអ្នកនិពន្ធមិនមានបំណងអធិប្បាយអំពីប្រយោជន៍របស់សាសនាដទៃទេ សូមអធិប្បាយចំពោះតែប្រយោជន៍នៃព្រះពុទ្ធសាសនាក្នុងប្រទេសកម្ពុជាយើងប៉ុណ្ណោះ ដូចសេចក្តីតទៅនេះ :

វិជ្ជានៃពុទ្ធសាសនា ជាវិជ្ជាដែលមានគុណភាពមានតម្លៃ គួរអ្នកសិក្សាចំណាយពេលវេលា ដើម្បីសិក្សាគម្ពីរព្រះពុទ្ធសាសនាដែលជាសាសនារបស់ជ្តីខ្លួនយើងឲ្យយល់គោលបំណងរបស់ព្រះពុទ្ធ ទំនៀមលោកអ្នកប្រាជ្ញក្នុងសម័យជាន់មុនផង ដើម្បីស្គាល់ប្រាស់នូវប្រយោជន៍របស់សាសនាក្នុងបច្ចុប្បន្នទំនៀមរបរលោកផង ព្រោះថាសាសនាទាំងអស់ សុទ្ធតែមានទ្រឹស្តីសម្រាប់ប្រៀនប្រដៅមនុស្ស ឲ្យចុះចូលជឿតាមឧត្តមគតិរបស់គ្រូអ្នកប្រៀនប្រដៅ ។ សាសនាខ្លះមានប្រយោជន៍ច្រើន សាសនាខ្លះពុំសូវមានប្រយោជន៍ ប៉ុន្តែខុកជាយ៉ាងណាក៏ដោយ យើងគួរតែសិក្សាឲ្យស្គាល់មូលហេតុនៃសាសនានោះ ។ ដើម្បីជាគ្រឿងសម្គាល់ប្លែងយោបល់

អំពីសាសនា សម្រាប់លាតត្រដាង ខ្ញុំតជាមេគំនិតក្នុងការពិភាក្សាណា មើលឲ្យកើតសតិបញ្ញាបរិបូណ៌ សម្រាប់ហានៈនៃខ្លួនយើងជាបុរសស្ត្រីអ្នកសិក្សា ។ យើងអ្នកសិក្សា ដោយការមើលសាសនាច្រើន ដោយការពិនិត្យពិចារណាច្រើន អាចឃើញប្រយោជន៍នៃព្រះពុទ្ធសាសនាច្រើនយ៉ាង ប៉ុន្តែ ក្នុងទីនេះ សូមអធិប្បាយដោយសង្ខេបតាមលោចលំ ដូចដំណើរសេចក្តីដែលត្រូវរៀបរៀងតទៅនេះ :

១ -- ព្រះពុទ្ធសាសនាជាផ្លូវនៃសន្តិភាព : ព្រះពុទ្ធសាសនាសម្បូណ៌ដោយស័ក្តិធម៌និងប្រពៃណីដ៏ល្អ ដែលគួរប្រតិបត្តិតាម ជាផ្លូវដើម្បីឲ្យកើតជ្រាជ្រួតភ្លឺថ្លាឃើញធម៌លែងខ្វល់ខ្វាយ ទាំងសេចក្តីសុខមកឲ្យដល់មនុស្សអ្នកប្រតិបត្តិ ខ្ញុំតដូចជាដួងប្រទីបមួយដ៏ធំក្នុងលោក សម្រាប់ជ្រាលបំភ្លឺមនុស្សលោកឲ្យឃើញផ្លូវប្រតិបត្តិ ដើរគាត់តម្រង់ទៅរកសន្តិសុខទាំងក្នុងបច្ចុប្បន្នទីបរលោក ជាសាសនាលួកពាក់ព័ន្ធឃើញថ្លាសតល់តំលៃមានលោកៈជាដើម ឃើញមគ្គផលនិព្វានបាន ។ ព្រះពុទ្ធសាសនាមានគុណភាពប្រកបដោយប្រយោជន៍ជាច្រើនយ៉ាង ដូចយ៉ាងការកែចម្រើនឈានលឿនទៅមុខរបស់មនុស្សលោក ក៏ច្រើនតែកើតមកអំពីព្រះពុទ្ធសាសនាជាអ្នកចង្អុលប្រាប់ជាដំបូង សូម្បីវិជ្ជាសាស្ត្រទំនើបវិទ្យាសាស្ត្រដែលពាក់ព័ន្ធជាវិជ្ជាសម័យថ្មី ក៏ច្រើនតែកើតមកអំពីទ្រឹស្តីពុទ្ធសាសនាដែលអ្នកប្រាជ្ញបច្ចុប្បន្នផ្តិតយកមកបៀបខ្ញុំតជាមេគំនិត ។

គ្រប់ប្រទេសពាំងអស់ ច្រើនតែទទួលដឹងថា សេចក្តីចម្រើនក្នុងសិល្បវិទ្យាទាំងសន្តិភាពនៃសង្គមមនុស្ស ជាទទួលកំណើតអំពីពុទ្ធសាសនាដោយពិត ។ អ្នកប្រាជ្ញប្រវត្តិសាស្ត្រប្រទេសជប៉ុន ជាន សរសេរចុះក្នុងប្រវត្តិសាស្ត្រថា "ព្រះពុទ្ធសាសនា ជាសាសនាដាំ សេចក្តីចម្រើនមកប្រគល់ឲ្យប្រទេសជប៉ុន ព្រះពុទ្ធសាសនាជាន់បើកភ្នែក ប្រទេសជប៉ុនដោយច្រើស្តីមុនដំបូងបង្អស់ ឲ្យប្រទេសជប៉ុនទទួលសុខសន្តិភាពឈរមុខទៅរកសេចក្តីចម្រើន មានតិត្តិសព្ទមុនគេក្នុងចំណោមជាតិក្នុកទៀ ព្រោះហេតុនោះ យើងជាជាតិជប៉ុន នៅចុងច្បាបូជាប្រទេស គួរណាស់តែសើរើសិក្សាអនុវត្តព្រះពុទ្ធសាសនាដោយគោរពមិនត្រូវធ្វេសប្រហែស" ។ បើជាមនុស្សក្នុងសកលលោកព្រមព្រៀងគ្នាកាន់ព្រះពុទ្ធសាសនាឲ្យត្រឹមត្រូវដិតជល់គ្រប់គ្នាពាំងអស់ ប្រាកដជាជាន សន្តិភាពដោយពិតពុំខាន ។

២ – ព្រះពុទ្ធសាសនា ជាឃ្លាំងនៃការសិក្សា : ការសិក្សាពុទ្ធសាសនាគ្មានចំណង់ខាងសម្ភារនិយម ដូចវិជ្ជាបច្ចេកទេសក្នុងផ្លូវលោកដែលទាក់ទងដោយគ្រឿងសស្ត្រាវុធទេ គឺមានគោលដៅចំពោះតែខាងចិត្តនិយម ។ ប្រទេសកម្ពុជារបស់យើង ដែលបានទទួលគម្ពីរព្យាប់ព្រះពុទ្ធសាសនាមកសិក្សាឲ្យមានការចេះដឹង ក្នុងផ្លូវលំនៃសាសនាក្តី ក្នុងផ្លូវអក្សរសាស្ត្រក្តី ច្រើនតែកើតអំពីវត្តអារាមរបស់ព្រះពុទ្ធសាសនាជា

ដំបូង យើញថា ការសិក្សារបស់ខ្មែរបានទៅក្នុងហ្វាំងគឺព្រះពុទ្ធសាសនា ជាច្រើនណាស់ សូម្បីតែផ្លាំពេទ្យ ក៏ច្រើនតែកើតមកអំពីបព្វជិតពុទ្ធសាសនាដែរ ពោះបើមានវិទ្យាហាមមិនឲ្យបព្វជិតធ្វើពេទ្យមើលជម្ងឺ ក៏ហាមបានដោយក្រណាស់ ដោយហេតុបព្វជិតមើលជម្ងឺឲ្យខេ ។ មិនចាប់យកថ្លៃ។

๓ - វត្តអារាមជាសភាសែមហាជន : ការប្រជុំគ្នាដើម្បីសន្ទនាពីធម៌អាថ៌ ឬពីព្រឹត្តិការណ៍ណាមួយ តាមសេចក្តីចេះដឹងកន្លងសម័យនិយមនោះ។ ក៏ត្រូវតែធ្វើក្នុងវត្តអារាម ។ មួយទៀត វត្តអារាមខុតជាកេន្ទ្រកម្មរបស់ការជាង មានការជាងឈើការកសាងសាលាវិហារជាដើម។ ប្រកបនៃសេចក្តីចម្រើនរបស់ប្រទេសយើង ដែលមានឈ្មោះជាប់មកថាជាប្រទេសមានអក្សរសាស្ត្រ មានបុរាណវត្ថុជាកេរ្តិ៍ដំណែល មានប្រជាជាតិជាម្ចាស់ប្រទេស មានព្រះមហាក្សត្រសោយរាជ្យ ក៏ដោយអំណាចគុណនៃព្រះពុទ្ធសាសនា ឬថាព្រះពុទ្ធសាសនាខុតជាមន្ទីរសម្រាប់តាំងខុតឯកសារប្រជុំវប្បធម៌ខាងផ្នែកអក្សរសាស្ត្រ ប្រវត្តិសាស្ត្រនិងសិល្បៈហត្ថកម្មជាដើមរបស់ជាតិ ឲ្យជាតិមានជីវិតរស់នៅរហូតមក រួមសេចក្តីថា "ព្រះពុទ្ធសាសនាមានវត្តនេះហើយ ជាទីមហាសន្និបាតរបស់អ្នកស្រុក"។

๔ - វត្តអារាមជាសាលារៀន : យើងបានឃើញជាក់ច្បាស់ហើយថា វត្តអារាមកាលដែលប្រទេសយើង មិនទាន់មានសាលារៀនអក្សរសាស្ត្រ ខាងក្រៅវត្តតាមផ្លូវការនោះឡើយ មានតែវត្តអារាមហ្នឹង

ឯងជាសាលារៀន កាលដែលមិនទាន់មានមន្ទីរពេទ្យព្យាបាលរោគ
មានតែវត្តអារាមជាមន្ទីរពេទ្យ សម្រាប់មើលជម្ងឺនៃមហាជន មិនត្រឹម
តែមើលជម្ងឺកាយប៉ុណ្ណោះទេ គឺមើលជម្ងឺក្នុងចិត្តផងដែរ ព្រោះ
ថា ការកើតទុក្ខព្រួយបារម្ភក្នុងផ្លូវចិត្តនេះ ចាត់ជារោគមួយយ៉ាងចំណាស់
វត្តអារាមនៃពុទ្ធសាសនាឈ្មោះថាជាកន្លែងសម្រាប់រម្ងាប់រោគកាយ - ចិត្ត
របស់ពុទ្ធបរិស័ទដើរវត្តដែលមានទុក្ខឲ្យធូរស្រាលឲ្យជាសះស្បើយ ។

៥- **វត្តអារាមជាកន្លែងអាហារូបករណ៍** : ក្នុងខេត្តកំពង់ចាម
មានវត្តច្រើនណាស់ វត្តលង្កា វត្តបទុមវត្តីជាដើម ជាវត្តទទួលបន្ទុក
នៃពួកភិក្ខុ - សាមណេរ ទីណាក្មេងតូចធំបានច្រើនណាស់ ។ វត្តនីមួយ ។
មានភិក្ខុ សាមណេរទីណាក្មេងដែលចេញស្រុកពន្លះ អំពីស្រុក - ខេត្តផ្សេង ។
មកសំណាក់អាស្រ័យនៅ ដើម្បីសិក្សារៀនសូត្រយកចំណេះវិជ្ជា ព្រោះ
ថា ក្រុងកំពង់ចាមជាទីប្រជុំធំនៃវិជ្ជា សម្បូណ៌ដោយការសិក្សាជាងទីឯ-
ទៀត ។ ពួកភិក្ខុដែលមកនៅក្នុងវត្តទាំងនោះបានយូរឆ្នាំ ទាំងមាន
សមត្ថភាពគ្រាន់បើ ហើយបានធ្វើជាមេកុដិ មេក្រុម នៃវត្តនីមួយ ។ អាច
ទទួលចិញ្ចឹមភិក្ខុ សាមណេរទីណាក្មេងឲ្យនៅរៀនសូត្រ ពាល់តែសម្រេច
អាចទទួលលទ្ធផលនៃការសិក្សាបាន ។ ពួកក្មេងដែលមកនៅអាស្រ័យ
ជ្រកកោនក្នុងវត្តជាមួយនឹងព្រះសង្ឃនោះ សុទ្ធតែជាកូនអ្នកស្រែចម្ការ
ក្រខ័ណ្ឌទ្រព្យសម្បត្តិ ។ គួរឲ្យគាំពោះអាណិតប្តូរអាសូរពួកក្មេង

កំសត់ទាំងនេះពន់ពេក បើកុំតែមានវត្តព្រះពុទ្ធសាសនាជាកន្ទែងអាហារូបករណ៍ ប្រហែលជាក្មេងកំសត់ទាំងនោះមិនបានទទួលរស្មីការសិក្សាដូចកូនអ្នកមានទ្រព្យទេ ព្រៃរសេចក្តីឲ្យច្បាស់ថា " កូនអ្នកក្រីក្រសៅដោយសារបាយវត្ត " ទំព្រាំទ្រនៅប៉ពេញការសិក្សាទាំងរហែមរហាមពាល់តែសម្រេចផលនៃការសិក្សា អាចឡើងឋានៈទៅជាអ្នកមានដ៏ការពារខ្ពង់ខ្ពស់ តាមសមគួរដល់សមត្ថភាពរបស់ខ្លួនបាន ។ ចំណែកខាងកូនអស់លោកឥស្សរជនឬកូនគហបតី គេមិនចាប់ត្រូវការឲ្យមកជ្រកកោននៅអាស្រ័យក្នុងវត្តឡើយ ។

កូនចៅរបស់អ្នកក្រក្រ បានទទួលសេចក្តីសង្គ្រោះអំពីបវ្ជិតព្ទ្ធសាសនិតក្នុងរំនាំនីមួយ ។ បានច្រើននាក់ណាស់ ដូចយ៉ាងវត្តធំ ។ មានក្មេងចំនួនពី ៣០០ ដល់ ៤០០ នាក់ ។ ចំនួនពួកក្មេងទាំងប៉ុណ្ណេះ បើជារង្វាស់តិចទទួលយកទៅចិញ្ចឹមនោះ ភាគបង់ប្រាក់ពវិភាជាតិមិនមែនតិចទេ ក្នុងមួយឆ្នាំ ។ ក្មេងទាំងនេះ ឈ្មោះថារស់នៅដោយអាស្រ័យនឹងម្ចប់ព្រះពុទ្ធសាសនា នៅជ្រកកោនក្រោមដំណាយព្រះពុទ្ធសាសនា ហើយតស៊ូនឹងប្រឹងសិក្សា ពាល់តែបានលទ្ធផលនៃការសិក្សារបស់ខ្លួន ។ ក្នុងករណីនេះ យើញថា ព្រះពុទ្ធសាសនា នៅប្រទេសកម្ពុជាយើង មានប្រយោជន៍ធំទូលាយអាចជួយសង្គ្រោះទំនុកបម្រុងដល់ប្រទេសជាតិបានគឺថាព្រះពុទ្ធសាសនាទុកដូចជាកន្ទែងអាហារូបករណ៍មួយដ៏ប្រសើរ របស់

ពួកក្មេងអ្នកក្រីក្រ អាចចំណាយដើរតមនុស្សត្រូវការ ដែលមិនមានលំនៅសម្រាប់ជ្រកកោនធំឯអាហារបរិភោគ ។ វត្តពុទ្ធសាសនាឈ្មោះថាបានជួយសម្រួលការៈនៃរដ្ឋាភិបាល ឲ្យធូរស្រាលបានច្រើនណាស់ ។

៦- វត្តអារាមគាំទ្រទាំងផ្លូវធម៌ទាំងផ្លូវលោក : លោកគ្រូចៅអធិការ ឬ គ្រូសូត្រជាដើមក្នុងវត្តនីមួយ ។ ដែលភ្ជាក់ខ្លួនដោយការសិក្សាធម្មវិន័យ ចូលយល់ផ្លូវសិក្សាតាមសម័យនិយមទៀត ។ ការសិក្សាចម្បាំងព្រះពុទ្ធសាសនារបស់ចពួដ៏តពុទ្ធសាសនិកនោះ ជាកម្លាំងមួយដែលនាំឲ្យមានប្រយោជ្ញស្មារតីចរិបូណ៌ ក្នុងផ្លូវធម៌ផង ផ្លូវលោកផង គឺថាការសិក្សានោះអាចជួយឲ្យមានមធ្យោបាយ ជួយឲ្យមានឧត្តមគតិ មានសមត្ថភាពដល់ខ្លួន ដល់ពួកៗបាសកដើរវត្តដែលជាអ្នកសិក្សា អាចដឹកនាំចិត្តឲ្យមានសទ្ធាជ្រះថ្លាក្នុងការកសាងសេនាសនៈសម្រាប់បម្រើព្រះពុទ្ធសាសនាផង បម្រើប្រទេសជាតិផង ។ ដូចយ៉ាងសាលាសិក្សាអក្សរសាស្ត្រមានសាលាបឋមសិក្សាជាដើម ដែលកើតមានព្រោងព្រាត ក្នុងស្រុក-ខេត្តផ្សេង ។ មានវិទ្យាល័យ តាកែវ ស្វាយរៀងជាដើម ច្រើនតែកើតអំពីចំហាយនៃការសិក្សាព្រះពុទ្ធសាសនាជាដើមអាទិ៍ គឺថាសាលាសិក្សាទាំងនោះកើតឡើងបានដោយសារស្នាដៃព្រះសង្ឃ មានលោកគ្រូចៅអធិការ ឬ គ្រូសូត្រជាដើម ណែនាំពួកគ្រូហស្ថដើរវត្តឲ្យកសាងដោយឥតមើលចំណាំរដ្ឋាភិបាលឡើយ លុះ

កសាងហើយ ជូនប្រគល់សាលាសិក្សានោះ ដល់រដ្ឋាភិបាល ដើម្បីឲ្យ
ពលការចាត់ចែងរកគ្រូបង្រៀនតាមផ្លូវការតទៅដែលអាចតាំងការរដ្ឋាភិបាល
ជួយកម្ចាត់ឲ្យរដ្ឋាភិបាលចំណេញថវិកាជាតិបានច្រើនណាស់ ។

ដំណើរនេះសឲ្យឃើញថា « សាសនា គាលបើបុគ្គលណាមួយ
ប្រាថ្នាខ្លួលការពារសិក្សាល្អហើយ អាចនាំឲ្យទុះឃើញសារប្រយោជន៍
កន្លងផុតដែលមិនផង ផ្លូវលោកផង » ។ ព្រះពុទ្ធសាសនាឈ្មោះថាជាសាសនា
មួយជួយមហាជនប្រទេសកម្ពុជា ឲ្យចេះស្រឡាញ់ប្រទេសជាតិរបស់ខ្លួន
បានដោយបរិបូណ៌ ជាសាសនាមានទ្រឹស្តីល្អ អាចជួយសាងសាមគ្គី
របស់ជាតិឲ្យមានវឌ្ឍនធម៌ ឲ្យមានការគោរពជាតិ លើកតម្កើងជាតិ ។

๓ - វត្តអារាមជាកន្លែងរិប្បធម៌ជាតិ : អក្សរសាស្ត្រ
របស់ជាតិ បើកុំតែបានវត្តអារាម ប្រហែលជាសាបសូន្យអស់ទៅហើយ ។

ហេតុអ្វីក៏ពោលដូច្នេះ គាលប្រទេសយើងស្ថិតនៅក្រោមអំណាច
អាណានិគមបារទេស គេប្រើភាសាខ្មែរគ្រាន់តែបង្រៀនបាន់ប៉ុណ្ណោះ
តាមសាលារៀន មានបង្រៀនដែរ តែមានសភាពស្ពឹកស្ពើរណាស់ នៅ
តាមក្រសួងពាណិជ្ជកម្ម ប្រើសុទ្ធតែភាសាបរទេស លើកលែងតែក្រសួង
យុត្តិធម៌ចេញ ជាក្រសួងដែលមានប្រើភាសាខ្មែរ ដោយភាគច្រើន
បន្តិច ។ ចុះហេតុអ្វីក៏ភាសាខ្មែរ អក្សរសាស្ត្រខ្មែរ វប្បធម៌ខ្មែរមាន
អាយុរហូតមកដល់សព្វថ្ងៃនេះ ? ព្រោះមានវត្តអារាមជាកន្លែងចិញ្ចឹមទុក

ឲ្យមានជីវិតរស់នៅ ។ កុមារកូនអ្នកស្រុក តែងមកនៅរៀនអក្សរខ្មែរឯវត្ត-អារាម ។ ចាស កទាំងសិក្ខាការកំរៀនធម៌ព្រះពុទ្ធសាសនាដែលចារឹកជាអក្សរខ្មែរ នៅវត្តអារាម ភិក្ខុ សាមណេរសិក្សាធម៌នីយព្រះសម្ពុទ្ធ ព្រមទាំងតម្ពីរតម្រា ក្បួនច្បាប់ផ្សេង ។ ចារឹកជាអក្សរខ្មែរនៅតែក្នុងវត្តអារាម ។ ផ្លូវចុះវត្តអារាមជាឃ្លាំងអក្សរសាស្ត្រខ្មែរ ដែលទុកជាពន្ធឹរស្ទើរបស់ជាតិកាលបើបាត់អក្សរសាស្ត្រ ជាតិក៏អាប់ទិនសាបសូន្យទៅជាលំដាប់ ។ ដោយហេតុនេះ ពុទ្ធសាសនានៅប្រទេសយើង ឈ្មោះថាជាសាសនាជួយជ្រោមជ្រែងរក្សាទុកនូវវប្បធម៌អក្សរសាស្ត្រជាតិដោយពិត ។

បពិត្រជាតពុទ្ធសាសនិក ដែលបានរៀនក្នុងផ្លូវគន្ថធុរៈ គឺរៀនតម្ពីរបាលីព្រះត្រៃបិដក ចេះចាំយល់សព្ទភាសាបាលី អាចប្រែពីបាលីមកជាភាសាខ្មែរយកសេចក្តីបានដោយងាយ ទើងនិពន្ធជាសៀវភៅសិក្សាជាដំបូន្មានអប់រំ ជាកំនិពន្ធន៍ ជារឿងលេខប្រកបដោយគតិវៃឆ្លៀវ ខ្លីខ្លះ បានចោះពុម្ពផ្សាយជាសៀវភៅធម៌អាថ៌ជំតូចតរគោក សូមអញ្ជើញមើលក្នុងមន្ទីរ ពុទ្ធសាសនបណ្ឌិត្យ ទើងឃើញសៀវភៅខ្មែរជេរជាសមានព្រះត្រៃបិដកជាដើមព្រមទាំងបណ្ណាគារផ្សេង ។ ទើងឃើញសៀវភៅខ្មែរផ្សាយផ្នែកព្រះពុទ្ធសាសនា ចេញច្រើនតែកើតអំពីស្នាដៃព្រះសង្ឃ ដែលបានរៀនក្នុងផ្លូវព្រះពុទ្ធសាសនា ។ ប្រទេសកម្ពុជាដែលមានវប្បធម៌ចម្រើនរុងរឿងលឹម ។ មកនេះ ដោយកម្លាំងរស្មីវប្បធម៌ព្រះពុទ្ធសាសនាជាច្រើនដ ។

ព្រះអភិធម្មបិដក

(កម្ពីរព្រះមហាបដ្ឋាន)

លោក ប៊ូ-ប៊ុ រៀបរៀង

(គឺឆ្នាំ ១៩៦២)

អនន្តរប្បច្ចយ សមនន្តរប្បច្ចយ

តទនន្តរំ អនន្តរប្បច្ចយំ ឧស្សេត្វា ចិត្តចេតសិកា ធម្មា អនន្តរប្បច្ចយេន បច្ចយោតិ អាធិម្ហា អនន្តរប្បច្ចយោ ច សមនន្តរប្បច្ចយោតិ ឯកត្តោយេវ តិ ។

លំដាប់នេះ សូមវិស្ជនាកន្លងអនន្តរប្បច្ចយតទៅ សេចក្តីថា តទនន្តរំ អនន្តរប្បច្ចយំ ឧស្សេត្វា សម្តេចព្រះបរមលោកុត្តមាចារ្យ ប្រទានព្រះសទ្ធម្មទេសនាទូរអធិបតិប្បច្ចយចប់ហើយ ក្នុងលំដាប់នោះ ទើបសំដែងទូរអនន្តរប្បច្ចយជាដើមជាលំដាប់ ។ តទៅ ។ ក្នុងអនន្តរប្បច្ចយ នឹងសមនន្តរប្បច្ចយពីរបទនេះ មានសេចក្តីដូចគ្នា ឥតប្លែកគ្នាទេ ផ្សេងគ្នាតែអនន្តរប្បច្ចយពុំមានស័ល ឯសមនន្តរប្បច្ចយមានស័លចូលជាមួយផងៗ

ចិត្តនឹងចេតសិកដែលកើតកន្លងលំដាប់នោះឯង ឈ្មោះថា អនន្តរប្បច្ចយ នឹងសមនន្តរប្បច្ចយ ។ ចិត្តនឹងចេតសិកនោះកើតក្នុងលំដាប់គ្នា មិនដែលដាច់ឃ្លាតពីគ្នាឡើយ ហើយពុំមានធម្មជាតិណាមួយកើតត្រង់ចន្លោះកណ្តាលកាត់ឯទេ ដូចសម្បដិច្ឆនចិត្តជាអនន្តរប្បច្ចយនឹងសម

នន្តរប្បច្ច័យនៃវិញ្ញាណ ៣ ខ្ទង់ គឺចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ ។ សម្បដិច្ឆន្នចិត្តនេះ ជាអនន្តរប្បច្ច័យនឹងសមនន្តរប្បច្ច័យ នៃវិញ្ញាណ ៣ ខ្ទង់នោះ ។

អនាគាមិផលចិត្ត ជាអនន្តរប្បច្ច័យ នឹងសមនន្តរប្បច្ច័យនៃនិរោធសមាបត្តិ ព្រោះហេតុនិរោធសមាបត្តិមានអនាគាមិផលចិត្ត នឹងអរហត្តផលចិត្តជាទីបំផុតវង់ ជាខ្ទង់ទ្រូង ។

សន្តីរណចិត្ត គឺចិត្តសម្រាប់ពិចារណានូវអារម្មណ៍ ជាអនន្តរប្បច្ច័យនឹងសមនន្តរប្បច្ច័យនៃសម្បដិច្ឆន្នចិត្ត គឺចិត្តសម្រាប់ទទួលអារម្មណ៍ ។

វោដ្ឋវនចិត្ត គឺចិត្តសម្រាប់កំណត់ដឹងនូវអារម្មណ៍ ជាអនន្តរប្បច្ច័យនឹងសមនន្តរប្បច្ច័យនៃសន្តីរណចិត្ត ។

ជវនចិត្ត គឺចិត្តសម្រាប់រលឿន ៧ ស្ទុះ ៧ ជាអនន្តរប្បច្ច័យនឹងសមនន្តរប្បច្ច័យ នៃវោដ្ឋវនចិត្ត ។

តទាលម្ពណចិត្ត គឺចិត្តសម្រាប់ផ្តក់ទោងនូវអារម្មណ៍ ជាអនន្តរប្បច្ច័យ នឹងសមនន្តរប្បច្ច័យ នៃជវនចិត្ត ។

សហជាតប្បច្ច័យនោះ ចានដល់ចិត្តចេតសិកនឹងរូបដែលកើតឡើងព្រមគ្នា ដូចរូបកលាបៈដែលកើតនឹងរលត់ព្រមជាមួយនឹងជីវិនន្ទិចិត្ត ។

អញ្ញមញ្ញប្បច្ច័យនោះ ចានដល់ចិត្តនឹងចេតសិកដែលកើតឡើងហើយជាបច្ច័យដល់គ្នា ឲ្យសម្រេចកិច្ចការកុសលនឹងអកុសល ។

ឧបនិស្សយប្បច្ច័យនឹងឧបនិស្សយប្បច្ច័យនោះ មានសេចក្តីដូចគ្នា មិនផ្សេងគ្នាទេ ។ ឧបនិស្សយប្បច្ច័យនឹងឧបនិស្សយប្បច្ច័យនោះ បានដល់ធម៌ដែលកើតឡើង ជាធីអាស្រ័យ ជាបច្ច័យដល់គ្នានឹងគ្នា ដូចឧបាទាយរូប ២៤ តែងមានមហាភូតរូបជាធីអាស្រ័យ ។

ឧបាទាយរូប ២៤ នោះគឺ បសាទរូប ៥ គោចររូប ៤ ភាវរូប ២, ហទយរូប ១ ជីវិតរូប ១ អាហាររូប ១ បរិច្ឆេទរូប ១ វិញ្ញត្តិរូប ២ វិការរូប ៣ លក្ខណរូប ៤ ផ្សំចូលគ្នាជាឧបាទាយរូប ២៤ ។

បសាទរូប ៥ នោះ គឺ ចក្ខុប្បសាទជាធីអាស្រ័យដល់ចក្ខុវិញ្ញាណ ១ សោតប្បសាទជាធីអាស្រ័យដល់សោតវិញ្ញាណ ១ ឃានប្បសាទជាធីអាស្រ័យដល់ឃានវិញ្ញាណ ១, ជិវ្ហាបសាទជាធីអាស្រ័យដល់ជិវ្ហាវិញ្ញាណ ១ កាយបសាទជាធីអាស្រ័យដល់កាយវិញ្ញាណ ១ ។

កាយបសាទនោះ ឈ្មោះថាជាឧបនិស្សយប្បច្ច័យ នឹងឧបនិស្សយប្បច្ច័យដល់កាយវិញ្ញាណ ។ អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា បសាទរូប ៥ ប្រការមានចក្ខុប្បសាទជាដើម ជាធីអាស្រ័យដល់វិញ្ញាណ៧ ៥ មានចក្ខុវិញ្ញាណជាដើម ។ បណ្តាឧបាទាយរូប៧ ២៤ តែងមានមហាភូតរូប ៤ ជាធីអាស្រ័យ ។

មហាភូតរូប៧ ៤ នោះ គឺ បឋវីធាតុរូប ១ អាបោធាតុរូប ១ តេជោធាតុរូប ១ វាយោធាតុរូប ១ ។

បឋវីធាតុនោះ មាន ២០ ប្រការ មានកេសាជាដើម មានមត្តលុទ្ធំ
ជាបរិយោសាន ។

អាបោធាតុនោះ មាន ១២ ប្រការ មានបិត្តំ ទឹកប្រមាត់ជាដើម
មានមុត្តំ ទឹកនោមជាបរិយោសាន ។

តេជោធាតុនោះ មាន ៤ ប្រការ មានសន្តប្បត្តិ គឺភ្លើងដែល
ញ៉ាំងសរីរៈឲ្យក្តៅ ឲ្យក្តៅអុជ ។ ជាដើម ។

វាយោធាតុនោះ មាន ៦ ប្រការ មានឧទ្ធង្គមាវាតា គឺឲ្យលើបក់
ឡើងខាងលើជាដើម ។ ធាតុទាំង ៤ នេះហៅថា មហាភូតរូប ៤ ប្រការ ។

មហាភូតរូប ៤ ប្រការនេះ តែងជាទីអាស្រ័យដល់ឧបាទាយរូប
២៤ ប្រការ ។ ហេតុដូច្នោះ អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា មហាភូតរូប៤នោះ
ជានិស្សយប្បច្ច័យ ទំនងជាឧបនិស្សយប្បច្ច័យដល់គ្នា សំនួនព្រះពុទ្ធ
ដីកាទេសនានូវអនន្តរប្បច្ច័យ ទំនងសមនន្តរប្បច្ច័យ សហជាតប្បច្ច័យ
អញ្ញមញ្ញប្បច្ច័យ នីនិស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យ ទ្រង់ប្រាប់ឲ្យសត្វ
ពិចារណាឃើញបច្ច័យអម្បាលនេះ ដោយព្រះវិត្រែលក្ខណញ្ញាណ តើជាកំ
បញ្ញាចុះឃើញដោយអនិច្ចំ ទុក្ខំ អនត្តា ឲ្យពិចារណាឃើញថា បណ្តា-
ចិត្តនីងចេតសិកធម៌ទាំងពួង បើជាលោកិយហើយនីងបានខៀងខាត់នីងនាំ
ឲ្យបានសុខ នីងឲ្យបានជារបស់ខ្លួនដោះកំភតអង្គីមានឡើយ ខាងក្រោយ
នីងឃើញទីកើតនីងទីរលត់នៃធម៌ទាំងឡាយជាបច្ច័យដល់គ្នានីងគ្នា ។

និស្សយប្បច្ច័យ នឹងឧបនិស្សយប្បច្ច័យ តាំងពីប្រការនោះ ព្រះមានព្រះភាគទ្រង់ត្រាស់ទេសនា នឹងឲ្យពិចារណាឃើញថា ធម៌ទាំងរូប ๒๘ នឹងមហាភូតរូប ๔ រួមគ្នាជា ๒๘ ។ រូបតាំង ๒๘ ប្រការនោះ មិនបានខ្វៀងចាត់ទេ តាំងមកនូវខុទ្ទកៈ នឹងមិនមែនជារបស់ខ្លួន ។ កាលបណ្ឋិតពិចារណាឃើញដូច្នោះហើយ ក៏នឹងយាងចុះកាន់អរិយគោត្រភូញ្ញាណ នឹងបានព្រះសោតាបត្តិមគ្គនឹងព្រះសោតាបត្តិផល ។ ពោលមកតាំងនេះ ដោយអំណាចនៃបុគ្គលអ្នកមានប៉ារមីចាស់ក្លា ទើបអាចពិចារណាឲ្យឃើញច្បាស់លាស់ដោយ អនិច្ចំ ទុក្ខំ អនត្តាបាន ។ ឯបុគ្គលតាំងនៅក្នុងបុថុជ្ជនវិស័យ ជាបច្ចិមាជនតាសត្វកើតមកខាងក្រោយបំផុត ជាសត្វត្រាន់តែឃើញខ្លះម្តងមួយកាល នឹងបានសវនាការស្តាប់ក៏ចាត់ជាល្អប្រសើរជាងមិនបានឮមិនបានស្តាប់ ព្រោះហេតុតាក្យដែលថា អនិច្ចំ ទុក្ខំ អនត្តានេះ កាលព្រះពុទ្ធសាសនារៀវកេយអាប់ខន់ទៅ នឹងបានឮបានស្តាប់ បានពោលតាក្យថា អនិច្ចំ ទុក្ខំ អនត្តា នោះឥតអត្ថីមានឡើយ ។ ហេតុនោះ ទើបពោលថា បុគ្គលបានស្តាប់, បានធ្វើបរិកម្មការនាអនិច្ចំ ទុក្ខំ អនត្តានេះល្អប្រសើរជាងមិនបានឮ មិនបានពោល ។ ការដែលបានឮនឹងបានពោលដូច្នោះ នឹងជាឧបនិស្សយបុព្វកសនាទៅក្នុងអនាគតកាល លុះដល់ជាតិជាអវសានក៏នឹងឃើញដោយព្រះត្រៃលក្ខណញ្ញាណច្បាស់លាស់បាន លុះឃើញសិប់ សួនឆន្ទនៅយ

កិន្នឹងបានសម្រេចអរិយមគ្គអរិយផលក្នុងកាលខ្លួនជាបច្ចុប្បន្នភវិកសត្វ ។

គម្ពីព្រះបរមត្ថនេះ មានអត្ថដ៏ល្អិតសុខុមគម្ភីរភាពណាស់ កម្រនឹងសំដែងឲ្យចូលចិត្តបានងាយ នឹងនាំគម្ពីរក្នុងព្រះសូត្រមកសំដែងជាសណ្តាប់សមគួរតាមសតិបញ្ញាឲ្យយើញផ្លូវដាតួយ៉ាង ។ ក្នុងគម្ពីរតិកនិបាតអង្គុត្តរនិកាយមានអត្ថាធិប្បាយថា ឧបនិស្សយប្បច្ច័យនោះ មាន ៣ ប្រការគឺ មាន ចាត់ជាឧបនិស្សយ ១ សីល ចាត់ជាឧបនិស្សយ ១ ភាវនា ចាត់ជាឧបនិស្សយ ១ ។ ឧបនិស្សយទាំង ៣ ប្រការនេះ ឈ្មោះថា កុសលូបនិស្សយ ។ កុសលូបនិស្សយនេះ ក៏ចាត់ជាបច្ច័យរាប់បញ្ចូលក្នុងឧបនិស្សយបច្ច័យដូចគ្នា ព្រោះហេតុទាននោះ ជាឧបនិស្សយឲ្យបរិបូណ៌ដោយភោគសម្បត្តិ បរិបូណ៌ដោយបញ្ញាគុណជាបដល់បានសម្រេចព្រះអមតនិព្វាន សមតាមព្រះពុទ្ធដីកាក្នុងកាលទានសូត្រថា ភោជនទានា បុគ្គលឲ្យភោជនាហារជាទាន ឈ្មោះថា ឲ្យអាយុជាទាន ព្រោះសត្វទាំងឡាយបានបរិភោគអាហារទើបអាចញ៉ាំងជីវិតឲ្យតម្រង់នៅបាន ហើយបុគ្គលអ្នកឲ្យភោជនាហារជាទាននោះ ឈ្មោះថាឲ្យកម្លាំងជាទាន ព្រោះភោជនាហារបណ្តាលឲ្យកើតកម្លាំងពលំ បដិភាណំ ទេតិ បុគ្គលអ្នកឲ្យភោជនាហារជាទាននោះ ឈ្មោះថា ឲ្យបញ្ញាជាទាន ព្រោះបុគ្គលនឹងមានបញ្ញាចេះចាំអ្វីៗបាន ក៏ដោយសារតែបានបរិភោគអាហារ ។

មានពាក្យអធិប្បាយថា ការឲ្យគោដនាហារជាទាននោះមានផលប្លែកៗគ្នា ដោយអំណាចនៃបដិគ្គាហក:អ្នកទទួលទាន ។ អ្នកឲ្យប្រទីបជាទានឈ្មោះថា ឲ្យចក្ខុជាទាន ។ អ្នកឲ្យទីនៅជាទានឈ្មោះថា ឲ្យសុខគ្រប់ចំពូក ។ អ្នកឲ្យធម៌ជាទានឈ្មោះថា ឲ្យព្រះនិព្វានជាទាន(๑) ។ ទានទាំងនេះចាត់ជាទានូបនិស្ស័យ ។

សីល ๕ សីល ๘ សីល ๑๐ ទីឃនិកាយសីលក្ខន្ធវគ្គ ๒๗ នោះ កប់បញ្ចូលក្នុងសីលូបនិស្ស័យ ។

ការដែលចំរើនព្រះកម្មដ្ឋានបទណាមួយនោះ កប់បញ្ចូលក្នុងការនូបនិស្ស័យទាំងអស់ ។

ឧបនិស្ស័យទាំង ๓ ប្រការនេះ ជាបច្ច័យឲ្យបុគ្គលបានសម្រេចសម្បត្តិសួគ៌និងសម្បត្តិព្រះនិព្វាន ។ ហេតុនោះ ទាន សីល និងភាវនា ទើបចាត់ចូលក្នុងឧបនិស្ស័យបច្ច័យ ។

ប៉ុន្តែ ក្នុងគម្ពីរព្រះមហាបដ្ឋាននេះ សម្តេចព្រះមានព្រះភាគម៉ាន សំដៅយកទានូបនិស្ស័យ សីលូបនិស្ស័យ និងភាវនូបនិស្ស័យទាំង ๓ នេះទេ ទ្រង់ត្រាស់ទេសនាសំដៅយកចិត្តនឹងចេតសិកជាដើមដែលអាស្រ័យនូវគ្នានឹងគ្នា ។ ព្រះត្រាស់ទេសនាក្នុងបរមត្ថនោះ ជាអត្ថដ៏ល្អិតសុខុម

๑– ការឲ្យធម៌ជាទាន សំដៅយកអ្នកកសាងគម្ពីរស្លឹករឹតឬសៀវភៅជាលើកដំបូង សម្រាយក្តីផ្ញើបន្ទុកជាវសៀវភៅព្រះត្រៃបិដកដែលពុទ្ធសាសនបណ្ឌិតប្បោះពុម្ព យកទៅជាកំវត្ថុប្រទេនព្រះសង្ឃជាដើម ។

តម្ក័រភាពណាស់ កម្រនឹងពិចារណាឲ្យឃើញបានទើបយកឧបនិស្ស័យ ๓ នេះ មកសំដែងឲ្យឃើញសេចក្តីថាជាឧបនិស្សយប្បច្ច័យនឹងញ៉ាំងសត្វឲ្យបានសម្រេចព្រះនិព្វាន ។

ប្រការមួយទៀត បុញ្ញតិរ៉ាយវត្តុតាំង ๑๐ ប្រការនោះ បើពោលដោយសង្ខេបនៅត្រឹម ๓ ប្រការតើ ទានមយៈ ๑ សីលមយៈ ๑ នឹងភាវនាមយៈ ๑ តាំង ๓ ប្រការនេះ ជាធំ ជាដើមចម ជាទីអាស្រ័យនៃកុសលតាំងពួង ទើបចាត់ជាឧបនិស្សយប្បច្ច័យឲ្យសម្រេចព្រះនិព្វានបាន ឯព្រះពុទ្ធដីកាដែលទ្រង់ត្រាស់ដោយចរមត្តនោះ ទ្រង់សំដៅយកចិត្តនឹងចេតសិក យករូបធម៌នឹងនាមធម៌ដែលអាស្រ័យនូវគ្នានឹងគ្នា គឺចិត្តជាទីអាស្រ័យដល់ចេតសិក ចិត្តជាបច្ច័យដល់ចេតសិក ។ ឯចេតសិកបើគ្មានចិត្តជាទីអាស្រ័យទេ ក៏មិនអាចកើតឡើងបាន ។ បើពោលដោយសង្ខេប រូបធម៌ជាទីអាស្រ័យដល់នាមធម៌ រូបធម៌ជាបច្ច័យដល់នាមធម៌ ។ ឯនាមធម៌នោះ បើគ្មានរូបធម៌ជាទីអាស្រ័យទេ នាមធម៌ក៏គ្មានដែរ ។ ព្រះពុទ្ធទ្រង់សំដែងនូវរូបធម៌នឹងនាមធម៌តាំងពីឲ្យនេះឃើញថា រូបធម៌នឹងនាមធម៌មិនទៀងទាត់ទេ តែងតាំងឲ្យកើតទុក្ខនឹងមិនមែនជារបស់ខ្លួន ។

ព្រះសម្ពុទ្ធទ្រង់ទេសនាឧបនិស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យនេះដើម្បីឲ្យឃើញថា ធម៌ជាទីអាស្រ័យនឹងធម៌ជាបច្ច័យតាំងពួងនោះថា អនិច្ចំ ទុក្ខំ អនត្តា ។ (នៅមានត)

៨ - កបណាវត្ថុកថា

សម្តែងរឿងនិទានមនុស្សក្រសត់តវៅខៀត ដោយពាក្យថា អម្ហាកំ ភគវតិ បរិនិព្វុតេ ជួច្នេះជាដើម អធិប្បាយថា កាលព្រះមានព្រះភាគជាម្ចាស់នៃយើង ទ្រង់ចូលព្រះបរមនិព្វានទៅហើយ ក្រោយនោះមានមនុស្សក្រសត់ម្នាក់ នៅក្រុងពារាណសី តែងធ្វើការស៊ីឈ្នួលចិញ្ចឹមជីវិតដោយសេចក្តីលំបាកវេទនា ។

សម័យមួយនោះ មនុស្សចាំងឡាយ អ្នកនៅកន្លែងនោះគេបបួលគ្នាចាត់ចែងធ្វើមណ្ឌប (ពេលសម្រាប់ចំពោះព្រះអាទិត្យ) ជាដើម ហើយឲ្យទូរមហាទានក្នុងទីនោះ។ ដោយច្រើន ។ ឯមនុស្សក្រសត់នោះ លុះបានឃើញមហាទានរបស់គេហើយ ក៏គិតគិចារណាថា អាត្មាអញកើតមកជាមនុស្សទន់ឥតដៃ គ្រាន់តែដើរធ្វើការស៊ីឈ្នួលចិញ្ចឹមជីវិតបានដោយសេចក្តីលំបាកពន់ពេក ព្រោះតែអាត្មាអញពុំបានធ្វើបុណ្យទុកមកពីជាតិមុន ប្រសិនបើជាតិនេះ អាត្មាអញពុំបានធ្វើបុណ្យខៀតខេ លុះដល់ទៅជាតិខាងក្រោយ អាត្មាអញទីធំរឹងតែតែទ័លក្រលើសជាងនេះក្រៃលែង សូម្បីតែសំពត់ស្បៀកដណ្តប់ ឬទីលំនៅគ្រាន់ទីធំសំណាក់អស្រ័យក៏បានដោយកម្រថែមខៀត វេលានេះ ព្រះពុទ្ធទ្រង់

ចានត្រាស់ប្រាកដក្នុងលោកហើយ មនុស្សចាំងពួងគេចានចាត់ចែង
ឲ្យចានដល់ភិក្ខុសង្ឃ ជំរះផ្លូវទៅតា ស្ថានសួគ៌ ដូច្នេះត្រូវតែអាត្មាអញ
ចាត់ចែងឲ្យចានដូចគេទើបប្រពៃ ឯផលានិសង្សចាននេះ ខឹងកើតមាន
ដល់អាត្មាអញ ដើម្បីសេចក្តីចំរើ ដើម្បីសេចក្តីសុខ អស់កាលជា
យូរអង្វែងតទៅខាងមុខ ឯកន្លងប្បន្ននេះ សូម្បីតែអង្ករមួយនាឡិក
អាត្មាអញពុំមានផង ប្រសិនបើអា អញមិនខំព្យាយាមប្រឹងប្រែងទេនោះ
មុខជាអាត្មាអញមិនអាចនឹងញ៉ាំងប្រ យោជន៍នោះ ឲ្យសំរេចបានឡើយ ។
ហ្ន៎ឃើយចុះអាត្មាអញត្រូវតែធ្វើព្យាយ មឲ្យមាំមួន សន្សំព្រួយចំរើនខុក
ខឹងចាត់ចែងឲ្យចានដល់ភិក្ខុសង្ឃឲ្យសំរេចប្រយោជន៍តាមសមគួរចុះ ។

ចាប់ដើមតាំងតែពីកាលនោះមក ចុរសក់សត់នោះតែងដើរស្វែងធ្វើ
ការស៊ីឈ្នួលក្នុងស្រុកនោះ ។ សន្សឹំបានបន្ទុបង្កាំងឲ្យយផង បាន
រៀតចាំងឲ្យយមានសណ្តែកល្ងខឹងអង្ករជាដើមផង ដោយការស៊ីឈ្នួលខ្លះ
ដោយការសុំគេខ្លះ ហើយប្រមូលមកគុកក្នុងទីជាមួយគ្នា លុះថ្ងៃជា
ខាងក្រោយ ក៏បបួលមនុស្សចាំងឲ្យយដែលមានសទ្ធាឲ្យមកបួលធ្វើទាន
ជាមួយនឹងខ្លួន ហើយចាត់ចែងធ្វើភេងមណ្ឌបក្នុងទីនោះ ។ បានធ្វើប្រដាប់
ស្អាងមណ្ឌបនោះ ដោយគ្រឿងសំអាងផ្សេង ។ មានផ្កាឈើជាដើម
ហើយនិមន្តភិក្ខុសង្ឃប្រមាណប្រាំបីអង្គចូលមកគង់ក្នុងភេងនោះ ហើយ
ប្រគេនចុះយាសត្រមាំងម្ហូបចំណីដ៏ប្រណីតដល់ភិក្ខុចាំងអស់នោះឲ្យទាន់

ស្តប់ស្តល់ចរិបូណ៌ក្នុងកាលនោះឯង ។

លុះចំណេរមកខាងក្រោយ បុរសកំសត់នោះដឹងនឹងខ្លួនណាស់ កំបានឧត្តរលឹកដល់ទានដ៏ប្រសើរ ដែលខ្លួនបានធ្វើហើយនោះ ហេតុតែកុសលកម្មនោះឯង កំបានឡើងទៅកើតក្នុងស្ថានទេវលោកទាយមួយរំពេច ប៉ាដូចជាគេភ្ញាក់អំពីដេកលក់ដូច្នោះឯង ។

រីឯវិមានមាសយ៉ាងធំ សមគួរដល់បុណ្យរបស់ទេវបុត្រនោះ កំបានកើតឡើងប្រាកដក្នុងស្ថានទេវលោកនោះ ចំណែកឯទេវតាទាំងឡាយដែលស្ថិតនៅក្នុងទីប្រមាណប៉ុនាវុតដោយជុំវិញ សោតសឹងកាន់យកនូវគ្រឿងភូសុតត្បូងត្បូងត្រង់មានប្រការផ្សេង ។ ហើយប្រគំឡើងព្រមគ្នាក្នុងកាលនោះដែរ ។ ទាំងស្ត្រីទេពអប្សរទាំងឡាយប្រមាណមួយពាន់ តែងតាមហែរចាមរកមចំរើនទេវបុត្តនោះ អស់កាលដ៏ច្រើន ។ ទេវបុត្រនោះក៏បានសោយទិព្វសម្បត្តិដ៏ប្រសើរ ដោយឧឡារនិសង្សទានដូចបានពណ៌នាហើយនោះឯង ។

អថ តេ ភិក្ខវេ សំ លុះដល់ថ្ងៃមួយជាខាងក្រោយ មានព្រះថេរៈមួយអគ្គព្រះទាមមហាសំឃរក្ខិត លោកស្ថិតនៅក្នុងសុវណ្ណសេលវិហារ ជាព្រះថេរៈបែកធ្លាយក្នុងបដិសម្ភិទាទាំងបួន លោកបានឮពាក្យគ្រាប់ទៅតាំងពីកំណែនទេវតាទាំងឡាយ ហើយបានឃើញទេវបុត្តនោះកំពុងរុងរឿងដោយទេវសម្បត្តិដ៏អស្ចារ្យធំធេរប្រៀបមាពុំបាន ទើបលោកចូលទៅជិត

ហើយសួរនូវបុញ្ញកម្មនៃខ្មៅបុត្តនោះដោយតិស្សារ ។

ចំណែកឯខ្មៅបុត្តនោះ កំបានសម្តែងប្រាប់នូវបុញ្ញកម្មដែលខ្លួនបានធ្វើហើយ ដោយសមគួរតាមពិតដល់ព្រះថេរៈនោះឯង ។ ព្រោះហេតុនោះ បានជាព្រះតន្ត្រវចនាចារ្យពោលជាបច្ចព្រះគាថាទាំងឡាយដូចមានតទៅថា:

សព្វសោ ណ្ហាមយោ អសិ ចាសោនោ រតនាមយោ
សោ ណ្ហាសិង្គសតាកិណ្ណោ ធុទ្ធិក្កោវ បភស្សរោ
កុជាតារសតាកិណ្ណោ ក.ណ្ហាមាលាហិ មណ្ឌិតោ
មុត្តា កណ្ណាថាលម្ពន្តិ តត្ត តត្ត ឋនោរមា
ឯកកកព្ភសតាកិណ្ណោ សយថាសនវិកត្តោ
សព្វកោរកេហិ សម្បណ្ណោ បុញ្ញវន្តកិនា កតោ ។

អធិប្បាយថា ម្នាលខ្មៅតា ច្រកាខសម្រេចដោយមាសសុទ្ធ ទំនឹងកែវសុទ្ធ សំឯ ដរដោសដោយកំពូលមាសច្រើនកបរយដ៏ភ្លឺផ្លេក ។ បុគ្គលដែលក្រឡេកមើលអាចធ្វើឲ្យវង្វេងភ្នែក ទាំងដរដោសដោយកំពូលមាសច្រើនកបរយ សំឯច្រជាប់ដោយកម្រងផ្កាមាសទាំងឡាយ រីឯកែវមុក្តាសោតតំ សំយុងចុះជាភ្លឺភ្លើង មានទាំងចង្កើមផ្កា គួរជាទីរីករាយសព្វអន្ទៅនៅច្រកាខនោះ។ ឯគួច្រកាខនោះមានលែងច្រើនកបរយ ទាំងមានទំដេកខឹងទំអង្គុយដ៏វិចិត្រផ្សេង។ ខឹងត្រប់គ្រាទំដោយគ្រឿងឧបភោគបរិភោគជា-

ទិព្យវិមលជាងឈើតបុញ្ញកម្មបស់អ្នកតាក់តែងឲ្យហើយដោយពិត ។

ឯត្ថន្តិ បមុកា តន្ត កេរមណ្ឌលមជ្ឈគ្គា
តាយកា កាចិ តេនប្ប្ដិ ភនេន្តិ កាចិ តន្តិយោ
តតោ តតោវុត្តជ្ជាតេ ចាសាធនស្ស សមន្តតោ
សហជ្ជក នេវបុត្តា តមោត្វា អាជតាធយោ
ភនេន្តិ បរិភវេត្វា ឯត្ថតីតាធិជា សធា
ទុលំយន្តិ បលំយន្តិ សិលាយន្តិ សមន្តតោ
ឯវំ មហិទ្ធិកោ ធានំ អុវំ ចជ្ជោវ កាសតិ
បុញ្ញាមិ តំ នេវបុត្ត តតិ កម្ម អតរិ បុព្វេ ។

រីស្រីរថ្កាំជាទិព្យទាំងឡាយ ចានចូលទៅកាន់ទីកេរមណ្ឌល (កេងស្ពារ) ហើយច្រៀងកំកងទីនោះ ស្រីខ្លះស្រែកច្រៀង ស្រីខ្លះបន្លឺរ ស្រីខ្លះប្រគំ ស្រីខ្លះដេញរំណាលាន់ញ្ជុរំ ឯទេវបុត្រទាំងឡាយព្រមទាំងស្រីទេពអប្សរ សឹងកាន់យកទូវត្រឿងតូរ្យតន្ត្រីមានអង្គច្រាំ មានមោតគងជាដើម(១) ហើយស្ថិតនៅដុំវិញច្រាសាទ ក្នុងទីប្រមាណបីគាវុតអំពីកេងស្ពារនោះ ហើយប្រគំដោយសែ្នងមានកំនងច្រៀងជាដើមអស់កាលទាំងពួង ខ្លះសេងសែ្នងលោតរឡើងលោតចុះហើយកំ ខ្លះធ្វើសំឡេងបន្លឺរដោយបបូរមាត់ ខ្លះរកស្ទុះទៅស្ទុះមកដោយដុំវិញម្ចាស់ទេវបុត្រ។ ឥឡូវនេះ អ្នកមានវិត្ថុនុកាតច្រើនយ៉ាង បើដូចជា

๑- ក្បាច់ខ្លះថា «ស្រវែងជាដើម» ។

ព្រះចន្ទតេជាវង់ដ៏រុងរឿងឰដ៏កណ្តាលអាកាសតួរជាទីអស្ចារ្យ អាត្មាភាព
សួរនូវបុញ្ញកម្មនោះ តើកាលពីមុនអ្នកបានធ្វើបុញ្ញកម្មដូចម្តេចខ្លះ ? ។

ឯទេវបុត្តនោះ លុះបានស្តាប់ព្រះបន្ទូលសួរដូច្នោះហើយ ក៏ពោលនូវបទព្រះគាថាតាំងឰយនេះថា:

អកោសិ ពុទ្ធសេ បុព្វេ ពារាណស្យំ បុរុត្តមេ
ទានំ ទេន្តេ ឯកា តត្ថ ឯមន្តេ្តាន តិក្ខត្តុំ
ឯវន្តោ កត្តិយា សោហំ ទានំ ទេន្តេ មហាជនេ
តុដ្ឋហដ្ឋេ បមុទិតេ ឃរំ ចិន្តេសហំ តទា
សមុដ្ឋាវ្តាលញ្ជាក ឥមេ ជនា បត្តបិ
បហាតុវ បមោទិតា សមុត្តិមនុភោន្តិ តេ
ពុទ្ធុប្បាទោ អយំទានិ ឯម្មោលោកេ បវត្តតិ
សុសីលាបិ បវត្តន្តិ ទក្ខិណេយ្យា ដិនោរសា
អនុវជ្ជាវសំសាក អថាយាទ្យលុប្ជវិតា
កល្យាណវិមុខា សត្តា តាមំ កច្ចន្តិ ទុក្កតំ ។

អធិប្បាយថា: កាលពីមុនខ្ញុំបានកើតជាអ្នកកំសត់នៅក្នុងបុរីឈ្មោះពារាណសីដ៏ខ្ពង់ខ្ពស់ នៅជនតំាងឰយក្នុងទីនោះ គេបានទំមន្តក្នុងប្រើនអង្គមកឰយទាន, ឯខ្លួនខ្ញុំនោះជាអ្នកចិញ្ចឹមជីវិតដោយការស៊ីឈ្នួលគេ លុះបានឃើញមហាជនមានចិត្តត្រេកអរក៏កាយចំណាយចាយទ្រព្យឰយ

ទានដូច្នោះហើយ ខ្ញុំបានគិតយ៉ាងនេះថា ជនទាំងឡាយនេះគេបាន
សំពត់ទីឯគ្រឿងអលង្ការស្អាតពាក់ចរិបូណ៌ ជនទាំងនេះដែលគេជ្រះថ្លា
រីករាយទីបុណ្យ ហើយមុខជាទីឯបានសោយនូវសម្បត្តិជាសុខ ក្នុងបរ-
លោកដោយពិត ក៏ក្នុងបច្ចុប្បន្ននេះ ជាកាលកើតឡើងនៃព្រះពុទ្ធ ព្រះធម៌
តំពុងប្រព្រឹត្តទៅក្នុងលោក ទាំងខ្ញុំណេយ្យបុគ្គលទាំងឡាយ ដែល
ជាបុត្តនៃព្រះជិនស្រីសោត ក៏សឹងមានសីលល្អប្រព្រឹត្តទៅជានិច្ច លោក
បដិសេធសំសារវដ្ត: ដែលអ្នកប្រាជ្ញតែងគោលតំរង់ចោលហើយ
បានឮមកថា សត្វទាំងឡាយដែលមានមុខប្រាស់ចេញចាកកាឡាណ-
ធម៌ហើយ បែរទៅចំពេញអប្បាយគួមិទ្យេពេញលេញ រមែងគ្រាចំទៅ
កាន់ទុគ្គតិដោយពិត ។

ឥធាធិ ទុក្កិតោ ហុត្វា ជីវាមិ កសិវេនហំ
ឆលិទ្ធោ កបណោ ធិទ្ធោ អប្បភោគោ អធាធ្យិយោ
ឥធាធិ ពីជំ ភវេបមិ សុខេត្តេ សាធុសម្មតេ
អបេរ្យាជាម ស្វាហំបិ បរត្ថ សុខិតោសិយំ ។

ក្នុងបច្ចុប្បន្ននេះ អាត្មាអញដល់នូវសេចក្តីទុក្ខលំបាក ជាអ្នកកសិត
កំព្រា ជាមនុស្សសំណល់ឥតមានទីពឹង ឥតភោគសម្បត្តិ រស់នៅដោយ
កម្រៃតក ។ គួរតែអាត្មាអញជាំនូវពូជបុណ្យទុក ក្នុងស្រែល្អ ដែលលោក
កំណត់ថាជាស្រែបុណ្យប្រពៃ ក្នុងកាលឥឡូវនេះចុះ តទៅមុខទៀត

អាត្មាអញនឹងបានដល់នូវសេចក្តីសុខ ក្នុងបរលោកដោយពិត ។

ឥតិ ចិន្តយិ តំក្ខិត្តា កិត្តិ កត្វានឯកជា
មណ្ឌបំ តត្ថ ការេត្វា ឯមន្តេត្វាន កិត្តកេ
ទាយាសេន អទាសហំ ទាយាសំ អមតាហាំសោ
តេន កម្មវិបាកេន ឯវំលោកេ មនោរមេ
ជាតោម្ហិ ទិព្វកាមេម្ហិ មោទមានោ អនេកជា
និយាយុកោ វណ្ណវន្តោ តេជសិវ អហោសិហំ ។

លុះខ្ញុំបានតតិដូច្នេះហើយ ក៏ដើរត្រាច់ទៅសូមទានគេខ្លះ ធ្វើការស៊ីឈ្នួលគេខ្លះច្រើនសណ្ឋាន បានទូវកោតទ្រព្យជាបច្ច័យ លុមតាក់តែងហើយក៏ធ្វើមណ្ឌបក្នុងទីនោះ ស្រេចហើយនិមន្តតិក្ខុច្រើនអង្គ មកប្រគេនចង្ហាន់ជាយជាយាស លុះខ្ញុំបានប្រគេនទូវអមតរស គឺជាយាសរួចហើយ ខ្ញុំក៏បានអង្គាសទៅកើតក្នុងស្ថានសួគ៌ទេវលោក ដែលជាទីរីករាយដោយកាមគុណជាទិព្វគាំងឡាយ ខ្ញុំមានចិត្តក្សេមក្សាន្តដោយសម្បត្តិទិព្វច្រើនប្រការគឺមានអាយុវែង មានពណ៌សម្បុរល្អដូចមាស មានតេជៈច្រើនដូចព្រះអាទិត្យ ដោយផលនិសង្សនៃទាននោះឯង ។

(នៅមានត)

(តមកពីភ្នំ ១៩៦២)

សារិកាធ្វើយវិញថា ប្អូនបានឃាត់បងដែរ តែបងថាប្អូនស៊ើរើមាន់ចិត្តមិនត្រង់នឹងបង ទើបប្អូនស្រដីរឿងអភ្លមង្គលច្រាប់បង ។ សេកឃាត់សារិកាថា ន! សារិកាស្អួនបងអើយ កុំស្រដីសសោះអន្ទងខ្លាចអភ្លមង្គលដល់យើងទាំងពីរពុំថែនឹងគ្នា រីបក្សីទាំងពីរ ត្រេកអរសាទរនឹងគ្នាស្នេហាលុះអស់រាត្រីកាលយូរបន្តិចទៅ មានកាលសម័យថ្ងៃមួយ សេកសោមបណ្ឌិតទិតទៅខៀបដឹតសារិកាបរចោសំណេះសំណាលនឹងគ្នាថា សម្ផសាលំគេក ម៉ៃស្រីសារិកាសម្លាញ់បងអើយ បងឱបំណាស់សព្វថ្ងៃបងបង្ហើតកូនថ្មើមណាស់ ស្មើរតែដកដង្ហើមមិនរួចដោយបងមានទុក្ខច្រទំពីប្រការជាកម្រក្រៃក្រៃ ន!សារិកាពុំជាបងអើយ ចូរនាងចាំស្តាប់បងនឹងថ្លែងទុក្ខនោះច្រាប់នាង ទុក្ខមួយ ឣាព្រះបាទសិរីរ៉ែទេហាជឥសូរតំតួលបង ប្រើបងមកកេកឥយាថា បើបានតាប់ចិត្តហើយ កុំព្រងើយទៅច្រមក់អស់កាលយូរ ចូរបាត្រឡប់មកជានាប់ច្រាប់ឣញ ។ នឹងប្រដាប់ទៅធ្វើឣាពាហ៍ពិពាហ៍ ព្រះករុណាឆ្លាំថាដូច្នេះ សារិកាពុំជាមាសបងអើយ ទុក្ខមួយនោះណាបងនឹងទៅ តាលំយាទៅជាសង្ឃរស្នេហាស្មើដង្ហើមថ្មើមបង បើនឹងទៅឯក្តៅកូនហាប្តូយពុសដូចជានឹងនេះដូចនឹងប្រែឆ្នាយចេញ ឯមេញកូនចិត្តបង សារិកាពុំជាស្អួនបង នាងគិត

ពាក្យណាមើលនេះ បងនៅខ្លាចមិនចេះគិតគ្រង់នេះណាសារីកាពុំដាច់អើយ សេកស្រដីនូវបទគាថាដូច្នេះថា:

ហន្ទ ខោ មំ អនុជានាហិ រត្តិយោ សត្តមត្តិយោ
យាវាហំ សរីរាវសេសំ អាភោគេមិ មហេសិនោ
សង្ខោ ច មេ អាវុសោ សាលិកាយ ឧបដ្ឋាកត្តិ។

ម្នាលសារីកាពុំដាច់បងអើយ ចូរនាងបើកអនុញ្ញាតឲ្យបងទៅលំនៅនៃព្រះបាទសិរីរាជ បានតែ៧ថ្ងៃហើយបងនឹងទូលព្រះបាទសិរីរាជអម្ចាស់បងនោះឲ្យសព្វព្រះរាជហឫទ័យ ហើយនឹងនាំអស់បរិវារបណ្ដាការ ដូចជា ៨ថ្ងៃ បងនឹងមកដល់នាងហើយ ព្រះអង្គនឹងធ្វើអាពាហ៍ពិពាហ៍ ផ្សំយើងទាំងពីរឲ្យស្នេហានឹងគ្នា ជាសង្សារអស់កាលជាំលង់ កុំនាងខ្វល់ឯបងឡើយ កុំនាងជាទុក្ខអផ្សុកនៅឲ្យស្រណុកហាង សារីកាស្ដាប់ពាក្យសេកសោមបណ្ដិតហើយ មិនចង់ឲ្យសេកហ្វាតឃ្លាតីឯនោះ គាឡោះអាល័យក្រៃពេក ប៉ុន្តែមិនអាចដើម្បីនឹងឃាត់សេកបានឡើយ ហើយសារីកាផ្ដាំសេកនូវបទគាថាដូច្នេះថា:

ហន្ទ ខោ តំ អនុជានាមិ រត្តិយោ សត្តមត្តិយោ
សចេ ភុំ សន្ធរេឡេន ឆាកច្ឆសិ មមន្តិកំ
មញ្ញេ ចិរញ្ញនសន្តំ មំ មញ្ញេ អាគមិស្សសីតិ។

ម្នាលសេកសោមបណ្ដិតដ៏មានវាចាប្រៀបស្មោះស្មគ្គូបន្ទបបងអើយ ចិត្តប្អូនមិន

បង់ឲ្យបងទៅទៀយ ពុំនែអាស្បាត្រះថាខជាអម្ងាស់របស់បងនោះជាខមួង់ ចូរបងទៅដោយព្រះគុណាឆ្នាំនោះចុះ បងសំពួតាញ់ប្អូនអើយប្អូនសូមផ្តាំថា ទៅតែ ៧ ថ្ងៃ ត្រូវត្រឡប់ម្តីមាមកដល់យល់ប្អូនវិញ ទើបប្អូនធឹងបានស្រាកទុក្ខ បទប្អូនភ្ជាប់ទៅជាមួយគួរអ្វីឃ្លាតឃ្លាតិចនៃ ទុក្ខនោះធ្ងន់ក្រែណាស់អម្ងាស់ប្អូនអើយ ប្អូនភ្ជាប់មានចៅទំនៅទ្រនំជាមួយគ្នា ប្អូនភ្ជាប់ស្តាប់សំតូកាសា ចៅចរចាស្រដី ប្អូនភ្ជាប់សុំទឹកឃ្មុំច្របល់ឆឹលាជជាក់ឆឹលលាដ៍មាសមួយ ប្អូនឆឹងចៅភ្ជាប់នៅក្រង់ជាមួយគ្នា ម្ល៉ះហើយប្អូនឆឹងស្ងាត់ស្រងាត់ម្នាក់ឯង ហៃសេកសោមបណ្ងិតសម្ងាញ់ប្អូនអើយ ប្អូនគិតច្នោះរឹងស្រណោះរឹងអាល្បោះរឹងអាល័យ ពីថ្ងៃនេះទៅចៅសម្ងាញ់ប្អូនអើយ ប្អូនគិតឥតស្លៀស្លើយឥតខំនេរ ឥតសុខ ឥតស្រណុកប៉ុនល្អដូលីទៀយ បងទៅតែ ៧ ថ្ងៃ លុះកត្រឹមួល ៨ ថ្ងៃ បើបងមិនមកដល់ប្អូនឈ្មោះថាមិនអាល័យមកដល់ប្អូនទៀយ ប្អូនក៏មិនមានដំរិតរស់នៅបាន កុំបងសន្ទិដ្ឋានគួនចិត្តថាប្អូនរស់ សមប្អូនស្លាប់មិនខាន ។ បើបងមកដល់ខុសសម្បុះនោះ មុនជាមិនបានយល់មុខប្អូនស្រី ខឹងចិត្តសំនៅដូចជាប្រក្រតីខេណ្ឌកអម្ងាស់ប្អូនអើយ ។ សេកសោមបណ្ងិតស្តាប់តាស្សាកាចរចាដូច្នោះហើយ មានចិត្តអាណិតអនាថកំទ្វើយវិញថា ហៃស្រីសារិកាពុំដឹងមាសបងអើយ! កុំនាងស្រដីដូច្នោះ ពស្រណោះអាល្បោះអាល័យក្នុងចិត្តបងក្រែពេកសត្វថ្ងៃបងកំនឹកសង្រែអាល័យមហិមាតេកហោង

តែថានឹងទៅចិត្តបងបងនៅលំនៅជាមួយនឹងនាង បងទៅ ៧ ថ្ងៃ លុះត្រឹមតាត់ប៉ុន ៨ ថ្ងៃ បើបងមិនអាល័យមិនបានមកយល់មុខប្អូនស្រីទេ បងក៏មិនមានជីវិតរស់នៅបានដែរណា អាវិតាពុំឆាមាសបងអើយ ។ សេកស្រដីថា ដូច្នោះ ប៉ុន្តែក្នុងចិត្តគិតថា អាវិកាអើយមានជីវិតរស់ក្តីស្លាប់ក្តី ប្រើអញឲ្យទៅធ្វើម្តេចហ្ន៎: សេកសោមបណ្ឌិតគិតហើយទៅស្ងាបហើរហាមាត់ផ្តាំសត្វអាវិកាថា ទៅណានាងណាអាវិកាពុំឆាមាសបងអើយ ! ៧ ថ្ងៃដូចជា ៨ ថ្ងៃ ស៊ីមប្អូនស្រីយល់មុខបងហោង ។ សេកអាវិកាស្តាប់បណ្តាំសេកសោមបណ្ឌិតផ្អកផ្អើសកង់ចិត្ត នឹងហាមាត់ស្តីពុំបាន មានតែសូតសូបសញ្ជប់សញ្ជឹងក្អែកមើលទៅសេកម៉ក់ៗ ។ សោមបណ្ឌិតហើរផ្លុកផ្លោះទៅសំរែងនាយឆ្វាយឆ្ងាយបន្តិច ហើយហើរត្រឡប់វិលមកចំពន្លឺមផ្តិតជិតចំពុះជាមួយនឹងអាវិកា ហើយពោលថា ឧស្រីអាវិកាស្ងួនបងអើយ ! បងហើរទៅហើយបងគិតដើមស្រីនឹងហើរទៅពុំរួច ឥតាំងតាំងចម្អែងស្ងាបត្រមតាំងក្រោកដើង ។ សេកសោមបណ្ឌិតផ្តិតមេត្រីស្រដីផ្តាំអាវិកាជាបង្ហើយថាទៅណានាងណាអាវិកាពុំឆាមាសបងអើយ ! នាងទំអត់ពុក្កអត់សោកអង្សាកអំម្ងាងចំរាំបងមកដល់ រួចហើយសេកទៅស្ងាបខ្ទាបឆ្ពោះទៅនគរមិថិលាដោយទៅតម្ងាំងស្មើរៀលសោះសា ទៅដល់ព្រះមហាសថហើយហើរទៅចំលើស្មា ទើបព្រះមហាសថស្តេចលើលាទៅតន់លើប្រាសាទស្ងាត់ទើបសេកថ្វែងអាថ សេចក្តីកំចាំងតាំងពួងប្រាប់ព្រះមហា-

សេចក្ដីដូចសារិកាច្រាប់នោះហោង ។ ព្រះមហាសត្វយកគំនរឈ្មុំលាយឡំនឹងលាជឲ្យសេកបរិភោគស្រេច ហើយយកប្រេងអប់ស្រឡាបខ្លួនគន្ធពាំដោរមួយវិសេនដង្គមកលាបចំពុះហូតដល់ស្នាបដកបទៅដល់ក្រចកជើង ហើយយកសេកទៅទុកក្នុងក្រន៌ដូចប្រក្រតីនោះហោង ។ រីឯស្រដីតាលព្រះមហាសត្វបណ្ឌិត អ្នកអាចប្រើទៅសេកសោមបណ្ឌិតទៅដណ្ដឹងអស់អាថ៌សារតើសេចក្ដីកំចាំងចាំងភ្លឺឆ្ងាយ អំពីសត្វសារិកាមិញស្រេចទៅប្រការអម្បាលនេះហោង ។ តមត្ថំ បកាសេន្តោ សត្ថា អាហ ។ សត្ថា ព្រះសាស្ដាចារ្យដ៏ឆ្នើប្រសើរ បកាសេន្តោ ព្រះអង្គសំដែងថ្វែងធម៌ទេសនា តមត្ថំ ខ្លួនអាចសេចក្ដីនោះ អាហ ទ្រង់ព្រះបន្ទូលថា:

តតោ ច សោ ទោ តញ្ញេ មាឡវេ សុវិមលញ្ចិ តោ
មហោសធសស្ស អត្ថាសិ សាលិ តាយ ។ចំ ។ធ្ដ្ដ ។

កិត្តកវេលៃតក្នុងដង្ហាយអើយ លំដាប់នោះ សេកសោមបណ្ឌិតវិលមកដល់មិចលាន្តរហើយ ខ្លួលពោធិសត្វតាមដំណើរពាក្យសារិកា ។ ពោធិសត្វស្ដាប់ពាក្យសេកនោះហើយ គិតថា ព្រះចាវរិទេហាកជនេះមិនយកពាក្យអញឡើយ ខ្លួនតែងតបញ្ជាលប៉ុនោះ បើអញឲ្យទៅហើយ កំណើលុះដល់ខ្លួមហាវិនាសធំក្រៃ បើដូច្នោះគួរអញក្រាបខ្លួលស្ដេច បពិត្រអម្ចាស់ឲ្យស៊ីក្ដីយសសក្ដា បើអញមិនសង្គ្រោះដោះ

ម្ភក្ខស្តេចនេះហើយ។ សមមានដំនៀល ទំងាកតតម្ពដល់អញមិនខេឡើយ
ហើយទំងមានអ្នកក្រាបដូចវៃតនទំងស្រដីថា មហាសេដ្ឋអ្នកក្រាបដូតត
ការណ៍ថ្វាយ ដូច ម្តេចកំរៀនាសបង់នូវព្រះមហាក្សត្រជាអម្ចាស់អាត្ម បើ
ដោយអញតិត តួរអញទំងទៅមុន ឲ្យជាដំណឹងមកព្រះមហាក្សត្រឲ្យ
បានដឹងសេចក្តីអំពីព្រះបាទបុលន ហើយអញទំងធ្វើព្រះនគរ រកបន្ទាយ
ឲ្យមានជាច់ណាតនោះប្រពៃ អញទំងប្រដាច់នូវពាជមន្ទីរថ្វាយព្រះបាទវៃ-
ហាពជ ជាអម្ចាស់អញហោង មួយសោតអញទំងធ្វើទម្ពង្គដើងឲ្យបានមួយ
គាវុត ហើយអញធ្វើទម្ពង្គធំឲ្យបានកន្ទះយោជន ទៅយកព្រះពជធីតាព្រះ
បាទបុលនព្រហ្មទត្តពជ ថ្វាយព្រះបាទវៃហាពជអម្ចាស់នៃអញ ។
ព្រះបាទបុលនទំងស្តេចមួយរយមួយ លើកនូវពលសកលយោធាសេនា
ពាហន ទាំងប្រាំបីដណ្តប់អង្គកិនី ហើយអញទំងអម្ចាស់អញចុះកន
ទម្ពង្គដើង ហើយឲ្យស្តេចឡើងទៅកាន់នគរវិញ ឲ្យរួចចេញដូចព្រះ
ច័ន្ទរួចចេញអំពីមាត់ក្រហូនោះហោង បើអញទៅតិតការណ៍ផងជាទម្ងន់
ម្ភងនេះ បានដូចគំនិតអញតិតហើយ ស្រីស្អុះស្តីទំងមានដល់អញ ឯព្រះ
បាទវៃហាពជមិញ ទំងសព្វព្រះពជហ្មុខ័យត្រេកអរសោមនស្សក្រៃពេក
ហោង ។ ពោធិសត្វតិតពិចារណា ដោយប្រការអម្បាលនោះស្រេច
ហើយនាំនូវអាច័រិយអំពីដំណើរសេចក្តីមានគុណ ពោធិសត្វសូត្រ
នូវបទព្រះគាថាដូច្នេះថា :

យសេ្សវ ឃរេ កុញ្ជេយ្យ កោតំ
តសេ្សវ អត្តំ បុរិសោ ឧវេយ្យាតិ ។

នរបុរសបុគ្គលឯណាមួយ ជាទន្ទវសិរីសម្បត្តិយសស័ក្តិអំពីព្រះមហាក្សត្រណាៈហ៎ីយ ពុំបំពេញប្រយោជន៍ដល់ស្តេចនោះទេហៅថាជាមិត្រក្រុស្តស្តេចនោះហោង ។ ឆន្មតាអ្នកប្រាជ្ញពុំដែលធ្វើទន្ទវអំពើក្រុស្តមិត្រឡើយ ។

ពោធិសត្វព្រះអង្គតតស្រេចហើយ លីលាទៅស្រង់ទន្ទវទឹកអប់គន្ធតិដោរប្រពៃ តីនាងអមក ប្រជាប់សម្រាប់ថ្វាយព្រះអង្គ ពុំលង់ឡើយ ស្តេចឡើងទៅភ្ជាន់ព្រះរាជមន្ទីរ ក្រាបថ្វាយបង្គំព្រះបាទវិទេហរាជ ហើយអង្គុយទៅក្នុងដំស្ថានមួយសមគួរនឹងអាត្មា ហើយទូលថាឆេះបតិក្រក្សត្រថ្លៃជាអម្ចាស់ប្រសើរអើយ ព្រះអង្គនឹងស្តេចទៅកាន់នគរចត្តបញ្ចាលឬម្តេច ព្រះបាទវិទេហរាជ ស្តាប់ពាក្យពោធិសត្វហើយមានព្រះបន្ទូលថា អើអញតតនឹងទៅ ។ ព្រះអង្គមានព្រះបន្ទូលទៀតថាមៃហបាមហោសថអើយ ចូរបាទៅនឹងអញកុំបានៅអាយឡើយ បាមហោសថអើយ បើអញពុំបាននាងបញ្ចាលចន្ទីនោះហ៎ីយ តើប្រយោជន៍អ្វីដោយរាជសម្បត្តិនេះ ចូរបាទៅមួយអន្ទឹងនឹងអញហោង ។ រីឯណើរទៅភ្ជាន់នោះ នឹងមានប្រយោជន៍ច្រើនប្រការ នឹងបានជាមេត្រីមួយអន្ទឹងនឹងព្រះបាទបុលន្ទ ហើយនឹងបាននាងបញ្ចាលចន្ទីមកជាមហេ-

ស៊ី បរិបូណ៌មួយអន្លើនឹងអញ្ជាហោង ។ ឮដំណាលនោះ ពោធិសត្វ
ស្តាប់ព្រះបន្ទូលព្រះមហាក្សត្រ នូវប្រការអម្បាលនោះហើយ ទើប
ក្រាបទូលថា ឆេះបពិត្រព្រះភូមិន្ទនរបតី ស្រីសម្តែងពេកក្សត្រថ្ងៃប្រសើរ
អើយ ពោះយោបល់ស្តេចនឹងទៅដូច្នោះ នោះអញខ្ញុំនឹងទៅជាមុខ នឹង
ទៅប្រដាប់ព្រះរាជមន្ទីរថ្វាយព្រះបាទអម្ចាស់ បើខ្ញុំប្រដាប់ព្រះរាជមន្ទីរបួច
សព្វគ្រប់បរិបូណ៌ហើយ ខ្ញុំនឹងឲ្យរាជទូតមកជូនលំអាលឯណាម៉ិញ ក៏សូម
ឲ្យអម្ចាស់ស្តេចយាងទៅកាលនោះហោង ។ ព្រះបាទវេទេហរាជស្តាប់ពាក្យ
ពោធិសត្វទូលនូវប្រការអម្បាលនោះហើយ ស្តេចទ្រង់នូវព្រះអំណរអរ
ក្រៃពេក តបថា មហោសថអ្នកប្រាជ្ញ មិនអាចតោះតើយបោះបង់បំរាស
ច្រើនឡើយ ហើយអ្នកលីលាចេញអំពីព្រះនគរនោះទៅហោង ។
តមត្ថំ បការោសេន្តោ សត្ថា អាហ ។ សត្ថា រ៉ព្រះដ៏ជាគ្រូ
បការោសេន្តោ ព្រះអង្គទ្រង់សម្តែង តមត្ថំ នូវអាថិសេចក្តីនោះ
ថាកាលដំ ឲ្យប្រាកដដល់មនុស្សសត្វផងពាំនឹងឮហើយហោលជាគាថា
ថា :

តតោ ច ថាយាសិ បុរេ មហោសថោ
បញ្ចាលរាជស្ស បុរំ សុរម្មំ ឥវាសជាឥ
មាបេតុំ វរេនហាសច្ឆាយសស្សិនោតិ ។

ភិក្ខវេ លំដាប់នោះព្រះមហោសថ

អ្នកចេញអំពីនគរមិថិលា ទៅកាន់នគរទត្តរថភ្លាល ដែលជាក្រុងជាទីរីករាយ ដើម្បីទំនិញប្រដាប់ព្រះរាជមន្ទីរ ថ្វាយព្រះបាទវិទេហរាជ ព្រះអង្គមានយសបរិវារដ៏ច្រើន ហើយគោធិសត្វ អ្នកឱ្យប្រដាប់ព្រះរាជមន្ទីរដំណាក់ស្តេចដោយទៅលង្វែកផ្លូវទៅទីមួយ ។ រវាងមួយយោជន៍ នោះអ្នកឱ្យដាក់ពុកទូរអាមាត្យជាកំណាន់យានដ៏រសេះ ហើយអ្នកផ្តាំថា ភ្នុម្ហ៊ីរីអ្នកចាំងឡាយ ចូរចងសម្រាប់ប្រដាប់ពុកយានដ៏រសេះនេះ កាលយើងយកទាងបញ្ជាលចន្ទីបានហើយ ត្រឡប់រំលឹមកនោះ ចូរគ្នាយើងយកយានដ៏និះចាំងនេះថ្វាយអម្ចាស់ នាកាលស្តេចត្រឡប់រំលឹមកនោះឱ្យដល់មិថិលានគរយ៉ាងនាប់ប្រញាប់ ឱ្យចេញផុតតំណាប់ដៃសត្រូវនោះហោង ។ រីឯគោធិសត្វឯងដ៏សោត ព្រះអង្គទៅដល់នាន្នេះស្ងើចគង្គា ហើយអ្នកឱ្យហៅទូរអាមាត្យមួយឈ្មោះអានន្ទកុមារ ទើបអ្នកនិយាយដូច្នេះថា ម្នាលអានន្ទកុមារអើយ ចូរថ្មាយកទូរជាងឈើបីរយនាក់ ទៅនៅខាងលើទឹក ហើយចូរយកឈើទ្វីមធ្វើជាទូកឱ្យបានបីរយ ហើយអញ្ជើញទៅហោង ។ ទើបព្រះបាទវិទេហរាជ ស្តេចមានព្រះបន្ទូលថា ខែហាមហោសថអើយ បើដូច្នោះតើថានឹងយកសេនាយោធា ទូរបណ្តាកាអ្វីទៅមុន តើគួរថានឹងយកទៅពុះ ។ គោធិសត្វទូលថា ឆេះ បពិត្រក្សត្រថ្លៃ ប្រសើរអើយ គួរតែប្បីមានសេនាយោធា ទូរវេហ៍ពលផងដ៏ច្រើនហោង ។ ស្តេចទ្រង់ព្រះសណ្តាប់ហើយ មានព្រះបន្ទូលថា ម្នាលចាមហោសថអើយ ! បើថា

ទ័ងយកតួលសក្កលយោធាប៉ុន្មាន ។ ក្តី កំតាមតែចាយភ្យឲ្យជួនការណ៍ទ័ង
ទៅនោះឯងហោង ។ រីព្រះមហាសត្វថា ម្នាលតម្រមហាក
អើយចូរអង្គាស់ឲ្យបើកយកអ្នកទោសផងទៅក្នុងក្តី តែឲ្យក្រុងប្រុះជ្រួល
ច្រវ៉ាក់តាងក៏ងខ្លោះឃ្លាងច្រវ៉ាក់សោនោះមក ឲ្យទៅទ័ងខ្ញុំហោង ។
ព្រះចាវិទេហរាជ ស្តេចមានព្រះបន្ទូលថា ម្នាលចាមហាសត្វអើយ
ចូរចាយកតាមតែចំណង់ចិត្តនៃចាប៉ុន្មាន ។ អញមិនថាអ្វីឡើយ ហើយ
ព្រះមហាសត្វត្រាស់ថា ទ័ងអស់សេនាយោធាទាហានឲ្យបើកយកទូវអ្នក
ទោស ទៅក្នុងតាងក៏ងខ្លោះឃ្លាងនោះ ឲ្យនាំមកទូវអ្នកទោសទាំង
អម្បាលនោះ ដើម្បីទ័ងសម្រេចទូវសារពើការ ឲ្យដ៏ស្តេចទ័ងទៅនោះ
ឲ្យមកចំរើអញហោង ។ រីព្រះមហាសត្វ អ្នកធ្វើសាធុការ តីរង្វាន់ត្រាន់
ត្រប់សត្វនោះផងហើយ អ្នកឲ្យយកសេនាជា ។ នោះ ១៨ ក្រុមសុទ្ធ
ជាអ្នកឈ្លាសសិល្បៈផ្សេង ។ ហើយអ្នកឲ្យយកជាងឈើ ជាងស្បែក
ជាងគូរបូផង ឲ្យយកទ័ទៅទូវគ្រឿងប្រើន ជាដើម តីកាំបិតត្រា ដ៏ង
បបធំ បបត្រទ័ត ទ័ងពន្លាកអន្ទងធងតាំងឡាយ ហើយអ្នកបង្គាប់រៀបតួល
សកលៈយោធាឲ្យប្រដាប់សម្រាំង ទូវបែបច្រក ឲ្យជាងឈើធ្វើគ្រឿងឲ្យល្អ
កុំបីប្រហែសស្មារតីទៅឲ្យដ៏ស្តេចនោះឡើយ ហើយឲ្យស្រាវគ្រាវជ្រៃស
រើសរកយកអ្នកទន្តប្រយោជន៍ទ័ងធ្វើបន្ទាយ ហើយចំពេញទូវសឿង
ទុកឲ្យគាប់ ហើយសឹមព្រះស្តេចត្រឡប់មកវិញហោង ។ តោធិសត្វ

ឯងអ្នកធ្នូងទៅកាន់ត្រើយគង្គានាយដោយនៅខ្លួកបរ បទនឹងសំគាល់ ជាទដើងនោះឯង ហើយថាប់ដើមអំពីឡើងតំពង់នោះ អ្នកគិតដូច្នេះថា វ៉ែស្ថានមានចម្ងាយកន្លះយោជន៍នោះអ្នកគិត នឹងធ្វើទុម្មឹធំ មានឮដ៏ស្ថាននោះ។ រីព្រះពាជមន្ទីរស្តេច មានឮដ៏ស្ថាននេះ ពោធិសត្វអ្នកគិតកត់សំគាល់ថា ទុម្មឹដើងនោះប្រមាណ ១ គាវុតក៏នឹងមានហោង ។ ចាប់ដើមអំពីទុម្មឹធំនោះ ពាប់ទៅដល់ព្រះពាជមន្ទីរស្តេចចុលនី គិតចូលទៅកាន់ទន្លេនោះហោង ។ រីព្រះបាទចុលនីពាជ ស្តេចឮដំណើរនៃពោធិសត្វថា នឹងមកច្នោះក្លែកំលុះខ្លួរអំណរក្រៃពេក ហេតុស្តេចគិតថា ឥឡូវនេះ ក្តីប្រាថ្នាអញមិញនឹងពេញបរិបូណ៌ ចូលមកដល់អញហើយ អញនឹងបានយល់មុខនៃសត្រូវអញហោង ។ រីព្រះបាទវរុណពាជ ស្តេចនឹងមកឮដ៏ស្ថាននេះមិនលែងឡើយ កាលបើដូច្នោះហើយ អញនឹងសម្លាប់អ្នកទាំងពីរនោះឲ្យស្លាប់ ហើយអញនឹងប្រមូលពាជសម្បត្តិមកសោយពាជ្យជាស្តេចឯកពាជ្យក្នុងដម្ពទ្វីបទាំងមូល រីតែឡូងក្នុងនន្ទនោះសមនឹងឆ្លាយភ្លាក់ផ្អើលអស់ស្តេចមួយរយមួយឲ្យតក់ឫទ្ធតក់ឫទ្ធយៅ តាតា រីយ ១បមាដូចក្អែកផងឃើយល់ដំបង សមនឹងចាលតង៌នោះរុះកយៅ ។ ជាកវេសុ ឡើយនឹង(១)លែងអ្នកនន្ទវង៌ រមៀលមើលខ្លួរលំអរូបសម្ប័ទនៃអាត្មា ក៏ព្រះមហាសត្វអ្នកចូលទៅកាន់ទ្វារពំង ហើយអ្នកឲ្យទៅខ្លួលប្តឹងស្តេចនោះថា ឱទ បពិត្រព្រះភូមិន្ទនរបតី ស្រីសម្ងួតខេតអម្ងាស់

(១) បណ្តាអ្នកនន្ទ ។

អើយ ឥឡូវនេះព្រះមហាសត្វ ទ្រាតជអ្នកមកថ្វាយបង្គំអម្ចាស់ហោង ។ នាកាលពាក្យស្តេចបន្ទូលថាឲ្យចូលមកដូច្នោះ ពោធិសត្វអ្នកចូលទៅបង្គំប្រណម្យស្តេច ហើយអ្នកបំរើនៅឰដ៏ស្ថានមួយគួរសមដល់អត្តា ជាអ្នកទើបនឹងមកពីឆ្ងាយនោះហោង ។ កាលនោះស្តេចបុលនីធ្វើការប្រស្រ័យបន្ទូលសួរទៅចរចារទៅវិញទៅមកនឹងពោធិសត្វនោះ ហើយដណ្តឹងថា តាត ម្ចាលចៅមហាសត្វអើយ ស្តេចវិទេហរាជនោះតើដល់មកអង្គាល់ ។ រីព្រះមហាសត្វទូលថា ទេវ បពិត្រមហារាជអើយ កាលអញខ្ញុំមកដល់ហើយនោះ បានឲ្យស្តេចត្រឡប់ទៅវិញហោង ។ ស្តេចមានព្រះបន្ទូលដណ្តឹងថា ចៅឯងតើមានបើប្រាថ្នាប្រយោជន៍អ្វីចូរព្រះសែនស្រដីនិយាយស្រាយប្រាប់អញាហោង ។ ព្រះមហាសត្វទូលថា បពិត្រមហារាជអើយ អញខ្ញុំមកនេះប្រយោជន៍ដើម្បីនឹងសម្រាប់ប្រដាប់ប្រដាបំរុងសង់ទ្វារព្រះរាជមន្ទីរ ថ្វាយស្តេចយើងខ្ញុំហោង ។ ព្រះបាទបុលនីបន្ទូលថា តាត ម្ចាលចៅមហាសត្វអើយ សាធុពិរោះពេកហោង ។ លំដាប់នោះ ស្តេចមានព្រះបន្ទូលប្រើឲ្យអ្នកផងលៀងស្បៀងអាហារដល់នាយសេនាទាំងឡាយនៃពោធិសត្វនោះ ហើយធ្វើខ្ទមសក្ការៈដល់ពោធិសត្វឲ្យនៅផង ១ ជាចំណែកព្រះមហាសត្វ ហើយស្តេចបន្ទូលថា តាត ម្ចាលចៅមហាសត្វអើយ ស្តេចវិទេហរាជជាអម្ចាស់នៃចៅនៅមិនទាន់មកដល់ដរាបណា ចៅនៅក្រសាលសប្បាយដរាបនោះហោង ។

រីឯងនឹងធ្វើអំពើតបវិញ ធ្វើដល់យើងចូរចៅទៅចុះ ។ លំដាប់នោះ ព្រះមហាសត្វពោធិសត្វអ្នកឡើងលើព្រះពន្លឺរស្មី អ្នកឈរឱ្យជើងជណ្តើរអ្នកក៏រមៀលមើលកត់សំគាល់ថា ខ្ញុំព្រះមុខ្ញុំដើងនឹងឡើងទៅលើនេះ ការនោះរឹតម្រិះនៃពោធិសត្វនោះ គិតសម្រេចស្រេចហើយហោង ហើយស្តេចមានបន្ទូលនឹងអញថា តា ម្នាលចៅមហាសត្វអើយអំពើណាដែលតបវិញនឹងធ្វើដល់យើង ចូរចៅធ្វើនូវអំពើនោះចុះ លំដាប់នោះ ពោធិសត្វអ្នកទូលស្តេចថា ឱទ្រ បពិត្រមហាពន្ធអើយអញខ្ញុំកាលចូលមកនោះអញខ្ញុំឈរទៅឱ្យជើងជណ្តើរ អញខ្ញុំឈរមើលមើលអំពើថ្មី នឹងមកឮដំស្នានេះបន្តិច ខ្ញុំយល់នូវពោសនោះពុំគាន់ស្រេច ឮដំជើងជណ្តើរធំសមនឹងកើតមានពោសនាអម្ចាស់ហោង អម្ចាស់អើយគោះយោបល់ចូលចិត្តនៃអម្ចាស់ អញខ្ញុំចង់ឱ្យបាននូវឈើនឹងធ្វើឱ្យល្អតាប់ចិត្តអម្ចាស់ ហើយតបវិញនឹងក្រាលទៅនូវកម្រាលផងតាំងឡាយ ឱ្យទូលាយទៅហើយស្តេចទ្រង់បន្ទូលថា តា ម្នាលចៅមហាសត្វអើយ មិនថ្លៃទេចូរចៅក្រាលកម្រាលឱ្យប្រពៃចុះ ។ ព្រះមហាសត្វអ្នកឱ្យទាំងចេញនូវជើងជណ្តើរនោះ ខ្ញុំព្រះមុខ្ញុំមានត្រង់ស្នានឯណាមិញ កុំអ្នកឱ្យឃក្តាមេតស្ទះត្រង់ រង់ពីក្រោមជើងជណ្តើរត្រង់ស្នានោះប្រយោជន៍មិនឱ្យអ្នកផងដឹង ប្រយ័ត្នមិនឱ្យមានជ្រុះនូវធូលីដីខ្សាច់ ម្តេចក៏អ្នកធ្វើមិនឱ្យកម្រើកដូច្នេះ ប្រយោជន៍នឹងក្រាលរៀបឱ្យដិតប្រកិតធ្លុតនៅជើងជណ្តើរនោះ រីស្តេចនោះសភាព

មិនដឹងនៅលង្ហែកនោះ ក៏ទុកចិត្តថា មហាសថនេះរាធ្វើទូវក្តីស្រឡាញ់អញឯងពិតប្រាកដមែន តែងឯងដូច្នោះហើយ ស្តេចតន់ស្ងៀមនៅហោង ។ សោ មហាសត្តោ ព្រះមហាសត្វនោះ កាលបើសម្រេចទូវអំពើការថ្មីនោះហើយ បុនទិវសេ លុះព្រឹកឡើងអ្នកនៅទូលស្តេចថា ទេវ បពិត្រព្រះករុណាមិនរនាថនរបតីស្រីសម្ផតិតេពប្រសើរអើយ យើងខ្ញុំនោះ យោបល់ដឹងទូវស្តាយលំនៅសមជាតិនៅនៃស្តេចយើងខ្ញុំ ស្តេចនឹងឲ្យតន់ត្រង់ស្តាយឯណាហើយក៏យើងខ្ញុំនឹងនំឲ្យជំរះឲ្យស្រឡះរាបតាបល្អ ទើបតាប់ចិត្តអញខ្ញុំហោង ។ ព្រះបាទបុរោហិតក្រាបទូលថា បណ្ឌិតវិហារថៅអ្នកប្រាជ្ញអើយ សាធុ នាគាក្យថៅថ្លែងសំដែងមកនោះពីរោះ ។ ពេក រីពាក្យអញនេះថារៀបប៉ុន្តែផ្ទះនៃអញហោង តម្រិះថៅចង់នៅផ្ទះឯណា ។ ចូរថៅយកត្រង់នោះចុះ ។ តោធិសត្តអ្នកស្តាប់ទូវព្រះបន្ទូលនៃស្តេចនោះហើយ អ្នកទូលវិញទៀតថា បពិត្រមហារាជអើយ យើងខ្ញុំនេះជាអ្នកមកអំពីស្ថានឆ្ងាយ អស់ខុនណាងស្ងួតដំនៃអម្ចាស់នោះមានច្រើនពួកដំនាផ្ទះនៃអាត្មា ហើយខ្ញុំករុណានឹងយកខុនណាងធំនោះធ្វើមុខជាមានដម្លោះប្រកែក ដាំដុតពាក្យនឹងយើងហើយ តើយើងនឹងធ្វើម្តេចមួយអន្ទឹងនឹងគេនោះបាន បើព្រះបាទអម្ចាស់យកពាក្យអ្នកធំនោះ មិនបានល្អឹកអ្វី បើអម្ចាស់យកពាក្យអស់ចាំងនោះ ឥ ខ្ញុំនេះខុសភ្លាត់ព្រួយចិត្តគេនឹងថាថៅមហាសថ ពាក្យលើអ្វីមាល្អាយម៉្លេះអេះ ។

ព្រះអង្គមានព្រះបន្ទូលថា ម៎ៃហៅថៅមហាសថអើយ រ័ស្ចានឯណា ។ ជា
ស្ចានគាប់ចិត្ត នឯងនិហើយ ចូរហៅយកនាស្ចាននោះមៅហោង ។ ឯរ
បតាត្រមហាពជអើយ អ្នកផងនោះគេនឹងមកទូលអម្ចាស់មុខជាម្ចាស់មិន
ស្រណុកព្រះទ័យនឹងយើងខ្ញុំនោះឡើយ ហើយយើងខ្ញុំនឹងយកទូរស្ចានលំ
មៅថៅជាកថណា អម្ចាស់សូមឲ្យយកជាកបនោះ រ័ពលនៃយើងខ្ញុំនឹងឲ្យ
ថៅចាំគ្នាបន្ទាយ កុំឲ្យអ្នកផងចាំងឡាយតែងនឹងមកតិតទូលព្រះករុណា
ជាអម្ចាស់ រ័ហេតុមានប្រការដូច្នេះស្រេចចុងហោង ។ លំដាប់នោះ
កាលបើអ្នកផងចាំងឡាយបានគ្នាត្រអាលចេញចូលថៅមកហើយ សម
និងស្រណុកព្រះកដហ្ចឹទ័យនៃអម្ចាស់ក្តី ចិត្តយើងខ្ញុំក្តី សមនឹងបាន
ស្រួលហោង ។ រ័ព្រះចុងចុលនិស្តេចទូលយកទូរភាក្យព្រះ
មហាសថថា សាធុ គាប់ហោង ។ ម្ល៎ះហើយតោងិសភ្នអ្នកជាតំពុក
ទូរតាលអាត្មាឯងិមៅចាំឮដីស្ចានចាំងបួន តីមៀបដើងិផណ្តើរក្តី មៀប
ក្បាលដើងិផណ្តើរក្តី ឮដីគ្នារាំងក្តី អ្នកផ្តាំដូច្នេះថា រ័ក្មេងចាំងឡាយ
កុំឲ្យមានអ្នកឯណាមួយដើម្បីនឹងចូលថៅបានឡើយ ។ លំដាប់នោះ
តោងិសភ្ន អ្នកលីលាថៅកាន់ព្រះកដមន្ទីរ ព្រះមាតានៃស្តេចនោះ ឈ្មោះ
នាងិសលាកទើ អ្នកស្រដីផ្តាំដូច្នេះថា ន្តុម្ចា រ័អ្នកចាំងឡាយ ចូរសំ-
ដែងទូរអាការៈគាប់តាសំរ៉ែលើងទូរផ្ទះនេះបងំហោង ។ រ័មនុស្សម្ចាមហា-
ជនផងចាំងឡាយ សឹងដ៏តែប្រញាយទីនៃថៅផ្ទះ នាងិសលាក-

ទេវី ប្រយោជន៍ដើម្បីនឹងនាំចេញទៅនូវឥដ្ឋក្តី នូវដីក្តី ចាប់ដើមអំពីជញ្ជាំងរនាំងជុំវិញទៅដល់ដម្បូល យកឈើត្រួលទៅខ្ទាស់ទ្វារ អាការទាំងនោះ ក្រុណានោះព្រះមាតានៃស្តេចនោះ នាងពុតជាមានទោះហើយ នាងលើលាមកស្រដីថា តាត ម្នាលក្មេង ឯងមកកាប់តាស់ផ្ទះអញធ្វើហ៎ៈ។ ព្រះមហាសត្វអ្នកស្រដីថា យើងជាន់ជាឱ្យទំលាយនេះ ប្រយោជន៍នឹងធ្វើការដើម្បីព្រះរាជមន្ទីរនៃស្តេចជាអម្ចាស់នៃយើងហោង បពិត្រព្រះនាងសលាកទេវី ទោះយោចម្ព្រះនាងថាដូច្នោះហើយ តើប្រើស្តេចអម្ចាស់យើងទៅតន់ត្រង់ស្ថានឯណាវិញ នាពលសកលយោធា សេនាមហានយានដ៏រសេះរះនេះ នៃស្តេចយើងច្រើន រត់ត្រង់ស្ថានឯទៀតយល់ជាចន្លៀតមិនគ្រាន់ឡើយ ហើយយើងធ្វើនាស្ថានឯទៃឱ្យធំទូលាយឲ្យទៅទោះយល់ជាពុំបាន មានតែត្រង់ស្ថានេះឯង ។ រីនាងសលាកទេវី នាងស្រដីថា រីអ្នកតាំងឡាយ មិនដឹងអញនេះជាព្រះមាតានៃស្តេចទេហ៎ៈ ។ តោបិសត្វអ្នកថា យើងនេះពុំដឹងថាអ្នកឯណាមួយជាព្រះវន្ទ្យអគ្គព្រះញាតិទេ នាសង្ឃឹតមកធ្វើនេះតាមដោយព្រះបន្ទូលនេះឯង ហើយមានព្រះបន្ទូលផ្តាំទៀតថា ម៎ៃចៅមហាសត្វអើយ រៀបប៉ុន្តែផ្ទះអញឯង រីផ្ទះសំណល់ក្រៅអំពីនោះ ធ្វើទៅតាមចិត្តចៅហោង ហេតុនោះហោងយើងមកធ្វើដោយនូវបន្ទូលនៃស្តេច រីយើងនឹងដឹងស្គាល់នាងនេះអ្នកនេះដូច្នេះ ។ នោះមិនដឹងឡើយ ។ នាងសលាកទេវីស្តាប់ហើយនាង

ធ្វើយវិញថា បើដូច្នោះហើយអញនឹងទៅកាន់សំណាក់នៃកូនអញហើយ
រួចមកអញនឹងដឹងឥឡូវនេះ ។ គោធិសត្វអ្នកថា យើងបានជាគាប់
គាស់រំលើងនេះ ដោយនូវពាក្យស្តេចហោង នាងមកឃាត់យើង
ដូច្នេះនេះយល់ជាពុំគប្បីឡើយ ។ រីនាងសលាកទៅឮលាហើយ
នាងទៅកាន់ភ្នាក់ង៉ែង ដោយទៅគំនិតដូច្នេះថា ឥឡូវនេះ អញនឹងដឹង
នូវអំពើរបៃអ្នកតាំងឡាយ ក្នើនោះហោង ឮដំណឹងនោះអ្នកចាំភ្នា
ជង ក៏ទាំងកំនំភ្នាក់ជាកំនំឆ្លាប់ហើយ ស្រដីដូច្នេះថា ម្នាលនាងទៅ-
អើយ កុំបីចូលទៅឡើយ ។ នាងទៅ ស្រដីថា អញនេះជាម្តាយ
ស្តេច ម្តេចឡើយកិអ្នកតាំងឡាយហ៊ានពាយបាយមិនបើកឲ្យអញ
ចូលទៅខ្នោះកូវ ។ រីឯស់អ្នកផ្នាំភ្នាងនឹងថា យើងមិនស្គាល់មិនដឹង
អ្នកជាម្តាយស្តេចទេ យើងនេះគឺស្តេចបង្គាប់ថា អ្នកតាំងឡាយកុំឲ្យ
អ្នកឯណាមួយដើម្បីនឹងចូលទៅខ្នោះ ម្ល៉ោះហើយចូរនាងចេញទៅវិញ
ទៅ ដូច្នេះហើយនាងលាទៅភ្នាងឯភ្លឺង គេសឹងថាដូចគ្នា នាងទៅ
កាន់ភ្នាងឯលិច សឹងគេថាដូច្នោះហោង ។ នាងលាទៅភ្នាងឯជើង
គេសឹងថាដូចសំដីយើងបានឮនោះហ៊ាយហោង ។ នាងសលាកទៅ
នាងមិនយល់នូវអំពើគប្បី ប្រាប់កូនហើយនាងវិលត្រឡប់មកមើលមើល
លំនៅនៃគាត្មាហើយ នាងឈរស្ងៀមទៅនោះហោង ។ ឮដំណាល
នោះមានបុរសម្នាក់ធំក្តីធំ ស្រដីនឹងនាងថា ដូនចាស់នេះតើឈរធ្វើអ្វី

នៅនេះ ចូរចៀសចេញទៅ ហើយក្រោកឡើងទៅចាប់ដៃ ព្រាន
ដួលទៅឲ្យដ៏ក្រឡាមហាប្រថពី នាងក្រោកឡើងអំពីនោះនាងគិតដូច្នេះថា
រឿងនេះគាំងនេះគឺស្តេចបង្គាប់ពិតមិនខេឡើយ គិតដូច្នោះហើយ នាង
ទៅកាន់សំណាក់ នៃចៅមហាសថអ្នកជ្រាជ្ញវិញ ហើយនាងថា
តាត ឱចៅមហាសថអើយ ហេតុអ្វីក៏ចៅឲ្យគាប់តាស់លំនៅនៃ
អញ ។ ព្រះមហាសថអ្នកមិនស្រដីមួយអន្ទើនឯងនាងឡើយ បុរស
ដែលឋិតនៅក្នុងសំណាក់ នៃមហាសថនោះថា ឱទេវី ម្នាលនាង
ខៅ អើយ នាងស្រដីម្តេចដូច្នោះ រឿងស្ថានលំនៅស្តេចវិនេហរាជ ជា
អម្ចាស់នៃយើងនឹងចង់ធ្វើត្រង់ស្ថានឯណាក៏បាន ។ នាងថាម្នាលចៅ
មហាសថអើយ អញឃើញថា រឿងស្ថានលំនៅទីនៃធំក្រៃ មានសភាព
ដូច្នេះឮដ៏ក្នុងនគរនេះឥតអង្គីមានឬ ម៉្លេះចុះចូរចៅយកមាសមួយសែន
តម្លឹងនេះ ចូរទៅធ្វើក្នុងទីឯទៀតហោង ។ ព្រះមហាសថ អ្នកថា
ឱទេវី ម្នាលនាងអើយ សាធុ ពីពេះពេកហោង រីនាងសោតចូលកុំស្រដី
ច្រាច់ទូសភាពថា យើងយកទ្រព្យសម្បត្តិនៃអ្នកឯណាមួយឡើយ ។
អញសោតនឹងឲ្យលែងនៃផ្ទះអម្ចាស់នោះហោង សូម្បីផ្ទះអ្នកដទៃឯណា
មួយ ថាម៉ែឲ្យទ្រព្យសម្បត្តិដល់យើងហើយ យើងនឹងលែងនៅផ្ទះ
អ្នកនោះហោង ។ នាងសលាក ទេវី ស្រដីថា តាត ម្នាលចៅ
មហាសថអើយ សេចក្តីគួរគប្បីៗសនោះមាន ដល់អញឯង គេ

ខ្ញុំដ៏ចំ ព្រះមាគាព្រះមហាកស្សត្រមិញ ឥឡូវនេះអ្នកឲ្យទ្រព្យទៅអ្នកដទៃវិញ យល់ខ្ញុំចង្រៃខ្ញុំដ៏ចំយើងជាកស្ត្រីទុគ៌តអ្វីមាល្បាយនេះ ហេតុនោះហើងអញមិញស្រដី ប្រាប់អ្នកដទៃឯណាមួយឡើយ ។ សោ មហាសត្តោ តស្សា សន្តិកា សុតសហាសុំ កហោត្វា សាធុតិ អាហ ។ ពោធិសត្តូនិយាយថា ម្នាលនាងអើយ ពាក្យនាងស្រដីនោះពីកេះ ។ ពេកហើង យើងខ្ញុំដ៏ចំយកមាសមួយសែនតម្លឹងអំពីនាងហើយ យើងខ្ញុំដ៏ចំលែង ខ្លួនផ្ទះនៃនាងនោះហើង ។ រីផ្ទះកែវដ្ឋព្រាហ្មណ៍ នៅត្រង់ស្ថានឯណាមិញ កំពោធិសត្តអ្នកនាំអស់បរិពារខ្លួនឲ្យទៅគាន់ស្ថាននោះ ម្ចាំះហើយអ្នកឲ្យធ្វើនៅអំពើដូចយើងខ្ញុំដ៏ចំនោលហើយអំពីមុខនោះហើង ។ រីកែវដ្ឋព្រាហ្មណ៍នោះខ្ញុំដ៏ចំមហាមា ចាតៈថើដូច្នោះធំចាំអញឯង ទៅក្រាបទូលព្រះមហាកស្សត្រមើលហ៎ៈ ម្ចាំះហើយកែវដ្ឋព្រាហ្មណ៍ដើរលេណ៎ះទៅគាន់ក្លាកំដ៏ កន្លែងនោះអស់មនុស្សម្នាមហាជនផងដ៏ចំនឲ្យ ដែលពោធិសត្តអ្នកឲ្យចាំក្លាកំដ៏ះនោះមិញ កាលបើបានយល់កែវដ្ឋព្រាហ្មណ៍ដូច្នោះហើយ អ្នកអើយខ្ញុំវាយ ខ្ញុំដ៏តែត្រូនដ៏ជបដ៏ បន្ទុះបុស្សរីផងដ៏ចំនឲ្យត្រូវដល់ខ្លួនដ៏ កែវដ្ឋព្រាហ្មណ៍តខ្លួនជានស្បែកឡើងដ៏ កែវដ្ឋព្រាហ្មណ៍នោះ មិនយល់ខ្លួនអំពើគួរចាប់កាន់ឡើយ ហើយត្រឡប់រិលមកឲ្យខ្លួមួយសែនតម្លឹងមាស ដល់ព្រះមហោសថវិញហើយ រីអស់ផ្ទះ

ដង្ហើមដឹកមួយកន្ធរនេះក្លិ ព្រះមហាសត្វអ្នកយល់ខ្លួនថាជាចេកលអ្នកយកទ្រព្យសម្បត្តិ រើសមាសបានដាច់ច្រើនគោដឹកមួយហោង ។ រីព្រះមហោសថអ្នកពិចារណាថា ឥឡូវនេះអស់កម្លាំងសាកលនគរនេះហើយកំអញនឹងទៅកាន់កដត្រកូលស្តេចវិញហោង ។ ឮដំណាលនោះ ព្រះចាទបុលនីស្តេចបន្ទូលដណ្តឹងទៅចៅមហោសថអ្នកប្រាជ្ញថា បណ្ឌិតអើយចៅអ្នកប្រាជ្ញអើយ រើស្នាលំនៅចៅតើប្រដាប់បានហើយឬនៅ ។ ពោធិសត្វថា ម្ហារាជ បពិត្រមហាក្សត្រអើយ អ្នកធង់ធាំធ្លាយតេពុំហានពាយដាយនឹងអស់យើងខ្ញុំឡើយ តេសំឯងឲ្យហោង ។ អបិ ច បន មួយនិសោត រីអស់អ្នកធាំងអម្លាសនោះថា បើយើងខ្ញុំយកហើយ រើសការនឹងប្រាសស្រឡាញ់នៃអ្នកធង់ធាំងនោះ តំលាំបាកយល់ហាក់ដូចយើងខ្ញុំឥតប្រណី នឹងធ្វើនោះយល់ពុំគួរ ឥឡូវនេះអញខ្ញុំនឹងសូមធ្វើព្រះពរមន្ទីរ នៃស្តេចយើងខ្ញុំនោះត្រាំអំពីព្រះនគរ ដំមានស្ថានបម្ងាយ ១ គាវុត ឮដំណាំងនោះមានឈ្មោះដូច្នេះ ។ នៅឮដំណាលផ្លែកនគរ នៃនេះស្នងតគ្គានោះហោង ។

(នៅមានត)

អក្សរសាស្ត្រខ្មែរ	ខ្មែរគួរចែកជួរ
ឲ្យបានខ្ជាប់ខ្ជួន	តង់រង្គៀតត់ចត់
ព្រោះអក្សរជាតិ	គោលជាតិប្រាកដ
អក្សរលេង	ជាតិកំសោយ

ប. ព.

វិបត្តិសតិសម្បជញ្ញៈ (វិចារណាកថា)

លោក ផេង-ជ្រៀវ រៀបរៀង

អ្វីជាកត្តាចម្បងដែលបណ្តាលឲ្យមានវិបត្តិនេះ? ធ្វើយ៉ាងម៉ាកត្តាចម្បងនោះគឺប្រាក់ ។ មិត្តអ្នកអានទាំងឡាយមុខជាឆ្ងឿនឆ្ងល់ទំនងយោបល់នេះ ដោយទឹកថា ប្រាក់កើតមានសម្រាប់មនុស្សប្រើតាំងពីកន្លងបុរាណកាល ដោយប្រការម្តេច ក៏សំអាងយកប្រាក់ជាកត្តានាំឲ្យមានវិបត្តិសតិសម្បជញ្ញៈ? ក្នុងបុរាណកាលពិតជាមានប្រាក់មែន តែមិនមានហេតុក្រៅមកញ៉ាំងប្រាក់ឲ្យកកេ្រញលឲ្យក្រញែងខ្លួនឲ្យសៃដែងមហិច្ឆិច្ឆដូចឥឡូវ បានជាកន្លងសម័យដើម ប្រាក់មិនសូវសៃដែងរំខ្ចីខ្ចាំងដូចបច្ចុប្បន្ន។ ប្រាក់នេះឧបមាដូចសត្វហ៊ីង ។ ហ៊ីងបើនៅជាធម្មតា ខ្លួនវាមានសភាពដូចគេដូចឯង គ្មានបណ្តាលចង់ឲ្យអ្នកណាក្រេឡេកមើលឡើយ តែកន្លងពេលណាដែលគេយកដៃ ឬ យកឈើអ្វីទៅធ្វើឲ្យប៉ះពាល់ដល់រូបកាយវា ហ៊ីងក៏ស្រាប់តែបំភ្លោំងកាយមួយរំពេច ឯប្រាក់ក៏មានឧបមេយ្យដូច្នោះ ។

តើអ្វីជាដៃ ឬ ជាឈើដែលធ្វើឲ្យប្រាក់កក្រាស ? ឆ្លើយថាគឺ
ចំនៀមខម្ញាច់ចរខេស ។

តាមរយៈហូរហែមក មនុស្សក្នុងប្រទេសណា រមែងប្រកាន់ខ្ជាប់នូវ
ចំនៀមចំលាប់ប្រទេសនោះ គឺថាតាំងតាំងលំនៅ គ្រឿងសំលៀកបំពាក់
អាហារចំណីព្រមទាំងគ្រឿងបរិភោគនឹង១បរិភោគសព្វយ៉ាង ។ ហេតុអ្វី
ក៏ដូច្នេះ ថាដោយសម្រេចទៅតាមទឹកដី ធាតុអាកាស . . . ដែលជាទី
អាស្រ័យនៅ ។

ឥឡូវតាមការសង្កេត ឃើញមានការប្រែប្រួលខ្លាំង ។ ការប្រែ
ប្រួលនេះបណ្តាលមកពីអ្វី ? ឆ្លើយថាបណ្តាលមកពីមានចំនៀមខម្ញាច់ខាង
បស្ចិមទិសចូលរុកគន់ខន្ត្រានយាងពេញទំហឹងក្នុងទ្វីបអាស៊ី ពិសេសគឺ
អាស៊ីទ្វីបភាគអាគ្នេយ៍ ម្ល៉ោះហើយអ្នកមានសមត្ថភាព អ្នកមានមធ្យោបាយ
ដែលអាចនិយមតាមចំនៀមខម្ញាច់នេះបាន ក៏ទៅជាផ្ទាស់ចំនៀមខម្ញាច់
ខ្លួនចោល ហើយប្រកាន់យកវប្បធម៌គេទុកជាវប្បធម៌ខ្លួន ។

ដោយប្រការម្តេចក៏ធ្វើដូច្នេះ ? ឆ្លើយថា វាសច្បាយ វាវែកយ វា
ហឺហាហឹកហាក់ វាន់ឲ្យត្រេកត្រអាល វាន់ឲ្យខ្ពស់មុខ វាន់ឲ្យសម្បើម ។
ត្រង់លក្ខណៈនេះហើយដែលនាំឲ្យមនុស្សផ្តើល ព្រោះមនុស្សត្រង់ហាន
ត្រូវការណាស់នូវរបស់ដូចគោលខាងលើ ម្ល៉ោះហើយមនោថលនាក៏កើត
ឡើង តែស្ទុះទៅមិនដល់ ព្រោះខ្វះសមត្ថភាព ព្រោះមធ្យោបាយមិនគ្រប់

គ្រាន់ ។ ចំណែកអ្នកមានសមត្ថភាពចេះតែស៊ុំទំផ្អែមបញ្ឆោម អ្នកមានសមត្ថភាពស្តួចស្តើងចេះតែសំឡឹងសំឡក់ ម្យ៉ាតចង់ដែរ ដូចក្មេងក្រខ្សត់បើញាក្ងូនអ្នកមានស៊ុំនំ គ្មាចង់ស៊ុដែរ ម្ល៉ោះហើយវាត្រូវតែពុំចាំដាក់ឥពុកម្តាយ ក្មេងខ្លះចិត្តដៅហ៊ានសុះឆក់ពីដៃគេយកមកស៊ុកំសឹងមាន ។

ចំពោះការខ្វះសមត្ថភាពនេះហើយដែលនាំឲ្យមនុស្សផ្លាស់ប្តូរចរិត គឺធ្វើយ៉ាងណាដែលអាចញុំាងគោលបំណងអាត្មាឲ្យសម្រេចបាន ។ ត្រង់ចំណុចនេះហើយដែលបណ្តាលឲ្យមានវិបត្តិសតិសម្បជញ្ញៈ គឺព្រះសង្ឃឈប់គិតដល់វិន័យ នាម៉ឺនឈប់គិតដល់បទបញ្ជា ប្រជាពលរដ្ឋសាមញ្ញឈប់គិតដល់ច្បាប់ខ្លួនឯ ។

វិន័យហាមផ្តាច់មិនឲ្យបព្វជិតត្រេកអរចំពោះប្រាក់ តើវិន័យនេះហួសសម័យហើយ ។ គួរតែកែប្រែឬយ៉ាងណា ? ធ្វើយថាវិន័យត្រូវនៅជាវិន័យមិនត្រូវកែប្រែទេ ព្រោះច្បាប់សាសនាមិនអាចកែប្រែផ្លាស់ប្តូរបានឡើយ បើច្បាប់មនុស្សទើបអាចកែប្រែបាន ។ បើដូច្នេះ បព្វជិតត្រូវប្រែតិបត្តិដូចម្តេច ? ថាត្រូវតែគោរពភាក្យសំដីរបស់អាត្មាកន្លងពេលដែលចួលបួស សរុបសេចក្តី បព្វជិតត្រូវតែគោរពវិន័យដូចដែលមានចែងក្នុងវិន័យចំដក ។ បើដូច្នេះ តើដូចម្តេចនឹងស្របតាមមនោចលនា ? ធ្វើយថា ព្រោះតែពេញចិត្តអនុលោមតាមមនោចលនានេះហើយ បានជាកើតមានវិបត្តិសតិ-សម្បជញ្ញៈ ។

អំពីនាម៉ឺនត្រូវវិស័យវិញ តាលព័ដើម តាមដែលខ្ញុំដឹង ក្នុងខ្ញុំថ ណាក៏ដោយ ក្នុងប្រទេសណាក៏ដោយ គេតែងឧម្ភាក់កំហុសនេះតែងៗ លើចៅក្រមខ្លះ ថាជាអ្នកពេញចិត្តកេងរកប្រាក់ ក្នុងវិស័យដទៃគេមិន សូវពោលថា មានការកេងរកប្រាក់ឡើយ តែសម័យឥឡូវ គឺមានការ ពេញឥតខ្វះចន្លោះត្រង់ណាឡើយ ហើយបើសង្កេតឲ្យហ្មត់ចត់បន្តិចទៅ ទៀតឃើញថា ខាងចៅក្រមដូចជាស្តួចស្តើងជាងវិស័យដទៃទៅវិញព្រោះ របៀបកេងរកប្រាក់ មានលក្ខណៈច្រើនបែបយ៉ាង គ្រោតគ្រាតក៏មាន សុខុមក៏មាន ដោយចំពោះក៏មាន ដោយមិនចំពោះក៏មាន ។ សូមរឿ ក្រុមខ្លះ ដែលពីដើមគេធ្លាប់ឱយមនុស្សជាក្រុមសុចរិតទៀងត្រង់មាន ជាអាទិ៍ គឺក្រុមគ្រូបង្រៀន ក្រុមឫទ្ធិលក់ពេទ្យ ។ ឥឡូវ សូមសង្កេត ពិនិត្យមើលចុះ ទៅពេលវិស្សមកាលម្តង ។ ពួកគ្រូសាមញ្ញក្តី ពួកសាស្ត្រាចារ្យក្តី តែងចេញទៅរៀនខ្លួនតាមសមត្ថភាពដើម្បីរកប្រាក់ ក្រៅពីប្រាក់បៀវត្ស បើគ្រូបង្រៀនកេងរកប្រាក់ក្នុងវិស្សមកាលហើយ តើវិស្សមកាលនឹងមានន័យដូចម្តេចទៅវិញ ? បើពួកគ្រូពេទ្យដែលខ្វះលុយ ប្រាក់បៀវត្សពឹកជការហើយមានបើកគ្លីនិក (clinique) ផ្ទាល់ខ្លួនសម្រាប់ រកប្រាក់ក្រៅ តើមុខរបរដែលខ្លួនត្រូវបំពេញចំពោះការសាធារណៈមាន ដំណើរការសាធារណៈដូចម្តេច ? ទង្វើហុចផលយ៉ាងណា ? ។ល។ សួរថា តើបើធ្វើយ៉ាងហ្នឹង វាខុសឬត្រូវ ? ចំពោះសំនួរនេះ

សូមមិត្តអ្នកអានជួយរៃប្ដូយមើលផងចុះ ។ បើខ្ញុំថាត្រូវទៅ ព្រោះមានការប៉ះពាល់ដល់ប្រយោជន៍សាធារណៈ បើខ្ញុំថាខុសទៅ បើអ្នកជិតខាងចេះតែចំពាំនំផ្អែមបញ្ចោមជាក់មុខ នាំឲ្យគ្នាស្រក់ទឹកមាត់ពាល់ថ្ងៃតើត្រូវឲ្យគ្នាគ្រាំលេបតែទឹកមាត់ខ្លះទៅឬយ៉ាងណា ? ព្រោះមនុស្សគ្រប់រូប គ្រប់ជាន់ថ្នាក់ ត្រូវការចង់រកតែសុភមង្គលដល់អាត្មារឿង ។ ខ្លួន។

ចំពោះបញ្ហានេះ តើត្រូវដោះស្រាយដូចម្ដេច ? តើអ្នកណាខ្លួលខុសត្រូវកែងការដោះស្រាយ ? ។

បើចង់ដោះស្រាយបញ្ហាវិបត្តិសតិសម្បជញ្ញៈនេះ បើតាមយោបល់ខ្ញុំគឺបានតែសុំឲ្យអ្នកមានសមត្ថភាពជួយដោះស្រាយទើបរួច សូមឲ្យគេចេះនឹកគិតអាណិតអាសូរដល់អ្នកជិតខាង ដែលគ្នាពុំមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីផ្ទាស់ប្ដូរទៅមុខម្ដាប់មោះផង សុំឲ្យគេកុំចេះតែយកទំផ្អែមមកស៊ីបញ្ចោមជាក់មុខគ្នាខ្លាំងពេក សុំឲ្យគេមេត្តាបន្ធូរបន្ថយការផ្ទាស់ប្ដូរទៅមុខម្ដាប់នេះខ្លះទៅ ។

ឯវិបត្តិសតិសម្បជញ្ញៈមែនកើតមានច្រើនតែនៅសម័យណាដែលសម្ភារៈនិយមមានការរីកចំរើនលើសលុប ។ វិបត្តិសតិសម្បជញ្ញៈនឹងគុណសម្បត្តិខាងសីលធម៌ ប្រៀបដូចជាដែកគោលពីរៈ បើតាមួយចូលតាមួយទៀតគោងតែចេញ ។ បើគេចង់ឲ្យដែកគោលទាំងពីរនេះអាស្រ័យនៅរួមគ្នា គួរគេប្រឹងតស៊ូធានាការយ៉ាងណាឲ្យវានៅជាប់ក្នុងសាច់ឈើតាម

ស្មើគ្នា មិនត្រូវសំពងឯកន្ទួតតាមួយឲ្យជ្រុះចេញឡើយ ។

សម័យបច្ចុប្បន្ន ក្នុងសាកលលោកយើញថា ថាសដញ្ជើងខាងសម្ភារៈនិយមមានកម្លាំងក្រៃពេក តែខម្លួនមិនស្មើគ្នានេះ ហើយដែលបណ្តាលឲ្យមានចលនាជាអកុសលច្រើនអនេក ចលនានេះនាំឲ្យសិល-ធម៌មានកម្លាំងខ្សោយ បើសិលធម៌ថយកម្លាំងហើយ គុណវិបត្តិត្រូវមានកម្លាំង គឺវិបត្តិសតិសម្បជញ្ញៈនេះឯង បើវិបត្តិនេះកើតច្រើនហើយនាំឲ្យមានអនាធិបតេយ្យ ជាបច្ច័យឲ្យកើតភ្លើង ។ ដូចយើងយើញស្រាប់ នៅប្រទេសជិតខាងយើង ភ្លើងនេះពេលកលកាលែតថ្ងៃ នេះមកពីអ្វី ? នេះមកតែវិបត្តិសតិសម្បជញ្ញៈ កើតមានពេញទំហឹង ។ នៅប្រទេសយើងសព្វថ្ងៃ ក៏គង់មានវិបត្តិនេះច្រើនដែរ តែពុំអាចឲ្យកើតទៅជាភ្លើងបាន ដោយសារតែផ្នាក់ជាលសង្គមដែលមានព្រះអង្គសម្តេចព្រះនរោត្តម-សីហនុ ព្រះប្រមុខរដ្ឋជាប្រធាន ព្រះអង្គជាព្រះអគ្គមហាវីរបុរសរដ្ឋដ៏ឆ្នើម ព្រះអង្គជាបង្គោលគ្រាក់ដែលសត្វកណ្តៀត្រូវប៉ពណិប្រកាសចុះយ៉ាមថា ខ្ញុំមិនមានសមត្ថភាពនឹងកែរំលែ ឬបំបាត់បានឡើយ តែគោះជាយ៉ាំងនេះក៏គួរតែយើងត្រូវដឹងខ្លួនត្រង់គ្នា រកថ្នាំពុតការពារទៅអនាគត បើដឹងស្ងាប់ហើយទើបរកថ្នាំ គឺជាការឥតប្រយោជន៍ ។

ដោយគណៈកម្មការជាតិនៃការសិក្សាផ្នែកអក្សរ..ក,,

(នៅឆ្នាំ ១៩៦២)

Succession ab-intestat	នវត្តរាធិការដែលមិនមានកាសាសន៍ ។
Succession testamentaire	នវត្តរាធិការមានមានកាសាសន៍ ។
Successeur (n.n.)	នវត្តរាធិការី ។
Successif (adj.)	ដែលតតី ... ។
Successible (adj.)	ដែលអាចតតិ ... ។
Successibilité (n.f.)	នវត្តរាធិការភាព ។
	—T—
Tester (v.int.)	ធ្វើមតកាសាសន៍ ធ្វើសំបុត្របណ្តាំ : ។
Testament (n.m.)	មតកាសាសន៍ : សំបុត្របណ្តាំ ។
Testateur (trice) (n.n.f.)	អ្នកធ្វើមតកាសាសន៍ ។ បុរស – ស្ត្រី ។
Tuteur (n.m.)	ជន្ធង់ : ឈើ ឬឫស្សី ដែលគេដឹកដាំបញ្ឈរ ធ្វើជាសសរ ឲ្យអ្វី ឬប្រែបគោងឡើង ។
Tuteur (n. m.)	អ្នកព្យាបាល (ច្បាប់) : អ្នកពិភក្តិរក្សាអនីតិជន ព្រមទាំងគ្រប់គ្រងទ្រព្យនៃជនគោះ ។
Tutelle (n.f)	ព្យាបាលភាព ; ការពិភក្តិរក្សាអនីតិជន ព្រមទាំងគ្រប់គ្រងទ្រព្យនៃជនគេះ ។
	— A —
1— Absence d'une personne	អវត្តមាននៃបុគ្គលម្នាក់ (ច បា) ។
2— Absent (n.m.)	អវត្តមានបុគ្គល (ច បា) ។
3— Acquérir de droit par prescription	បានកម្មសិទ្ធិពេញទី ដោយអាជ្ញាយុកាល (ច បា) ។
4— Acquéreur (n.m.)	អ្នកជាវ អ្នកទិញ ។ ន. អ្នកជាវព្រះពុទ្ធរូប អ្នកទិញអចលនទ្រព្យ ។

5— Action en contestation d'état — បណ្តឹងដំទាស់នឹងភាព ។

6— Action en réclamation d'état — បណ្តឹងទាមទារភាព ។

7— Acte — ឈុត (ព សិល្ប) : សង្កាត់រឿងមួយ ។ ។ ល. ល្ខោនរឿងមួយឈុត ក្នុងមួយឈុតមានច្រើនឆាក ។

8— Affiche de publications de mariage — ប័ណ្ណប្រកាសនៃការផ្សាយអាពាហ៍ពិពាហ៍ ។

9— Appartement(n.m.) — បន្ទប់លំនៅ : លំនៅមានបន្ទប់ច្រើនដែលគ្រួសារនីមួយៗអាចនៅបាន ។

10— Attractions (n.m.) — ជាកអាកស្សូតា (ព សិល្ប) : ទស្សនីយភាពប្លែក ។ ដែលច្រើនលេងនៅពេលបន្ទោះ នៃការបញ្ចាំងភាពយន្ត ឬ មហោស្រព ។

11— Asprirations intellectuelles et religieuses — ប្រាថ្នាខាងបញ្ញា និងខាង សាសនា ។

— B —

12 - Bien imprescriptibles — ទ្រព្យគ្មានអាជ្ញាយុកាល ។

13— Bulletin de naissance — ព្រឹត្តិបត្រកំណើត ។

— C —

14— Cadavre (n.m.) — សាកសព ។

15— Cas fortuit — ករណីពុំគួរកាល : ព្រឹត្តិការណ៍ដែលកើតឡើងដោយចៃដន្យ ក្រៅពីកំហុសនៃភាគីណាមួយក ឬ អ្នកធ្វើឱ្យមានការខាត ។

16— Cas de force jeure (n.m) — ករណីប្រជានសត្តិ : បុព្វហេតុដែលគេមិនអាចហាត់បានហើយដែលគេមិនមែនជាអ្នកទទួលការខុសត្រូវ ។

17— Cassier judiciaire pénal — បញ្ជីឆ្លើយទោសខាងបទព្រហ្មទណ្ឌ ។

18— Centre d'Etudes Judiciaires — មជ្ឈមណ្ឌលសិក្សាយុត្តិធម៌ ។

19— Civilisation moinsimparfaite — អរ្យធម៌មិនសូវទំ'ខាប ។

20— Confection de lois — ការតែងក្បាច់ ។

21— Contectionner les lois — តែងក្បាច់ ។

22— Cours de droit civil — វិជ្ជាបង្រៀនន៍តិសាស្ត្របរវេណី ។

—D—

23— Date de naissance — កាលបរិច្ឆេទកំណើត ។

24— Délai franc — រយៈពេលគត់ : រយៈពេលដែលមិនរាប់ថ្ងៃដើមនឹងថ្ងៃចុង ។ រយៈពេលប្តឹងទូរណំពីដីកា លោកចាងហ្វាងសាលាដំបូងសម្រេច អំពីកិច្ចការប្រញាប់ ត្រូវគិត ៣ ថ្ងៃគត់ ចាប់តាំងពីថ្ងៃកាត់សេចក្តី ។ បើលោកចាងហ្វាងកាត់សេចក្តីអំពីកិច្ចការប្រញាប់ខ្លួចខាងលើនេះ នៅថ្ងៃ១ សីហា ភាគីដែល មិនស្កប់ចិត្តនឹងដីកានោះ ត្រូវប្តឹងទូរណំឲ្យបានទាន់មុនថ្ងៃ៥ សីហា ទើបយកជាការបាន។

25— Déclarant (n.m.) — អ្នកដូនដំណឹង ។

26— Dépouille mortelle — សព ។

27— Disparition d'une personne — ការបាត់នៃបុគ្គលម្នាក់ ។

28— Domicile réel — លំនៅប្រាកដ : ទីហានរបស់បុគ្គលម្នាក់ដែលត្រូវប្រើប្រាសសិទ្ធិ ព្រមទាំងប្រតិបត្តិតាមកាតព្វកិច្ចរបស់ខ្លួន ។

29— Domicile matrimonial — លំនៅអាពាហ៍ពិពាហ៍ : ទីហានដែលបុគ្គលម្នាក់រៀបអាពាហ៍ពិពាហ៍ខ្លួន ។

30— Domicile légal — លំនៅនីត្យានុកូល : លំនៅដែលក្បាច់តម្រូវឲ្យដល់បុគ្គលខ្លះ ។ ឧ. អ្នករាជការមានលំនៅក្នុងដំបន់ដែលខ្លួនបំពេញមុខងារ ស្ត្រីមានប្តី មានទីលំនៅជាមួយនឹងប្តី អនីតិជនៅលីវ ឬ បរាធីន មានលំនៅជាមួយនឹងលំនៅឪពុកម្តាយខ្លួន ។ ល ។

31— Domicile élu — លំនៅជ្រើសតាំង : ទីឋានដែលភាគីបានក្រឹត ដើម្បីប្រតិបត្តិតាមកិច្ចសន្យាខ្លួន ។ ឧ. ឈ្មោះក នៅភ្នំពេញ តែនឹងឈ្មោះខ នៅព្រៃជ្រៃ បានធ្វើកិច្ចសន្យាមួយ ហើយបានព្រមព្រៀងគ្នាយកគេហដ្ឋានជនម្នាក់នៅភ្នំពេញ ជាលំនៅជ្រើសតាំង ។

32— Domicile voloutaire — លំនៅស្ម័គ្រ : លំនៅដែលបុគ្គលម្នាក់ អាចជ្រើសរើសខ្លួនឯងដោយសេរីភាព ។

33— Dissoudre une société ou une association — រំលាយក្រុមហ៊ុន ឬ សមាគម ។

34— Dissolution d'une société ou association — ការរំលាយក្រុមហ៊ុន ឬ សមាគម ។

35— Durée illimitée — ថិរវេលាឥតខណ្ឌ ។

36— Docteur d'Etat — វរិដ្ឋវេជ្ជបណ្ឌិត ។

37— Docteur d'Université (en médecine) — វេជ្ជបណ្ឌិតស លវិទ្យាល័យ ។

38— Docteur ès-sciences — បណ្ឌិតវិទ្យាសាស្ត្រ ។

39— Docteur ès-lettres — បណ្ឌិតអក្សរសាស្ត្រ ។

— E —

40— En qualité de citoyen — ក្នុងហិនៈជាពលរដ្ឋ ។

41— Enterrer un cadavre — កប់សាកសព ។

42— Epreuve d'examen — វិញ្ញាសានៃការប្រឡង ។

43— Etre humain — មនុស្សលោក ។

44— Etre vivant — ជីវលោក ។

45— Etat physique individuel — ភាពរូបវន្តរៀងខ្លួន ។

46— Espèce humaine — ប្រភេទមនុស្ស ។

47— Eteindre une personne morale — រំលត់នីតិបុគ្គលមួយក្រុម ។

48— Exinction d'une personne morale — ការរំលត់នីតិបុគ្គលមួយក្រុម ។

វិបត្តានុក្រមសំស្ក្រឹត-ខ្មែរ

ព្រះមហាថាន-ខាត់ រៀបរៀង

(តពីឆ្នាំ ១៩៦២)

អតៃលប្បរ គុ. ដែលគេចាញ់ដោយប្រើងមិនមាន។

អតោទ្យ មើល អាតោទ្យ ។

អត្តរ្ជ គុ. ដែលគប្បីបរិភោគ ។

អត្តិ គុ. ដែលស៊ី ។

អត្តឫ ក ន. អ្នកស៊ី ។

អត្យង្គិ គុ. ដែលមានកង្វេះក្រៃលែង (ដំរី) ដែលទូន្មានដោយកង្វេរ ដោយតិចាក ។

អត្យប្ប គុ. ដែលធ្ងុះក្រៃលែង ដែលមើលធ្ងុះទៅម្ខាង ។

អត្យតិក្រាន្ត គុ. ដែលប្រព្រឹត្តកន្ធងក្រៃលែង ដែលប្រព្រឹត្តមេថុនធម្ម ។

អត្យតិមាត្រមិ ក្រ. វិ. ដោយមាត្រាក្រៃលែង ។

អត្យតិរិប ឆាគុ. កន្ធងក្រៃលែង ។

អត្យទ្ភុត គុ. ដែលមិនដែលមានក្រៃលែង ដែលអស្ចារ្យកន្ធង ។ ឧបុ. សេចក្តីអស្ចារ្យកន្ធង ។

អត្យន្តនិលោគ្រវែត គុ. ដែលមានសន្ទុះខ្លាំងក្រៃលែងជាងខ្សល់ ។

អត្យន្តុស្ស ធាតុ. រលឹកតាមក្រៃលែង រលឹករឿយ ៗ ក្រៃលែង ដើញតាមស្លឹត ។

អត្យុទ្ធ គុ. ដែលខ្ទៀងក្រៃលែង ដែលជាប់រឹងក្រៃលែង ដែលកំរោល ក្រៃលែង ទាំងអស់ ។ *អត្យន្តម* ក្រ. វិ. ដោយអាការជាប់ ស្ថានរឹង; ជាជិវាប ពិតណាស់ ។ *គត* គុ. ដែលចេញទៅជា ជិវាប (ស្លាប់) ។

អត្យភិស្សូត គុ. ដែលរាឡកក្រៃពេកកន្ទុង ។

អត្យម៉ិរ គុ. ដែលជាអមរក្រៃលែង អមរប្រសើរ ។

អត្យមម៌ណ អត្យមម៌ិន គុ. ដែលទ្រទ្រង់ក្រៃលែងមិនបាន ដែលក្រោរក្រោធ ក្រៃលែង ។

អត្យម្ពុជាន នបុ. កិរិយាធឹកទឹកក្រៃលែង ។

អត្យយ បុ. កិរិយាប្រព្រឹត្តកន្លង (វេលា) កិរិយាជាប់ជង់ ទីបំផុត សេចក្តី ស្លាប់ ទុក្ខទោស សេចក្តីវិនាស ការខូះខាត បែបបទ ។ *អត្យយីភាវ* បុ. ការនៃកិរិយាប្រព្រឹត្តទៅដោយសេចក្តីស្លាប់ ។

អត្យរ្ថ គុ. ដែលមានអត្ថក្រៃលែង ពេកកន្ទុង ។ *អត្យរ្ថម* ទាំងណាស់ ពេកណាស់ ។

(នៅមានត)

៣០ - ទន្សាយនឹងអណ្តើក

ដើរមួយៗតែឲ្យខឿន រត់ទៅនាវ៉ែតបានការ ។ ឧទាហរណ៍ដូចជាទន្សាយនឹងអណ្តើក ដែលបញ្ជាក់ឲ្យឃើញច្បាស់ដូចខាងក្រោមនេះ :

អណ្តើកនិយាយនឹងទន្សាយថា ក្នាល់គ្នាលមើល ! បើឯងរត់ដល់មុនអញ ។ ទន្សាយឆ្លើយថា : ខឿនតែដល់មុន ឯងប្រាកដជាក្នាល់ឬ? នែអាសំឡាញ់ ! ឯងត្រូវភ្នាក់ខ្លួនថា ក្នាល់មិនបានទេ ។ - បានក៏ដោយ មិនបានក៏ដោយ អញនៅតែក្នាល់ ។

និយាយគ្នាស្រេចហើយ គេយកវគ្រាំទ្រមកដាក់នៅក្បាលទីសម្រាប់អ្នកចាំងពីរ ទន្សាយបើលោតតែមួយផ្លោតដាច់អណ្តើកបាត់ តែមិនដូច្នោះ វាអាល់យកចូលព្រៃ ឆាកវកវាលស្មៅខ្ចី ដើរលេងស៊ីន អាល់យកៅស៊ីស្មៅ ៅដេក ៅផ្ទៀងស្តាប់ តើឲ្យលាន់នេះបកមកពីទិសណា ទុកឲ្យអណ្តើកបែបនាហ្នឹង ចេះតែៅម្នាក់ឯង វាចេះតែធ្វើព្រងើយ ហើយលូបប់ ។ ៅ អណ្តើកចេះតែៅ ទំរើងប្រញាប់អស់ពីចិត្ត ចាំងតឹងចាំងធ្ងន់មិនបង្អែបង្អង់ឲ្យខាតពេល ។

ទន្សាយមើលឆាយរឿងក្នាល់នេះ ដោយគិតថា អញនឹងគ្នានល្ប៉ីណោះ បើកាលណាអញប្រញាប់ប្រញាប់ចេញធាប់ស្មើនឹងអណ្តើក

ជំនះបែបនេះឥតបានការ បើដូច្នេះ វាឈប់ស៊ីស្មៅ ឈប់សម្រាកកាយ ឈប់លេងឲ្យសប្បាយក្នុងចិត្ត វាក្មេចគិតឯការដែលខ្លួនត្រូវតែភ្ញាល់ ។ ស្រាប់តែលោក្រឡេកមើលទៅ ឃើញអណ្តើកដ៏តដល់ខ្លួនខន្ធាយភ្ញាក់ខ្លួន កំតាំងចោះពួយទៅពីនាយដូចព្រួញ តែសន្ទុះដែលលឿននោះឥតប្រយោជន៍ ឥតបានការ ដ្បិតអណ្តើកដល់ទីមុនស្រេចហើយ ។

អណ្តើកស្រែកថា «ម៉ែច! អញនិយាយត្រូវឬទេ? សន្ទុះយ៉ាងលឿនរបស់អ្នកឯងបានការអ្វី តើអញទេជាអ្នកឈ្នះ ហើយមិនដឹងជាយ៉ាងណាទៅទៀតទេ ប្រសិនបើអ្នកឯងមានស្មារតីដូចអញ" ។

๓๑- ទីជ្រកយឺងនិងទន្លា

មិនត្រូវចំអកនឹងមើលងាយឲ្យអ្នកមានទុក្ខវេទនាទេ ព្រោះអ្នកណាមួយអាចដឹងថា ខ្លួនទៀងតែបានសុខជានិច្ច ។

ខន្ធាយនិងខាទៅអាស្រ័យជាមួយគ្នា ក្នុងចំការមួយប្រកបដោយសេចក្តីសុខ ។ ថ្ងៃមួយ ព្រានឆ្កែលើកមកប្រទះកន្លែងនោះ ពួកលឿតដែលមកជិតដល់ នាំឆ្កែឲ្យខន្ធាយរត់ស្វែងរកទីជ្រកពួន វាខំរត់ទៅរកវួនពួន: ហើយធ្វើឲ្យឆ្កែបាត់ជានអស់ ។ តែខាស់ខ្លួនឯងឲ្យក្ងិចបានជាឆ្កែតាមកិតខន្ធាយខំរត់ទាល់តែដាច់ដង្ហើម ។ ខាដែលឃើញដូច្នេះចំអកឲ្យហើយពោលថា ចុះឯងអួតថា រត់លឿន ឥឡូវដល់ឯងមានបានការអ្វី? ។

ខាកំពុងតែស៊ើចនិងខន្ធាយ តៀរតាមខាន់: ខាពីងលើស្មាប

ថាស្ទាបអាចជួយខ្លួនអំពីគ្រោះថ្នាក់បាន តែវាមិនគិតដល់សត្វប្រមង់ ។
សត្វខេះ ក្រចកយ៉ាងមុត ធាបតែមួយក៏ប់ ជាប់ក្បាលម៉ាត់ ។

៣២ - ជ្រូក ពពែ និងចៀម

គេដាក់ពពែ ចៀមនឹងជ្រូកមួយយ៉ាងជាត់ ក្នុងរខេះជាមួយគ្នានាំ
យកទៅលក់ឯបុណ្យតាំងវត្ត ។ វាមិនមែនទៅលេងសប្បាយទេ បើតាមរឿង
គឺគេនាំវាទាំង ៣ យកទៅលក់ ។ នៅតាមផ្លូវ ជ្រូកស្រែកខ្លាំងពេក
ដូចជាគេចំរុងនឹងចាក់កវាឥឡូវហ្នឹងហើយ ។ សម្រែកវាធ្វើឲ្យអ្នកទាំងពួង
ថ្ងន់ស្ទើរបែកត្រចៀក ។ សត្វដទៃដែលជាសត្វស្ងួត ឆើងឆ្ងល់នឹង
ជ្រូកដែលស្រែកហៅឲ្យគេជួយ ហើយគេសម្លឹងមើល មិនឃើញមានអ្វី
គួរឲ្យខ្លាចសោះ ។

អ្នករខេះសួរជ្រូកថា: « ហេតុបានជាឯងស្រែកខ្លាំងម្ល៉ះ ? តាឯងធ្វើ
ឲ្យគេថ្ងន់ត្រចៀកគ្នា តាឯងមិនស្ងៀមទេឬ ? តាឯងត្រូវរៀនស្ងៀម
រៀនអត់ទ្រាំ ដូចគេទាំងពីរនាក់នេះ ឯងមើលចៀម ពពែនោះ
អ្វីមួយម៉ាត់សោះ វាស្ងួតណាស់ » ។ ជ្រូកឆ្លើយថា: « តាហ្នឹងវាភ្លើបើ
វាដឹងការណ៍វាដូចខ្ញុំ នោះវាស្រែកបែកបំពង់កជាងខ្ញុំទៅទៀត ហើយតា-
មួយនោះទៀត ប្រហែលជាស្រែកបែកក្បាលផងមិនដឹង: ពពែដឹងថា
គេយកវាទៅតឹកដោះ ចៀមតាត់យកពេម ដែលខ្ញុំថាដូច្នេះ មិនដឹង
ជាត្រូវឬមិនត្រូវទេ ប៉ុន្តែ ប្រហែលជាត្រូវ ចំណែកខាងខ្ញុំសំពាច់គេស៊ី:

សេចក្តីស្លាប់របស់ខ្ញុំខឿនណាស់ ខ្ញុំសូមលាហើយ លានេះគឺលាឈប់ មានជួបដំបូលទីឆ្នាំទ្រូងដែលខ្ញុំធ្លាប់ជ្រក " ។

ជ្រូកចេះនិយាយដូចមនុស្សមានច្រើន តែសំដីហ្នឹងមានប្រយោជន៍ អ្វី ? ដើរសេចក្តីស្លាប់ខឿនហើយ ស្រែកថ្ងូរទីឆ្ងាយក៏មិនអាចផ្លាស់ប្តូរ វាសនាបានឡើយ ។

៣៣- ត្រដេវរ៉ឺប ក្លួនវាំងឆ្ងាស់ស្រែ

ខ្លួនត្រដេវតូចតាំងខ្លួន នេះហើយជាសុភាសិតសម្រាប់មនុស្សឆ្លងតាំងពួន លោក « អេហ្សុប » បានសំដែងសុភាសិតនេះ ព្រមទាំងមាន ឧទាហរណ៍ជាសំអាងដូចតទៅ:-

ត្រដេវរ៉ឺបតាំងខ្លាយ តែងធ្វើសំបុកវាក្នុងស្រែដែលកំពុងលាស់ជា រស្មៅ គឺថាក្នុងរយៈវេលាដែលធម្មជាតិក្នុងលោកកំពុងតែពេញស្រឡាញ់ ពេញលូតលាស់ ដូចជាត្រីត្រូវទឹងទឹក ខ្លាត្រូវទឹងព្រៃ ត្រដេវរ៉ឺបត្រូវ ទឹងចំការ ។ ប៉ុន្តែ បណ្តាត្រដេវរ៉ឺបតាំងនោះ មានត្រដេវរ៉ឺបមួយក្លេច ខ្លួន បណ្តោយឲ្យដូរទីមួយកន្លែងទៀបានតាក់តណ្តាល មិនទាន់បានតិត ពងក្លួនទីនឹងគេ តាមកាលវេលាខៅឡើយ ។ លុះចាស់គំនិតវាសុខចិត្ត សម្រេចថា ត្រូវគោរពតាមធម្មជាតិ ដូច្នេះត្រូវតែពង ។ រួចចាប់ធ្វើសំ- បុកពងគ្រាប ហើយក្លាស់ក្លួនយ៉ាងរហ័ស: ការដែលវាធ្វើតាំងប៉ុន្មាន គឺ សម្រេចដូចច្រើនថ្ងាំ ។ មេត្រដេវរ៉ឺបប្រឹងថែរក្សាក្លួនដោយមធ្យឹត បើទីង

ចេញទៅរកចំណីម្តង ។ រាផ្តាំកូនកុំឲ្យទៅស្ទៀម ឲ្យឃ្លាំចាំមើល ព្រោះ
ស្រែវាទៅជុំវិញពុំទាំងអស់ មុនពេលដែលកូនត្រដេវប៉ុចនេះដុះក្រាស ដុះ
ស្អាបចេះហើរបាន ។ មេត្រដេវប៉ុចនិយាយនឹងកូនថា: « បើកាលណា
ម្ចាស់ស្រែមកជាមួយនឹងកូន ចូរបាកាល់គ្នាប្រុងស្តាប់ឲ្យច្បាស់ តើគេ
និយាយថាដូចម្តេចខ្លះ រួចហើយយើងនឹងនាំគ្នាដើរចេញ" ។ មេត្រដេវ-
ប៉ុចចេញស៊ើមិនទាន់ផុត ម្ចាស់ស្រែនឹងកូនមកដល់ភ្លាម ។ ឪពុក
គោលថា: « ស្រែវានោះខ្ចីអស់ហើយ ចូលឯងទៅផ្ទះមិត្រភក្តិយើង
ហើយប្រាប់ថា: ម្នាក់ៗ ត្រូវយកកណ្តៀវមួយមកដើម្បីជួយយើងកាត់
ច្រូតស្រូវស្អែកនេះពីព្រលឹម » ។ មេត្រដេវប៉ុចត្រឡប់មកវិញឃើញ
កូន អាខ្លះយំ អាខ្លះត្បើរត្បើរស្រែកប្រាប់ឪពុកថា: « គេថាស្អែកហ្នឹង
គេហៅសំឡាញ់មកជួយច្រូតស្រូវពីព្រហាមហើយ » ។ មេត្រដេវប៉ុច
ប្រាប់កូនថា. បើគេថាដូច្នោះ យើងកុំប្រញាប់ផ្លាស់កន្លែងអី ប៉ុន្តែ
ស្អែកត្រូវឯងពាល់គ្នាប្រុងស្តាប់ឲ្យជាក់ម្តងទៀត ណ្ហើយកុំភ័យ! នេះ
ចំណី នាំគ្នាស៊ីចុះ » ។ លុះបរិភោគចំណីឆ្អែតគ្រាលណា ត្រដេវប៉ុចទាំង
មេ - កូន នាំគ្នារះដកជាសុខសាន្តទៅ ។ ព្រឹកឡើងគ្មានសំឡាញ់ណា
ម្នាក់មកសោះ ។ មេត្រដេវប៉ុចក៏ហើរទៅរកចំណីបាត់ទៅ ។ ម្ចាស់
ស្រែមកដល់ដូចមុនទៀត ហើយពោលថា: « ស្រែវាទាំងនេះដិតដួលអស់
ហើយ សំឡាញ់យើងយល់ខុសទាំងអស់ យើងមិនត្រូវផ្តេកទៅលើ

មនុស្សក៏ដល់ធ្វើការដោយយឺតយូរដូច្នេះឡើយ បើអីចឹង កូនឯងទៅឯ
ចងប្អូនយើងវិញ ហើយប្រាប់គេឲ្យមកជួយដូចពេលមុន" ។ ពួក
កូនសត្វ ឮហើយក៏តក់ស្លុតអ្វីប្រៀបគ្មាន ហើយប្រាប់មេវាថា: "ម៉ែ! ម្តង
នេះ ដល់ហើយយើង" ។ រីឯមេត្រដេរវ៉ៅប្រាប់កូនថា: "មិនបានអ្វីទេ កូន!
ចូលឯងដេកជាសុខសិនចុះ កុំភ្ញាក់ផ្អើលឡើយ" ។ មេត្រដេរវ៉ៅយល់
ត្រូវមែន ព្រោះត្រីកឡើង គ្មានខ្លះណាមកសោះ ។ លុះតទី ៣ ម្ចាស់ស្រែ
ទៅមើលស្រូវទៀត ហើយពោលថា: "ការកាន់ច្រឡំរបស់យើងធំអ្វី
ម៉្លេះទេ ព្រោះទៅតែតែទីពឹងអ្នកដទៃជាជាងខ្លួនឯង ។ សំឡាញ់ក្តី
ចងប្អូនក្តី ទីនឹងពុកជាទីពឹងដ៏ប្រសើរជាងខ្លួនយើងពុំបានឡើយ ម្ចាលកូន
សំឡាញ់! ចូរឯងចាំរឿងនេះពុកចុះ បើដូច្នេះ តើត្រូវធ្វើដូចម្តេច? ត្រូវតែ
ពួកយើងកូនផ្ទះ ស្អែកនាំគ្នាកាន់កណ្តៀវមួយម្នាក់មក លុះតែធ្វើយ៉ាងនេះ
ទើបការហ្នឹងធាប់ហើយ យើងបង្ហើយចម្រូតយើងតាមចិត្តចង់" ។
រឿងនេះ ចានដល់ដល់មេត្រដេរវ៉ៅ វាក៏ប្រាប់កូនថា: "ពេលនេះហើយ
កូន! ដែលយើងត្រូវតែដើរចេញ" ។ ក្នុងពេលនោះ កូនបក្សីតាំងប៉ុន្មាន
ក៏ចបួលគ្នាលោតផ្លោះផ្លោតចេញពីកន្លែងនោះដោយស្ងាត់ ។ ល ។

(នៅមានត)

រឿងសាមកុក

កណ្ឌទី ៩១

ទេសកាថ្មីលេខ ៤ - ភាគ ៤ ប្រៃរៀបរៀង

(ឆ្នាំ ១៩៦២)

> រឿងសាមកុកពុកជាយុទ្ធសាស្ត្រ
> អ្នកកាងវែឆ្លាសបើបានអាន
> នឹងចេះឧបាយកលចំណាន
> ពាំងមានសន្តានស្នេហាជាតិ ។
>
> ——— យួរ-អ៊ុន ———

សុំឲ្យលោកលើកទ័ពទៅស្កាត់ស្កក់ដើមផ្លូវស្រុកសែឈួន កុំឲ្យខ្មៅតាលែត្រឡប់មកវិញបាន ហើយត្រូវលើកទ័ពមួយចំកទៅវាយយកស្រុកកេងដីវ៉ មុខជានឹងបានដោយងាយ ។ ស៊ុនគួនថា អ្នកគិតការនេះត្រូវណាស់ ។ ខ្លួលខាងនឹកុកថៃដើរចេញមកដល់ក្រោយនាគ ឮសំដីបា្លស់ក៏ស្រែកថា នរណាគិតការដូច្នេះ ក្រាបថ្នាំនឹងឲ្យខ្មៅតាសម្លាប់កូនស្រីអញចេញឬ? គួរតែឲ្យគាត់ក្បាលចេញ ហើយក៏ដើរស្រាលដើងចេញមកស្រៅនាគនិយាយនឹងស៊ុនគួនថា ប្អូនស្រីចៅតែមួយ ម្តាយទំពោះក្បាមក ថ្មមបីដួចដួងដីតែមាតា វេលានេះបានជាលើកឲ្យជាកំលោខ្មៅតាហើយ ចៅនឹងមកដឿគាន់យកពាក្យមនុស្ស ដែលញុះញង់នឹងសម្លាប់ប្អូនបង្កើតឯងឬ ? ប្អូនចៅកំបានសម្បត្តិរបស់បងជាធំនៅក្នុងស្រុកកាំងតាំង មានទាំងអាណាខ្មៅត្រឡឹងដល់ ៨១ ដំបន់ ម្តេចនៅមិនទាន់ឆ្អែតចិត្តឬ? ទើបចង់ឲ្យទៅយកស្រុកកេងដីវ៉ដែលជាសម្បត្តិអ្នកដទៃទៀត។

ស៊ុនគួនបានឮមាតាថា កំទេចគំនាប់ខ្លួលតាក្សថា ខ្ញុំបានខុសហើយ សូមមាតាអត់ទោសបុះ ហើយកំបណ្តើញទីប្រុក្សាតាំងពួនចេញទៅអស់ ។ នាងដឹកកៃថកក៏ត្រឡប់ចូលទៅវិញ ។ ស៊ុនគួនអង្គុយនៅតែម្នាក់ឯងរំពឹងគិតថា គ្រានេះ ចើមិនបានស្រុកគេនដីវែហើយ ៖ កាលណាឡើយទៅមុខទៀតនឹងគិតបាន ។ ខ្លួលទៀវចៀវចូលមកដល់ហើយសួរថា ហេតុអ្វីថ្ងៃនេះលោកអង្គុយជាទុក្ខមុខមិនសប្បាយ ?។ ស៊ុនគួនថា ដែលខ្ញុំជាទុក្ខនៅដូច្នេះ ព្រោះគិតដល់សេចក្តីដែលនិយាយគ្នាអំបាញ់មិញនោះ ។

ទៀវចៀវថា នឹងជាទុក្ខថ្លៅដោយសេចក្តីប៉ុណ្ណោះ ងាយមិនក្រប៉ុន្មានទេ សូមឲ្យលោកមានសំបុត្រធ្វើទៅដល់នាងស៊ុនហ៊ូយិនប្អូនលោកជាសេចក្តីស្វាត់ថា ឥឡូវមាតាឈឺធ្ងន់ មានចិត្តគិតដល់នាងណាស់ នឹងសុំឃើញមុខតែម្តង បើយ៉ាងម្តេចឲ្យទំរិះគិតឲ្យបានមកដោយឆាប់ប្រញាប់ តាំងយប់ថ្ងៃកុំឲ្យខាន ហើយឲ្យនាំយកអាតៅបុត្រឡៅពីមកជាមួយផង ឡៅពីមានបុត្រតែមួយគឺតដ៏នឹងស្មុគចិត្តអាណិតអាល័យ ដើម្បីត្រូវយកស្រុកគេនដីវែមកប្តូរយកកូនទៅបើបបាន កាលណាឡៅពីនឹងឈប់មានចោលកូន បើឡៅពីជាច់អាល័យសោះសូន្យហើយ យើងក៏ត្រូវលើកទ័ពទៅច្បាំងយកស្រុកគេនដីវែតែម្តង មុខជាគ្មានចំនងនឹងចងធំរឹងបានទេ ។

ស៊ុនគួនថា អ្នកគិតនេះត្រូវណាស់ ចើបឲ្យតែងសំបុត្រស្វាត់មួយច្បាប់តាមពាក្យទៀវចៀវ ហើយប្រើដំរីសឿនដែលជាមនុស្សស្និទ្ធភ្លាប់ប្រើ

ប្រាសទាន់ក្នុងមកពីដើមនោះ ឲ្យលបចុះទូកទៅស្រុកកេងដើម្បីនឲ្យមាតាដឹង លុះដីវ៉ែនទៅដល់ស្រុកកេងដីវ៉ែហើយ ក៏ចូលទៅគាប់នាងស៊ុនហ៊ូយីន ហើយយកសំបុត្រនោះឲ្យនាងស៊ុនហ៊ូយីនមើល ។ នាងក៏មើលដឹងសេចក្តីហើយសំគាល់ថាមែន មានសេចក្តីសៅសោកណាស់ ទើបសួរថា មាតាដែលឈឺនោះជាប្រការម្តេច ? ។ ដីវ៉ែនថា មាតាលោកឈឺធ្ងន់ណាស់ ហើយបើមិនបានឃើញមុខលោក ក៏មុខជាធឹងស្លាប់ហើយផ្តាំថា ធឹងសូមឃើញមុខអាតៅជាចៅប្រុសផង នាងស៊ុនហ៊ូយីនថា ឥឡូវឡៅពីក៏មិនទៅផង ដែលយើងនឹងទៅនោះត្រូវចាំឲ្យដំណឹងខុនបេងដឹងផង ។

ដីវ៉ែនថា មាតាលោកឈឺធ្ងន់ ត្រូវតែស្រួតទៅឲ្យទាន់ដង្ហើម ធឹងចាំឲ្យដំណឹងខុនបេងសិនទៅ បើខុនបេងថា ចាំផ្ញើដំណឹងទៅឲ្យឡៅពីជ្រាបសិនទើបទៅបាន ឡៅពីក៏ទៅផ្ញើរឲ្យ ទំពាំសំបុត្រទៅដល់ហើយចាំតបមក ធឹងមិនទាន់តែងឲ្យណាស់ទៅទេឬ? កាលណាធឹងទាន់ដង្ហើមមាតាលោក ក៏ធឹងខ្លួចការទៅ នាងស៊ុនហ៊ូយីនមានសេចក្តីអាណិតស្រឡាញ់មាតាពន់ប្រមាណណាស់ ដ៏ដូចក្តីងងុតកង់ដើមទ្រូង ត្រូវធឹងចង់ទៅឃើញមាតាដោយប្រញាប់ប្រញាល់ណាស់ ក៏រៀបចាត់ចែងរបស់ប្រើប្រាស់ធឹងខ្លួនគ្រាណា ហើយឲ្យស្រីបម៉ើ ៣០ នាក់ កាន់គ្រឿងអាវុធគ្រប់ដៃស្រេចហើយ ក៏ពាយកអាតៅឡើងរថបរចេញចាកស្រុកកេងដីវ៉ែ

លុះទៅដល់កំពង់ចតទូក ដាវសៀនក៏អញ្ជើញឲ្យនាងចុះទូក ។

ខណៈនោះជូឡុងដឹងថា នាងស៊ុនហ៊ូយិនចេញដំណើរទៅស្រុកកាំង តាំងហើយ ក៏ឃុំតាកោន ៤ នាក់ស្រួតតាមទៅខាង ហើយកំពុងតែដកយុថ្កាខ្លែចេញទូក ជូឡុងក៏ស្រែកហៅថា កុំគាស់ចេញទូតទៅឈប់មួយរំពេចសិន យើងខ្លែងសុំនិយាយការខ្លែងនាងស៊ុនហ៊ូយិនបន្តិច ដាវសៀនក៏ស្រែកថា ឯងនេះជាអ្វីទើបមកឃាត់នាយចៅហ្វាយទូកដូច្នេះ មិនមានកោតក្រែង ហើយក៏ឲ្យតាហានចាប់ត្រឿងសាស្ត្រាវុធទូកត្រង់ដៃទើបឲ្យថយទូកចេញទៅ ជូឡុងក៏បង្ហាយសេះស្រួតតាមទៅដល់មាត់ច្រាំង ហើយថា អ្នកនឹងអញ្ជើញទៅក៏ទៅចុះ តែថាខ្ញុំបានដំណាងបន្តិចសិន ដាវសៀនក៏មិនព្រមឲ្យឈប់ បង្ខំឲ្យតាហានស្រួតចែវទូកចេញទៅ ជូឡុងក៏បង្ខំយកសេះទៅតាមមាត់ច្រាំង ចម្ងាយផ្លូវប្រហែល ១០០ សិន (៤គ.ម.) ទទួលឃើញទូកត្រឹមួយចតនៅត្បែរមាត់ច្រាំង ជូឡុងក៏លោតចុះពីលើខ្នងសេះហៅតាហានឲ្យចុះចែវទូកតាមដាវសៀន កាន់លំពែងឈរកណ្តាលទូក បង្ខំឲ្យចែវតាមទៅ ។ ដាវសៀនក៏ឲ្យតាហានយឺតឆ្ងាញ់ ជូឡុងតាត់ព្រួញដោយអាវុធ មិនបានត្រូវដល់ខ្លួនសោះ លុះចែវទៅជិតទូកដាវសៀន ។ ក៏ឲ្យយកលំពែងចាក់ ជូឡុងក៏យកក្របីចាក់ទល់គ្នានឹងលំពែងជុំខ្លួនឲ្យតាហានសង្កត់ញ្ជួលទៅ ហើយលោកឡើងលើទូកបាន តាហានដាវសៀនតាំងអស់គ្នាក៏ខ្ចាចជូឡុងប្រៀនតែគេចយកខ្លួន ជូឡុងក៏ស្ទុះចូលទៅក្នុង

ខ្លួកតឹង ឃើញនាងស៊ុនហ៊ួយិនពាក់អង្គុយនៅទីនោះ ក៏យកក្រមីច្រែកក្នឹងស្រោមហើយគំនាប់ដាក់ថា អ្នកនឹងអញ្ជើញទៅណា ហេតុម្តេចក៏មិនបានប្រាប់ខ្ញុំឲ្យដឹងសិន ។

នាងស៊ុនហ៊ួយិនប្រាប់ថា មាតាខ្ញុំឈឺធ្ងន់ណាស់ បានជាស្រួតប្រញាប់មិនទាន់នឹងប្រាប់ខ្លួនបងឆាប ។ ដូឡ្បឹងថា ដែលអ្នកនឹងទៅសួរមាតាក៏គួរហើយ តែត្រូវការអ្វីយកអាតៅទៅផង នាងស៊ុនហ៊ួយិនថា អាតៅបុត្រឡៅពីកំបីដូចជាបុត្រប្រុសខ្ញុំដែរ បើខ្លួនមិនទៅ ត្រូវតែយកវាទៅផង នឹងចោលខុកក្នុងស្រុកក៏មិនគួរ មិនមាននរណានឹងថែរក្សានៅវេលាដែលវាឈឺថ្កាត់ បានជាខ្ញុំយកជាប់នឹងខ្លួនទៅ ដូឡ្បឹងថា ឡៅពីចៅហ្វាយខ្ញុំបាទ មានបុត្រតែមួយដែលជាសាលោហិតក្នុងខ្លួន ស្រឡាញ់ដូចជីវិតខ្លួនឯង កាលគ្រានៅវាលទៀងមិនទៅ ខ្ញុំបាទទៅស្បាថាំគាប់ឆ្លាតលើ ១០ ម៉ឺនមិនមានស្តាយជីវិត ក៏ព្រោះប្រាថ្នាអាតៅជាតែវិត្តកបស់ឡៅពី បើខ្លួនខ្ញុំបាទនឹងស្ងាប់កណ្តាលវាលវាង្គតក្នុងទីឥតចូលក៏មិនសូវស្តាយ គួរឬអ្នកមកនាំយកអាតៅទៅ ឲ្យឃ្លាតចាកឡៅពីជាចិត្ត ។

នាងស៊ុនហ៊ួយិនថា ខ្លួនឯងគ្រាន់តែជានាយ ឥហាន គួរឬ ឥហានមកកន្ទុងចង្កាប់គាកូនលំនៅនាយទៅហ្វាយដូច្នេះ ទុកជាកោងព្រហើនណាស់ ត្រូវថយចេញទៅឲ្យឆាប់ ហើយក៏ឲ្យស្រីប៉ែរចូលទៅអូសតន្ត្រាក់អាឲ្យចេញ ដូឡ្បឹងក៏ប្រាប់ស្រីប៉ែរទៅតាមអស់នោះដួល

ត្រឡប់ត្រឡែនអស់ហើយថា ម៉េចអ្នកនឹងដណ្តើមយកអាតៅទៅឡើយឬនឬ ? គោះដំរៃខ្ញុំឲ្យនឹងស្ងាប់ទៅពីនេះក៏តាមការចុះ ខ្ញុំឲ្យមិនព្រមឲ្យអ្នកយកអាតៅទៅទេ ថាហើយក៏ចូលទៅដណ្តើមយកអាតៅរបូតពីដៃនាងស៊ុនហ៊ួយិន នាំចេញមកឈរនៅមុខគេក មិនដឹងនឹងតតូចម្តេចនឹងឡើងបើគោកឲ្យន ក្រឡែកគេកូកគូចពួកឲ្យហានដើរសៀនកំប្រាន ចេញតាមមិនឲ្យន ដូឡុងក៏ខ្លាចតែនតែ លុះនឹងធ្វើចលាចលកាច់សម្លាប់គ្នាជ្រុលច្របល់ឡើងក៏មិនគួរ ព្រោះនាងស៊ុនហ៊ួយិនទៅក្នុងគេកូកនោះផងស្រាប់តែទាំងពួងព្រួតចូលគ្នាដណ្តើមយកអាតៅក៏មិនឲ្យន ព្រោះដូឡុងកាន់ក្រចឹមទៅជាប់នឹងដៃ ។

ឯដើរសៀនកំប្រាស់ប្រាល់ទៅក្នុងគេកឲ្យនឹងឲ្យហានចែវទៅ ខ្លួលខៀវហ៊ុយទៅក្រវែលយាមល្បាតតាមផ្លូវ ដឹងដំណឹងក៏ស្រួតតាមទៅមើល ដូឡុងក្រឡែកឃើញគេកខៀវហ៊ុយដោតទង់បញ្ជរបញ្ចុះពាហានព្រម ស្រួតចែវស្ទាក់ពីមុខចូលមក មិនឲ្យដឹងថាខៀវហ៊ុយកំទឹកកំយណាស់ តតាស៊ុនគួនក្លែងធ្វើកលទឹងសម្លាប់ខ្លួនចេញ លុះឲ្យឮខៀវហ៊ុយស្រែកមកថា អ្នកនឹងទៅក៏ទៅតែខ្លួនចុះ ចូរយកអាតៅដាក់ឲ្យយើងទុក ដូឡុងក៏អរណាស់ ខៀវហ៊ុយចូលមកដិតកំហុចលំពែងទៅឲ្យដូឡុងចាប់ ដូឡុងលោតចុះមកកន្ទុំគេកខៀវហ៊ុយឲ្យន ដើរសៀនឃើញដូច្នោះ ក៏តន្ត្រាក់ក្រចឹចេញនឹងកាប់ខៀវហ៊ុយ ។ ក៏លើកលំពែង

ចាក់តែងដែរសៀនដួលចុះ ហើយសួរទៅកាត់ក្បាលចោះទៅក្នុងស្លែងខ្លួក
ត្រូវនាងស៊ុនហ៊ូយិនទ ? កំព័យណាស់ ទើបនិយាយថា ហេតុម្តេច
ខ្ញុំវហ៊ុយបានជាមកធ្វើផ្តេសផ្តាសឲ្យយើងដូច្នេះ ខ្ញុំវហ៊ុយថា អ្នកជា
បងប្តូរខ្ញុំបាទ បើមិនស្រឡាញ់បងខ្ញុំបាទដោយស្មោះត្រង់ តែងតែចាស
ទៅស្រុកវិញ មិនបានអាឡោះអាល័យទេ គួរតែខ្ញុំបាទនឹងធ្វើអាក្រក់
ដល់អ្នកឲ្យលើសអ្នកដទៃទៅទៀត ។

នាងស៊ុនហ៊ូយិនថា វេលានេះមានតែខ្ញុំឈឺធ្ងន់ណាស់ បានជាខ្ញុំ
ស្រួតទៅប្រញាប់ បើនឹងចាំប្រាប់បងអ្នកឲ្យដឹងសិន មិនរឹតតែយូរវេ-
លាតាលណានឹងទៅតាន់ដង្ហើមមានតា អ្នកតាំងពីនឹងឃាត់ឃាំងមិនឲ្យ
ខ្ញុំទៅ ខ្ញុំក៏ត្រូវតែលោតទឹកឲ្យស្លាប់ឥឡូវនេះ ខ្ញុំវហ៊ុយ ឮដូច្នោះក៏
ពីគ្រោះនឹងដួលថា បើយើងនឹងឃាតខ្លាំងពុក ក៏ដូចយើងកែងឲ្យនាង
ស៊ុនហ៊ូយិនស្លាប់ ព្រោះមាតាឈឺធ្ងន់ណាស់ដូច្នេះ ម្តាយនឹងកូន
របស់គេ មិនគួរនឹងឃាត់ខ្លាំងឡើយ គួរហើយតែយើងយកអាគៅពុកចុះ
ទោះបីនាងស៊ុនហ៊ូយិននឹងទៅក៏តាមអញ្ជាស្រួយចុះ លុះគិតគ្នាហើយក៏
និយាយនឹងនាងស៊ុនហ៊ូយិនថា ឡៅតីបងខ្ញុំបាទក៏ត្រូវជាមាត្រះទៅហៀន
គេ ដែលអ្នកបានមកទៅនឹងបងខ្ញុំបាទ ? កំមានចិត្តអាណិតស្រឡាញ់
មិនសូវឲ្យមានសេចក្តីខ្វាសពេក ទោះបីខ្លួនអ្នកនឹងទៅក៏ត្រូវនឹករលឹក អា-
ល័យសេចក្តីកំសត់តម្រិតដែរដែរ ធម្មតាកំយោ នឹងស្វាមីដែលមេត្រីនឹង

គ្នាជាស្ដេចនោះ រតនមិនត្រូវបោះបង់ឲ្យខុសពីប្រពៃណីលោកទេ អ្នក
អញ្ជើញទៅត្រាតែតត្រឡប់មកវិញកុំខាន ថាហើយក៏ពាក់តោតចុះខ្លួនជា
មួយនឹងជូឡុងវិលមកវិញ ឯនាងស៊ុនហ៊ូយិនក៏បង្ខំឲ្យពាហាន ១០ នាក់
ស្រុតចេះខ្លួនចាំងយប់ - ថ្ងៃទៅស្រុកកាំងតាំង ។

ខុងចេងដឹងដំណឹងថា នាងស៊ុនហ៊ូយិនរត់ទៅជូព្នេះ ក៏លើក
ពាហានចុះស្រុតតាមទៅជួបនឹងជូឡុង ខៀវហ៊ុយកណ្ដាលផ្លូវ បានអា-
តោមកវិញក៏ពេញអំណរក្នុងចិត្តណាស់ ចាំង ៣ នាយក៏នាំគ្នាត្រឡប់មក
ស្រុកវិញ ខុងចេងក៏ចាត់ឲ្យចំរើនាំសំបុត្រទៅប្ដឹងដល់ឡៅតិងស្រុកសែ-
ឈួន សេចក្ដីថា ឥឡូវនាងស៊ុនហ៊ូយិនរត់ត្រឡប់ទៅស្រុកកាងតាំង
វិញទៅហើយ ។

ឯនាងស៊ុនហ៊ូយិននោះ លុះទៅដល់ស្រុកកាំងតាំងក៏ដឹងសេចក្ដីទៅ
ដល់ស៊ុនគួនត្រប់ប្រការ ។ ស៊ុនគួនលុះដឹងថា ខៀវហ៊ុយ ឧទ្ធដជូឡុង
ដេញដណ្ដើមយកអាតៅទៅវិញ ហើយសម្លាប់ដីវិតស្លាប់ ក៏មានសេចក្ដី
ខឹងខ្ញាំងណាស់ ថាឥឡូវប្អូនយើងត្រឡប់មកវិញហើយ ឯឡៅតិ
ឧទ្ធយើងក៏ជាប់ចាកប្រពៃណីដែលចងគ្នាជាសាសោហិតតទៅ យើងនឹង
លើកពាហានទៅវាយយកស្រុកកេងជីវិញឲ្យបាន ទើបឲ្យហៅនាហ្នឹង
ចាំងពួងចូលមកប្រឹក្សា ហើយក៏ឲ្យគេណ្ដែចំពាដែលនឹងលើកទៅ ខ្លួន
ចំរើរេះមកប្រាប់ថា ឥឡូវបងធ្លូលើកកងទ័ពមកវាយយកស្រុកកាំងតាំង

ហើយ ស៊ុនគួនក៏ឲ្យឈប់កងទ័ពពុក ហើយប្រកាន់ដំបូលាបាហ្មិន តាំងពួន ដើម្បីគិតតស៊ូជាមួយចូនួ ។

ខណៈនោះ មានទាហ៊ានចូលមកថ្លែងថា ដែលខៀវហៀនឈឺទៅ រក្សាខ្លួននៅឯស្រុកនោះដល់ខ្លួវសេចក្តីស្លាប់ហើយ ធ្វើសំបុត្រជូនលោក មួយច្បាប់ ។ ស៊ុនគួនខ្លួលយកសំបុត្រនោះមកមើលឃើញសេចក្តីថា លោកនឹងទៅកងស្រុកកាំងតាំងនោះមិនគួរទេ សូមឲ្យលើកទៅតាំងនៅ កងស្រុកចោះឡែងយើញថា មានភូមិហានធំល្អណាយ ទីឯជាទីតាំងខ្លួន ជាធំតទៅបាន ស៊ុនគួនយើញសំបុត្រហើយក៏អង្គុយយំសោកស្តាយ ហើយនិយាយនឹងទាហ៊ានតាំងពួនថា ខៀវហៀននេះ មានសេចក្តីស្រ-ឡាញ់ខ្ញុំដោយសុចរិត លុះនឹងស្លាប់ហើយក៏នៅធ្វើសំបុត្រខុកឲ្យខ្ញុំទៀត ដើម្បីនឹងឲ្យជាប្រយោជន៍ទៅខាងមុខ គួរតែយើងនឹងខ្លួលធ្វើតាមនោះ ស៊ុនគួនក៏តាំងឲ្យកេណ្ឌមនុស្សទៅធ្វើការរៀបចំទីកន្លែងឯស្រុកចោះឡែង ខណៈនោះ លីបងក៏ចូលមកនិយាយនឹងស៊ុនគួនថា ឥឡូវចូនួ លើកកងទ័ពមក ការកំពង់តែតាល់ដល់ខ្លួននឹងទីខែត្រទ័ណ្ឌដែតណាស់ មកហើយ សូមលោកចាត់ទាហានឲ្យស្រួតទៅដីកស្មាមក្លោះកំងតាំងកង ទ័ពចូនួទៅមាត់តាមយីស៊ូ ស៊ុនគួនយល់ឃើញត្រូវផង ទើបឲ្យកេណ្ឌ ទាហាន ៣ ហ៊ុន ទៅធ្វើការតាំងថ្ម-យប់ឲ្យហើយដោយស្រួចហ៊ាស ។

(នៅមានត)

៥ - រឿងកុមារឡៅសាន និងចៅក្រម

(រឿងព្រេងជាតិថ្មអង់)

5— Lao San et le Magistrat

(Conte de la Nationalité tchouang)

កាលពីព្រេងនាយ មានតាចាស់ម្នាក់ជាអ្នកខ្វត់តែលំបាកគោកយ៉ាកតន់ពេក ។ តាចាស់នេះ ប្រកបមុខរបរត្បាញថ្មស្បែរធ្វើជាលលក់ចិញ្ចឹមជីវិតខ្លួននឹងគ្រួសារ ។

តាចាស់មានបុត្រ ៣ នាក់ ។ ថ្ងៃមួយតាត់រៀបទទួលអនិច្ចកម្ម ក៏ហៅបុត្រទាំង ៣ នាក់មកហើយឲ្យដំបូន្មានថា :

« មនុស្សទាំងអស់ត្រូវមានមរណកស្មើ ដោយអាពុកមានមរណធ្វើដូច្នេះ ចានជាមរណនេះ ចានធ្វើឲ្យកូនឯងនៅរស់នានមានជីវិតលុះសព្វថ្ងៃតែឥឡូវ កូនឯងទាំងអស់គ្នាត្រូវចិញ្ចឹមជីវិតដោយខ្លួនឯង ! » ។

អាពុកនៃអ្នកទាំងបីពោលមកដល់ត្រឹមនេះ ក៏ផុតជីវិតក្នុងពេលនោះទៅ ។ អ្នកទាំងបីចានប្រមូលថ្មតាសដែលសល់ពីអាពុកយកមកចិញ្ចាំរមណ្ឌសមួយជាក់សពអាពុកហើយធ្វើបុណ្យរួចយកទៅកប់ជាស្រេច ។

ក្រោយដែលចានបំពេញករណីយកិច្ចរួចហើយ ថ្មតាសដែលនៅ

សល់មានតែ ៣ ស៊ូ (សេន) ហើយអ្នកទាំងបីបានចែកគ្នាមួយស៊ូម្នាក់ ។

កូនច្បង បានប្រាក់មួយស៊ូគឺតាំងដើរលេងសើចយប់ថ្ងៃទាល់តែអស់ប្រាក់នោះ ។

កូនទីពីរ ជាអ្នកឲ្យសប្បាយធ្វើការព្យាយាមយប់ថ្ងៃ ។ ក្រោយដែលអាពុកលេតទុនបាត់បង់ទៅ គេបានធ្វើជានាយសួនច្បា ។ គាត់យកប្រាក់មួយស៊ូនោះទៅទិញគ្រាប់ដី សាឡាត់ ខាត់ណា ។ល។ គេថែទាំសួនច្បានោះដើម្បីយកផលដំណាំទៅលក់ តែបើគុតជាទិញាយាមយ៉ាងណា ក៏ទៅតែក្រខ្សត់ ។

កូនទីបីនាម «ឡៅសាន» ជាកូនទៅទៅក្មេងណាស់ ។ ឡៅសានចេះតែសួរខ្លួនឯងថា: «តើអញគេរៀងជីវៈបែបណា?» ។ លុះឡៅសានដើរទៅដល់មាត់ស្ទឹងមួយ គេបានឃើញអ្នកនេសាទម្នាក់ ។ ក៏ទំព្យាយាមពិនិត្យពិចារណាមើលទៅអាកប្បកិរិយា ឧបនិស្ស័យ កាយវិការនៃអ្នកនេសាទនោះ ហើយបានយល់ជាក់ច្បាស់អំពីរបរស្ងួចត្រី ។ ក៏ទិញផ្ទៃសន្ទូចពីរឧបនិស្ស័យដែលជាចំណែកកេរ្តិ៍មរតកពីបិតាមកហើយ ទៅស្ងួចត្រីបានជាច្រើន ។

មានកាលមួយថ្ងៃ កុមារឡៅសានបានអង្គុយស្ងួចត្រីទៅមាត់ស្ទឹងនោះជាច្រើនម៉ោងមិនបានត្រីសោះ ។ កុមារឡៅសានក៏ស្រែកថា: "ថ្ងៃនេះ ជាថ្ងៃអតមង្គល រកស្ងួចត្រីមិនបានសោះ" ។ ដល់គោលដូច្នេះ

កុមារឡៅសាន កំរៃឈ្លោកទៅកន្លែងកន្លែកបានឃើញត្រីមួយធំ ស្ថិតនៅជិតសន្ទូច ហើយហាមាត់ធំចាំចរកោតត្រីគួច ។ ដែលវៃហលមកស៊ីសន្ទូច ។ កុមារឡៅសានមានចិត្តក្តៅក្រហាយខ្លាំង កំលើកសន្ទូចបោះទៅចំមាត់ត្រីធំនោះ ។ ត្រីធំក៏ស៊ីខ្ទុយសន្ទូច កុមារឡៅសានក៏ទាញបន្តិចម្តង។ យកមកលើគោក ។ តឹកន្លែពេលនោះ កុមារចាប់ជាន់តែត្រីមួយនោះឯង ។

ពេលសាយណ្ហសម័យ កុមារឡៅសានមានបំណងចង់យកត្រីធំនោះទៅចំអិនធ្វើជាអាហារបរិភោគ ។ ដល់យកត្រីធំនោះទៅវះពោះ ក៏ស្រាប់តែមានឃើញត្រីគួច។ ច្រែន ហើយថែមទាំងមានត្រីឆ្ពិន «Carpe» មួយគួចយ៉ាងល្អ ស្រកាមាសនៅរស់នៅឡើយ ។ កុមារឡៅសានមានចិត្តអាណិតអាសូរកូនត្រីឆ្ពិនមាសនោះណាស់ ក៏យកទៅដាក់ក្នុងអាងទឹកស្ពាន់គួចល្មមមួយ ។ កូនត្រីឆ្ពិនមាសនោះក៏បត់កន្ទុយហែលវិលវង់តាមសេចក្តីអាងទឹកនោះ ។ កុមារឡៅសានគាន់តែមានចិត្តពេរពន់ដោយករុណាជាយ៉ាងក្រៃលែងចំពោះកូនត្រី ។ ភរតែងយកដង្វាយ ឬប្រលឹងឬស្វែងកឲ្យត្រីនោះបរិភោគកល់ថ្ងៃ ។

ឡៅសាន មានចិត្តស្រឡាញ់កូនត្រីឆ្ពិនមាសនោះណាស់ តែងយកទៅជាមួយផង នៅពេលដែលវាទៅស្ទូចត្រី ទៅផ្សារ ឬទៅមើលល្ខោនជាដើម ។

(នៅមានត)

ព្រះរាជពិធីបុណ្យនៅភ្នំប្រាសាទព្រះវិហារ

កាលពីថ្ងៃទី ៤ មករា ១៩៦៣ វេលាម៉ោង ១០ ព្រឹក សម្តេចព្រះប្រមុខរដ្ឋ ជាទីគោរពនឹងជាទីស្នេហាស្មើដោយជីវិតនៃយើង ទ្រង់ស្តេចយាងតាមព្រះទីនាំងជាកូតាពីភជ្ជានីភ្នំពេញ ទៅដល់ចំណតអាកាសយានស្រុកជាំក្សាន្ត ដែលមានរយៈឆ្ងាយពីទីប្រជុំស្រុកជាំក្សាន្តប្រមាណ ៧ គ.ម. រួចទ្រង់បន្តព្រះរាជដំណើរតាមព្រះទីនាំងទៅដល់ទីប្រជុំស្រុកដោយមានទត្តមសេនីយ ង៉ោ - ហ៊ូ ទីប្រឹក្សាអមព្រះអង្គ ឧឡឹកជាមហាសារថីបើកបរដឹកនាំព្រះរាជដំណើរផង ឋានទៅដល់ចំណតអាកាសយានទ្វេម្ភាគបក្រពាំរសេសនាមុខព្រះពន្ធា នៅវេលាម៉ោង ១០ ឧឡឹក ៣០ នាទី ដើម្បីទ្រង់ធ្វើជាព្រះអធិបតីភាព ក្នុងពិធីសម្ពោធទ្វារគណៈនេយ្យដ្ឋានរាជសហការណ៍ឧឡឹកមន្ទីរយោសនាការ ដែលមានឯកទត្តមមៀច - គន្ធឧឡឹកសហជីវិនទឹម - ដុង ជាមេដឹកនាំកសាងទុកជាហិតប្រយោជន៍ចំពោះតសរដ្ឋនៅស្រុកជាំក្សាន្តនេះ ។

លុះទ្រង់ធ្វើជាព្រះអធិបតីកន្លងពិធីសម្ពោធសមិទ្ធិថ្មី ។ ចាំង ២ នេះរួចហើយ វេលាម៉ោង ៩ រសៀល សម្តេចព្រះបិតាតីឡាជាតិស្តេចយាងទៅធ្វើជាព្រះអធិបតីភាពក្នុងឧកាសសម្ពោធមើកការប្រកួតតីឡាចាល់ភាត់ដែលមានធ្វើនៅតីឡាស្តានជាំក្សាន្ត ដោយក្រុមតីឡាព្រះបរមរាជវាំង «ក» ឧល់ឧឡឹកក្រុមតីឡាកង៍យោធពលខេមរភូមិន្ទ «ក» ។ ឯលទ្ធផល : ក្រុម

ភ័ណ្ឌព្រះបរមកជាតិ ចានឈ្នះក្រមភ័ណ្ឌខេមរភូមិន្ទ ៩ ពលទ័ន្ធសូន្យ ។

នៅវេលាម៉ោង ៧ យប់នៃថ្ងៃដដែលនេះ មានធ្វើព្រះរាជពិធីចំរើនព្រះបរិត្ត ក្រោមព្រះអធិបតីភាពនៃសម្តេចព្រះប្រមុខរដ្ឋ នៅព្រះពុទ្ធពិសេសខាងកើតព្រះដំណាក់ ដោយមានសម្តេចព្រះសង្ឃនាយកចាំងតំរកណៈជាដើម ចានទិមន្តទៅកាន់ទីតាសនៃព្រះរាជពិធីចំរើនព្រះបរិត្តនោះឯង ។

លុះចប់ព្រះរាជពិធីនេះហើយ មានអុជធាំជ្រួចភ្លើងទៀនទៅខាងមុខព្រះពុទ្ធពិសេសយ៉ាងអធិកអធ័មក្រៃលែង ហើយសម្តេចព្រះបិតាជាតិខ្ញុំសព្វព្រះរាជហឫទ័យប្រថាប់ក្រសាលជាមួយកូនចៅព្រះអង្គ លុះត្រាតែចប់ពិធីអុជធាំជ្រួច ទើបស្តេចយាងលាកូនចៅព្រះអង្គទៅគ្គួលកាន់ព្រះដំណាក់វិញ ដោយព្រះសុវត្ថិភាព ។

ព្រឹកឡើង ថ្ងៃទី ៥ មករា ១៩៦៣ សម្តេចព្រះបិតានៃបេតិកភណ្ឌជាតិ ជាទីស្នេហានឹងជាទីគោរព ក្រោយដែលស្តេចបានធ្វើជាព្រះអធិបតីក្នុងពិធីសម្ពោធសមិទ្ធិថ្មីៗ ទៅស្រុកជាំក្សាន្តរួចហើយ ស្តេចបានបន្តព្រះរាជដំណើរទៅកាន់ភ្នំព្រះវិហារ ដែលមានចម្ងាយ ៤០ គ.ម. ពីទីប្រជុំជនស្រុកជាំក្សាន្ត ដើម្បីស្តេចទៅនមស្សការព្រះវត្តនៅត្រែ នឹងប្រកបព្រះរាជពិធីបុណ្យជាក់ចាត្រវេចឆ្លាន់ប្រគេនព្រះសង្ឃតាមប្រពៃណីនៃព្រះពុទ្ធសាសនា នឹងជាព្រះអធិបតីក្នុងពិធីបង្ហូតឆ័ត្រជាតិខ្មែរយើងទៅលើភ្នំ

ព្រះវិហារ ជាទំនិត្តរូបនៃការចាប់ផ្តើមចូលមកកាន់មាតុប្រទេសជាទីស្នេហា នៃយើងវិញ នៃបុព្វណាវត្តជាកេរ្តិ៍ដំណែលដូនតាខ្មែរយើង ដែលប្រទេសសៀមបានលួចយកទៅដោយកម្លាំងចិត្តកន្ធត់ធ្ងាំ ១៩៥៣ ។

យើងសូមដកបថា ផ្លូវគមនាគមន៍ពីភ្នំពេញទៅព្រះវិហារ គេត្រូវធ្វើដំណើរតាមផ្លូវជាតិលេខ ១ ហើយត្រូវឈប់សម្រាក ៥ កន្លែងគឺ: ពីភ្នំពេញដល់កំពង់ធំ ១៧០ គ.ម. ពីកំពង់ធំទៅរវៀង ៩២ គ.ម. ពីរវៀងទៅកំពង់ប្រណាក ៦៥ គ.ម ពីកំពង់ប្រណាកទៅជាំក្សាន្ត ៥៧ គ ម. ពីជាំក្សាន្តទៅព្រះវិហារ ៤០ គ ម. ។ បើករួមគិតទូរម៉ែត្រពីភ្នំពេញទៅដល់ភ្នំព្រះវិហារមានចំនួន ៤៣៩ គ. ម. ដោយគិតទៅតាមផ្លូវថ្មីថ្មី ដែលកងវិស្វកម្មមូនុ នឹងមន្ត្រីអ្នកកាជការ នឹងពលរដ្ឋស្ម័គ្រចិត្តបានស្ថាបនាឡើង ។

ប៉ុន្តែ មុននឹងពណ៌នាអំពីព្រះកដសន្ទនកិច្ច នឹងព្រះកដពិធីផ្សេង ។ នៅភ្នំក្រុងសាទព្រះវិហារ យើងសូមធ្វើអត្ថាធិប្បាយដោយត្រួស ។ អំពីតំណាត់នឹងការសំគាល់ឃើញ ព្រមទាំងឯកសារខ្លះ ដែលស្តីអំពីភ្នំក្រុងសាទព្រះវិហារនេះ ដើម្បីឲ្យអ្នកអានបានជ្រាបដូចតទៅ:

ព្រះវិហារបិតនៅក្នុងខែត្រកំពង់ធំ ស្រុកជាំក្សាន្ត លើផ្លូវកុំជនវែកត្រង់ព្រំប្រទល់ចុងបំផុតនៃប្រទេសថៃនឹងប្រទេសកម្ពុជា ។

ក្រុងសាទព្រះវិហារតាំងនៅលើខ្ពង់កប(១)កំពស់ ៦៤៥ ម៉ែត្រ តាម

๑- ខ្ពង់ភ្នំ ឬ ខ្ពង់ទួលដែលមានសភាពរាបស្មើល្អ ។

ផែនដីកូមិសាស្ត្រថ្មាក់ ។ បើតាមអ្នកកូមិសាស្ត្រគេថានិយាយថា ៖ ខ្ពស់ពីខាងជើងទៅខាងត្បូងមានប្រវែង ៤០០ ទីន ៥០០ ម៉ែត្រ ។ តួប្រាសាទដែលសង់នៅត្រង់តែមខាងត្បូងបំផុត លាតសន្ធឹងទៅទិសខាងជើងដោយថ្នល់មួយទៅលើខាងជើងបំផុតនៃខ្ពស់ពេក ។

ទៅខាងត្បូង គឺនៅត្រង់ជើងនៃតួប្រាសាទ ខ្ពស់ពេកមានសភាពចោតត្រង់មកលើពីរាល់កម្ពស់ ។ ចំណែកទៅត្រង់ទិសខាងជើងវិញ គឺនៅទីនៃខ្ពស់ពេកដ៏ទេរដំកល់ទៅរកប្រទេសថៃ ។

រឿងនេះហើយ ដែលនាំឱ្យអ្នកសាងប្រាសាទពន្លូតថ្នល់ដណ្តើរពីខាងជើងទៅខាងត្បូង ។ ខ្ពស់ពេកមានសភាពស្មើស្មុខស្មាធ ។ ខ្ពស់ពេកនេះ ពង់ចូលក្នុងដួរកំពូលភ្នំ ហើយតាំងនៅត្រង់បន្ទាត់ដែលបែងចែកទឹក ។

ព្រះវិហារពិតជាពង់បញ្ចូលយ៉ាងជាច់ខាតក្នុងកើម្តេតក ខាងសិល្បៈនឹងខាងប្រវត្តិសាស្ត្រខ្មែរ ។ អំពីរបៀបសំណង់វិញ លក្ខណៈត្រង់បែបយ៉ាងតាំងអស់នៃតួប្រាសាទ ដូចជាទម្រង់ផែនការរបៀបសំណង់ដំណើរតាក់តែងចម្លាក់រូបភាពផ្សេង ។ គឺជារបស់សិល្បៈខ្មែរតាំងស្រុងដូចជាសិលាប្រាសាទអង្គរដែរ ដែលអាចបញ្ជាក់ឱ្យយើងដឹងថា យើងពុំមានខ្ចីសិល្បៈបរទេសណាមួយ យកមកបញ្ចូលលាយឡំឡើយ ។

ប្រាសាទព្រះវិហារសង់ខ្ពស់ទៅទិសខាងជើង ។ តួប្រាសាទកណ្តាល ដែលសង់នៅត្រង់តែមខ្ពស់ពេក មានតំពែងព័ទ្ធជុំវិញតែមួយ

ផ្លូវកែសាងថ្មីពីរំពាងដំទៅភ្នំប្រាសាទព្រះវិហារដោយឆ្លងកែងខេមរភូមិន្ទ ដើម្បីព្រះបូជនីយកម្មថ្ងៃទី ៥-២-៦៣

ជាន់ ។ ប៉ុន្តែ ទោះបីឥតកំពែងជុំវិញក៏ដោយ ប្រាសាទនេះ
គឺតង់មានគោប៉ុរៈ(១) ៥ ដែរ ។

គោប៉ុរៈទី ១ គឺជាគោប៉ុរៈនៃកំពែងទី ១ ដែលតភ្ជាប់ទៅទីព្រះ
លាន ដែលតាំងទៅខាងមុខគេទៅខាងជើង ។ គោប៉ុរៈទី ២ សម្រាប់
បើកឲ្យចេញពីទីព្រះលាន ហើយទៅដល់ផណ្តើរមួយ តាំងទៅខាងជើង
រួចមានតួថ្មថ្កល់មួយមានខាតទៅសងខាង ។ ទៅទីចំងុតនៃថ្កល់នេះ
គេឃើញមាន គោប៉ុរៈទី ៣ រួចមានផណ្តើរថ្មមួយ ហើយនឹងថ្កល់មួយ
ទៅដល់គោប៉ុរៈទី ៤ គេចេះទៅទិសខាងជើង ។ ពីគោប៉ុរៈទី ៤ ទៅ មាន
ថ្កល់មួយយ៉ាងវែងគេចេះទៅគោប៉ុរៈ ទី ៥ ដែលមានផណ្តើរមួយពីខាងមុខ ។

ពីខាងកើតនឹងពីខាងលិចនៃកំពែងទី ១ មានសង់អគារពីរខ្នងភ្ជាប់
ទៅទីនោះ ។ កន្លងខាងមុខកំពែងទី ១ មានបណ្ណាល័យពីរទៅ
ព័ទ្ធពីខាងមុខគោប៉ុរៈទី ១ ។ មានសាលវែងពីរសន្ធឹងពីខាងជើង ទៅខាង
លិចត្រង់គោប៉ុរៈទី ៣ ។ ទៅពីខាងមុខឈឿងខាងកើតនៃគោប៉ុរៈទី ៤
មានស្រះទឹកមួយ ដែលប្រៀបបាននឹងស្រះទឹកទៅប្រាសាទនាគព័ទ្ធ
កន្លងជុំវិញនៃប្រាសាទអង្គរ ។

យើងសូមជំរាបថា ក្បាច់រចនាទៅប្រាសាទព្រះវិហារ មានរបៀប
ប្លែកគ្នាខ្លះពីក្បាច់រចនាតាំងឡាយទៅប្រាសាទអង្គរ ប៉ុន្តែមានរចនារឿង

១– ភ្លោងទ្វារ ។

ត្រង់ជួរណា ដែលជារឿងមានយ៉ាងច្រើនខោឯប្រាសាទចុងពួន ។

ការពិនិត្យមើលប្រាសាទព្រះវិហារ តុំចាប់តាំងដល់ប្រវត្តិសាស្ត្រ
ក៏អាចបញ្ជាក់ដឹងថា ប្រាសាទព្រះវិហារពិតជាស្នាដៃបុព្វបុរសអ្នកសាង
ប្រាសាទអង្គរជាន់ស្ថាបនាឡើង គឺព្រះអតីតវីរៈក្សត្រខ្មែរយើង ក្នុង
ព្រះទត្តិយវង្សវ័ន្ត ។

បើយើងពិចារណាមើលដោយពិនិត្យយ៉ាងហ្មត់ចត់ទៅតាមលទ្ធិសាស-
នាវិញ យើងអាចសន្និដ្ឋានបានថា ព្រះមហាក្សត្រដែលស្ថាបនាប្រាសាទ
ព្រះវិហារនៅលើកំពូលភ្នំ យ៉ាងខ្ពស់ស្ថិតស្ថេរនេះ ពិតជាសម័យនោះ
ព្រះមហាក្សត្រទ្រង់ជ្រះថ្លាក្នុងកាន់ច្រើន កាន់លទ្ធិសាសនាព្រាហ្មណ៍
ព្រោះថា ប្រាសាទព្រះវិហារតាមគ្រប់រក្សាចំរបង ពិតជាស្ថាបនាបូជាដល់
ព្រះសិវៈដែលជាកំពូលអ្នកដឹកនាំខាងព្រាហ្មញ្ញសាសនា ។ ហើយប្រាសាទ
ព្រះវិហារនោះ ពិតជាកសាងឡើងក្នុងរយៈគ្នាំខាងចុងនៃសតវត្សទី ៩ ។

ប្រាសាទព្រះវិហារ ចានត្រូវប្រទេសថៃឡង់ដ៍ រំលោភយក
ដោយកម្លាំងតាំងពីគ្រាស ពីឆ្នាំ ១៩៥៣ ជាដើរដំណែលដូនតារបស់ខ្លួន ។
ព្រះពជរដ្ឋកិច្ចលើខ្មែរ ដែលមានសម្តេចព្រះនរោត្តម-សីហនុ ជាប្រធាន
ព្រះអង្គទ្រង់ទំប្រឹងប្រែងយ៉ាងគេញចំហឹង ក្នុងការតាមតារយកមកវិញ
នូវភ្នំប្រាសាទព្រះវិហារពីរដ្ឋាភិបាលថៃ តាមផ្លូវចរចា ដោយសន្តិភាព
ជារច្រើនលើកច្រើនគ្រា តែរដ្ឋាភិបាលថៃឡង់ដ៍តុំព្រមប្រគល់ភ្នំប្រាសាទ



ពិធីបង្ហូតទង់ជាតិខ្មែរ នៅប្រាសាទភ្នំព្រះវិហារក្នុងឱកាសបូជនីយសាកម្មនៃសម្តេចព្រះវរោត្តម
សីហនុព្រះប្រមុខរដ្ឋប្រទេសកម្ពុជា ថ្ងៃទី ៤ កុម្ភៈ ១៩៦៣ ។

ព្រះវិហារមកប្រទេសកម្ពុជាវិញឡើយ ។

ដោយគោរពទៅតាមអនុសញ្ញាដែលមានសេចក្តីថា: ការស្នុគ្រស្មាញចាំងឡាយ ដែលមិនអាចដោះស្រាយបានតាមផ្លូវទូតឬតាមកិច្ចព្រមព្រៀងសម្រុះសម្រួលណាមួយនោះ ត្រូវដាក់ជូនទៅឲ្យអ្នកអាជ្ញាកណ្តាលម្នាក់ឬច្រើនខាក់ដួយនៃចំណែក បើគ្មានអ្នកអាជ្ញាកណ្តាលទេ ត្រូវដាក់ជូនទៅតុលាការអចិន្ត្រៃយ៍អន្តរជាតិនោះ ដើម្បីសម្តេចព្រះអគ្គមគ្គុទ្ទេសក៍ជាទីស្នេហានៃយើង ស្តេចបានលើកយកបញ្ហាព្រះវិហារនេះ ប្តឹងទៅតុលាការអន្តរជាតិទៅក្រុងហ្គាហេ ។

ដំណើរដំនេះនេះ ត្រូវបានមកលើប្រទេសកម្ពុជា កាលពីថ្ងៃទី ១៥ មិថុនា ១៩៦២ ដោយតុលាការអន្តរជាតិបានសម្រេចថា: "ភ្នំក្រោសាធព្រះវិហារតែងជារបស់ខ្មែរ ហើយមិនគៅក្នុងដែនដីខ្មែរ" ។


ដើម្បីតបស្នងសងគុណ ចំពោះព្រះគុណានុភាពនៃព្រះរតនត្រៃទីងវត្តដ៏ស័ក្តិសិទ្ធិចាំងឡាយទៅប្រាសាទព្រះវិហារនោះ សម្តេចព្រះនរោត្តម-សីហនុ ព្រះប្រមុខរដ្ឋ ព្រមចាំងឥស្សរជនជាន់ខ្ពស់ជាច្រើនក្នុងព្រះរាជធានី ចាំងពីហាន ចាំងស៊ីវិល គណៈប្រតិភូ ខេត្ត ស្រុក ឃុំក្នុងព្រះរាជអាណាចក្រ ដែលមានជាអាទិ: ព្រះរាជវង្សានុវង្សខ្មែរ សមាជិកឧត្តមក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក ប្រធានទីងសមាជិកនៃសភាចាំង ២ អ្នកអង្គម្ចាស់នាយករដ្ឋមន្ត្រី ទីងសមាជិកនៃព្រះរាជអាជ្ញាកិច្ចាល,

ចៅហ្វាយខេត្តត្រប់ខេត្តចាំងអស់ ។

ចុំណែកឥស្សរជនចរខេសវិញ យើងបានសង្កេតឃើញឯកអគ្គ-រាជទូត - រដ្ឋទូត - ភារធារីនៃប្រទេសឥណ្ឌា ចាក់ឆ្ងាំ ដប៉ុន អង់គ្លេស, យូហ្គោស្លាវី រុស្ស៊ី ឥណ្ឌូណេស៊ី ចិនប្រជាមានិត អូស្ត្រាលី, អាមេរិកាំង ណាវ ប៉ូឡូញ ចេកូស្លូវ៉ាគី អាល្លឺម៉ង់ គណៈបេសក-កម្មនានា អ្នកនែយក្នុងនៃទីភ្នាក់ងារសារពត៌មាន និងអ្នកសារពត៌មានជាច្រើន ព្រមទាំងលោកមេធាវីរបស់ខ្មែរទាំង ២ គឺ: លោកវ៉ូហ្គ្រែ-ប៉ាំងតូ និងលោកប៉ូល-រីចែរទាំង ២ នេះ ជាសាស្ត្រាចារ្យនៅមហាវិទ្យាល័យ ច្បាប់នាក្រុងប៉ារីស ។

ផ្នែកខាងគណៈប្រតិភូព្រះសង្ឃ យើងបានសង្កេតឃើញមានជាង ៤០ អង្គ ដែលមានសម្តេចព្រះមហាសុមេធាធិបតី ជោតញ្ញាណោ (ជួន - ណាត) សង្ឃនាយកគណៈមហានិកាយ និងសម្តេចព្រះសុធម្ម-ធិបតី ឥន្ទញ្ញាណោ (កុល - ខេស) សង្ឃនាយកគណៈធម្មយុត្តិក-និកាយជាដើម ចូលនិមន្តទៅគាន់ប្រាសាទព្រះវិហារដែរ ។

ក្រោយដែលបានយាងដោយព្រះបាទ ឡើងទៅដល់ប្រាសាទព្រះ វិហារហើយ សម្តេចព្រះប្រមុខរដ្ឋ និងព្រះរាជបរិវារ ស្តេចបានទ្រង់ ព្រះពស្ត្រ និងស្បែកគាត់ជាបុញ្ញការី តាមប្រពៃណីនៃព្រះពុទ្ធសាសនា ប្រោះព្ញនមស្ការព្រះតេនវត្រៃ ជាក់ជាក្រប្រតេនព្រះសង្ឃនៅទីនោះ ហើយ



សម្តេចព្រះនរោត្តម-សីហនុព្រះប្រមុខរដ្ឋប្រទេសកម្ពុជា អមដោយអង្គទូតនានា មេដាវីទាំងពីរ
នាម៉ឺនមុខមន្ត្រី ព្រមទាំងប្រជាពលរដ្ឋចំនួនប្រាសាទព្រះវិហារក្នុងឱកាសបួងសួងនិរយោសកម្មថ្ងៃទី ៥-២-៦៣

តមក តែក្រោយពេលដែលព្រះសង្ឃធានេចង្ហាន់ត្រង់រួចហើយ សម្តេចព្រះប្រមុខរដ្ឋ ស្តេចយាងទៅជាព្រះអធិបតីកឋិនពិធីបង្ហូតទង់ជាតិនៅលើប្រាសាទព្រះវិហារទៀត ។

ក្រោយដែលបានធ្វើព្រះពរជាពិធីចប់សព្វគ្រប់ នៅលើភ្នំប្រាសាទព្រះវិហារហើយ សម្តេចព្រះបិតាជាតិ ព្រមទាំងឥស្សរជនជាព្រះពរជារបស់ស្តេចបានយាងចេញពីភ្នំព្រះវិហារនៅវេលារសៀលថ្ងៃដដែល តាមព្រះពីនាំដ៏ខ្ជួនម្ចាស់ចក្រនិងវត្តមកកាន់ព្រះពរជានីភ្នំពេញវិញ ដោយព្រះសុវត្ថិភាព ។

យើងសូមបញ្ជាក់ថា ផលប្រយោជន៍ដែលឡើងទៅកាន់ភ្នំប្រាសាទព្រះវិហារមាន ២. ២៨៨ ម៉ែត្រ ផ្លូវឡើងទៅកាន់ប្រាសាទព្រះវិហារនេះ ពិតមែនតែមានសភាពខ្លុះខ្លោម ដោយការបំផ្លេចបំផ្លាញនៃបច្ចាមិត្រក៏ដោយ ប៉ុន្តែសភាពស្រួលងាយ ក្នុងការឡើងទៅកាន់ភ្នំប្រាសាទព្រះវិហារនេះ ត្រឡប់មានសភាពប្រក្រតីឡើងវិញ ដោយសារស្នាដៃនៃកម្មករស្ម័គ្រចិត្តរបស់យើង ។

នៅក្បែរជើងភ្នំ មានភូមិមួយហៅថាភូមិឫស្សី ដែលមានគេហដ្ឋាននៃប្រជាពលរដ្ឋ ២៥ ខ្នង ។

X X X

នៅពេលដែលនិមន្តមកដល់ភ្នំពេញវិញ សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ នឹងសម្តេចព្រះសុធម្មាធិបតីសង្ឃ

នាយកគណៈធម្មយុត្តិកនិកាយ ជាទីគោរពព្រះសង្ឃដីកាពីរច្បាប់ ចំពោះសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ដីវិតលើឥស្សរជន នឹងសម្តេចព្រះប្រមុខរដ្ឋ ដើម្បីថ្វាយព្រះពរជ័យសួស្តី ។

ព្រះសង្ឃដីកាចុះថ្ងៃទី ៦ មករា ១៩៦៣ នៃសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ មានសេចក្តីថា:

សូមថ្វាយព្រះពរ សម្តេចព្រះមហាក្សត្រិយានី បរមបពិត្រ ជាអម្ចាស់ដីវិត

សូមទ្រង់ជ្រាប ។

អត្ថាការ ព្រមជាមួយនឹងព្រះពុទ្ធសាសនាគណៈមហានុត្រមសង្ឃបានទៅកាន់កុំព្រះវិហារ ហើយបានវិលមកដល់ក្រុងភ្នំពេញវិញទៅវេលាម៉ោង ១០ នឹង ៣០នាទីនៃថ្ងៃទី ៦ មករា ១៩៦៣ ដោយអាកាសយានយន្តមកភូមិន្ទ ប្រកបដោយសេចក្តីសុខនឹងសោមនស្សពាក់ព័ន្ធ ចំពោះពុទ្ធសាសនាដ៏ឧត្តមហាមង្គលនៃព្រះពុទ្ធពិធីបុណ្យសម្ពោធប្រាសាទព្រះវិហារ ដែលជាពិធីអស្ចារ្យក្រៃពេក ក្រោមព្រះពុទ្ធានុភាពនៃសម្តេចព្រះប្រមុខរដ្ឋ ។

សូមថ្វាយព្រះពរ

ដោយសម្តេចជាអម្ចាស់ មានព្រះហឫទ័យរីករាយ ហើយបានទ្រង់ព្រះមេត្តាប្រោសព្រះពុទ្ធានុគ្រោះមួយថ្ម ១ គួរឲ្យយកទៅនោះអាចឲ្យអាត្មាភាពបានឡើងទៅកាន់ប្រាសាទព្រះវិហារបាន ប្រសិនបើមិនមានប្រជាជនសង

ឃោងនោះទេ អាត្មាភាពក៏ពុំអាចនឹងឡើងទៅកាន់ប្រាសាទព្រះវិហារនោះ បានឡើយ ។

អាត្មាភាព សូមថ្វាយព្រះពរមហាដោគដ៏យសស័ក្តិមង្គលគ្រប់ប្រការ សូមសម្តេចជាអម្ចាស់ ទឹងសម្តេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋ ទ្រង់ឈ្នះជាច្បើលដ៏យជំនះមុន ។ ជានិច្ចនិរន្តរ៍តរៀងទៅ។ សូមព្រះអង្គមានព្រះជន្មវស្សាខ្ពយាយុយឺនជាង ១០០ វស្សា ដើម្បីជាម្លប់ដ៏ត្រជាកត្រជុំនៃប្រជាពលរដ្ឋខ្មែរជាកូនចៅរបស់ព្រះអង្គ ជាតំនាក់នៃសាគលលោកតរៀងទៅ: ព្រមទាំងជាព្រះមាតា ព្រះបិតានៃសន្តិសុខ សន្តិភាពរបស់សាគលតំកពលោកផង! ។

សូមថ្វាយព្រះពរ ទៅថ្ងៃទី ៦ មករា ១៩៦៣

សម្តេចព្រះមហាសុមេធាធិបតី ជួន - ណាត (ដោតញ្ញាណោ)

X X X

ព្រះសង្ឃដីកាចុះថ្ងៃទី ៧ មករា ១៩៦៣ នៃសម្តេចព្រះសុធម្មាធិបតី សង្ឃនាយកគណៈធម្មយុត្តិកនិកាយមានសេចក្តីថា:

សូមថ្វាយព្រះពរ សម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ដ៏វិត

សូមទ្រង់ជ្រាប ។

អាត្មាភាព ព្រមទាំងព្រះសង្ឃទាំងឆ្នង ដែលបានទទួលព្រះភជនិមន្តទៅកុដិពិធីបុណ្យឡើងកំពូលព្រះវិហារ បានប្រកបដោយសេចក្តីសុខសប្បាយគ្រប់ព្រះអង្គ ដោយព្រះតេជានុភាពនៃសម្តេចព្រះប្រមុខរដ្ឋជាអម្ចាស់ ។

ចំណែកអាត្មាភាព ដោយព្រះមហាករុណាគុណដ៏ខ្ពង់ខ្ពស់នៃសម្តេច
ជាអម្ចាស់ ដែលទ្រង់ព្រះមេត្តាប្រោសព្រះរាជទានកៅអីស្នង កំបានទៅ
ដល់លើកំពូលភ្នំព្រះវិហារដោយស្រួល បានទៅធ្វើគារវកិច្ចនមស្ការព្រះ
ពុទ្ធរូប ត្រមាំង៍ប្រោះព្រំសុគន្ធកប៉ូជារួចហើយ កំបានដើរមើលប្រាសាទ
ចាក់បែកដែលមានក្បាច់រចនាខឹងថែវត្ថុផ្សេងជារច្រើនកន្លែងទៀត អាត្ម
ភាពមានសេចក្តីសោមនស្សជាពន់ពេកណាស់ ចំពោះបុកណាវត្តនៃបុព្វ
បុរសបង់ខ្មែរជាទីអស្ចារ្យនេះ លុះចុះពីលើកំពូលភ្នំមកវិញ សម្តេច
ព្រះប្រមុខរដ្ឋ កំទ្រង់ប្រោសព្រះរាជទានឲ្យដំរីទន្តីឈ្មោតចម្រុមកវិញ កំធ្វើដំ-
ណើរតែងាយស្រួលទំនងទាប់ទៅទៀត ព្រះសង្ឃទាំងពួងកំបានប្រកប
ដោយសេចក្តីសុខសប្បាយ ទាំងធ្វើដំណើរទៅ-មកត្រង់ព្រះអង្គ ។

សេចក្តីនេះ អាត្មាភាព សូមថ្វាយព្រះរាជកុសលចំពោះសម្តេចជា
អម្ចាស់ទំនឹងសម្តេចព្រះប្រមុខរដ្ឋ សូមទ្រង់បានប្រកបដោយព្រះបរមសុខ
ក្នុងព្រះសិរីរាជសម្បត្តិបវរកាលជាស្ថាពរ មានព្រះជន្មវស្សាទី
ឃាយុជាងរយព្រះវស្សា កុំបីមានអន្តរាយបានឡើយ ដើម្បីបានជាម្លប់
ដ៏ត្រជាក់នៃប្រជាពលរដ្ឋ អស់កាលជាអង្វែងតរៀងទៅ ។

សេចក្តីគួរពុំគួរសូមទ្រង់ព្រះមេត្តាប្រោស

សម្តេចព្រះសុធម្មាធិបតីសង្ឃនាយក

ឥន្ទញ្ញាណោ ភិក្ខុ - ឧទ្ទេស

សកម្មភាពទូទៅ

នឹងសកម្មភាពនៅធមាសទី ២ ឆ្នាំ ១៩៦២

នៃក្រុមជំនុំខ្មែរខ្មាប់ខ្នុរ

ក្រុមជំនុំខ្មែរខ្មាប់ខ្នុរ ជាផ្នែកមួយសំខាន់ណាស់ក្នុងចំណោមផ្នែកនានារបស់ក្រុមពុទ្ធសាសនបណ្ឌិត្យ ក្រសួងធម្មការ ក្រុងភ្នំពេញ ។

គោលធំរបស់ក្រុមជំនុំនេះ នៅត្រង់ការស្រាវជ្រាវប្រមែប្រមូលរកនូវឯកសារផ្សេង ។ ស្តីពីខ្មែរខ្មាប់ខ្នុរ ដែលទាក់ទងដោយព្រហ្មញ្ញសាសនា និងពុទ្ធសាសនា ហើយនិងនៅត្រង់ការតែងសៀវភៅស្តីពីអារ្យធម៌ខ្មែរនោះ ។ ចោះពុម្ពផ្សាយចេញជាបន្ត ។ ដើម្បីជាប្រយោជន៍ខាងជាតិពន្ធុវិជ្ជា ។

ក្រុមជំនុំនេះមានតាំងសមាជិកធ្វើយធ្វងច្រើនរូប ពយៅតាមក្រុងតាមខេត្ត តាមស្រុកនានា ពួតាំងព្រះពជ្ឈាណាចក្រ សម្រាប់ធ្វើការទាក់ទងគ្នាខាងការស្រាវជ្រាវរកខ្មែរខ្មាប់ខ្នុរ ។

មកទល់នឹងដំណាច់ឆ្នាំ ១៩៦២ ក្រុមជំនុំបានទទួលឯកសារជាភាសាខ្មែរចំនួន ៦៣៤០ រឿង អំពីសមាជិកធ្វើយធ្វងឲ្យការណ៍មកខ្លះ អំពីការអេះតយកការណ៍ផ្ទាល់របស់បុគ្គលិកនៃក្រុមជំនុំខ្លះ អំពីការដាក់ប្រឡងប្រជែងកល់ធមាសកល់ឆ្នាំខ្លះ - អំពីវិញ្ញាជនក្រៅពីនេះឲ្យការណ៍មកខ្លះហើយបានរក្សាទុកនូវឯកសារទាំងនោះដោយចំពូក ។ ក្នុងនូមានឋត ១០០ ក្រមទាំងបានប្រែចេញជាភាសាចាក់ងគ្រប់ឯកសារទាំងនោះផង ។

ឯកសារទាំងនោះមានប្រយោជន៍សំខាន់ដល់អ្នកស្រាវជ្រាវ ទាំងខាងខេមរជន ទាំងខាងជនបរទេស ដែលក្រុមដំនុំបានទទួលជនរួមជាតិ និងជនបរទេសចូលមកសាកសួរព្រឹត្តិទំនៀមទម្លាប់ខ្មែរលោះថ្ងៃគ្រិចណាស់ ។

មិត្តភាពបៀបចាត់ការ

ក្រុមដំនុំបានចាត់ការតាមគោលដៅ ដូចរៀបរាប់ដោយសង្ខេបខាងមុខនេះ :

១- បានប្រមូលឯកសារស្តីពីជាតិពន្ធសាស្ត្រខ្មែរ ជាអាទិ៍គឺប្រវត្តិការណ៍ផ្សេងៗ ទំនៀមផ្សេងៗ និងដំនឿផ្សេងៗ ដែលមានសេចក្តីអធិប្បាយយ៉ាងហ្មត់ចត់ត្រប់ ។

២- បានផ្សាយចេញជាភាសាខ្មែរនូវទំនៀមផ្សេងៗ ដោយពួកៗ ដែលបានចោះពុម្ពចេញហើយនូវសៀវភៅ ៧ ក្បាល គឺ ព្រះរាជពិធីភូមិសាស្ត្រ ភាគ ១ ភាគ ២ ភាគ ៣ ប្រជុំរឿងព្រេងខ្មែរ ភាគ ១ ភាគ ២ ភាគ ៣ ភាគ ៤ ហើយបម្រុងនឹងចោះពុម្ពប្រជុំរឿងព្រេងខ្មែរ ភាគ ៥ និងភាគខាងចុងៗ តទៅទៀត ។

៣- បានផ្សាយចេញជាភាសាបរទេសនូវសៀវភៅ ២ ក្បាល គឺ ពិធីភូមិសាស្ត្រ ១ ពិធីកសិគ្រឹស្តសាវនៃខ្មែរ ១ ហើយបម្រុងនឹងចោះពុម្ពសៀវភៅ ១ ទៀត ស្តីពីជីវភាពនៃជនជាតិខ្មែរ ។

៤- នៅការិយាល័យក្រុមដំនុំទំនៀមទម្លាប់ មានសារមន្ទីរមួយ

តំកល់វត្តដំណាងខ្សែ ។ ដែលជារបស់បុកណារបស់ខ្មែរ ត្រូវតាំងមាន
ផ្ទាំងតំនូររូបភាពតំណាងទំនៀមផ្សែង ។ របស់ខ្មែរ ចោះភ្ជាប់នៅជញ្ជាំង
នៃមន្ទីរក្រុមដំនុំផង សម្រាប់ជាជំនួយស្មារតីអ្នកទស្សនា ។

ក្រៅពីការដម្ងក ជាអាទិតីការស្រាវជ្រាវ ការអង្កេត ការពិនិត្យ
ការប្រៃឯកសារភាសាខ្មែរនៅជាភាសាបរទេស ទឹងការសរសេរតែងជា
សៀវភៅស្តីអំពីទំនៀមទម្លាប់ខ្មែរ សម្រាប់ចោះពុម្ពផ្សាយចេញក ។ នៅ
ខាងមុខនោះ, មានការប្រឡងប្រៃឯកលាលធមាសរៀងកលាំ ដើម្បី
ជ្រើសរើសយកឯកសារទំនៀមទម្លាប់ ចំពោះឯកសារណាដែលខ្លះ ។

នៅធមាសទី ២ ឆ្នាំ ១៩៦២ ក្រុមដំនុំទំនៀមទម្លាប់បានជ្រើសរើសយក
ឯកសារទំនៀមទម្លាប់អំពីរបក្ខជន ដោយបើកការប្រឡងប្រៃឯទំនៀម
ទម្លាប់ពាក់ទងដោយទឹក ១ ដោយពពិល ១ ទឹងបានស្រាវជ្រាវរកឯកសារ
ទំនៀមទម្លាប់អំពីសមាជិកឆ្នើយឆ្នង ដោយសាកសួរឲ្យគេសរសេរឆ្នើយ
ឲ្យការណ៍មក ។

លទ្ធផលនៃការជ្រើសរើស ទឹងការស្រាវជ្រាវនោះ ក្រុមដំនុំបាន
ទទួលឯកសារទំនៀមទម្លាប់ ៦៣ រឿង អំពីរបក្ខជនទឹងអំពីសមាជិក
ឆ្នើយឆ្នង ៣៤ រូប ដូចរៀបរាប់ខាងមុខ គឺ

១- លោក គៀត-គី ឃុំកំពង់ហ្លួង ស្រុកពញាឮ ខេត្តកណ្តាល
ឯកសារស្តីអំពីប្រវត្តិទីក្រុងឧត្តុង្គមានជ័យ អំពីទឹក អំពីពពិល ទឹងអំពី

ពន្ធវាតារខ្មែរ ។

២- លោក ហុង-ស៊ុន-ហេង អធិការដ្ឋានបឋមសិក្សាកំពង់ចាម អំពីប្រវត្តិភូមិ-ឃុំ-ស្រុកនានា ខ័ណ្ឌប្រវត្តិភូមិឫស្សីបីឆ្នាំភូមិតាកយ នៅខេត្តកំពង់ចាម ហើយខ័ណ្ឌរឿងព្រេងកុំប្រុស-ស្រីក្នុងខេត្តជាមួយ ។

៣- លោក ភ័ណ-គួ ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ អំពីក្បួនភ័ណ្ឌហោះ អំពីទឹក អំពីពពិល អំពីវារីបថ ខ័ណ្ឌពិធីការពារ ។

៤- កិក្ខុ ណុប-ភាង វត្តអង្គព្រះចេតិយ ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ អំពីពពិល ។

៥- លោក កង-កែម ឃុំកំពង់ហ្លួង ស្រុកពញាឮ ខេត្តកណ្តាល អំពីទឹក ខ័ណ្ឌអំពីពពិល ។

៦- លោក ឃួង-អ៊ូច ឃុំអង្កាញ់ ស្រុកកៀនស្វាយ ខេត្តតាកែវ អំពីពពិល អំពីទឹក អំពីភ្លើង ។

៧- លោក ខាំ-កែវ ឃុំគោរះ ស្រុកល្វាឯម ខេត្តកណ្តាល អំពីទឹក ។

៨- លោក សំ-សាកឿន សិស្សថ្នាក់ទី ៤ ទំនើបជាតិ នៃអនុវិទ្យាល័យមុនីបុត្រ ឃុំតាខ្មៅ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល អំពីពពិល ខ័ណ្ឌអំពីទឹក ។

៩- លោកពេជ្រ-ចិត្ត សមាជិកក្រុមជំនុំទំនៀមទម្លាប់ អំពីប្រវត្តិ

សាលាលេខ១៥ ឧទ្ធរណ៍ប្រវត្តិស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។

១០- លោក សម-ម៉ាស៊ី ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល អំពីទីក ។

១១- លោក ចាំ-ហោង ស្រុកកន្ត្រៃច ខេត្តព្រៃវែង អំពីទីក ឧទ្ធរណ៍ពីលា ។

១២- លោក កែវ-អ៊ុន ឃុំចេក ស្រុកស្វាយរៀង ខេត្តស្វាយរៀង អំពីពីលា ឧទ្ធរណ៍អំពីទីក ។

១៣- លោក សាន-ឡុង គ្រូបង្រៀនទៅសាលារៀនច្រាមយ៉ាម ឃុំច្រាមយ៉ាម ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម អំពីពីលា ។

១៤- លោក កែវ-កុល ភូមិជ្រៃរយោង ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ អំពីទីក ឧទ្ធរណ៍អំពីពីលា ។

១៥- លោក សួន-ម៉ុម ភូមិចន្ទ្រា ឃុំស្ពឺ ស្រុកចុង្កុំ ខេត្តព្រៃវែង អំពីទីក ឧទ្ធរណ៍អំពីពីលា ។

១៦- លោក ឌី-ហាម សិស្សអនុវិទ្យាល័យមុនីបុត្រ ឃុំតាភៀ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល អំពីពីលា ឧទ្ធរណ៍អំពីទីក ។

១៧- លោកកិត្តិ ព្រាប-ស៊ុត វត្តច្រា ឃុំធ្នក ស្រុកស្វាយរៀង ខេត្តស្វាយរៀង អំពីពីលា ។

១៨- លោក ខេត-វស់ ឃុំលំចង់ ស្រុកសំរោង ខេត្តតាកែវ

អំពីទឹក នឹងអំពីពពិល ។

១៩- អ្នកស្រី ខេព-សាងឿម ឃុំលំពង់ ស្រុកសំរោង ខេត្តតាកែវ អំពីទឹក ។

២០- លោក ដឹម-ឈុំ ឃុំឫស្សីព្រៃ ស្រុកសណ្តាន់ ខេត្តកំពង់ធំ អំពីពពិល នឹងអំពីទឹក ។

២១- លោក ច្រាក់-ខាត់ ឃុំពង្រ ស្រុកឆ្លូង ខេត្តក្រចេះ អំពីពពិល នឹងអំពីទឹក ។

២២- លោក សុខ-នូវ កូមិនោធិតូច ឃុំកំពង់ហ្លួង ស្រុកពញាឮ ខេត្តកណ្តាល អំពីទឹក ។

២៣- លោក ម៉ក់-ចេង ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ អំពីទឹក ។

២៤- លោកគ្រូ ចាប-ចន្ទ វត្តក្តីក្រៅ ឃុំខ្នាវស ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម អំពីទឹក នឹងអំពីពពិល ។

២៥- លោក រឿម-យឹម ឃុំលំពង់ ស្រុកសំរោង ខេត្តតាកែវ អំពីទឹក នឹងអំពីពពិល ។

២៦- លោក មៅ-ហ៊ុន ឃុំអន្សាចំបក់ ស្រុកក្រគរ ខេត្តពោធិសាត់ អំពីទឹក នឹងអំពីពពិល ។

២៧- លោក ពៅ-ឡាន ឃុំព្រៃកឯង ស្រុកកៀនស្វាយ ខេត្ត

កណ្តាល អំពីពពិល ។

២៨- លោក តៅ-យ៉ ឃុំបឹងត្រាញ់ ស្រុកសំរោង ខេត្តតាកែវ អំពីទឹក ឧដ្ឋពពិល ។

២៩- លោក កែវ-សារិន ភូមិត្នោត ឃុំខ្ចារ ស្រុកបាគាន ខេត្តព្រៃវែង អំពីទឹក ។

៣០- លោក សៅ-ភៅ ឃុំព្រែកឯង ស្រុកកៀនស្វាយ ខេត្តកណ្តាល អំពីពពិល ។

៣១- លោក មាស-សោម ស្មៀនឃុំ។ សួង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម អំពីទឹក ។

៣២- លោកកិត្តិ ឥត-សុទ្ធ វត្តសង្វរ ឃុំកំពង់ហ្លួង ស្រុកពញាឮ អំពីពពិល ឧដ្ឋអំពីទឹក ។

៣៣- លោក ង៉ោក-ថេង លេខាធិការសហការណ៍ឧបភោគបរិភោគ ឃុំផ្អាវ ស្រុកដើមចៃ ខេត្តកំពង់ចាម អំពីពពិល ។

៣៤- ព្រះវិន័យធរ អ៊ុម-សុម វត្តសាកវ័នតេជោ ក្រុងកំពត អំពីទឹក ឧដ្ឋអំពីពពិល ។

៣៥- កិត្តិ កែវ-ថៃ វត្តត្តគ្រៅ ឃុំខ្ចារសេ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម អំពីទំនៀមផ្សេង ។ ។

អំពីលទ្ធផលនៃការប្រឡង

ក្រុងដំទុំបានជួបជុំពិនិត្យវិញ្ញាសាប្រឡងដោយហ្មត់ចត់ ឃើញ
បានលទ្ធផលដូចបានរៀបរាប់ខាងមុខ :

ផ្នែកវៀងធំតា

- លេខ ១ បានដល់លោកតង-ឆែម នៅឃុំកំពង់ហ្លួង ស្រុក
ពញាឮខេត្តកណ្តាល ត្រូវបានវង្វាន់ ៧០០រ០០ ។

- លេខ ២ បានដល់ព្រះវិន័យធរ អ៊ុម-ស៊ុម គង់វត្តសាកវ័នតេជោ
ក្រុងភ្នំពេញ ត្រូវបានវង្វាន់ ៥០០រ០០ ។

- លេខ ៣ បានដល់លោក រៀម-យឹម នៅឃុំលំចង់ ស្រុក
សំរោង ខេត្តតាកែវ ត្រូវបានវង្វាន់ ៤០០រ០០ ។

- លេខ ៤ បានដល់កិក្ខុ ខិត-សុខ្ខ គង់វត្តសង្វរ ឃុំកំពង់ហ្លួង
ស្រុកពញាឮ ខេត្តកណ្តាល ត្រូវបានវង្វាន់ ២០០រ០០ ។

ផ្នែកវៀងពពិល

- លេខ ១ បានដល់លោក សាង-ឡុង គ្រូបង្រៀននៅសាលា
រៀនប្រាមយ៉ាម ឃុំប្រាយ៉ាម ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ត្រូវបាន
វង្វាន់ ៧០០រ០០ ។

- លេខ ២ បានដល់ព្រះវិន័យធរ អ៊ុម-ស៊ុម គង់វត្តសាកវ័នតេជោ
ក្រុងភ្នំពេញ ត្រូវបានវង្វាន់ ៥០០រ០០ ។

-លេខ ៣ ចាន់ដល់លោក កង-កែម នៅឃុំកំពង់ហ្លួង ស្រុក ពញាឮ ខេត្តកណ្តាល ត្រូវចាន់ប្លាន់ ៤០០រ០០ ។

-លេខ ៤ ចាន់ដល់លោក ព័ណ-គួ នៅឃុំអង្គតាសោម ស្រុក ត្រាំកក់ ខេត្តតាកែវ ត្រូវចាន់ប្លាន់ ២០០រ០០ ។

ប្លាន់ដែលត្រូវចាន់ដល់លោកអ្នកប្រឡងជាប់ចំនួននេះ ក្រុមដំនុំចាន ប្រគេន-ចាន់ជូនគ្រប់រូបហើយ ។

ចំណែកប្លាន់ដែលត្រូវចាន់ដល់សមាជិកធ្វើយទ្ធន នោះ ក្រុមដំនុំ ចាន់ជូនហើយខ្លះ នៅខ្លះទៀត ចាំជូនថ្ងៃខាងមុខ ។

ក្រុមដំនុំចំនៀមទម្លាប់ មានអំណរក្រៃពេក ចំពោះការដែលលោក អ្នកជាបេក្ខជន ឬជាសមាជិក ចាន់ព្យាយាមសរសេរឯកសារដាក់ប្រឡង ឬធ្វើអំណោយក្នុងធម្មាសនៈ ២ ខ្នាំ ១៩៦២ រួចមកហើយនោះ ។

ចំពោះធម្មាសនៈ ១ ខ្នាំ ១៩៦៣ នេះ ក្រុមដំនុំមានបើកការប្រឡង ២ មុខទៀត គឺ អំពីរឿងព្រេងពាក់ព័ន្ធដោយប្រវត្តិសាស្ត្រ-កូមិសាស្ត្រ ខ្មែរដែលយានៃខ្លះ ដូចចាន់ចែកប្រកាសប្រឡងនោះ ផ្សាយខ្លួទៅតាម ខេត្ត-ស្រុក ខ្មែរដែនបទខានាវួចហើយ ។ ដូច្នេះសូមព្រះគេជព្រះ គុណ-លោកអ្នក យកព្រះទ័យ យកចិត្តទុកដាក់ជួយចំនុកបំរុងក្រុមដំនុំ ចំនៀមទម្លាប់ដោយការតែងឯកសារដាក់ប្រឡងឬធ្វើអំណោយតទៅទៀត

ដើម្បីញ៉ាំងឯកសារ ស្តីពីអារ្យធម៌ខ្មែរ ឲ្យមានសម្បូណ៌ ក្នុងការិយាល័យ
ក្រុមជំនុំទំនៀមទម្លាប់ ជាសម្បត្តិរបស់ជាតិតទៅ ។

ក្រុមជំនុំសូមទទួលអំណរគុណទុកជាមុន ។

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

អនុសាវរីយ៍មហាសន្និបាតនៃមន្ត្រីសង្ឃលើកទី ១៩

អនុសាវរីយ៍មហាសន្និបាតនៃមន្ត្រីសង្ឃលើកទី ១៩ បានចាប់ផ្តើមពីថ្ងៃពុធ ១៥កើត ដល់ថ្ងៃចន្ទ ៩រោច ខែបុស្ស ឆ្នាំខាលចត្វាស័ក ព.ស. ២៥០៥(៩-១៤ មករា ១៩៦៣) នៅវត្តបទុមវតីរាជវរារាម ឧដ្ឋវត្តុ ណ្ណាលោម ក្រោមអធិបតីភាពនៃសម្តេចព្រះសង្ឃនាយកគាំង៩ពីរតណៈ ។

ថ្ងៃទី ១

ថ្ងៃពុធ ១៥កើតខែបុស្ស (៩-១-៦៣) វេលាម៉ោង ១៤ នឹង ៣០ នាទីទៅម៉ោង ១៥ ជាពេលបើកវគ្គសន្និបាត នៃមន្ត្រីសង្ឃ គាំង៩ពីរតណៈ សហជីវិនម៉ែន-ឈុំ អនុរដ្ឋលេខាធិការក្រសួងធម្មការ ដោយមានលោក ចាន់-សុន នាយកការិយាល័យក្រសួងធម្មការ លោក លឹម-ឆ្លួន សេង នាយខុទ្ទកាល័យ លោក យឿម-ចឹម អគ្គលេខាធិការ នៃពុទ្ធសាសន បណ្ឌិត្យ លោកតែ-ម៉ែង-ហាប់ អគ្គលេខាធិការនៃពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ព្រមគាំង៩សហការ៍ឯទៀតជូនដំណើរផង បានអញ្ជើញទៅកាន់វត្តបទុមវតី ឧដ្ឋវត្តុ ណ្ណាលោម ដើម្បីបើកសម័យប្រជុំមហាសន្និបាតសម្រាប់ឆ្នាំខាលចត្វាស័ក ព.ស. ២៥០៥ នេះ ។

ថ្ងៃទី ២

ថ្ងៃព្រហស្បតិ៍ ១ រោចខែបុស្ស (១០-១-៦៣) វេលាព្រឹកម៉ោង ៨ មានការនិមន្តព្រះសង្ឃគាំង៩ពីរតណៈចំនួន ៤០ អង្គ ចំពោះព្រះសត្តប្បការ-ណាភិធម្ម ទុទ្ធិសព្រះពាជកុសលថ្វាយព្រះចិតារ នៅចេតិយគាំង៩ ខាង

មុខព្រះវិហារព្រះកែវមរកត ។ នៅម៉ោង ១០ ទឹង ៣០ នាទី ព្រះសង្ឃ
ចាំងពីគណៈ ខ្លួចចង្ហាន់ថ្ងៃត្រង់នៅវត្តបទុមវតី ទឹងវត្ត ណាលោម
ចំពោះមុខសហជីវិនអនុរដ្ឋលេខាធិការក្រសួងធម្មការ ។

នៅថ្ងៃដដែលនេះ ក្រសួងធម្មការ បានបើកធ្វើពិធីអនុស្សាវរីយ៍មហា
សន្និបាតនៃមន្ត្រីសង្ឃលើកទី ១៩ នៅយប់នៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត
ក្រោមព្រះអធិបតីភាពនៃសម្តេចព្រះប្រមុខរដ្ឋ ជាព្រះកឋតំណាងដ៏ខ្ពង់-
ខ្ពស់នៃសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង ។

ចាប់តាំងពីម៉ោង ១៩ ទឹង ៣០ នាទី ៣ នៅកន្លែងប្រារព្ធពិធីនោះ
គេបានសង្កេតឃើញ សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈ
មហានិកាយ សម្តេចព្រះសុធម្មាធិបតីសង្ឃនាយកគណធម្មយុត្តិក -
និកាយ ព្រះពោធិវង្ស ហួត-តាត ចាងហ្វាងខ្លួនៃពុទ្ធិកសិក្សា ព្រះ
សង្ឃជាពាជាគណៈហានានុក្រម មេគណ អនុគណ គ្រប់ខែត្រ-
ស្រុក ចៅអធិការគ្រប់វត្តកងពាជធានី ព្រមទាំងព្រះសង្ឃជាច្រើនពាន់
អង្គទៀត ដែលទំមន្តមកពីវត្តនានា កងក្រុងនិងខែត្រក្រៅ ដើម្បីរួបរួម
កងមហាសន្និបាតនេះ ដែលមានសភាពដ៏សមរម្យ ៗ តាមសមណសា-
រូបយ៉ាងក្រៃលែង ។

ក្នុងចំណោមសង្ឃជន គេបានសង្កេតឃើញ អ្នកអង្គម្ចាស់
នរោត្តម-កន្តុល នាយករដ្ឋមន្ត្រី អ្នកអង្គម្ចាស់នរោត្តម-មុនីតាណា



មហាសន្និបាតនៃព្រះសង្ឃប្រជុំនៅអគ្គ មានសម្តេចព្រះសង្ឃនាយកទាំងពីរគណៈជាអធិបតី ក្នុងឱកាសពិធីអនុស្សាវរីយ៍លើកទី ១៥

នាយ៉ាតទ្រីកវិទ្យាល័យព្រះសុរាម៉ិត ថ្ងៃទី ១១-២-៦៣

ប្រធានក្រុមប្រឹក្សាព្រះពុទ្ធសាសនាចក្រ ឯកឧត្តម ហៅសែនកុសល ប្រធានវត្តសិកា ឯកឧត្តមខេត-ផន ព្រះពុទ្ធប្រតិភូប្រចាំក្រុងភ្នំពេញ ឯកឧត្តម សឺន-សាន ខេសាតិចាលធនាគារជាតិកម្ពុជា ព្រមទាំងសមាជិកព្រះពុទ្ធាកិច្ចាល សមាជិកសភាទាំងពីរ ខាងក្រសួងធម្មការ មានសហជីវិន ម៉ែន-ឈុំ អនុរដ្ឋលេខាធិការក្រសួងធម្មការជាអ្នកចាត់ចែងពិធី សហជីវិន ចាន់-សុន នាយកការិយាល័យ សហជីវិន លឹម-ឆ្លួន-សេង នាយរុក្ខ-ការិយ ព្រមទាំងមន្ត្រីតំណាងក្រសួងនានា ប្រធានពុទ្ធិកសមាគម ប្រធានសមាគមគិលានសង្គ្រោះ សាស្ត្រាចារ្យនៃពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុពុទ្ធិកវិទ្យាល័យព្រះសុកម្រិត ព្រមទាំងមន្ត្រីពុទ្ធសាសនាច្រើនរូបទៀត ជាទីស្តេចយាង អញ្ជើញមកដើម្បីរួបរួមជាកិត្តិយសក្នុងពិធីនេះដែរ ។

នៅវេលាម៉ោង ១៦ នឹង ៣០ នាទី សម្តេចព្រះប្រមុខរដ្ឋជាព្រះពុទ្ធតំណាងដ៏ខ្ពង់ខ្ពស់ នៃសម្តេចព្រះមហាក្សត្រីយានីជាអម្ចាស់ដ៏វិតលើត្បូងដោយមានឧត្តមក្រុមប្រឹក្សាព្រះពុទ្ធបល្ល័ង្ក ព្រមទាំងព្រះពុទ្ធបរិតាជាល់ព្រះអង្គជាច្រើនទៀត អមព្រះពុទ្ធដំណើរផង ជាទីស្តេចយាងមកដល់កន្លែងប្រារព្ធពិធី ដោយជាទីទួលគារវកិច្ចដ៏ខ្ពង់ខ្ពស់បំផុតអំពីក្រុមការហានរក្សាព្រះអង្គដែលលើកអាំណេរើនកិច្ច ទីឆាបន្ទីទួរបទក្លែងបន្លំលាថ្វាយជាព្រះពុទ្ធ-កិត្តិយសផង ។

តមក សម្តេចវត្រង់ថ្វាយនូវលិខិតក្រាបថ្វាយបង្គំអំពីឥស្សរជនជាន់ខ្ពស់ នឹងមន្ត្រីអ្នកភក្តីការចាំងឡាយ ដែលរង់ចាំក្រាបថ្វាយបង្គំសុំដែងសេចក្តីស្វាមីភក្តិចំពោះព្រះអង្គ ហើយដង្ហែព្រះរាជដំណើរចូលទៅថ្វាយបង្គំព្រះសង្ឃ ដែលមានសម្តេចព្រះសង្ឃនាយកចាំងពីរគណៈជាប្រធាន ។ ខណៈនោះ បពិត្រទូលបង្គំជាតិកំចាន់ចង្ហើរឡើងជាគ្រឿងញាំងកម្លាំងឲ្យប្រព្រឹត្តទៅដោយកាពុងរឿង ។

ក្រោយដែលសម្តេចព្រះបិតាជាតិ ស្តេចគង់ប្រថាប់លើព្រះសុវណ្ណ-រាជ្ជៈ ក្នុងយានៃពុទ្ធិកវិញ្ញាល័យព្រះសុរាម្រិត ស្រួលព្រះឥរិយាបថហើយ សហជាវិនមែន-ឈ្មោះ អនុរដ្ឋលេខាធិការក្រសួងធម្មការ ថ្វាយវិច្ឆិសុន្ទរកថាបញ្ជាក់អំពីដំណើរពុទ្ធសាសនាទៅប្រទេសកម្ពុជា ដែលមានសេចក្តីចំរើនរុងរឿងរហូតមក ដោយថ្វាយទូលការឧបត្ថម្ភអំពីព្រះមហាក្សត្រចាំងឡាយគ្រប់ព្រះអង្គ ជាពិសេស សហជាវិនអនុរដ្ឋលេខាធិការក្រសួងធម្មការថ្វាយរៀបរាប់ អំពីការប្រែងបង្កើតឲ្យមានបណ្ណាល័យគ្រប់វត្តកន្លែងព្រះពុទ្ធសាសនាចក្រធាង ។

តមក ព្រះតេជព្រះគុណព្រះសាសនសំវរ កាន់-ឯល មេគណខេត្តកណ្តាល ថ្វាយវិច្ឆិសុន្ទរកថាមួយក្នុងនាមនៃមន្ត្រីសង្ឃ ដែលមានសម្តេចព្រះសង្ឃនាយកចាំងពីរគណៈជាប្រធាន ទំនងព្រះសង្ឃក្នុងកម្ពុជរដ្ឋចាំងមូលរដ្ឋបញ្ជាក់អំពីការប្រព្រឹត្តទៅនៃព្រះសង្ឃចាំងអស់កន្លងកម្ពុជរដ្ឋ ។

លុះចប់សុន្ទរកថាចាំងពីរនេះហើយ ព្រះសង្ឃក៏ថ្វាយធម្មទេសនាប្រសិទ្ធិពរជ័យថ្វាយចំពោះសម្តេចព្រះប្រមុខរដ្ឋ ដើម្បីជាសុភមង្គល



សម្តេចព្រះនរោត្តម-សីហនុព្រះប្រមុខរដ្ឋប្រទេសកម្ពុជា ទ្រង់ថ្លែងព្រះសង្កថាក្នុងពិធីអនុស្សាវរីយ៍លើកទី ១៩ នាយ៉ាពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត

ដំបូរសើចចំអោះព្រះអង្គ ។

បន្ទាប់មក សម្តេចព្រះបិតាជាតិស្តេចចាន់ថ្លែងព្រះសង្ឃថាឥតត្រាន់តែ
ពុទ្ធដំណាក់តែមួយបញ្ជាក់អំពីព្រះពុទ្ធគុណនេះទេ សូមអង្គព្រះវិហារ ជាដំណាក់ដែលគុណ
ភាវៈនេះគង់នៅជាតិ ដើម្បីគ្រប់អាចារ្យប្រគល់ដល់យើង ដោយឃុត្តិធម៌
ដែរ តែពួកឯទៀតទេ ឱ្យសង់ការណ៍ក្នុងប្រទេស ក្រៅប្រទេស ក្នុងសម័យ
ជុំគ្នា ដោយទ្រង់បញ្ជាក់ថា ឥឡូវប្រទេសយើងតិចណាស់ តែសង្ឃភាព
ច្រើនណាមែន ព្រោះតែយើងប្រកាន់ខ្ជាប់នូវនេះយ៉ាងយូរអង្វែងឥតប្រែប
ដោយអតតិធម៌ ។

លុះចប់ព្រះសង្ឃថាដំណាន់ទី៣សារនេះហើយ សម្តេចព្រះប្រមុខរដ្ឋគិ
ច្ចក្រាបថ្វាយបង្គំលាព្រះសង្ឃគាំងអស់ ដែលមានសម្តេចព្រះសង្ឃនា-
យកគាំងពីរគណៈជាប្រធាន ហើយដោយមានព្រះពុទ្ធបរិតាដែលជាផ្លែ
អមតធំ ចាន់ស្តេចយាងនិវត្តចូលព្រះបរមរាជវាំងវិញ ។

ពិធីនេះចាន់ចប់សព្វគ្រប់នៅវេលាម៉ោង ១៨ ក្រោយព្រះសង្ឃចាន
ឆ្លងគ្រប់គ្នាហើយ ។

ចាប់តាំងពីថ្ងៃទី ១១ រហូតដល់ថ្ងៃទី ១៤ មករា ១៩៦៣ ព្រះសង្ឃ
គាំងពីរគណៈប្រជុំនៅវត្ត ណ្ណាសោម នឹងវត្តបទុមវតី ក្រោមអធិបតីភាព
នៃសម្តេចព្រះសង្ឃនាយកគាំងពីរគណៈ នឹងតាមកម្មវិធីដែលសម្តេចគាំងពីរ
ព្រះអង្គបានចាត់ធ្វើ ។

សុន្ទរកថា

ថ្វាយដោយ សហជីពនៃ ម៉ែ ន - ឈុំ អនុវដ្ដលេខាធិការក្រសួងធម្មការ

សូមព្រះតេជៈគំរលំលើតួន

សូមព្រះកដឋានក្រាបបង្គំទូលសម្ដេចព្រះទេបយុកដ ព្រះប្រមុខរដ្ឋ

សូមទ្រង់ជ្រាបក្រោមលង្គ័នធូលីព្រះបាទ ។

ក្នុងនាមនៃក្រសួងធម្មការ ខ្ញុំព្រះបង្គំជាខ្ញុំសូមព្រះកដឋានព្រះបរម-
រាជវរោកាសថ្វាយទូលអំណរព្រះមហាករុណាទិគុណដ៏ក្រៃលែង ដោយ
កតញ្ញូតាធម៌ដ៏ស្មោះចំពោះសម្ដេចព្រះមាតាជាតិ និងសម្ដេចព្រះប្រមុខរដ្ឋ
ដែលទ្រង់សព្វព្រះកដហឫទ័យ ស្ដេចយាងមកជាព្រះកដាធិបតី ក្នុងឧកាស
បើកពិធីអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃលើកទី ១៩ សម្រាប់ឆ្នាំរាល
ចត្វាស័ក ព.ស. ២៥០៥ នេះ ។

សូមនមស្ការចំពោះសម្ដេច

ខ្ញុំព្រះករុណា សូមថ្វាយអំណរគុណចំពោះសម្ដេចព្រះសង្ឃនាយក
ទាំង ២ ព្រះអង្គដែលបានទិមន្តមកជាអធិបតី និងចំពោះព្រះថេរានុត្ថេរៈគ្រប់
ព្រះអង្គ ដែលបានទិមន្តមករួមប្រជុំក្នុងមហាសន្និបាតនេះ ។

សូមទូលទ្រង់

សូមដំរាបឯកឧត្ដម

ទូលព្រះបង្គំជាខ្ញុំ ខ្ញុំបាទ សូមសំដែងអំណរគុណទ្រង់ - ឯកឧត្ដម -

លោកស្រី - អស់លោក ដែលបានស្តេចយាង - អញ្ជើញមកកាន់ទីមហា-
សន្និបាតនេះ ជាកិត្តិយសដ៏ប្រសើរ ។

លំដាប់ពីនេះ ខ្ញុំព្រះបង្គំជាខ្ញុំ សូមព្រះពរជាន ព្រះបរមរាជានុញ្ញាត
ថ្លែងន្លះស្តាន់ការពារនៃព្រះពុទ្ធសាសនាដោយសង្ខេបដូចតទៅ៖

ព្រះពុទ្ធសាសនាទៅប្រទេសយើង តែងតែមានសេចក្តីរុងរឿងជា
ដរាបមក ដោយសារបានទទួលការទុបត្ថម្ភ ទំនុកការគាំពារដ៏ម៉ឺងម៉ាត់អំពី
ព្រះពរជាម្ចាស់ ព្រមទាំងប្រជាពលរដ្ឋទូទាំងព្រះពរជអាណាចក្រ ដោយផ្លូវ
អាទិសប្បជា គឺសម្ភារៈនឹងដោយផ្លូវបដិបត្តិប្បជា គឺសេចក្តីប្រព្រឹត្តិ ។

ការទុបត្ថម្ភដោយផ្លូវសម្ភារៈ គឺព្រះមហាក្សត្រគ្រប់ព្រះអង្គ ទាំងកន
អតីតកាលទាំងកន្លងបច្ចុប្បន្នកាល តែងតែគាំទ្រព្រះពុទ្ធសាសនាយ៉ាងមាំ
មួន ដោយទ្រង់បានកសាងនូវបុជនីយដ្ឋានទុកជាអនុស្សាវរីយ៍ ។ ភាពរណ៍
កន្លងសម័យអង្គរ ព្រះពរជាទាំងឡាយ មានព្រះបាទជ័យវរ្ម័នទី ៧ ជាដើម
ទ្រង់បានកសាងប្រាសាទបូជនីយដ្ឋានខាងពុទ្ធសាសនា ទំនើមទុំរពេទ្យជា
ដើមសម្រាប់ទុបត្ថម្ភប្រជាពលរដ្ឋខាងចរិយាទីសុខភាព ព្រមទាំងកសាង
វត្តអារាមនានា សម្រាប់ជាមូលដ្ឋាននៃវប្បធម៌របស់ជាតិ ទៅសម័យ
កណ្តាល ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមបរមរាជវរាតកន្លងព្រះ
សុវណ្ណគោដ្ឋ ទ្រង់បានកសាងព្រះវិហារព្រះកែវមុនីតិ សម័យបច្ចុប្បន្ន
សម្តេចព្រះទុបយុវរាជព្រះប្រមុខរដ្ឋ ទ្រង់បានទំនុកបំរុងវត្តចាស់ ។ ទាំង

ស្តាបនាវត្តថ្មី ។ ជាច្រើន មានវត្តនៅខេត្តព្រះសីហនុ ខេត្តតេនគីរី ខេត្តកោះកុង ទឹងពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ។ សម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ដីវិតលើតួង ទ្រង់ចាន់ផ្តើមដួសដុលព្រះវិហារព្រះកែវមរកតជាដើម ។

ជាពិសេស សម្តេចព្រះប្រមុខរដ្ឋជាអម្ចាស់ ទ្រង់ចាន់តាមតារតាមរយៈគុណការអន្តរជាតិ យកប្រាសាទព្រះវិហារជាពុទ្ធបូជនីយវត្ថុខ្មែរពិត ។ ដែលសៀមរំលោភយកទៅតាំងអំណាចនោះ ឲ្យចានមកជារបស់ខ្មែរវិញ ដែលយើងតាំងអស់គ្នាមានសម្តេចព្រះបិតាជាតិទ្រង់ជាព្រះរាជាធិបតី ទើបតែសម្តេចនៅថ្ងៃទី ៤ ខែ ៩ មករា ព.ស ២៥០៩ នេះ ចាត់ទុកជាការទប-តម្កព្រះពុទ្ធសាសនាដោយផ្លូវសម្ភារៈសំខាន់ចំផុត ។ ឯការទប្តម្កដោយផ្លូវប្រតិបត្តិនោះ គឺការកាន់សីល កាន់ធម៌យ៉ាន់ម៉ឺងម៉ាត់ដោយកាយ វាចា ចិត្ត តាមហានៈជាឧបាសក ឧបាសិកា ឬជាភិក្ខុ សាមណេរ ។ ការកាន់បែបនេះ ព្រះរាជបល្ល័ង្កទឹងប្រជាពលរដ្ឋ ចានប្រព្រឹត្តតៗ ជាហូរហែមក គឺព្រះមហាក្សត្រទ្រង់ព្រះផសង់ព្រះអង្គផង ទ្រង់ចំបួសព្រះរាជបុត្រផង ទ្រង់ចំបួសប្រជាពលរដ្ឋផង ។ ឯការទ្រង់ចំបួសព្រះរាជបុត្រនោះ ឧទាហរណ៍ក្នុងអតីតកាល: ចំណែកបុព្វបុរសដូចព្រះចុងជ័យវរ្ម័នទី ៧ ទ្រង់ចំបួសព្រះរាជបុត្រព្រះនាមតាមលិន្ទ ឲ្យស្តេចយាងទៅសិក្សាពុទ្ធសាសនាខាងលេរាទេ នៅប្រទេសស៊ីរីលង្កា ។ ព្រះថេរៈអង្គនេះហើយ ដែលនាំ

ព្រះពុទ្ធសាសនាខាងថេរៈវាទ លង្កាវង្សចូលមកផ្សាយក្នុងប្រទេសកម្ពុជាមុនដំបូងបង្អស់ ។ ចំណែកស្ត្រី ដូចព្រះនាងឥន្ទ្រទេវីអគ្គមហេសីព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់សិក្សាជ្រាបច្បាស់នូវបរមត្តវិជ្ជាខាងពុទ្ធសាសនា រហូតដល់ព្រះពជាទ្រង់តាំងព្រះនាងជាមហាសាស្ត្រាចារ្យ សម្រាប់ប្រដៅប្រជាពលរដ្ឋទ្វេខាងផ្លូវចរិយា ឲ្យមានសីលធម៌តាមពុទ្ធកាល ។ សម័យបច្ចុប្បន្ន សម្តេចព្រះប្រមុខរដ្ឋ កាលទ្រង់គង់នៅក្នុងឧកញ៉ាសម្បត្តិនៅឡើយ ទ្រង់លះភាជសម្បត្តិ ទ្រង់ព្រះផ្នួសភ្ជាល់ព្រះអង្គ ទ្រង់សិក្សាព្រះពុទ្ធសាសនា បានជ្រាបច្បាស់នូវមគ្គផលដ៏មាបដ៏បពា ហើយព្រះអង្គទ្រង់ដឹកនាំប្រជាពលរដ្ឋឲ្យបានសុខសន្តិភាពដោយត្រហ្វៃហារធម៌តាមសំអាងព្រះពុទ្ធសាសនា ។

តាមន័យនេះយើញថា ព្រះពុទ្ធសាសនាបានថ្កើងរុងរឿងដោយសារតែព្រះបរមរាជូបត្ថម្ភនៃព្រះមហាក្សត្រតៗរៀងរហូតមក ។

ធម្មតា រថប្រទេះដែលនឹងលឿនស្រួលទៅបាននោះ អាស្រ័យដោយកង់ទាំងគ្រឿងស្តាំលៃស្មើគ្នាយ៉ាងណា ប្រទេសដែលនឹងបានសុខសន្តិភាពរុងរឿងស្រួលបាននោះ ក៏អាស្រ័យដោយចក្រទាំង ៤ គឺអាណាចក្រនឹងពុទ្ធចក្រលៃទៅស្មើគ្នាយ៉ាងនោះដែរ ។

មួយទៀត ចំពោះគ្រែជាវចនាដែលជាគោលនៃការគ្រប់គ្រងប្រទេសកម្ពុជាមាន ៣ យ៉ាងគឺ ជាតិ សាសនា ព្រះរាជបល្ល័ង្កនោះ ជាតិខ្មែរជាកង់ខាងអាណាចក្រ សាសនាខ្មែរជាកង់ខាងពុទ្ធចក្រ ព្រះរាជបល្ល័ង្កខ្មែរជា

នាយសារថីអ្នកញ៉ាំងកង់ទាំងពីរឲ្យវិលស្មើគ្នា ដើម្បីប្រទេសកម្ពុជា
ជានសន្តិភាពជារាបមក ។

ប្រទេសកម្ពុជា ជាប្រទេសធ្លាប់ញ៉ាំងកង់ឲ្យវិលទៅស្មើគ្នាមកហើយ
គឺទាង់ព្រះរាជបុត្រក្នុងបានរក្សាទុកនូវក្បួនច្បាប់ទាង់អាណាចក្រ សម្រាប់
បង្ហាប់ការវែនដ៏ ទើបទ្រង់ទំនុកបំរុងវត្តអារាមឲ្យរក្សាទុកនូវតម្ពីរដីការក្បួន
ច្បាប់ ទាង់ពុទ្ធចក្រសម្រាប់អប់រំប្រជាពលរដ្ឋឲ្យមានកាយ វាចា ចិត្ត សុច-
រិតត្រឹមត្រូវ ។ ឯតម្ពីរដីកាទាង់ពុទ្ធចក្រនោះ ព្រះសង្ឃបានដំកល់ទុកក្នុង
វត្តជាប្រពៃណីជារៀងរាបដរាបមក ។

សូមទ្រង់ព្រះមេត្តាប្រោស

តាំងពីសម័យដែលព្រះរាជរដ្ឋាភិបាល បានបង្កើតសាលាបាលីជាន់
ខ្ពស់ ព្រះរាជបណ្ណាល័យទង់ពុទ្ធសាសនបណ្ឌិត្យឡើង បានប្រមូលតម្ពីរ
ដីកាអំពីវត្តនានា ក្នុងព្រះរាជអាណាចក្រមកពិនិត្យចុះពុម្ពផ្សាយសម្រាប់
ឲ្យវត្តទាំងនោះជាវយកទៅរៀនសូត្រតាមតម្ពីរដីកាដើមនោះវិញ ។ តាំង
ពីពេលនោះមក វត្តនានាក្នុងព្រះរាជអាណាចក្រ ក៏បានជាវយកទៅរៀន
សូត្រតាមស្ទ្រេត បានទាំងបង្កើតបណ្ណាល័យខ្លះមកហើយ ។

អាស្រ័យហេតុនេះ ក្រសួងធម្មការមានប្រាថ្នាទង់បង្កើតឲ្យមាន
បណ្ណាល័យគ្រប់វត្តក្នុងព្រះរាជអាណាចក្រ ជាទង់ដំកល់សាស្ត្រាស្នាត់ត
ស្រាង់បុរាណ ហើយគួរមានសៀវភៅចុះពុម្ពធម៌អាចក្បួនច្បាប់ទាង់ផ្នែ

លោក ផ្លូវធម៌ មានទស្សនាវដ្តី ការសែតនានា មានការសែតអ្នកជាតិនិយមជាដើម សម្រាប់តែក្តី សាមណេរ ទីដ៏ៗ ជាសក្តអានមើលអប់រំកាយ វាចា ចិត្ត ។

បើដូច្នេះដូរនេះ ក្បួនច្បាប់ គតិលោក គតិធម៌ទីដ៏មានសម្បូណ៌ឡើង អ្នកអានអ្នកមើលទីដ៏មានច្រើនឡើង ហើយប្រជាពលរដ្ឋក៏ទីដ៏នាំគ្នាអប់រំផ្លូវកាយ វាចា ចិត្ត ឲ្យមានសីលធម៌តែខ្ពង់ខ្ពស់ឡើង នាំឲ្យប្រទេសមានវឌ្ឍនភាពខាងផ្លូវលោក ផ្លូវធម៌ល្អឡើង ទៅជាការប្រទេសកដ៏ពិភពលោក ។

ទីបញ្ចប់ កដ៏នាមនៃក្រសួងធម្មការ ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមបួងសួងចំពោះគុណព្រះរតនត្រៃ ទីដ៏ទៅតាំងមួយម៉ឺនលោកធាតុ សូមជួយអភិបាលថែរក្សាព្រះពុទ្ធចលុង្គ សម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ដីតែលើតួង ទីដ៏សម្តេចព្រះប្រមុខរដ្ឋ ដែលជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ សូមព្រះអង្គបានប្រកបដោយព្រះសុខភាព មានព្រះជន្មវែងយឺនយូរ ដើម្បីជាម្លប់ត្រជាក់នៃប្រជាពលរដ្ឋតរៀងទៅ ។

សូមសម្តេចព្រះសង្ឃនាយកតាំង ២ ព្រះអង្គ ព្រមតាំងព្រះសង្ឃគ្រប់រូប ដែលបាននិមន្តមកជាប្រធាន-មកប្រជុំក្នុងមហាសន្និបាតនេះ ព្រមតាំងព្រះសង្ឃទូទៅក្នុងព្រះពុទ្ធអាណាចក្រ បានសុខចំរើនគ្រប់ប្រការ ដើម្បីថែរក្សាព្រះពុទ្ធសាសនាឲ្យបានថ្កុំថ្កើងរុងរឿងរហូត ៥០០០ ព្រះវស្សា ទីដ៏

សូមឱ្យអនុសាវនីយកម្មមហាសន្និបាតលើ ១៩ នៃមន្ត្រីសង្ឃនេះ នឹងអនុសាវនីយកម្ម
លាស់ជាប់តទៅ ប្រកបដោយជោគជ័យសិរីសួស្តីកុំបីអាក់ខានឡើយ ។

សូមព្រហ្មវិហារធម៌របស់សម្តេចព្រះមហាកត្រីយានី សម្តេចព្រះ
ប្រមុខរដ្ឋ នឹងព្រះសង្ឃមានសម្តេចព្រះសង្ឃនាយកគាំង ២ ព្រះអង្គជាប្រ-
ធាន ជួយស្រោចស្រង់ប្រទាក់ព្រំប្រជាពលរដ្ឋគ្រប់ប្រភេទពួគាំងប្រទេស
ឱ្យជួបប្រទះតែនឹងសេចក្តីសុខសេចក្តីចំរើនជានិរន្តរ៍តទៅ ! ។

X X X

សុទ្ធរកថា

ថ្លែងដោយព្រះតេជព្រះគុណព្រះសាសនសំរែ គាង - ឈូ

មេគណវែងត្រកណ្តាល

សូមថ្វាយព្រះពរ សម្តេចព្រះទេបយុវរាជ ព្រះប្រមុខរដ្ឋ

សូមទ្រង់ជ្រាប ។

អាត្មាភាព កងនាមនៃមន្ត្រីសង្ឃក្នុងព្រះពុទ្ធសាសនិកភូមិភាគវែងត្រ
ក្រៅ ស្រុក ក្នុងព្រះពុទ្ធអាណាចក្រ សូមថ្វាយព្រះពរថ្លែងនូវអំណរព្រះ
គុណាទិគុណដ៏ខ្ពង់ខ្ពស់បំផុតនៃសម្តេចគាំង ២ ព្រះអង្គ ជាព្រះមាតាជាតិ
ជាព្រះបិតាឯករាជ្យជាតិ ដែលទ្រង់ព្រះមេត្តាប្រោសបានស្តេចយាងមក
ជាព្រះពុទ្ធជាធិបតីរៀងរាល់ឆ្នាំ ក្នុងពិធីអនុសាវនីយកម្មមហាសន្និបាតនៃមន្ត្រីសង្ឃ
ឱ្យព្រះគ្រូសង្ឃមានសោមនស្សរីករាយ ។ ក្នុងវេលានេះ ព្រះគ្រូសង្ឃ

តិសុទ្ធសឹងតែមានសោមនស្សសោទរចំពោះព្រះមហាករុណាទិគុណ ដ៏ខ្ពង់ខ្ពស់ រកកល់លើសជាងពីកន្លងមុនៗនេះទៅទៀត ព្រោះមានការណ៍ពិសេសអស្ចារ្យមួយដ៏ប្លែក គឺបានទទួលជ័យដំនះបានប្រកាសាទព្រះវិហារជាកេតនតណ្ហារបស់ខ្មែរដែលឃ្លាតមួយពេលវែងនោះ វិលត្រឡប់មកជារបស់ប្រទេសកម្ពុជាវិញ ហើយបានធ្វើព្រះរាជពិធីសម្ពោធជាថ្មីឡើងវិញ កន្លងពេលថ្មីៗនេះ ។

សូមថ្វាយព្រះពរ

អាត្មាភាពសូមព្រះរាជទានព្រះរាជវិភាសដើម្បីថ្លែងសេចក្តីដោយសង្ខេបថ្វាយ អំពីអំណាននៃសេចក្តីសង្ឃឹមតក់ក្តៅ ចំពោះក័ព្វវាសនានៃព្រះពុទ្ធសាសនាក្នុងព្រះរាជាណាចក្រកម្ពុជា ដែលក្នុងសម័យនេះកំពុងតែបញ្ចេញពន្លឺរស្មីដ៏ភ្លឺត្រចះ ហើយគង់នឹងចេះតែភ្លឺរុងរឿងជាងនេះទៅទៀតនាអនាគតកាល ដោយសារព្រះរាជមធ្យោបាយដ៏ក្លឹងក្លាខ្លាំងនៃសម្តេចព្រះមាតាជាតិ នឹងសម្តេចព្រះបិតាឯករាជ្យជាតិ ដែលអាត្មាភាពក្នុងនាមនៃព្រះភិក្ខុសង្ឃទាំងអស់ ពុំអាចនឹងពណ៌នាបាន ព្រោះមានអត្ថន័យដ៏សុខុមគម្ភីរភាពជាអតិបរមា ។

សូមថ្វាយព្រះពរ

ពុទ្ធបរិស័ទ ទាំងបព្វជិត-គ្រហស្ថ ស្មើរតែទាំងអស់គ្នាមានការយល់ឃើញថា ប្រទេសឯទៀតៗ ខ្លះដូចជាប្រទេសថៃជាដើម ក៏សុទ្ធមានព្រះ

ពុទ្ធសាសនា មានបព្វជិតពុទ្ធសាសនិក មានឧបាសកឧបាសិកា ដូចជាប្រ-
ទេសកម្ពុជាយើងដែរ ចុះហេតុអ្វីក៏មានបរិយាន្តឆ័ស្លដូមិផ្ទុយគ្នាអំពីខ្មែរ
ឆ្ងាយម្ល៉ះ ? ប្រទេសខ្មែរ ក្នុងសម័យនេះសម្បូណ៌ដោយសាមគ្គីភាព និង
សន្តិសុខ ត្រជាក់ត្រជុំប្លែកច្រើនណាស់ ប្រជាពលរដ្ឋទូទៅមានការ
សប្បាយរីករាយដោយសន្តិសុខ សន្តិភាពគ្រប់គ្រាន់ ខុសគ្នាអំពីប្រជា-
ជនខ្មែរក្នុងប្រទេសដទៃឯង ឆ្ងាយពីគ្នាដូចមេឃនឹងដី ។ បព្វជិតគ្រហស្ថ
ខ្មែរ ទោះបីអ្នកស្រុកនៅខ្មែរក៏អាចស្តាប់ឮ យល់ច្បាស់បានថា មកពីមានប្រមុខ
របស់ប្រទេសដឹកនាំប្រជាជនឱ្យដើរតាមផ្លូវខុសគ្នា ទោះបីមានព្រះពុទ្ធ-
សាសនាដូចគ្នាក៏គ្រាន់តែមានៗប៉ុណ្ណោះ ប៉ុន្តែយកព្រះពុទ្ធសាសនាទៅ
ជាក់ពីក្រោយខ្នង គឺប្រមុខរបស់ប្រទេស នាំឱ្យប្រជាពលរដ្ឋប្រព្រឹត្តទាស
ចេញពីផ្លូវសន្តិសុខនឹងសន្តិភាពទៅវិញ ។

សូមថ្វាយព្រះពរ

ឯប្រទេសកម្ពុជា ក៏បានជាកន្លងសម័យដែលប្រទេសដឹកនាំកំពុងមាន
ការច្របូកច្របល់នេះ ខ្មែរចេះតែមានសេចក្តីសុខសប្បាយ មកពីមានប្រមុខរដ្ឋ
គឺអង្គសម្តេចព្រះប្រមុខរដ្ឋខ្មែរ ព្រះអង្គកៀងប្រមូលខ្មែរ ដឹកមុខខ្មែរ ឱ្យ
ដើរតាមផ្លូវត្រូវ ផ្លូវត្រូវនេះ គឺជាព្រះពុទ្ធសាសនា ។ បានសេចក្តីថា
ខ្មែរកន្លងសម័យនេះ ច្រើនជាគាន់តាមលំអានព្រះពុទ្ធសាសនាមែនៗ ក៏
បានសេចក្តីសុខសប្បាយមែនៗ ដោយមកពីមានព្រះប្រមុខរដ្ឋ ស្ទួចយោង

យ៉ាត្រាន់តាំមុខឲ្យប្រជាពលរដ្ឋដើរតាមផ្លូវត្រូវ ។ ដោយហេតុនេះ បាន
ជាពុទ្ធបរិស័ទខ្ជិលច្រអូសតិចតួចណាស់មែន ឬថ្វាសិនប្រែចរិយាឲ្យខុសផ្ទុយគ្នា
អំពីមាគ៌ានៃយោបាយសន្តិវិធីនៃសម្តេចព្រះបិតាឯកពុទ្ធជាតិឡើយ ។

សូមថ្វាយព្រះពរ

សព្វថ្ងៃនេះ មន្ត្រីសង្ឃកំពុងខំប្រឹងរកមធ្យោបាយនឹងរំលាករំលាយ
អធិករណ៍នៃបញ្ហាជាតិ ដែលមានសេសសល់ខ្លះបន្តិចបន្តួចនោះឲ្យបានសូន្យ
រម្ងាប់ កុំឲ្យមានទៅសល់តទៅទៀត ប៉ុន្តែសូមទ្រង់ព្រះមេត្តាប្រោស
សូមឲ្យព្រះពុទ្ធជាតិបាលជួយណែនាំខ្លះផង ចំពោះហេតុការណ៍ណាមួយ
ដែលព្រះពុទ្ធជាតិបាលអាចនឹងកាត់រកឃើញ ។ ចំណែកពុទ្ធបក្ខ ក៏នឹង
ចេះតែខំប្រឹងរំលែករកមធ្យោបាយប្រតិបត្តិការ តាមផ្លូវស្របជាមួយគ្នា
មិនហ៊ានឲ្យប្រទាំងនឹងនយោបាយរបស់ប្រទេសឡើយ គ្រាន់តែសូមឲ្យ
ព្រះវិន័យពុទ្ធសាសនាបិតនៅជាស្ថាពរតរៀងទៅប៉ុណ្ណោះ ។

ទៅចំណុចនេះ សង្ឃសន្និបាតសូមបង្ហាញមនោសញ្ចេតនាដោយគារវ
ភាពថ្វាយព្រះពរសាធុការចំពោះសម្តេចទាំងពីរព្រះអង្គ សូមព្រះអង្គមាន
ជោគជ័យសិរីសុភមង្គលវិបុលសុខ ឈ្នះអស់មារសត្រូវគ្រប់ទិសទីជានិច្ច
និរន្តរ៍ ! សូមព្រះអង្គមានព្រះជន្មវស្សាយឺនយូរក្រៃលែងជាងរយព្រះវស្សា

សូមថ្វាយព្រះពរ

សេចក្តីត្រូវពុំត្រូវ សូមព្រះពុទ្ធទានអភ័យទោស

X X X

ព្រឹត្តិសាស្ត្រ

ទស្សនាវដ្តី ផ្សាយចំណាំងខាងសាសនា និងអក្សរសាស្ត្រ




ឆ្នាំទី ៣៥ លេខ ២ ខែ កុម្ភៈ

ព.ស. ២៥០៥ គ.ស. ១៩៦៣

- ក្នុង ១៣ -



ព្រះបរមរាជវាំងវត្តឧណ្ណាលោម ដើលពីទិសខាងកើត



ភ្នំពេញសន្ទេស

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

បេញ្ញវាល់ខែពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
	ព្រះបន្លង្គមកែវ (វិថារណកថា)	១២៦
	ពុទ្ធធម៌ ភិក្ខុបន្ទូ-សុធាវិទ និស្សិតក្នុងទ្វិកមហាវិទ្យាល័យព្រះសីហនុរាជ រៀបរៀង	១៣១
	ព្រះអភិធម្មបិដក (គម្ពីរព្រះមហាបដ្ឋាន) លោក ប៊ូ-ប៊ី ប្រែរៀបរៀង (ត)	១៥៣
	ធុរសភាហិណី សម្តេចព្រះធម្មលិខិត ស្រ៊ី-ឯម ឧត្តមប្រាំល្អប្រែរៀបរៀង (ត)	១៥៩
	លោកវេថាគត (ត)	១៦៤
ផ្នែកអក្សរសាស្ត្រ		
	សេចក្តីសង្គ្រោះ (វិថារណកថា) លោក ផេង-ទ្រីវ តែងរៀបរៀង	១៧៦
	ពាក្យខ្មែរប្រែពីបរទេស ដោយគណៈកម្មការជាតិនៃការសិក្សាផ្នែកអក្សរ «ក» (ត)	១៨៥
	ឧទានុក្រម សំស្ក្រឹត-ខ្មែរ ព្រះគេតជ្រះគុណ ប៉ាង-ខាត់ រៀបរៀង (ត)	១៨៩
	ល្បឹកល្បាហ្វុងតែន លោកផេង-ទ្រីវ ប្រែពីភាសាចាវ៉ាំង (ត)	១៩១
	រឿងសាមកុក លោកនាយ គូ-កន ប្រែរៀបរៀង (ត)	១៩៧
	រឿងទ្រាងចិន លោក វ៉ាយ ប៊ុក ប្រែពីភាសាចាវ៉ាំង (ត)	២០៣
	រឿងប្រយោជន៍រួមជាតិ (ទំនៀមទម្លាប់) លោក ផ្លិន-សាំងហាយ តែងរៀបរៀង	២០៧
	រឿងព្រេងវិហារ	២១២
ផ្នែកកំណត់ទិដ្ឋប្រវត្តិការណ៍		
	ធម្មបុណ្យរំលឹកព្រះគុណសម្តេចព្រះសុគន្ធាសង្ឃរាជាធិបតីព្រះនាម ប៉ាន	២១៩
	ធម្មទេសនាសៀវភៅ ១៦ ក្បាលពីសាធារណរដ្ឋខ្មែរទៅកាន់ភ្ញៀង នៅពុទ្ធសាសនបណ្ឌិត្យ	២២៤

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃដាវ ២៣០រ៉ូ០

ពាក្យឃាត់មិនឲ្យ	ធ្វើការអាក្រក់
ជាការណែនាំ	ឲ្យធ្វើល្អៗ
ឲ្យផ្ចិតផ្ចង់ចិត្ត	កុំឲ្យហ្មងសៅ
បីវេះលោកហ្នើ	ពុទ្ធសាសនា

វិចារណកថា ព្រះចន្ទ្រមែកវ

លោក ឌឹក - តាម រៀបរៀង

ហេតុដែលនាំឲ្យខ្ញុំយករឿងព្រះចន្ទ្រមែកមកធ្វើជាវិចារណកថា ដោយខ្ញុំចង់ឲ្យដឹងជាក់ថា តើព្រះចន្ទ្រមែកវិវរបស់ព្រះសម្មាសម្ពុទ្ធ មានប៉ុន្មាន? នៅកន្លែងណាខ្លះ?

តាមរឿងព្រះចន្ទ្រមែកវិវរបស់លោកអាចារ្យ ចាប - តិន សុវណ្ណដោតោ ចោះត្បូតផ្សាយពីព្រះពុទ្ធបណ្ណាល័យ ព.ស. ២៤៧៦ ថាលោកបានមើលអានគម្ពីរជាច្រើន ដូចយ៉ាងគម្ពីរឈ្មោះ តាហាវគ្គ សង្គីតិយវគ្គ . . . ដោយបង្ហើញសង្ខេបទៅលោកនិយាយថា ព្រះចន្ទ្រមែកវិវរបស់ព្រះសម្មាសម្ពុទ្ធមានតែ ៤ ព្រះអង្គ ។ ដល់ព្រះបរមគ្រូទ្រង់ចូលកាន់ព្រះនិព្វានទៅ ពុទ្ធបរិស័ទបានបួជាសពព្រះសម្មាសម្ពុទ្ធ ដោយមានអាចារ្យភ្នក់ គោណជាមេកយចំណែកចែកព្រះធាតុ ។ ខ្ញុំមិនបានបរិយាយឲ្យពិស្តារទេ ព្រោះខ្ញុំចង់បញ្ជាក់តែរឿងព្រះចន្ទ្រមែកវិវរ ។ លោកអាចារ្យ គោណ បាន

ចែកជូចេះ :

១- ព្រះចង្កឹមតែវមួយ ទ្រះឥន្ទ្រយកទៅត្រែត្រឹងព្រាសូតិ

២- ជាន់ទៅស្ថេចនាគ

៣- ជាន់ទៅប្រទេសគន្ធារ

៤- ជាន់ទៅរដ្ឋកលិង្គ

ចំណែកព្រះទាឋាដែលជាន់ទៅរដ្ឋកលិង្គនោះ មានរឿងវែងច្រើនរហូតដល់ព្រះពុទ្ធសករាជ ៨៤០ ព្រះទាឋាអង្គនេះ មានស្តេចពីរព្រះអង្គនាំទៅដល់កោះលង្កា ក្រុងអនុរាធតាមទំនៀមទម្លាប់របស់ព្រះពិតា ។ លុះចំណេរក្រោយមក ពុទ្ធសករាជ ២១៣៥ ព្រះបរមទាឋាជាន់ទៅប្រតិស្ថានទៅក្រុងកន្ឌី (Kandy) វិញ ។

ហេតុដែលនាឲ្យយកមកតំណាលដូចេះ ព្រោះទៅថ្ងៃទី ១០ មិថុនា ឆ្នាំ ១៩៦១ ថា នាយករដ្ឋមន្ត្រីប្រទេសស្រីលង្កា លោកស្រី ប៊ណ្ឌារណៃកេ ជាន់ទទួលព្រះចង្កឹមតែវមកពីប្រទេសចិន ។ ព្រះសង្ឃដែលហែហមព្រះចង្កឹមតែវនោះមកស្រីលង្កាមានព្រះតេជព្រះគុណ ស្រីរកេជលសោ (Shirop-Jhaltso) ព្រះជន្ម ៧៨ វស្សា ជាប្រធានពុទ្ធសាសនមទៅប្រទេសចិន ។ គេជាមានទម្ងន់ ៣៥០ ផោង (រង្វាស់ផ្សារលាអង់គ្លេស) ។ គេឆ្ងល់ថា ព្រះចង្កឹមតែវមានតែ ៤ ព្រះអង្គទេ ដូចជាន់អធិប្បាយមកខាងលើ ចុះមើចជាន់ជាមានព្រះចង្កឹមតែវមួយទៀតទៅប្រទេសចិន ?

តាមទស្សនាវដ្តី ពុទ្ធសាសនាសាកលលោក WORLD BUDDHISM ផ្សាយចេញពីប្រទេសស្រីលង្កាលេខ ១១ ខែមិថុនា ១៩៦១ ថា៖

« លោកបណ្ឌិត សុំស្នើទៅរដ្ឋាភិបាលស្រីលង្កា ឲ្យរៀបចំកន្លែងណាមួយដ៏គួរដើម្បីទទួលព្រះទាឋាធាតុដែលគេថាយកមកពីស្រុកចិននោះ ដុតឲ្យពុទ្ធបរិស័ទនមស្ការបូជា » ។

លោក អាណូល រតនយកេ ថា៖ « ត្រូវតែរៀបចំដំកើងព្រះចង្កឹមកែវ ទោះមកពីប្រទេសចិនក្តី រុស្ស៊ីក្តី ប៉ូឡូញក្តី . . . . » ។

រឿងនេះហើយដែលជាហេតុនាំឲ្យមានសេចក្តីឆ្ងល់អំពីព្រះចង្កឹមកែវ ដែលយកមកពីប្រទេសចិនទៅគោះស្រីលង្កានៅឆ្នាំ ១៩៦១ នេះ ។

តម្លៃខាងព្រះពុទ្ធសាសនា មិនដែលមានសំដែងអំពីព្រះទាឋាដែលទៅប្រទេសចិននោះ ។ តែថាកាលដែលប្រទេសចិនចង់បានព្រះចង្កឹមកែវ ទៅគោះស្រីលង្កាអំពីស្តេចព្រះនាម មហានាម ស្តេចនេះកំពុងជារួបសំណាកដួចព្រះចង្កឹមកែវពិត ។ ដែលប្រតិស្ឋានទៅក្រុងកន្តូនៀទៅប្រទេសចិន ។

ខ្លះថា មានស្តេចប្រទេសចិនព្រះនាម សុំនកោ (Chinko) រកមធ្យោបាយដើម្បីលួចយកព្រះចង្កឹមកែវពីប្រទេសស្រីលង្កា ក្នុងកាលដែលស្តេចព្រះនាម កុវនតតាហ្ស ទោយយកជ្យទៅគោះស្រីលង្កា ។ លោករតនយកេ ពោលថា ជនជាតិចិនបានយកធ្មេញចិនម្នាក់ ដែលជាពុទ្ធសាសនិកខាង

មហាយាន មិនមែនគួរព្រះចង្កឹមតែវរបស់ព្រះពុទ្ធទេ» ។

លោក ប.ន គួរពោលថា៖ «ការដែលអនុញ្ញាតឲ្យយកមាហារតុមកតាំងដូច្នេះ ដើម្បីសំដែងឲ្យឃើញឯកភាពក្នុងនៃពុទ្ធសាសនិក» ហើយគាត់ថាន្ថែមតទៀតមានថា៖ «ការលុកលុយប្រទេសនីមួយៗក្នុង» ហើយគាត់ថាន្ថែមថា «ចំនោរពតែព្រះពុទ្ធសាសនាទេ ដូច្នេះម្តេចក៏ថាចំនួកមធ្យោបាយដើម្បីធ្វើប្រទេសនីមួយឲ្យសាបសូន្យ ព្រះពុទ្ធសាសនាទៅវិញ» ។

លោក ជ្រិ ណាសូយោថា៖ «ចំនួន ៩០០ លាននាក់ ថាន្ថែមប្តូរគោរពព្រះមាហាតុ ដូច្នេះចំនួនមិនមែនគួរថានឹងក្លែងបន្ថែព្រះចង្កឹមតែវទេ» ។

លោក ជ្រិ ត្រាម រ៉ូឌ្រីកូថា៖ «គ្មានតម្លៃរណាមួយនិយាយអំពីព្រះចង្កឹមតែវទៅប្រទេសចិនទេ» ។

ក្រោយពីថ្ងៃទៅ លោកបណ្ឌិត គោឌុកម្ភុរ ខាងបុពណាវត្តថាន្ថែមរកឃើញអក្សរចារឹកទៅស្តម្ភមហិន្ទទៅក្រុងតិរ៉ូ ខាងត្បូងប្រទេសស្រីលង្កាថា ស្តេចកវន្តិស្ស ថាន្ថែកបំពុកព្រះចង្កឹមតែវខាងក្រោមខាងធ្វេង ទៅតិស្សមហារាមក្រោមព្រះមហាស្តូប ។ ទៅអក្សរចារឹកនោះថា ការបញ្ចុះព្រះចង្កឹមតែវទៅមហាស្តូប ទៅតិស្សមហារាម ទៅសតវត្សទី ៤ ពេលដែលព្រះចង្កឹមតែវលឿញ្ជាញទៅក្នុងប្រទេសស្រីលង្កា ដែលសព្វថ្ងៃទៅក្រុងតន្ទី» ។

លោកបណ្ឌិត គោឌុកម្ភុរ ថា៖ «តាមមហាបរិនិព្វានសូត្រថា ពាល

ព្រះពុទ្ធទ្រង់បរិនិព្វាន ហើយទង់ដីកាវែកព្រះថាហ៊ា មានតែប្រទេសបួនទេ ដែលបានទទួលព្រះចង្កឹមកែវគឺ សក្កៈ ១, កតនាគ ១, កលិង្គ ១ និងគន្ធារៈ ១ The four were taken respectively to the world of Sakra, the Naga world, Kalinga and Gandhara. ។ ត្រង់នេះយើញថាតិតដូចជាលោកអាចារ្យ ចាប-ពិន និយាយក្នុងរឿងព្រះចង្កឹមកែវមែន» ។

តាមគាថាដែលបានតែងឡើងនៅកន្លែងសតវត្សទី ១ នៃព្រះពុទ្ធសកាជ ថា ប្រទេសដែលបានទទួលព្រះចង្កឹមកែវនោះ មិនមែនប្រទេសគន្ធារៈទេ គឺសីហលទ្វីប (ស្រីលង្កា) ។

តស្តុតាងមួយទៀត តាមប្រវត្តិសាស្ត្រប្រទេសស្រីលង្កាបានបង្ហាញការដែលប្រទេសស្រីលង្កាធ្លាក់ចុះនៅក្រោមអាណាព្យាបាលរបស់ពួកអារ្យន ដែលមកតិទិសនិតែនៃប្រទេសឥណ្ឌា ដូចយ៉ាងរដ្ឋគន្ធារជាដើម ពួកអារ្យនបានមកតាំងទីនៅជិបន់មតម សិទ្ធលប៊ូនឹងកតគ្រាមខាងត្បូងប្រទេសស្រីលង្កា ។ គេបានរកឃើញសិលាចារឹកមួយនៅវត្តសិទ្ធលប៊ូវថា: «យើងដឹងតាមកាលនុប្បវត្តិថា ព្រះចង្កឹមកែវនៅអនុរាធបុរី គឺគេយកមកតាំងក្នុងលិង្គប្រទេសឥណ្ឌា យកមកប្រតិស្ឋានៅអនុរាធបុរីក្នុងរាជ្យស្តេចព្រះនាមកិត្តីរែមវ៉ន (មុខ ត ស. ៣០១-៣២៨)[1] ។ រឿងព្រះចង្កឹមកែវនេះគេដឹងច្បាស់ណាស់នៅប្រទេសស្រីលង្កា ។

១- ត្រង់ គ. ស. នេះបើតាមលោកអាចារ្យ ចាប-ពិន និយាយថា គ. ស. ៨៤០ ព្រះចង្កឹមកែវចេញពី ផ្ទៃលិង្គមកប្រតិស្ឋានៅអនុរាធបុរី ។ បើយកសៀវភៅរៀបរាប់សាកាដមកពិនិត្យទៅឃើញថា ព. ស. ៨៤០ ត្រូវដាច់ គ. ស. ២៩៦ ។ តែតាមកាលនុប្បវត្តិស្រីលង្កាថាមុន គ. ស. ៣០១-៣២៨ ហាក់ដូចជាមិនពិត ដូច្នេះខ្ញុំសូមលោកអ្នកអានវិនិច្ឆ័យដឹងចុះ ។

ភិក្ខុ ចន្ទ-សុជាវិន
និស្សិតពុទ្ធិកមហាវិទ្យាល័យព្រះសីហនុពាជ រៀបរៀង

ឧទ្ទេស ៣ ដង

សូមនមស្ការ ចំពោះព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ (ព្រមទាំងព្រះធម៌ទំនឹងព្រះអរិយសង្ឃដោយសេចក្តីគោរព) ។

វេលានេះ សូមលើកយកតបធម៌អំពីមង្គលដ្ឋទីបនីមកពណ៌នា ដើម្បីជាគ្រឿងតាំងចារណានៃពុទ្ធបរិស័ទទាំងឡាយដូចតទៅ៖

ពាក្យថា តប: ជាឈ្មោះនៃសេចក្តីប្រតិបត្តិក្នុងសាសនាទាំងឡាយ ទៅក្នុងលោកនេះ ប្រែថា (សភាវ) "ដុតបំផ្លាញចោលនូវបាបធម៌ទាំងពួង" ឬប្រែថា (សភាវ) ជាគ្រឿងដុតបំផ្លាញចោលនូវបាបធម៌ទាំងពួង (នៃយោគី) មានបទវិគ្រោះថា ទាបកេ ឆម្មេ តបតីតិ= តបោ, ឬ ទាបកេ ឆម្មេ តាបេតីតិ= តបោ ឬថា ទាបកេ ឆម្មេ តបតិ ឯតេនាតិ= តបោ ។

ពាក្យថា "ទាបឆមិ" ប្រែថា "ធម៌អាក្រក់ ឬ អំពើអាក្រក់ អំពើលាមក" បានដល់អំពើកាប់សម្លាប់ លួចប្លន់ ឆបោកប្រវ័ញ្ចន៍មនុស្ស សត្វជាដើមឲ្យវិនាសដ្ឋិតិ ខូចឲ្យសម្បត្តិជាដើម ដោយអំណាចលោភៈ ទោសៈ មោហៈដែលជាមូលនៃអកុសល ។

សេចក្តីប្រតិបត្តិដែលអ្នកប្រាជ្ញតាំងខ្លួនក្នុងប្រព្រឹត្តដើម្បីកំចាត់បង់នូវកិលេស អំពើអាក្រក់ទុច្ចរិតតាំងអស់នោះ ហៅថា តបៈ គឺជាបរិយាយវត្តប្រវត្តបទនៃយោគីតាំងខ្លួន អ្នកឃើញទោសក្នុងកាមទាំងទោសនៃការបៀតបៀន របស់ធម្មតាលោកនេះ ។

ពុទ្ធសាសនាក្តី ពាហិរសាសនាគឺសាសនាខាងក្រៅក្តី រមែងមានតបធម៌សំរាប់សាសនិកជនប្រតិបត្តិរៀងៗខ្លួន ប៉ុន្តែពុំស្មើគ្នាតែងប្លែកគ្នាទៅតាមទ្រឹស្តីនៃសាស្តាចារ្យនីមួយ ៗ។

ព្រះពុទ្ធសាសនា ជាសាសនាសំដែងអាងកម្មនិងផលរបស់កម្ម គឺថា បើបុគ្គលធ្វើអំពើអាក្រក់ មានលួចប្លន់ កូតកុហកជាដើម ទើបបានទទួលផលអាក្រក់ ទុក្ខទោសសៅហ្មង បុគ្គលធ្វើកម្មល្អ មានការរក្សាសីលចំរើនមេត្តាភាវនាជាដើម រមែងបានទទួលផលល្អ គឺសេចក្តីសុខស្អាតបរិសុទ្ធ កាលដែលទទួលផលរបស់អំពើនោះ ចេះល្អក្តី អាក្រក់ក្តី ត្រូវទទួលខ្លួនឯង អ្នកដទៃពុំអាចទទួលល្អ ឬអាក្រក់ជំនួសខ្លួនបានឡើយ ប៉ុណ្ណោះជាដើម តំណាងតបធម៌បរិបូណ៌ សំរាប់តុទ្ធបរិស័ទប្រតិបត្តិអប់រំខ្លួនឲ្យបានបរិសុទ្ធស្អាតចាកអំពើអកុសលទុច្ចរិតផ្សេង ។ តាំងនោះ តែងបើសំដែងដោយសង្ខេបមាន ៦ ប្រការគឺ:

១- ខន្តិ សេចក្តីអត់ធន់

២- សីល ការរក្សាកាយវាចាទុកឲ្យល្អ

๓ – ទោសៈ ឥកម្មៈ: ការរក្សាខ្លួនពីទោសថស័ល

๔– ឆុតន្តៈ: ការរក្សាខ្លួនពីឆុតឆ្គ

๕– ឥន្ទ្រិយសំវរៈ: ការសង្រួមខ្លួនឥន្ទ្រិយ

๖– វីរិយៈ: សេចក្តីព្យាយាម ។

សូមអធិប្បាយពន្រ្លឹកសេចក្តីនៃមាគ៌ាធម៌ខាងលើនេះមួយម្តងៗ ជាលំដាប់គ្នាដូចតទៅ៖

๑– ទិដ្ឋិ សេចក្តីអត់ធន់ ចាននដល់ការអត់ធ្មត់ទន់ងក្តៅ ត្រជាក់ សេចក្តីស្រេកឃ្លាន ឬពាក្យអក្រក់របស់ជនដទៃ ឬថា ការស៊ូទ្រាំការងារដែលជា ករណីយកិច្ចពុះពារខ្លួនឲ្យបានសម្រេចផ្សេងៗ មិនខ្ជិលច្រអូសមិនចុះចាញ់ទុក្ខសន្តាបនោះ ។ ដ្បិតថា កិច្ចការទាំងពួងនៅក្នុងលោក ដូចជាការធ្វើពាណិជ្ជកម្ម កសិកម្មក្តី ការសិក្សារៀនសូត្រខ្លួវិជ្ជា មានអក្សរសាស្ត្រទ្រឹតសាស្ត្រជាដើមក្តី ការប្រព្រឹត្តិធម៌ឬសមាធានធម៌ក្តី តែងមានទុក្ខសន្តគ្រោះថ្នាក់មហន្តរាយជាធម្មតា ។ បើបុគ្គលពុំមានសេចក្តីអត់ធន់ទេ ពុំអាចនឹងធ្វើទៅបានឡើយ តែបើមានសេចក្តីអត់ធន់ហើយ មិនញាប់ញ័រនឹងក្តៅ ត្រជាក់ សេចក្តីស្រេកឃ្លានជាដើមនោះ រមែងបានសំរេចប្រយោជន៍ក្នុងអាសានមិនខាន ។

ម្យ៉ាងទៀត ពាក្យថា ទិដ្ឋិ សេចក្តីអត់ធន់នេះ បានដល់ការអត់សង្កត់ចិត្តមិនឲ្យគ្រោធខឹង ក្នុងពេលដែលជួបប្រទះនឹងអកោសវត្ថុ ពាក្យដែរ

ប្រទេច ๑๐ យ៉ាង ឬនឹងបហារណាវត្ថុគ្រឿងប្រហារផ្សេង ។ បុគ្គលកាលឮ ឬឃើញជនដទៃដេរប្រមាថពោលពាក្យទ្រគោះបោះបោកវាកខ្វក់ ហើយអត់ធ្មត់មិនដេរ មិនប្រទូស្តបន្ទោសដូចជាពុំបានឮ ពុំបានឃើញ ទំបញ្ជូនចិត្តទៅរកការងារបស់ខ្លួនតែម្យ៉ាង ឈ្មោះថាអ្នកមានខន្តីធម៌ ។

ខន្តីធម៌នេះ លោកពុកដូចជាទឹកសំរាប់លាងដំរែទូវៀកក្នុងលោក បើបុគ្គលពុំមានខន្តីធម៌ ក្រែវគ្រោធប្រទូស្តបច់ពោះបុគ្គលដែលប្រទូស្តដែលដេរបំពោះខ្លួន ឥតគឺអាឃាតព្យាបាទគុំគួនទឹងចេះតែចំរើនឡើងរហូតដល់នៅសអន្តរាយម្ខាត់ៗ មិនអាចរលុបបាត់ឡើយ សមដូចព្រះភាសិតក្នុងធម្មបទខុទ្ទកនិកាយសំដែងថា :

ន ហិ វេរេន វេរានិ សម្មន្តីធ កុទាចនំ
អវេរេន ច សម្មន្តិ ឯស ធម្មោ សនន្តនោ ។

ពៀរតាំងពីយូរកន្លងមកលោកនេះ មិនដែលរម្ងាប់ទៅដោយពៀរក្នុងកាលណាម្តងទេ តែងសូប់រម្ងាប់បានដោយការមិនមានពៀរ ធម៌នេះជាប្រពៃណីរបស់អ្នកប្រាជ្ញអំពីបុរាណ ។

អដ្ឋកថាចារ្យបានអធិប្បាយតទៀរប្រៀបធៀបសេចក្តីនៃព្រះភាសិតនេះថា ទីដែលប្រឡាក់ដោយវត្ថុមិនស្អាត មានលាមកទឹកមូតទឹកសំបោរជាដើម បើបុគ្គលយកវត្ថុមិនស្អាតដែលនោះទៅលាង ពុំអាចធ្វើវានោះឲ្យស្អាតបាត់ធ្លុំក្លិនអសោចបានឡើយ តាមពិត ទីនោះតែតែប្រឡាក់ ធ្លុំ

កុំឧអសោចខ្វះខ្វែងខ្វៃតយ៉ាងណាមិញ តៀរចាំងឲ្យាយក្នុងលោកនេះ
តែយ៉ាងនោះដែរ លុះត្រាតែបុគ្គលយកចិត្តដ៏ស្អាតគឺខន្តិធម៌ធឹងមេត្តាធម៌
មកណាងជំរះ ទើបតៀរនោះស្ងប់រម្ងាប់ទៅបាន ។

មួយវិញទៀត ខន្តិធម៌នេះ សំរាប់អត់សង្កត់ចិត្តមិនឲ្យរំកើបញាប់ញ័រ
ឃ្លេងឃ្លាងតាមអំណាចលោកធម៌ ៨ ប្រការ ។

ពាក្យថាលោកធម៌ បានសេចក្តីថា ធម៌ដែលគ្របសង្កត់សត្វលោក
សត្វលោកប្រព្រឹត្តទៅតាមធម៌នោះ ចែកជាពីរពួក ។ ពួកខាងល្អមាន ៤
ប្រការគឺ៖ ការបានលាភ ១ ការបានយសសក្តិ ១ ការបានសេចក្តីសរ-
សើរសើរដំកើង ១ ការបានសុខកាយសប្បាយចិត្ត ១ ។ ពួកខាងអាក្រក់
មាន ៤ ប្រការគឺ៖ សាបសូន្យលាភ ១ សាបសូន្យយសសក្តិ ១ ត្រូវគេ
និន្ទាតិះដៀលិះគន់ ១ បានទុក្ខទោស ១ ។

លោកធម៌ទាំង ៨ ប្រការនេះ តែងកើតមានចំពោះបុគ្គលពាល់រូប
តែងកើតឡើងនឹងសាបសូន្យទៅវិញផ្ទាស់ប្តូរវេនគ្នា កាលបើលោកធម៌
ពួកល្អកើតឡើង ខាងអាក្រក់ក៏សាបសូន្យបាត់ទៅ កាលបើលោកធម៌
ខាងអាក្រក់កើតឡើងវិញ ខាងល្អក៏សាបសូន្យបាត់ទៅ ។ បុគ្គលម្នាក់ៗ
តែងបានល្អក្នុងគ្រាខ្លះ បានអាក្រក់ក្នុងគ្រាខ្លះ ពុំដែលបានល្អ ឬអា-
ក្រក់រហូតឡើយ ប៉ុន្តែបើបុគ្គលពុំមានសេចក្តីអត់ធន់ទេ ចិត្តនោះនឹងភ្លើត
ភ្លើនពេកក្នុងគ្រាដែលបានលាភ យស សេចក្តីសុខ សេចក្តីសរសើរ
ហើយនឹងធ្លាក់ចិត្តខ្វាំងក្នុងពេលលាភ យស សេចក្តីសុខ សេចក្តីសរសើរ

នេះសាបសូន្យនៃនាសទៅវិញ ។ កាលបើដូច្នោះ បុគ្គលនោះនឹងទៅជាអ្នកមានជម្ងឺចិត្ត គឺជាមនុស្សខូចចិត្ត ព្រោះហេតុនេះ ទើបទន្ទិធម៌នេះពុំគួរជាឧបាយដ៏ប្រសើរសំរាប់ការពារចិត្តឲ្យមានសុខភាពជាស្ថាពរបាន ។

រីឯការមិនមានទន្ទិធម៌ តែងបណ្តាលឲ្យកើតទៅជាទោសសត្រូវច្រើនអនេកប្បការទៅក្នុងលោក មានការប៉ះទង្គិចគ្នាជាដើម ។ បុគ្គលដែលគ្មានទន្ទិធម៌ឈ្មោះថា អ្នកចិត្តស្រាល ដាប់ទឹងដូចក្តោងចំបើងដែលធាងនេះកលជាល នរជនប្រុសស្រីតែងដឹងភាពបុគ្គលដែលមានចិត្តស្រាលនេះ ។ ជានន័យថា បុគ្គលដែលគ្មានទន្ទិធម៌ ជាអ្នកមានចិត្តស្រាលតែងធ្លាប់ខ្លួនឲ្យខូចសេចក្តីថ្លៃថ្នូរ ព្រោះហេតុនោះទើបអ្នកប្រាជ្ញតាំងឆ្ងាយតែងចំរើនវិបស្សនាទន្ទិធម៌នេះ ពុកជាកម្ចាំងក្នុងការបំពេញខ្លួនតាមបធម៌ផ្សេង ។ ហៅថា ទន្ទិតលៈ ប្រែថា « កម្ចាំងគឺទន្ទិ » សូម្បីមានជនដទៃបៀតបៀនដល់រូបកាយរបស់លោក ក៏ពុំប្រទូសត្តបនឹងជននោះវិញឡើយ ដូចនិទានព្រះតិស្សត្ថេរៈ

សេចក្តីដំណាលក្នុងធម្មបទខុទ្ទកនិកាយថា មានត្រកូលជាងកែវពីរនាក់កំរៃនឹងស្វាមី ជានិមន្តព្រះថេរៈមួយអគ្គព្រះនាមតិស្សៈ មកទទួលភត្តាហារនៅគេហដ្ឋានរបស់ខ្លួនរៀងរាល់ថ្ងៃ ឥតមានមោះហ្មងអ្វីឡើយ ។ កំរៃជាងកែវនោះ ជាស្ត្រីមានសទ្ធាជ្រះថ្លាក្លាហ៊ានក្នុងព្រះពុទ្ធសាសនា ទំយកចិត្តទុកដាក់អង្គាសភត្តាហារដោយសេចក្តីគោរព ។

ថ្ងៃមួយ វេលាព្រឹក ព្រះរាជាទ្រង់ប្រើអាមាត្យឲ្យយកកែវមណីដ៏មានតម្លៃមកឲ្យជាន់នោះដែរ ។ ពេលនោះគាត់កំពុងអង្គុយចំពាក្យសាច់ចំពោះមុខព្រះថេរៈ មានដៃប្រឡាក់ដោយឈាមខ្លួលកែវនោះមកជាក់នៅលើជ្រុញ រួចចូលទៅក្នុងបន្ទប់ទឹកដើម្បីទឹងលាងដៃ ។

រសេចក្តីថា ជាន់កែវនោះមានចិញ្ចឹមសត្វក្រៀលមួយ ពេលគាត់ចូលបាត់ទៅក្នុងបន្ទប់ទឹក ក្រៀលស៊ុះមកចឹកលេបកែវចូលទៅក្នុងពោះដោយសំគាល់ថាជាដុំសាច់ ។ ជាន់ចេញមកមើលពុំឃើញ គិសួរព្រះថេរថា លោកម្ចាស់យកកែវមណីខុកឬ ? លោកឆ្លើយថា អាត្មាភាពមិនបានយកខុកទេ ។ ជាន់នោះចូលទៅសួរគេរំយោគេឯត ក៏រំយោក៏ថាពុំដឹង ។ គាត់កើតមានសេចក្តីសង្ស័យខ្លាំងលើព្រះថេរៈ ហើយនិយាយប្រាប់ការំយោថា កែវនោះពិតជាព្រះថេរៈនេះយកហើយ ព្រោះគ្មានបុគ្គលណាជាគំរប់ពីរនៅទីនេះទេ អញនឹងចងការយកសួរយកកែវវិញលុះត្រាតែបាន ។ ការំយោ ទឹកភ្នែកជោគព្រះថេរៈនិយាយអង្វរថា ឧអ្នកជាម្ចាស់ប្អូនអើយ ! ព្រះថេរៈនេះលោកមានឥទ្ធិឫទ្ធិស្រេតគំស្រេតសុភាពណាស់ ! ភ្លាប់និមន្តមកនាំកុងធ្លុះយើងយូរអង្វែងឆ្នាំហើយ ពុំដែលមានសៅហ្មងអ្វីសោះ អ្នកធ្វើយ៉ាំងនេះពុំសមគួរទេ ។ ជាន់កែវពុំព្រមស្តាប់ការំយោអង្វរគំយកកែវទៅចងការយកថ្វេសុំពន្ធព្រះថេរៈតាមកំហឹងចិត្តឥតមានត្រាប្រណីតិចតួចឡើយ ។

ព្រះថេរៈមានកង្កាយបែកតុលពង់ត្រាំត្រាដោយដំបង មានក្អែក
លៀនស្រែកឆ្ងាំឆ្ងឹតដោយឃ្លាបរបស់ជាងកែវ មានឈាមហៀរហូរស្រោច
ស្រប់ពេញកង្កាយតាំងមួល រងនូវទុក្ខវេទាជាខារុណតន់ប្រមាណ ។
លោកខំអត់ធន់ធឹងជម្ងឺដោយខ្ជាន់ចិត្តធឹងរូបកាយរបស់លោក ឲ្យឈប់
ជាក់ព្សាស់នូវគោសនៃវដ្តសំសារនេះ គោះតេវយដំសួរចម្ងើយយ៉ាងណា
ក៏ពុំហ៊ានច្រាប់ថា សត្វក្រៀលលេបកែវមណីគោះឡើយ ។ ដូនជា
ពេលនោះសត្វក្រៀលជុំក្ងិនឈាមព្រះថេរៈ ក៏មកដើម្បីជឹកឈាមនោះ ។
ជាងកែវកំពុងក្តៅក្រហាយដោយសេចក្តីក្រោធនឹងព្រះថេរៈ ហើយឃើញ
ក្រៀលមកទេសចាក់ដើងរបស់ខ្លួន ក៏ចាត់ត្រូវសត្វក្រៀលនោះដួលប្រ-
ាប់ស្លាប់ក្នុងណះនោះមួយរំពេច ។ ព្រះថេរៈឃើញដូច្នោះ ទំត្រូវសួរ
ថា ម្នាលឧបាសក តើសត្វក្រៀលនោះស្លាប់ហើយឬ ? ជាងកែវទូលឆ្លើយ
ថា នែលោក! បើលោកពុំព្រមឲ្យកែវមណីមកអញវិញទេ អញនឹងធ្វើឲ្យ
ឲ្យស្លាប់ដូចជាសត្វក្រៀលនេះឥឡូវដែរ ។ ព្រះថេរៈតោលថា អ្នកចូរ
បន្ទរចំណងឃ្លាបឲ្យអាត្មាបន្តិចសិន បើសត្វក្រៀលនេះស្លាប់ហើយ អាត្មា
នឹងច្រាប់ ប៉ុន្តែបើសត្វនេះមិនទាន់ស្លាប់ទេ គោះបើអ្នកតាបឲ្យអាត្មា
ដូចម្តេច គឺអាត្មាពុំច្រាប់អ្នកឡើយ ។ ម្នាលឧបាសក! អាត្មាពុំបាន
យកកែវរបស់អ្នកទេ សត្វក្រៀលដែលស្លាប់នេះហើយដែលចឹកលេប
កែវគោះទៅ ។

និមន្តតែបានឮពាក្យនេះភ្លាម ជាន់តែមានសេចក្តីរំភើបជាខ្លាំង ស្ទុះយកសត្វក្រៀលទៅវិះ លុះបានឃើញតែវាហើយ ក៏តក់ស្លុតគិតសង្វែគនឹកអាណិតអាសូរដល់ព្រះថេរៈជាខាន ក្រោយហួសប្រមាណ ចូលទៅក្រាបទៀបថ្វាយ សូមទាមទោសថា «បពិត្រលោកម្ចាស់ដ៏ចំរើន ! សូមលោកម្ចាស់ប្រោសប្រណីអត់ឱទោសនេះ ដល់ខ្ញុំព្រះករុណាម្ប៉ាន់ទៀត លោកម្ចាស់ធ្លាប់និមន្តមកទទួលភត្តាហារទៅនេះយ៉ាងណាកាលពីមុនរៀងមកនោះ សូមកុំមានព្រះទ័យរង្កៀស និមន្តមកយ៉ាងនោះដដែលតទៅទៀត កុំអាក់អន់ព្រះទ័យនឹងខ្ញុំព្រះករុណាឡើយ ។

ព្រះថេរតបថា ម្នាលឧបាសក ! ទោសនេះមិនមែនជាទោសរបស់អ្នកទេ ហើយមិនមែនជាទោសរបស់អាត្មាដែរ គឺជាទោសរបស់វដ្តសំសារទេ អាត្មាអត់ទោសនេះដល់អ្នក ។ ម្ប៉ាន់ទៀត ចាប់តាំងពីថ្ងៃនេះតទៅ អាត្មាលែងហ៊ានចូលមកកាន់ត្រកូលទៀតហើយ ព្រោះទោសនេះជាទោសនៃការចូលមកកាន់ត្រកូល បើកម្ចាស់ស្នងអាត្មានៅមាន អាត្មានឹងចាញ់មដីវិតដោយសារកម្ចាស់ស្នងនោះ រួចពោលគាថានេះថា :

បច្ចតិ មុដ្ឋនោ កត្តំ ថោកំថោកំ កុលេ កុលេ
បិណ្ឌិកាយ ចរិស្សាមិ អត្ថិ ជង្ឃពលំ មម ។

មហាជនតែងចំអិនភត្តបន្តិច ។ កន្លងត្រកូល ។ ដើម្បីអ្នកប្រាជ្ញកម្ចាស់ស្នងរបស់អាត្មាមាន អាត្មានឹងត្រាច់ទៅដើម្បីបិណ្ឌបាត ។

កាលព្រះថេរៈ ពោលគាថានេះចប់ហើយ កំបានដំណើរក្នុងខណៈនោះឯង ។

និទានេះ ជាបុគ្គលាធិដ្ឋានបញ្ជាក់សេចក្តីថា ព្រះថេរៈជាអ្នកប្រាជ្ញខ្ពង់ខ្ពស់មានឥទ្ធិធម៌ដ៏ប្រសើរ សូម្បីជាងតែប្រុសស្តេចសោះលោក កំលោកពុំប្រុសស្តេតបតែប្រុសដែរ សូម្បីតែសេចក្តីអាក់អន់ក្នុងចិត្តបន្តិចបន្តួចក៏គ្មានឡើយ ។

មួយទៀត ឥទ្ធិធម៌នេះ ពុកជាគ្រឿងលំអអង្គរបស់អ្នកប្រាជ្ញ ជាវត្តប្រតិបត្តិបស់អ្នកប្រព្រឹត្តធម៌សមដូចពុទ្ធភាសិតថា

ឥដ្ឋំ ជីវសុ្សលង្ការោ ឥដ្ឋំ តនោ ទមសច្ចនោ

ឥដ្ឋំ ជាអលង្ការ របស់អ្នកប្រាជ្ញ ឥទ្ធិជាតបធម៌របស់អ្នកបំពេញខ្លួតប: ។ ឥទ្ធិធម៌ ជាបារមីម្យ៉ាងនៃព្រះពោធិសត្វ ហៅថា ឥទ្ធិបារមី ប្រែថា (ធម្មជាតិ) ជាគ្រឿងដល់ខ្លួវត្រើយ (និព្វាន) គឺឥទ្ធិ ។ ឥទ្ធិធម៌ជាតប:ដ៏វិសេស សមដូចពុទ្ធភាសិតក្នុងធម្មបទថា ឥទ្ធិ បារមំ តនោ តីតិ ក្ខោ ឥទ្ធិ គឺសេចក្តីអត់ធន់ជាតប: ដ៏ប្រសើរក្រៃលែង ។

ហេតុនេះ ពុទ្ធបរិស័ទអ្នកប្រាជ្ញទ្ធឹងបន្ត្រាត់បង់នូវកង់កិលេសចេញអំពីឥន្ទសន្ធានគប្បីរក្សាឥទ្ធិធម៌ដែលជាតប:ដ៏ប្រសើរនេះ តាមសមគួរចុះ ។

๒– សីល: ការរក្សាកាយវាចាពុកឱ្យល្អ ជានដល់ការសេមាធានខ្លួនិងចិត្តសីលប្តូបញ្ញាសីល ។ បញ្ញាសីលនេះ ដូនតាលោកហៅថា

និច្ចសីល ព្រោះជាសីលដែលបុរសស្ត្រីតបម្រុងរក្សាអស់កាលជានិច្ច ដូន
កាលលោកហៅថាកល្យាណធម៌ ព្រោះជាធម៌ធ្វើបុគ្គលអ្នករក្សាឲ្យបាន
ល្អគួរជាទីគប់អានស្រឡាញ់នៃជនដទៃ ដូនកាលលោកហៅថាកុរុធម៌
ព្រោះអ្នកស្រុកនៅដែនកុរុ តែងរក្សាសីល ៥ នេះជានិច្ចតាំងអស់គ្នា ដូន
កាលលោកហៅថា បុព្វណធម៌ ព្រោះធម៌នេះមានមកតាំងអំពីបុព្វណមុន
ពុទ្ធសម័យទៅទៀត ដូនកាលលោកហៅថា តបធម៌ ព្រោះអាចដុតបំផ្លាញ់
ចោលនូវបាបធម៌ឲ្យរៀនាស សមដូចក្នុងលោមសកសុត្រជាតក មាន
បាលីថា តទោ ករិស្សាមិ បហាយ តាវទេ ប៉ុណ្ណេះជាដើម
ប្រែថា អាត្មាអញនឹងធ្វើនូវសីលតាំងឡាយ លះបង់នូវតាមតាំងឡាយ ។
តទោ ក្នុងពីនេះប្រែថា សីល ពាក្យថាតបនេះ ជាឈ្មោះរបស់សីល
នោះឯង ។

កំសីលតាំងឡាយ ដែលបុគ្គលរក្សាល្អ ហើយមានអានិសង្ស
ធំធាតុណាទុកភាពដ៏ប្រសើរអាចរក្សាឃុំគ្រងបុគ្គលនោះឲ្យរួចផុតពីសេចក្តីអន្ត
រាយគ្រប់ប្រការដូចនិទានចក្កនកុមារអ្នកនៅក្នុងសីហឡទ្វីប ។

សេចក្តីដំណាលក្នុងមង្គលត្ថទីបនីមង្គលសូត្រថា កាលចក្កនកុមារនៅ
តូច មាតាមានរោគាពាធជាទម្ងន់ គ្រូពេទ្យប្រាប់បងថាឲ្យរកសាច់ឆ្មាយ
ស្រស់ដើម្បីយកមកផ្សំឱសថ ។ បងក៏បង្គាប់ឲ្យចក្កនកុមារដើររកខ្លាយ
រស់ ហើយទៅស្រែចាត់ទៅ ចក្កនកុមារបានដើរទៅកាន់វាលស្រែ ឃើញ

ខន្ធាយកំពុងស៊ីសំណាបទ្វីកងថ្នាលកំសុះទៅចាប់ ។ សត្វខន្ធាយឃើញមនុស្សកំសុះរត់យ៉ាងខ្លាំងទៅតាមលើវល្លិ៍ព័ទ្ធព័ទ្ធជាប់ខ្ចប់ព័ះស្រែកយំឮក្រៃៗ ពេលនោះចក្កនកុមារសុះទៅចាប់បានដូចចំណង ប៉ុន្តែឃើញខន្ធាយនោះភ័យញ័រខ្លួនចំប្រប់ស្រែក កំតិចារណាថា «ខន្ធាយនេះមានសេចក្តីភ័យតក់ស្លុតគ្រោះជិវិត អាត្មាអញចង់ឲ្យមានារបស់ខ្លួនវិស ហើយសម្លាប់ជីវិតខន្ធាយ ដែលគ្មានកំពុងភ័យញ័រខ្លួនត់យ៉ាងនេះ ពុំគួរសោះឡើយ" ហើយកំភោលថា " ម្នាលខន្ធាយ ! អ្នកចូលបាត់ភ័យចុះ អញនឹងលែងឯងឲ្យទៅស៊ុសស្មៅផឹកទឹកដួបជុំញាតិមិត្តក្នុងជិវិតវិញ" ហើយកំចុះលែងខន្ធាយនោះទៅ ។

លុះចក្កនកុមារមកដល់ផ្ទះ បានប្រាប់ហេតុនេះដល់បងសត្វគ្រប់ប្រការ តែបងស្តីបន្ទោសជាខ្លាំង ។ ចក្កនកុមារកើតទៅអង្គុយខឿបជាមាតា ហើយពោលទូវសច្ចកថាថា បពិត្រអ្នកម្តាយ ចាប់តាំងពីកូនកើតកាលណា តុំដែលបានទៅផ្តាច់បង់នូវជិវិតសត្វតាំងខ្លាយជាទៃទេ ដោយសច្ចកថានេះ សូមកេតអ្នកម្តាយជាសុះស្បើយទៅ ។ ខណៈនោះ កើតមានហេតុអស្ចារ្យពន់ពេកណាស់ ពេតាពាធមាតាបស់ចក្កនកុមាកំជាសុះស្បើយក្នុងខណៈនោះមួយរំពេច ។

ម្យ៉ាងទៀតបុគ្គលអ្នកមានសីល តែងជាទីគោរពនៃទេវតានិងមនុស្សតាំងខ្លាយ ដូចនិទានសក្កទេវរាជ សេចក្តីដំណាលក្នុងមង្គលជាដែលនេះ

ថា សក្កទេវរាជក្រាបថ្វាយទីដ៏ទៅកាន់ទីព្រាន ចុះចាកវេជយន្តប្រាសាទហើយ ផ្តន់ទូរអញ្ជើញថ្វាយបង្គំទៅដល់ទីសំងំ ១០ ។ មាតលិទេវបុត្រឃើញដូច្នោះ សួរថា បពិត្រព្រះទេវតាខ្ពស់ តើព្រះអង្គថ្វាយបង្គំនមស្ការអ្នកណា ? ។ សក្កទេវរាជ កាលក្រាបសេចក្តីនោះដល់មាតលិទេវបុត្រ ក៏ពោលទូរគាថា ដែលមានក្នុងបឋមសក្កនមស្សនសូត្រ ទុតិយវគ្គ សក្កសំយុត្ត ថា:

យេ កេចិមេ បុព្ពកេហិ សីលវន្តោ ឧទាសុ វា
ឯត្ថន្តរា ធារំ ទោសេន្តិ តេ ឥមស្មិំ មាតលិ។

ម្នាលមាតលី! បុគ្គលទាំងឡាយណាជាគ្រហស្ថ ជាអ្នកធ្វើបុណ្យ មានសីល ជាទុថាសកតែងចិញ្ចឹមកូនប្រពន្ធដោយធម៌ ខ្ញុំនមស្ការទូរបុគ្គលទាំងឡាយនោះ ។

សីលនេះ មានគុណានិសង្សច្រើនជាអនេកប្បការ ដូចមានពុទ្ធភាសិតក្នុងវិសុទ្ធិមគ្គ ត្រង់សីលនិទ្ទេសវែងថា:

សាសនេ កុលបុត្តានំ បតិដ្ឋា ឧត្តមំ ឋិតា
អាធិសំសមរាជ្ជានំ តស្មា សីលេសុ បោរេន។
ន កត្ថា យមនាភាបិ សរក្ខ កិ សរេស្សតិ
និន្នគាភាចរាតីតំ មហាឧទធិ
សក្កាណិ វិសោនេតុំ តំ មលំ ឥធ ចាណិនំ
វិសោធយតិ សត្តានំ យំ វេ សីលមលំ មលំ ។

ឯតំ សជលធារូតា ឯ ចាបិ ហារិចន្ទនំ
នេវ ហោក ឯមណាយោ ឯ ចន្ទតារណាគ្គក
សមយន្តិ សត្តានំ បរិឡាហំ សុរក្ខិតំ
យំ សមេតិ ឥមំ អរិយំ សីលំ អច្ចន្តសីតលំ ។
សីលគន្ធសមោ កន្ធោ កុតោ ឯាម ភវិស្សតិ
យោ សមំ អនុវាតេ ច បដិវាតេ ច តាយតិ ។
សត្តាកេមាណសោចាណំ អញ្ញំ សីលសមំ កុតោ
ឡាវំ ឥច ឥតិ ឡាកេ- ឯតារិស្សប្បវេសនេ
សោភន្តេវំ ឯ ភជាតោ ម្ហុត្តាមណិរិក្ខសិតា
យថា សោភន្តិ យតនោ សីលក្ខន ភូសិតា ។
អត្តានុវាទាទិភយំ វិទ្ធំសយតិ សព្ពសោ
ជនេតិ កិត្តិំ ហាសញ្ច សីលំ សីលវតំ សទា ។
ភុណាមិ ម្ហូលភូតស្ស នោសាធំ ឥលយាតនោ
ឥតិ សីលស្ស កិញ្ចាយ្យ អាដិសំសកថាម្ហុំ ។

ការដើរពីដំនៃកុលបុត្រតាំងឆ្ងាយក្នុងសាសនា ក៏ព្រោះសីលហើយ ពុំមានឡើយ អ្នកណាគប្បីនោលកំណត់ខ្លួនអាទិសដ្ឋរបស់សីលនោះបាន ។ មហានទីគឺទន្លេគង្គាក្តី ទន្លេយមុនាក្តី ទន្លេសរភូក្តី ទន្លេអចិរវតីក្តី ទន្លេមហីក្តី មិនអាចដុះខ្លួរមន្ទិលនៃសត្វតាំងឆ្ងាយ ក្នុងលោក

នេះបានដែរ មានតែទឹកតិស័លដើមដំរនូវមន្ទិល នៃសត្វតាំងឡាយ
នោះបាន ។ ឱសថ ត្រមាតាំងទឹកក្តី ចន្ទន៍ក្រហមក្តី តែវមុក្តាក្តី តែវ
មណីក្តី ពន្លឺព្រះចន្ទ្រដ៏ថ្លាត្រជាក់ក្តី មិនអាចរម្ងាប់នូវសេចក្តីក្តៅក្រហាយ
របស់សត្វតាំងឡាយក្នុងលោកនេះបានដែរ មានតែទឹកតិស័លដ៏ប្រសើរនេះដែល
មានគុណដ៏ត្រជាក់ត្រៃលែង ទើបរម្ងាប់សេចក្តីក្តៅក្រហាយនោះបាន ។
ក្នុងណាបក់ទៅក្នុងទីបណ្តាយខ្សាច់ផង ក្នុងទីប្រាសខ្សាច់ផងបានស្មើគ្នា
ក្នុងនោះស្មើដោយកំណើតទឹកតិស័លដែរ ដោយមិនមានមកអំពីណា ។ ធម្មជាតដ៏ខ្ពង់
ដណ្តើរឡើងទៅកាន់សគ្គភូមិ ឬ ជាដូរកន្លងកិរិយាញុំាងជនឱ្យចូលទៅ
និព្វានដែរ ស្មើដោយទឹកតិស័លដែរ មានមកអំពីណា ។ ត្រពាំងតាំងឡាយ
ត្រង់រីកូសិតដោយតែវមុក្តាផង តែវមណីរមែងសោភ័ណ តែពុំល្អដូចយោគី
តាំងឡាយ ដែលតាក់តែងកាយដោយគ្រឿងសំភក់តាក់តែងតិស័លទេ ។
តិស័លរបស់បុគ្គលអ្នកមានតិស័លតាំងឡាយ រមែងកំចាត់បង់នូវភ័យមាន
អត្តានុវាទភ័យជាដើមដោយប្រការតាំងពួង រមែងញុំាងកើរឈ្មោះឆ្ងល
សេចក្តីរីករាយផង ឱ្យតើតឡើងគ្រប់ពេល ។ បណ្ឌិតគប្បីជ្រាបនូវប្រជាន
នៃអានិសំសកថារបស់តិស័ល ដែលជាឫសគល់នៃគុណតាំងឡាយ ជា
គ្រឿងសម្ងាប់នូវកម្ចាត់នៃទោសតាំងឡាយដោយប្រការដូច្នេះចុះ ។

๓ - ឧបោសថកម្ម ការរក្សានូវឧបោសថសីលតាមកាល ។
ការរក្សានូវឧបោសថសីលនេះ លោកហៅថាប្រព្រឹត្តតបធម៌ ព្រោះ

អាចធ្វើអនុស្សយក្តីលេសដែលដេកត្រាំនៅក្នុងសន្តាន ឲ្យរះរើងស្ងួតៗជាលំដាប់បាន ។ តបធម៌នេះជាឈ្មោះនៃឧបោសថកម្ម សមដូចក្នុងមហាហំសជាតកថា « ឆានំ បរិហ្ហរតិ សីលំ អាជ្ជវំ មទ្ទវំ តបំ ប៉ុណ្ណោះជាដើមប្រែថា ធ្វើនូវាន សីល បរិច្ចាគ ភាពជាអ្នកមានចិត្តស្លូតត្រង់ ភាពជាអ្នកមានចិត្តទន់ភ្លន់ ធ្វើនូវឧបោសថកម្ម ។ តបំ ក្នុងន័យនេះ ប្រែថា ឧបោសថកម្មគឺជាឈ្មោះរបស់ឧបោសថសីល ។

ឧបោសថសីលនេះជាកិច្ចតាសេសមួយក្នុងព្រះពុទ្ធសាសនា សំរាប់ពុទ្ធបរិស័ទសមាទានតាមកាល ដើម្បីធ្វើចិត្តរបស់ខ្លួនឲ្យបានបរិសុទ្ធវិសេសវិសាល មិនមានកាល់ថ្ងៃទេ ក្នុងមួយខែមានត្រឹមតែ ៨ ថ្ងៃ គឺថ្ងៃ ៨ កើតនឹង ៨ រោច ហៅថា បញ្ចមីឧបោសថ ថ្ងៃ ៨ កើតនឹង ៨ រោច ឈ្មោះអដ្ឋមីឧបោសថ ថ្ងៃ ១៤ កើត ១៤ រោច ឈ្មោះចាតុទ្ទសីឧបោសថ ថ្ងៃ ១៥ កើត ១៥ រោច ឈ្មោះបណ្ណរសីឧបោសថ ។ កាលដែលត្រូវរក្សាតំណត់យប់មួយនឹងថ្ងៃមួយ ។ សាធុជនតម្រិះសមាទានរក្សាចាប់តាំងអំពីពេលអរុណរះ រហូតទៅទល់នឹងពេលអរុណរះជាថ្ងៃក្នុងថ្ងៃបន្ទាប់ ។ ប៉ុន្តែ មើបុគ្គលពុំអាចរក្សាឲ្យគេញាកាលតាំងមួល តែរក្សាបានត្រឹមតែថ្ងៃមួយប៉ុត្រឹមតែយប់មួយ ឧបោសថចែបនេះឈ្មោះឧបវុត្ថឧបោសថ ប្រែថាឧបោសថពាក់កណ្តាល ។ កល្យាណកិច្ចដែលពុទ្ធបរិស័ទគប្បីធ្វើជាមួយគ្នានេះមានច្រើនប្រការ មានការស្តាប់ធម៌ទេសនានឹងចំរើនកម្មដ្ឋានជាដើម ។

ឧបោសថសីលនេះជាកល្យាណកម្មមានផលានិសង្សប្រសើរវិសេស
អាចយឺតយោងបុគ្គលអ្នកសមាទានឲ្យបានសេចក្តីសុខចូលចូលយៅកន្លែងលោកនេះ នឹងឲ្យបានសំរេចសម្បត្តិទៅកន្លែងបរលោកទៀត ។ សូម្បីតែអ្នកដែលធ្វើទានចំពោះបុគ្គលដែលរក្សាឧបោសថសីល គង់បានសំរេចសម្បត្តិដូចទានបុរេហិតម្នាក់ ។

សេចក្តីដំណាលក្នុងគម្ពីរមង្គលត្ថទីបនីមង្គលសូត្រ ត្រង់ក៏ដូចជាតកក្នុងតំសនិបាតថា ក្នុងអតីតកាល ព្រះពោធិសត្វសោយព្រះជាតិជាសូត្រខ្ទង់សោយរាជ្យនៅក្នុងក្រុងពារាណសី មានព្រះទ័យជ្រះថ្លាក្នុងកុសលធម៌មានទាន សីលនឹងឧបោសថជាដើម ទ្រង់ពន្យល់ណែនាំពរជនរបស់ព្រះអង្គឲ្យជ្រះថ្លាបំពេញកុសលផ្សេងៗ ប៉ុន្តែមានបុរេហិតរបស់ព្រះអង្គម្នាក់ដែលជាអ្នកកាត់ក្តី មិនត្រមធ្វើតាមព្រះឱវាទ ជាអ្នកស៊ីសំណូកខ្លាំងសាច់ខ្លួនខ្លែនក្តួនក្តី ។ ក្នុងថ្ងៃឧបោសថមួយ គាត់ចូលទៅគាល់ព្រះរាជាកាលព្រះអង្គនឹងពួកសេវាមាត្យស្តួរ គាត់កុហកថាគាត់ជាអ្នករក្សាឧបោសថសីលដែរ ថ្ងៃមួយខាងក្រោយមកជាថ្ងៃឧបោសថ មានស្ត្រីម្នាក់ជាឧបោសថិកា កាលជាប់ធ្វើការងារក្តៅចមិនដឹងជាថ្ងៃឧបោសថ លុះពេលក្រៀកណាស់ទៅហើយ ទើបបានដឹងហើយគិតថា « អាត្មាអញពុំអាចនឹងប្រព្រឹត្តកន្លងខ្លួនឧបោសថសីលឡើយ » ហើយក៏ខ្ពើមគាត់ចាប់អធិដ្ឋានឧបោសថសីលតាក់តែងកាល ទើបឧបោសថរបស់នាងឈ្មោះថាឧបត្ថម្ភសថ ។ ពេលនោះ ពពួកបុរេហិតបានដឹងថា • ឋានិកាន៎ោះរក្សាឧបោ-

សថសីលហើយមិនបានបរិភោគអាហារអំពីព្រឹក ក៏មានចិត្តអាណិតយកផ្លែស្វាយធ្វើជាភេសជ្ជៈមកឲ្យទុជាសិកានោះ ។ ដោយកុសលកម្មប៉ុណ្ណេះលុះគាត់ធ្វើមរណកាលទៅ ក៏បានទៅកើតជាវេមានិកប្រេតក្នុងកន្លះវិមាន (វិមានជាវិការៈនៃមាស) ក្នុងអម្ពវន ចំហាយយោជន៍ ក្បែរច្រកនៃខន្ធគ្គាក្នុងហិមវន្តប្រទេស សោយសម្បត្តិទិព្វតែក្នុងវេលាយប់ មានឥទ្ធិស្រីខេតអប្សរៈចោមរោមជាបរិវារ គួរជាទីរីករាយដ៏ក្រៃលែង តែលុះដល់អរុណរះឡើងទិព្វសិរីទាំងអស់ក៏អន្តរធានបាត់ទៅ អត្តភាពរបស់គាត់ក៏ក្លាយទៅជាប្រេតកំពស់ ៩០ ហត្ថ ត្រូវភ្លើងឆេះរោលរាលក្តៅក្រហាយអន្ទះអន្ទែងដោយគាត់ប្រហារខ្លួនាសាច់ខ្លួនៃកូនក្តី ក៏ត្រូវមានក្រចកដ៏ប៉ុនផ្លែចបគាប់ខ្លាភ្ញាំខ្លួនប្រេតនោះឲ្យរេចុក្ខវេទនាជាពារុណ លុះព្រះមានព្រះភាគត្រាអស្ដង្គតទៅទិព្វសិរីក៏កើតឡើងដល់គាត់ទៀត រួចគាត់ក៏ក្លាយទៅជាទេវបុត្រវិញ ។

រឿងនេះបញ្ជាក់ថា បុរេហិតនោះបានសោយសម្បត្តិទិព្វតែក្នុងវេលាយប់ព្រោះគាត់បានធ្វើភេសជ្ជៈគាន់ដល់ស្ត្រីអ្នកគ្រាទុបព្វជ្ជោសថ ក្នុងវេលាយប់ គាត់ក្លាយទៅជាប្រេតក្នុងវេលាថ្ងៃ ព្រោះគាត់កូតកកុហកគាត់ក្តីរឿចក្នុងវេលាថ្ងៃ ។

៤- ឩតង្គៈ ការកន្ទ្រាន់ឬធុតង្គៈ ។ ក្នុងដីកានៃខេមាភិរតិយុត្តលោកហៅធុតង្គនេះថា តបៈ ព្រោះធុតង្គនេះអាចញ៉ាំងសេចក្តីល្មោភផ្សេងៗ ដោយអំណាចនៃតណ្ហាឲ្យរម្ងាស់ស្ងប់ស្ងៀម ។

ធុតង្គនេះ ជាវត្តប្រតិបត្តិរបស់បព្វជិត ដែលត្រូវធ្វើបន្ទាប់អំពីសីល ។

កុលបុត្តកុងសាសនា កាលតាំងនៅសិប់សួនក្នុងអារាមវត្តហើយ ប្រាថ្នាធំងធ្វើធុតង្គដើម្បីកែកយធំងកាន់តែខ្ពស់ទៀត គប្បីដំរះសីលរបស់អាត្មាឲ្យបានបរិសុទ្ធសិន ព្រោះសីលជាមូលនៃភាវនា ។

ឯធុតង្គ ដែលព្រះមានព្រះភាគបានអនុញ្ញាតដល់សាវកតំងពួយ មាន ១៣ គឺ:

១- បំសុកូលិកង្គៈ អង្គនៃកិកុអ្នកទ្រទ្រង់នូវសំពត់បំសុកូលវៀរមិនប្រើប្រាស់ចីវរដែលគេយកប្រគេន ។

២- តេចីវរិកង្គៈ អង្គនៃកិកុអ្នកទ្រទ្រង់នូវចីវរបី វៀរមិនប្រើប្រាស់ចីវរជាគំរប់ប្លួន ។

៣- បិណ្ឌបាតិកង្គៈ អង្គនៃកិកុអ្នកប្រព្រឹត្តបិណ្ឌបាត វៀរមិនទទួលឆាន់នូវអតិរេកលាភ ។

៤- សបទានចារិកង្គៈ អង្គនៃកិកុអ្នកត្រាច់ទៅតាមប្រកក្លុក វៀរខ្លួរលោលុប្បចារភាព ។

៥- ឯកាសនិកង្គៈ អង្គនៃកិកុអ្នកមានអាសនៈមួយ គឺឆាន់មួយកន្លែង ឬមួយពេលក្នុងមួយថ្ងៃ ។

៦- បត្តបិណ្ឌិកង្គៈ អង្គនៃកិកុអ្នកឆាន់ដុំបាយក្នុងបាត្រ វៀរខ្លួរភាជនៈជាគំរប់ពីរ ។

៧- ខលុបច្ឆាកង្គៈ អង្គនៃកិកុអ្នកឆាន់ៈលុបច្ឆាកត្តៈ វៀរមិនឆាន់អតិរេកភាជន ។

๘ - អាវញ្ជនកថ្ពង់: អង្គនៃកិកុអកនៅកន្លែងព្រៃ ឬរៀនវៀរសេនាសនៈដែលតាំងនៅស្បែកស្រុកភូមិ ។

๙ - រុក្ខមូលិកថ្ពង់: អង្គនៃកិកុអកនៅស្បែគល់ឈើ ឬរៀនវៀរដែលមានដំបូល ។

๑๐ - អព្ភោកាសិកថ្ពង់: អង្គនៃកិកុអកនៅកន្លែងចំរ៉ល ឬរៀនវៀរមានដំបូលនឹងចំមានមួយ ។

๑๑ - សោសានិកថ្ពង់: អង្គនៃកិកុអកនៅកន្លែងព្រៃស្មសាន ។

๑๒ - យថាសន្ថតិកថ្ពង់: អង្គនៃកិកុអកៈត្រេកអរកន្លែងសេនាសនៈតាមមានតាមបានលះបង់លោលុភាពកន្លែងសេនាសនៈ ។

๑๓ - ឯសនិកថ្ពង់: អង្គនៃកិកុអកអង្គុយ ឬរៀនវៀរយោបថសឹង ។

๔ - ឥន្ទ្រិយ: ការសង្រួមខ្លួនវៀនទ្រិយ ។ ឥន្ទ្រិយនោះមាន ៦ ប្រការគឺ:

ក) ចក្ខុន្ទ្រិយ: ឥន្ទ្រិយគឺភ្នែក

ខ) សោតិន្ទ្រិយ: ឥន្ទ្រិយគឺត្រចៀក

គ) ឃានិន្ទ្រិយ: ឥន្ទ្រិយគឺច្រមុះ

ឃ) ជីវ្ហិន្ទ្រិយ: ឥន្ទ្រិយគឺអណ្តាត

ង) កាយិន្ទ្រិយ: ឥន្ទ្រិយគឺកាយ

ច) មនិន្ទ្រិយ: ឥន្ទ្រិយគឺចិត្ត ។

ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត នេះជាធំកន្លែងការខ្លួលខ្លួ

ឥដ្ឋារម្មណ៍នឹងអនិដ្ឋារម្មណ៍ ព្រោះហេតុនោះទើបឈ្មោះថា ឥន្ទ្រិយ ។
ជួនកាលលោកហៅថា អាយតនៈ ប្រែថា «អណ្តូងជាទីហូរចូលនៃបុណ្យនឹងបាប» ឬប្រែថា «បន្ទាយសំរាប់ហូរចេញចូលនៃគុសលនឹងអគុសល» ជួនកាលលោកហៅថា ទ្វារ ព្រោះជាទីចេញចូលនៃខុច្ចរិតនឹងសុចរិត ។

បុគ្គលដែលសង្រួមប្រយ័ត្នខ្លួនវៃន្ទ្រិយមិនឲ្យអកុសលធម៌គ្របសង្កត់បាន ឈ្មោះថាបំពេញតបធម៌ ព្រោះអាចធ្វើខ្លួនឲ្យស្ងប់ស្ងាត់ពីកិលេសគ្រឿងសៅហ្មងទាំងពួងបាន ។

៦- វីរិយៈ សេចក្តីព្យាយាម ។

ពាក្យថា វីរិយៈជាវេវចនៈនឹងពាក្យថា បធានៈ នឹងឧដ្ឋានៈ ប្រែថា «សេចក្តីព្យាយាម ប្រឹងប្រែង» ដូចគ្នា ។

សេចក្តីព្យាយាមនេះជាគុណធម៌ដ៏វិសេស អាចញុំាងប្រយោជន៍ផ្លូវលោកនឹងផ្លូវធម៌ឲ្យសំរេចទាំងសងខាង អាចយឺតយោងនូវជនឲ្យរួចផុតអំពីទុគ្គវេទនាទៅកាន់សេចក្តីសុខក្សេមក្សាន្តបាន សមដូចពុទ្ធភាសិតថា «វីរិយេន ទុក្ខមច្ចេតិ បុគ្គលកន្លងផុតសេចក្តីទុក្ខបានដោយសេចក្តីព្យាយាម» សេចក្តីព្យាយាមលោកពុំតែជាកម្លាំងក្នុងកិច្ចការទាំងពួងហៅថាវីរិយៈទេ ប្រែថាកម្លាំងគឺសេចក្តីព្យាយាម ជាឥទ្ធិបាទធម៌ ហៅថាវីរិយិទ្ធិបាទ ប្រែថាធម៌ជាគ្រឿងតាំងទ្រឲ្យបានសំរេចឫទ្ធិអំណាចគឺវីរិយៈជាអង្គនៃការត្រាស់ដឹង ហៅថា វីរិយសម្ពោជ្ឈង្គៈ ប្រែថាអង្គជាគ្រឿង

ត្រាស់ដឹងគឺវីរិយៈ ជាធម៌ធ្វើទីពឹង ហៅថា វីរិយ ជាឧត្តរណៈ ប្រែថា ធម៌ជាគ្រឿងធ្វើខ្លួនទីពឹងគឺវីរិយៈ ជាធម៌នាំឲ្យមានសេចក្តីអង់អាច លោក ហៅថា វីរិយ វេសារជ្ជករណៈ ប្រែថា ធម៌ជាគ្រឿងធ្វើខ្លួនសេចក្តីក្លា-ហានគឺវីរិយៈ ជាបារមីធម៌នៃព្រះពោធិសត្វទាំង ៦ ឋាយ ហៅថា វីរិយ-បារមី ប្រែថា ធម៌ជាគ្រឿងដល់ខ្លួនត្រើយ (និព្វាន) គឺវីរិយៈ ។

ការបានសំរេចវិជ្ជា ๘ ទំ ๒ ស ក្តី ការបានកោតសម្បត្តិត្រមាំងបំពេញ សម្បត្តិ ប្លុយសសក្តិក្តី ការបានសម្បត្តិបរិសោភគឺ សម្បត្តិសួគ៌ ប្លុងនិព្វានក្តី រមែងបានដោយសេចក្តីព្យាយាមទាំងអស់ ។

សាធុជនអ្នកប្រាថ្នាហាន ๒ ទំ ๒ ស ក្នុងលោកនេះ ប្លុកងលោកខាងមុខ គប្បីប់ពេញសេចក្តីព្យាយាមតាមយថាហេតុចុះ ។

ក៏សេចក្តីព្យាយាមនេះចែកជា ๖ ប្រការគឺ:

ក] សិរវប្បធានៈ ព្យាយាមប្រយ័ត្នមិនឲ្យបាបកើតឡើងក្នុងសន្តាន

ខ] បហានប្បធានៈ ព្យាយាមលះបាបដែលកើតឡើងហើយ

គ] ភាវនាប្បធានៈ ព្យាយាមញុំាងកុសលឲ្យកើតឡើងក្នុងសន្តាន

ឃ] អនុរក្ខណាប្បធានៈ ព្យាយាមរក្សាកុសលដែលកើតឡើងហើយ មិនឲ្យសាបសូន្យទៅវិញ ។

ការពណ៌នាអំពីតបធម៌ សន្មតថាចប់ដោយសង្ខេបតែប៉ុណ្ណេះ ។

ព្រះអភិធម្មបិដក

(គម្ពីរព្រះមហាបដ្ឋាន)

លោក ប៊ូ-ប៊ុ រៀបរៀង

(ភាគ)

បុរេជាតប្បច្ចយ បច្ឆាជាតប្បច្ចយ

ឧបនិស្សយំ ឧសេ្សត្វា សម្តេចព្រះមានព្រះភាគត្រាស់ទេសនាទូរឧបនិស្សយប្បច្ចយចប់ហើយ ទើបទ្រង់ត្រាស់ទេសនាទូរបុរេជាតប្បច្ចយ តទៅទៀត ។

បុរេជាតប្បច្ចយោ ធម្មំណាកើតមុនជាបច្ច័យដល់ធម្មំកើតក្រោយ ធម្មំនោះឈ្មោះថា បុរេជាតប្បច្ច័យ ។ មានអត្ថាធិប្បាយថា ធម្មំកើតមុនជាបច្ច័យដល់ធម្មំកើតខាងក្រោយនោះ បានដល់បសាទរូបទាំងប្រាំ ទីឆវិញ្ញាណទាំងប្រាំជាដើម ។ បសាទរូបទាំងប្រាំនោះកើតមុន ជាបច្ច័យដល់វិញ្ញាណទាំងប្រាំ គឺថា ចក្ខុប្បសាទ សោតប្បសាទ ឃានប្បសាទ ជិវ្ហាបសាទ កាយប្បសាទ កើតមុនហើយជាបច្ច័យឲ្យចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណកើតបាន ។

សម្តេចព្រះមានព្រះភាគទេសនាទូរបុរេជាតប្បច្ច័យចប់ហើយ ទើបទ្រង់ត្រាស់ទេសនាទូរបច្ឆាជាតប្បច្ច័យ ថាធម្មំកើតខាងក្រោយ ជា

បច្ច័យដល់ធម៌ដែលកើតមុន ។ ធម៌ដែលកើតខាងក្រោយនោះ ជាទដល់វិញ្ញាណខាងក្រោយ ជាបច្ច័យដល់វិញ្ញាណដើម ។

ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ទេសនាទុំបុរេជាតប្បច្ច័យ នឹងបច្ឆាជាតប្បច្ច័យនោះ ដើម្បីឱ្យសត្វខាងខ្លាយតិចារណាឱ្យយើញថា បណ្តាធម៌ខាងអស់ដែលកើតមុនជាបច្ច័យដល់ធម៌កើតខាងក្រោយ នឹងធម៌ដែលកើតខាងក្រោយ ជាបច្ច័យដល់ធម៌ដែលកើតមុន ។ ធម៌កើតមុនក្តី ធម៌កើតក្រោយក្តី សុទ្ធតែមិនខៀង សុទ្ធតែជាទុក្ខ មិនមែនជារបស់ខ្លួនទេ អ្នកប្រាជ្ញគប្បីសន្និដ្ឋានដូចជានវិសជ្ជនាមកនេះចុះ ។

អាសេវនប្បច្ច័យ

អាសេវនប្បច្ចយនិទ្ទេសេ បុរេជាតំ ឥវនំ បច្ឆាជាតស្ស ឥវនស្ស បច្ចយោ ហោតិ ទុតិយំ តតិយស្ស ឥវនស្ស បច្ចយោតិ ។

លំជាប់នេះ សូមវិសជ្ជនាក្នុងអាសេវនប្បច្ច័យតទៅ ដំណើរសេចក្តីថា សម្តេចព្រះបរមសាស្តាត្រាស់ទេសនាទុំបច្ឆាជាតប្បច្ច័យចប់ហើយ ក្នុងលំជាប់នោះ ទើបត្រាស់ទេសនាទុំអាសេវនប្បច្ច័យ ។

ព្រះអដ្ឋកថាចារ្យគោលការ្យអធិប្បាយ អនុលោមតាមព្រះពុទ្ធដីកាថា អាសេវនប្បច្ច័យនោះ ជាទដល់ដវនចិត្តដែលកើតនឹងជាអាសេវនប្បច្ច័យដល់ដវនចិត្តដែលកើតខាងក្រោយ ។

ឯចិត្តដែលជាដំនៃចិត្តនោះមាន ៥៤ ដួង គឺចាត់ជាអកុសលដំន ១២ កុសលដំន ២០ (១) កិរិយាដំន ១៨ ផលដំន ៤ ។ ដំនចិត្ត ៥៤ ដួងនេះ បើដួងណាមួយកើតឡើងហើយ ក៏ជាអាសេវនប្បច្ច័យឲ្យកើតតទៅដល់ ៧ ខណៈ ។ ១ខណៈមិនមែនកើតតែមួយហើយរលត់ទៅទេ មិនមែនកើតតែពី ១ខណៈហើយរលត់ទៅទេ ។ សូម្បីបុគ្គលភ្ញីក សន្ធប់ក្នុងកាលដ៏តនឹងអស់ជីវិត ចិត្តប្រព្រឹត្តទៅអន់ខ្សោយហើយដំនចិត្តក៏ទៅតែប្រព្រឹត្តទៅត ។ គ្នាដល់ប្រាំពីរខណៈ ។ ។ គប្បីចូលចិត្តថា ដំនចិត្តជាបឋមនោះ ជាអាសេវនប្បច្ច័យដល់ទុតិយដំន ទុតិយដំនជាអាសេវនប្បច្ច័យដល់តតិយដំន ។ ជាអាសេវនប្បច្ច័យដល់ចតុត្ថដំនៈ ។ ជាអាសេវនប្បច្ច័យដល់បញ្ចមដំន ។ ជាអាសេវនប្បច្ច័យដល់ឆដ្ឋមដំន ។ ជាអាសេវនប្បច្ច័យដល់សត្តមដំន គ្រាតថាដំនដែលកើតតាំង ៧ ខណៈនោះ មានអារម្មណ៍តែមួយ ដូចគ្នាមិនប្លែកគ្នាទេ ។

ក្នុងអាសេវនប្បច្ច័យនេះ សម្តេចព្រះមានព្រះភាគទ្រង់ត្រាស់ទេសនាដោយចិត្តជាកុសល ទើងចិត្តជាអកុសល ទើងជាកិរិយាចិត្ត ទើងជាផលចិត្ត ដ៏ជាទីសេពតប់ដល់គ្នាទើងគ្នា គឺចិត្តជាកុសលទើងជាអកុសលនោះ ក៏អាស្រ័យដល់អាសេវនចិត្តជាកុសល ទើងចិត្តជាអកុសល ។

---

(១) – កុសលដំនៈ ២០ គឺៈ មហាកុសល ៨ , រូបាវចរកុសល ៥, អរូបាវចរកុសល ៥, លោកុត្តរកុសល ៤ ។

បើជវនៃចិត្តដែលកើតមុនខោះជាកុសលហើយ ចិត្តកើតខាងក្រោយខោះ ជាអាសេវនៈហើយក៏ជាកុសលទៅតាម ។ បើចិត្តមុនជាអកុសល ចិត្តដែលមកសេពតាប់ក៏ជាអកុសលទៅតាមគ្នាដែរ ដូចបុគ្គលដែលអាស្រ័យសេពតាប់នូវមនុស្សគ្រោលក៏ជាគ្រោលទៅតាមគ្នា បើសេពតាប់អ្នកប្រាជ្ញក៏ជាអ្នកប្រាជ្ញទៅតាមដែរ ។ ឧធ័លើកសេចក្តីមកសំដែងឲ្យឃើញបែបយ៉ាងជាឧបមានៃចិត្ត ព្រោះហេតុឧធ័សំដែងដោយចិត្តខោះ តម្រូវឧធ័ពិចារណាឲ្យយល់ណាស់ ។ ឧធ័លើកយកបុគ្គលមកសំដែងឲ្យយល់ថា បើសេពតាប់គ្រោលទៅជាគ្រោល បើសេពតាប់អ្នកប្រាជ្ញទៅជាអ្នកប្រាជ្ញ ។ យ សព្ទ តតិ តោ បុគ្គលឧធ័ជាគ្រោលជាអ្នកប្រាជ្ញខោះ ក៏អាស្រ័យដល់អាសេវនៈការសេពតាប់ ។ កុំថាតែមនុស្ស សូម្បីសត្វតិរច្ឆាន តឹតជសារដើរសាហាវនៃធ័សត្វបក្សីក៏អាស្រ័យទីជាអាសេវនៈ បើអាសេវនៈដោយមនុស្សគ្រោល តឹបានឃើញអាការកិរិយាគោលក៏ចាដ៏អាក្រក់ ក៏ជាតជសារច្រាសចាកអាការមារយាទដ៏ល្អ បើបានឃើញអ្នកប្រាជ្ញធ្វើអាកប្បកិរិយាយ៉ាងណា ក៏ជាតជសារដើរល្អទៅដោយអំណាចនៃអាសេវនៈ តឹការសេពតាប់ដូចមាន៖

រឿងមហិទ្ធាមុខតជសារ

អតីតតេ ពារាណសិយំ កិរ៉ បានវុច្ចតា ព្រះបាទព្រហ្មទត្តត្រង់ពជសម្បត្តិកុងនគរពារាណសី ព្រះអង្គមានតជសារសមួយប្រកប

ដោយមានយោគដ៏ល្អ ជាមង្គលគជសារ មិនដែលបៀតបៀនចាប់ជោក ប្រហារអ្នកណាមួយឡើយ ។ អនេកជិវសំ វត្តិការកេ ក្នុងរាត្រីកាលថ្ងៃមួយ ចោរពាំងឆ្មាយទៅអង្គុយជិតហើយនិយាយគ្នាឲ្យសំភ្លាថា ឱវំ ឧម្មត្តោ កិន្នុតត្ថោ អ្នកពាំងឆ្មាយគប្បីលោយទម្លួងដោយអាការយ៉ាងនេះ គប្បីកាត់ខ្លួវិតនៃជញ្ជាំងផ្ទះដោយអាការយ៉ាងនេះ គប្បីលោយទម្លួងនឹងកាត់ខ្លួតយ៉ាងនេះហើយចូរនាំទៅដោយអាការយ៉ាងនេះ គប្បីវាយម្ចាស់ផ្ទះហើយនាំទៅ គប្បីប្រកបដោយអាការក្លាហានកាចយោរយៅ ឱវំ មន្តេត្វា ចោរពាំងឆ្មាយប្រឹក្សាគ្នាដូច្នេះហើយ ក៏នាំគ្នាចេញពីទីនោះទៅ ។

តេសំ វចនំ សុត្វា ចំណែកមង្គលគជសារបានស្តាប់ចោរពាំងឆ្មាយនិយាយគ្នា ក៏សំគាល់ថាគេមកបង្រៀនខ្លួន ទើបប្រកបដោយអាការកាចសាហាវចាប់ទ្រមាក់របស់ខ្លួនជោកសម្លាប់ ។ ជនពាំងពួននាំសេចក្តីនោះក្រាបទូលព្រះមហាសត្រ សូមទ្រង់ជ្រាប ។ ព្រះបាទព្រហ្មទត្តមានព្រះរាជឱង្ការឲ្យកេព្រះបរមគោធិសត្វ ដែលជាមហាមាត្យឲ្យទៅតិចារណាមើលអាការនៃដំរី ។ ព្រះបរមគោធិសត្វទទួលព្រះរាជបញ្ជាហើយទៅពិនិត្យមើល មិនឃើញពេគអ្វីទៅក្នុងដំរីសោះ លុះពិនិត្យមើលឲ្យល្អិតទៅទៀតក៏ដឹងថា គជសារមានអាការសាហាវនោះ

ព្រោះហេតុសេពគប់នឹងមនុស្សពាល បើបានសេពគប់នឹងអ្នកច្រៀងហើយ
មុខជានឹងត្រឡប់មានអាការស្តួតបួតល្អវិញ តាលតំបារណាមើលដឹងដូច្នេះ
ហើយ ទើបត្រឡប់មកក្រាបទូលព្រះបាទព្រហ្មទត្ត សូមទ្រង់ជ្រាបគ្រប់
ប្រការ ។ ព្រះបាទព្រហ្មទត្តបង្គាប់ឲ្យពួជបុរសចាំឯឡាយទៅអញ្ជើញ
ពួកព្រាហ្មណ៍អ្នកមានសីល ឲ្យមកអង្គុយសន្ទនាគ្នាជិតដំរីនោះ ។

ចំណែកព្រាហ្មណ៍ចាំឯឡាយ អ្នកមានសីលាចារវត្តមកអង្គុយហើយ
និយាយគ្នាថា មនុស្សចាំឯឡាយដទៃនោះ យើងមិនគួរនឹងប្រហារទេ
យើងគួរតែមានសន្ដានប្រកបដោយមេត្តាករុណានឹងខ្លួន ។ ស្តេចមង្គល
តជសារ កាលបានស្តាប់បានឃើញអាការកិរិយាមារយាទល្អដូច្នោះ ក៏
ត្រឡប់មានអាការស្តួតបួតល្អលែងកាចសាហាវ ព្រោះបានសេពគប់នឹង
អ្នកច្រៀង ៖

រឿងបណ្ឌារអស្សរាជ

មានរឿងមួយទៀត ស្តេចបណ្ឌារអស្សរាជ ជាអស្សរាហ៍នៃព្រះបាទ
សាមរាជ ជាសេះសិន្ធព ជាតិដ៏ល្អ ប៉ុន្តែ ត្រឡប់ទៅជាសេះដើងខ្លួក
វិញ អាស្រ័យហេតុអ្នកថែរក្សាដើងខ្លួក ។ ចំណែរក្រោយមកព្រះ
បរមពោធិសត្វជាមហាមាត្យ បង្គាប់ឲ្យផ្លាស់អ្នកថែរក្សាសេះ ឲ្យអ្នកដើង
ជាល្អទៅថែរក្សាវិញ ស្តេចបណ្ឌារអស្សរាជបានសេពគប់នឹងមនុស្សល្អ ក៏
ត្រឡប់មានកិរិយាល្អដូចដើម ។ (នៅមានត)

សម្តេចព្រះធម្មលិខិត ល្អ - ឈ ប្រែរៀបរៀង

(តមក)

លុះទេវបុត្ត បានសម្តែងប្រាប់នូវបុញ្ញកម្មដែលខ្លួនបានធ្វើ ដោយសេចក្តីពិស្តារចប់ស្រេចហើយ ចំណែកខាងព្រះថេរ ក៏និមន្តត្រឡប់ចុះមកកាន់ស្ថានមនុស្សលោកវិញ ហើយបានប្រកាសសម្តែងប្រាប់នូវទិព្វសម្បត្តិដែលខ្លួនបានឃើញជាក់ច្បាស់ដល់មនុស្សទាំងឡាយ ។

ឯមហាជនសោត កាលបើបានស្តាប់តិមានោះហើយ ក៏មានសេចក្តីត្រេកអរ ខំខ្ជាប់ខ្ជួយចំណាយទ្រព្យធ្វើនូវកុសលកម្មផ្សេងៗ លុះបុត្តទៅហើយក៏បានទៅកើតក្នុងស្ថានសួគ៌ទេវលោកដោយច្រើន ។

ព្រោះហេតុដូច្នោះ ទើបព្រះគន្ធវចនាចារ្យទាំងឡាយ អ្នកសម្តែងរឿងនិទាននេះ លោកបានពោលជាបទព្រះគាថាផ្ញើនវែមទៀតថា :

អជានន្តិយោ ទុក្កតនិន្នតោសិ ទានំ
ទទន្តោនិកតោ រីសេសំ សគ្គប្បភយំ
ទីបមន្តយញ្ចិ ហាន្តាន មច្ចុរមេលំ ឧទាទ ។

អធិប្បាយថា សូមម្បីមនុស្សកំសត់ទុគ៌ត មនុស្សសំណល់ឥតមានទីពឹងពំនាក់ បានឲ្យទានតែម្តងឯ ក៏អាចបានទៅកើតទិព្វសម្បត្តិដ៏វិសេសផ្សេងៗ ដល់ម្ល៉ោះ អ្នកទាំងឡាយជាសប្បុរសបើមានទ្រព្យថ្នាចធំបានទៅទីពឹងទាំ

តីស្ថានសួគ៌កន្លងបរលោក ត្រូវតែសម្ងាប់ផ្តាច់ចង់ខ្លួនសេចក្តីតំណាញ់ដែលជាមន្ទិលដល់កុសលធម៌ ឲ្យជ្រះស្រឡះចញ្ចាចាកសន្ថានហើយ បរិចាគទ្រព្យឲ្យទានតគន់នឹងបានសោយសម្បត្តិទិព្វដោយពិត ។

លម្អែងរឿងនិទានមនុស្សកំសត់ជាគំរប់ ៨ ក្នុងវគ្គទីបីចប់តែប៉ុណ្ណេះ ។

៩- ទេវិប្បុត្តវិត្តកថា

សំដែងរឿងនិទានទេវបុត្តតទៅទៀត ដោយវារបាលីថា : ឥតោ ឋុទ្ធេ ជានេឯស្ស កិរ សម្មាសម្ពុទ្ធកាលេ ដូច្នេះជាដើម ប្រែសេចក្តីថា ឮថាវឿង ។ មកថា ក្នុងពុទ្ធកាលនៃព្រះសម្មាសម្ពុទ្ធខ្មែរព្រះនាមនារទៈមុនកន្លងកប្បនេះ ជម្ពូទ្វីប (គឺឥណ្ឌៀបច្ចុប្បន្ននេះ) ទៅជ្រាកដណ្តើមថា អញ្ញតរទ្វីបទៅឡើយ ។

មានសម័យមួយ អញ្ញតរទ្វីបនោះកើតរៃរឹតប្រែប្រួលផ្លែក្រាម តឹងភ្លៀងអត់ជាយអត់ទឹក ជនតាំងឡាយធ្វើស្រែចំការ ច្បារដំណាំ ស្លុងជកសាបគ្រោះពុំកើត សេចក្តីភ័យគ្រោះអត់ជាយអត់ទឹកស្រែកហ្មងយ៉ាងធំ តែងបៀតបៀនសត្វតាំងឡាយធ្វើឲ្យវិនាសទៅជាច្រើន ។

គ្រានោះឯង មានព្រះចេះមួយអង្គមិនជ្រាកដណ្តើម ជាសាវកនៃព្រះសម្មាសម្ពុទ្ធខ្មែរព្រះនាមនារទៈ លោកជាអ្នកប្រព្រឹត្តសោសានិកធុតង្គ ជានត្រាច់ទៅបិណ្ឌបាតក្នុងអញ្ញតរគ្រាមមួយ ពុំបានចង្ហាន់តិចតួចឡើយ មានតែបាតខេដូចគេលាងស្អាត ហើយនិមន្តទៅតាមច្រកដទៃទៀត ។

កាលនោះ មនុស្សពាំងឡាយនៅកងផ្ទះមួយនោះបានយកអង្ករប្រ-
មាណមួយនាឡីមកវេចខ្ចប់ទុកក្នុងសំពត់សាជក ហើយកាន់យកភ្លុមចុះ
រៅកាន់កំពង់ដើម្បីជនឹកផឹក បានឃើញព្រះថេរៈអង្គនោះហើយ កំ
មានសេចក្តីសោមនស្សជ្រះថ្លា លើកហត្ថាឡើងថ្វាយបង្គំដោយគោរព
ស្រេចហើយទទួលយកបាត្រអំពីព្រះហស្តព្រះថេរៈ ហើយចាត់ចែងដណ្តាំ
បាយដោយអង្ករមួយនាឡីនោះ លុះបាយឆ្អិនហើយកំដោះដាក់ក្នុងបាត្រ
ប្រគេនចំពោះព្រះថេរៈនោះរហាង ។

ចំណែកឯពាំងបាយសោតសឹងនៅពេញចម្អិនដោយបាយវិញ
ដដែល ដោយកំឡាំងសទ្ធានៃមនុស្សពាំងឡាយនោះ ។

ឯមនុស្សពាំងនោះ លុះបានឃើញសេចក្តីអស្ចារ្យដូច្នោះហើយ កំ
ដល់នូវសេចក្តីសោមនស្សរីករាយក្នុងចិត្តថា: នែអស្ចារ្យពេកណាស់ ផល
នេះប្រាកដជាផលទានដែលយើងពាំងឡាយ បានប្រគេនបាយដល់ព្រះ
ថេរៈឃើញជាក់ច្បាស់ក្នុងថ្ងៃនេះឯង ។ លុះមនុស្សពាំងនោះ បាន
គិតដូច្នោះហើយ ក៏ឃោសនាមហាជនឲ្យចូលមកប្រជុំគ្នាឲ្យបរិភោគបាយ
ដរាបដល់ឆ្អែតតែពាល់ៗគ្នា ទើបបរិភោគដោយខ្លួនឯងជាខាងក្រោយ ។

រីបាយដែលនោះក្នុងឆ្នាំងដែលជនពាំងឡាយដួសយកប៉ុន្មានវែកៗក្តី
ហើយចែកដល់មហាជនឲ្យបរិភោគ ក៏ពុំចេះអស់សឹងតែនៅពេញឆ្នាំង
វិញដដែលគួរជាទីអស្ចារ្យក្រៃពេក ។ ចាប់ដើមតាំងពីកាលនោះមក

មនុស្សទាំងឡាយនោះតែងឲ្យទានដល់មហាជនដែលបានទៅដល់ ឲ្យ
បរិភោគផ្កែតគ្រប់គ្នាទាំងអស់ ។ លុះមនុស្សទាំងនោះធ្វើមរណកាល
ក្សីណាក្សីយដំរីតទៅហើយ ក៏បានកើតក្នុងស្ថានសួគ៌ទេវលោកទាំងអស់
គ្នាដោយផលទាននោះឯង ។ ចំណែកព្រះថេរៈនោះសោត លោកក៏
បានទទួលយកចង្ហាន់ដ៏ល្អបានោះ ហើយនិមន្តទៅតង់ទៅទៀបគល់
ឈើមួយដើម ហើយឆ្លាភ្ជា ឆាន់នូវចង្ហាន់នោះ ។

បានឮមកថា កាលនោះ មានខេវប្តូតមួយអង្គទៅអាស្រ័យនឹងដើម
ឈើនោះ លំបាកដោយការស្វែងរកអាហារបរិភោគតាន់ពេក លុះបាន
ឃើញព្រះថេរៈកំពុងតែឆាន់ចង្ហាន់ដូច្នោះ ក៏លះបង់អត្តភាពនៃខ្លួនហើយ
និម្មិតជាមាណពចាស់ម្នាក់ដើរទៅឈរកន្លែងទីដែលនៃព្រះថេរៈនោះ ។

ឯព្រះថេរៈលោកពុំបានគិចារណាមើល ក៏ចេះតែឆាន់ចង្ហាន់នោះទៅ។

ឯខេវប្តូត កាលបើព្រះថេរៈលោកឆាន់ពំនូតបាយជាដំបូងទំនឹងពំនូត
បាយជាកណ្តាលរួចហើយ លោកឆ្លាភ្ជានឹងបរិភោគពំនូតបាយជាបុងក្រោយបំផុត
ខេវប្តូតក៏ក្អកកណ្តាស់ញាក់ព្រះថេរៈឲ្យបានដឹងថាខ្លួនបានទៅស្ថិតនៅកន្លែងទីនោះ ។

លុះព្រះថេរៈបានឃើញខេវប្តូតនោះហើយ ក៏កើតសេចក្តីក្តៅក្រហាយស្តាយក្រោយគិតអាណិតមាណពចាស់ ហើយយកពំនូតបាយជាទីបំផុតដាក់ក្នុងដៃខេវប្តូតនោះឯង ។

លំដាប់នោះ ខេវបុត្តថ្មានខ្ចួលយកតំខ្លួតថ្មាយនោះហើយ កំឈរពីតំង
គិតថា ខំនង់ជាពីអតីតជាតិមក អាត្មាអញពុំដែលថ្មានឲ្យថ្មានដល់សមណ
នឹងព្រាហ្មណ៍ទាំងឡាយផង ដល់មនុស្សកំព្រា មនុស្សកំសត់នង់មនុស្ស
អ្នកដំណើរដើរផ្លូវឆ្ងាយទាំងឡាយផង ដោយហោចទៅគ្រាន់តែសត្វតិរ
ច្ឆាន មានក្អែកនឹងឆ្កែជាដើមក៏អាត្មាអញពុំដែលឲ្យថ្មានដល់ម្តងឡើយ
ព្រោះហេតុនោះ ថ្មានជាអាត្មាអញកើតមកជាខេវបុត្តរកតែថ្មាយបរិភោគ
តុំថ្មាននាជាតិនេះ បើដូច្នេះត្រូវតែអាត្មាអញយកដុំថ្មាយនេះប្រគេនចំពោះ
ព្រះថេរៈវិញចុះ ទើបផលានិសង្សថ្មានខ្លះនឹងកើតមានដល់អាត្មាអញ
ដើម្បីជាប្រយោជន៍ផង ដើម្បីសេចក្តីសុខផង់អស់កាលជាអង្វែងទៅខាង
មុខដោយពិត ។ លុះខេវបុត្តនោះគិតយ៉ាងនេះហើយក៏លះបង់នូវចំណង់ក្នុង
ដុំថ្មាយនោះ ដោយសេរៀចូលទៅជិតព្រះថេរៈទូលថ្វាយបង្គំត្រលោកម្ចាស់
ដ៏ចំរើន សូមលោកម្ចាស់កុំធ្វើសេចក្តីសង្រ្គេះដល់ខ្ញុំក្នុងលោកនេះទៀយ
សូមលោកម្ចាស់ធ្វើសេចក្តីសង្រ្គេះដល់ខ្ញុំក្នុងបរលោកវិញ លុះពោល
យ៉ាងនេះហើយក៏យកថ្មាយទៅដាក់ចុះក្នុងចង្ក្រានព្រះថេរៈនោះដូចដើមវិញ។
ក្នុងខណៈនោះឯង គ្រាន់តែដុំថ្មាយថ្មានធ្លាក់ចុះក្នុងចង្ក្រានហើយ ស្រាប់តែ
ភាជន៍សម្រាប់ដាក់ថ្មាយត្រមាំងមួយចំណីទាំងឡាយ ដ៏ជាទិព្វវិសេស
រកតម្លៃនឹងប្រាកដមួយរំពេច ក្នុងទីប្រមាណ៣ គាវុត ។

(នៅមានត)

(តមក)

រីព្រះចុតុលនី ស្តេចស្តាប់ពាក្យពោធិសត្វហើយ មានហឫទ័យក្រែក
អរក្រៃ ដោយឃើញព្រះហឫទ័យតតង់ថ្លៃ យុជ្ឈន្តា ជាម នាប៉ហៅនឹង
ច្បាំងឮដំកងព្រះនគរនេះ ជាពុកមិនអាចដើម្បីនឹងដឹងជាសេនាគាត្មាឬអ្នក
ដទៃឡើយ ថាបើឯក្រៅនគរនោះ ដើម្បីនឹងច្បាំងនោះជាសុខឯងអេះ
ម្ចាងនេះអញនឹងសម្លាប់អ្នកជងនោះឲ្យស្លាប់បង់ ឮដំកងនគរយើងនេះឯង
ស្តេចតិចារណាខ្លួវប្រកាអម្បាលនោះហើយ អ្នកបន្ទូលថា តាត ម្ចាល
ចៅអ្នកច្រាជអើយ ចូរចៅធ្វើស្តានមានសំគាល់អម្បាលនោះឯងហោង ។
ព្រះមហាសត្វអ្នកខ្លួលថា មហារាជ បពិត្រមហារាជអើយ រីអញខ្ញុំនឹង
ធ្វើឮដំស្តានោះហោង ។ ទីស្តានដែលយើងធ្វើនោះ គឺពលសេកល
យោធាសេនានៃអម្ចាស់នោះ ពុំគប្បីនឹងទៅប្រយោជន៍នឹងកេ។ស នឹង
ស្វឹកឈើជាដើម បើនឹងទៅនោះក៏នឹងធ្វើឈ្មោះប្រកែកជដែកនឹងគ្នា ក៏នឹង
ស្រណុកព្រះរាជហឫទ័យនៃអម្ចាស់ នឹងយើងខ្ញុំនោះឥតអង្គីមានឡើយ ។
ស្តេចមានព្រះបន្ទូលថា បណ្ឌិត ចៃចៅអ្នកច្រាជអើយ ចូរចៅធ្វើផ្តាច់
ខ្លួវពាក្យ ឲ្យជ្រះស្រឡះដំណើរនឹងទៅមកនោះ។ កុំឲ្យមានសោះឡើយ។
ម្ចាស់ហើយពោធិសត្វអ្នកខ្លួលថា ឆេវ បពិត្រមហារាជអើយ ដ្បិតដំរីនៃ
យើងខ្ញុំនោះរាជាសត្វស្រឡាញ់ខឹកក្តាត់ តិតបន់លែងក្នុងខឹកនោះឯង
ជាដើម កើតបែកជាកក់ល្អក់អាក្រក់នឹងផឹកពុំបាន ក្រែងមានអ្នកនៅក្នុង

នគរខ្លះ ម្ចាស់ហើយគេខឹងក៏ធ្វើឲ្យមហាភាជថា បពិត្រមហាភាជអើយ ចាប់ដើមអំពីកាលចៅមហាសថគាត់មក រីឯតស្អក់ក្រខ្វក់ចាំងអស់ យើងធ្វើរកទំកផឹកនោះគ្មានឡើយ ។ ម្ចាស់ហើយស្តេចមានព្រះបន្ទូលថា ម៉ៃអ្នកច្រាជអើយ ចូរឲ្យអ្នកចាំងឡាយលែងខ្លួនដំរីអ្នកចាំងឡាយនោះឲ្យលែងទំកហោង ។ ស្តេចមិនមានព្រះបន្ទូលថាទេឡើយ ម្ចាស់ហើយឲ្យខ្លួនខ្លួនស្គរគេស្រដីឃោសនាច្រាប់ច្រាមថា ម្នាលមហាជនឆងចាំងឡាយអើយ អ្នកឯណា ។ នោះយោបីចេញអំពីនគរនេះទៅកាន់បន្ទាយ ចៅមហាសថដោយរណ្តាប់នោះហើយ ក៏អញ្ជើញឲ្យត្រឡប់ជាណ្តោះមួយភាន់ជនដល់អ្នកនោះឯងមិនលែងឡើយ ។ មហាសត្តោ ភជាំ វិដ្ឋិត្វា កាលនោះព្រះមហាសត្វអ្នកថ្វាយបង្គំលាព្រះបាទបុលន្ធុះមកអំពីលើព្រះពជមន្ទីរ នាំអស់ពលសេនាលើលាចេញពីនគរបន្ទាយនោះស្មោះឆ្ពោះទៅត្រង់កំពង់ស្ទឹង ។ រីពោធិសត្វ កាលអ្នកមកអំពីបុរីមិថិលាមហានគរនោះ កិលាសភស់កូមិតែធំជាហានព្រះចុងស្អាតឡើងទៅ នោះពុំចាប់ពាក្យវៀសនឡើយ លុះដល់អ្នកចុះមកវិញនាហានោះហើយ ទើបរណ្តាប់ស្រុកជាទីលំនៅឈ្មោះតគ្គលីត្រាម ហើយអ្នកយកអស់គោឈ្មោលនឹងជំរីសេះរទេះ ពលថ្មើរដើរជាក់ព្វជំស្រុកនោះហើយ ទើបអ្នកចាត់ចែងលំនៅទីហានក្នុងនគរកំណត់ត្រង់នេះ គួរជាព្រះភូជមន្ទីរតូចធំ ត្រង់នេះគួរជាហាន១ម្នក់ធំ ត្រង់នេះគួរមានជា១ម្នក់ដើង អ្នក

តិចារណាកត់សំគាល់ សារតើច្រកាទើរៃ ។ ដោយលំនៅនោះស្រេច
ហើយ ទើបអ្នកដំកល់ពាល ៦.០០០ នាក់ជាកំណាន់ ឲ្យដឹកមហាមុទ្ធត្រង់
កំពង់ផ្នែស្ទឹងគង្គា រីឯមហាមុទ្ធប្រដាប់ត្រង់កំពង់នោះ អ្នកឲ្យជញ្ជូន
ទូរអាចម៍ដ៏ធំធាក់ស្បែកធំ ។ ឲ្យយកទៅចាក់ទម្លាក់ក្នុងស្ទឹងនោះហើយ
អ្នកឲ្យយកដំរីបរបញ្ជាន់ បំបាត់ឋងំមិនឲ្យឃើញអាចម៍ដីនោះឡើយ អស់
ដំរីពេជាន់បែកជាកក់ល្អក់ខាំងចំពាល់កករ ហូរចុះទៅនឹងរកចំកថ្ងាគោះគ្មាន
ឡើយ ។ ឯកវាសិគោ អស់ពស្ត្រអ្នកនគរចត្តរបញ្ចាល ពុំស្មេហ៍
ស្នាលត្រអាលចិត្តនឹងគោធំសត្វដល់តិចឡើយ សឹងស្រដីនឹងគ្នាថា យើង
អើយចាប់ដើមអំពីកាលព្រះមហាសថមកនៅនគរយើងនេះ យើងមិន
ដែលបានចំកថ្ងាដឹកឡើយ ជាហេតុផលអ្វីដូច្នេះមុខគួរគេត យើងរកសំពត់
ស្បៃកគោះគ្មាន មានតែស្បៃកនៅបង្កើះនេះមិញតើ មិនដឹងគន់គិតតំនិត
មហាសថយ៉ាងណា ? កាលនោះរឯចន្ទិត្តប្តីសែនៃគោធំសត្វឮប់
ស្តីទ្វីស្នាលនឹងគ្នា បានប្រាប់ដល់អ្នកបញ្ជាលនគរថា ម្នាលអ្នកទាំងឡាយ
កុំអាលនិយាយប្រាជ្ញប្រាយ ពាយតាស្យោរយៅតោលពោសព្រះ
មហាសថថា ជាចុងយកលុយលាយដោយចំកល្អក់នោះគ្មានទេ យើងនឹង
ថ្លែងប្រាប់ឲ្យដឹងក្នុងតម្រិះព្រះមហាសថ ដ្បិតមានដំរីមកពីនគរមិថិលាកក្លា
កំឡែងសេងចំកខ្លាំងមហិមា ពាបែកលេកតកវល់អាក្រក់ល្អក់ហេតុបន្ទោះ
ហោង ។ តោធិសត្តាំ អនិប្បាយោ ជាម ឧជ្ឈតិ ឆាបីបេ

ចំណង់តោងដ៏សត្វ បើអ្នកត្រុះរិះគិតត្រង់ណាហើយ មិនដែលឃ្លាតឡើយ សម្រេចដូចចិត្តគំនិតប្រាថ្នាខោះហោង ។ ហេតុដូច្នេះ នាគាលព្រះអង្គឲ្យដឹក ១មង្គ្គាំង៥ហើយ បើដោយរមិលមើលខោះ កំយល់កម្រក្រៃក្រៃនឹងប្រាជ្ញាគំនិតអ្នកដទៃ អ្ហ៎ះហើយក្នុងមហាប្រថពីខោះមិនតែសាច់ដីទេ មានដើមឈើឫស្សៈឈើរវាងក្រួសឫដែលនឹង នាំយកចេញកំហេតុតែបុណ្យសម្ភារព្រះចារមើនៃតោងដ៏សត្វមហាបុរសវត្ថុវិសេស អ្នកវិះគិតឲ្យដឹក ខោះឈើក្តី ឫស្សៈឈើរវាងក្តី ពុំអាចដើម្បីនឹងបិតថែរនៅបានឡើយ ហើយសឹងស្រុតចុតៅមិនព្រួយឆ្ពើសដល់ឫស្សៈឈើមួយឡើយ មានសុទ្ធតែដីធុលីជ្រះល្អប្រាកដហោង ។ រ័ម្មង្គ្គដើងសោត ព្រះអង្គដាក់ពល ៣០០០ នាក់ប្រដាប់ឲ្យដឹក១មង្គ្គដើង ធ្វើគ្មារលេចឡើងទៅឯលើហើយឲ្យដញ្ជូនគាចម៍ដ៏អំពី១មង្គ្គដើង ឡើងទៅចាក់ទម្លាក់ត្រង់កំពែងនគរហើយជាន់ជាវដ្ត ប្រកិតតាំងបន្ទាយលាយលាបខ្លួវចាយអ ដ៏សឹកំបោរតាន់តាប់ប្រដាប់ខ្លួវលំបានាងប្រាសស្រេច ហើយដឹកចេកលស់ដល់ពាល់នឹងដើងជណ្តើរស្តុចស្រេច ព្រះអង្គផ្តន់ប្រដាប់ស្រាប់ពីមុខនោះឯង រ័មហា១មង្គ្គធំនោះ អ្នកឲ្យប្រដាប់ចេញចូល ចុះឡើងទៅក្នុងនគរបន្ទាយ ឯលើគ្មារប្រដាប់នោះមានតំពស់ ១៩ ហត្ថ ពិចិត្រសឹងជាយន្ត ថាបើនឹងបើកពាំងគ្មារនោះហើយ ឲ្យជាន់គន្លឹះមួយកន្លះ បើជាគេពាំងទាំងគ្រប់សព្វអស់គ្មារទាំងនោះ ថាបើនឹងបើក ជាន់តែគន្លឹះ

មួយក៏វាកក្រើករបើកឯង រីឯសង្ឃទាន១មង្គលនោះក្តី ឯលើក្តី អ្នកឲ្យរៀបឥដ្ឋប្រកិតប្រពៃ ហើយនៃត្រលាំងជុំយអ ដីសង្កត់ចោរពណ្តើកយល្អអ្នកឲ្យប្រជាប់មានគ្នារនោះ ៨០ ប្រជាប់ដោយគ្នារតូចនោះ ៦៤ ថាមើនឹងកប់ទាំងអស់នោះត្រូវជា ១៤៤ អ្នកត្រៃរ៉ៃរៀនឹងព្រះត្រាជ្ញា យន្តត្រប់អស់គ្នារទាំងនោះ ថាបើគរៀបនឹងជាន់តែគទ្វីះ ១ នោះ ក៏នឹងរបើកអស់គ្នារទាំងនោះ ក្លឹងឡើងត្រចះស្រឡះល្អ ថាបើនឹងកំងនោះសោត ជាន់តែគទ្វីះមួយកន្ទឹងថ្ងស់ រួចគេកាំងត្រចងងឹតឈឹង ក្នុង១មង្គនោះឥតប្រមាណឡើយ ហើយអ្នកឲ្យប្រជាប់ដ្ឋាប្រទីបជ្វាលានោះ ១០០០ មានទាំងជង់ន-ភាសសំយ៉ុងទៅនៅទាំងរង្គនារ លាបពណ៌រៀបរៀងសង្ឃទាន១មង្គនោះ ក៏ក្លឹងព្រោងព្រាយពណ្តើកយត្រចះល្អមហិមា ថាបើនឹងចង់ឲ្យងងឹតនឹងជាន់តែគទ្វីះ ១ ក៏នឹងដូចជាគេកាំងត្រប់បន្ទប់ ងងឹតល្មប់ដូចកន្ទុនរក ថាបើនឹងចង់ឲ្យក្លឹងជាន់តែគទ្វីះ ១ ក៏នឹងដូចគេបើកអស់ទាំងប្រទីបជ្វាលាទាំងពួង នោះយើលក្លឹងត្រចះស្រឡះល្អ ។ រីសង្ឃទាន១មង្គនោះសោត អ្នកឲ្យប្រជាប់ លែ្ងងក្រឡាព្រះបន្ទំលៀសាច ចិញ្ចោនទូវមាសប្រាក់តែវកងចរបូណិតិជតែ្ន ជាសម្រាប់មហាសុត្រទាំង ១០១ ហើយអ្នកឲ្យក្រាលនូវកម្រាលលើតែ្ន ក្រឡាព្រះបន្ទំទាំង ១០១នោះសឹងរៀមចំត្រៀរខ្ពស់សួតចួតត្រតែ្នមាលា កបន្ទរំភ្យោនោះជារយ បើកជាំងត្រប់សត្វលែ្ងងក្រឡាព្រះបន្ទំលៀសាច សឹងគន់មើលហើយអ្នកឲ្យស្មាច់រូប

ស្រីនឹងក្រដាស ពាសខ្លួរសំពត់ដ៏ល្អត់ចំត្រ សាកសាធជារូបភ្នាតតួចដូច
ស្រីក្រមុំព្រហ្មចារី ហាក់នឹងស្រដីសើចញញឹម បន្សុំខុកនៅក្រឡាព្រះបន្ទំ
ទីមួយ ។ រង្ហួយរហង់ត្រង់សៀរសំពត់ស្រគត់ដន្ទ្រើយ ប្រឹមប្រើយរបៀប
រៀបស្ទៀមទៅ ថាបើតុំបានយកដៃស្ទាបឡើយ សន្ធិដ្ឋានស្មានជាស្រី
មានវិញ្ញាណ ថាបើយកដៃស្ទាបដកចេញអស់គំនូរនោះ ទើបដឹងថាលោក
គួរទេកូរ ខាមួយទីសោត រីសង៏ខាងមហាទម្ងន់នោះ អ្នកឱ្យផ្ទង់គួរចេញ
ជាតិមានហានត្រៃត្រឹង្ស ក្នុងព្រះសុមេរុបព៌តរាជ ចញ្ចោចល្អកណ្តាលកុំសក្តិប-
រិតណ្ឌាំង ៧ វិលាសសត្តសីខន្ធមហាសមុទ្រប្រាកដ មហាស្រះធំទាំង
៧ ប្រកបខ្លួរទ្វីបទាំង ៤ មានទ្វីបតូចពីរោនជាបរិវារ នៅព្រៃព្រះហិមពាន្ត
មានព្រឹក្សាលតាវល្លិ៍ អនោតត្តស្រះមានមនោសិលាបាទ មានមណ្ឌល
ព្រះគាងិត្យ ព្រះចន្ទ្រចរបរាជរង្ស ប្រាកដមណ្ឌលទឹសុ៊ន្ទរនឹងកុំយុតន្ទរ
រហើយអ្នកឱ្យប្រដាប់ខ្លួរពាក់មានហានឧកាមាវចរសួគ៌ទាំង ៦ ជាន់ អំពីចតុ-
ម្មហារាជគាឡើងទៅ ដល់តាវត្តិង្សមម្តេចឥន្ទ្រាធិរាជ ខ្លួរសម្បត្តិ
បរិបូណ៌ តាវត្តិង្សជាបង្អស់ រីកូមិហានមានឮដ៏មហាទម្ងន់ ព្រះអង្គ
ឱ្យប្រាយភាយចាក់ជាខ្លួរខ្លាច់សល្អបរិសុទ្ធប្រាកដដូចប្រាក់ រីជាន់ឯលើ
សោត អ្នកឱ្យគួរជាបទុមផ្កាឈូកកុមុទុត្បល លំពង៏សំយុង៏ចុះទាំងខង
ត្រសង៏ត្រសុំល្បាស្ទាបល្អដូចកម្រង៏ក៏សួគ៌ ។

តេសុ តេសុ ឋានេសុ កន្ធជាមបុច្ឆាជាមាធិ ឯលកិត្តា

សុខម្នាទេវសកំ វិយ ខុម្មង្គំ អលង្ការីសុ ។ ឬយ
ន័លែងអស់ហានទាំងនោះ អ្នកក្រងផ្កាសុពណ៌មាលាមាសចងម្ងំយោលំ
ត្រសងស្អាត ចាំដូចសុធម្មទេវសភា មុខគួរតែពិតពិលរមិលរមើលក៏ប្លែក
ស្រុតចុះមក មានក្លាកជនាមហាខម្មង្គនោះហោង ។

តាងិបិ ខោ តំណិ វង្ឍកស្សតាងិ តំណិ ជាកស-
តាងិ តង្ងិត្វា ងិដ្ឋិតបរិកម្មានិ ឧព្ភសម្ភារំ អ្ងវេត្វា
កង្ការយ អាហារិត្វា បណ្ឌិតស្ស អាហេសុំ ។

ព្រះមហាសត្វ អ្នកឲ្យប្រជាប់ខម្មង្គធំខម្មង្គដើងស្រេច បរិបូណ៌មិន
យូរឡើយ អ្នកប្រើអស់ជាងខងទាំង ៣០ មានអាខន្ធកុមារឯងជាធំ
នាំអស់ខូកខងប្រមាណ ៣០០ ឲ្យខូកខ្លួរគ្រឿងឈើធ្វើបន្ទាយ ធ្វើព្រះ
រាជមន្ទីរកិច្ចការទាំងឲ្យយនាំមកដោយស្ទឹងគង្គាលិន្ទាគ្រាម មកឲ្យព្រះ
មហាសត្វអ្នកប្រាជ្ញ ទើបព្រះមហាសត្វ អ្នកឲ្យរើរើឈើទាំងនោះអំពី
ខូកមកឯលើ ហើយទើបអ្នកបង្គាប់ជាងខូកថា ម្នាលគ្នាយើងទាំងឲ្យាយ
យកខូកទាំង ៣០០ ទៅលាក់ខុកឲ្យកំប៉ាំងរង់ទៅនោះ ដូច្នេះ ទំពំ
អញឲ្យទៅយកព្រះវរាជមាតានឹងព្រះរាជបុត្រាបុត្រីនឹងព្រះរាជទេវី ព្រះ
ប៉ាខបុរោនិអំពីព្រះរាជមន្ទីរ រៀលចុះមកដោយខូរខម្មង្គដើង ខ្លើងមកខម្មង្គ
ធំ ជុំវិញឯណាមួយនោះ ក៏ឮគ្នាយើងអុំខូកទាំង ៣០០ នាំចូលមក
នាគ្នារខម្មង្គធំនោះ ត្រង់កំពង់ស្ទឹងគង្គាលិន្ទាគ្រាម នាសុខវិញ្ញមោះហោង ។

ព្រះមហោសថ អ្នកបង្គាប់ ប្រើឲ្យធ្វើកំណាត់ថ្លឹងផ្សេង ១ ឲ្យដំណើរ ទៅហើយ ទើបអ្នកឲ្យដឹកគួរក្រៅបន្ទាយនោះ ៣ ជាន់ គួ ១ បង្គីសំឯក្នុងនោះ ជ្រៅពេញដោយទឹក គួកណ្តាលជាន់តាន់សឹងកក់ គួក្រៅបណ្តាច់នោះសឹងរាំងស្ងួត រីកំពែងបន្ទាយចម្ងាយកំពស់ ១៨ ហត្ថ ប្រកិតឥដ្ឋល្អ ហើយមានលំអោនាងច្រាល សារតើប្រការបន្ទាយនោះ ស្រេចទើបអ្នកឲ្យសង់ព្រះពន្ធមន្ទីរត្រឹមស្មើហើយ ធ្វើពេងខ្ទមនិងនឹងផ្ទះគួគួចធំហើយអ្នកឲ្យប្រដាប់ពេងដំរី ពេងសេះ ពេងរទេះនោះស្រេចហើយ ទើបអ្នកឲ្យដឹកស្រែះនោះជ្រៅពេញដោយទន្លូទឹកថ្លា មានផ្កាព្រលឹតលំចង់ស្បង្គីជសឹង ជីរកំរៅលេចទន្លូឈូកសច្រាលទន្លាលជាសតាសពេញណាស់ ណាន់តាន់តាច់ល្អប្រពៃ វិស័យដូចនន្ទវាបុក្ខរណី ជាវាមានទន្លូនោសួតិ ច្រាកដរហោង ។

ឥតិ មហាឧម្មង្គោ ជង្ឃឧម្មង្គោ ឯតរន្តិ សព្វមេតំ ចតុហិ មាសេហិ និដ្ឋិតំ ។

រីទើងស្រដីដំណើរដំណាលកាលព្រះមហោសថ អ្នកឲ្យប្រដាប់មហាឧម្មង្គធំនៅឧម្មង្គជើងនៅឧបការនតរាំងពួង ស្រេចនៅប្រការអម្បាលនោះហោង ។ អណ្តាច់នោះ រីព្រះមហាសត្វ អ្នកត្រៃរិះតតប្រដាប់ទ្រព្យព្រះពន្ធការាំងពួងនោះ ៤ វ៉ែ ស្រេចបរិបូណ៌ដោយព្រះប្រាជ្ញានោះ រហើយ អ្នកប្រើរាជទូត ឲ្យលៅទូលព្រះបាទវិទេហរាជជាម្ចាស់

ប្រយោជន៍ដើម្បីនឹងអញ្ជើញមកនោះហាង ។ តមត្តំ បតិគ្គាសេន្តោ
សត្តា អាមា ។ តែអាថ៌ធម៌ឯណាពុំគាន់ច្រកគង បទព្រះចុលឯ
ណាពុំគាន់ចែងច្បាស់ លុះព្រះអគ្គមុខគ្រាស់ហើយ ព្រះអង្គមានបន្ទូល
នឹងកិកូផងតាំងពីដើម ទូវព្រះគាថាដូច្នេះ ។

និវេសនានិ មាបេត្វា វេឧទេហស្ស យសស្សិនោ
អថស្ស បហិណិ ទូតំ ឱហិតានិ មហាភគ
មាបិតិ តេ និវេសនន្តិ ។

តិកូវៃ ហៃកិកូផងតាំងពីដើមអើយ រព្រះមហាសថអ្នកច្រើនដូ អាច
តាក់តែង អណ្តាប់ព្រះពាជមន្ទីរ ថ្វាយព្រះចុលវិទេហពាជ ដ៏ប្រកប
ទូវយស បរិពារច្រើនរួចស្រេចបរិបូណ៌ ហើយអ្នកប្រើពាជទូតឲ្យទាំពតិ
មានទៅទូលអញ្ជើញព្រះចុលវិទេហពាជ ទូវពាក្យថា មហាភគ បពិត្រ
ព្រះសម្មតិទេពមហាពាជក្សត្រថ្ងៃប្រសើរអើយ អំពីព្រះមហាសថដ្បិត
ប្រជាប់ព្រះពាជមន្ទីរ ថ្វាយព្រះអគ្គនោះក៏រួចស្រេចហើយ ឥឡូវនេះ
សូមអញ្ជើញស្តេចលីលាយាត្រាទៅហាង ។

ពាជា តស្ស វចនំ សុត្វា តុដ្ឋចិត្តោ មហន្តេន
បរិវារេន និក្ខមិ ។ ព្រះមហាក្សត្រស្តេចស្តាប់ពាក្យពណិនានោះ
រហើយ ព្រះអង្គមានព្រះពាជហឫទ័យត្រេកអរសោទរណាស់ គ្រាស់
បង្គាប់ប្រើអស់មុខមន្ត្រី ឲ្យប្រុងប្រៀបសេនាយោធ ស្រេចស្តេច

លើសាចេញអំពីព្រះនគរ មួយអន្លើនឹងអស់បរិវារជនច្រើន ។ តមត្ថុ
ភគវាសេន្តោ សត្តា អាហ ។ កិត្តកេវ បៃតកកុដ្ឋធម៌តំណ្យាយ
អើយ ព្រះជាទេវរាជ ស្តេចមានព្រះដំណើរលើសាយោងមួយ
អន្លើនឹងមហាយោធាតាំង ៤ ជំពូក គឺតបៃចោមរោមជាបរិវារ ស្តេច
ត្រេកត្រអាល ដើម្បីនឹងចង់យល់ឧបការ ព្រះនគរបវរព្រះពជ្ឈាន មាន
កម្ពុជស្រុកកម្ពលរដ្ឋភស្ត្រ ពពួកពលសកលយោធាសេនាអាមាត្យ ខ្លួ
ដំរីសេះរទេះ អនន្តវណ្ណា នឹងពណ៌នាគ្រាពប់តុំបានឡើយ ហើយ
ស្តេចលើសាជាលំដាប់ដោយជលំនឿនតង្គាលិន្ទាគ្រាមនោះឯង ។

អណ្តាប់នោះ រីព្រះមហាសថអ្នកមកខ្លួលអញ្ជើញ ស្តេចឲ្យចូល
ទៅក្នុងព្រះនគរនៃអាត្មាដែលធ្លើនោះហោង ។ រីព្រះមហាក្សត្រលើសាឡើង
ទៅលើប្រាសាទនោះហើយ ស្តេចចូលទៅស្រង់ទឹកអប់ត្រឡប់ខ្លួតន្ទ
ពីដោរស្រេច ស្តេចទ្រង់ខ្លួតគ្រឿងប្រដាប់ប្រពៃហើយនៃសោយខ្លួក្រយា
ស្ងោយមានសាច់សាញ៉ាំគ្នា ភោជនាហារត្រគាល មានឧដារសនោះ
ផ្សេង ។ ស្រេចស្តេចគង់សម្រាន្តជាសុខចន្ទិច នាកាលថ្ងៃរសៀលខន់ ។
នោះស្តេចប្រើរាជខ្លួតអាំពតិមានទៅជ្ញានព្រះជាខុព្ធន៍ ដើម្បីនឹងឲ្យដឹងខ្លួ
សភាពអាត្មាព្រះអង្គយ៉ាគ្រាមកនោះហោង ។

តមត្ថុ ភគវាសេន្តោ សត្តា អាហ ។ កិត្តកេវ បៃ
កិត្តកុដ្ឋធម៌តំណ្យាយអើយ នាកាលព្រះជាទេវរាជ ស្តេចជ្ញានទៅ

តន់ក្នុងព្រះនគរនោះហើយ ព្រះអង្គប្រើកដូតនាំពតិមានចូលទៅទូលព្រះបាទបុប្ផវន្ត ខ្លួរតាសូថា ។

មភោកដ ចតាត្រក្សត្រប្រសើរអើយ រាព្រះបាទវិទេហរាជស្តេចមកដល់ហើយ ដើម្បីនឹងថ្វាយបង្គំព្រះបាទព្រះអង្គជាអម្ចាស់សោត ចូរឲ្យនាំនារីព្រះរាជបុត្រីដ៏ប្រកបខ្លួលក្ខណាទាំងពួង ដ៏ប្រដាប់ខ្លួរគ្រឿងសឹងប្រពៃហើយនៃ មានពពួកស្រីព្រះស្តេចជាបរិវារ នាំទៅជាព្រះរាជទេពីរបស់នៃអម្ចាស់យើងហោង ។ ចុទ្បនិរាជាបិ ខ្លួតសុ្ត វចនំ សុត្វា ។ រាព្រះបាទបុប្ផវន្តស្តេចបានឮពាក្យរាជខ្លួតនោះហើយ មានព្រះហឫទ័យសោមនស្សថា រាអ្នកដ៏សត្រូវនៃអញនឹងរួចទៅឯណាឲ្យ អញនឹងកាត់យកក្បាលអ្នកទាំងពីរមកដាក់ឲ្យតែបានសាន្តចិត្ត ស្តេចមានអំណរក្នុងព្រះហឫទ័យ ស្រេចស្តេចឲ្យព្រះរាជទ្រព្យរង្វាន់រាជខ្លួតនោះហោង ហើយចខ្លួលខ្លួរបទព្រះគាថាជាលំដាប់ ។

ស្វាគតន្តេបិ វេទេហា អថោ តេ អនុរាគតិំ
ឧក្កុដ្ឋាយ បរិប្បុដ្ឋ អហំ ឥច្ឆាមិ តេ
សុវណ្ណេន បដិច្ឆន្នំ ទាសិគណា បុរក្ខតំ ។

វេទេហា ម្ចាលស្តេចវិទេហរាជ រាដំណើរអ្នកនឹងមកនេះ ឃើញជាប្រពៃពេក ហាក់ដើយមិនមកអំពីចម្ងាយ បីដូចជានៅអាយជាងយើងម្ចាលខ្លួតអើយ ថារាបើបានឮក្បាររាជាការឯណា អ្នកឲ្យមកប្រាប់

អញ ។ ខ្ញុំនាំនារីដ៏ប្រជាប់ខ្លួរគ្រឿងតាំងពួង សំដីមាស ខ្លួរខ្ចីប្រុស-ស្រីផងច្រើនជាបរិវារ នៃព្រះជាម្ចាស់ទេហាកជនោះឯង ប្រើភាជខ្លួតនោះ ។ ស្តាប់ហើយក្រាបលាមកខ្លួលដូចបណ្តាំនោះហោង ។ រីព្រះជាម្ចាស់ទេហាកជស្តេចស្តាប់ហើយ ប្រើភាជខ្លួតទៅនាំពតិមាន ជាខ្ញុំតឫក្សពេលាសោភាជាមង្គលនាថ្ងៃនេះឯង ។

តមត្តំ បការសេន្តោ សត្ថា អាហ ។ ភិក្ខវេ ម្នាលភិក្ខុផងតាំងឡាយអើយ រីព្រះមហាកស្សបត្ថេរព្រះនាមហៅព្រះជាម្ចាស់ទេហាកជ ព្រះអង្គជ្ញានជណ្តើងរកឫក្សពារពេលាជាខ្ញុំតម្ជាមង្គលដ៏ប្រកបខ្លួនខ្ញុំតឫក្សប្រពៃ ទើបព្រះអង្គប្រើភាជខ្លួតនាំពតិមានទៅខ្លួលព្រះជាម្ចាស់ឬទ្ធីត្រហ្មខ្ញុំតភាជថាដូច្នេះ ។ មហាភាជ បពិត្រមហាភាជព្រះភូមិន្ទនិន្ទនរបតិក្សត្រៃថ្ងៃប្រសើរអើយ ឫក្សពារពេលាជាខ្ញុំតមសមខ្លួនខ្ញុំតឫក្សតាំងពួង សំដីចរិបូណ៌ាសម័យនេះឯង សូមអម្ចាស់ឲ្យព្រះពាជធីតាប្រជាប់ប្រកបខ្លួរព្រះលក្ខណាល្អដ៏ប្រជាប់ខ្លួរគ្រឿងសំដីមាស មានពួកស្រីផងច្រើនជាបរិវារ ជាបរិវារថ្ងៃនៃអម្ចាស់យើងខ្ញុំហោង ។

ចុទ្ធរីភជាបិ អាហ ។ រីព្រះជាម្ចាស់ចុទ្ធរីមានព្រះបន្ទូលថា ម្នាលខ្ញុំតអើយ កុំបីជាអ្នកឡើយ អញនឹងប្រជាប់កូនអញខ្លួរគ្រឿងសំដីមាសដ៏ល្អ នឹងខ្ញុំស្រីផងច្រើនថ្វាយទៅជាជាខ្ញុំតបរិចារិកានៃអ្នកឥឡូវនេះឯង ឯក្រាយភាជខ្ញុំតនោះលើសមកហើយ ស្តេចឲ្យដំណើរទៅតាន់

ស្តេច ១០១ នឹងអស់មហាយោធាតាំង ១៨ អក្ខោភិនី ថាដូច្នេះ ម្នាលអ្នកតាំងឡាយអើយ ចូរប្រដាប់ខ្លួនកាចមម្ចាំង ចូរអ្នកតាំងឡាយប្រុងប្រយ័ត្នប្រដាប់គ្រប់អាគ្នាទីនៃ ហើយយើងនៅតាត់យកក្បាលនៃសត្រូវនៅថ្ងៃនេះមកដំកល់ខុកធឹកស្រាដ៏ឃក្នុងថ្ងៃស្អែកនោះឯង ។ រីព្រះបុឡន ខាកាលស្តេចនឹងទៅនោះ ស្តេចខុកនៅអ្នកតាំង ៤ គឺនាងសលាកទៅព្រះវរមាតាខ្លួនាងឯងទៅ ខ្លួនព្រះកដបុត្រឈ្មោះហៅចៅបញ្ចាលចន្ទកុមារ ខ្លួនព្រះកដធីតាឈ្មោះនាងបញ្ចាលចន្ទី នៅមួយអន្ទឹងសស្រីព្រះស្នំឲ្យដឹកនាំស្តេចព្រះកដមន្ទីរមួយ ហើយស្តេចឲ្យចាំរក្សាឯក្រៅព្រះកដតាំង ខ្លះប្រដាប់គ្រឿងចម្ចាំង ស្រេចស្តេចចេញមកមួយអន្ទឹងនឹងអស់សេនាប្រយោជន៍ដើម្បីនឹងទៅចាមរកមនតរតោងសត្វនោះឯងហោង ។

ឯតោងសត្វ អ្នកប្រដាប់ខ្លួនក្រយាស្បៀងអាហារថ្វាយព្រះចាទិវេហកដ មួយអន្ទឹងនឹងអាចារ្យតាំង ៤ ខ្លួនអស់រហ៍ពលផងច្រើន នាំមកចៅព្រះមហាក្សត្រ រីអ្នកខ្លះសោតស៊ីចំណីអាហារ អ្នកខ្លះផឹកស្រាទំពាត្រីសាច់ អ្នកខ្លះមានខ្លួនខឿយត្រយល់ចាក ហេតុតែមកអំពីផ្លែផ្លាយហើយប្រែខ្លួនដេកលក់ទៅ រីអាចារ្យតាំង ៤ មាននាចារ្យសេនកៈជាដើម ខ្លួនអស់នាហ្មឺនសព្វមុខមន្ត្រី ព្រះកដវង្សាខ្លាំងនឹងតាលផងច្រើនសឹងអង្គុយចាំគាល់ព្រះចាទិវេហកដ ដែលតង់កណ្តាលថ្ងៃរោងធំតតដ៏អ្នកប្រដាប់ប្រសើរ ។

(នៅមានត)

អក្សរសាស្ត្រខ្មែរ	ខ្មែរគួរចិញ្ចឹម
ឡាននង្គាប់ខ្លួន	គង់រឹងរួតរាំមិនត់
ព្រោះអក្សរជាតិ	ដោលជាតិប្រាកដ
អក្សរលត់	ជាតិក៏រលាយ

ប. ព.

សេចក្តីសង្គ្រោះ (វិចារណកថា)

លោក ផេន-ដ្រីវ រៀបរៀង

សេចក្តីសង្គ្រោះជាការណ៍យកចិត្តរបស់មនុស្ស ។ បើខ្វះសេចក្តីសង្គ្រោះ ខ្លួនត្រូវប្រគ្រាយចាកនាមដើមចេញ ។ ការយល់ដូច្នេះ តើរដោយហេតុអ្វី ? ព្រោះមនុស្សជាកេតដែលបណ្ឌិតបានចាត់ទុកថាប្រសើរបំផុតនៅលើផែនដី ។ មាតាបិតាត្រូវសង្គ្រោះបុត្រធីតា គ្រូបាធ្យាយត្រូវសង្គ្រោះសិស្ស អ្នកមានភោគទ្រព្យ ត្រូវសង្គ្រោះអ្នកខ្សត់ភោគទ្រព្យ អ្នកមានកម្លាំងត្រូវសង្គ្រោះអ្នកខ្សោយ អ្នកមានបណ្ឌាសក្តិធំ ត្រូវសង្គ្រោះអ្នកមានសក្តិតូច រដ្ឋាភិបាលត្រូវសង្គ្រោះប្រជារាស្ត្រ ហើយសេចក្តីសង្គ្រោះនេះត្រូវតែប្រព្រឹត្តច្រាសសាដើមវិញជាធម្មតា ។

ចំពោះការសង្គ្រោះនេះ ភាសិតបុរាណមានចែងថា: « អ្នកមានកម្សត់ ដូចសំពត់ព័ទ្ធពីក្រៅ អ្នកប្រាជ្ញកម្សត់ខ្លៅ ដូចសំពៅខ្វះសំបាន ។

អ្នកខ្ពស់ក្បាលជាប ដោយសភាពធម៌បុពណ អ្នកដែនក្បាលហ្វាន នាអ្នកវង
ក្បាលខ្មោ ។ ក្បាលទៅមកវិញ ឥតកំដឹងអស់អម្បាល ចំណេរចិនគាន់កាល
ដូចរបងជាច់បន្ទា » ។

ភាសិតនេះបញ្ជាក់ចន្លែមថា សេចក្តីសង្គ្រោះពិតជាការណ៍យកចិត្តទៃ
មនុស្សឥតតែប្រែបានឡើយ ។

ឯសេចក្តីសង្គ្រោះនេះមានពីរប្រភេទគឺ ๑- សេចក្តីសង្គ្រោះអចិន្ត្រៃ
๒- សេចក្តីសង្គ្រោះដោយមិនបានដឹងជាមុន ។

ខ្ញុំសូមលើកទុកសេចក្តីសង្គ្រោះទី ๒ ទៅពិចារណាខាងក្រោយ ហើយ
សូមពិចារណាសេចក្តីសង្គ្រោះទី ๑ ជាបឋម ។

តាមការគ្រិះរិះ សេចក្តីសង្គ្រោះនេះគួរចែកជាពីរផ្នែក គឺសេចក្តី
សង្គ្រោះរំដោះទុក្ខនឹងសេចក្តីសង្គ្រោះការពារ ។

តើសេចក្តីសង្គ្រោះរំដោះទុក្ខមានលក្ខណៈមានន័យដូចម្តេច ? ចំពោះ
រឿងនេះ មានមនុស្សគាត់ច្រើនន័យមធ្លើ ។ ទៅតាមផ្លូវក្តី ទៅតាមផ្លូវ
ប្តឹងទៅទីផ្សារក្តី អ្នកក្រីក្រខ្លះសមត្ថភាព តែងដើរចូលប៉ះដើម្បីរកស៊ី ដ្បិត
គេស្រឡាញ់ជីវិត ។ ឯវិធីធ្វើនៃជនក្រុមនេះដើម្បីទទួលនូវសេចក្តីមេត្តា
ករុណាពីសំណាក់មនុស្សដទៃ មានសភាពផ្សេង ។ គ្នា ខ្លះយើញមនុស្ស
ដើរមក លើកដៃសំពះសុំដោយត្រង់ ។ ខ្លះអង្គុយព្រឿងមានជាក់ស្តែងប្តឹង-
ប៉ុនពីមុខដើម្បីទទួលសេចក្តីអាណិត ខ្លះទៀតសុគជាបទផ្សេង ។ តាមខ្លួន

រចេះ ខ្លះទៀតរកចាក់ស្បាច់លាយច្រឿងកំផែង ឬកូតទ្រវែញចាប៉ី មាន ខ្លះចេះរហូតធ្វើឲ្យទស្សនិកជនសប្បាយរីករាយមួយខណៈដោយសិល្ប: របស់ខ្លួន មានជាអាទិគឺការស្តាំនក្នែកនឹងធ្វើតាយរីការតាមចំណង់របស់ ខ្លួន ។ មិនតែប៉ុណ្ណោះ មានជនខ្លះទៀតដើរឃ្វាំចាមើលនៅត្រង់តុះអ្នកលក់ អាហារ ហើយញាមានសំណាលអ្វីនៅបុតចាន ជារបស់ដែលសល់ពីអ្នកស៊ី ខ្លួនក៏ស្ទុះភ្លែតទៅលើកហុតបង្ហើយ ឬក៏តាយស៊ីភ្លាម ។ ដើម្បីប្រញាប់ ទៅតុមួយទៀត ។ ពួកសប្បុរសដែលបានឃើញហើយ តែងធ្វើមានៈខ្លះ ក៏ឲ្យជាបច្ច័យតិចច្រើនតាមមាន ខ្លះក៏ទិញអាហារឲ្យតែម្តង ។ នេះជា ក្រុមមួយផ្នែកដែលមានឈ្មោះថាសេចក្តីសង្រ្គោះរំដោះទុក្ខ ។

ជនមួយក្រុមទៀត មានសេចក្តីទុក្ខដោយជម្ងឺ ហើយខ្លះសមត្ថភាព ខាងសម្ភារៈ ក៏ទៅសុំសំណាក់អាស្រ័យទៅមន្ទីរពេទ្យត្រង់កន្លែងឥតថ្លៃ ដើម្បីទទួលសេចក្តីសង្រ្គោះពីរដ្ឋាភិបាល ។ ចំពោះជនក្រុមនេះក៏មាន សប្បុរសខ្លះមានសមត្ថភាពបរិបូណ៌បានរកទំណិនឯកណាត់សំពត់ឬសំ- លៀកបំពាក់យកទៅឲ្យ ដើម្បីញ៉ាំងអ្នកជម្ងឺចាំងនោះឲ្យយល់ថា ខ្លួនទៅ មានគេនឹកឃើញដែរ ខ្លួនគេមិនបោះបង់ស្មោះទេ ម្ល៉ោះហើយចិត្តសប្បាយ ចិត្តធូរស្រាល ជម្ងឺក៏អាចជាសះស្បើយបានឆាប់ ។

មានពិធីដ៏ប្រពៃមួយយ៉ាងទៀតហៅសិសុពិធ ។ ក្នុងពិធីនេះ តាម ការសង្កេត គេធ្វើចំពោះតែកូនក្មេង ហើយក្នុងមួយឆ្នាំមានតែម្តង ។ នៅ

ប្រទេសយើង នេះច្រើនធ្វើនៅពេលចូលឆ្នាំ ។ ឯកាសនោះ អ្នកសប្បុរស
តាំងចិត្តខ្ជួនដូចជាអាពុកម្តាយបង្កើតរបស់កុមារកំសត់ទាំងនោះ ។ ត្រង់
នេះគួរឲ្យកោតសរសើរណាស់ ព្រោះគេចេះធ្វើចិត្តឲ្យបានល្អម្តងក្នុងមួយឆ្នាំ
ចំពោះអ្នកក្រខ្សត់ ។ ពោះបីក្មេងនោះកើតកម្រមាស ឬកើតស្រែងស្រកី
អណ្តែង តែក៏មិនខ្ចើមរអើម តែចាប់ស្លាប ឬចោសអង្អែលផ្តែតទឹកសិតសក់
ឲ្យ ។ ស្ងៀកពាក់សុទ្ធតែស់ពត់ភោគាវថ្មី ។ ហើយបាត់ទឹកអប់ជាក់សព្វ
សព្វាង្គកាយផ្សាយក្លិនក្រអូបឈ្ងុយឈ្ងប់ រួចគេឲ្យបរិភោគនំចំណីយ៉ាងប្រណីតចំណែក ។ ដែលគ្នាឥតសង្ឃឹមថានឹងបានជួបប្រទះក្មេងមួយដ៏វិតខ្ជួន ។ តទៅទៀត គេពោលពាក្យផ្តែមល្អែមទៅវិក ម្ចាស់ហើយកុមារនោះ ។ មានចិត្តរំភើបនឹងសប្បាយរីករាយហាក់ដូចជាគាត់ទើបនឹងចុះមកពីស្ថានសួគ៌ រួចទើបគេប្រគល់ជូនទៅឲ្យមាតាបិតាវិញដោយទឹកមុខញញឹមច្រមុះច្រមុយ ។

មានអ្នកសប្បុរសជាច្រើនទៀត មិនធ្វើសេចក្តីល្អចំពោះតែមនុស្សជាតិគ្នាតើធ្វើហូតដល់សត្វតិរច្ឆានវែមទៀត ។ សត្វតិរច្ឆានពួកខ្លះក៏ជាសត្វអនាថាដូចជាជនក្រុមខ្លះដែរ តើមានការរស់ដោយសេចក្តីលំបាកតន់ពេក ។ សត្វតិរច្ឆានក្រុមនេះ គេច្រើនជួបប្រទះតែនៅទីក្រុង ហើយកាន់ច្រើនជាសត្វវិឆ្ន ។ នៅទីក្រុងមានការជួបប្រទះនឹងកយន្តការយ៉ាងខ្លាំងជាញឹកញាប់ រម្ចាស់ហើយថ្លៃ គោងកេងីលាក់ខ្ជួនពួនអាត្មាដោយព្រៃតុម្ពាត ឬដោយ

ក្រសែតែកែនៈគាត់កំចាំងពីក្នុងសាធារណជន ។ សួរថាបើដំណើរនៃជីវិត
ខ្លួនទៅក្សេមាត់ជ្រោះយ៉ាងនេះ ហេតុម្តេចក៏មិនកែសាគ្នាទៅរកកន្លែង
ដែលប្រាសចាកមរណភ័យ?- ឆ្លើយថា ចានជាមិនជាប់ចិត្តថយចេញ ទី ១ៈ
មកពីគ្នាជាសត្វតិរច្ឆាន ទី ២ មកពីការញ៉ាំមនឹងអាហារឆ្ងាញ់ ពោះបី
យូរ ។ ចានម្តង តែជារបស់មានខ្លាសក្រែលង ត្រូវតែទៅគ្រាំរសតាមរបៀបនេះតទៅ ។

ចំពោះសត្វតិរច្ឆានក្រុមនេះ មានសប្បុរសខ្លះមិនជាប់ចិត្តចោះបង់
ចោល ចានទាំយកចំណីអាហារដើរស្កាត់កេ ដួបប្រទះហើយក៏ដាក់ឲ្យ ឬ
ចោះឲ្យបរិភោគ ។ ចំណែកសត្វតិរច្ឆានខ្លួលបរិភោគចាំងក៏យាខ្លះ តាម
ស្មានមើលទៅ ក្អែកសក្រឡើតក្រឡាប់ប៉ុន្តែតែនឹងជាយ គឺថាស៊ីចាំងក៏យ
ចាំងអរ ព្រោះឃ្លានហើយ ។

សេចក្តីសង្រ្គោះនៃមនុស្សសប្បុរសដូចចានពណ៌នាមកនេះ ជាការ
ប្រសើរក្រៃពេក តែគ្រាន់តែជាការរំដោះទុក្ខនៃជនន្ទឹងសត្វតិរច្ឆាននោះ ។
ដោយពេលដោយខណៈ ។

តើសេចក្តីសង្រ្គោះការពារនោះមានលក្ខណៈមានន័យយ៉ាងណា ?
ចំពោះរឿងនេះ អ្នកសង្រ្គោះមានការយល់ដឹងច្បាស់ មានចិត្តមេត្តាករុ-
ណាធំជាអតិបរមា យល់ហេតុផលក្នុងអតីត បច្ចុប្បន្នន្ទឹងអនាគតដ៏ពេញ-
លេញ មានការពិសោធន៍បរិបូណ៌ គឺថាមានចំណង់ចង់ឲ្យជនអ្នកខ្លួល

សេចក្តីសង្គ្រោះបានប្រទះសេចក្តីសុខ សេចក្តីចម្រើន សេចក្តីសប្បាយរីករាយខ្លួនខ្លួយអស់រយៈវេលាយ៉ាងយូរទើបជាប់លាប់ផង ។ បើពោលម្យ៉ាងទៀតគឺជាសេចក្តីសង្គ្រោះដែលត្រូវមានឡើង ត្រូវកើតឡើងក្នុងពេលដែលទុក្ខ ឬគ្រោះថ្នាក់មិនទាន់មាន គឺធ្វើសេចក្តីសង្គ្រោះសម្រាប់ការពារគ្មានទីគ្រោះថ្នាក់មុនឲ្យហើយ មិនបណ្តោយទុកឲ្យជនោះ ។ មានទុក្ខវេទនាហើយ បានធ្វើសេចក្តីសង្គ្រោះជាក្រោយនោះទេ ។ សេចក្តីសង្គ្រោះបែបនេះ បណ្ឌិតចាំងឡាយតែងនិយមសរសើរថាប្រសើរជាងសេចក្តីសង្គ្រោះចាំងពួង សូម្បីភាសិតបាំងក៏មានចែងថា « Prévenir vaut mieux que guérir) ប្រែថា: «ការពារប្រសើរជាងមើលឲ្យជា » ។ ន័យនេះបកស្រាយបញ្ជាក់តាមទៀតថា: តាមន័យជាអត្ថាន្តរូប ត្រូវកេងំាមកលេបមកដឹកការពារទើងកេតជាមុនឲ្យហើយ កុំឲ្យកេតនោះចូលមកញាំញីខាន់នេះជាការប្រសើរជាងទុកឲ្យកេតកើតរួចហើយ ទើបរកថ្នាំមកព្យាបាលបន្សុះឲ្យជាកន្លងពេលក្រោយ ។ តាមន័យជាអត្ថបដិរូប:ចំពោះការណ៍អ្វីផងចាំងពួង ត្រូវតែប្រយ័ត្នមុន ត្រូវតែដួយមុន ត្រូវតែគាំពារមុន ត្រូវតែប្រាប់តឲ្យល់ឲ្យដឹងមុន កុំបណ្តោយទុកដល់មានគ្រោះថ្នាក់ហើយ កុំបណ្តោយទុកដល់ថ្នាក់ការហើយ ទើ[illegible]ធ្វើ ទើបបានដួយ:ខាន: ពុំប្រពៃឡើយ។ ។ តាហារណ៍ដូចអត្ថន័យ: ត្រូវប្រយ័ត្នមុនឲ្យហើយស្រេច បើភ្លើងនេះរួចហើយទើបដួយលង់ ឯការដួយលង់ប្រសើរដែរ តែមិនប្រសើរស្មើការមិន

រដ្ឋនោះទេ ។

ចំពោះសេចក្តីសង្គ្រោះការពារនេះ តាមការពិចារណា ឃើញមានហូរ
ហែជាធម្មតា តែច្រើនតែដើម្បីប្រយោជន៍ផ្ទាល់ខ្លួន ដូចជាមាតាបិតាមើល
ថែរក្សាបុត្រធីតា បង្រៀនវិជ្ជាមេធូនិងវិជ្ជាជីវៈ ទំពាំណោយប្រាក់កាសឲ្យ
ទៅសិក្សាឯសាលារៀន មិត្រកត្តិខ្លះប្រកបដោយចិត្តធម៌ខ្ចាំងជួយពន្យល់
និងឲ្យប្រាក់កាសដល់មិត្រផង គ្នាឲ្យយកទៅប្រកបមុខរបរដើម្បីចិញ្ចឹមជីវិត
បង់ជួយប្អូន ។ ជួយបង់ មាជួយកូយ ។ ជួយមា ។ ល ។ តែចំពោះ
សាធារណៈ តាមការពិចារណា ឃើញដូចជាមានដែរ តែមិនសម្បូរ ។

សរុបសេចក្តីថា យើងជាមនុស្សត្រូវតែធ្វើសេចក្តីសង្គ្រោះពាំងពីរ
ប្រការនេះខានមិនបាន កំប៉ុន្តែបើចង់ឲ្យសេចក្តីសង្គ្រោះនោះហុចផលដល់
អ្នកដែលខ្លួនមានសភាពស្និតស្នាំ មានសភាពមាំមួន គួរតែប្បីតែនិយម
សេចក្តីសង្គ្រោះការពារខ្លួនជាប្រសើរ ។ សេចក្តីសង្គ្រោះនេះ មនុស្សអាច
ធ្វើបាន ប្រសិនបើចិត្តកុំងប់ងល់លើអត្ថខត្ថពន់ពេក ។

ជាអវសាន មានសេចក្តីសង្គ្រោះមួយទៀតដោយមិនបានដឹងជាមុន:
សេចក្តីសង្គ្រោះនេះក៏មិនមែនតួច ក៏មិនត្រូវព្រងើយកន្តើយ មិនត្រូវបន្ទ
បន្ទោបក្តីការពិចារណាឡើយ ។ តើសេចក្តីសង្គ្រោះនេះដូចម្តេច? សេចក្តី
ទុក្ខនឹងគ្រោះភ័យជាវត្ថុមិនទៀង ជាវត្ថុដែលត្រូវកើតមានឡើងដោយឥតឲ្យ
សាម៉ីខ្លួនបានដឹងមុនទេ ដូចជាវេយ្យាបុរកខង្គ្រេច ឬក្អូក ឱ្យលត ក្តៀងនេះឆ្លុះ

ការលំបាកលំបិនខ្លួនកាលមនុស្ស ចើបានដួចប្រទះហើយ តាមច្បាប់មនុស្ស-ធម៌មិនគប្បីដើរលើងធ្វើមិនដឹងមិនឮ បណ្តោយទុកឲ្យអ្នកវង់គ្រោះប្រកាច់ប្រកិនតែម្នាក់ឯរឹឡើយ ព្រោះអំពើនេះជាការណាយកចិត្តរបស់មនុស្សហើយ ចើឃើញហើយគួរចាត់ចែងតាមការណ៍តាមសមត្ថភាព ដើម្បីឲ្យអ្នកវង់គ្រោះបានធូរស្រាល ដោយផ្លូវចិត្តក្តី ដោយផ្លូវសម្ភារៈក្តី ។ ជាការអាណោចអធម្មតាណាស់ ការធ្វើឲ្យអ្នកវង់គ្រោះយល់ច្បាស់ថាអាត្មាអញកើតមកលើផែនដីជាជនកំព្រា ជាជនត្រូវគេបោះបង់ចោលដូចសត្វជាតុ ។ ជាការរុងរឿងនឹងថ្ងៃថ្ងូរតែកណាស់ ការដែលធ្វើឲ្យអ្នកវង់គ្រោះមានសេចក្តីគក់ក្តៅ មានសេចក្តីសប្បាយរីករាយដោយសង្ឃឹមថា ខ្លួនជាជនមួយប្រមានគេពប់អាន មានគេជួយថ្នាក់ថ្នម មានសាច់ញាតិនឹងកសា្លណាមិត្រាសគេញ ។

តាសិតអាពប់តោលថា: „ មិនត្រូវរង់ចាំឲ្យទុក្ខព្រះអាទិត្យសំងួតខ្លួនទើតក្តែកនៃអ្នកគំសត់ មុនដៃអ្នកឡើយ „ ។ ការណ៍នេះបញ្ជាក់ឲ្យឃើញថា: ត្រូប្រទេសមានអារ្យធម៌ រមែងលើកយកសេចក្តីសង្គ្រោះទុកជាមនុស្សធម៌ដ៏ពិតប្រាកដ ។

ដូចេ្នះ សេចក្តីសង្គ្រោះគាំងពីរបៃបដូចបានរៀបរាប់មកខាងលើនេះ មនុស្សត្រូវតែធ្វើ ហើយប្រសិនបើមានគេយល់ផ្សេងទៅវិញ ហាក់ដូចមិនសមសោះ ។ ក៏ប៉ុន្តែ បើមនុស្សនិយមយកសេចក្តីសង្គ្រោះការពារមកអនុវត្ត ឃើញថាជាការប្រសើរវិសេស ។

56 — Formule de promulgation des lois — រូបមន្តនៃការប្រកាសឲ្យប្រើច្បាប់ ។

57 — Frères et sœurs germins — បងប្អូនប្រុសស្រីសហមាតាបិតា: បងប្អូនប្រុសស្រីដែលកើតពីឪពុកមួយម្តាយមួយរួមគ្នា ។

58 — Frères et sœurs-consanguins — បងប្អូនប្រុសស្រីសហបិតា: បងប្អូនប្រុសស្រី ដែលកើតពីឪពុកមួយ ម្តាយទីពៃ ។

59 — Frères et sœurs-utérins — បងប្អូនប្រុសស្រីសហមាតា: បងប្អូនប្រុសស្រីដែលកើតពីម្តាយជាមួយឪពុកទីពៃ ។

60 — Immeubles par destination — អសង្ហារិមដោយឧទ្ទេស: សង្ហារិមដែលសន្មត់ជាអសង្ហារិមព្រោះជាប់នឹងអសង្ហារិមនេ ។ ១. ដីលំដីណាំច្រប់យ៉ាង ដែលទិនភាន់ជ្រួតកាត់ បេះ ដីកតាស់ ឬដើមឈើដែលដុះ លើអសង្ហារិម ។

61 — Immeubles par détermination de la loi — អសង្ហារិមដោយកំណត់ច្បាប់: សង្ហារិមដែលច្បាប់ចរិកថា ត្រូវគុំកជាអសង្ហារិម ។ ១ តាវិដែលមានចំណុះស្មើនឹង ៥០០ ហាប ឬលើស ។ ២ – ផ្ទះទឹកចំណុះដូចខាងលើ ។ ៣ - សិទ្ធិលើវត្ថុជាអចលនៈ ។

62 — Immeubles par nature — អសង្ហារិមដោយធម្មជាតិ ។ ១. ដី អាគារដែលសង់លើព្រឹះ ឬអាគារសង់ពីដីឡើ ។ ល ។

63 — Influence des condamnations pénales sur la capacité des personnes — ឥទ្ធិពលនៃទណ្ឌកម្ម ខាងព្រហ្មទណ្ឌ លើសមត្ថភាពនៃបុគ្គល ។

64 — Influer (v. int.) — មានឥទ្ធិពលលើ ... ។

5 — Inhumer un cadavre — បញ្ចុះសាកសព ។

66 — Incinérer un cadavre រំលាយសាកសព ។

67 — Intermède (n. m.) ជាកល់ណែ (ត សិប្បៈ)

— J —

68 — Jugement déclaratif d'absence សាលក្រមប្រកាសអំពីអវត្តមាន ។

69 — Jouissance d'un droit ការអាស្រ័យសិទ្ធិ ។

70 — Jouir d'un droit អាស្រ័យសិទ្ធិ ។

71 — Juriste (n. n.) នីតិវិទ្ធ : អ្នកចេះនីតិសាស្ត្រ ។

72 — Jurisconsulte (n.m.) អ្នកនីតិប្រិស្សា : អ្នកជំនាញខាងក្បាច់ ដែលមានការដូនយោបលច់ភ្ជាប់ញ្ញានីតិសាស្ត្រ ។

— M —

73 — Métier (n. m.) អម្រស់ របៈ : ការចិញ្ចឹមជីវិតដោយកម្លាំង ។ ឧ. របៈកសិកា របៈជាងកាត់សក់ របៈជាងកាត់ដេរ ។

74 — Modalités (les) de la confection des lois របៀបនៃការតែងក្បាច់ ។

— N —

75 — Nom de famille d'une personne គោត្តនាមនៃបុគ្គលម្នាក់ នាមសម្រាប់ប្រើរួមគ្នា ចំពោះសមាជិកទាំងអស់នៃគ្រួសារ ដែលជាដំណនៃជាតិកំណើត ពីបុរសទាំងឪ្យក ដែលកើតពីជនករួមម្នាក់ ។

76 — Notifier les actes juridiques វិញ្ញត្តិលិខិតតុលាការ ប្រាប់ឲ្យដឹងពីលិខិតតុលាការតាមផ្លូវក្បាច់ ។

77 — Notification des actes juridiques វិញ្ញត្តិលិខិតនៃតុលាការ ។

78 — Notions sommaires sur les preuves សញ្ញាសង្ខេបចំពោះភស្តុតាង ។

— O —

79 — Officier de police judiciaire មន្ត្រីក្រុមនគរបាលយុត្តិធម៌ ។

80 — Officier de l'état civil មន្ត្រីអត្រានភូលដ្ឋាន ។

81 — Origine des êtres humains ដើមកំណើតនៃមនុស្សលោក ។

82 — Palais de justice សាលាយុត្តិធម៌ ។

83 — Parties ភាគី ។

84 — Plaignant — អ្នកប្តឹង ។

85 — Permis d'incinération d'un cadavre — លិខិតអនុញ្ញាតរំលាយសាកសព ។

86 — Permis d'inhumation d'un cadavre — លិខិតអនុញ្ញាតបញ្ចុះសាកសព ។

87 — Période de présomption d'absence d'une personne — សម័យនៃសន្និដ្ឋានចំពោះអវត្តមាននៃបុគ្គលម្នាក់ ។

88 — Publier les lois — ផ្សាយច្បាប់ ។

89 — Publication des lois — ការផ្សាយច្បាប់ ។

90 — Publication d'un mariage — ការផ្សាយអាពាហ៍ពិពាហ៍ ។

91 — Publier un mariage — ផ្សាយអាពាហ៍ពិពាហ៍

92 — Pupille (n.m.) — ជាលិក : អនីតិជនតាំងព្រា នៅក្នុងអាណាព្យាបាលរបស់អ្នកព្យាបាល ។

93 — Perquisition domiciliaire — ការឆែកឆេរលំនៅ

94 — Professionnellement (adv.) — ដោយវិជ្ជាជីវៈ ។

95 — Prénom ou nom particulier — បុគ្គលនាម ឬ នាមខ្លួន : នាមដែលប្រាប់ខ្សែ គឺជាពាក្យមួយម៉ាត់ដែលត្រូវដាក់បន្ទាប់ពីនាម ឬ គោត្តនាម ដើម្បីសំគាល់ឈ្មោះផ្ទាល់ខ្លួន របស់សមាជិកនីមួយៗ នៃគ្រួសារ ។

96 — Profession (n.f.) — វិជ្ជាជីវៈ ការចិញ្ចឹមជីវិតដោយវិជ្ជា ។ ខ. វិជ្ជាជីវៈពេទ្យ វិជ្ជាជីវៈស្មាត្តិ ។

— Q —

97 — Qualité de citoyen — ឋានៈជាពលរដ្ឋ ។

— R —

98 — Rang de femme mariée — ទីនៃភរិយា ។

99 — Réapparaître — ត្រឡប់វិញ ។

100 — Réapparition de l'absent — ការត្រឡប់វិញនៃអវត្តមានបុគ្គល ។

101 — Registre des publications de mariage — បញ្ជីនៃការផ្សាយអាពាហ៍ពិពាហ៍ ។

102 — Résidence (n. f.) នីវាសនដ្ឋាន : ទីជានដែលបុគ្គលម្នាក់ផ្ទាប់អាស្រ័យនៅ ឬ អាស្រ័យនៅជាប្តេជ្ញាស្ថិតស្ថេរ ។ ๒. អ្នករាជការម្នាក់មានលំនៅនីត្យានុកូលនៅភូមិភាគ ហើយមាននីវាសនដ្ឋាននៅផ្សេងក្រៅព្រៃកញ្ជើ និង ក្រុងកែប ។

103 — Saynète (n. f.) ឆាកកំផ្លែង (សិល្បៈ) ។

104 — Scène (n. f.) ឆាក (សិល្បៈ) : វាគដែលល្ខោនសំដែងរឿង ភាគនៃឈុត ។

105 — Signification d'un jugement ការប្រដិទន្ទនៃសាលក្រមមួយ ។

106 — Signifier un jugement ប្រដិទសាលក្រមមួយ : ប្រាប់ឲ្យដឹងពីសាលក្រមតាមផ្លូវតុលាការ ។

107 — Sommiers judiciaies ក្រាំងផ្តោលកោស ។

108 — Sujet d'examen ou de concours ប្រធានវិញ្ញាសានៃការប្រឡង ឬ ការប្រឡងប្រជែង ។

109 — Sources du droit cambodgien ប្រភពនៃនីតិសាស្ត្រខ្មែរ ។

110 — Sous-acquéreur អ្នកជាវវិត អ្នកទិញត ។ ๒. អ្នកជាវវិតព្រះពុទ្ធរូប អ្នកទិញទ្រព្យសង្ឃវត្ថុ ។

111 — Syndicat professionnel សហជីពនៃវិជ្ជាជីវៈ : ក្រុមជនដែលមានគោលបំណងតែមួយ ក្នុងរឿងការពារប្រយោជន៍រួមនៃវិជ្ជាជីវៈ ។ ๒. សហជីពនៃជំនួបស្ពឹត សហជីពនៃស្មាក្តី ។

112 — Système de publication des lois បែបបទនៃការផ្សាយច្បាប់ ។

113 — Témoins សាក្សី ឥសិណ ។

114 — Traité du droit civil អភិប្រាយនៃនីតិសាស្ត្របវេណី ។

115 — Visite domiciliaire ការពិនិត្យដល់លំនៅ ។

(នៅមានត)

វិបត្តានុក្រមសំស្ក្រឹត-ខ្មែរ

ព្រះមហា ថាំង-ខាត់ រៀបរៀង

(តមក)

អត្យធិ គុ. ដែលមានភាក់ពណ្តាលក្រៃលែង ដែលច្រើនជាងភាក់ពណ្តាល ។

អត្យល្ប គុ. ដែលតិចក្រៃលែង ដែលខ្លោយពេក ។ –ត្ត. ឧបុំ. ភាវនៃ . . . តិច ក្រៃលែង ។

អត្យវស្ថិ ធាតុ. លះបង់ចោលក្រៃលែង ឲ្យរួចខ្លួនក្រៃលែង ដែលឲ្យមានតិស្សរភាព ។

អត្យតិ ធាតុ ស៊ីច្រើនក្រៃលែង ។

អត្យវាទ ឧបុំ. កិរិយាបរិភោគក្រៃលែង ។

អត្យម្ពុំ ស្ត្រី ឈ្មោះឱ្ងាស់ ។

អត្យស ធាតុ. ឈ្លះ(ដោយបាញ់ធ្នូ) ។

អត្យសហ្ស គុ. ដែលទម់ក្រៃលែងមិនបាន ។

អត្យសិត គុ ដែលខ្មៅក្រៃលែង ដែលខ្មៅស្រិល ។

អត្យាកុល គុ. ដែលរឹករក្រៃលែង ដែលចង្អៀតចង្អល់កន្ទុង ដែលគ្រួលច្របល់ក្រៃពេក ។

អត្ថាគ ប៉ុ. កិរិយាមិនបរិច្ចាគ ។ *អត្ថាគិនិ* គុ ដែលមិនបរិច្ចាគ ។

អត្ថាចារ ប៉ុ. អាចារក្រៃលែង អាចារប្រសើរ ។

អត្ថាទរ ប៉ុ កិរិយាអើតើក្រៃលែង កិរិយាអើតើប្រសើរ ។ *អាត្ថាទរេណ* ដោយប្រញាប់ប្រញាល់ក្រៃលែង។ *អត្ថាទរេបរ* គុ. ដែលប្រយ័ត្នប្រយែងក្រៃលែង ។

អត្ថាទិត្ត ប៉ុ. ព្រះអាទិត្យក្រៃលែង ព្រះអាទិត្យប្រសើរ ។ គុ. ដែលដាព្រះអាទិត្យក្រៃលែង ដែលដាព្រះអាទិត្យប្រសើរ ។

អត្ថាទ្ធ ធាតុ. អើតើក្រៃលែង ពោរពេញក្រៃលែង ។ *អត្ថាទ្ធត* គុ. ដែលអើតើក្រៃលែង ដែលពោរពេញក្រៃលែង ។

អត្ថាធន្ធ ប៉ុ. សេចក្តីរីករាយក្រៃលែង ។

អត្ថាបន្ន គុ. ដែលដល់ហើយក្រៃលែង ដែលលំបាកក្រៃលែង ។

អត្ថាយត ធាតុ. ប្រឹងប្រែងក្រៃលែង ។

អត្ថាយត គុ ដែលចំពើនខ្ពស់ក្រៃលែង ។

អត្ថាយុស គុ ដែលមានអាយុក្រៃលែង ដែលមានអាយុច្រើន ។

អត្ថារុហ ធាតុ ឡើងក្រៃលែង ។ *អត្ថារុឡ្ហ* គុ ដែលឡើងក្រៃលែង ដែលឡើងខ្ពស់ ។

(នៅមានត)

រឿងល្បែកឡាហ្វុងតែន

លោក ដេង - ទ្រីវ ប្រែរៀបរៀង

(តទៅ)

៣៤ - អណ្តើកនឹងទាពីរ

អណ្តើកមួយអង្គ្រុននឹងខ្លែងព្រមទាំងស្រុកកំណើតរបស់ខ្លួន ។ មនុស្សទាំងឡាយតែងប្រាថ្នានឹងទៅបរទេសតាមចំណង់ ដូចជាមនុស្សខ្លួន តែងធុញគ្រាន់នឹងទីលំនៅរបស់ខ្លួនដូច្នោះដែរ ។ អណ្តើកនិយាយរឿងនេះប្រាប់ទាទាំងពីរជាមិត្រ ។ ទាក៏ប្រាប់ថា កុំឲ្យព្រួយ គង់នឹងជួយមិត្រឲ្យបានសប្បាយដូចសេចក្តីបំណង ហើយពោលថា : «មិត្រឃើញប្លែក ផ្លូវអាកាសដ៏ធំទូលាយ យើងជានាគនឹងតាំងនាំយោងមិត្រទៅលេងប្រទេសអាមេរិក មិត្រនឹងបានឃើញស្រុកទេសនឹងផែនដីរបស់គេត្រប់សព្វព្រមទាំងមនុស្សផង ហើយដោយដំណើរនេះ មិត្រនឹងបានសំគាល់ពុកឪវ័ន្តខៀមទម្លាប់ប្រទេសផ្សេង ។ ដ៏ប្លែកគាំងបន់យើងផង » ។ អណ្តើក កាលបើបានស្តាប់ពាក្យអធិប្បាយ ក៏ស្ម័គ្រព្រមតាម ។ ទាទាំងគូរៀបចំខ្លួននឹងនាំមិត្រអណ្តើកចេញទៅលេង ។ ទាយកឈើមួយកំណាត់ឲ្យអណ្តើកខាំចំកណ្តាលហើយប្រាប់ថា : « ចូរមិត្រខាំឲ្យជាប់មែនចៃនប្រយ័ត្នរបូតធ្លាក់ » ហើយវាទាំងពីរតាំងពុងដំបងសងខាង ។ មនុស្សទាំងឡាយឯរឿងឆ្ងល់ពេក ដោយឃើញអណ្តើកជាសត្វយឺតហើយមានស្លុកផង ហេតុម្តេចក៏អាចហើរជាមួយទាទៅកណ្តាលអាកាសបាន ។

អ្នកខ្វះស្រែកថា: អស្ចារ្យណាស់ហើយ ! ចូរមើលស្តេចអណ្តើកហោះលើមេឃកណ្តាលតពក ។ អណ្តើកឆ្លើយតបថា: «ពិតមែនហើយ អញជាស្តេចអណ្តើក ចូរអ្នកកាល់គ្នាកុំនិយាយចំអកសើចលេងឲ្យអញ» ។ កន្លងពេលដែលកំពុងហោះយ៉ាំងនោះ អណ្តើកមិនត្រូវហាមាត់និយាយអ្វីសោះ ព្រោះតែកហាមាត់និយាយ ទើបបបូតមាត់ពីដំបងដែលកំពុងខាំអណ្តើកភ្លាត់មកបែកស្មុកខ្វេច នៅត្បូរដើងអ្នកដែលសំឡឹងមើល ។

ការណ៍ដែលមិនចាំពាក្យបណ្តាំនេះហើយ ដែលនាំឲ្យអណ្តើកបានដល់នូវសេចក្តីវិនាស ។

៣៥- លៀសធឹងអ្នកក្តី

ថ្ងៃមួយ អ្នកដំណើរតោនាក់ ដើរទៅប្រទះលៀសមួយនៅលើឥវ៉ាច់ ដែលរលកបក់ចោតមក ។ លៀសជារបស់ស៊ីនៅបាន បើដូច្នេះ អាចាំងតែត្រូវដណ្តើមគ្នា ។ អាមួយស្ទុះកែតនុនចុះរៀបនឹងស៊ើស អាមួយទៀតប្រាននូវុញជ្រុលទៅមុខត្រឡប់តតែត ហើយស្តីឲ្យថា: ត្រូវឯងដឹងឲ្យប្រាកដ តើនរណាត្រូវបាននេះសុំ គឺនរណាដែលបានឃើញមុន នរនោះត្រូវបាន ហើយខ្លួនត្រូវតែមើលមាត់។

អាទី ១ ឆ្លើយថា : បើគេដំរះក្តីដូចឯងថានេះ ពុទ្ធោអើយ! តែកអញក៏ល្អដែរ ។

អាទិ ២ ឆ្លើយតបថា: ក្អែកអញកំមិនមែនស្អុយ ហើយអញ
ចានយើញមុនអាឯងនេះទៀតផង ។

អាទិ ១ ឆ្លើយទៀនវិញថា: អាឯងគ្រាន់តែចានយើញ អញចាន
ដឹងមុនអាឯងនៅទៀត ។

អាពាំងពីរកំពុងតែជជែកគ្នា ជួនមានម្នាក់ទៀតមកដល់ អ្នក
ពាំងពីរយកអាគន្លុះ ឆ្លើជាចៅក្រមដំរេះក្តី ។ អ្នកមកថ្មីចូកបែបសម្លឹម
ចាប់ចើតលៀសរួចហុតអស់រលើង ចំណែកអាពាំងពីរនាក់ មើល
មាត់ឆ្លើក្អែកឡើងឡង់ ។ ហុតរួចហើយ ភនិយាយសំដី ចាង
ហ្វាងតាត់ក្តីថា: «នែ! ចៅក្រមកាតសេចក្តីថា: ត្រូវអាឯងពាំងពីរ
ចានសំចកលៀសមួយចំហៀងម្នាក់ មិនចាំចាប់បង់ប្រាក់ក្រឡាក្រម
ក្រាលចាតសាលាទេ ហើយទៅផ្ទះរៀងខ្លួនចុះ ឈប់ទាស់គ្នាទៀត »។

សូមពិចារណាមើលចុះ អ្នកកើតក្តីចំណាយប្រាក់អស់ប៉ុន្មានម្នាក់
កាលណា មានរឿងក្តីម្តង ។ ហើយតើតគួរមើល តើនៅសល់ប៉ុន្មាន
សម្រាប់ខុកចិញ្ចឹមកូនប្រពន្ធ ? អ្នកនឹងដឹងប្រាកដថា ចៅក្រមស៊ីប្រាក់
អស់រួច ខុកតែសេ្មាងនឹងគាសឲ្យអ្នកកើតក្តី ។

៣៦ -សេះធឹងបបក

រដូវសេ្រក ខ្សល់បក់មកត្រសៀក ។ សេ្មាក់តុងលាស់ខ្លី
ដែលពួកសត្វតាហន: ចាំងឡាយត្រូវចេញពីគ្រាលទៅសេ្មងជាចំណី ។

មានចចកមួយ ទើបចេញពីទីតឹកកកមក ជាន់ប្រទះសេះមួយដែលគេលែងឲ្យស៊ីស្មៅលស្មៅ ។ ជាន់ឃើញហើយ ចចកសប្បាយពេក ព្រោះវាអត់ចំណីយូរ ចចកនឹកថា : នេះជាមហាលាភមែន ខ្ញុំនៅតែជាន់យកទៅញុះទុកច្រាកជ ។ ហេតុម្តេចសេះនេះមិនទៅជាចៀមវិញ នោះចំជាប្រសើរ តែគោះជាយ៉ាងនេះ កំមុខជាជាន់ដៃអញឥឡូវហ្នឹងមិនខាន បើអីចឹងត្រូវប្រើប្រាជ្ញាបោកប្តូរធ្វើដូចម្តេចអេះ? គួរប្រើគំនិតបោកទើបប្រពៃ » ។ គិតដូច្នោះហើយ ចចកដើរចូលទៅសឹម ។ រួចនិយាយថា “ ខ្ញុំស្គាល់ច្បាស់ទូវាជាតំនឹងអាទុកាពព្រឹក្សា ក្នុងព្រៃនឹងក្នុងទឹកលំបាកប៉ុន្មានដែលអាចយកមកធ្វើជាថ្នាំតែកេតបាន ហើយមិនអួតទេ ខ្ញុំថែមទាំងចេះធ្វើគ្រូពេទ្យមើលជម្ងឺសត្វគ្រប់ទាំងអស់ផង ប្រសិនបើលោកសេះមានជម្ងឺ កុំលាក់បំបាំងខុក ខ្ញុំចចក សូមជាមានឹងមើលជូនដោយឥតយកថ្លៃ ព្រោះតាមច្បាប់គ្រូដែលប្រាប់សំគាល់មក លោកដែលគេលែងឲ្យទៅតែម្នាក់ឯងដូចបែបហ្នឹងប្រាកដជាមានជម្ងឺអ្វីមួយមិនខាន” ។

សេះឆ្លើយថា « ខ្ញុំមានបបូរមួយនៅជាតជើងមែន » ។

គ្រូពេទ្យចចកប្រាប់ថា; នែ! កូន! គ្មានកន្ទែងណាដែលឈឺជាងកន្ទែងហ្នឹងទៀយ បើអីចឹងខ្ញុំសូមមើលជូនត្រមាំងវែងផងដើម្បីជាឆាប់» ។

អាខ្ចប! ធ្វើតែកេតទុកាសឲ្យជាន់ស្រួលដើម្បីទាំសេះស៊ី ។ លុះចចកទៅដិតជើង សេះសង្ស័យក៏ធាក់ចំនឹងត្រូវមាត់ចចកខ្ចប ។ ចចក

ម្ដុំរស្អុយនឹកគិតថា តារណ៍នេះសមនឹងអាត្មាអញហើយ មនុស្សពាល់ប្លែ ត្រូវគិតតែឲ្យមានការរៀនខ្លួន អម្បាញ់មិញនេះ ឯងគិតធ្វើជាអ្នកកេញ្ចាំ ស្គាល់ឈើព្រៃ ឥឡូវមានក្លាយទៅជាសាប់ចំញ្ជាំទៅវិញ ។

៣៧- កញ្ជ្រោងបបកនឹងសេះ

កញ្ជ្រោងមួយទៅក្នុងទៅខ្សាយ ហើយបានប្រទះសត្វសេះជារលើកដំបូង មិនស្គាល់ជាសត្វអ្វី ពិតមែនតែវាជាពូជសត្វធាត ។ កញ្ជ្រោងប្រាប់បបកដែលទៅក្នុងដែរហើយនោតថា: « ចូរឯងរត់ទៅមើល មានសត្វមួយមកស៊ីស្មៅទៅទីវាលរបស់យើង រូបល្អហើយធំផង អញបានឃើញសត្វនោះមានចិត្តត្រេកអរសប្បាយណាស » ។

បបកសួរហើយសើចផងថា: « សត្វនោះធំជាងយើងទៅទៀតឬ ? អាណិតអញ ចូរឯងរៀបរាប់ឲ្យអញស្តាប់មើល » ។

កញ្ជ្រោងធ្វើយថា: « ប្រសិនបើអញជាជាងគំនូរឬសិល្បការនោះ អញនឹងធ្វើឲ្យឯងបានសប្បាយមុននឹងបានឃើញ បើអ៊ីចឹងមក ! តែមិនដឹងជាដូចម្ដេចទេ ? ប្រហែលសត្វនោះជាវត្ថុដែលទេពធ្វើឲ្យយើងទេដឹង ? » ។

កញ្ជ្រោងនឹងបបកនាំគ្នារត់ទៅ ចំណែកសេះដែលគេឲ្យស៊ីស្មៅទៅទីវាល ឮបបកឃើញ ឮបបកស្គាល់សត្វជាគូកនគ្នាតាំងពីរោះ ក៏ភ័យប្រុងនឹងស្ទុះរត់ចេញឲ្យឆ្ងាយ ។ ខណៈកញ្ជ្រោងស្រែកសួរថា: « សូម

លោកម្ចាស់អត់ទោស យើងខ្ញុំចង់ដឹង តើលោកព្រះទាមអ្វី?» ។

សេះមានប្រាជ្ញាដែរ គំនូរយប្រាប់ថា: «ថែអ្នករាល់គ្នាចង់ដឹង ឈ្មោះខ្ញុំ ចូរមើលចុះ ម្ចាស់ខ្ញុំបានចារទុកនៅដុំពែកក្រចកដើង» ។

កន្ត្រោងសួរសេះថា ដូនតាមិនសូវចេះអក្សរ ។ ក៏ប្រាប់ថា: «ឪពុកម្ដាយខ្ញុំ មិនបានឲ្យខ្ញុំទៅរៀន ព្រោះគាត់ជាអ្នកក្រខ្សត់ ហើយមានតែរូងមួយទុកឲ្យជាកើប៉ុណ្ណោះ ឪពុកម្ដាយលោកចចកជាអ្នកធំ មានមុខ មានមាត់ មានទ្រព្យច្រើន បានឲ្យកូនទៅសាលារៀនចេះអានសព្វគ្រប់» ។

បានឮសំដីបញ្ឆោតដូច្នោះ ចចកល្ងីល្ងើតក៏ស្មានដើរចូលទៅភ្លាម ការក្រអឺតមិនដឹងស្ងាប់ មានតម្លៃឆ្នេញ ៤ ជាថ្នូរ ។ សេះចាចមួយដើងរួចចោលទៅវិញ ។ ចចកដួលខ្ចោកហូរឈាមហាម ។ ឃើញដូច្នោះ កន្ត្រោងក្រាប់ថា: «នែបងចចក! នេះហើយជាសេចក្ដីពាល់ដៃលអ្នកប្រាជ្ញទំយាយទុងអញថា សត្វហ្នឹងចារទៅទុងក្នុងមចងឯងថា: របស់អ្វីដែលយើងមិនស្គាល់ត្រូវយើងប្រយ័ត្ន» ។

(នៅមានត)

រឿងសាមកុក

ឧកញ៉ាវិបុលកដសេនា ទួ - ភាន ប្រែរៀបរៀង

(តទៅ)

រឿងសាមកុកឧកញ៉ាយុទ្ធសាស្ត្រ
អ្នកវាងវៃនៃឆ្នាំសរបើបានអាន
នឹងរបៈនយោយកាលចំណាន
ទាំងមានសន្តានស្នេហាជាតិ ។

—— យួរ-អ៊ុន ——

ទីវៀតវៃជាទីប្រឹក្សាខាងចូតួ កំពុលភៀនយោយនឹងចូតួថា បណ្តា
នាហ្នឹនតាំងពួនដែលជាខ្ញុំកដការក្នុងព្រះចៅហៀនតេនោះ នរណានឹង
មានសេចក្តីគាប់ប្រសើរដូចមហាឧបកដនេះគ្មានសោះ គ្រានេះលោកប្រ-
កបដោយសេចក្តីឧស្សាហ៍ហាលខ្សល់ហាលថ្ងៃ លើកទ័ពទៅបង្ក្រាបបក្ខ-
មិត្រក្នុងព្រះរាជអាណាចក្រឲ្យរាបជាប ដើម្បីនឹងចំនុកចំរុងផែនដីព្រះចៅ
ហៀនតេឲ្យនៅជាសុខក្សេមក្សាន្ត អាណាប្រជានុកស្ត្រីតាំងពួនក៏មាន
សេចក្តីត្រេកអរណាស់នោះ ផែនដីព្រះចៅហៀនតេ កំត្រឡប់បរិ-
បូណ៌ចំរើនជាប្រក្រតីឡើងវិញ សេចក្តីគាប់ប្រសើររបស់លោកក្នុងគ្រានេះ
ក៏តែតែវិសេសខ្ពង់ខ្ពស់ជាងសេចក្តីគាប់ប្រសើររបស់លីបងដែលជាឧបកដ
របស់ព្រះចៅដងប៊ុនអងទៀត ដែលលោកនឹងតាំងនៅក្នុងទីមហាឧបកដ
ប៉ុណ្ណោះមិនសមគួរទេ សុំឲ្យលឿនទីឡើងជាអ៊ុយកុង គឺប្រកបដោយយស
៩ ប្រការទៀត ទើបនឹងសមតាមកិត្តិគុណដែលគាប់ប្រសើររបស់លោក។

ឯយស ៩ ប្រការនោះគឺ៖ ប្រការ ១- ត្រូវដំរេចចូលតាល់ទីមសេះ ៨, ប្រការ ២- ត្រូវតែងខ្លួនមានតួយ៉ាងដូចព្រះពជបុត្រហ្លួងឯកំ, ប្រការ ៣- ឲ្យមានតន្ត្រីត្រែស័ង្ខប្រគំតាមយាមព្រឹកល្ងាច ប្រការ ៤- ទីនៅឲ្យលាបដោយជាតិចន្ទ័លយ៉ាងដំណាក់ព្រះពជបុត្រហ្លួង ប្រការ ៥- ឲ្យមានផ្ទៃព្រះពេងជាទីចេញនិយាយពាក្យផ្តាំផ្ញើនាម៉ឺនតំាងពួង ប្រការ ៦- ឲ្យមានពួកគាហាន ៣០០ កន្លះអង្គ ប្រការ ៧- ឲ្យហែហមដោយក្បួនយ៉ាងស្តេចមានព្រះគាស(១) ប្រការ ៨- ឲ្យមានគាហានកាន់ដងសែងក្រៅក្នុងខ្វែងស្តាំដោយខ្លាត, ប្រការ ៩- ទីដែលទីណាកន្លែងណាឲ្យមានទៅភ្នាក់ងារទ្រនំដើងធូបហែចេញ ៧ ខាងមុខយ៉ាងហែស្តេច ។

ស៊ុនហុកថា ដែលទីវៀរៀនិយាយនេះ ខ្ញុំបានមិនយល់ឃើញផងទេ ឯមហាឧបរាជទីដែលធ្វើតាមនោះមិនសមគួរឡើយ ព្រោះតែដើមមហាឧបរាជបញ្ជាះបញ្ជូលប្រៀនបង្ហាត់សេនាគាហានតំាងពួង តំាងចិត្តនឹងស្នងព្រះគុណព្រះមហាក្សត្រឲ្យបានផែនដីជាសុខដោយសុចរិត ព្រោះថាជាខ្ញុំផែនដីរបស់លោកហើយ គោះបើជាមានសេចក្តីតាប់ប្រសើរដល់យ៉ាងណាក្តី ក៏គួរនឹងត្រៀមខ្លួនគោរពតាមទំលាប់ប្រពៃណីខ្ញុំនឹងម្ចាស់ ។

បពិត្រជូនោះ កំនឹកឯងខ្លាំងណាស់មុខមាំនៅ ។ ទីវៀរៀថា ការនឹងធ្លើហើយមានអ្នកមកឧទ្ធំងាស់ដូច្នេះ នឹងជឿស្តាប់តុំបាន ទើបតែងរឿងក៏វ៉ៃក្រាបបង្គំទូលព្រះចៅហៀនតេ សុំឲ្យបពិត្រឡើងជាទីអ៊ុយកុង ព្រះ

១- ពាសនេះប្រហែលជាពាក្យទេដឹងដែលមានន័យថាក្លៀងតួរឬត្រី ?

ចៅហៀនតេកំទ្រង់ព្រះរាជទានឲ្យតាមសុំ ។ ស៊ុនហុកដឹងដូច្នោះ កំ
ដកដង្ហើមធំហើយថា មិនដឹងថាការនេះដល់ម្ល៉េះចៅហើយ សេចក្តីនេះ
កំដឹងចៅដល់ចូឆួ ។ កំមានសេចក្តីតូចចិត្តថា ស៊ុនហុកនោះ គ្មានចិត្តនឹង
ចង់ជួយឲ្យយើងបានជាធំសោះ ។ ណានោះ ព្រះចៅហៀនតេសោយ
រាជសម្បត្តិបាន ១៧ ឆ្នាំ (ព្រះពុទ្ធសករាជ ៧៤៩) ជាទេសកាលវែកត្តឹក
ចូឆួក៏លើកកងទ័ពចៅវាយស្រុកកាំងតាង ព្រះចៅហៀនតេគ្រាស់បង្គាប់
ឲ្យយកស៊ុនហុកចៅក្នុងកងទ័ពផង ។

ស៊ុនហុកដឹងថា ចូឆួមានសេចក្តីទឹងនឹងខ្លួន ក៏ទឹកភ្នែកប្រាប់ថាឈឺ
ចៅមិនរួច ។ ចូឆួក៏ឲ្យយកថាសទេមានតម្របចិទ្ធបោះគ្រាប់ចាំ មើលដូច
ជាមានដាក់បៃស៊ុនចៅក្នុងនោះ ហើយប្រើមនុស្សឲ្យយកចៅជូនស៊ុន-
ហុក មានសរសេរជាអក្សរថា កុំឲ្យនរណាបើក ។ លុះស៊ុនហុកបើក
មើលក៏ឃើញតែថាសទេ ក៏ចូលចិត្តថា ចូឆួនឹងតតប្រឡូសក៏ឃាដល់ខ្លួន
ក៏មានសេចក្តីតោមនស្សលេបថ្នាំពិសស្លាប់ តាលស៊ុនហុកអនិច្ចកម្មនោះ
អាយុបាន ៥៥ ឆ្នាំ, ស៊ុនហ៊ិនជាកូនក៏ចៅដំរាបចូឆួ ។ មានសេចក្តីស្តាយ
ណាស់ ក៏ឲ្យប្រាក់មាសចៅតែងការសព ហើយចូឆួក៏លើកកងទ័ពចៅ
តាំងនៅជែនស្រុកយីស៊ូ ហើយប្រើចូហង៉ឃុំតាហាន ៣ មុំនលើកចៅ
ស្ទាត់លាតត្រដែតស្តាប់មើលកិច្ចការចាំងពួង ក៏ត្រឡប់មកប្រាប់ចូឆួវិញ
ថាចៅជាយទន្លេនោះ ឃើញមានទង់ដៃតហែគ្នាចៅជាច្រើន តែមិន

បានឃើញមនុស្សតាំងនៅត្រង់ទីណា ចូធ្លកំមានសេចក្តីសង្វែយមិនខុកចិត្តដល់ពាក្យការ កំឲ្យលើកតាហានស្រូតទៅតាំងនៅដំបន់មាត់តាមយើស្ទឹ ហើយឃុំនាំតាហានឯកប្រមាណ ១០០ ប៉ាយ ឡើងទៅមើលលើកំពូលភ្នំ ឃើញគូកចម្ការឯកតង់ទ័ពស៊ុនគួន មកតាំងនៅខាងត្រើយម្ខាង ឯស៊ុនគួននោះតែងខ្លួនចាំងសប្បាធនះ។ មានតាហានចាមកោមធ្វើស្តាំដោយក្បួន ។ ចូធ្លថា នរណាមានកូនដូចស៊ុនគួនទេះ កំគួរកប់អានថាល្អណាស់ ដែលមានកូនដូចឡៅចុងនោះកំដូចគ្មានទេមិនជាប្រយោជន៍។

ចូធ្លថាមិនខានផុតមាត់ ខ្លួលតាហានស៊ុនគួនដែលតួនទៅក្នុងស្មាមភ្លោះនោះបានការក៏ស្រែកហៅលើកខ្លួបតីក្រោយចូធ្លឡើងទៅ សុនគួនកំដេញតាហានចែវគូកចូលទៅស្តាត់ផ្លូវតាមមាត់ព្រៃក ។

ចូធ្លឃើញដូច្នោះភ័យណាស់ ស្រែកឲ្យតាហានចូលច្បាំង ចំណាយចេញមក ទៅធ្លកំចាំការពារមិនឲ្យអន្តរាយនាំចូធ្លចូលបន្ទាយ ខ្លះនោះ ចូធ្លកំឲ្យចំណាចំរ៉ាន់ទៅធ្លាប់ច្រើន ។ លុះវេលាប្រហែលយាម ២ ស៊ុនគួនកំឲ្យតាហានចូលរណ្តំវាយ ចំណាយបន្ទាយចូធ្ល ដុតភ្លើងនេះឡើងគាចចូលបន្ទាយបាន ហើយតាចំតាហានចូធ្លស្ទាបរំនាសជាច្រើន ចូធ្លក៏បែកថយទៅតាំងនៅផ្លូវប្រមាន ៩០០ សិន (២០ គ.ម.) ។ ធ្វើយ៉ុកជំកបចូធ្លថា ព័ដើមមហាទបាជនីធ្លើកទ័ពទៅកាយដំបន់ទីណា ខ្លីធ្លចាំទៅចាំមកចិដូចជាគ្រានេះគ្មាន រាមធ្លបង្គុំតាហានឲ្យស្រូតតួតទៅយ៉ាង

រហ័សណាស់ សត្រូវមិនទាន់ដឹងខ្លួនទឹងចាត់ចែងការពារខ្លួនបាន ក៏មានជ័យជំនះសត្រូវដោយងាយ គ្រានេះមហាទេពជាលើកកងព័ពមកបណ្តែតបណ្តោយឲ្យយឺតយូរណាស់ ដូចជាមិនទុំឲ្យបានការ បានជាស៊ុនគួនដឹងខ្លួន រៀបចាត់ចែងការពារជាមាំមួន បានជាយកជ័យជនះមិនបានត្រឡប់ជាពាក្យប្រៀបគេទៅវិញ ដែលមហាទេពជនឹងគិតធ្វើការគេទៅតែបើយ៉ាងដូច្នេះឃើញជាមិនបានឡើយ សុំឲ្យលោកលើកទ័ពត្រឡប់ចូលក្រុងវិញចុះ ដើម្បីប្រោះព្រំនាហានឲ្យមានចិត្តក្លាហាន សឹមលើកមកធ្វើការជាថ្មីតទៅទៀត ខឹងបានការជាមាំមួនមិនសៀបប្រៀបដូច្នេះ ។ ចូរឆ្លើមិនតបថាម្តេច ។ ធឿយ៉ុក កំត្រឡប់រំលេទៅវិញ ។ ចូរឆ្លេដកលក់នៅកងនៃថ្ងៃនោះ យល់សប្តឃើញថា បានឮសម្លេងរលេកកងនៃផ្ទៃមហាសមុទ្រ ចោកបក់គឹកកង ដូចសម្លេងមនុស្សអឺងឺខ្ទៅ ក៏ក្រោកចេញទៅមើលឃើញព្រះអាទិត្យមួយដួងផុសរះឡើង ពីកណ្តាលផ្ទៃសមុទ្រ មានរស្មីដិបរស្មុខថ្លា ហើយឃើញព្រះអាទិត្យ ច្រាតជទៅលើអាកាសពីរដួងនឹងព្រះអាទិត្យដែលផុសពីផ្ទៃមហាសមុទ្រនោះ ទៅឆ្ងាត់ចុះទៅមុខបន្តិចយូចូរឆ្លេក៏ភ័យភ្ញាក់ឡើង ខ្លួលមានមនុស្សចូលទៅជំរាបថាវេលាថ្ងៃត្រង់ហើយ ចូរឆ្លេគិតថា យល់សប្តនេះនឹងជាប្រការម្តេច ទើបចាត់ចែងតាហានសេះ ៩០ ចេញទៅមើលនៅមុខបន្តិយ ។ ខ្លួលក្រឡេកឃើញស៊ុនគួនចាំងសប្បធនមាសតែងខ្លួនពាក់គ្រោះមាស លើកតាហានមកតាមលើកំពូលភ្នំ។ ស៊ុនគួនក៏ក្រឡេកទៅឃើញចូរឆ្លេ ទើបឲ្យបញ្ឈប់តាហាននៅទីនោះ

ហើយគិយកសៃចង្អុលទៅត្រង់ចូនទូថា មហាឧបាសិកាជាធំនៅក្នុងស្រុកក្រុងប្រុកបដោយយសស្រឹង្គារបរិវារជាច្រើន មានសេចក្តីសុខបីដូចទៅនៅក្នុងវិមានទិព្វហើយ តួរឬនៅមិនជាន់តេញចិត្តឆ្អែតចិត្ត លុះដោយអំណាចនៃសេចក្តីលោភទុច្ចរិត មិនបានតិត្រោះតិចារណា ដោយបញ្ញាជាធម៌ លើកគាហានមកតេញចូចារ ដើម្បីតែនឹងបៀតបៀន ធ្វើឲ្យគេវិនាសដោយពាលាការរបស់ខ្លួនមិនសមគួរឡើយ ។

ចូនទូតបថា ដែលយើងលើកទំមកជាងនេះ មិនមែនឧធ្លាមានសេចក្តីច្រណែនឡើយ តែថាព្រោះខ្លួនអ្នកនៅក្នុងដែនដីនៃព្រះចៅហៀនតេជាអម្ចាស់ ហើយមិនមានសេចក្តីគតញ្ញូធ្លាស្តេចជាម្ចាស់ត្រឡប់ក្រឡាស់មិនចំណុះចុះចូលតាមការប្រវែណី ហើតុនេះទើបព្រះចៅហៀនតេត្រាស់ប្រើឲ្យយើងលើកទំពាមកបង្ក្រាបពួកបច្ចាមិត្រ ដើម្បីនឹងចាប់យកទៅប្រហារដ៏តែតាមទោសានុទោស ស៊ុនគួនសើចហើយថា មហាឧបាសិកាចារាខេះ ដូចជាមិនមានសេចក្តីគិតខ្វាស់សោះព្រោះខ្លួនយើងនៅក្នុងដែនដីព្រះចៅហៀនតេត្រាកដ យើងក៏មិនមែនជាក្សត់អកតញ្ញូសោះឡើយ ពាក្យដែលយើងពុមកហើយថា រូបដែលជាក្សត់ធឧព្រះចៅហៀនតេនោះ ចំពោះលើខ្លួនអ្នកឯងវិញតើ ដែលកន្លងព្រះមហាក្សត្រគិតតែនឹងបំបាត់ស្តេច គេចដណ្តើមយកដែនដីដើម្បីខ្លួន ជាន់ជាយើងមានសេចក្តីកតញ្ញូឈឺជួសដែនដី គិតធ្វើការនេះដើម្បីតែកំចាត់សត្រូវដែនដីឲ្យអស់ចេញ ។

(នៅមានត)

រឿងព្រេងជាតិ

លោក ភ៉ាយ - ប៊ុក ប្រែរៀបរៀង

(តទៅ)

ថ្ងៃមួយ កុមារឡៅសានបានយកត្រីទៅលក់ឯផ្សារ ក្មេងមិនបានយកកូនត្រីឆ្កែនមាសទៅជាមួយផង ។ ដល់ពេលត្រឡប់មកវិញ កូនត្រីឆ្កែនមាសនោះបាត់រកមិនឃើញ ។ ឡៅសានធ្លាប់តាន់ពេក អង្គុយសម្រក់ទឹកភ្នែក ទៅពីមុខអាងទឹកស្ងាត់ឯណេះ ព្រោះកូនត្រីឆ្កែនមាសបាត់ . . ។

ពេលអាណារៈថ្ងៃមួយ កុមារឡៅសានបានទៅស្ទូចត្រី អង្គុយក្រោមដើមជ្រៃតិនត្រាលក់នៅទីនោះ ដោយមានព្រះភាយបក់ផាត់រំភើយ ។ ទឹងសព្វសូវរលកទឹកដូចជាក្មេងរណ្តាំគ្នាជាសុខដុមរមនា ។ ពេលនោះ កុមារឡៅសានក៏ឮសូរសំឡេងមនុស្សម្នាក់ហៅ ហើយបើកភ្នែកមើលឃើញកុមារម្នាក់អាយុប្រហែលគ្នា បានគោះស្មាហើយពោលថា: «ឧប្បន សម្លាញ់អើយ! អូនឯងស្គាល់បងឬទេ ?»

កុមារឡៅសានងឿងឆ្ងល់ ព្រោះខ្លួនគ្មានបងណាសោះឡើយ ។ តែកុមារនោះបានធ្វើយតបមកម្តងទៀតថា :

«អូនមិនស្គាល់បងទេឬ បងជាតណ្ឌាណម៉ាក្តូនឆ្កែនអូន! អូនជាបុព្វការីនៃបង! » ។

ឡៅសានងាកទៅមើលកុមារនោះ ហើយមានចិត្តកាន់តែឆ្ងល់ពន់ពេក ។ ទើបកុមារនោះពោលជាថ្មីថា : «ខ្ញុំនេះឯងជាកូនត្រីឆ្កែនមាស កូន

ត្រីដែលប្អូនឯងបានដួយសង្គ្រោះឲ្យបានរស់ពន្ធមានជីវិត ហើយដែលប្អូនឯងបានយំយកទៅតាមប្អូនឯង កន្លងពេលធ្វើដំណើរ ទៅស្ងួចត្រីឬទៅមើលល្ងាចជាដើម . . » ។

កុមារឡៅសាន គាលបើបានស្តាប់ខ្លួវាចានៃកុមារនោះ ទើបយល់ដាក់ប្បាស់ថា កុមារនេះជាកូនត្រីឆ្កែនមាសបានតាឃ្យាខ្លួនជាមនុស្ស ។

កុមារនេះ ជាបុត្រកុដន្ធនាគ ។ ស្តេចនាគចាំងឡាយនៅឯបាតាលឯណោះ ។ មានថ្ងៃមួយ ព្រះកដបុត្រនេះបានទិម្តិតខ្លួនជាកូនត្រីឆ្កែនមាស ត្រេចលេងកំសាន្តសប្បាយតាមដងស្ទឹង តែទៅដល់ទីកន្លែងនោះស្រាប់តែមានត្រីធំមួយលេបបាត់ទៅ គឺត្រីដែលកុមារឡៅសានស្ងួចបាននោះ . . . ។

ព្រះកដបុត្រស្តេចនាគពោលបន្ថែមថា: « ប្អូនឯងបានដួយសង្គ្រោះបងឲ្យមានជីវិតឡើងវិញ បានឲ្យទៅគេហដ្ឋានសុខស្រួល ឲ្យមួបអាហារបរិភោគផ្អែមស្ងប់ស្ងល់ . . ព្រះបិតាខ្ញុំនឹងខ្ញុំមិនភ្លេចនូវគុណបកាដំលើសលុបនោះទេ ហេតុដូច្នេះ ទើបព្រះបិតាឲ្យខ្ញុំ មកអញ្ជើញប្អូនទៅលេងកំសាន្តសប្បាយឯព្រះបរមកដរាំងសម្តេចព្រះបិតាខ្ញុំឯណោះ » ។

កុមារឡៅសានក៏ក្រាបបង្គំទូលព្រះអង្គម្ចាស់ថា: « តើទូលបង្គំអាចទៅក្រាមទឹកបានឬ ? » ។

ព្រះអង្គម្ចាស់ទ្រង់មានបន្ទូលថា: « បូរអូនឯងឆ្លងកែកហើយយក

ដៃកាន់អាវុធរួចដើរតាមមក ។ ។

កុមារឡៅសានក៏ធ្វើតាមបន្ទូលព្រះពុទ្ធបុត្រនាគ ។ នៅស្ពានក្រោម កុមារឡៅសាននេះ ឃើញផ្លូវមួយធំ ហើយខាងចុងផ្លូវមានព្រះបរមពុទ្ធរូបស្ពែកកុដន្តនាគចាំងរស្មីភ្លឺសន្ធោសន្ធៅលេចឡើងជាទីអស្ចារ្យ។ ឡៅសានទៅដល់ឃើញសសរនៃព្រះបរមពុទ្ធរូបនោះ រចនារំលេចដោយកែវចរណៃក្រហម ជញ្ជាំងស្ពាធនាដោយកែវចរណៃលឿង ហើយដំបូលដោយកែវចរណៃបៃតង ។ គេក្រឡេកទៅឃើញព្រះបរមពុទ្ធរូបនោះមានពន្លឺភ្លឺស្វាងរុងរឿងត្រចះត្រចង់ពន់ពេក ។

កុមារឡៅសានទៅដល់ព្រះបរមពុទ្ធរូប ក៏ចូលទៅថ្វាយបង្គំគុដន្តនាគ ។ ស្ដេចនាគ ទ្រង់សព្វព្រះពុទ្ធហឫទ័យពន់ពេកនឹងកុមារឡៅសាន ទ្រង់ឲ្យបញ្ជាឲ្យរៀបបន្ទប់មួយស្អាតល្អសម្រាប់កុមារស្ថិតនៅ ហើយឲ្យគេយកមួបចំណីឈ្មួយឆ្ងាញ់មកឲ្យឡៅសានបរិភោគ ។ ព្រះអង្គម្ចាស់ទ្រង់មកនាំកុមារឡៅសាន ត្រាច់លេងកំសាន្តសប្បាយតាមព្រះពុទ្ធដែលមានផ្លែឈើគ្រប់បែប - យ៉ាង ទឹងបុប្ផាផ្សាយគន្ធពាសោរល្អយល្អប់ណាស់ ។ មានផ្លែគូលេនឥតគ្រាប់ ហើយមានរសជាតិផ្អែមពិសាណាស់ មានផ្លែមៀនមានសាច់ធំប្រហែលនឹងពែងតែ មានដើមចេកនឹងប៉ែស(១)ដុះយូរណាស់មកហើយ ។ ក្រៅពីនេះ នៅមានវត្ថុប្លែកអស្ចារ្យជួបជាវត្ថុធម្មជាតិដែលស្ថិតនៅស្ថានមនុស្សលោកដែរ ។

១- ប៉ែសជាដើមព្រឹក្សខាងអ៊ីរ៉ុប ផ្ទៃសឿងស្មុកពណ៌ខ្លឹចប្រពេញភាគតែសាច់ទន់រស់ជាតិផ្អែម.

ក្រោយដែលបានស្តេចទៅនាស្ថានកុដង្គនាគអស់រយៈវេលា ១ ថ្ងៃ ខ្លៀសានក៏ក្រាបបង្គំទូលព្រះអង្គម្ចាស់ថា :

« ទ្រង់ព្រះមេត្តា ! ទ្រង់មានព្រះរាជហឫទ័យដ៏សប្បុរសជាអនេកប្បការ ចំពោះខ្ញុំបង្គំ ក៏ប៉ុន្តែ ខ្ញុំបង្គំគ្មានអ្នកណានៅផ្ទះសម្បែងថ្ងៃ ។ ឥឡូវនេះ ខ្ញុំបង្គំ សូមវិលត្រឡប់ទៅវិញ ទៅថ្ងៃស្អែកតើព្រះមេត្តាទ្រង់មានព្រះរាជហឫទ័យយ៉ាងណា ? » ។

កូនស្តេចកុដង្គនាគ ទ្រង់មានព្រះបន្ទូលតបទៅកុមារខ្លៀសាន ថា ! « អូនអញ្ជើញទៅចុះតាមចំណង តែអូនកុំភ្លេចទៅមកសួរបងផង ។ ចូរអូនស្តាប់បណ្តាំបងឲ្យច្បាស់ បើព្រះវរបិតាបងទ្រង់មានព្រះរាជឱង្ការសួរអូនអំពីសារៈវត្ថុដែលអូនចង់បាន ចូរអូនក្រាបបង្គំព្រះវរបិតាបងថា អូនចង់បានតែមាន់ញីសមួយប៉ុណ្ណោះ » ។

ដល់ថ្ងៃស្អែក ពេលព្រឹក កុមារខ្លៀសាន ក៏ចូលទៅក្រាបថ្វាយបង្គំលាស្តេចកុដង្គនាគ ។ មុនឡើងឲ្យខ្លៀសានចេញដំណើរទៅ ព្រះអង្គទ្រង់នាំកុមារខ្លៀសានដើរទៅខស្សនាព្រះរាជទ្រព្យគ្រប់យ៉ាង ហើយទ្រង់មានព្រះរាជឱង្ការថា :

« ឧបុត្រសំឡាញ់អើយ ! ចូរនាងជ្រើសរើសព្រះរាជទ្រព្យ ដែលនាងគេញចិត្ត បីតាន់ឯងឲ្យនាងតាមចំណងទាំងអស់ កុំនាងភ័តញញើតអ្វីសោះឡើយ » ។

(នៅមានត)

តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

ទំនៀមទម្លាប់ នៃទេមរជាតិ
ខ្មែរគួរខ្មីឃ្នាត សិក្សាពេញទី ។
ព្រោះទេមរជាតិ ជាជាតិសោភ័
ក្នុងទ្វីបអាស៊ី តាំងពីព្រេងនាយ ។

ប. ព.

អំពីវុក្ខជាតិព្រៃដែលមានឧស

លោក ជួន - សៀង មៃ ខ្មែរលើ
ធ្វើការនៅសាលាខេត្តស្វាយរៀងរៀបរៀង

មុននឹងខ្ញុំចាប់យកដងចាំកាមកសម្រក់ខ្លឹតខ្មៅ ទៅលើក្រដាសកាលណា ខ្ញុំសូមលោកអ្នកមេត្តាចំណាយពេលប្រាំនាទី ដើម្បីអានខ្លួវដំខឿនឹងទំនៀមទម្លាប់នៅស្រុកវបស់ខ្ញុំ ដែលជាស្រុកមួយនៅឆ្ងាយអំពីភជនានីក្តៅពេញ ។

ប៉ានជាខ្ញុំហ៊ានពោលដូច្នេះ ព្រោះខ្ញុំយល់ថាវុក្ខជាតិព្រៃ គឺជាវុក្ខជាតិមួយដ៏ប្រសើរយ៉ាងធំណាស់ មានផលប្រយោជន៍អាចជួយសង្គ្រោះដល់មនុស្សនៅតាមជនបទឆ្ងាយអំពីទីក្រុង ដែលអាចយកវុក្ខជាតិព្រៃមកប្រើការផ្សំធ្វើជាថ្នាំសម្រាប់សម្ងាប់សត្វកាចបានផង ទឹងជួយសង្គ្រោះមនុស្សផង ។ នេះមកពីការពិសោធន៍វបស់ខ្ញុំធ្វើឲ្យឃើញពិត ខុកឲ្យតែខ្មែរលើវបស់ខ្ញុំកាន់តាម ដើម្បីជាទំនៀមទម្លាប់រហូតមកដល់ សព្វថ្ងៃនេះពិតប្រាកដ ។

ហេតុបណ្តាលមកពីអ្នកចាស់ទុំខ្មែរលើកខាងមុខ ហាមយកកត់ស្តុតាងខាងរុក្ខជាតិព្រៃមកធ្វើជាចំណែមទម្លាប់ទុកមកដល់សព្វថ្ងៃនេះ តើពិត្រោះរុក្ខជាតិព្រៃមានផលប្រយោជន៍ ជួយដល់ក្រុមខ្មែរលើខាងស្រុកខ្ញុំជាច្រើន ហេតុនេះបានជាខ្ញុំចំណាត់ចង្រៀនកូនចៅឲ្យបានចេះឲ្យបានដឹងថា រុក្ខជាតិព្រៃឲ្យផលល្អ តែក្រឡត់ណាស់តិចបានកេរ តែលុះត្រាតែមនុស្សខ្មែរចំរើនចេះច្រើនណាស់ទើបបានដឹងនូវរុក្ខជាតិមានតម្លៃ ។

ប្រសិនណាជាមនុស្សយើងតាំងអស់គ្នាចំរើនកេរធ្វើការពិសោធន៍នេះឲ្យមែនទែន ប្រហែលជាខ្មែរយើងអាចផ្សំថ្នាំអ្វីមួយបានយ៉ាងពូកែ ហើយអាចយកមកដាំជារុក្ខជាតិស្រុកឲ្យបានចំរើន មានផលល្អតណាស់ល្អ នឹងអាចជួយផ្តល់សេដ្ឋកិច្ចជាតិយើងខ្លាំងផង ព្រោះការរៀនកម្មាំនេះ ដូចជារយើងរៀនដាំស្វ ឱសាលារៀន ព្រោះការរៀនកាប់ដើរៀនដាំដំណាំអាចធ្វើឲ្យយើងចេះកេស៊ី កាលបើយើងចេះកេស៊ីហើយយើងក៏អាចចេះផ្សំថ្នាំជួយដំណាំដាំដុះយើងឲ្យបានផ្លែផ្កាល្អដែរ ។

តែបើលោកអ្នកនៅមានសេចក្តីងឿងឆ្ងល់ អំពីរឿងរុក្ខជាតិនេះខ្ញុំសូមអធិប្បាយជូនស្តាប់ ដូចខាងក្រោមនេះ :

រុក្ខជាតិនោះឈ្មោះរុក្ខជាតិអ្វីទៅ ដែលអាចឲ្យផលប្រយោជន៍ជាងគេ គឺឈ្មោះដើមដំរេកំ ។ ដើមដំរេកំនេះមានពីរយ៉ាង :

ទី១ ដើមកាងមូលដូចកាងដើមចំប៉ា កំពស់កាមានពីជួនម៉ែត្រ ឬ

ត្រាំមែ្រត្រឡើងទៅលើ សំបកវាមានសម្បុរដូចគ្នាទឹងសំបកផ្លាចំប៉ាដែរ ឫសវាមានបី គឺ: ឫសទី ១ ហៅថាឫសរយោង, ឫសទី ២ ឈ្មោះឫសចិញ្ចឹមដាត់ ឫសទី ៣ ហៅឫសកែវ ឫសកែវនេះវែងជាងគេ ហើយដុះចាក់ជ្រៅត្រង់ទៅក្រោម សំបកវាមានសម្បុរដូចសំបកត្រចៃកយើងដែរ ស្វឹកវាពងល្អិត ។ ដូចជាផ្លាចំប៉ា តែពងមូលខ្លី ។ ផ្លាវាស្រដៀងទឹងផ្លាកូឡាបសដូចគ្នាទាំងអស់ ផ្លែវាមូលដូចផ្លែត្រចៃកតូច ។ ហើយល្អិត ។ គ្រាប់វាខ្មៅរលោងដូចជាគ្រាប់សណ្តែកបាយ ។

ទី ២ ដើមវាជាវល្លិ៍ មូលតូចវែងមានកំពស់ប្រវែងពី ១០ម ឡើងទៅលើ ស្វឹកវាវែង ។ ដូចជាស្វឹកចំប៉ី ផ្លាវាស ដូចផ្លាទឹកដោះគោ ដើមវាដូចគ្នាទឹងដើមចំប៉ីទាំងអស់ ផ្លែវាវែងដូចគ្នា គ្រាប់វាដូចគ្នាទឹងគ្រាប់ក្សេត ។ ដើមរុក្ខជាតិនេះច្រើនដុះនៅព្រៃកំគាមវាលធំ ដែលពុំសូវមានគេចូល ។

តឺដូចជាស្រុកសៀមប៉ាង - ចាន់ឌុះ-សៀមហួង-ណាអូង-ព្រះអង្គាល់ កោះតឺ - ឈើគាល - អូរស្វាយ កោះស្រឡាយ - កាំងមេម៉ាយ - សៀមបួក-ស្រែក្រសាំង - កាំងដេសរ - ខេះ - កញ្ចាញគោក - តំកុន - ថ្លាបរាំត់ - តែងជាវ - ប៉ួយ - តិរវែង្ហា ហាងខូសួន - ហាងខូចាន - ប្រជុង - ដើងប្រចាត - ឫទាំ ។ល។

ដើមដ៏វែងគ្រាន់នេះ មុនដំបូងគេត្រូវស្មោះដើមដែលមូលធំនោះយកសំបក

មកកាប់ជាកន្លះ ។ ឲ្យល្អិត ឯដើមវល្លិ៍គេកាត់ឲ្យខ្លី ។ ដំឲ្យខ្លះ ទើបគេយកថ្នាំងជាក់ទឹកពេញ គេមង្គាត់ក្តៅឲ្យនេះ ហើយលើកថ្នាំងនោះជាក់ខ្ទៅក្នុងដើងក្រានោះទៅ ទើបគេស្រាវចំនួនដប់ទឹក លុះត្រាតែទឹកនោះរលីហើយចេញដំខាប់ រួចគេចាក់ទឹកម្ពីងខ្លះបានគេយកក្បាលពស់វែកក្បាលពស់ថ្នាន់ នឹងផ្លែឈើមកជាក់ផ្សំឲ្យទាល់តែបានខាប់ឡើងខ្លាំ បានគេយកបន្លះប្តូសមកចូកជាក់ទៅក្នុងចំពង់ ។ លុះបានហើយ ទើបខ្ញុំចាប់យកថ្នែមួយមក រួចយកចុងកាំបិតបន្ទោះលាបដំរទៅចុងកាំបិត រួចខ្ញុំចាក់ទៅចំក្បៀថ្នែនោះ ទើបខ្ញុំលែងវាឲ្យតែ ថ្នែនោះតែបានចំនួន ២ម កំដួលដេកស្លាប់មួយរំពេច ។ ចុះមកពីអ្នកបានជាវាស្លាប់ ព្រោះមកពីដំរនោះវាមានដំរលោយពិសដោយផ្សំថ្នាំគ្រប់មុខ ដើម្បីឲ្យវាញ៉ាយកឈាមវិលមុខស្លាប់ ។ នេះខ្ញុំបានពិសោធយើញពិត ។ ការពិសោធន៍នេះហើយដែលនាំឲ្យអ្នកស្រុកខ្ញុំតែងចិញ្ចឹមដំរតែ ទៅពេលដែលគ្មានត្រីហើយនឹងការសង់ទៅរបស់ខ្មែរលើខ្ញុំនេះផង ព្រោះក្លែងជាតិព្រៃនេះមានផលប្រយោជន៍មួយបែប គាចទុកឲ្យអ្នកស្រុកខ្ញុំជាខ្មែរលើកាន់ទុកជាំនៀមទម្លាប់ រហូតមកដល់សព្វថ្ងៃនេះ ។ ខ្ញុំសប្បាយចិត្តណាស់ដោយបានកេរយើញនូវការពិសោធន៍ក្លែងជាតិព្រៃ ដែលមានផលប្រយោជន៍ដួយចិញ្ចឹមមនុស្សយើងសព្វថ្ងៃនេះ ។ ហេតុដូច្នេះហើយបានជាអ្នកស្រុកខ្ញុំគេកាន់ជំនៀមទម្លាប់នេះទុក ព្រោះខ្លាចកូនចៅខាងក្រោយគ្មា

មិនបានដឹងការពិសោធន៍, ត្រូវតែទុកឲ្យវាកាន់ឲ្យវាចេះដឹងផងនូវក្តីជាតិ
មានផល ត្រចាំបែបត្រង់យ៉ាងពាំងអស់ ។

ជាពិសេស សូមលោកអ្នកអានពាក្យឃ្លោងរបស់ខ្ញុំនៅខាងក្រោមនេះ :

កូនចៅប្រុសស្រី ចូរកុំបំភ្លៃ មើលងាយចំណាំ
បើយើងខំរៀន ទុស្សាហ៍ហត្ថកម្ម
ទំដាំដំណាំ ជាប្រាំពូកែ ។
ដូចជាឈើព្រៃ បើយើងចេះលៃ
ខ្លះអ្វីស្រុកខ្មែរ យើងចេះរៀនវាក យកមកកែប្រែ
អាចឲ្យពូកែ ជួយខ្លួនយើងបាន ។
យើងត្រូវអប់រំ កុំគាប់រំលំ ឈើពាំងប៉ុន្មាន
ព្រោះឈើនេះហើយ គ្នាទៅក៏ជារុក្ខា
ទុកជាបូកណា ទំនៀមទម្លាប់ខ្មែរ ។

ជំយ ជំនះ ដោយ យុត្តិធម៌ របស់ ខ្មែរ នៅ តុលាការ អន្តរជាតិ

អំពី រឿង ព្រះ វិហារ

អារម្ភកថា

យើងមានសេចក្តីរីករាយនឹងរួបរួម នូវជ័យជំនះយ៉ាងខ្លាំងពេញ សាកលលោករបស់ខ្មែរយើងក្នុងរឿងក្តីក្បាលទ្រព្រះវិហារ ដែលជាកេរ្តិ៍ដំណែលនៃបុព្វបុរសខ្មែរយើង ហើយដែលថៃបានរំលោភយកទៅដោយកម្លាំងចិត្ត ក្នុងឆ្នាំ ១៩៥៤ ។

ការលែងត្រឡប់ចូលមកកម្មជារបស់យើងវិញ នៃបុរាណវត្ថុដ៏មានតម្លៃនេះ ប្រវត្តិសាស្ត្រពុំអាចនឹងបំភ្លេចបានទេ ព្រោះបូជនីយដ្ឋាននេះជាសម្បត្តិប្រសើរបំផុតនៃប្រជាជាតិខ្មែររបស់យើង ។ ជោគជ័យនេះជាជោគជ័យអន្តរជាតិ ហើយជាលទ្ធផលក្រោមការដឹកនាំដ៏ភ្លឺស្វាងនៃសម្តេចព្រះនរោត្តម សីហនុ ព្រះប្រមុខរដ្ឋខ្មែរ ។

ស្ថាព្រះហស្តដ៏ឆ្នើម ក្នុងការប្រមូលមតិនូវបេតិតភ័ណ្ឌដោយគ្មានបង្ហូរឈាមនេះ បានបញ្ជាក់ឲ្យសាកលលោកឃើញយល់ច្បាស់ណាស់ទៅទៀតថា: ព្រះអគ្គមគ្គុទ្ទេសក៍ខ្មែរ ពិតជាស្រឡាញ់សន្តិភាព ហើយស្អប់ខ្ពើមសង្គ្រាមជាទីបំផុត ព្រមទាំងគ្មានប្រថុម្ភអ៊ូក្រៅពីរួមរស់នៅដោយសន្តិវិធីជាមួយនឹងប្រទេសជិតខាងឡើយ បើប្រទេសទាំងនោះមានការគោរពដល់ឯកភាពរបស់ខ្លួនដែរ នឹងបូរណភាពនៃដែនដីប្រទេសកម្ពុជា ។

ដើម្បីជាអនុស្សាវរីយ៍ ចំពោះព្រះកាដំណើរស្តេចយាងទៅធ្វើបុណ្យ
គោរពនមស្សការចំពោះព្រះតុម្ពបដិមាករ នៅលើប្រាសាទព្រះវិហារជា
លើកដំបូង នៅថ្ងៃទី ៩ ខែមករា ១៩៦៣ នោះ ក្រសួងយោសនាការជាតិ
ធ្វើតេតាសនេះចាត់ផ្សាយជាសាធារណៈ ដើម្បីនឹងឲ្យជាគោលលក្ខ
ណៈក្នុងសាវតារជាតិតទៅ ។

អត្ថបទនេះបានដកស្រង់ពីអត្ថបទជាតិនិយម


និពន្ធដោយ សហជីវិន ហ៊ឹ - ឆឹម

បញ្ហាព្រះវិហារ

ខ្មែរយើងទទួលជ័យជំនះជាលើកដំបូងនៅតុលាការអន្តរជាតិ

អំពីរឿងព្រះវិហារ

បងប្អូនអ្នកអានទាំងអស់នៅចាំបានថា ពាក្យបណ្តឹងដែលពាជវង្ស-
កិច្ចខ្មែរយើង ចានប្តឹងទៅតុលាការអន្តរជាតិអំពីប្រាសាទព្រះវិហារ
ដែលជាកេរ្តិ៍ដំណែលពីដូនតាខ្មែរយើង ដែលពាជការថៃឡន់ដ៏បានយកទ័ព
មកជាត់នៅទីនោះ ហើយរឹបអូសយកទៅធ្វើជាប្រាសាទនឹងទឹកដីរបស់
គេដោយកម្លាំង បងប្អូនអ្នកអាននៅជាច់ស្រយាលពីខ្មែរជុំជន ដែល
សុម្មេងវិទ្យុពុំបានបន្ទឺទៅដល់ នឹងនឹកឆ្ងល់ថា « តើរឿងព្រះវិហារ
នោះដល់ណាហើយ ។



ជណ្តើរថ្មឡើងទៅកាន់ភ្នំប្រាសាទព្រះវិហារ ផ្នែកខាងប្រទេសកម្ពុជាយើង

១- ជាបឋមយើងត្រូវអរយ៉ាងក្រៃលែង ដែលជនបរទេសនឹងជឿថា ខ្មែរយើងបានខ្ពស់ជ័យដ៏ខ្ពង់ខ្ពស់ជាលើកទី ១ នៅតុលាការអន្តរជាតិហើយ ។

២- មិត្តអ្នកដែលតាំងសួរតាមរឿងនេះហូរហែ ដែលនឹកឆ្ងល់ថា ហេតុដូចម្តេចបានជាមានពាក្យថា ជ័យជំនះទីមួយ ? ។

បានជាយើងពោលថា ជ័យជំនះនេះជាទីមួយ ព្រោះតាមនីតិវិធីនៃតុលាការអន្តរជាតិ តួតំណាងនីតិប្រទេសថៃឡង់ដ៏បានប្រើមធ្យោបាយជាដំបូង គឺប្តឹងជំទាស់ជាបឋមដើម្បីបដិសេធសមត្ថកិច្ចនៃតុលាការអំពីរឿងព្រះវិហារយើងនេះ ។ បើពោលម្យ៉ាងទៀតថា ប្រទេសថៃឡង់ដ៏បានតវ៉ាជាលើកដំបូងថា តុលាការអន្តរជាតិគ្មានសមត្ថកិច្ចអ្វីនឹងជំរុះរឿងវិវាទអ្វី ដែលកើតឡើងរវាងប្រទេសថៃនឹងកម្ពុជាអំពីព្រះវិហារទេ ។

តាមគំនិតនេះ ប្រទេសថៃប្រាថ្នាមិនឲ្យតុលាការអន្តរជាតិសំរេចរឿងព្រះវិហារ ព្រោះបើនិច្ឆ័យទៅ តុលាការនឹងឃើញការពិត គឺព្រះវិហារជាកម្មសិទ្ធិរបស់ខ្មែរ ហើយប្រទេសរបស់គេប៉ុនប៉ងនឹងកាន់កាប់ទឹកដីត្រមាំងបុកណាត់របស់យើងនេះ ដោយកម្លាំងតទៅទៀត ។ ម្ល៉ោះហើយគេប្រើមធ្យោយជាដំបូង គឺធ្វើឲ្យតុលាការអន្តរជាតិសំរេចប្រកាសថា អង្គការនេះគ្មានសមត្ថកាពអ្វីនឹងកាត់សេចក្តីរឿងវិវាទនេះទេ បើតុលាការសំរេចយ៉ាងនេះទៅ គេនឹងកាន់កាប់ដោយកម្លាំងតទៅទៀតនូវព្រះវិហាររបស់យើង ។

ចំណែកខាង ប្រទេសកម្ពុជាយើង ។ តវ៉ាថាអង្គការគុណាការអន្តរជាតិនេះ មានសមត្ថកិច្ចពេញទំនឹងវិនិច្ឆ័យសេចក្តីអំពីរឿងព្រះវិហារបស់យើង ។ ឥឡូវនេះ យើងត្រូវបានជ័យជំនះហើយ ដោយគុណាការអន្តរជាតិ ក្រោយដែលបានស្តាប់សេចក្តីដោះសារយ៉ាងអង់អាច នៃអ្នកតំណាងរបស់យើង បានសម្រេចប្រកាសថា គុណាការអន្តរជាតិនេះមានសមត្ថកិច្ចពេញទំនឹងសម្រេចវិនិច្ឆ័យរឿងព្រះវិហារ ដែលខ្មែរយើងបានប្តឹង ។

បើយើងពោលតាមពាក្យសាមញ្ញថា គុណាការអន្តរជាតិបានទាត់ចោលសេចក្តីដោះសារបស់ថៃឡង់ដ៍ដែលតវ៉ាថា អង្គការនេះមិនមានសមត្ថកិច្ចសម្រេចសេចក្តីអំពីពាក្យបណ្តឹងរបស់ខ្មែរ ក្នុងរឿងព្រះវិហារ ហើយគុណាការបានយល់ឃើញថា ការតវ៉ារបស់ខ្មែរ ត្រូវតាំងសេចក្តីដោះសារបស់យើង ត្រឹមត្រូវតាមគន្លងច្បាប់អន្តរជាតិ ដែលគុណាការជាអ្នកអះអាង ។

នេះជាជ័យជំនះលើកទី ១ ។ នៅលើកទី ២ ទៀត ដែលជាលើកបន្ទាប់ គុណាការត្រូវពិនិត្យ ទំនឹងវិនិច្ឆ័យពាក្យបណ្តឹងរបស់យើងដែលតវ៉ាថា ព្រះវិហារជារបស់ខ្មែរ ។

. ការសំរេចលើកក្រោយនេះ ដែលនឹងដល់អនាគតផ្លូវច្បាប់ នៃព្រះវិហារយើង នឹងចាប់ផ្តើមនៅឆ្នាំ ១៩៦២ ។

๒ - ជ័យដំនះលើកដំបូងនេះ យើងបានមកដោយសារអ្នកចំណានជំអាន់ អាចរបស់ពជរង្គាកិចាល ក្រោមព្រះពជបត្តម្ភដឹកនាំដ៏វៃឆ្លាតនឹងស្ងួតស្ងាញ នៃសម្តេចសហជរិន ដ៏ជាទីស្នេហានៃប្រជាពលរដ្ឋខ្មែរ ។

យើងសូមបញ្ជាក់ថា ទោះបីនីតិវិធីទៅចំពោះមុខតុលាការអន្តរជាតិនេះ ជាលើកដំបូងយ៉ាងណាក៏ដោយ ក៏ការពិបាកមានច្រើនជាអនេក។ ការពិបាកទីមួយ ដែលយើងត្រូវខ្ចប់ខ្ចល់ គឺដូចខ្មែរយើងដឹងស្រាប់ តួកថៃគេមានច្បាក់ច្រើនណាស់ ដែលសម្រាប់ចាយក្នុងរឿងព្រះវិហារនេះ ការពិបាកម្យ៉ាងទៀតដែលយើងមានគឺ: ប្រទេសយើង ដែលជាប្រទេសតូចតាច ចេញមុខតុះតារជាលើកដំបូង ប្តឹងមកតុលាការកំពូលនេះ ដើម្បីរកយុត្តិធម្មឲ្យយើង ។ ម្យ៉ាងទៀត គឺជាការពិសោធន៍ជំហរបស់យើង ដែលចង់ដឹងចង់ឃើញយ៉ាងដាក់ថា តើចៅក្រមតុលាការជំនោះមានគំនិតសុចរិតពិតត្រង់ រកយុត្តិធម៌ឲ្យយើងបានឬទេ ? ។

ចំពោះការពិបាកទីមួយ យើងអាចសង្កេតឃើញច្បាស់ថា រដ្ឋាភិបាលថៃបានចំណាយច្រាក់ច្រើនណាស់ ក្នុងការជួលមេធាវីនឹងទីប្រឹក្សា។ ម៉ើធ្វើការប្រៀបធៀបទៅ យើងអាចពិនិត្យឃើញថា ខាងយើងម្ខាក់ខាងគេដល់ទៅពីរនាក់ ។

ខាងខ្មែរយើង មានសហជរិនក្រឿង-កាង សមាជិកក្តុមប្រឹក្សាព្រះពជា ជាភ្នាក់ងាររបស់ពជរង្គាកិចាល និងមេធាវី ៣ នាក់ គឺ លោក

រ៉ូហ្សេ-ប៉ាំងតូ (Roger-Pinto) លោក ប៉ូលរ៉ឺទែរ (Paul Reuter) ពាំង
ពីរនាក់ជាសាស្ត្រាចារ្យនៅមហាវិទ្យាល័យច្បាប់នៅប៉ារីស ទី៣លោក ឌាន
អាឈីសុន (Dean-Acheson) អតីតរដ្ឋលេខាធិការអាមេរិកាំង ។ គិត
ទៅខាងយើង មានតែបួននាក់ ។

ចំណែកខាងថៃ គេមានគ្នាតែជល់ទៅ ៨នាក់ ដោយមានអ្នកអង្គ
ម្ចាស់វង្សាមហិប ជយង្កូរ (Vongsam-Hip Jayankura) ឯកអគ្គរាជទូត
សៀមនៅប្រទេសម៉ិកូថា (១) ជាតំណាង ចំណែកមេធាវី ទី៣ខ្លីប្រឹក្សាគេ
យកសុទ្ធតែដើរ៣សម្លឹម ។ ដូចតទៅ:

១) សេរ៉ីហ្វ្រង់ សូសស្កៃសស្ស (Sir Frank Soskice) សមាជិកក្រុម
ប្រឹក្សាព្រះរាជា ជាអតីតអគ្គព្រះរាជអាជ្ញានៃប្រទេសអង់គ្លេស

២) លោក សេនីប្រមោជ មេធាវីសៀម

៣) លោក ហ៊ីមណៃនៃហ៊ីដ (james NEVIN HYDE) មេ-
ធាវីសមាជិកអាវ៉ូកានៃរដ្ឋញូវយ៉ក ទី៣ជាមេធាវីដ៏មានគុណភាពជាន់ខ្ពស់
នៃសហរដ្ឋអាមេរិក

៤) លោក ម៉ាសែល ស្លូសុនី (Marcel Slusuny) មេធាវីសមា-
ជិកអាវ៉ូកាបែលហ្សិក

៥) លោក ឡឺកេស្ន (J.G.Le Quesne) មេធាវីសមាជិកអាវ៉ូកា
អង់គ្លេស

១- ហៅថា ហុលង្គ កំបាន ។ តុលាការអន្តរជាតិតាំងនៅក្រុង ឡាអេ ប្រទេស ហុលង្គ ឬ
ប៉ែស៊ីបា នេះ ។

๖) លោក ជាវីជ្ញទ្យ មេធាវីអមតុលាការជាន់ខ្ពស់អង់គ្លេស

๗) លោក សំពុងសុចាវិតគុល សមាជិកផ្នែកច្បាប់ក្រសួងការបរទេសថៃ ។

ប៉ុន្តែយើងត្រូវកត់សំគាល់ថា ទោះបីខាងថៃមានគ្នាគេច្រើនយ៉ាងនេះក៏ដោយ កំខាងខ្មែរយើងដែលមានតែ៤រូបទោះ មានប្រៀបច្រើនជាងអ្នកតំណាងរបស់ប្រទេសថៃឆ្ងាយណាស់ ។ ព្រោះម្យ៉ាង អ្នកតំណាងខាងខ្មែរយើងចាំង ៤ នាក់ សុទ្ធតែជាអ្នកចំណានពិត។ មិនមែនជាអ្នកចំណានគ្រាន់តែថាទេ ។

សហជីវិន ប្រឿង-កាង បណ្ឌិតខាងច្បាប់ (មហាបវរញ្ញ) ឥឡូវជាអ្នកជំនាញខាងច្បាប់អន្តរជាតិ ព្រោះលោកមានឱប្លូមខាងវិជ្ជាស្ថានសិក្សាជាន់ខ្ពស់អន្តរជាតិ (Diplomé de l'Institut des Hautes Etudes Internationales) នៅមហាវិទ្យាល័យច្បាប់នាក្រុងប៉ារីស ។

ចំណែកលោកវ៉ូហ្ស៊ែរ-ចុងតូ ឥឡូវលោកប៉ូលវិទ្យា សាស្ត្រាចារ្យនៅមហាវិទ្យាល័យច្បាប់ ជាពិសេស លោកវ៉ូហ្ស៊ែរ-ចុងតូ ជាសាស្ត្រាចារ្យខាងចំណេះខាងច្បាប់សាធារណៈ (Droit public) ឥឡូវច្បាប់អន្តរជាតិ (Droit International) លោកបានធ្លាប់មកធ្វើជាចាងហ្វាងឥឡូវមេប្រយោគនៅមហាវិទ្យាល័យច្បាប់កុំតែភ្លេចយើង ។

(នៅមានត)

ផ្នែកគំណាត់ដ៏ឯកប្រវត្តិការណ៍

ពិធីបុណ្យរំលឹកព្រះគុណ

សម្តេចព្រះសុគន្ធាសភាជាធិបតីបញ្ញាសីលោ ទ៉ាំង

កាលពីថ្ងៃទី ៣ កុម្ភៈ ១៩៦៣ ខេត្តកន្ទឹងវត្តបទុមវតីរាជវរាភម មានជួបជុំពុទ្ធបរិស័ទ ព្រះសង្ឃ ១ថ្នាក់ ១ថ្នាក់តាជីនវត្ត ធ្វើពិធីបុណ្យរំលឹកគុណសម្តេចព្រះសង្ឃរាជាធិបតីបញ្ញាសីលោ ទ៉ាំង ក្រោមព្រះអធិបតីភាពនៃសម្តេចព្រះសុធម្មាធិបតីសង្ឃនាយកគណៈធម្មយុត្តិកនិកាយ ។

ក្នុងពិធីនោះ សម្តេចព្រះសុធម្មាធិបតីសង្ឃនាយក បានថ្លែងសុន្ទរកថាមួយយ៉ាងសង្ខេប រៀបរាប់អំពីបុព្វហេតុបុណ្យរំលឹកព្រះគុណនេះដោយមានសេចក្តីដាក់ថា :

ការធ្វើបុណ្យរំលឹកនេះ ត្រូវធ្វើចំលៀងថ្ងៃដែលសម្តេចព្រះសុគន្ធាសង្ឃរាជាធិបតីព្រះនាម ទ៉ាំង ទ្រង់បានគាំគណៈធម្មយុត្តិកនិកាយមកប្រតិស្ឋានក្នុងព្រះរាជអាណាចក្រកម្ពុជា តាមព្រះរាជនិមន្តន៍នៃព្រះបាទសម្តេចព្រះហរិវរ្ម្យកមាឥស្សរាធិបតី ព្រះអង្គឌួង ។

ការធ្វើបុណ្យរំលឹកនេះ ត្រូវធ្វើរៀងរាល់ឆ្នាំ ហើយនៅឆ្នាំនេះជាឆ្នាំលើកទី ២ ដែលគណៈកម្មការសង្ឃបានសំរេចរួច ។

តមក ព្រះសង្ឃបានធ្វើកិច្ចនមស្ការព្រះរតនត្រៃ ដោយពុទ្ធបរិស័ទ

ធ្វើនមស្ការជាពាន់ក្រោយ ។

លុះចប់កិច្ចមនស្សការហើយ សម្តេចព្រះសង្ឃនាយកបានថ្វាយដំណូលធ្វើចំពោះព្រះកត្ត្រព្រះនាយលក្ខណ៍ សម្តេចព្រះសុគន្ធាសង្ឃរាជាធិបតីព្រះនាមបញ្ញាសីលោ ទ្វាន តាមទំនៀមយ៉ាងក្បោះក្បាយដោយសព្វគ្រប់បញ្ជាក់ពីការនាំសមណវង្សគណៈធម្មយុត្តិកនិកាយនេះ ចូលមកប្រទេសកម្ពុជាហើយបន្ទាប់មកលោកអាចារ្យវត្ត ត្រូវថ្វាយដំណូលធ្វើចំពោះព្រះបរមនាយលក្ខណ៍ នៃអតីតព្រះមហាក្សត្រខាំងឡាយ មានព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរធិបតីព្រះអង្គឌួងជាដើម បញ្ជាក់ពីការឧបត្ថម្ភព្រះពុទ្ធសាសនា តាំងពីពេលដែលព្រះអង្គទ្រង់បាននាំយកគណៈធម្មយុត្តិកនិកាយនេះ មកប្រតិស្ឋានក្នុងប្រទេសកម្ពុជាពីឆ្នាំ ១៨៥៤ ។

តមក មានព្រះថេរៈមួយអង្គទៀតថ្វាយដំណូលពីធម្មយុត្តិកប្រវត្តិ ដែលមានសេចក្តីជាអាទិ៍ នេះ បញ្ជាក់ពីពេលនាំចូលមកប្រទេសខ្មែរ ទីដំណើរប្រវត្តិរបស់សម្តេចព្រះសុគន្ធាសង្ឃរាជាធិបតី បញ្ញាសីលោ ជ្រាន ចាប់តាំងពីថ្ងៃខែកើតរហើយបានសិក្សាអក្សរសាស្ត្រនៅប្រទេសខ្មែរ រហូតទៅសិក្សាប្រទេសថៃលុះត្រាបាននាំយកគណៈវង្សធម្មយុត្តិកនិកាយមកប្រតិស្ឋានដោយព្រះកដនិមន្តន៍នៃព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរធិបតីព្រះអង្គឌួង ។

សូមជំរាបជូនថា នៅពេលចប់សុន្ទរកថាម្តង ។ មានទេដ្ឋិសផ្សាយកុសលបុញ្ញាភិសេកថ្វាយចំពោះអតីតព្រះមហាក្សត្រ ចំពោះសម្តេចព្រះសង្ឃនា-

យកទាំងអស់ ដែលខ្ញុំលះទុំវត្តនេះនឹងអនុមោទនាហើយ សូមព្រះអង្គបានខ្ញុំលះយកនូវឥដ្ឋមុខុញ្ញាណ ដែលកើតឡើងពីការធ្វើបុណ្យនេះ ។ បុញ្ញជនបានលើកកុសលបុញ្ញកថានេះ ថ្វាយចំពោះសម្តេចព្រះមហាក្សត្រីយានីជាព្រះមាតាជាតិ សម្តេចព្រះប្រមុខរដ្ឋ សូមព្រះអង្គបានប្រកបដោយជោគសុខមហាប្រសើរគ្រប់ប្រការ នឹងសូមព្រះអង្គបានប្រកបដោយព្រះជន្មវស្សាយឺនយូរ នឹងបានជាម្លប់ដ៏ត្រជាក់នៃកូនចៅព្រះអង្គជានិរន្តរ៍ ហើយនឹងជួនពរសត្វសាធុការដល់ពុទ្ធបរិស័ទ ដែលបានជួយឧបត្ថម្ភកម្លឹងកិច្ចការបុណ្យនេះឲ្យបានប្រកបដោយពុទ្ធពរ ៤ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

លុះព្រឹកឡើងថ្ងៃទី ៤ កុម្ភៈ ១៩៦៣ មានធ្វើបុណ្យដាក់ជាត្រចំពោះព្រះសង្ឃចំនួន ១០០ អង្គ នៅមុខព្រះចេតិយ នឹងមុខព្រះវិហារវត្តបទុមវតីព្រមទាំងវេរកត្តគារប្រគេនព្រះសង្ឃ ។ ខ្ញុំសព្រះពុទ្ធកុសលថ្វាយចំពោះព្រះវិញ្ញាណក្ខន្ធនៃព្រះអតីតសម្តេចព្រះសង្ឃនាយកទាំងឡាយ នឹងព្រះវិញ្ញាណក្ខន្ធនៃអតីតព្រះមហាក្សត្រទាំងឡាយ មានព្រះបាទសម្តេចព្រះហរិវរក្សក្រមាឥស្សរធម្មិកព្រះអង្គខ្ចីងជាដើមបន្តមកទៀតជាកិច្ចបញ្ចប់ ។

សូមបញ្ជាក់ថា ការធ្វើបុណ្យរំលឹកព្រះគុណ គឺនៅតាមវត្តគណៈធម្មយុត្តិកនិកាយក្នុងដែនៃព្រះពុទ្ធអាណាចក្រកម្ពុជា ក៏មានធ្វើបុណ្យនេះនៅថ្ងៃជាមួយគ្នានេះដែរ ។

ពិធីប្រគល់សៀវភៅ ១៦ ក្បាល ជាអំណោយនៃ សាធារណរដ្ឋកូរ៉េខាងត្បូង ចំពោះក្រសួងធម្មការ

កាលពីថ្ងៃទី ២៥ កុម្ភៈ ១៩៦៣ នៅសាលអានសៀវភៅនៃមន្ទីរពុទ្ធសាសនបណ្ណិត្យ (ក្រសួងធម្មការ) មានធ្វើពិធីប្រគល់សៀវភៅ ១៦ ក្បាល ជាអំណោយរបស់រដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េខាងត្បូង ចំពោះក្រសួងធម្មការ ដែលធ្វើឡើងក្រោមអធិបតីភាពនៃលោក ម៉ែន - ឈុំ អនុរដ្ឋលេខាធិការ ក្រសួងធម្មការ ។

នៅក្នុងពិធីប្រគល់សៀវភៅខាងលើ ១៦ ក្បាលនេះ ព្រះវិន័យមុនី ប៉ុណ្យ - សម្ភាជ តំណាងសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ ព្រះធម្មត្រៃលោកាចារ្យ ច័ន្ទ - សាលី តំណាងសម្តេចព្រះសុធម្មាធិបតីសង្ឃនាយកគណៈធម្មយុត្តិកនិកាយ ព្រមទាំងព្រះសង្ឃទីពាដាគណៈហានុក្រមជាច្រើនអង្គទៀត ហើយនិងមន្ត្រីអ្នកពាក់ការក្រសួងធម្មការជាច្រើនទៀត ចូលនិមន្តអញ្ជើញទៅជួបជុំនៅក្នុងទីកាសនោះផង ។

យើងសូមបញ្ជាក់ថា សៀវភៅជាអំណោយនៃសាធារណរដ្ឋកូរ៉េខាងត្បូងចំនួន ១៦ ក្បាលនេះ ចោះពុម្ពជាអក្សរចិនបួកណា ស្តីអំពីព្រះពុទ្ធសាសនាផ្នែកមហាយាន ។

ក្បួនច្បាប់នេះមានអាយុកាលជាង ២.០០០ ឆ្នាំហើយ ដែលបុព្វបុរសជាតិខ្មែរក្នុងសម័យនោះបានទ្វាក់ជាអក្សរចំនួនលើបន្ទះក្តារ ចំនួន ៩០.០០០ ផ្ទាំង ដោយអ្នកប្រវត្តិសាស្ត្រជាតិខ្មែរយល់ឃើញថា ក្បួនច្បាប់នេះមានសារៈសំខាន់ពាក់ព័ន្ធខាងព្រះពុទ្ធសាសនានោះ ក៏ឯកទេសម្នាក់ បានញែកបន្ទះក្តារមកចោះពុម្ពចង់ជាសៀវភៅនេះឡើង ។

ដូច្នេះ សៀវភៅចាំង ១៦ ក្បាលនេះ បានជារូបមន្តមួយបញ្ជាក់សារជាថ្មីក្នុងការប្តូរវប្បធម៌រវាងប្រទេសចាំង ២ ។ សហប្រតិបត្តិការវប្បធម៌ដោយមិត្តភាពរវាងប្រទេសចាំង ២ នេះជាវិភាគទានលើកទឹកចិត្តយ៉ាងប្រសើរ ចាំងជាហេតុនាំឲ្យមានការស្គាល់ និងការយោគយល់គ្នារឹតតែវិសេសវិសាលតទៅក្នុងមិត្តភាពរវាងព្រះពុទ្ធសាសនាផងនឹងប្រទេសចាំងពីរផង។

ក្រោយដែលមានការជួបជុំហើយ ពិធីប្រគល់សៀវភៅបានប្រព្រឹត្តទៅគឺជាបឋម លោក លី-ចាក-គឿន កុងស៊ុលនៃសាធារណរដ្ឋកូរ៉េខាងត្បូងប្រចាំប្រទេសកម្ពុជា និងលោក ម៉ែន-ឈុំ អនុរដ្ឋលេខាធិការ បានឡើងថ្លែងសុន្ទរកថាជាបន្តបន្ទាប់គ្នា ហើយដែលនៅពេលចប់សុន្ទរកថាម្តងៗសូរស័ព្ទះដៃយ៉ាងកងរំពងបានកើតមានជាសញ្ញាសំដែងនូវសេចក្តីអបអរសាទរ ។

បន្ទាប់មក លោកកុងស៊ុលនៃសាធារណរដ្ឋកូរ៉េ ក៏បានលើកសៀវភៅ ១ ក្បាល ជូនទៅលោកអនុរដ្ឋលេខាធិការ ជានិមិត្តរូបនៃការប្រគល់



ឯកឧត្តម លី - ទាកគឿន ក្នុងស៊ុលសាធារណៈធ្លីក្បែរខាងត្បូងប្រចាំប្រទេសម៉ុងហ្គា ខ្មែរសុំនូវកថាខណ្ឌនៅឧកាសពិធីប្រគល់សៀវភៅពុទ្ធ
សាសនា ១៦ ក្បាលពីលំពុទ្ធសាសនបណ្ឌិត្យ នៅថ្ងៃទី ២៥-២-៦៣

សៀវភៅចាំង ១៦ ក្បាល ។

តមក ព្រះសង្ឃក៏បានសូត្រធ្វើយធម្មដេសនាប្រសិទ្ធិពរជ័យ ទីឆ្ងាយ សញ្ញាជូនពរសេចក្តីសុភមង្គលដល់លោកកុងស៊ុល ជាតំណាងនៃរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េខាងត្បូង សូមឲ្យការប្តូរសៀវភៅនេះដាមដរូបនៃវប្បធម៌ខាងពុទ្ធសាសនាបានរីកចំរើនជាលំដាប់តទៅ ។

X X

X

សុន្ទរកថារបស់លោកលី - ចាក - គឿន

ដែលថ្លែងក្នុងឧកាសប្រគល់សៀវភៅចាំង ១៦ ក្បាល

កាលពីថ្ងៃទី ២៥ កុម្ភៈ ១៩៦៣

ឯកឧត្តម

ព្រះថេរានុត្ថេរៈ

អស់លោក

កិត្តិយសបានផ្តល់ឲ្យខ្ញុំមកជាតំណាងរដ្ឋាភិបាល នៃសាធារណរដ្ឋកូរ៉េ ក្នុងពិធីប្រគល់ដោយអត្ថន័យយ៉ាងពេញលេញនេះ ក្នុងគោលបំណងនឹងបង្ហាញជូនពរដល់កិច្ចប្រទេសកម្ពុជា ខ្ញុំសូមហាក្យដ៏ក្រម្រួយ ក្នុងចំណោមសម្ដីហាន់ឡាយស្តីពីព្រះពុទ្ធសាសនា ។

ព្រះពុទ្ធសាសនាមានអ្នកកាន់យ៉ាងច្រើននៅគ្រប់តែទីកន្លែង ។ នៅប្រទេសកូរ៉េ ព្រះពុទ្ធសាសនា មានប្រវត្តិកាលយ៉ាងវែងឆ្ងាយក្នុង

សន្តតិវង្ស (Sillas) កាលពី ៥៧ ឆ្នាំមុនសាសនាព្រះយេស៊ូគ្រិស្ត ។

ក្នុងពេលសព្វថ្ងៃនេះ ព្រះពុទ្ធសាសនាគឺជាសាសនារបស់ប្រទេសដែលមានទំហំធំទូលាយជាងគេ ហើយមានមនុស្សយ៉ាងច្រើនកុះករ ។ នៅប្រទេសកូរ៉េ មានព្រះវិហារសម្រាប់ព្រះពុទ្ធសាសនាចំនួនជាង ១.៥០០ ជាកន្លែងដែលមានព្រះសង្ឃចំនួន ៧ ០០០ អង្គ និងអ្នកកាន់ព្រះពុទ្ធសាសនាជិត ដល់ទៅ ៣ លាន ៥ សែននាក់ ។

ប្រទេសរបស់ខ្ញុំមានសេចក្តីពេញចិត្តនឹងឃើញការជាណាចក្រកម្ពុជាជាប្រទេសមួយប្រកបដោយសាសនាដូចគ្នា ហើយរដ្ឋាភិបាលនៃប្រទេសរបស់ខ្ញុំមានសេចក្តីរីករាយជាពិសេស នឹងអាចប្រគល់ជូនអត្តសង្គហៈគាំង ប៉ុន្មាននេះ ជូនចំពោះរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា ដើម្បីឧបត្ថម្ភប្រើប្រាស់តាមត្រូវការ ព្រោះអត្តសង្គហៈនេះហើយដែលមានចែងនូវប្រវត្តិសាស្ត្រក្នុងសម័យដ៏រុងរឿងនៃសាសនារួមមួយ ដែលយើងកាលគ្នាឃ្លាងគាន់នេះ ។

ខ្ញុំសូមថ្លែងនូវសេចក្តីសង្ឃឹមរបស់ខ្ញុំថា វិភាគទានដ៏សមរម្យនេះនឹងអាចផ្តល់នូវភាគផលរបស់ខ្លួន ក្នុងការកែចំរើនខាងការសិក្សាទាំងឡាយចំពោះព្រះពុទ្ធសាសនាទៅក្នុងប្រទេសកម្ពុជា ដែលមានសភាពយ៉ាងច្រើនប្រសើរហួសហើយនោះ នឹងចំពោះការកែចំរើននៃការប្តូរវប្បធម៌គ្នាទៅវិញទៅមក ដូចជាទៅក្នុងការពង្រឹងចំណងមិត្តភាពទាំងឡាយក្នុងការបង្រួបបង្រួម



សហជីវិន ម៉ែន-ឈុំ អនុរដ្ឋលេខាធិការក្រសួងពត៌មាន ថ្លែងសុន្ទរកថាជាច្រើនតបនឹង លោក លី ទាក ឆៀនកុងស៊ុលតូរយ៉ែនាងឆ្លង នៅ
ឧកាសពិធីប្រគល់សៀវភៅ ១៦ ក្បាល ជិល់ពុទ្ធសាសនាបណ្ណិត្យ នៅថ្ងៃទី ២៥-២-៦៣

ប្រទេសព័រតាមសាសនាដូចគ្នា គឺព្រះពុទ្ធសាសនានេះ ។

សូមអរគុណ

X X

X

សុន្ទរកថារបស់លោក ម៉ែន - ឈុំ អនុរដ្ឋលេខាធិការ ក្រសួងធម្មការ ថ្វែងតបវិញ នៅថ្ងៃទី ២៥ កុម្ភៈ ១៩៦៣ មានសេចក្តីដូចតទៅ៖

ព្រះថេរានុត្តេរៈ

ឯកឧត្តម

អស់លោក

ជាបឋមខ្ញុំព្រះករុណា ខ្ញុំបាទ សូមសំដែងនូវសេចក្តីគោរពដោយកតញ្ញូតា ទឹងអំណរគុណដ៏ស្មោះរបស់ខ្ញុំព្រះករុណាខ្ញុំបាទ ចំពោះព្រះថេរានុត្តេរៈទាំងអស់ដែលបានឱមន្តមក ដើម្បីលើកដំកើងពន្លឺនៃពិធីប្រគល់សៀវភៅ ព្រះពុទ្ធសាសនាដែលរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉ែ បានធ្វើអំណោយនេះ ។

ឯកឧត្តម លោកអគ្គកុងស៊ុល

កន្លងថ្ងៃនេះ ខ្ញុំមានកិត្តិយសយ៉ាងធំ ទឹងសេចក្តីរីករាយយ៉ាងពិតប្រាកដ ដែលបានអញ្ជើញមកជាអធិបតីនៅកន្លងពិធីទទួលសៀវភៅព្រះពុទ្ធសាសនា ដែលរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉ែខាងត្បូងបានប្រគល់មកឲ្យរដ្ឋាភិបាលនៃប្រទេសកម្ពុជា ។

តើដោយសេចក្តីរីករើបយ៉ាងខ្លាំង ដែលខ្ញុំបានគាន់គាប់ឯកសារតាំងនេះ ព្រោះថាជាឯកសារខាងព្រះពុទ្ធសាសនាដែលចំរើមូលនៃព្រះពុទ្ធសាសនាដ៏ពិតប្រាកដ ដែលប្រទេសយើងតាំងពីរបុរាណមកដំរើដូចគ្នា ។ ការនេះ គឺតែតែធ្វើឲ្យល្អប្រសើរឡើងទៀតនូវចំណងមិត្តភាពដែលចងភ្ជាប់ប្រទេសយើងតាំងពីរ ។

សូមឯកឧត្តមឲ្យជាកថា អំណោយនេះ គឺជាប្រកពនៃការសិក្សាថ្មីមួយមិនចេះចប់ចំពោះពុទ្ធបរិស័ទតាំងអស់ ហើយជាការបង្កើនសៀវភៅព្រះពុទ្ធសាសនាទៅក្នុងបណ្ណាល័យនៃវិទ្យាស្ថានព្រះពុទ្ធសាសនារបស់យើងឲ្យកាន់តែបានច្រើនឡើងទៀត ជាពិដែលសៀវភៅព្រះពុទ្ធសាសនាតាំងពីបុរាណ របស់ឯកឧត្តមនេះនឹងតាំងនៅជាតិខាងសៀវភៅព្រះពុទ្ធសាសនាដ៏មានតម្លៃស្មើគ្នាជាមិនខាន ។ សម្រាប់ជូនសាធារណជនខ្មែរ នឹងបរទេសទស្សនា ។

ក្នុងនាមនៃព្រះពុទ្ធសាសនាជាលប្រទេសកម្ពុជា ក្នុងនាមនៃព្រះសង្ឃនឹងពុទ្ធបរិស័ទខ្មែរតាំងអស់ ហើយនឹងក្នុងនាមផ្ទាល់ខ្ញុំ ខ្ញុំសូមសំដែងនូវអំណរគុណដ៏ស្មោះស្ម័គ្រ នឹងកតញ្ញូតាយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តមនឹងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េខាងត្បូង ។



ព្រះតេជគុណព្រះពោធិវង្សហូត-ភាគ នឹងព្រះសង្ឃរាជាគណៈហិរញ្ញប្រទាន សាច្ចាយន៍ធម៌ជាយន្តប្រសិទ្ធិពរជ័យ នៅឧកាសពិធីប្រគល់
សៀវភៅ ពុទ្ធសាសនាជាអស្សាចិន ១៦ ក្បាលជូនពុទ្ធសាសនបណ្ឌិត្យនៅថ្ងៃទី ២៥-២-៦៣

ពុទ្ធសាសនា


ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ




ឆ្នាំទី ៣៥ លេខ ៣ ខែ មិគ

ព. ស. ២៥០៥ គ. ស. ១៩៦៣

– ភ្នំពេញ –



ព្រះវិហារវត្តបទុមវតី រាជវិរាជ ថតពីទិសឆៀង ។



កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

បេញ្ចរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បណ្ឌិតរៀន	ទំព័រ
អំពីរឿងអសោក (វិចារណកថា)	លោក ផេង-ត្រីវ រៀបរៀង.	២២៩
តបធម៌ ភិក្ខុជាច់ សើយសារី រៀបរៀង		២៣៦
ព្រះអភិធម្មបិដក (គម្ពីរព្រះមហាបដ្ឋាន)	លោក ប៊ូ-ប៊ី ប្រែរៀបរៀង (ត)	២៤៤
ឧរុសវាហិណី សម្តេចព្រះធម្មលិខិត ល្ង-ឯម ឧត្តមប្រឹក្សា ប្រែរៀបរៀង (ត)		២៥០
មហោសថជាតក (ត)		២៦០

ផ្នែកអក្សរសាស្ត្រ		
ការនិយាយស្តី (វិចារណកថា)	លោក ផេង-ត្រីវ តែងរៀបរៀង	២៧២
ពាក្យខ្មែរប្រែពីបរទេស	ដោយគណៈកម្មការជាតិនៃការសិក្សាផ្នែកអក្សរ «ក» (ត)	២៨៤
វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះភេដព្រះគុណ ប៉ាង-ខាត់ រៀបរៀង (ត)		២៨៦
រឿងសាមកុក	លោកឧកញ៉ា ន្ហ-កន ប្រែរៀបរៀង (ត)	២៨៨
ល្បែកឡាហ្វុងនៃន	លោកផេង-ត្រីវ ប្រែពីភាសាថាវ៉ាង (ត)	២៩៨
រឿងព្រេងចិន	លោក វ៉ាយ ច៊ុក ប្រែពីភាសាថាវ៉ាង (ត)	៣០៧
ការដំនុំដំរះដោយយុត្តិធម៌នៃតុលាការអន្តរជាតិពីរឿងវត្តព្រះវិហារបស់ខ្មែរទៅក្រុងឡាអេ(ត)		៣១៨
ប្រវត្តិសង្ខេបនៃផ្ទៃស្វាយជន្លី		៣៣០

ផ្នែកកំណាត់ឧដ្ឋានប្រវត្តិការណ៍	
ពិធីបង្ហូរទូលទឹសកុសលផ្កូនចំពោះវិញ្ញាណក្ខន្ធ នៃឯកឧត្តមរាជេន្ទ្រប្រាសាទអតីតប្រធានាធិបតី នៃ ប្រទេសឥណ្ឌា	៣៣២

មួយឆ្នាំមាន ១២ លេខ តម្លៃដាវ ២៣០ ខ្លួ

ពរសុភសាធុការធាំបី

ទុកាសត្តាំងាល –

ចាស់ល្អត្រកាល　　បេញ្ញាដុតទៅហ៊ាយ　　ត្នាំថោះថ្នីចូល

មកមូលជារត្រាយ　　ឲ្យខ្មែរបានស្បើយ　　ចាកគ្គីទុក្ខា ។

ពុទ្ធសាសនៈ –

បណ្ឌិត្យគារវៈ　　សូមពួកទេពតា　　រក្សាត្នាំថ្មី

ឃ្នាតខ្ចីរក្សា　　សម្តេចព្រះមហា-　　ក្សត្រិយានី ។

សូមសម្តេចនុ –

ប្រកបដោយនូវ　　ព្រះជន្មដ៏វែ　　យឺនយូរនាំស្រុក

បានសុខក្សេមខ្លី　　ឈ្នះអស់ពៃរ　　ល្បីសុសសាយទៅ ។

បលទាសង្គម –

ថ្លៃថ្លាឧត្តម　　ដែលសម្តេចនុ　　ទ្រង់ជាប្រធាន

សូមមានបិតនៅ　　នាំស្រុករកផ្លូវ　　ចំរើនថ្កើងថ្កាន ។

វង្ហាតិថ្កាល –

សង្គមត្រកាល　　សូមបានសុខសាន្ត　　ទាំងក្រសួងប្រជា

នានាប៉ុន្មាន　　បានសុះគ្រប់ប្រាណ　　គ្រប់កាលសម័យ ។

លោកអ្នកទស្សនា –

កម្ពុជសុរិយា　　ដោយភក្តីអាល័យ　　នឹងដោយសទ្ធា

ជ្រះថ្លាពេកក្រៃ　　សូមបានជោគជ័យ　　សុខចំរើនហោង!

ពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ	ធ្វើការអាក្រក់
ជាការណាមក	ឲ្យធ្វើល្អទៅ
ឲ្យផ្ទុំសមាធិចិត្ត	កុំឲ្យហ្មងសៅ
បីនេះលោកហៅ	ពុទ្ធសាសនា

ប.ព.

វិចារណាកថា

អំពីរឿងអសោក

លោក ដេង - ទ្រីវរៀបរៀង

តាមសេចក្តីកត់គម្ពីរបាលីពុទ្ធសាសនាថា អសោកជាមហាពជម្ពួយព្រះអគ្គកនវ័ន្ធ្យមោរ័យ:ដែលមានមហិទ្ធិរិទ្ធិដ៏អស្ចារ្យក្នុងសម័យនោះ ទ្រង់សោយពជ្យនៅនគរបាតលីបុត្រ ហើយមានប្រទេសពជចំណុះយ៉ាងច្រើន គឺថាក្នុងសម័យនោះ គេទុកព្រះអង្គជាព្រះពជាធិពជក្នុងជម្ពូទ្វីប ។ នេះសំដៅយកប្រទេសឥណ្ឌាទាំងមូល ។

ចានជាខ្ញុំយករឿងអសោកនេះមកចុះផ្សាយ ព្រោះមានសេចក្តីបរិយាយពីប្រកតខ្លះ មានសភាពមិនស្របគ្នានឹងសេចក្តីបរិយាយក្នុងគម្ពីរបាលីពុទ្ធសាសនា ផ្នែកខាងហីនយាន ។

ចំពោះប្រវត្តិព្រះបាទអសោក ខ្ញុំលើកទុកមិនចានយកមកចុះផ្សាយទេ ខ្ញុំលើកយកតែទង្វើយខ្លះក្នុងប្រវត្តិនោះ ដែលមានលក្ខណៈប្លែកគួរជួចយ៉ាង :

១) អំពីព្រះបាទអសោកមានសទ្ធាកើតក្នុងព្រះពុទ្ធសាសនា តាមគម្ពីរ
ជាលិខាងថេរវាទ ឬហីនយាន ឬខុទ្ទកនិកាយ មានសេដែងថា: ព្រះបាទ
អសោក មានព្រះរាជហឫទ័យបែរមករកព្រះពុទ្ធសាសនា ដោយសារ
សាមណេរម្នាយអង្គ ព្រះនាមនិគ្រោធសាមណេរ ត្រូវជាកូយរបស់
ព្រះអង្គ ។

ដំណាលថា: ថ្ងៃមួយព្រះបាទអសោកគង់នៅក្នុងប្រាសាទ តែឯព្រះ
សីហបញ្ជរ ។ មិនដឹងទេសកាលអ្វី ស្រាប់តែទ្រង់បែរព្រះភក្ត្រចេញ
ទៅក្រៅ ហើយទ្រង់ឃើញសាមណេរម្នាយអង្គ គ្រងស្បង់ចីវរជាបរិ-
មណ្ឌល និមន្តកាត់ព្រះលានស្តេច មានដំណើរស្រគត់ស្រគំ សង្រួម
អន្ទ្រៃយគួរជាទីជ្រះថ្លា ។ ទតឃើញហើយ ព្រះបាទអសោកពេញព្រះរាជ
ហឫទ័យ ក៏ទ្រង់ព្រះរាជបញ្ជាឲ្យអាមាត្យទៅនិមន្តសាមណេរនោះមកកាន់
ព្រះរាជដំណាក់ ហើយទ្រង់ប្រគេនភោជនាហារយ៉ាងប្រណីតដល់សាម-
ណេរ ។ លុះភត្តកិច្ចចប់ហើយ ដោយទ្រង់សព្វព្រះរាជហឫទ័យនឹងអា-
ការសង្រួមអន្ទ្រៃយដ៏សមរម្យនៃនិគ្រោធសាមណេរ ព្រះបាទអសោកនិមន្ត
សាមណេរ សូមឲ្យសំដែងធម៌ជាទីសណ្ដាប់ចំពោះព្រះអង្គ ។ និគ្រោធ
សាមណេរពោលថា: «អប្បមាទោ អមតំ បទំ បមាទោ
មច្ចុនោ បទំ អប្បមត្តា ន មីយន្តិ យេ បមត្តា យថា
មតាទិ» ប្រែថា «សេចក្តីមិនប្រហែស ជាទីតាំងមិនស្លាប់ សេចក្តី

ប្រហែសជាច្បាយស្ងាប់ ពួកអ្នកមិនប្រហែស ឈ្មោះថាមិនស្ងាប់ ពួកអ្នកប្រហែសខុកដូចជាស្ងាប់ ។ ។

ដោយអាស្រ័យតែព្រះធម៌ប៉ុណ្ណោះ ព្រះបាទអសោកជ្រាបបាន កំចាប់ជ្រះថ្លាក្នុងព្រះពុទ្ធសាសនាពីពេលនោះមក ។

ក្នុងសៀវភៅលោកគីម-អាន ត្រង់សេចក្តីប្រៀបធៀបកាសាបាកំង (រឿងអសោក) ថាព្រះបាទអសោកបានពេញព្រះភាជហឫទ័យចំពោះព្រះពុទ្ធសាសនា ដោយសារទ្រង់បានស្តាប់ព្រះធម៌ទេសនារបស់ព្រះថេរៈមួយព្រះអង្គឈ្មោះសមុទ្ទកុក្ខ ។

ដំណាលថា: ព្រះបាទអសោក បានបង្កើតពន្ធនាគារពិឃាដមួយ មានឈ្មោះថា: «តុកជាទីសុខសម្រាន្ត» ខុកសម្រាប់ពិឃាដមនុស្សពេស ។ ពន្ធនាគារនេះមានឈ្មោះពេជ្ឈឃាដ៍ឈ្មោះចណ្ឌគិរិកៈជាអ្នកត្រួតត្រា ។ តាមជញ្ជាំងខាងក្រៅនៃពន្ធនាគារ មានការរចនាតាក់តែងលំអគួរជាទីទស្សនាក្រៃពេក តែខាងក្នុងគឺជាកន្លែងពិឃាដមនុស្ស ។ តាមក្នុងរឿងគេសំដែងថា: ចណ្ឌគិរិកៈបានសុំពរពីសំណាក់ព្រះបាទអសោកថាបើឈ្មោះណា ទោះជាគ្មានទោសក៏ដោយ ឲ្យតែដើរចូលមកក្នុងពន្ធនាគារនេះ ខ្លួនត្រូវមានអំណាចចាប់សម្លាប់បានតាំងអស់ ព្រះបាទអសោកមិនបានត្រិះរិះសួរគ្រប់ ក៏ទ្រង់ប្រទានពរនេះដល់ចណ្ឌគិរិកៈ ម្ល៉ោះហើយតែមនុស្សណាមិនបានជាដឹង លោតែជ្រុលដើរចូលទៅ មុខជាបានដៃចណ្ឌ-

គិរកៈហើយ ។

កាលនោះ សម្ដុទ្ធមាណព ខាងក្រោយមរណភាពនៃមាតាបិតា នឿយណាយក្នុងគ្រហាវាស ចាន់ចូលជាភិក្ខុមានឈ្មោះ សម្ដុទ្ធភិក្ខុ ហើយតែងនិមន្តពីស្រុកមួយទៅស្រុកមួយ ដើម្បីធ្វើសមណធម៌ ។ លុះនិមន្តទៅដល់ពន្ធនាគារនោះ ដែលសភាពខាងក្រៅគួរឲ្យខ្ពើមព្រឺសរមើលរមើល លោកអាល័យតែតគំនូរនឹងគ្រឿងលំអផ្សេងៗ ព្រោះមិនដឹងជាគុក ស្រាប់តែនិមន្តចូលរហូតដល់ខាងក្នុង។ ពេលដែលលោកត្រូវនិមន្តចេញ ចណ្ឌគិរកៈឃាត់មិនឲ្យចេញ ដោយគ្រាប់ថា លោកត្រូវស្លាប់ព្រោះចូលក្នុងទីនេះ ។ លោកសួរថា ហេតុម្ដេចក៏យ៉ាងនេះ ចើតាគ្នាគ្មានទោស ? ចណ្ឌគិរកៈគ្រាប់ថា នៅកន្លែងនេះគឺយ៉ាងដូច្នេះ ព្រោះព្រះចាន់អស្រោកចាន់ប្រទានពរហួចហើយ ។ លុះព្រឹងំណឹងអកុសលនេះ សម្ដុទ្ធភិក្ខុទ្រហោយំ ។ ចណ្ឌគិរកៈសួរថាហេតុអ្វីក៏លោកយំ ? ព្រះថេរៈមានពុទ្ធដីកាថា ដែលលោកយំនេះ ដោយនឹកខ្លាចស្លាប់ក៏ទេ ព្រោះរូបតែកើតហើយ មានការស្លាប់ជាធម្មតា តែដោយលោកនឹកស្ដាយណាស់ ព្រោះលោកមិនទាន់ចាន់បំពេញសមណធម៌បរិបូណ៌ ហើយស្រាប់តែមកស្លាប់ដូច្នេះ ។ រួចលោកអង្វរចណ្ឌគិរកៈថាសុំធ្វើសមណធម៌ចាន់ត្រាំពីរថ្ងៃសិនសឹមសម្លាប់លោក តើចាន់ឬទេ ? ចណ្ឌគិរកៈយល់ព្រមឲ្យតាមសេចក្ដីសុំ។

ក្នុងពេលនោះ ព្រះថេរៈលើកយករូបបែកធ្លាយមកពិចារណា ព្រោះលោកឧត្តរយើញចណ្ឌគិរកៈ កំពុងសំពងក្បាលដោយញញួរដែក ធ្លាយ

ចេញខ្លះ តែកសៀនធ្ងៃ ឈាមហូរតាសតេញច្រាណ នៃប្រុសកំឡោះ ម្នាក់ដែលទៅលួចសាហាយនឹងព្រះស្ងួបស់ស្តេច ជនពាំងពីរច្រាណត្រូវ ចណ្ឌគិរីកៈធ្វើការុណកម្មយ៉ាងសាហាវយោរយៅ គួរជាទីស្បថស្បែងក្រែ ពេក សម្តុំគ្នាកុយកឿងនេះមកពិចារណាតេញមួយយប់ ទើបបាន សម្រេចសោតាបត្តិផល រួចលោកចំរើនតមកទៀតដល់ថ្ងៃទី៧ លោក បានសម្រេចអរហត្តផល ។

ព្រឹកឡើងថ្ងៃទី ៨ ចណ្ឌគិរីកៈទៅប្រាប់លោកថា កត្រីទី៧កន្ទុង ទៅហើយ តែឃ្លាត្រែតែលគាត់សម្លាប់ហើយ ។ លោកឆ្លើយថា: «កត្រី របស់អាត្មាកន្ទុងផុតហើយ ដួងព្រះអាទិត្យរបស់អាត្មានេះឡើងហើយ ពេល ជាមង្គលមកដល់ហើយ អ្នកនឹងសម្លាប់អាត្មាក៏ធ្វើតាមប្រាថ្នាចុះ » ។ ចណ្ឌគិរីកៈឃើញថ្លែកទើបសួរថា: លោកថាអ្វី ខ្ញុំស្តាប់មិនបាន? ។ ព្រះថេរៈតោលបញ្ជាក់ថា: លោកអស់អវិជ្ជាហើយ (កត្រីកន្ទុងផុតហើយ) លោកអាចចាក់ធ្លុះយល់ហេតុផលកងត្រៃលោក (ដួងព្រះអាទិត្យរះហើយ) លោកបានចំពេញសមណធម៌សព្វគ្រប់ហើយ (ពេលជាមង្គលមកដល់ ហើយ) អាត្មាបានរស់នៅយូរគួរសមដែរហើយ បើអ្នកចង់សម្លាប់ក៏ធ្វើ តាមប្រាថ្នាចុះ ។

ចណ្ឌគិរីកៈទឹងក្តៅឥតឧបមា ក៏ចាប់លោកចាំងកំហែងចោះទៅកន្ទុង ខ្លះចឹកកំពុងពុះ ក្តៅងងេះយ៉ាងសន្ធោសន្ធៅ តែចឹកត្រឡប់ទៅជាត្រជាក់

វិញ គ្មានបណ្តាលឲ្យព្រះថេរៈក្តៅចិត្តចំពោះឡើយ ។ បណ្តាគំរាកៈក្តៅខ្លាំងក៏គាំងដុតភ្លើងជាថ្មីបន្តែមទៀតយ៉ាងច្រើនលើសមុន តែទឹកនៅតែត្រជាក់ដដែល ។ បណ្តាគំរាកៈធ្លាយយ៉ាងនេះអស់រាប់ជាន ព្រះថេរៈគង់ធ្វើព្រងើយ គ្មានក្តៅចិត្តចំពោះ ។ ឃើញហេតុដូច្នេះ បណ្តាគំរាកៈបានទៅក្រាបទូលព្រះបាទអសោក ។ ក៏ស្តេចយាងមក ហើយបានទ្រង់យល់ហេតុអស្ចារ្យមែន ។ ចំណែកព្រះថេរៈយល់ឮសំឡេងថា នៅថ្ងៃក្រោយ ព្រះបាទអសោកនឹងបានជាពុទ្ធសាសនូបត្ថម្ភក៍ដ៏ឆ្នើមក្នុងជម្ពូទ្វីប ដើមហោះទៅឮដូច្នោះ សំដែងបាដិហារ្យទេសនាទូន្មានព្រះបាទអសោក ឲ្យទ្រង់យល់នូវសេចក្តីនៃព្រះសទ្ធម្ម រួចក៏ទំនន្តទៅតាមអាកាសចៀសចេញទៅ ។ ព្រះបាទអសោក លើកព្រះហស្តគាំងគួរប្រណម្យចំពោះព្រះថេរៈ ហើយតាំងព្រះទ័យថាចាប់ពីថ្ងៃនេះទៅ ទ្រង់ត្រូវលះបង់អំពើអកុសលចោលចេញ ហើយនឹងចំពេញកុសលតាមឧភតនៃព្រះថេរៈ ។

ព្រះបាទអសោក ថ្លែងប្រាប់ចំនងយ៉ាងច្បាស់ចេញពីគុកជាទីសុខសម្រាន្តស្រាប់តែបណ្តាគំរាកៈហែតថា ព្រះអង្គយាងចេញទៅក្រៅមិនបានទេ ព្រោះព្រះអង្គចូលមកក្នុងទីនេះហើយ ។ ស្តេចសួរថា ឯងចង់សម្លាប់យើងឬ ? បណ្តាគំរាកៈឆ្លើយថា: ពិតមែន ព្រះករុណាថ្លៃវិសេស ។ ព្រះបាទអសោកទ្រង់មានព្រះបន្ទូលថា: បើដូច្នេះ មិនជាការណ៍អ្វីទេ យើងក៏ត្រូវសុខចិត្តឲ្យអ្នកសម្លាប់ដែរ តែយើងត្រូវសួរចំពោះឯងថា: បណ្តាយើងគាំងពីរនាក់

តើអ្នកណាចូលមកកន្លែងនេះមុន ។ បណ្ឌិតវិកៈឆ្លើយថា ខ្លួនគាត់ចូលមុន ។ ព្រះបាទអសោកត្រាស់ថា: អ្នកចូលមុនត្រូវស្លាប់មុន អ្នកចូលក្រោយត្រូវស្លាប់ក្រោយ រួចទ្រង់បញ្ជាឲ្យពួកសេនាចាប់បណ្ឌិតវិកៈសម្លាប់ក្នុងពេលនោះមួយរំពេច ។

អំពីព្រះបាទអសោកដែលទ្រង់មានសទ្ធាក្នុងព្រះពុទ្ធសាសនា បើតាមរឿងដូចពណ៌នាមកខាងលើ យើញថាមានសេចក្តីផ្សេងគ្នាវែងឆ្ងាយណាស់ ជាមួយនឹងដែលមានសេចក្តីថា នេះគ្រាន់តែជាមេរៀនបន្តិចបន្តួចឲ្យទ្រង់ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា នឹងសេចក្តីប្រែពីភាសាថ្មកំណរបស់ព្រះតេជគុណ គីម-អាន ដែលថា សម្តេចត្រូវបានខ្លួនឯងស្តេចអសោកឲ្យជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ។

ចំពោះការណ៍នេះ គួរគប្បីពិចារណាដែរ បើខុសតែឈ្មោះ យើងត្រូវសន្និដ្ឋានថា ដោយមានការភ្លាំងភ្លាត់ ព្រោះចារចម្លងរមែងតែបណ្តាលឲ្យមានហេតុដូច្នេះ នេះគឺផ្សេងគ្នាទាំងឈ្មោះទាំងដំណើររឿង ។

២) អំពីមួយជាយនៃព្រះបាទអសោកដែលទ្រង់មានបំណងចង់ឃាញព្រះអនុជរបស់ព្រះអង្គឲ្យជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ក្នុងគម្ពីរមហាវង្សព្រះនាមព្រះអនុជហៅថា «តិស្សៈ» ក្នុងសេចក្តីប្រែរបស់ព្រះតេជគុណ គីម-អាន ព្រះអនុជព្រះនាម «វិតសោក» តែត្រង់ការខុសឈ្មោះគ្នាប៉ុណ្ណោះ មិនជាការអ្វីឡើយ ឲ្យតែដំណើររឿងមានសភាពស្របគ្នា ។ ក្នុង

សៀវភៅព្រឹត្តិប័ត្រនៃសាលាបារាំងចុងបូពាប្រទេស ក្បាលទី ៤-១៩០៤
(Bulletin de l'Ecole Française Extrême Orient Tome IV 1904)
ត្រង់ការពិនិត្យផ្នែកអក្សរសាស្ត្រខាងពុទ្ធសាសនា នៃលោក ហ៊ុយ ប៊ែរ
(Etude de littérature Bouddhique par Mr Ed-Huber) ស្តីពីព្រះ
បាទអសោក មានចែងថា មនុស្សដែលព្រះបាទអសោកប្រទានដំបូន្មាន
ដើម្បីឲ្យយល់ច្បាស់នូវព្រះពុទ្ធសាសនា មិនមែនព្រះអនុជរបស់ព្រះអង្គទេ
គឺជាមន្ត្រីមួយរូបរបស់ព្រះអង្គឈ្មោះ "យស" ។ ចំពោះរឿងនេះ ក្នុង
គម្ពីរមហាវង្សនិងសេចក្តីប្រែរបស់ព្រះតេជគុណ គឹម-អាន មានការស្រប
គ្នាត្រង់រូបបុគ្គល គឺថាជាតួព្រះអនុជតែមួយ គ្រាន់តែខុសព្រះនាម ឯក្នុង
សេចក្តីរបស់លោក "ហ៊ុយប៊ែរ" តួរូបបុគ្គលនោះគឺបែរជាមន្ត្រីទៅវិញ មិន
មែនជាព្រះអនុជរបស់ស្តេច ។

អំពីដំណើរទៅជាយកលនៃព្រះបាទអសោក ក្នុងគម្ពីរមហាវង្ស មាន
ពិស្តារជាងសេចក្តីប្រែរបស់ព្រះតេជគុណ គឹម-អាន និងសេចក្តីរបស់លោក
ហ៊ុយប៊ែរ គឺថាក្នុងសេចក្តីប្រែ គឹម-អាន មានពោលតែត្រង់ព្រះបាទ
អសោកឲ្យព្រះអនុជសោយរាជ្យ ៧ថ្ងៃ ក្នុងសេចក្តីលោកហ៊ុយប៊ែរ មាន
ពោលតែត្រង់ព្រះបាទអសោកឲ្យអាមាត្យទៅរកក្បាល តាមតែក្បាលសត្វ
អ្វីក៏ដោយ ចំណែក "យស:" ព្រះបាទអសោកឲ្យទៅរកក្បាលមនុស្ស
មកថ្វាយលោក ។ ក្នុងគម្ពីរមហាវង្ស មានតាំងឲ្យសោយរាជ្យផង មានតាំង
ឲ្យរកក្បាលផង ។

(នៅមានត)

កំពុ ថាច់ - សើយ សារី រៀបរៀង

ឧទាហរណ៍ ៣ ដង

វេលានេះ សូមតាំងអំពីកល្យាណធម៌ ៥ ប្រការ ដែលមានក្នុងគម្ពីរធម្មបទដ្ឋកថា ត្រង់អត្ថវណ្ណនា ដោយហេតុសុភាសិតនេះជាបឋមឧបនិស្ស័យចូលទៅក្នុងកល្យាណធម៌ ដូចមានបាលីថា៖

អត្តានមេវ បឋមំ បដិរូបេ និវេសយេ

អថញ្ញមនុសាសេយ្យ ន កិលិស្សេយ្យ បណ្ឌិតោ ។

សេចក្តីថា: បណ្ឌិតគួរតាំងខ្លួនក្នុងគុណធម៌ដ៏សមគួរជាមុនសិន សឹមប្រៀនប្រដៅអ្នកដទៃជាខាងក្រោយ ទើបមិនសៅហ្មង ។

សេចក្តីអធិប្បាយ:ពាក្យថា បណ្ឌិតគួរតាំងខ្លួនក្នុងគុណធម៌ដ៏សមគួរនោះ ចានដល់ការដំកល់ខ្លួនក្នុងកល្យាណធម៌ ៥ ប្រការឲ្យល្អប្រពៃ មិនឲ្យមានសៅហ្មងប្រការណាមួយឡើយ ។ បុគ្គលអ្នកដំកល់ខ្លួនក្នុងកល្យាណធម៌ដែលបរិយាយខាងក្រោមនេះ ទើបលោកហៅបុគ្គលមានគុណធម៌តាំងនៅក្នុងខ្លួន ប្រសិនបើចង់ប្រៀនប្រដៅអ្នកដទៃជាខាងក្រោយវិមិនសៅហ្មងដោយហេតុផ្សេង ។ មានពាក្យតុះតិះដៀលអំពីសំណាក់នៃវិញ្ញូជនថាងាយជាដើម, កល្យាណធម៌ប្រែថា ធម៌ដ៏ល្អ មាន ៥ ប្រការដូចបន្ទាប់មានតិកាគាថានេះ៖

๑- មេត្តា គឺតបន់តែឲ្យគេបានសុខ ចាំឯបន់ឲ្យគេប្រាសចាកទុក្ខ; ๒- សម្មាអាជីវៈ ចិញ្ចឹមជីវិតដោយប្រពៃ; ๓- សទារសន្តោសៈ គ្រេកអរស្កប់ចំពោះតែភរិយារបស់ខ្លួន មិនគ្រេកត្រអាលនឹងស្ត្រីដទៃ; ๔- សច្ចៈ ពិតត្រង់; ๕- សតិ មានស្មារតីបរិបូណ៌មិនវង្វេងវង្វាន់ ។

សូមលើកមាតិកាមួយ ។ យកមកអធិប្បាយដូចតទៅ៖

ធម៌ទី ๑- មេត្តា គឺតបន់ឲ្យតែគេបានសុខ ចាំឯបន់ឲ្យគេប្រាសចាកទុក្ខ; អធិប្បាយថា: ឥស្សរជនចាំឯឲ្យមានព្រះពាជាដាដើម នឹងពួកគ្រប់ក្រសួង ដែលព្រះអង្គ អស់លោក-អ្នកតែងមានព្រះទ័យមានចិត្តគោរពេញដោយមេត្តាព្រហ្មវិហារធម៌ គ្របជណ្តប់ទៅលើប្រជាពលរដ្ឋគ្រប់ប្រភេទ គឺមានការជួយសង្គ្រោះក្នុងវេលាដែលប្រជាពស្ត្រូមានអាសន្ន ឬមានគ្រោះថ្នាក់ ដូចភ្លើងឆេះ ទឹកជន់លិចផ្ទះសម្បែង ឬអ្នកក្រីក្រលំបាកដាដើម ដែលព្រះអង្គ-អស់លោកទ្រង់មានព្រះទ័យ មានចិត្តសន្តោស កាលបើឃើញភ្លើងឆេះមានការជួយចាត់វិធានការដូចជាបាញ់ទឹកជាដើម ដើម្បីញាំងអគ្គិភ័យនោះឲ្យចាលបាញ់ ម្យ៉ាងទៀតមានសេចក្តីសង្គ្រោះដល់ប្រជាពស្ត្រក្រីក្រលំបាក ឬដល់ប្រជាពស្ត្រដែលលិចចុះក្នុងហាយនភាព មានការប្រទាន-ឲ្យទ្រព្យវត្ថុផ្សេង ។ មានសំពត់ ភោអាវ នឹងរូបិយវត្ថុជាដើម ដើម្បីជួយទប់ទល់ដល់ដីវភាពប្រជាពស្ត្រដែលធ្លាក់ចុះទៅក្នុងមហន្តរាយ ឬមានការជួយការពារទ្រព្យសម្តគ្រប់បែបយ៉ាង មានចោរលួច ឬមានពួកចង្រៃ-

មិត្រចូលមកវុកពនចង្កើតចលាចល ធ្វើបាបប្រជាកស្ត្រកុងឥដ្ឋបន្ទុកឥ
ក្រុង ខេត្តក្រៅជាដើម មិនតែប៉ុណ្ណោះសោតទៀត ថែមទាំងរំលែងរក
មធ្យោបាយដ៏ប្រពៃ ដើម្បីលើកដម្កើងនូវជីវភាពរបស់ប្រជាកស្ត្រឲ្យទៅ
កាន់សេចក្តីចំរើនដោយសេដ្ឋកិច្ចគ្រប់យ៉ាង មានចំនប់ចប់ពីក លើកថ្លៃ
ដីកស្រែអណ្តូង ធ្វើស្ពានសង់សាលារៀនជាដើម ដើម្បីជាប្រយោជន៍សា-
ធារណៈដល់ពលរដ្ឋទូទៅ ដូចដែនការសម្តេចព្រះមហាក្សត្រយើងសព្វថ្ងៃ
នេះឯង ។ ការងារទាំងប៉ុន្មាននេះចាត់ចូលកុងឥានមួយហៅថា សាធារណ
ឥានប្រកបដោយមេគ្គាជាកល្យាណធម៌ ដែលព្រះអង្គទ្រង់សំដែងថា ជា
ឥានមានផលវិសេសជាងឥានទាំងពួង មានអានិសង្សខ្ពស់ខ្ពស្តើយចំផុត
អធិប្បាយមកប៉ុណ្ណោះ ទើបសមនឹងពាក្យថា: តិតបន់តែឲ្យគេបានសុខ
ទាំងបន់ឲ្យគេច្រាសចាកទុក្ខ ។

ទី ២ សម្មាអាជីវៈ: ការចិញ្ចឹមជីវិតដោយប្រពៃ អធិប្បាយថា បុគ្គល
ដែលចិញ្ចឹមជីវិតដោយល្អ ជាអ្នកមានប្រក្រតីរស់នៅដោយឥធម៌ គឺវៀរចាក
ព្យាយាមជាគ្រឿងចិញ្ចឹមជីវិតខុស ដែលប្រព្រឹត្តទៅដោយអំណាចនៃ
កិរិយាប្រព្រឹត្តកន្ទុងច្បាប់ បើជាគ្រហស្ថវៀរចាកជំនួញ ៥ ប្រការ មានសត្ថ-
វណិជ្ជា ការជួញសាស្ត្រាវុធ មានជាវលំពែងជាដើម ដែលជាគ្រឿងប្រ-
ហារជីវិតសត្វទាំងពួងមានមនុស្សជាដើម បើកិកអ្នកបួសកុងពុទ្ធសាសនា
វៀរចាកការប្រព្រឹត្តកន្ទុងនូវសិក្ខាបទ ៦ ប្រការ មានកិកអ្នកច្រាំថ្នាលាមក

ឲ្យសេចក្តីប្រាថ្នាត្រូបសង្កត់បាន ហើយពោលអួតខ្លួនថាមនុស្សធម៌ គឺមហា-
គ្គតធម៌ធំឆ្ងាយក្តីរធម៌ដែលមិនមានក្នុងខ្លួន ព្រោះហេតុតែគ្រឿងចិញ្ចឹម
ជីវិត ប៉ុន្តែលុះដែលរៀបចាកអំពើលាមកដូចសំដែងរួចមកហើយ ទើប
ឈ្មោះថា ការចិញ្ចឹមជីវិតប្រកបដោយធម៌ ។

ទី ៣ សន្ថារសន្ថោសៈ ត្រេកអរស្មោះត្រង់ចំពោះតែភរិយា
របស់ខ្លួន មិនត្រេកត្រអាលនឹងស្ត្រីដទៃ ។ ប៉ុន្តែលុះជាស្វាមីត្រូវមានការ
ចែកវិលេកឲ្យវត្តុសព្វយ៉ាងដល់ភរិយា គឺត្រូវឲ្យអំណាចដាច់ក្នុងផ្ទះ ឲ្យ
គ្រឿងអលង្ការសំលៀកបំពាក់ តាមកម្លាំងទ្រព្យដែលរកបាន កុំរិះគន់
ដណ្តើមធំក្នុងផ្ទះ កំណាញ់ស្តិតស្វាញ ហើយត្រូវមានពាក្យសំដីពីពេះ
ខន់ផ្អែម គួរឲ្យចាប់ចិត្តចំពោះភរិយាខ្លែត គឺត្រូវហៅរកភរិយាដោយពាក្យ
សុភាពរាបសារ កុំដេរប្រទេចផ្តាសា តំហក តម្រាម ឬប្រើសំដីសោះ
កក្រស់ ពាក្យឈ្លើយ មិនចុះរបៀប ម្យ៉ាងខ្លែតកុំមើលបំណាំប្រកាន់
ទោសចំពោះភរិយា ក្នុងវេលាដែលភរិយាប្រព្រឹត្តភ្លាំងភ្លាត់ម្តងម្តួយគាល
ឲ្យមានការលុបលាងចោល កុំថ្ងៃនេះធ្វើជាកប់អាន ថ្ងៃនេះទឹងមិនកប់អាន
ហើយត្រូវតាំងចិត្តឲ្យស្មោះត្រង់ គឺកុំប្រព្រឹត្តកន្ទងចិត្តភរិយា បើភរិយា
ឈឺថ្កាត់ ត្រូវរកថ្នាំសង្កូវ ឬអញ្ជើញគេឲ្យហ្មកមកព្យាបាលកេត កុំបណ្តែត
បណ្តោយឲ្យសោះ យ៉ាងនេះហៅថា មានការសន្ថោសចំពោះភរិយា ។

ទី ៤ សច្ចំ ខ្លែងត្រង់ ការពិតត្រង់ សេចក្តីពិត ដំណើរខ្លែង

ពាត់ ហៅថា សច្ចៈ ។

ការកុហក ពាក្យមិនពិត មិនទៀងត្រង់ ហៅថាមុសាវាទ ។ ធម៌ពីរប្រការនេះជាគូបដិបក្ខនឹងគ្នា ឬថាផ្ទុយគ្នា បើនរជននណាពោលពាក្យសច្ចៈ នរជននោះឈ្មោះថាមិនពោលពាក្យមុសាវាទ បើពោលមុសាឈ្មោះថាមិនពោលសច្ចៈទេ នរជននាំយកកុហក ឈ្មោះថាកន្ទុងបង់នូវពាក្យសច្ចៈដែលជាធម៌ឯក សមដូចព្រះពុទ្ធភាសិតថា៖

ឯកធម្មមតីតស្ស មុសាវាទិស្ស ជន្តុនោ
វិតិណ្ណបរលោកស្ស នត្ថិ បាបំ អការិយំ ។

សេចក្តីថា: ជនអ្នកនិយាយកុហក កន្ទុងសច្ចធម៌ឯក មានបរលោកធ្លាក់ផុតហើយ មិនមែនជាបុគ្គលមិនធ្វើបាបទេឬ; ។

អធិប្បាយថា ជនអ្នកនិយាយកុហក គឺនិយាយមិនពិត មិនត្រូវតាមដប្រជាគឺ ខ្លួនមិនឃើញថាឃើញ មិនឮថាឮ មិនដឹងថាដឹង ដោយគំនិតប្រុងឲ្យគេចូលចិត្តខុសយល់តាមខុស គោះបើអ្នកស្តាប់នោះជឿក្តី មិនជឿក្តីក៏ឈ្មោះថា និយាយកុហក ។

សំដីកុហកធ្វើឲ្យអ្នកដទៃនាំសជីវិតក៏សឹងមាន វិនាសដោយទ្រព្យសម្បត្តិក៏មាន ការពោលពាក្យមិនពិតរមែងឲ្យផលក្នុងលោកខាងមុខ ផលនោះឯងមានកម្លាំងច្រើនរមែងឲ្យទោសក្នុងបច្ចុប្បន្ន ដូចជានាងចិញ្ចាមាណាវិកា ដែលពោលបង្កាច់ព្រះពុទ្ធជាម្ចាស់ ធរណីស្រូបធ្លាក់ទៅឯក្នុងក្នុង

អរិយមហាន១ត រហូតមកដល់សព្វថ្ងៃនេះ បើសិនជាមានកម្ចាត់តិចវិញ ក៏ឲ្យគេសង្កៅក្នុងជាតិខាងមុខ។ បើអ្នកណាឧយ្យាយហើយ អ្នកនោះក៏កើតក្នុងឋ័ណា ច្រើនតែជាមនុស្សវៀចមាត់ ស្អុយមាត់ ឆៃបមាត់ ច្រើនមានគេចោទបង្កាច់ដោយពាក្យផ្សេង។ ។

សុភាសិតខាងលើនេះ សំដៅយកពាក្យពិត ការនិយាយឲ្យទាត់ជាធម៌ឯកឬជាធម៌មានតែមួយ ហៅថា សច្ចធម៌ ។ សំដីពិតនេះ ជាសំដីមិនស្អប់ ជាធម៌វិសេសជាងកល្យាណធម៌ទាំងអស់ សមដូចសុភាសិតថា:

សច្ចំ វេ អមតា វាចា ឯស ធម្មោ សនន្តនោ

សច្ចេ អត្ថេ ច ធម្មេ ច អាហុ សន្តោ បតិដ្ឋិតា ។

សេចក្តីថា ពាក្យមិនស្អប់ គឺពាក្យសច្ចៈនេះជាធម៌ដែលបណ្ឌិតព្រមព្រៀងហើយ សប្បុរសតាំងឡាយលោកស្ថិតនៅក្នុងសច្ចៈតាមធម្មតាមិនឃ្លៀងឃ្លាតឡើយ ។

៥- សតិ មានស្មារតីបរិបូណ៌មិនវង្វេងវង្វាន់ អធិប្បាយថា: សតិ ជាធម៌មានឧបការៈច្រើន ជាគុណធម៌ដ៏សំខាន់ខាងការនឹកឃើញក្នុងវេលាដែលធ្លាប់ហើយ និយាយហើយ គិតហើយ សូម្បីយូរៗក៏នឹកឃើញបាន ។ សតិជាធម៌សំខាន់បំផុត ដែលធ្វើចិត្តឲ្យបរិសុទ្ធម៉ត់ចត់ល្អ ជាធម៌ធ្វើសត្វឲ្យរឹងដំហរតាំងនៅតាមហាន:ខាងដើមរបស់ខ្លួនបានគឺ បើមានយសសក្តិ ដំណែងតោះតូចតោះធំក៏មិនធ្លាក់ពីដំណែងនោះ ឬបើមាន

កោគសម្បត្តិ ។ នោះក៏មិនមានអន្តរាយដោយហេតុផ្សេងឡើយ ព្រោះសតិជាគ្រឿងចាប់ចិត្តមិនឲ្យរវើរវាយសាត់អណ្តែតទៅតាមអារម្មណ៍ផ្សេងៗ ដូចចិត្តចង់ប្រព្រឹត្តអបាយមុខ សតិចាប់ភ្លាមថា ទីនេះជា «អបាយមុខ» ។ លុះសតិចាប់ដូច្នេះហើយចិត្តក៏មិនចង់ទៅតែម្ល៉ាង់ សមដូចទេសនាន័យដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដែងថា ឯកាយនោ អយំ ភិក្ខវេ មគ្គោ សន្តោ វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ ។

ប្រែថា ម្នាលភិក្ខុទាំងឡាយ ផ្លូវនេះជាផ្លូវជាទីទៅតែម្នាក់ឯង ដើម្បីសេចក្តីបរិសុទ្ធិរបស់សត្វទាំងឡាយ ដើម្បីកន្ទងបង់នូវសេចក្តីសោកស្រណោះអាឡោះអាល័យ នឹងសេចក្តីខ្សឹកខ្សួលទាំងឡាយ ដើម្បីរំលត់នូវទុក្ខនឹងទោមនស្ស ដើម្បីត្រាស់ដឹងនូវធម៌ដែលគួរត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ ផ្លូវនោះបានដល់សតិបដ្ឋាន ៤ យ៉ាងគឺ:

១- កាយានុបស្សនាសតិបដ្ឋាន ដំកល់សតិពិចារណាកាយជាអារម្មណ៍ ។

២- វេទនានុបស្សនាសតិបដ្ឋាន ដំកល់សតិពិចារណាវេទនាជាអារម្មណ៍ ។

៣- ចិត្តានុបស្សនាសតិបដ្ឋាន ដំកល់សតិពិចារណាចិត្ត

ជាអារម្មណ៍ ។

๔- ឧម្មាទុបសដ្ឋានាសតិបដ្ឋាន ដំកល់សតិពិចារណាកន្លែ
ធម៌ជាអារម្មណ៍ ។

បុគ្គលកាលបើបានតាំងសតិកំណត់អារម្មណ៍ ដូចសំដែងមកហើយ
ចិត្តក៏ធ្លាក់ចូលទៅក្នុងសេចក្តីគ្រេងសៅហ្មង ដល់ខ្លួនសេចក្តីជ្រះថ្លាជាខណៈ ។
ដោយលំដាប់ទៅ ឃសសត្តិជាដើមក៏ចំរើនដល់បុគ្គលនោះមិនខាន ។

សំដែងអំពីកល្យាណធម៌ ដែលជាធម៌មានគុណសម្បត្តិខ្ពង់ខ្ពស់
ដែលជាធម៌របស់ព្រះអរិយបុគ្គលតាំងឡើងអំពីរអស់កាលជានិច្ច ។

បុគ្គលអ្នកដំកល់ខ្លួនក្នុងកល្យាណធម៌ ៥ ប្រការនេះបាន ទើបហៅថា
បណ្ឌិតពេញបរិបូណ៌ ហើយចង់ខ្លួនានប្រៀនប្រដៅបុគ្គលដទៃជាខាង
ក្រោយទើបមិនសៅហ្មង ។ ព្រោះហេតុនេះ សាធុជនតាំងឡើងគួរ
តំអប់រំក្នុងកល្យាណធម៌តាំងនេះកុំបីត្អូសប្រហែសឡើយ ។

ព្រះអភិធម្មបិដក

(កថ្នីរព្រះមហាបដ្ឋាន)

លោក ប៊ូ-ប៉ូ រៀបរៀង

(តមក)

ហេតុដូច្នោះ អ្នកប្រាជ្ញតម្រិះដូច្នេះថា តាកាវល្លនីធ៌អាក្រក់នោះ អាស្រ័យដោយយការសេពគប់ចំពោះបុគ្គលល្អនីធ៌អាក្រក់ ។ នីធ៌ជាប់ស្រដីថ្នីដល់មនុស្សសត្វដែលមានជីវិត សូម្បីរបស់ឥតជីវិត គឺដើមស្វាយមានផ្លែជារសដ៏ផ្អែមល្ហែម ប៉ុន្តែទៅចូលលាយឡំជាមួយវល្ទិបណ្តូលតេជ្រនីធ៌ដើមស្វាយ កំបែរជាមានរសល្វីនី លែធ៌ជាទីទុយមនៃជនទាំងពួងទៅវិញ ។ លុះក្រោយ ព្រះបរមគោធិសត្វធ្វើទុក្ខយឲ្យដាំឈើអែម ឲ្យស្រោចទឹកឃ្មុំទឹកអំពៅទឹកស្ករត្នោត រសជាតិដែលល្វីនីនោះក៏ជាត់អស់ទៅ ត្រឡប់ជាមានផ្លែជារសផ្អែមពិសាឆ្ងាញ់ឡើងវិញ ។ ដើមស្វាយជារបស់ឥតចិត្តថ្នីមឥតវិញ្ញាណ នៅតែមានអាការប្រែប្រួលតីផ្អែមទៅជាជូរ។ ទៅជាផ្អែម ។

បុគ្គលនីធ៌ជាន់ខ្ពស់សេចក្តីសុខ នីរទុក្ខ នីរោគ នីរភ័យ ក៏អាស្រ័យតែជាន់សេពគប់នីធ៌អ្នកប្រាជ្ញ ប៉ើមានទុក្ខភ័យវិញ ហេតុតែរួមសង្វាសជាមួយមនុស្សពាល សមដូចព្រះពុទ្ធភាសិតថា៖

ពាលសង្គតចារី ហិ ទីឃមទ្ធាន សោចតិ
ទុក្ខោ ពាលេហិ សំវាសោ អមិត្តេនេវ សព្វទា ។

បុគ្គលដែលសេពគប់នឹងបុគ្គលពាលនោះ តែងនាំឲ្យកើតទុក្ខក្នុងជាតិនេះនឹងជាតិខាងមុខ ដូចជាសេពគប់នឹងសត្រូវគ្រប់ពេលវេលា សេពគប់នឹងអ្នកប្រាជ្ញ ដូចជាសមាគមនឹងញាតិដែលជាទីស្រឡាញ់ ។ ហេតុដូច្នោះអ្នកមានបញ្ញា គប្បីសេពគប់តែនឹងបណ្ឌិត កុំសេពគប់នឹងពាលព្រោះថាសេពគប់នឹងពាលជាហេតុនៃសេចក្តីវិនាស ។ បុគ្គលមួយសន្ថិសាមនុស្សពាលពាំនាំឲ្យឃ្លាយប្រៀបដូចត្រីស្អុយ ។ ការសេពគប់នឹងមនុស្សពាលនោះ ប្រៀបដូចជាស្វឹកឈើខ្ចប់នូវត្រីស្អុយ ។ អ្នកប្រាជ្ញពាំនាំឲ្យឃ្លាយប្រៀបដូចជាគ្រឿងក្រអូបគឺក្រឹស្នានឹងក្លាំពាក់ ។ ការសេពគប់នឹងអ្នកប្រាជ្ញនោះ ប្រៀបដូចជាស្វឹកឈើខ្ចប់នូវគ្រឿងក្រអូប ស្វឹកឈើរមែងក្រអូបទៅតាមធម្មតា ។ ការសេពគប់នឹងមនុស្សពាលអ្នកប្រាជ្ញតិះដៀល ។ ការសេពគប់នឹងបណ្ឌិត អ្នកប្រាជ្ញសរសើរ ព្រោះថាសេពគប់ពាលនាំឲ្យកើតទុក្ខពាំនាំពីរជាតិ សេពគប់អ្នកប្រាជ្ញ នាំឲ្យបានសុខពាំនាំក្នុងជាតិនេះនឹងជាតិមុខ ។

រឿងតាបសទូន្មានបុត្រ

សម្តេចព្រះបរមសាស្តា កាលសោយព្រះជាតិជាតាបសនៅក្នុងអរញ្ញប្រទេស កាលនឹងឲ្យឧភតជល់បុត្រដែលលាឃ្លាតចេញទៅនៅក្នុងនគរដើបប្រៀនប្រដៅថា ៖

តាត ម្នាលកូនជាទីស្រឡាញ់ ឯតោ កតោ កូននឹងទៅដំណើ

ទីនេះ ចូរតប់រកខ្លួនកុំឲ្យណាមិត្រមានចិត្តជាកុសល បុគ្គលណាមិនប្រព្រឹត្តខុសចំពោះដោយកាយវាចាចិត្ត កូនចូរសេពគប់នូវបុគ្គលនោះចុះ ។

ប្រការមួយទៀត បុគ្គលណាមិនបានប្រមាថមើលងាយ ជាអ្នកមានអនុកម្បាកចិត្ត គឺចិត្តជួយសង្គ្រោះ កូនចូរសេពគប់នូវបុគ្គលនោះចុះ ។ មា សេវ កូនចូរកុំសេពគប់នឹងមិត្រដែលមានចិត្តថោកអាក្រក់ជាដាច់ ។ បុគ្គលណា ចិត្តនឹកពាក់ព័ន្ធមិនដូចគ្នា មានចិត្តប្រែប្រួលត្រឡប់ត្រឡែន មានចិត្តដូចទឹកជ្រលក់គឺនាប់សាបរលាបពណ៌ ឯម្នាក្សត្រ ប្រសិនបើកូមិមណ្ឌលនោះមានតែមនុស្សបែបនេះម្នាក់ គ្មានមនុស្សឯទៀតទេ ក៏កូនកុំសេពគប់នឹងមនុស្សនោះឡើយ ប្រៀបដូចបុគ្គលមិនហ៊ានចូលទៅជិតអាសរពិស ចូរដៀសវាងឲ្យឆ្ងាយដូចមាគ៌ាដែលប្រឡាក់ដោយលាមក ចូរគេចចេញឲ្យឆ្ងាយ កុំសេពគប់ ដូចបុគ្គលដើរផ្លូវ ចៀសវាងនូវផ្លូវដែលប្រកបដោយអន្តរាយ ។

ប្រការមួយទៀត មនុស្សពាលតាំងខ្លួនជាទីតើតនៃភ័យ ១បដ្ឋគ ១បសគ្គ ។ ភ័យ ១បដ្ឋគនឹង ១បសគ្គណាដែលនឹងតើតមានឡើង ក៏តើតមានឡើងតែអំពីបុគ្គលពាល មិនមែនតើតមានឡើងអំពីអ្នកប្រាជ្ញទេ។ សម្បដិច្ឆយា បុគ្គលពាលតាំងខ្លួនោះឈ្មោះថាប្រកបដោយភ័យជុំវិញ អ្នកប្រាជ្ញតាំងខ្លួនជាទីក្សេមក្សាន្តគ្មានទុក្ខភ័យទេ ។

ហេតុដូច្នោះ សម្តេចព្រះបរមលោកុត្តមាចារ្យ ទើបទ្រង់ប្រទាន

ព្រះសទ្ធម្មទេសនាដល់ភិក្ខុពាំងឡាយថា សេយ្យថាបិ ភិក្ខវេ ម្ចាល
ភិក្ខុពាំងឡាយ ភ្លើងនោះ អាស្រ័យផ្ទះដែលបុគ្គលប្រក់ដោយស្បូវនឹងមាន
ជញ្ជាំងធ្វើអំពីដើមបបុស លុះផុតពីផ្ទះជញ្ជាំងបបុសនឹងផ្ទះដែលបុគ្គលប្រក់
ដោយស្បូវហើយ ក៏ឆាបឆេះនូវផ្ទះកំពូលតទៅទៀត សេចក្តីនេះដូច
ម្តេច ភ័យទុប្រពៃនឹងទុបសគ្គពាំងឡាយនេះ ក៏កើតតែអំពីបុគ្គល
ពាលដូច្នោះ ។ បុគ្គលពាលពាំងឡាយនោះអាចនាំនូវទុក្ខទោសភ័យ
ជាអាទិ៍មកឲ្យដល់បុគ្គលអ្នកសេពគប់ធ្វើតាម វាចា ប្រព្រឹត្តតាម ។ បុគ្គល
ពាលនោះប្រៀបដូចជាភ្លើងឆេះ បណ្ឌិតា បន ខាងអ្នកប្រាជ្ញ
ពាំងឡាយវិញ ប្រៀបដូចទីដ៏ប្រកបដោយអារក្ខាជុំវិញ អនុកម្បាវេបតិ-
ទោ វិយ មិនដូច្នោះ ប្រៀបដូចទីនឹងប្រកបដោយប្រទីបដែលបុគ្គល
អុជទុកបំភ្លឺ មិនដូច្នោះ ឧបមាដូចទីដ៏ប្រកបដោយថ្ងាយគឺគោជនាហារ
ដ៏បរិបូណ៌ដូចគ្នា ។ ឯអ្នកប្រាជ្ញពាំងឡាយនោះ អាចកំចាត់បង់នូវទុក្ខភ័យ
ជាដើមនៃបុគ្គលអ្នកចូលមកសេពគប់នឹងខ្លួន ។ ហេតុដូច្នោះ អ្នកមាន
ប្រាជ្ញាកុំគប្បីសេពគប់នឹងបុគ្គលពាល គប្បីសេពគប់តែនឹងបណ្ឌិតអ្នកមាន
ប្រាជ្ញាញាណ គប់ប្រាជ្ញក៏ជាប្រាជ្ញ គប់ពាលក៏ជាពាល ។ អាសេវ-
នៈការសេពគប់យ៉ាងណា ក៏ប្រព្រឹត្តទៅជាយ៉ាងនោះ ហេតុដូច្នោះ
អាសេវនៈ ការសេពគប់នោះ ទើបឈ្មោះថាជាបច្ច័យ ។ មនុស្ស
ដែលបុគ្គលសេពគប់ក៏ជាបច្ច័យដល់បុគ្គលអ្នកសេពគប់ សេចក្តីនេះមាន

ឧបមាដូចម្តេច ជវនចិត្តកំជាអាសេវនប្បច្ច័យដល់ជវនចិត្ត ។ ជវនចិត្តជាកុសល កំជាអាសេវនប្បច្ច័យដល់ជវនចិត្តជាកុសល ។ ជវនចិត្តជាកុសល ជាកិរិយាចិត្ត ឥឯ លោកុត្តរចិត្តកំមានឧបមេយ្យដូច្នោះ អ្នកប្រាជ្ញគប្បីចូលចិត្តដោយន័យដូច្នេះ ។

កម្មប្បច្ច័យ

កម្មប្បច្ចយដ្ឋេនេសេ កម្មាដិ ដិដ្ឋធម្មវេទនិយ-កម្មំ ឧបបជ្ជវេទនិយំ អបរាបរិយំ តុរិតំ ពាហុល្លំ យថាសង្ខំ កតត្តាកម្មំ ជនក្ខបត្តម្ភំ ឧបព័ន្ធក្ខប-ឃាដកញ្ចាតិ ឯតាឧសវិនេន វិភត្តាដិតិ ។

លំដាប់នេះ សូមវិសជ្ជនាកង់កម្មប្បច្ច័យតទៅ ដំណើរសេចក្តីថា កម្មប្បច្ចយដ្ឋេនេសេ កង់កម្មប្បច្ចយនិទ្ទេសមាតិកាព្រះអនន្តញ្ញាណប្រកាន់ព្រះសព្វញ្ញុទេសនាថា «កម្មប្បច្ចយោ» កម្មនោះបានឈ្មោះថាជាបច្ច័យ ព្រោះហេតុថា កុសលកម្មនិងអកុសលកម្ម ដែលបុគ្គលធ្វើនោះជាបច្ច័យឲ្យនូវបដិសន្ធិកំណើតកង់អបរាបរវេទនា និងជាបច្ច័យឲ្យបានសោយសុខនិងទុក្ខកង់បច្ចុប្បន្នកាលជាដើម ។

ព្រះអដ្ឋកថាចារ្យពោលអនុលោមតាមព្រះពុទ្ធដីកាថា «កិរិយ-តិតិ កម្មំ» សភាវៈឯណាដែលសត្វគប្បីធ្វើ សភាវៈនោះឈ្មោះថាកម្ម ។ បើរបស់ដែលធ្វើនោះជាកុសល កំឈ្មោះថាកុសល

កម្ម ។ បើបុគ្គលធ្វើនោះជាអកុសលកម្ម ក៏ឈ្មោះថាអកុសលកម្ម ។ បើធ្វើដោយកាយ ក៏ឈ្មោះថាកាយកម្ម ។ បើធ្វើដោយវាចា ក៏ឈ្មោះថាវចីកម្ម ។ បើធ្វើដោយចិត្ត ក៏ឈ្មោះថាមនោកម្ម ។ ក៏ពាក្យដែលធ្វើនោះឯងឈ្មោះថាកម្ម ។ កម្មសព្វ សំដៅយកចាំងពីវិចណៃក គឺចំណែកកុសលទើងអកុសល ប៉ុន្តែសាមញ្ញជនកន្លងលោកសន្និវាសច្រើនតែនិយាយខាងចំណែកអកុសល គឺកន្លងត្រាមានភ័យមានទុក្ខត្រួយហើយតែងលាន់មាត់ថា កម្ម ៗ ដូច្នេះ ដោយអំណាចនៃទុក្ខភ័យ ។ អ្នកប្រាជ្ញគប្បីចូលចិត្តថា កម្មសព្វនោះមិនមែនជាចំណែកតែខាងអកុសលម្យ៉ាងប៉ុណ្ណោះទេ ។

វិភត្តាទិ កម្មចែកចេញជា ១១ ប្រការគឺ៖

๑- ទិដ្ឋធម្មវេទនីយកម្ម	๗- អបរាបរិយវេទនីយកម្ម
๒- ឧបបជ្ជវេទនីយកម្ម	๘- ជនកកម្ម
๓- អបរាបរិយវេទនីយកម្ម	๙- ឧបត្ថម្ភកកម្ម
๔- គរុកម្ម	๑๐- ឧបបីឡកកម្ម
๕- អាចិណ្ណកម្ម	๑๑- ឧបឃាតកកម្ម ។
๖- យថាសន្នកម្ម	

សេចក្តីអធិប្បាយដោយសង្ខេប

(នៅមានត)

(តមក)

ឯខេវបុត្តកំបានថ្វាយបង្គំព្រះថេរៈនោះ ដោយដំកល់ចុះនូវអវយវៈមានអង្គច្រាំ ហើយកាន់យកកោដនដ៏ជាទិព្យតាំងនោះ ចាត់ចែងធ្វើទានប្រគេនព្រះថេរៈជាមុន ទើបបរិភោគខ្លួនឯងជាខាងក្រោយ ។

រំលេចដែលខេវបុត្តនោះបានឲ្យទានដល់ព្រះថេរៈផង ដល់មហាជនជាច្រើនផង រួចហើយកំប្រុងតែអំពីជាតិនោះ បានទៅកើតក្នុងស្ថានតាវតឹង្សទេវលោកវិញ បានសោយទិព្វសម្បត្តិដោយសិរី តែងអង្គាសទៅមកតែក្នុងកាមាវចរសួគ៌តាំង ៦ ជាន់គស់កាលជាយូរអង្វែង ។ លុះដល់មកក្នុងពុទ្ធកាលនៃព្រះមានព្រះភាគទ្រង់ព្រះនាមបទុម្មុត្តរៈ ជាម្ចាស់ត្រាស់ឡើងក្នុងលោក ខេវបុត្តនោះកំបានច្យុតចុះអំពីស្ថានទេវលោកនាយមកកើតក្នុងផ្ទះនៃសេដ្ឋីមាក់ជាមិច្ឆាទិដ្ឋិមានសម្បត្តិច្រើន ក្នុងនគរពារាណសី មាតាបិតាសន្មតនាមថា ខេវកុមារ ព្រោះមានរូបទោមល្អដូចទេវតា ។

លុះចំណេរកាលមកខាងក្រោយ ខេវកុមារនោះ បានដល់នូវភាពធំឡើងដ៏ធំក្តីហើយ មាតាបិតាកំធ្វើមរណកាលក្សីណក្សយជីវិតទៅ ។ ឯសម្បត្តិទ្រព្យតាំងប៉ុន្មានកំបានមកក្នុងកណ្តាប់ដៃរបស់ខេវកុមារតាំងអស់ ។ ខេវកុមារនោះកំបានរមៀលរមើលឃ្វាំងនានា មានឃ្វាំងពេញ

រៀងដោយកែវមានកែវមណី កែវមុត្តាជាដើម ហើយបានធ្វើសេចក្តីសន្និដ្ឋានចូលចិត្តថា បុព្វបុរសទាំងឡាយមានមាតាបិតារបស់អញជាដើម ជាមនុស្សមិច្ឆាទិដ្ឋិតតុំសត្រាន់តែសន្សំទ្រព្យសម្បត្តិទុកឥតប្រយោជន៍ តុំបានធ្វើទ្វារបុញ្ញកម្មតិចតួចឡើយ ឥឡូវនេះស្ថាប់ទៅកាន់បរលោក សូម្បីតែប្រាក់ចំនួនមួយកាកណិកក៏កាន់យកទៅពុំបានឡើយ ។ ចំណែកឯអាត្មាអញ ត្រូវតែកាន់យកទ្រព្យសម្បត្តិទាំងអស់នេះ ហើយទៅកាន់បរលោកប្រសើរជាងដោយពិត ។ ទេវកុមារបានពោលពាក្យដ៏ឃោរឃៅនេះហើយ ក៏ចាត់មនុស្សឲ្យយកស្ពាយផ្អែកទៅក្នុងនគរទាំងអស់ ឲ្យប្រជុំមនុស្សកំសត់ អ្នកដំណើរ អ្នកកំព្រានិងពួកអ្នកសួម ឲ្យចូលមកជួបជុំហើយក៏បានចាត់ខាយទ្វារឲ្យបើកទ្វារឃ្លាំងទាំងអស់ឲ្យទានដល់មនុស្សទាំងឡាយនោះ ឲ្យចូលយកតាមប្រាថ្នាប្រមាណ ៧ ថ្ងៃទើបអស់ រួចហើយទេវកុមារចូលទៅកាន់ព្រហ្មលោកខាងក្តាកាន់យកផ្នួសបួសជាតាបសឥសី បានធ្វើទ្វារកសិណបរិកម្ម ញុំាងអភិញ្ញាទាំងប្រាំមួយនិង សមាបត្តិទាំងប្រាំបី ឲ្យកើតឡើងក្នុងសន្តានអាចត្រាច់ទៅតាមអាកាសបានដោយប្រក្រតី ។

សម័យនោះឯង ព្រះមានព្រះភាគទ្រង់ព្រះនាមបទុមុត្តរៈទ្រង់គាស់រៃនៅដីតនគរហំសវតី មានតួកបរិសទ្យជាច្រើនជាគំនីមានទេវតានិងព្រហ្មតាមរោមរោមជាយសបរិវារ ព្រះអង្គសម្តែងធម៌ទេសនាប្រកបដោយព្រះអរិយសច្ចទាំងបួនដ៏ពិរោះគួរចាប់អារម្មណ៍ពន់ពេក ។

ក្នុងកាលនោះ តាបសឥសីនោះសោត កំពុងហោះមកតាមអាកាស ហើយបានឃើញខ្លួនមហាជនផង នូវស្មើនឹង ៦ ពណ៌ផ្សាយចេញអំពីព្រះសរីរកាយនៃព្រះមានព្រះភាគផង កំពុងសេចក្តីផ្តើមក្នុងចិត្តគិតថា « នេះតើគឺហេតុដូចម្តេច » ហើយក៏ចុះមកអំពីអាកាសវេហាស៍មួយរំពេច បានឃើញព្រះជិនស្រី ព្រះអង្គកំពុងសម្តែងព្រះធម៌ទេសនា ដោយដំណើរយ៉ាងយាសដ៏ប្រសើរ កំពុងចិត្តសោមនស្សជ្រះថ្លា ទ្រាំអង្គុយនៅក្នុងបន្ទោះបរិសទ្យប្រុងស្តាប់ព្រះធម៌ទេសនាដោយគោរព លុះបានស្តាប់ព្រះធម៌ចប់ស្រេចហើយ កំថ្វាយបង្គំព្រះមានព្រះភាគលាត្រឡប់ទៅកាន់អាស្រមបទវិញហោង ។

ឯតាបសឥសីនោះ បានស្ថិតនៅក្នុងកេវជាឥសីជរាបដល់អស់អាយុ កំបានឡើងទៅកើតក្នុងស្ថានតាវតឹង្សទេវលោក បានសោយទិព្យសម្បត្តិជាយូរអង្វែង តែងអន្ទោលទៅមកតែក្នុងកាមាវចរសួគ៌ទាំង ៦ ជាន់អស់កាលប្រមាណ ៣ កប្ប ។

មួយទៀត ទេវបុត្តនោះបានទៅកើតជាព្រះឥន្ទ្រាធិរាជជាស្តេចនៃទេវតាប្រមាណ ៥១ ជាតិ បានជាស្តេចចក្រពត្តិ ២១ ជាតិ សោយសម្បត្តិមនុស្សហើយទៅកើតក្នុងស្ថានសួគ៌វិញ ។

កាលដែលព្រះមានព្រះភាគជាម្ចាស់នៃយើង ទ្រង់បានត្រាស់ហើយ ទ្រង់ចូលបរមនិព្វានទៅ ទេវបុត្តនោះក៏ច្យុតចុះមកកើតក្នុងត្រកូលដ៏ស្តុក

ស្តេចមានឈ្មោះពុំប្រាកដ ក្នុងក្រុងសាវត្ថី លុះដល់ចំរើនវ័យធំឡើងមានអាយុ ៧ ឆ្នាំ ឃើញភិក្ខុជាធម្មកថិកមួយអង្គកំពុងសម្តែងធម៌ទេសនា ហើយបានចូលទៅជិតកាន់សំណាក់ភិក្ខុនោះ ប្រុងស្តាប់ព្រះធម៌ទេសនា តំបានន្លូវអនិច្ចសញ្ញាហើយអង្គុយចំរើនវិបស្សនាកន្លងទៅនោះ បានសម្រេចព្រះអរហត្តផលព្រមទាំងបដិសម្ភិទាបួន នឹងអភិញ្ញាច្រាំមួយ ជាព្រះអរហន្តវិសេសក្នុងលោក កំចាត់បង់នូវកិលេសទាំងពួង ហើយបានពិចារណាមើលន្លូវអំពើដែលខ្លួនបានធ្វើមកពីមុន ហើយប្រកាសច្រាច់នូវបុព្វចរិតនោះកន្លងទៅក្នុងកាលដំទុំព្រះកិក្ខុសង្ឃ ពោលន្លូវបទព្រះគាថាទាំងឡាយដូច្នេះថា :

ជារនោ កិរ សមុទ្ទោ បុព្វេ អាសិ នរុត្តមោ
លោកំ ពុទ្ធោ បមោចេន្តោ ឧទ្ទនោអមតំ បទំ
អធិប្បាយ ... ជានឮរឿង ។ មកថា កាលពីមុនមានព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមនារទៈដ៏ទត្តមជាន់នរជន ព្រះអង្គតែងប្រទានន្លូវទុច្ចាយនៃព្រះនិព្វានឈ្មោះអមតៈ ហើយញ៉ាំងសត្វលោកឲ្យរួចផុតចាកទុក្ខសព្វ ។ កាល ។

តស្មិំ សមយេ ឯកស្ស សាវកោ ធីទ្ធតន្ទ្រោ
កិក្កិតា ធីបកោ លទ្ធោ អាហារំ បរិភុញ្ជតិ

សម័យនោះមានព្រះថេរៈមួយអង្គ អ្នកផ្តាច់បង់នូវចំណងតិស៊ំយោជនៈ ជា

សាវ័កនៃព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមនារទៈនោះ លោកមានប្រាថ្នាដើម្បីស្វែងរកចង្ហាន់ឆ័ន្ទ លុះបានទូវចង្ហាន់ហើយក៏ឆាន់លើទីដួលមួយ ។

រុក្ខមូលំ គតាគច្ឆិ តត្ថសី រុក្ខទេវតា
ពុទ្ធុក្កិតា ឧទិក្ខន្តី អដ្ឋាសិ តស្ស សន្តិកេ

(កាលនោះ) ខ្ញុំកើតជារុក្ខទេវតាក្នុងទីនោះ បានចូលទៅជិតគល់ឈើដោយមានប្រាថ្នាចង់បរិភោគនូវអាហារ ក៏ឃើញមើល បានឃើញនៅក្នុងទីជិតនៃព្រះថេរៈជាសាវ័កនោះ ។

អដ្ឋាសិ មេ តត្ថបិណ្ឌំ ករុណាបុរិតន្តរេ
តហេត្វាន ទិត្តោ បិណ្ឌំ សហមានោ ឧទ្ទិ តទា

ព្រះថេរជាសាវ័កនោះ មានព្រះទ័យពេញដោយសេចក្តីករុណាជាដើម លោកបានប្រទានតត្តមួយពាន្ទូតដល់ខ្ញុំ លុះខ្ញុំកាន់យកហើយលះបង់នូវដុំបាយនោះហើយអត់សង្កត់នូវសេចក្តីស្រេកឃ្លាន បានប្រគេនដុំបាយនោះដល់ព្រះថេរវិញក្នុងកាលនោះឯង ។

អនិច្ចតា មយា បុព្វេ កតញ្ញូ ធាតុ សុបេសលេ
ជិឃច្ឆាបីឌិតោ ហោមិ ជាតោបិ ទេវយោនិយំ
អជ្ជ ខេត្តំវ លទ្ធំ មេ ទេយ្យធម្មោ ច វិជ្ជតិ
តំដំ ខេត្តំវ ភេបេមិ ករោតោ បរិមុត្តិយា
ឥតិ ចិន្តយិ វិដ្ឋិត្វា សាមិ ធាសស្ស ភៃ អលំ

សង្គហំ ๙๓ លោកស្មឹ កេនេ៩ បរលោកំ ๙តំ
វត្វា អថាសាហំ កុញ្ជំ សោចិ ឧយាឋ្ឋរេ តេជាហំ
បុញ្ញកម្មេន សុទ្ធន្តមលកក្ខណោ ។

(តមក) ខ្ញុំបានរំពឹងគិតថា អាត្មាអញបានកើតក្នុងកំណើតជាខ្មៅគ
ទំលក្រអត់អាហារ សេចក្តីស្រេកឃ្លានតែងបៀតបៀនជានិច្ច ព្រោះអាត្ម
អញពុំដែលបានឲ្យទានតិចតួច ដល់បុគ្គលដែលមានសីលជាទីស្រឡាញ់
កន្ងងជាតិពីមុនៗដល់ម្តងឡើយ ថ្ងៃនេះបុញ្ញវត្តអាត្មាអញបានហើយ ទាំង
ខ្មៅទានក៏អាត្មាអញបានដែរ ដូច្នេះត្រូវតែអាត្មាអញជាំពូជបុណ្យក្នុង
បុញ្ញវត្តនេះ ដើម្បីនឹងញុំាងខ្លួនឲ្យរួចផុតចាកកំពង់ដោយប្រពៃ លុះខ្ញុំបាន
គិតយ៉ាងនេះហើយ ក៏ថ្វាយបង្គំព្រះថេរៈទូលថាៈ បពិត្រលោកម្ចាស់ដ៏
ចំរើន លោកម្ចាស់កុំបាច់ធ្វើសេចក្តីសង្រ្គាះដល់ខ្ញុំក្នុងបច្ចុប្បន្ននេះឡើយ
សូមលោកម្ចាស់ធ្វើនូវសេចក្តីសង្រ្គាះដល់ខ្ញុំឯបរលោកវិញ លុះខ្ញុំពោល
ហើយក៏ប្រគេនថ្វាយដល់សមណៈអង្គនោះវិញ ឯសមណៈអង្គនោះសោត
មានព្រះទ័យប្រែនៅដោយសេចក្តីករុណា លោកបានទទួលយកហើយ
ក៏ឆាន់ចង្ហាន់នោះឯង ដោយបុញ្ញកម្មនោះ ទើបខ្ញុំបានបរិភោគនូវភោជនដ៏
ស្អាតឥតមន្ទិលសៅហ្មងឡើយ ។

តតោ ឧតោ ច នេវាសុ វដ្ឋតោ មហតី ឋិរី
ចិរកាលំ វសិត្វាន នេវិទ្ធីហិ សមង្គិតោ

ខ្ញុំឮតបុះចាកអត្តភាពនោះហើយ ចូលទៅសោយសម្បត្តិដ៏មានសិរីដ៏ប្រសើរក្នុងទេវលោកចាំង ៦ ជាន់ ប្រកបព្រមដោយទេវរាជ្ញីច្រើនជាអនេកបរិការស្ថិតនៅក្នុងទេវលោកនោះ អស់កាលជាយូរអង្វែងក្រៃពេក ។

សតសមាសេ្ឋ តោ កាបេ្ប បទុមុត្តរោ ជាយតោ
ឧបដ្ឋិ លោកជាយតោ ធម្មរាជា តថាគតោ

សម្តេចព្រះលោកនាយកជាម្ចាស់ទ្រង់ព្រះនាមបទុមុត្តរៈ ទ្រង់ជាអង្គតថាគត ជាស្តេចធម៌ តែងដឹកនាំសត្វលោកឲ្យឆ្ងងចាកសំសារៈចក្ក ព្រះអង្គបានត្រាស់ឡើងក្នុងមួយសែនកប្បមុនភទ្ទកប្បនេះ ។

មហិទ្ធិកោ តទា អាសឹ តាបសោ ភាវនេរតោ
សមាបត្តិបញ្ចកំ ញោ អាភោសេន ចភមហំ
តទាភោសេន កច្ចន្តោ វម្មេ ហំសវតីបុរេ
ពុទ្ធុំសីបវំកិំ តំ កេតុមាលាវិលាសិតំ
នេវសំយមវាត្យុហ្ម នេសេន្តំ អន្តសំ ជិនំ
ទិតវាន ឧភសា ដ្ឋិតោហំ បវិសន្តរេ
ធម្មំ សុត្វា ពុទ្ធោហំ ភារំ ភត្វាន សត្ថុនោ

កាលនោះខ្ញុំបានបួសជាតាបសឥសីនៅក្នុងព្រៃភាវនា (ជម្រុមដើមឈើច្រើន) ចំរើនឈានបានសំរេចសមាបត្តិ ៥ និងអភិញ្ញាចាំង ៥ ប្រកបដោយរឹទ្ធិ បានត្រាច់ទៅតាមអាកាស កាលដែលត្រាច់ទៅតាមអាកាស

នោះ ឃើញព្រះដ៏មានព្រះភាគទ្រង់មានព្រះទ័យត្រេកអរដោយដុំវិញ្ញាណ
ដូចលាភត្រជាដោយឧត្តមនគរដ៏ចំរើន មានចាំងពពួកទេវតាចាម
រោមជាបរិវារ កំពុងសំដែងព្រះធម៌ទេសនា ក្នុងក្រុងហ៊ិរណ្យវតីបុរីដែលជាទី
រមណីយដ្ឋាន ខ្ញុំក៏ចុះអំពីអាកាសមកដល់ដី ហើយឈរនៅក្នុងទ្វារ
បរិស័ទ ប្រុងស្តាប់ធម៌ទេសនាដោយគោរព ខ្ញុំមានចិត្តត្រេកអរក៏កាយ
យ៉ាងខ្លាំង ក៏បានធ្វើកិរិយាបូជាចំពោះព្រះសាស្តាថាវ្យាជាម្ចាស់ព្រះអង្គនោះ។

តតោ ចុតោ បសន្នោស្មិ តាវតឹសេ មនោរមេ
តឹសកប្បសហស្សានិ ឋវន្តោ នេវមានុសេ
ទុក្ខតឹ ជាតិជាតាមិ លភាមិ វិបុលំ សុខំ

ខ្ញុំបានច្យុតចុះចាកអត្តភាពអំពីតាបសនោះហើយ បានទៅកើតក្នុង
ឋានតាវតឹង្សដែលជាទីរីករាយនៃចិត្ត តែងត្រាច់ទៅកាន់ទេវលោកទីង
មនុស្សលោក តាំងដែលទៅកាន់ទុគ្គតិដល់ម្តង អស់កាលប្រមាណមិនបាន
ខ្ញុំតែងបានសោយសេចក្តីសុខដ៏បរិបូណ៌ ឥតមានសេចក្តីក្តៅក្រហាយ
ក្រហាន់ឡើយ ។

ឯកប្បញ្ញាសចតុក្ខត្តុំ នេវរជ្ជមការយឹ អនេកវីសតិក្ខត្តុំ ចក្កវត្តិអហោសហំ ។

ខ្ញុំបានសោយសម្បត្តិជាស្តេចនៃទេវតាប្រមាណ៧៥បមួយជាតិ
មួយទៀត ខ្ញុំបានសោយសម្បត្តិជាស្តេចចក្រពត្តិប្រមាណម្ភៃដងមួយជាតិ ។

ปเทสรชฺเช กาสาหิ๋ ตมฺหา ตหิ๋
สมฺมึ กตฺวาน กมฺมญฺจ ตตฺถ ตตฺถาภเต
โภคิโน ปุญฺญกมฺเมน สาวตฺถิปุรมุตฺตเม
อุปฺปชฺชิตฺวา กุเล เชฏฺเ ชาตียา สตฺตสฏฺิโก
สุตฺวา ธมฺมึ กเถนฺตสฺส กิกฺกุสญฺญาสญฺญิโน
กาสฏฺเ การิกาย อรหตฺตมปาปุณิ๋

ข้าพเจ้าขอนอบน้อมพระผู้มีพระภาคเจ้าพระองค์นั้น ๆ ในประเทศนั้น ๆ ในแคว้นนั้น ๆ ครั้นได้ทำกรรมนั้นแล้ว ๆ ในภพนั้น ๆ ในกำเนิดนั้น ๆ ในคติทั้งหลายนั้น ๆ ในภพทั้งหลายนั้น ๆ ในสังสารวัฏนั้น ๆ ในกัปนั้น ๆ ในกัปทั้งหลายนั้น ๆ ในอัตภาพนั้น ๆ ในอัตภาพทั้งหลายนั้น ๆ ในกำเนิดนั้น ๆ ในกำเนิดทั้งหลายนั้น ๆ ในคตินั้น ๆ ในคติทั้งหลายนั้น ๆ ในภพ

ហេតុនៃអំពើកុសលកម្មដែលខ្ញុំបានធ្វើនោះឯង ។

លុះព្រះអរហន្តអគ្គនោះ បានសំដែងយ៉ាងនេះហើយ ក៏បបួលមហាជនទាំងឡាយឲ្យខ្លាំងឡាយប្រកបកុសលកម្មជាប់ជានិច្ច ។

ព្រោះហេតុដូច្នោះ ព្រះគន្ថារចនាចារ្យ អ្នកតែងគម្ពីរនេះ បានពោលនូវបទព្រះគាថាដូច្នេះថា:

ជានេនមេវំ បរិមាយ ជិណ្ណិយា សុណាយ ធម្មស្ស មហាគ្គតោជិនំ លភិត្ថ សគ្គា តិវិធម្បិ សម្បទំ ឥលំ ភេន តោ ពហុនាយកស្ស តោ

សត្វទាំងឡាយតែងបានសម្បត្តិទាំងបីប្រការនេះគឺ ទេវសម្បត្តិ ១ មនុស្សសម្បត្តិ ១ និព្វានសម្បត្តិ ១ ដោយការយោនូវពាក្យតថាយជាពាក្យតបុងក្រោយបង្អស់មានប្រមាណប៉ុណ្ណេះនេះផង នឹងការស្តាប់ធម៌ទេសនាអស់កាលមួយរំពេចផង ម្នាលអ្នកទាំងឡាយដ៏ចំរើន នរណាមួយអាចពោលពណ៌នានូវផលនៃការយកអ្នកឲ្យច្រើន «ថាមានផលប៉ុណ្ណេះ» បាន? សូម្បីតែព្រះសម្មាសម្ពុទ្ធ ក៏ព្រះអង្គពុំអាចនឹងពណ៌នានូវផលានិសង្សនៃបុគ្គលអ្នកឲ្យបានច្រើនពោះបានដែរ ។

សំដែងរឿងនិទានទី ៤ នៃទេវបុត្តជាគំរប់ ៩ ក្នុងវគ្គទី ៥ ក៏ចប់សេចក្តីជាសង្ខេបតែប៉ុណ្ណេះឯង ។

(តមក)

ចុទ្ទដិវាជាបិ អដ្ឋារសអក្ខត្តុំ សេ-
ដ្ឋាយ តំ ឆត្តំ តិសន្ថិ ចតុសំខេបំ បរិត្តំបិត្វា អនេ-
កសតសហស្សាហិ ធញ្ញាហិ ជាយមានាហិ អរុណោ
ទគ្គច្ឆន្តេយេវ កមាណសង្ខោ ហុត្វា អដ្ឋាសិ ។

បពិត្រអើយ ឮដ៏កាលនោះ ព្រះបាទចុទ្ទនព្រហ្មទត្តកដជាឥស្សរៃ
មហាក្សត្រគាំង ១០១ ព្រះអង្គត្រទ្រង់ក្រោលើកពលសកលយោធា សេនា
គាំង ១៨អក្ខោភិនី មួយអន្ទើនឆ្ពេចឯកសតកដ ព្រះអង្គឲ្យប្រាមប្រាប់
បង្គាប់អស់មហាយោធាគាំងនោះ ឲ្យចូលទៅចោមរោមព្រះនគរជា ៧ ជាន់
ដិត រឹក្បាលដំរីនឹងក្បាលដំរី ដំដិតជាប់គ្នា ៧ ជាន់ កសេះនឹងកសេះជាប់
គ្នា ៧ ជាន់ ចម្ងោលរទេះនឹងចម្ងោលរទេះជាប់គ្នា ៧ ជាន់ ដុំដៃនឹងដុំដៃ
៧ ជាន់ដិតប្រកិត មានដៃកាន់ខ្លរៃអាវុធដ៏មានមុខមុតថ្លាបើដូចត្រើសូលប្រាក់
ពោះនឹងលោទៅចាក់គាប់គាត់តយុកក្បាលនៃសត្រូវមកនោះ តំសត្រូវពុំ
គាន់ដឹងខ្លួន រីតែមគប់ប្រសប់ពន្លឺទៅវិញទៅមក បើដូចពន្លឺព្រះអាទិត្យ
ព្រះចន្ទ្រទុំយប្រើនកែវលែង រីអស់សូរសព្ទគាំងនោះសឹងឮខ្ទរខ្ទារញ៉ាបើ
ដូចភ្លូកព្រះនគរនោះហោង ។ តំ ញត្វា មហាសត្តោ អត្ត-
នោ យោធានំ តិណ្ណំ សតានំ ខេមេសិ ។ រីព្រះមហាសថ

អ្នកដឹងខ្លួវហេតុនោះហើយ អ្នកបង្គាប់ប្រើខ្លួវសេនាយោធាចាំង ៣០០ ថា
ចូរអ្នកចាំងឡាយទៅដោយខ្លួវទម្ពង្គដើង ឡើងទៅយកព្រះវរមាតាព្រះ-
រាជទេពី ព្រះរាជបុត្រាបុត្រីនៃព្រះចុនចុឡនីឡាជ ហើយនាំឡើងមក
ដោយខ្លួវទម្ពង្គដើង យកឡើងមកឰដ៏មហាទម្ពង្គធំ កុំបីអ្នកចាំងឡាយ
ប្រហែសឲ្យរួចចេញទៅក្រៅទ្វារទម្ពង្គនោះឡើយ ហើយចូរអ្នកចាំងឡាយ
ទៅនៅចាំរក្សា ចំពាំយើងទៅគាលឯណាហើយ អ្នកចាំងឡាយនាំ
យកក្បួត្រចាំង ៤ ព្រះអង្គទៅឰដ៏សាលាធំ មាននៅនាទ្វារមហាទម្ពង្គនោះ
ឯង តេ តស្ស វចនំ សម្បដិច្ឆិត្វា ។ រីយោធាចាំងនោះ
ទទួលយកបណ្តាំពោធិសត្វហើយ សឹងទៅដោយខ្លួវទម្ពង្គដើង ឡើងទៅ
បើកឈើត្រនាប់ដែលគ្រប់ដើងដណ្តើរ ហើយទៅចាប់ចងខ្លួវមនុស្សដែល
តែងរក្សាខ្លួវអ្នកចំរើ ទំនើបគិតមកដាក់មនុស្សចាំទៅដើងដណ្តើរក្តី ទៅ
ក្បាលដើងដណ្តើរក្តី ទៅឰដ៏ដៃឆ្វេងក្តី ។ រីសេនាពោធិសត្វ សឹងដ៏
ចាប់ចងចុកមាត់ស្រែចនាំទៅចុកឰដ៏ហានកំចាំង ហើយនាំគ្នាទៅស៊ីចំណី
អាហារត្រកាលពីសាដែលអ្នកធនរណ្តាប់ចុកថ្វាយស្តេចនោះ ស៊ីពុំអស់
ឡើយ សឹងសាច់ចាប់ចងខ្លះបានត្រូនដ៏ដងសំពងរាយបែកបាក់ឆ្អាក់
ក្រែលរណែលនៅនោះ ខ្លះសោតយកកោដន៍ចាំងនោះមកបុកល្អិតជាធង់
ហើយឡើងទៅលើប្រាសាទ ។ រីនាងសលាកទេវីក្តី នាងនន្ទាទេវីក្តី
ព្រះរាជបុត្រាក្តី ភរដធីតាក្តី សឹងទុកចិត្តថាខ្លួនមានសត្រូវអំពីណាឡើយ

ហើយកំផ្ទុំដំលែងក្រឡាបន្ទំជាបរមសួស្តីនោះឯង ។ រីឯយោធាតាំងនោះ
បន្ទើស័ព្ទហៅទៅកាន់នាងតាំងនោះ នាងតាំងនោះចេញមកហើយដណ្តើង
អ្នកតាំងឡាយនោះថា មានប្រការម្តេចហ៎ះ ឯអស់សេនាយោធាព្រះពោ-
ធិសត្វ សឹងស្រដីនូវពាក្យបំពោតថា បពិត្រអ្នកនាងអើយ ព្រះមហាក្សត្រ
អង្វាស់យើង ចាប់បាននស្តេចវិទេហរាជនឹងព្រះមហេសី បុត្រតហតិ
សម្លាប់ហើយ ទឹងដំកើងអង្វាស់យើងតែមួយព្រះអង្គ ជាឥស្សរកំពូលស្តេច
ឯកសត្តរាជជាបរិវារហើយ ឥឡូវនេះទឹងសោយសុរាដ៏យកំសាន្តព្រះហឫ-
ទ័យ ហើយត្រាស់ប្រើយើងខ្ញុំឲ្យមកអញ្ជើញព្រះអង្គតាំង ៤ សូមព្រះអង្គ
អញ្ជើញស្តេចទៅឥឡូវនេះហោង ។ ក្សត្រតាំង ៤ ព្រះអង្គចុះទៅកន្លែងមង្គ
ជើងហើយបន្ទូលថា ម្នាលអ្នកតាំងឡាយអើយ ផ្លូវនេះយើងតុំដែលចុះ
មកឡើយ យោធាតាំងនោះថា បពិត្រអ្នកនាងអង្វាស់អើយ ផ្លូវនេះ
តុំដែលចុះប្រក្រតីឡើយ ផ្លូវនេះជាមង្គលទើបស្តេចប្រើយើងខ្ញុំមកអញ្ជើញ
ព្រះអង្គ ដ្បិតថ្ងៃនេះជាមង្គល សូមស្តេចអញ្ជើញដោយផ្លូវទៅហោង ។
ឯក្សត្រតាំង ៤ ព្រះអង្គនោះសឹងដើរទៅ ហើយសេនានោះខ្លះទៅកាន់ព្រះ
កដមន្ទីរវិញ ហើយចូលទៅបើតទង្វាយនូវគ្មានទីដណ្តើង ហើយចូលទៅ
កន្លែងមន្ទីរ រើសយកតែខ្ទឹមទ្រព្យដកបតែអស់ចិត្ត ខ្លះសោតស្ពាយដក់
យកមាសប្រាក់តាមចំណង់ចំណែង ។ ស្រេចហើយទៅហោង ។ យោធ
តាំងនោះ កាលបើបាននាំក្សត្រតាំង ៤ នោះទៅដល់មហាមង្គតាំងនោះ

ក្សត្រតាំង ៤ ព្រះអង្គ ស្តេចទតយល់ប្រជាប់ប្រជាមហាទម្ពន្ធ៍នោះ ល្អក្រៃ
វិស័យដូចសុធម្មទេវសភាសាលា គឺទេវតាប្រជាប់មានឥន្ទសួតិទេវលោក
នាយ ហើយសន្ទិដ្ឋានទុកក្នុងព្រះហឫទ័យថា រីឯនេះគឺអ្នកផងប្រជាប់
ហើយថ្វាយមហាក្សត្រហោង ។ អស់សេនាតាំងនោះអញ្ជើញក្សត្រតាំង
៤ ព្រះអង្គឡើងទៅតង់ឮដំណែលក្រឡាបខ្នុទ្ធមប្រពៃ ឮដំកង់មហាទម្ពន្ធ
នោះឯង ។ ឯសេនាខ្នះសោត នៅចាំរក្សាក្សត្រតាំង ៤ ព្រះអង្គ
សេនាខ្នះឡើងទៅជំរាបប្រាប់នូវសភាពឋានតាំងក្សត្រតាំង ៤ ព្រះអង្គមក ។
សោ តេសំ កថំ សុត្វា ឥទានិ មេ មហារាថា មត្ត-
កំ ចាបុណិសុត្តីតិ ។ ព្រះពោធិសត្វស្តាប់អស់សេនាតាំងនោះ
ហើយ អ្នកនឹងមានព្រះរាជហឫទ័យត្រេកអរថា រីឥត្ថាថ្លានៃអញសម្រេច
បរិបូណ៌ហើយហ្ន៎! ព្រះពោធិសត្វអ្នកជ្រាបដូច្នោះហើយ អ្នកឡើងទៅ
កាន់សំណាក់ស្តេចនៃអ្នក បិតព្វដ៏ឋានសមគួរនឹងអាត្មា ។ ឥដានិ
កិលេសានុរតាយ ឥទានិ មេ ឥត្ថរំ មេស្សតីតិ ចិ-
ន្តេត្វា ។ ព្រះមហាក្សត្រ ហេតុតែព្រះអង្គលុះដោយអំណាចកិលេស
តណ្ហាភតាំឲ្យវង្វើងខូនំក្តៅ ហើយទ្រង់ព្រះចិន្តាថា ព្រះបាទបុប្ផន័សម
ន័ងជូនព្រះធីតាដែមកឲ្យអញហោង ទ្រង់ព្រះចិន្តាដូច្នោះហើយ ស្តេច
ដោះអំពីអាសនាក្រឡាព្រះទីតាំងទតពីតពីលមើលមើលដំណើរផ្លូវមកនោះ
យល់គោមតប់ច្រើនក្រៃលែង សឹងមានពន្លឺភ្លឺប្រុះឡុះមកយល់បន្ទាយហើយ

ព្រមទាំងសេនាយោធាសឹងកាន់គ្រឿងអាវុធ ប្រកបជាសង្កាត់ ។ អធិក
ពន្ធឹកច្រើនមហាមាត្រ ស្តេចមានព្រះហឫទ័យឆ្ងៀសសង្ឃាថាអ្វីដូច្នេះ
ហ៎ះ ស្តេចបន្ទូលដណ្តឹងទៅកាន់អ្នកច្រាជ្រទាំង ៤ នូវបទគាថាដូច្នេះ ។

មាត្តំ អស្ស រថា បត្តិ សេនា តិដ្ឋតិ ចម្មិកា
ឧក្កា បធិត្តា ឈាយន្តិ កិំ ន មញ្ញន្តិ បណ្ឌិតា

ម្នាលអ្នកច្រាជ្រទាំង ៤ អើយ រីសេនាដំរី សេនារទេះ សេនាថ្មើ
ជើង ដ៏តាក់តែងក្រែកក្រាយ ស្តាយសំសៃឈរច្រងោកាន់គោមគប់ប្រ-
សព្វ នេះពុំរឿងយល់ជាក់ច្បាស់ច្រាកដ អ្នកទាំងឡាយគិតថាម្តេច
ស្តេចបុព្វនិមិត្តយ៉ើងឬអ្វីអេះ ។

តំ សុត្វា សេនកោ អាហ ។ តាបសសេនកៈស្តាប់
ហើយសង្ឃឹមព្រះបន្ទូលថា មហាពាជក្សត្រថ្លៃប្រសើរអើយ កុំបីព្រះអង្គ
ព្រួយព្រះហឫទ័យនោះឬាម្តេចឡើយ ឯគោមគប់ប្រសព្វក្តីយល់ច្រាកដនោះ
ដោយខ្ញុំគិតយល់ជាព្រះបាទបុព្វនិ ឲ្យនាំព្រះពាជធីតាមកថ្វាយព្រះបាទ
អម្ចាស់មិនខេះឡើយ ។ រីហេតុឯណាព្រះមហាក្សត្រសព្វព្រះពាជហឫទ័យ ហើយអាចារ្យទាំង ៤ នាំហេតុនោះមកទូលផ្សំតាមព្រះពាជហឫទ័យ
នៃមហាក្សត្រនោះឯងហោង ។ ព្រះបាទវិទេហពាជ ស្តេចស្តាប់ទូ
សព្វសេនាយោធា ស្រដីទៅមកបង្គាប់គ្នាថា ម្នាលសេនាពាហន
ទាំងឡាយអើយ ចូរឈរចាំនៅឲ្យដីថានមានឈ្មោះដូច្នេះ កុំតប្បីអ្នក

ទាំងឮយ៉ាងនេះសម្រេចហើយ ចូរប្រយ័ត្នក្តាត់ហោង ព្រះមហាសត្វ
ស្តេចចតទៅមុខលើអស់សេនាទាំងនោះ សឹងកំពាន់នូវអាវុធប្រកិតនោះដ៏
ច្រើនមហិមាក្រៃ ស្តេចមានព្រះហឫទ័យកិតខ្មាចនូវក្តីស្លាប់មកគំរាម
ហើយស្តេចបន្ទូលទៅកាន់ពោធិសត្វ នូវព្រះគាថាផ្សេងទៀតថា ។

ហន្ត អស្ស រថា បត្តិ សេនា តិដ្ឋតិ ចម្មិកា
ឧក្កា បដិគ្គា ឈាយន្តិ តិដ្ឋ តាហន្តិ បណ្ឌិតាតិ ។

បណ្ឌិត រៀបចេញមហាសេនាអ្នកច្រើនដូចម្តេច ព្រះសេនាដ៏រឹ សេនា
សេះ សេនារទេះ សេនាគរថ្មើជើង សឹងដំពាក់នូវគ្រោះក្រាយប្រពៃ
សឹងអុជតាមគប់ប្រសព្វឆេះភ្លឺរុងរឿង រីអ្នកចាំងឮយ៉ាងតើនឹងតតូធ្វើម្តេច
ហ៎ះ ។ ព្រះមហាសត្វស្តាប់ព្រះបន្ទូលមហាក្សត្រហើយ អ្នកតតូថា
អញនឹងបំភិតបំភ័យស្តេចកំឡៅនេះកុំបាន់ហើយ ឯក្រោយនោះសឹម
អញសំដែងចែងដោយកំឡាំងប្រាជ្ញានៃអញ ហើយអញនឹងលោមមហា-
ក្សត្រវិញហោង អ្នកតតូថ្នោះហើយទូលមហាក្សត្រថា ។

រក្ខតិ តំ មហារាជ ពុទ្ធនេយ្យោ មហាឫសេ
បទុដ្ឋោ តេ ព្រហ្មទត្តោ ទាសោ តំ យាតយិស្សតីតិ ។

បពិត្រមហារាជអើយ រីព្រះបាទពុទ្ធនីព្រហ្មទត្តរាជ ជាអម្ចាស់នៃ
អ្នកពុទ្ធនីកស្តេចនេះនឹងនឹមមហារាជក្តាត់ហោង នេឱ្យចោមចាំរក្សាព្យា-
ធ្យាល នេនឹងសម្លាប់មហារាជនាព្រឹកនេះមិនខេឡើយ រីអស់អ្នកធនឹងកាល

បើឮពាក្យនោះហើយ កើតមានភ័យស្ញប់ស្ញែងក្រៃលែង ចិត្តកំពុងភ័យខ្លាច រីស្តេចឯងក្តីសឹងកំពុងស្លុតទើបមាត់ បែកញើសចេញអំពីព្រះសុរិលៈ ស្តេចនោះកាលណាបើឮពាក្យនោះហើយ កំពុងភ័យខ្លាចនូវក្តីស្ញប់ស្ញែងជាំ ក្រង់ព្រះកន្សែងឡើកឡួលជំដួលកង់ព្រះអង្គ បន្ទូលនូវគាថាពីរបទថា

ឧត្ថេតិ មេ មហាទយំ មុខញ្ច បរិសុស្សតិ
ជិវ្ហាតិ ជាតិកច្ឆាមិ អត្តិនង្គ្យោ អាតុរោ ។
តម្ហាភយំ យថា ឧក្កា អន្តោ ឈាយតិ នោ ឥមិ
ឯវម្បិ មហាទយំ មយ្ហំ អន្តោ ឈាយតិ នោ ឥមិ ។

តាត ពែកាមហោសថបុត្រត្រកាលអើយ រីថ្លើមដង្ហើមនៃអញញ័រចំប្រប់ មាត់អញក៏សឹងរះរីងស្ងួតហួតក្រៀមអស់ហោង ។ ហឫទ័យនៃអញនោះក៏រៃងឈឺផ្សាក្តៅពុំរលត់ឡើយ ដូចភ្លើងនេះក្តៅងនៅក្នុងទ្រូងនោះហោង ដើងក្រានស្ងប់ជាងខ្លង ភ្លើងរមែងតែនេះហប់នៅតែខាងក្នុងមិនប្រាកដចេញមកខាងក្រៅទេ នោះមានប្រការម្តេចវិញ រីហឫទ័យនៃអាតុរកិនេះក្តៅខាងក្នុងជ្រួលោះហោង ។ ព្រះមហាសត្វ អ្នកស្តាប់ព្រះបន្ទូលទំនួញនោះហើយអ្នកគិតថា ស្តេចនេះរីងរូសប្រទូសរាយពុំយកពាក្យអញអំពីដើមមិញ ឥឡូវនេះ អញនឹងសង្កត់ផ្ញើផ្ញាល់ស្តេចនេះឡើងជាពុទ្ធមួយសារថែមទៀត ។ គិតដូច្នេះហើយពោលពាក្យថា

បមត្តោ មច្ចុជាតីតោ កិច្ចមញ្ញោសិ ទុត្តិយ

ឥមានិ ខោ តំ តាយន្តំ បណ្ឌិតា មន្តិនោ ឥមា ។

ទុតិយ បពិត្រក្សត្រប្រសើរអើយ អម្ចាស់ ហេតុមានអំពើធ្វើប្រមាទក្លែងស្មារតីរង្វើង លុះដោយខ្លួនក្តីចំណង់តាមតុណា អម្ចាស់កន្ទួងលែងពាក្យអញខ្ញុំ គំនិតខ្ញុំហើយ រីគំនិតក្រាជាខ្ញុំនោះកអស់ចំណេះរបែរបែកអសារទេ បើនឹងមានគំនិតដំរេះប្រពៃក្រៃអ្វីនឹងអ្នកអាចារ្យទាំង ៤ នោះ ចូរអម្ចាស់យកគំនិតអ្នកទាំងនោះមកក្សាមហាកដ្ឋដ៏កាលឥឡូវនេះហោង។ បពិត្រមហាកដអើយ ចូរអម្ចាស់ធ្វើតាមពាក្យនៃអ្នកអាចារ្យ តីខ្ញុំអម្ចាស់រមែងស្វែងរកប្រយោជន៍គាប់ តែងបញ្ចេចបង្អែរឥឡូវនេះ លុះដោយខ្លួនភ័យដូច្នេះ បីដូចម្រឹគត្រូវបង្កាត់ខេសាទផង មន្ទោ ទីយ អម្ចាស់បីដូចត្រីចង់ស៊ីអាហារមិនស្គាល់ខ្លួនជែកសន្ទូចវៀច ដែលគេចិតខ្លួសាច់ជាខ្មុយត្រីនោះពុំដឹងខ្លួក្តីស្ងាប់ ហេតុតែទៀស្មានថាជាអាហារគាត្មាចិតពាំទាំងចេញឯសន្ទូចនោះគេកត់ស្វែងខ្លួត្រីនោះតាញៅលើប្រថពី មានខ្លួនោះញ៉ាំចំប្រប់ ឥឡូវនេះ មហាកដក្រាជ្ញានាងបញ្ញាលចន្ទីជាព្រះកដបុត្រីព្រះបាទចុឡនី ស្តេចចូលមកកន្លែងស្រុកបញ្ញាលនគរ កំនឹងបង់អាត្មាព្រះអង្គឆាប់ឥឡូវនេះមិនទេឡើយ ហើយព្រះអង្គបីដូចម្រឹតកំចូលទៅផ្លូវនេសាទកំលុះខ្លួកែយធំពេកណាមហាកដ ឥតិ ឥ បពិត្រក្សត្រប្រសើរអើយ រីបុរសនោះអង្គឺសប្បុរសឯណានេះ ដូចអាចារ្យកេវដ្តព្រាហ្មណ៍បីដូចឥស្សរកែថ្មអ្នកឥតដំណឹង កំយកឥស្សពីសទៅដាក់ក្នុងថ្នក់ ឥស្សនោះកនឹងខាំវិញ

ហោង រីអ្នកដ៏មានប្រាជ្ញាពុំគួរធ្វើមេត្រីប្រសព្វនឹងអ្នកឥតធម៌សប្បុរសឡើយ បើអ្នកឯណាសើរើទៅប្រសព្វនឹងអ្នកឥតធម៌សប្បុរសនោះហើយនឹងជាទុក្ខទៀងជានិរន្តរ៍ពិតហោង ។ ឯនិទ្ទេ បពិត្រកុង្ក្រត្រប្រសើរអើយ រីបុរសឯណាមានដំណឹងដឹងច្រាកដហើយថាបុរសនេះ ជាអ្នកមានសីលតម្កុសត្តោ ជាន្តសូត្រវៀន ជានស្តាប់ធម៌ សំគាល់កត់ចាំទុកក្នុងចិត្តប្រព្រឹត្តតន្ទឹសុបរិតធម៌ទើបហៅជាអ្នកប្រាជ្ញ នេះគួរតប្បីធ្វើស្និទ្ធផ្តិតមេត្រីនឹងអ្នកនោះឯង ឯការជានកប់ប្រសព្វនឹងអ្នកមានធម៌សប្បុរសដូច្នោះ សុខោ ជាសុខទៀងក្តាត់ហោង ។

គ្រានោះ ព្រះមហាសត្វអ្នកនឹងសង្កត់ស្តេចនោះវិញទៀត អ្នកនឹងនាំពាក្យដែលព្រះមហាកុង្ក្រតដេរអ្នកអំពីមុននោះថា

ពាលោ តុវំ ឯលមូគោសិ ភាជ
យោ ឧត្តមត្តានិ មយិ លបិត្តោ
តាមេវហំ នច្ចលតោដិវេឡ្ឍា
អត្តានិ ជានិស្សំ យថាបិ អវញ្ញ
ឥមំ កលេ កហោត្វា ឆាសេឋ វិដិតា មម
យោ មេ វតនលាភស្សុ អន្តរាយាយ ភាសតីតិ ។

បពិត្រមហាភដអើយ រីអម្ចាស់ឯងស្រដីតះដៀលខ្ញុំថា ព្រះវិស្តឯងជាកូនគហបតី ស្រដីមានទឹកមាត់នោះហួរហៀរសៀវអៀវ

ដោយថ្លាល់ចាំងសង៖ខាងហើយរស់ខ្លួនតែងនឹងនឹកលះនាស់នឹងដឹងអ្វីជាប្រ-
យោជន៍អតិមង្គលនៃស្តេច ដូចជាអាចារ្យសេនកជាដើម ហើយអម្ចាស់
បង្គាប់អាមាត្យចាំងឡាយថាដូច្នេះ រីកូនគហបតីវាស្រដីឲ្យអន្តរាយលាក
នឹងបានស្រីតែម្នាក់អញ ចូរអ្នកចាំងឡាយឧស់កមហាសថនេះបំបរបង់
ចេញចាកអំពីស្រុកនៃអញនេះ ។ មហារាជអើយ ឥឡូវនេះ ព្រះបាទ
ចុឡនីព្រហ្មទត្តរាជនូវស្តេចចាំង ១០១ សឹងរឹងរូសហ៊ានក្លាក្រពើរលើកពល
សេនាយោធាចាំង ១៨ អក្ខោហិនី មកចោមរោមជាសង្កាត់ ។ ខ្ញុំនេះជាអ្នក
ជួបហ៊ានឯយនេះតើនឹងអ្វី នូវព្រះរាជការសង្គ្រាមតម្រេម៉្លេះ ។ បេះដូចែតស្រែចំ
ការថាពូជស្រូវនេះល្អមព្រោះបង្កុះកង់ស្រែដុំរៀនេះស្រែរបើសនូវស្រូវធ្ងន់
ស្រូវស្រាលនោះខ្ញុំបេះជានាគ្រាន់ចិញ្ចឹមជីវិតរស់បាន ត្រង់ការតម្រេឥឡូវ
នេះខ្ញុំពុំអាចគិតរក្សាព្រះអង្គបានទេ មានតែអ្នកអាចារ្យចាំង ៤ នោះ គាត់
មានដំរិះប្រាជ្ញាហើយជាអ្នកប្រាជ្ញចាស់ពុំ បរំបុកណាមានយោបល់យល់នូវ
នឹងដោះសារការរក្សាព្រះអង្គកាលគ្រាតម្រេនេះបាន រីត្រង់ខ្ញុំនេះនឹងគ្រាំរ៉ៃ
ថ្ងាយពុំបានឡើយ ។ តំ សុត្វា រាជា ចិន្តេសិ ។ រីព្រះមហាក្សត្រ
ព្រះអង្គស្តាប់ពាក្យពោធិសត្វនោះហើយទ្រង់ព្រះចិន្តាថា ចៅអ្នកប្រាជ្ញ
នេះស្រដីលើកទោសដែលអញធ្វើនោះឯង ហេតុនោះហោង ចៅអ្នក
ប្រាជ្ញដឹងនូវអនាគតនៃភ័យនឹងមកដល់ក្នុងអំពីមុន ឥឡូវនេះស្រដីសង្កត់
អញអស់កាលដ៏លង់ភៅ តើញ៉ាំងនឹងបានជាពំនាក់ដល់អញឬ ចៅ

មហោសថអ្នកប្រាជ្ញកំដោះអញដោយនូវសួស្តីភាពនេះពុំបាននោះ ស្តេច
តាំងណាជួញ្ជោះហើយ ស្រដីនឹងតោធសត្វជាតាថាពីរបេជ្ជខ្នះថា

មហោសថ អតីតេន ជានុវិជ្ជន្តិ បណ្ឌិតា
កឹ មំ អស្សាវ សម្ពុទ្ធំ ទាតោទនេវ វិជ្ជសិ
សាធេ បស្សសិ មោក្ខំ មេ ទេមំ ភាបន បស្សសិ
តេនេវ មំ អនុសាស កឹ មំ អតីតេន វិជ្ជសីតិ ។

មហោសថ ម្នាលជាមហោសថបុត្រស្ងួនសំឡាញ់អាពុកអើយ
អ្នកប្រាជ្ញនឹងតាំងអំពីបុរាណកាលមក ពុំដែលមានរំលឹកទោសដែលកន្លង
ទៅហើយ ឥឡូវម្តេចក៏មកចាក់ដោតអញទីនឹងលំពែង គឺសំដីចេញ
អំពីមាត់ជូចនាយសារថី កំពុងចាក់សេះទឹងដ៏ជន្លួញនោះហោង ម្នាលមហោ-
សថជាអើយ នោះយោបល់ប្រកាន់ទឹងឲ្យសុះ ទឹងឲ្យរួចដោយនូវ
សុះក្បែមក្បាច្ចដោយនូវគំនិតយោបល់ឯណា ចូរចាប់ភ្ជាញ្ជាប់អញ
ដោយនូវសួស្តី កុំបារំលឹកនូវទោសដែលកន្លងទៅហើយ នោះយកមក
ចាក់ដោតអញឡើយ ។

ឮដំណាលនោះ តោធសត្វអ្នកគិតថា ស្តេចនេះជាអ្នកឆ្កួតពេក មិន
ដឹងជាបុរសវិសេស ថាបើដូច្នោះហើយ អញនឹងធ្វើឲ្យលំបាកចិត្តចសឹម
អញធ្វើឲ្យបានលំទៅជាពំនាក់នៃស្តេចឯក្រោយវិញហោង តែតអម្បាល

នោះហើយ ទើបទូលស្តេចថា

អតីតំ មានុសំ កម្មំ ទុក្ករំ ទុរភិសម្ភវំ
ឯតំ សាក្ខាមិ មោចេតុំ តុវំ បជានស្សុ ខត្តិយ ។

ខត្តិយ បពិត្រមហាក្សត្រប្រសើរអើយ អំពើកន្លងទៅហើយនោះ មនុស្សផងនឹងបង្កើតឲ្យបានដោយ ។ ឃល់ជាតម្រេក ខ្ញុំមិនអាចដើម្បីនឹងដោះទូវមហាភជឲ្យរួចបានឡើយ ចូរជ្រាបតំលង់ព្រះហឫទ័យហោង ។

សន្តិ វេហាយសា នាគា ឥទ្ធិមន្តោ យសស្សិនោ
តេបិ អានាយ តេ ច្ចេយ្យុំ យស្សុ ហោតិ តថាវិធា ។

មហាភជ បពិត្រមហាភជអើយ រ៉ាជ័រឯណាមានរិទ្ធិជាសម្រាប់នៃស្តេច ដ៏មានយសសក្តិធំ រ៉ាជ័រនោះឈ្មោះទុជ្ជោសថនាគរាជអាចហោះទៅកណ្តាលអាកាសបាន រ៉ាជ័រនោះនឹងយកព្រះអង្គដំតល់លើខ្នងនឹងហោះរមួងឲ្យរួច ចេញទៅដោយដំណើរអាកាសនោះហោង ។

សន្តិ វេហាយសា អស្សា ឥទ្ធិមន្តោ យសស្សិនោ
តេបិ អានាយ តេ ច្ចេយ្យុំ យស្សុ ហោតិ តថាវិធា ។

ប្រការមួយនេះសោត មានសេះមួយមានរិទ្ធិអាចហោះទៅក្នុងដ៏អាកាសឈ្មោះពលាហកភជ អាចយកព្រះអង្គដាក់លើខ្នងនឹងហោះរមួងឲ្យរួចទៅបាន ។

អក្សរសាស្ត្រខ្មែរ	ខ្មែរគួរថែថ្នម
ឲ្យបានខ្ជាប់ខ្ជួន	គង់វង្សតត់ម៉ត់
ព្រោះអក្សរជាតិ	គោលជាតិប្រាកដ
អក្សរលត់	ជាតិក៏រលាយ

ប. ព.

(វិចារណាកថា)

ការនិយាយស្ដី

លោក ផេង-គ្រីវ រៀបរៀង

ការនិយាយស្ដីនេះ បើពោលឲ្យពិស្តារ មានសភាពច្រើនអនេក តែក្នុងទីនេះខ្ញុំសូមត្រិះរិះនឹងពិចារណាដោយសង្ខេបដូចតទៅនេះ៖

ភាសិតបុរាណខ្មែរថា: „សំដីជាឯក លេខជាទោ„ ។ តើភាសិតនេះមានអត្ថន័យយ៉ាងណា? តាមការពិចារណា យើញថាមនុស្ស បើខ្វះពាក្យសំដី គឺថាមិនចេះនិយាយស្ដី (មនុស្សគ) ឬនិយាយស្ដីដែរ តែតិចពេក មិនអាចមានជីវភាពចំរុងចំរើន ជីវភាពរុងរឿងបានល្អឡើយ ព្រោះសំដីនេះហើយដែលអាចឲ្យកើតអ្វីៗសព្វយ៉ាង ដូចធ្វើឲ្យកើតជាប្រាសាទធំៗជាទីក្រុងដ៏ល្អអស្ចារ្យ ឲ្យកើតជាទ្រព្យសម្បត្តិ ឲ្យកើតសេចក្ដី

សុខ ឲ្យបាត់ការឈ្លោះប្រកែក ឲ្យបាត់មានការព្យាបាទគ្នា ។ល។ ត្រង់នេះហើយដែលគេថា: «សំដីជាឯក» ។

ចំណែកលេខវិញ ត្រូវតែជាដើងក្រោយ គឺថាលុះណាតែសំដីមុនហើយ ទើបប្រើលេខគួរជាក្រោយ ឬនជាគេថា "លេខជាខោ" លេខជាតិពីរបន្ទាប់ពីសំដី ។ នេះជាសេចក្តីចកប្រៃនៃភាសិតខាងលើ: «សំដីជាឯក លេខជាខោ" ។ តើនឹងសន្និដ្ឋានពុកពាក្យ «ឯក» ហ្នឹងតែម៉ៅផ្នែកខាងល្អតាំងអស់ឬដូចម្តេច ? បើតាមការពិចារណាគេម៉ៅខ្លែងនឹងតាមការពិសោធន៍ដែលជាប់មាន ឮប់ឬនដូចប្រុះ ពាក្យថា «ឯក» មិនសំដៅយកសុទ្ធតែការល្អតាំងអស់ទេ ព្រោះមានពាក្យដែលគេនិយាយជាហូរហែដែរថា អ្នកនេះអាក្រក់ «លេខ១» អ្នកនោះខូចទឹលេខ១» ដូច្នេះអាចសន្និដ្ឋានបាននថា «សំដីជាឯក» មិនមែនលេខ១តែខាងល្អទេ គឺលេខ១ខាងអាក្រក់ដែរ ។

សេចក្តីសន្និដ្ឋាននេះ មានសក្ខាពស្រាបនឹងភាសិតខ្មែរមួយកន្លែងទៀតថា: «អណ្តាតជាអាវុធ អស់សុខទុក្ខឯកើតពីអណ្តាត» អត្ថន័យនៃភាសិតនេះថា សេចក្តីសុខ និងសេចក្តីទុក្ខរបស់មនុស្សគាំងឡាយ មានដើមចមតែពីអណ្តាត គឺពាក្យសំដីនេះឯង ។ តាមការសង្កេត ឃើញថាមានមនុស្សភាគច្រើន ដែលឬនខ្លួលបុណ្យ យស សក្តិ សម្បត្តិទ្រព្យ សេចក្តីចម្រើន ការសរសើរ លើកដំកើង មានក្តីឈ្លោះប្រាសំខ្សែង

ព្រោះតែពាក្យសំដីនៃអាត្មា ។ តើអាទិសង្ឃាទាំងនេះ បណ្តាលមកពីសាមីជនទិយាយស្តីបែបណា ? កន្លែណា ? កន្លែពេលណា ? ចំពោះអ្នកណា ?

ចំពោះពាក្យចោទទាំងនេះ ត្រូវឆ្លើយថា សាមីជនទោះពោលពាក្យប្រកបដោយលក្ខណៈដ៏ចំរុះអនុលោមទៅតាមទី តាមពេល ទឹងតាមមនុស្ស គឺថាសាមីជនជាអ្នកឆ្លាតវាងវៃយល់ច្បាស់ថា កន្លែទីនេះ អាត្មាអញគួរប្រើសំដីយ៉ាងនេះ នៅពេលនេះ អាត្មាអញមិនគួរយកពាក្យបែបនេះមកទិយាយទេ ចំពោះមនុស្សជុននេះ មនុស្សរបៀបនេះ អាត្មាអញគួរនិយាយសំដីយ៉ាងនេះទៅកេីតសម ។ សាមីជន កាលបើយល់ការណ៍ដូច្នេះហើយ រមែងខ្លួចខ្លួចខ្លាចយ៉ាងប្រពៃអំពីពាក្យសំដីនៃខ្លួនជាពិតប្រាកដ ។

ផ្ទុយទៅវិញ សាមីជនអ្នកទិយាយ ច្រេីនតែជួបប្រទះនូវបាបគ្រោះជាអនេក ។ តើដោយហេតុអ្វី ? ហេតុដែលនាំឲ្យខ្លួនខ្លួលកេីតមិនល្អគឺដោយយល់សោះ មិនមានអ្វីក្រៅពីសាមីជន មិនយល់ការណ៍ដូចពាណិនាមកខាងលើ ។ មានមនុស្សភាគច្រេីនណាស់ដែលគ្រាន់តែហាទិយាយនាំឲ្យគេមិនពេញចិត្ត ដួនកាលជួលទៅការស្អប់ខ្ពេីមាន ។ អ្នកខ្លះនិយមថាគឺជាវាសនាបុស្តាកសាងពីអតីតកាលមក ឬានជាគ្រាន់តែចាប់កោទិយាយ ត្រូវគេស្អប់មិនចង់ស្តាប់ ។ អ្នកខ្លះនិយមយល់ថា ធ្វេីដូចម្តេចជាធម្មតាបុស្តាអ្នកខ្លះទៀតចូលចិត្តថា អ្នកដែលនិយាយនោះជាមនុស្ស

មិនស្គាល់ប្រមាណ ជាមនុស្សច្រោសចាកការគួរសម ជាមនុស្សចិញ្ចឹមចិត្តខាងកតែយសសក្តិ ខាងចូលចិត្តការកោតសរសើរ ជាមនុស្សដំខោរកំសឹងមាន ។

ដូច្នេះការនិយាយស្តីនេះ បើមិនបានជាគិត បើមិនបានពិចារណាឲ្យម៉ត់ចត់ មុនពេលនិយាយទំនឹងក្រោយពេលនិយាយ សាមីជនទៅតែធ្វើឲ្យអ្នកស្តាប់មានការអផ្សុក មានការធុញទ្រាន់ ជួនកាលមានរហូតដល់សេចក្តីក្តៅក្រហាយផង ។ ខ្លះអ្វីពាក្យពីរោះ ពាក្យពិសារដែលគួរតែលើកយកមកពោល យកមកចរចា យកមកសន្ទនា ខ្លះអ្វីពាក្យប្រសើរ ពាក្យប្រពៃដែលគួរគប្បីនិយមទម្លាប់លើកមកថ្លែង លើកយកមកពិភាក្សា តែបានជាមិនធ្វើដូច្នេះ មកពីសាមីជនជាមនុស្សក្រៃចិត្តស្មារតី យល់ត្រូវជាខុស យល់ខុសជាត្រូវ ដោយទឹកចិត្តថាអាត្មាអញគ្រាន់ណាស់ជាងគេទាំងអស់ប្លែ សាមីជនជាមនុស្សលេះលោះ ។

តាមការសង្កេត មានពាក្យខ្លះដែលពួកអាវ្យជន ពួកអ្នកមានសុជីវធម៌ មិនសមទំនឹងយកមកប្រើជាសាធារណៈ មិនគួរនឹងលើកយកមកគាន់ខ្ពប់ជុំជាផ្លូវការ ព្រោះសំដីឬពាក្យអស់នេះជារបស់ក្មេងសាលារៀន ជារបស់អ្នកស្រុកភូមិសាមញ្ញ ជារបស់អ្នកផ្សារ ជារបស់អ្នកនិយមប្រមាថគេ ។ ពាក្យសំដីទាំងមួយ ។ សុទ្ធសឹងមានពេល មានកន្លែងរបស់វា មិនខុសគ្នាទំនឹងសំលៀកបំពាក់ឡើយ : ក្រមាំត្រូវស្លៀកនៅពេលណា កន្សែងណា

សារុងត្រូវស្លៀកនៅពេលណា កន្ទែងណា អាវចិនទោចិនត្រូវស្លៀក
តាក់នៅពេលណា កន្ទែងណា សំពត់ប៊ូរ (ក្រវ៉ាត់) ត្រូវប្រើទូរពេលណា
កន្ទែងណា ជាមួយទោអាវជុនណា ។ល។ ឯពាក្យសំដីក៏មានសភាព
យ៉ាងនោះដែរដូចពាក្យៈលោកតា តាកុំ យាយកុំ តាឯង អាចារ្យ អន្ធិត
(បណ្ឌិត) សហជីវិន លោក ព្រះគេជគុណ អ្នក អ្នកស្រី ។ល។ ពាក្យ
អស់នេះសុទ្ធសឹងមានទីកន្ទែង មានពេល ចំពោះមនុស្សណារបស់វា យើង
មិនគួរទម្លាប់យកមកប្រើតាមតែអំពើចិត្តបានទេ បើសាមីជនហើយមិន
គោរព ខឹងត្រូវទទួលឬជួបប្រទះសេចក្តីទុក្ខពីអ្នកស្តាប់ជាមិនខាន ។

តាមការសំគាល់យើញ មានមនុស្សភាគច្រើន តាំងពីជនសាមញ្ញ
រហូតដល់ឥស្សរជនជាចៅក្រសួង ច្រើនពេញចិត្តក្អេងស្មារតី យកពាក្យ
មកប្រើខុសទីកន្ទែង ខុសពេលវេលារបស់វា ។

មិនដឹងជាអ្នកណាបង្រៀនសិស្សទូទៅឲ្យហៅលោកគ្រូបង្រៀនថា
« លោកតា » ឯការហៅនេះ តាមការសង្កេត មិនចំពោះតែលោកគ្រូចំ-
ណាស់ៗ ដែលគួរហៅលោកតានោះទេ ច្រើនហៅទូទៅ ទោះបីលោកគ្រូ
នោះវ័យជុនតណ្តាល ឬវ័យក្មេងក៏ដោយ ។ ខ្ញុំឆ្ងល់ម្យ៉ាងទៀតថា គ្រូ
បង្រៀនមិនមែនមានសុទ្ធតែប្រុសទេ មានស្ត្រីខ្លះដែរ តែជាកុសលអ្វីចំ-
ពោះគ្រូស្ត្រី គឺកូនសិស្សមិនដែលឮហៅ « លោកយាយ » ម្តងសោះ បើ
និយមហៅគ្រូប្រុស « លោកតា » គួរតែហៅគ្រូស្រី « លោកយាយ » ទើប

ត្រឹមត្រូវ ទើបប្រាសចាកការរិះគន់ ។ មិនតែប៉ុណ្ណោះ មានឥស្សរជនខ្លះដែលតាំងដើមធ្លាប់រស់នៅក្នុងបណ្តាជនខាងលើ លុះខ្លួនមានវ័យចាស់ជាមកធ្វើជាចៅក្រសួងណាមួយហើយ ក៏មិនលះបង់វិស័យអកុសលនេះចោល នៅតែនិយមយកសំដីក្មេងសាលារៀនមកប្រើជាជាងប្រតេ តែគួរឲ្យអៀនខ្មាស់ឬទេ នៅកណ្តាលទីប្រជុំជាផ្លូវការ យើងយកពាក្យខុសទីកន្លែងមកប្រើដូច្នេះ បើជាតែងសេចក្តីវិញហើយប្រើសំដី ប្រើពាក្យខុសទីកន្លែង (Impropriété de termes) យ៉ាងនេះ តាមយោបល់ខ្ញុំថាមុខជាមិនសូវជាន់ខ្លួនឡើយ រួចមកប្រយោគនឹងខុកអ្នកនោះថាជាមនុស្សមិនគាន់ស្លាត់ខាងការតែងសេចក្តីឡើយ ។

ផ្ទុយទៅវិញ មានឥស្សរជនខ្លះ ឬអស់លោកខ្លះ ដោយខ្លាចគេនឹងក៏មិនដឹង ដោយនិយមប្រើសុដីរតមិពេកក៏មិនដឹង ឬជាធម្មជាតិតាក់តែងមកដូច្នេះក៏មិនដឹង បើមិយោយស្តីនឹងអ្នកណា មានការគួរសមជ្រុល បើគួរសមទៅលើនាយចៅហ្វាយ ទៅលើព្រឹទ្ធាចារ្យ ជាការគាប់ប្រសើរនេះមិនដូច្នោះ ជំពោះមនុស្សមានឋានៈស្មើគ្នា ហៅគេ «ព្រះតេជគុណ» ដូនកាលដោយគួរសមពេកទៅ ប៉ណ្ណោតក៏ហៅ «ព្រះតេជគុណ» ដែរ ។ ការប្រើពាក្យសំដីបែបនេះ ទាំងឲ្យបរាជ័យបស់ខ្លួនមានការភ្ញាក់ ឧទ្ធំមានសេចក្តីស្មើបព្រមតាំងអៀនខ្មាស់ណាស់ ដោយយល់ឮស្តាប់ថាខ្លួនមិនមានសមត្ថភាពគ្រប់គ្រាន់នឹងខួលពាក្យអាលបឧះអស់នេះឡើយ ហើយម្យ៉ាងទៀត

ទាំងឲ្យនឹកឆ្ងល់ចំពោះអ្នកនិយាយមកកាន់ខ្លួនថាហេតុម្តេចក៏ដូច្នេះទៅវិញ ?

អំពីពាក្យថា « តាបុ យាយបុ អាឯង អាចារ្យ អន្ធិត (បណ្ឌិត) ពាក្យទាំងនេះច្រើនតែអ្នកធំពោលទៅកាន់អ្នកតូចតាចជាធម្មតា ហើយច្រើនមិនសូវមានការស្មោះត្រង់ទេ គឺលាយឡំដោយគំនិតពីរយ៉ាង: ១) ចូលក្នុងការមើលងាយ ព្រោះថាមានចំណេះវិជ្ជាទន់ជ្រាយជាងខ្លួន ២) ចូលក្នុងការស្និទ្ធស្នាលជាង កុងការកាត់តម្លៃជាង ។

សូមបញ្ជាក់ថា: ពាក្យ « អាចារ្យ » និង « អន្ធិត (បណ្ឌិត) ទាំងពីរនេះ បើយោលទៅតាមសព្ទដើមរបស់ពាក្យ យើញថាមានអត្ថន័យដ៏ខ្ពង់ខ្ពស់ពន់ពេក មិនសមបើនឹងយកមកប្រើលេងជាលៃឡើងសោះ ។ អាចារ្យនឹងបណ្ឌិតនេះមានន័យថា អ្នកមានវិជ្ជាសីលធម៌គ្រប់គ្រាន់គួរជាទីគោរពនឹងសក្ការៈបូជានៃជនដទៃ ។ ក្នុងតម្រាព្រះសាសនាដែលជាសាសនាឯកក្នុងលោក មានយើញគេហៅព្រះពុទ្ធថា: « អាចារ្យ » និង « បណ្ឌិត » ដែរ ដូចពាក្យថា: « លោកុត្តមាចារ្យ » អាចារ្យដ៏ប្រសើរខ្ពស់ក្នុងលោក « មហាបណ្ឌិត » បណ្ឌិតដ៏ធំ ។ តែតាមការសំគាល់យើញនៅតាមភូមិជនបទទាំងពាក្យ « អាចារ្យ » និង « អន្ធិត » នេះ គេនិយមប្រើចំពោះអ្នកដែលបានបួសជា « តគុ » ហើយសឹកមកវិញ ព្រោះគេចូលចិត្តថាអ្នកដែលបានបួសក្នុងព្រះពុទ្ធសាសនា សុទ្ធសឹងអ្នកមានសីលធម៌ អ្នកមានវិជ្ជាផ្សេង ។ អាចធ្វើជាគ្រូបាធ្យាយគេបាន ព្រោះសម័យដើម នៅប្រទេសកម្ពុជា គេនិយម

ពុកវត្តអារាមជាសាលារៀន ជាកន្លែងអប់រំមនុស្ស ។ មានអ្នកខ្លះរហូតដល់ទៅប្រកាន់ថាអ្នកមិនចាន់បួស ហើយទៅស្តីដណ្តឹងកូនស្រីរបស់គេជាកិរិយា គេមិនព្រមឲ្យ ដោយគេយល់ថាអ្នកនោះជាមនុស្សគ្មានការអប់រំ ។

ខ្ញុំត្រូវបំលើកយកពាក្យ « អាចារ្យ » នឹង « បន្ទិត » មកពិចារណាបន្តិចតទៅទៀត ។ អ្នកភូមិជនបទនិយមហៅអ្នកដើបនឹងសឹកពីបួសថា « អាចារ្យ » ឬ « អន្ទិត-បន្ទិត » ។ លុះឮយយូរមក ពោះអ្នកដើបនឹងសឹកនោះចេះវិជ្ជាក្តី មិនចេះវិជ្ជាក្តី មានសីលធម៌ក្តី មិនមានសីលធម៌ក្តី ក៏នៅតែនិយមហៅ « អាចារ្យ » ឬ « បន្ទិត » ឥតផ្លាស់ប្តូរ ម្ល៉ោះហើយតរៗមក ពាក្យ « អាចារ្យ » នឹង « បន្ទិត » បានទៅជាសំនួនវោហារមួយ មានន័យថាមនុស្សធុនអន់ មនុស្សចោកថយដែលជាហេតុនាំឲ្យច្រាសចាកអត្ថន័យដ៏ចរិសុទ្ធដើមអស់រលីង ។ ប៉ុន្តែទៅនិយាយថ្លែងពោះអ្នកភូមិជនបទខ្លះដែលមានការខ្វះខាតខាងវិជ្ជានឹងសីលធម៌ ឯចំណែកយើងជាឥស្សរជន ជាអ្នកក្រុង តើគួឲ្យអៀនខ្មាស់ឬទេ ដែលទៅច្រើពាក្យដោយឥតដឹងន័យដ៏តិចតួចដូច្នេះ ។

ឯការនិយាយស្តីដោយមិនស្គាល់ទី ស្គាល់ពេល នឹងស្គាល់មនុស្សនេះជាហេតុបណ្តាលឲ្យចាត់ឈាកស្អប់ដែលត្រូវឬមានក៏មាន បណ្តាលឲ្យខូចលូនូវពាក្យគរហានិន្ទា នូវការស្អប់ខ្ពើមរហូតដល់នូវគ្រោះថ្នាក់ចំពោះខ្លួនក៏មាន ។

ដើម្បីបញ្ចេកវឿងនេះឲ្យកាន់តែច្បាស់ ខ្ញុំសូមលើកវឿងខ្លះក្នុងព្រះពុទ្ធសាសនាមកពណ៌នាជាគួយ៉ាងដល់អ្នកអានទាំងឡាយដូចតទៅ៖

ដំណាលថា មានកូនសេដ្ឋី ៣ នាក់ ជាមិត្រសម្លាញ់ បានចេញដើរលេងកំសាន្តជាមួយគ្នា បានប្រទះទឹងព្រានព្រៃម្នាក់មកតាមបរបាញ់បានសត្វយ៉ាងច្រើនផ្ទុកកង់រទេះបត្រឡប់មកផ្ទះ ។ បានឃើញដូច្នោះ ចំណាងក្នុងការមិកោតសាច់កើតឡើង ទើបសេដ្ឋីបុត្រទាំងបីនិយាយសុំសាច់ចំពោះព្រានព្រៃដោយសំដីផ្សេង ។ គ្នា ។ កូនសេដ្ឋីទី ១ ស្រែកសុំថា: «អេ! អាព្រានព្រៃ! ឲ្យសុំសាច់មួយដុំមក ?» ។ ព្រានទឹកក្នុងចិត្តថា: «ក្មេងនេះគ្មានការគួរសម សុំគេផង ហៅគេស្មើរដៅចង់សាច់ បើដូច្នេះអញត្រូវឲ្យសាច់ពាលយសុទ្ធសារសៅពាទើបគួរ ។ រួចព្រានអោសាច់ពាល ១ ដុំឲ្យទៅ ។ កូនសេដ្ឋីទី ២ ស្រែកសុំថា: «លោកបង! មេត្តាសុំសាច់មួយដុំមក» ។ ដោយយល់ថា កូនសេដ្ឋីទី ២ នេះ មានសុដីរធមិគួរសម ទើបព្រានអោសាចធម្មតាមួយដុំឲ្យទៅ ។ កូនសេដ្ឋីទី ៣ ស្រែកសុំថា: «លោកមា មេត្តាសុំសាច់មួយដុំមក» ។ ព្រានទឹកថា: កូនគេនេះគ្រាន់បើ មានតួដណាស់ និយាយស្គាល់ចាស់ក្មេង» ទើបអោសាច់ចំឡកយ៉ាងល្អមួយដុំហុចឲ្យទៅ ។

សូមអ្នកអានមេត្តាពិចារណាមើល តើហេតុអ្វី សេដ្ឋីបុត្រទី ១ បានសាច់ពាល សេដ្ឋីបុត្រទី ២ បានសាច់ធម្មតា ហើយសេដ្ឋីបុត្រទី ៣ បានសាច់

មានទីជារស់ ? មិនតឹមតែពីការនិយាយស្តីសម្តែងមិនសមនេះឯង ? ។

រឿងមួយទៀតដំណាលថា: កុងតម្លឺរពុទ្ធសាសនាដែរ មានសេដ្ឋីម្នាក់ឈ្មោះសុមង្គល បានកសាងវត្តថ្វាយព្រះពុទ្ធជាអម្ចាស់ ។ កាលព្រឹកលោកតែងតែទៅវត្ត ដើម្បីត្រួតពិនិត្យ ក្រែងព្រះសង្ឃមានការខ្វះខាតអ្វី លោកនឹងរៀបចំតាក់តែងប្រគេន ព្រោះគាត់ជាពុទ្ធសាសនិកមួយរូប មានសទ្ធាដ៏មុតមាំក្រៃពេក ។ មានចោរម្នាក់ យប់អាស័យដើរកាប់ទួលបានលុះជិតភ្លឺ ខ្លាចអ្នកស្រុកសង្ស័យ ក៏ចូលទៅដេកលើសាលាក្នុងវត្ត ខ្លួចមុខជិត តែលេចដើងប្រឡាក់កក់ចេញមកក្រៅ ។ លោកសេដ្ឋីឡើងទៅលើសាលាឃើញមនុស្សដេកខ្លួចជិតមុខ ឃើញតែដើងប្រឡាក់កក់ដូច្នោះ ក៏ភ្លាត់មាត់និយាយថា: មនុស្សរបៀបនេះ ជាអ្នកកេស៊ីយប់ ។ អាចោរបានឮសំដីមិនតិរោះដូច្នោះ លបបង្គិចក្រមាខ្លួរ មើលមុខសេដ្ឋី រួចចងសេចក្តីគំនុំពុកថា ម្ល៉េះហើយត្រូវអញបំផ្លាញគាត់នេះ ។

តពីនោះមិនបានប៉ុន្មានថ្ងៃ ក៏ទៅលួចដុតស្រូវក្នុងរំស្រែឆេះអស់ លបលួចចាប់កាត់សរសៃតែងសត្វពាហនៈមានគោក្របីជាដើមអស់ច្រើន មិនតែប៉ុណ្ណោះ លួចដុតទាំងវិហារដែលសេដ្ឋីបានកសាងថ្វាយព្រះពុទ្ធអង្គថែមទៀត ។

សូមអ្នកអានតាំងឮាយតិចារណាមើល លទ្ធផលដ៏អាក្រក់អស្ចារ្យនេះបណ្តាលមកពីអ្វី ? គឺមកតែពីសេដ្ឋីមិនចេះប្រើពាក្យសំដី ឬមកពីការប្រើ

ពាក្យដែលសាយឡាំដោយសេចក្តីម៉ៃលជាយ ។ មនុស្សក្អែកខ្វាក់យើង
ហៅគេថា «អាខ្វាក់» ពាក្យហៅនេះត្រង់ទៅតាមការណ៍ពិតមែន ។ ប៉ុន្តែ
ពាក្យដំណាស់ខឹងបំណងរបស់មនុស្សដែលសុទ្ធសឹងជាអ្នកចង់ស្តាប់ ចង់ឮតែ
ពាក្យពិកោះ ពាក្យជាមង្គល ម្ល៉ោះហើយមនុស្សខ្វាក់នោះត្រូវតែខឹង ត្រូវ
តែមិនពេញចិត្តនឹងសំដីដែលយើងហៅជាធម្មតា ។

គួរឲ្យគោតសរសើរ។ ហើយសរសើរទៀតចំពោះសម្តេចព្រះប្រមុខ
ផ្ទៃយើងជាពន់ពេក ព្រះអង្គចេះសព្វឥតមានខ្វះចន្លោះត្រង់កន្លែងណា
នេះឬនទើបសមជាទេពត្រកូលជាន់ខ្ពស់ឬតមក: ទី ១ ព្រះអង្គទ្រង់ច្បាស
ចាកការប្រកាន់ព្រះអង្គ ទី ២ ព្រះអង្គទ្រង់តែងតែពេញដោយច្បាប់សុដីវ-
ធម៌ ទី ៣ ព្រះអង្គទ្រង់ជាព្រះមហាក្សត្រដែលសព្វព្រះទ័យក្នុងការគោរព
មនុស្ស ។

សូមលោកអ្នកអានចាំងឡាយសង្កេតមើលចុះ នៅពេលដែលសម្តេច
យើងមានព្រះបន្ទូលម្តង ។ កូនចៅព្រះអង្គតាំងពីថ្នាក់ចាបដល់ថ្នាក់ខ្ពស់ អ្នក
ណាគិតពេញចិត្តនឹងត្រង់ត្រាប់ស្តាប់ព្រះសូរសៀង ដំណែនតិកោះរបស់ព្រះ
អង្គ ។ ការពិកោះដែលខ្ញុំលើកយកមកថាក្នុងទីនេះ មិនសំដៅយកអត្ថន័យ
ទេ ព្រោះអត្ថន័យនោះហួសវិស័យយើងទៅហើយ នេះគឺចំពោះតែទម្រង់
ព្រះភថា ពោះបីទៅតាន់ប្រជាភស្ត្រ ភពិកោះខាងភស្ត្រ ទៅតាន់ភ្នាក់ងារ
ភជការ ភពិកោះខាងអ្នកភ្នាក់ងារភជការ ទៅតាន់ឥស្សរជន ភពិកោះខាង

ឥស្សរជន ទៅកាន់ព្រះពុទ្ធវង្សានុវង្ស ពាក់ព័ន្ធនឹងព្រះពុទ្ធវង្សានុវង្ស ។ ព្រះវាចានៃព្រះអង្គ ពាក់ព័ន្ធសមទៅតាមឋានៈនៃមនុស្សទាំងឡាយ ។ តាមការសង្កេត ទឹកព្រះវាចារបស់ព្រះអង្គ គឺច្បាស់ថាកមានធម៌ ច្បាស់ថាកការប្រមាថដែលទាំងឲ្យដឹងឲ្យឃើញថាគេទៅក្រោមព្រះអង្គ មិនដល់នឹងព្រះអង្គ ។

មានភាសិតបុរាណខ្មែរមួយឃ្លាគេពោលថា: «សំដីសាធាតិមានយោធសារពួជ» ភាសិតនេះគឺពិតជាត្រូវណាស់ ។ គេគ្រាន់តែស្តាប់សំដី គេអាចយល់បានថា អ្នកដែលនិយាយជាជាតិអ្វី ជាតិអ្នកស្រុកឬជាតិបរទេសនេះម្យ៉ាង ម្យ៉ាងទៀតគេដឹងថាអ្នកនិយាយជាជាតិមនុស្សមានការអប់រំត្រឹមត្រូវ ឬការអប់រំខ្វះខ្លួន ។

សារុបសេចក្តី ភាសិតទាំងប៉ះ: «សំដីជាឯក សេចជាពេ» អណ្តាតជាអាវុធក្នុង អស់សុខទុក្ខផងកើតពីអណ្តាត» នឹង «សំដីសាធាតិ មានយោធសារពួជ» មានន័យមិនជាផ្សេងពីគ្នាប៉ុន្មាន គឺជាភាសិតសម្រាប់ជាស្មារតីយើងឲ្យប្រុងក្នុងការនិយាយស្តី: និយាយ ចានទទួលលាភនឹងការសរសើរក៏មាន និយាយ ចានទទួលអលាភនឹងការនិន្ទាព្រមទាំងគ្រោះកាចក៏មាន ។

ដូច្នេះ ចំពោះការនិយាយស្តី សូមអ្នកអានទាំងឡាយជួយពិចារណានឹងវិនិច្ឆ័យផង ថាតើគួរយើងនិយមអនុលោមទៅតាមរបៀបណា ? ។

ដោយគណៈកម្មការជាតិនៃការសិក្សាផ្នែកអក្សរ «ក»

(តទៅ)

1 — Accusé (n. m.) អ្នកជាប់ចោទ (ពាក្យ) : ជនដែលសាលាក្រុមចោទបានពិនិត្យឃើញថា មានប្រព្រឹត្តបទឧក្រិដ្ឋមែន កំសម្រេចបញ្ជូនទៅសាលាឧក្រិដ្ឋដំណុំរ: ។

—B—

2 — Bénéficier d'une présomption légale de paternité ទទួលសច្ចធារណ៍នីត្យានុកូល ចំពោះបិតុភាព ។

—C—

3 — Compétence (n. f.) សមត្ថកិច្ច សមត្ថកម្ម ។

4 — Compétent (adj.) ដែលមានសមត្ថកិច្ច ។

—D—

5 — Désuétude (n. f.) អប្បយោគ : ការមិនបានប្រើមកយូរពេលហើយ ។

6 — Désuet (adj.) អប្បយុត្ត ។

7 — Droit réel សិទ្ធិលើវត្ថុ ។

8 — Droit personnel ou droit de créance សិទ្ធិលើបុគ្គល ។

9 — Droit réel mobilier សិទ្ធិលើវត្ថុជាចលនៈ ។

10 — Droit réel immobilier សិទ្ធិលើវត្ថុជាអចលនៈ ។

11 — Droit objectif នីតិសាស្ត្រ ។

12 — Droit subjectif សិទ្ធិ ។

13 — Droits pécuniaires សិទ្ធិធនាយ័ត ។

14 — Droits nom pécuniaires សិទ្ធិឋានធនាយ័ត ។

—E—

15 — Elaborer (v. tr.) រចិត : ធ្វើឲ្យត្រូវគ្រាប ។ ខ : ក្រពៈរចិតអហារ ។ = ពាក់តែង ។ ខ: រចិតនីតិព្រហ្មទណ្ឌ ។

16 — Force probante des actes authentiques កម្លាំងជាក់ស្តែងនៃលិខិតឃើញថាភូត : អំណាចដែលដឹងជាប់នឹងលិខិតនេះ ដោយយកសេចក្តីជាភស្តុតាង ។

—I—

17 — Impératif (adj.) អាជ្ញាបញ្ជា ។

18 — Inculpé (n. m.) អ្នកត្រូវចោទ : (ពច្ប :) ជនដែលក្រុមអយ្យការបញ្ជូនទៅសុភាចាបុរស ឲ្យអង្កេតស៊ើបសួរ ពីបទមជ្ឈិម ឬបទឧក្រិដ្ឋ ហើយដែលសុភាចាបុរសនេះ កំពុងតែពិនិត្យ។

—J—

19 — Juge (n. m) ចៅក្រម (ពច្ប) : អ្នកកាន់អំណាចតុលាការ ។

—L—

20 — Loi impérative ច្បាប់អាជ្ញាបញ្ជា . ច្បាប់ដែលដាក់វិធានមួយ ទៅលើជនទាំងឡាយថាមិនឲ្យយកកិច្ចសន្យាផ្ទុយ មកអនុវត្តដំណើរឡើយ ព្រោះថាមានតែវិធានតោះទេ ដែលអាចរក្សាសេចក្តីរៀបរយដ៏សាធារណៈឬក្បួនចរិយាប្រពៃបាន ។

21 — Loi ordinaire ច្បាប់ធម្មតា : ច្បាប់ដែលឯកជនអាចកែប្រែបានដោយងាយដាងច្បាប់ធម្មនុញ្ញ ។

22 — Loi organique ច្បាប់អង្គិន (ពច្ប) : ច្បាប់ដែលបង្កើតអង្គការណាមួយឲ្យមានរូបរាងឡើង ។

—M—

23 — Magistrats du siège ou magistrats assis ចៅក្រមកាត់សេចក្តី ឬ ចៅក្រមអង្គុយ (ពច្ប) . ចៅក្រមមានភារៈកាត់សេចក្តី ហើយក្នុងពេលដំណើរតែងអង្គុយជានិច្ច ។

24 — Magistrats du Ministère public ou magistrats debout ចៅក្រមក្រុមអយ្យការ ឬ ចៅក្រមឈរ (ពច្ប) . ចៅក្រមទទួលភារៈតំណាងសង្គម ហើយក្នុងពេលដំណើរការណាអធិប្បាយ ត្រូវក្រោកឈរឡើង ។

—N—

25 — Objectif (adj.) វត្ថុនិស័យ . ដែលមានទីដៅជាខាងក្រៅខ្លួន ។

វិបត្តានុក្រមសំស្ក្រឹត-ខ្មែរ

ព្រះមហា ថាំ ង - ខាត់ រៀបរៀង

(តមក)

អត្យាវ្ឈិ ស្ត្រី. សេចក្តីចំរើនក្រៃលែង ។

អត្យាវ្រោបា ចុំ. កិរិយាឡើងក្រៃលែង ឬកពាឆ្មើងឆ្មៃ សេចក្តីខ្ពង់ខ្ពស់ ។

អត្យាតិ ស្ត្រី. សេចក្តីទុក្ខក្រៃលែង ។

អត្យាយំ គុ. ដែលប្រសើរក្រៃលែង ។

អត្យាកិ ចុំ. កិរិយាការកោតក្រៃលែង ។

អត្យាក្ឆ្យំ គុ. ដែលអស្ចារ្យក្រៃលែង ។

អត្យាគ្រ្ភមិ៍ដ គុ. ដែលមានអាស្រមក្រៃលែង ។

អត្យាសង្គ ចុំ. កិរិយាជាប់ជំពាក់ក្រៃលែង ។

អត្យាសទ ធាតុ. ទៅដិតក្រៃលែង ដោល ។ *អត្យាសន្ន* គុ. ដែលនៅដិតក្រៃលែង ។

អត្យាហិត គុ. សេចក្តីទុក្ខ ព្រោះកាច អំពើមានភ័យ ។

អត្ថុក្តិ ស្ត្រី. ការិយាពោលក្រៃលែង ការិយាពោលអួតខ្លួន ។

អត្ថុគ្រ គុ. ដែលភ្លៀវភ្លាក្រៃលែង ។

អត្ថុច្ច គុ. ដែលខ្ពស់ក្រៃលែង ។

អត្ថុច្ឆ្រយ ប្ញុ. ការិយាកឡើងក្រៃលែង ការិយាកសាង ។

អត្ថុច្ឆ្រិត គុ. ដែលខ្ពស់ឡើងក្រៃលែង ។

អត្ថុត្ត គុ. ដែលពោលក្រៃលែង ដែលប្រាថ្នា ។

អត្ថុត្តជ គុ. ដែលអស្ចារ្យក្រៃលែង ។

អត្ថុត្តម្បរិន៏ គុ. ដែលញាប់ញ័រក្រៃលែង ។

អត្ថុត្រម៏ ឆគុ. ទៅខាងលើក្រៃលែង ប្រសើរ ។ *អត្ថុត្រាន្ត* គុ. ដែលបិត
នៅផ្ទាយ ។

អត្ថុត្សេក្រ ប្ញុ. ការិយាអួតក្រៃលែង ។

អត្ថុទាត្ត គុ. ដែលខ្ពង់ខ្ពស់ក្រៃលែង ដែលប្រសើរលើស ។

អត្ថុទារ គុ. ដែលឧត្តមក្រៃលែង ។ — *ភា* ស្ត្រី. ភាវៈនៃជនមានសេចក្តីជ្រះថ្លា
ក្រៃលែង ។

អត្ថុន្នត គុ. ដែលខ្ពស់ក្រៃលែង ។ — *តិ* ស្ត្រី. សេចក្តីខ្ពង់ខ្ពស់ក្រៃលែង កំ-
ពស់ក្រៃលែង ។ (នៅមានត)

រឿងសាមកុក

ឧកញ៉ាវិបុលកដវេនា ទួ - កាន ប្រែរៀបរៀង

(តទៅ)

រឿងសាមកុកទុកជាឃ្លាសារ្ត
អ្នកវាងវៃឆ្លាសបើបានអាន
នឹងបោះឧបាយកលចំណាន
ទាំងមានសន្តានស្នេហាជាតិ ។

— ឃ្លោ-អ៊ុន —

ចូរឆ្ងល់ដូច្នោះ កំសុះប្រឡោតដោយអំណាចសេចក្តីក្រែវក្រោធពន់ប្រមាណ ខំបស្រែកប្រកាសថា តាហានណានឹងអាចទទួលយកតាសាចាប់ស៊ុនគួនឲ្យយើងបាន ថាមិនខាន់ផុតមាត់កំស្រាប់តែឮសម្លេងផាវអុជឡើងលើកំពូលភ្នំ ចូឆ្លូក្រឡេកទៅឃើញជីវិថាយ ហ៊ានតុងលើកតាហានបាញ់ធូចម្រុះបុះមកតាមប្រកង់ផ្ទៅខាងឆ្វេង, ឃើញតន់ចូ ភ្លូចៀង លើកតាហានចូលខ្លួចមកពីខាងស្តាំ បាញ់ធូចម្រុះមកចំខ្ទីតចូឆ្ងូ ព្រួញកំផ្ទាក់មកជាដូចគ្រាប់ភ្លៀង ចូឆ្ងូភ័យណាស់ក៏ដោះថយមកក្រោយ ។ ជីវិថាយតន់ចូ ភ្លូចៀង ឃើញថាឱកាសកំប៉ះពេលចូលប្រកាប់ ។

ខាងចូឃើញដូច្នោះ កំសុះចេញប្រញាប់ព្រមតាំងតាហានខ្លាំងប្រើនចូលទៅដួយចូឆ្ងូ បានតយុទ្ធគ្នាជាជ្រួលច្របល់ទៅមក កងទ័ពស៊ុនគួនក៏ថយទៅ ចូឆ្ងូក៏ត្រឡប់ទ័ពចូលបន្ទាយហើយគិតថា ស៊ុនគួននេះ មាន

សេចក្តីអង់អាចណាស់ ដោយហេតុពាសនាល្អប្រហែលដូចយើងយល់-
សប្តាយើញព្រះអាទិត្យធ្លាក់ចុះមកពីលើកំពូលភ្នំ គឺស៊ុនគួននេះទេដឹង, ថើ
តាមសង្កេតកាយើញថាអំណើះទៅមុខ ស៊ុនគួនតង់បានជាម្ចាស់កុកមួយ
មិនខាន ។ កងទ័ពចូនឯងកងទ័ពស៊ុនគួនតាំងតែច្បាំងគ្នានៅទីនោះ ប្រ-
ហែល ១ ខែជុំយមិនចាញ់មិនឈ្នះ លុះកន្លងបួលឆ្នាំថ្មីជាទេសកាលភ្លៀង
ខ្លាំងណាស់ ពាហនតាំងសង្គមាងធ្វើសង្គ្រាមនឹងគ្នាជាលំបាកណាស់
ស៊ុនគួនកាប្រើប៉ាវើឲ្យនាំសំបុត្រទៅដល់ចូនឯ សេចក្តីថា ខ្លួនយើងនឹងមហា-
ឧបាជ កាសុទ្ធតែជាខ្មាំព្រះចៅហៀនតេដូចគ្នា ព្រះចៅហៀនតេតាំងឲ្យ
អ្នកធ្វើសេនាបតីធំ គួរតែអ្នកជួយទំនុកបំរុងផែនដី ដើម្បីឲ្យអាណាប្រជា-
ទុកស្រួលនៅជាសុខ ដែលនឹងត្រឡប់លើកកងទ័ពមកធ្វើទុក្ខបុកម្នេញឲ្យ
អាណាខែត្រនីមួយៗព្រួយលំបាកដូច្នេះ កាយើញថាជាការខុសនឹងភជប្រ-
ពៃណី មិនសមគួរកងទ័ពសេនាបតីធំនោះឡើយ ប្រការមួយ កាលនេះ
ជារដូវភ្លៀង បណ្តាពលយោធាកាមានសេចក្តីវេទនាណាស់ គួរតែរំសាយ
កងទ័ពត្រឡប់សងខាងទៅវិញ បើបង្កើនធ្វើការនេះតទៅទៀត ក្រែងនឹង
មានភ័យដល់ខ្លួន ។

ចូនឯឃើញសេចក្តីសំបុត្រដូច្នោះ គិអស់សំណើចហើយថា ស៊ុន-
គួននេះមានសេចក្តីតាវៈដល់យើងជាអ្នកធំសមគួរណាស់ ហើយកឲ្យប់-
ណាចរង្វាន់អ្នកកាន់សំបុត្រឲ្យត្រឡប់ទៅប្រាប់ស៊ុនគួនវិញ រួចចូនឯក៏លើក

ទ័ពត្រឡប់ចូលទៅស្រុកហ៊ូតោ ឯស៊ុនតួនក៏លើកទ័ពត្រឡប់ទៅវិញ
ត្រឹស្រុកបុះឡែង ទើបប្រមូលមុខមន្ត្រីខ្ញុំពាជការចូលមកប្រឹក្សាថា
វេលានេះ ចូរធ្វើកំលើកទ័ពត្រឡប់ទៅស្រុកវិញហើយ ឯឡៅពីក៏ទៅមិនខាន
ត្រឡប់មកពីស្រុកសែឈួន គឺទៅតាំងទ័ពក្នុងដំបន់ដែនហែបាំងគួន បើ
ដូច្នោះ យើងត្រូវលើកទ័ពទៅពយយកស្រុកគេងដីវតែម្តង តើអស់លោក
នឹងយល់យើញប្រការម្តេច ។

ខៀវចៀវធ្វើយថា ដែលនឹងលើកកងទ័ពទៅវាយយកស្រុកគេងដីវ
គ្រានេះ សុំឲ្យឈប់សិនទៅចុះ ព្រោះខ្លាចក្រែងចូរធ្វើដំណឹងត្រឡប់លើក
ទ័ពមកធ្វើអន្តរាយដល់ស្រុកយើង ខ្ញុំបាទគិតយើញថា សូមឲ្យលោកមាន
សំបុត្រទៅដល់ឡៅដៀងចៅហ្វាយស្រុកសែឈួនថា ឥឡូវឡៅពីមិន
ប្លាននៀងត្រង់នឹងអ្នកទេ ត្រឡប់ចូលទៅខាងខៀវឡៃជាចិត្តមួយនឹងគ្នា
ទៅហើយគិតនឹងវិលមកធ្វើអន្តរាយដល់អ្នកវិញ ដើម្បីឲ្យឡៅដៀងមាន
សេចក្តីសង្ស័យនឹងឡៅពី ហើយមានសំបុត្រទៅដល់ខៀវឡៃខៀត
សេចក្តីថាស្រុកគេងដីវនោះ ឡៅពីមិនបាននៅទេ សូមលើកទាហាន
ទៅពយយកចុះ មុខជានឹងបានដោយស្រួល ។

បើឡៅដៀងនឹងខៀវឡៃបានដឹងដូច្នេះហើយ ក៏នឹងប្រមូលកងទ័ព
កំរើកឡើង មុខជាឡៅពីនឹងខៀវឡៃ ឡៅដៀងទៅជាច្បាំងគ្នាជាប់ដៃទៅ
វិញទៅមក ឯក្រោយនោះសឹមយើងលើកកងទ័ពទៅពយស្រុកគេងដីវឲ្យ

ចាន់ដោយងាយ ពោះបីឡៅតីនឹងដឹងកំត្រឡប់វិលមកវក្សាស្រុកមិនខាន់
មុខជានឹងកមុខរក្រោយឲ្យជាកង្វល់នៅទីនោះ, ស៊ុនគួនស្តាប់ក៏យល់ត្រូវ
តែបែងសំបុត្រ ២ ច្បាប់តាមការឲ្យវៀវៀវៀវាគ្រប់ប្រការ ហើយប្រើបំរើ
កាន់ទៅដល់ឡៅដៀងនឹងឲ្យ ។

ឯឡៅតីបោះចំណៅបន្ទាយហែជាំងគួន មានចិត្តរួសរាយរាក់ទាក់
នឹងអាណាប្រជានុកស្ត្រណាស់ ពួកបណ្តាពស្ត្រកំស្មោះសរត្រកអរស្រ-
ឡាញ់ជាច្រើន លុះឃើញសំបុត្រដែលខុងបេងឲ្យទៅដល់ថា នាង
ស៊ុនហ៊ូ-យិន ត្រឡប់ទៅស្រុកកាំងតាំង លុះដឹងថា ចូនួលើកទ័ព
ទៅច្បាំងនឹងស៊ុនគួននោះដំបន់យើស៊ូ ឡៅតីក៏ប្រកាន់ចាំងថងថា ឥឡូវ
ចូនួនឹងស៊ុនគួនច្បាំងជាប់ដៃគ្នាហើយ បើចូនួមានជ័យជំនះគាលណា
ក៏នឹងលើកទៅកយយកស្រុកកេងជីវវៀត ប្តូរបើស៊ុនគួនមានជ័យជំនះវិញ
ក៏នឹងលើកទៅកយយកស្រុកកេងជីវដែរ តើអ្នកនឹងគិតយើញប្រការម្តេច ។

ចាំងថងថា ដែលលោកនឹងត្រឡប់ទៅការពារស្រុកឯនាយនោះ គួរ
តែធ្វើសំបុត្រប្តាប់ទៅឡៅដៀងថា ឥឡូវចូនួលើកទ័ពទៅកយស្រុកកាំង
តាំង ស៊ុនគួនឲ្យមានសំបុត្រមកសុំកងទ័ពស្រុកកេងជីវទៅជួយ ដោយ
ខ្លួនយើងនឹងស៊ុនគួន ក៏ជាបងប្អូននឹងគ្នានឹងមិនទៅជួយក៏មិនត្រូវ យើង
នឹងសុំតាហានអ្នក ៣ ម៉ឺន នឹងសៀង ១០ ម៉ឺនថាំង ហើយនឹងកងទ័ព
ត្រឡប់ទៅជួយស៊ុនគួន ដើម្បីនឹងកំចាត់ចូនួចេញឲ្យបានសិន ប្រសិន
បើវៀវឡៃនឹងលើកទ័ពមកធ្វើអន្តរាយដល់អ្នក ក៏នឹងខាចអ្វីវៀវឡៃនោះ

ត្រោះសុទ្ធតែមនុស្សអ្នកលើល្បីល្បើដូចគ្នា បើយើងលើកទៅតំបាត់ចូរ
ស្រេចហើយ ក៏ឯងលើកត្រឡប់មកជួយខ្ញុំវិញ បើឡៅដៀង
ឲ្យតបាហានឯងស្បៀងអាហារតាលណា យើងក៏មានតម្លាងក្លាខ្លើង
ខ្លួនឯងនេះតិតប្រែប្រួលប្រការម្តេចក៏សឹងតែបាន ឡៅតីយល់ឃើញ
ត្រូវក៏តែងសំបុត្រប្រើបំរើឲ្យកាន់ទៅឲ្យឡៅដៀង ។

លុះអ្នកកាន់សំបុត្រនោះទៅដល់តយ អៀវហ៊ីយក៏ឲ្យគោរាយនៅ
រក្សាតយ ឯខ្លួនក៏ឃុំនាំអ្នកកាន់សំបុត្រនោះចូលទៅជួនឡៅដៀង ។ ក៏
សួរថា យើងឲ្យអ្នកនៅរក្សាតយ មិនបានឲ្យរកហេតុអ្វីឯងចូលមកនោះ
ក៏ខេ អៀវហ៊ីយថា ដែលខ្ញុំបាទមកនោះ ត្រោះឡៅតីឲ្យមានសំបុត្រ
មកដល់លោក ខ្ញុំបាទនឹងបណ្តោយតែអ្នកកាន់សំបុត្រចូលមក ដោយ
អំពើខ្លួនឯងក៏មិនបាន ត្រោះឡៅតីជាមនុស្សមានប្រាជ្ញាចេះគិតកល។ជាយ
វង្គមក្រៅល្បីឯកង ដែលនឹងឲ្យសុំស្បៀងអាហារនឹងយោធាតាហានោះ
សុំកុំឲ្យលោកត្រមឲ្យឡើយ បើឡៅតីបានមនុស្សនឹងស្បៀងអាហារជា
តម្លាងច្រើនហើយ ក៏ដូចជាយក។សៅឲ្យក្តៀង ឡៅដៀងថា ឡៅតី
ជាបងប្អូនរបស់យើង ហើយក៏មានសេចក្តីខឿងត្រង់ បើមិនឲ្យតាម
ប្រាថ្នាមិនបានឬ? ។

ឡៅប៉ាថា ឡៅតីនោះជាមនុស្សគ្មានកតញ្ញូ ដែលលោក
កមកពុកកងស្រុកសែឈួននេះ បើដូចជាយកភ្នាមកចិញ្ចឹមពុកកងកូមិ

ហើយមកថែមឲ្យមនុស្សខំធ្វើស្រែឯងជាកម្ចាំងទៀត ក៏តែងឲ្យមានកម្ចាំងតំរើបច្រើនឡើង ឃូរៅតំខំធ្វើពិតដូចពាក្យដែលអៀវហ៊ុយថាខោះច្រកដឡៅដឿងបានឮទ្រីប្រីក្សាចាំងតួងនាំខខំធ្វើដូច្នោះ កំឲ្យឆ្លៀកធ្វើចិត្តណាស់ ទើបចាត់ឲ្យពាហានតែពួកអាយុច្រើន ។ ចំនួន៤ពាន់ ខំធ្វើស្រូវ ១ ម៉ឺនចាំង ប្រគល់ឲ្យអ្នកកាន់សំបុត្រ ហើយកំចាត់ឲ្យមនុស្សនាំទៅប្រគល់ដល់ឡៅតី ហើយឡៅដឿងតីកំជាប់ហៀវហ៊ុយឲ្យរក្សាគយល្បាតលាត ក្រែវែលឲ្យមាំមួនជាងពីដើម ។

លុះអ្នកកាន់សំបុត្រនោះត្រឡប់វិលទៅវិញ កំចូលទៅដំកបឡៅ-តី ។ ខំធ្វើណាស់ ក្រែកឈរឡើងដេរថា ចោលម្បៀតមកជួយការពារ រក្សាស្រុកឲ្យតង់ល្អ យើងត្រាន់តែសុំមនុស្ស ខំធ្វើស្រែអាហារគួរឬឲ្យ យើងតែប៉ុណ្ណោះ យើងធ្វើការតទៅកំបង់កម្ចាំងខទេ ឡៅតីកំយក សំបុត្រនោះហែកឈ្វីចោលបង់ បំរើដែលនាំស្រែខំធ្វើឲ្យតមកដល់ ឃើញឡៅតីខំធ្វើចាំងដូច្នោះកំតិយណាស់ ចាំងអស់គ្នាក៏តវិលត្រឡប់ទៅស្រុកសែឈួនវិញគ្មានសល់ ។

ចាំងថងដំកបឡៅតីថា តីថ្ងៃមុនលោកធ្វើចិត្តសុភាពគ្មានសេចក្តីអ្វីជាអក្រក់ មនុស្សក្នុងស្រុកដឹងពួកៅ ឥឡូវលោកមកខំធ្វើចោះចាក ដូច្នេះ ថែមចាំងហែកសំបុត្រចោលហើយពោលពាក្យមិនពីពេះទៅវិញ មនុស្សចាំងពួងកំខំធ្វើដឹងពួកៅ មិនបង់ប្រយោជន៍ដែលធ្វើល្អមកខោះ

ជាអសារឥតប្រយោជន៍ខ្លះទេឬ ឬក៏ពីថា អ្នកនិយាយនោះត្រូវណាស់ ដែលខ្ញុំបានប្រមាទភ្លាត់ភ្លាំងទៅហើយដូច្នេះ ទីឆ៍ធ្វើប្រការម្តេចឲ្យល្អឡើងវិញបាន ចាំឆ៍ថឆ៍ថា ឥឡូវលោកបានជាធ្វើឲ្យទាស់ខុសទៅហើយ ទីឆ៍ត្រឡប់ធ្វើល្អតទៅមុខទៀត សេចក្តីរង្កៀសនោះក៏មិនសាបសូន្យ បើបានជាធ្វើខុសដល់ប៉ុណ្ណោះទៅហើយ ទីឆ៍សូមទៅក៏ពុំបានសុំឲ្យលោកចាត់ចាហាន ដែលមានថ្វីដៃស្គាត់ត្រូវទៅលបចាមរាយយកស្រុកសែឈួនឲ្យបានប្រការ ១ បើមិនដូច្នោះឲ្យលោកលើកកងទ័ពធ្វើជាប្រឆ៍ទីឆ៍ត្រឡប់វិលទៅស្រុកកេឆ៍ដីវិញ អាក្រក់ល្អតនឹតែអៀវហ្ចឹយកោរជាយ ដែលក្បាតយនោះទីឆ៍សំគាល់ថាលោកទៅមែនទីឆ៍ដូនៅ យើងទីឆ៍ចាប់យកខ្លួនទៅសម្លាប់ចេញ ដណ្តើមយកតយនោះឲ្យបាន ហើយសឹមលើកទៅរាយយកស្រុកសែឈួនប្រការ ១ បើមិនដូច្នោះទេ សុំឲ្យលោកលើកចាហានទៅទៅស្រុកច្នាំកតេសៀមិន រួចសឹមយើងលបវាត់ទៅស្រុកកេឆ៍ដីវ៉ា ដើម្បីទីឆ៍ចាត់ចែងពលចាហានឲ្យត្រម ហើយសឹមរលើកមករាយយកស្រុកសែឈួនជាក្រោយឲ្យបាន ។ ឯកលចាំឆ៍ ៣ ប្រការនេះ លោកទីឆ៍យើញប្រការឯណាល្អ ក៏តាមអធ្យាស្រ័យលោកចុះ ដែលលោកទីឆ៍សូមទៅមិនគិតធ្វើការតទៅនោះ យូរទៅភ័យទីឆ៍មានមកដល់ខ្លួនលោកជាប្រាកដ ។

ឮពីថា តំនិតដែលអ្នកគិតនេះល្អណាស់ តែថាកលជាបឋមនោះ យើញដូចជាស្តួតពេកណាស់ កល់ទី ៣ នោះក៏ដូចជា

ខឿយវៀលច្រើន កលដែលជាគំរប់ ២ នោះល្មមជាប្រមាណ យើញ
បានការខាងយើង ខ្លៅពីកំឲ្យមានសំបុត្រទៅដល់ខ្លៅដឿង សេចក្តីថា
ឥឡូវបួនឆ្នូលើកកងទ័ពមកធ្វើអន្តរាយស្រុកកេងជាវហើយ ទុងបងមាន
សំបុត្រមកដល់ខ្ញុំឲ្យស្រួតប្រញាប់លើកកងទ័ពទៅវិញ បើនឹងបង្អង់ទៅ
ឲ្យយូរកំពុងបាន ខ្ញុំនឹងសុំលាអ្នកទៅរក្សាស្រុកសិន ដែលខ្ញុំមិនបានបួល
មកតំនាប់តាមប្រពៃនោះ ព្រោះជាការគាក់ក្រហល់ពេកណាស់ សុំឲ្យ
អ្នកអត់ទោសបុះ ។

ខណៈនោះខឿវសុង ដឹងថា ខ្លៅពីឲ្យមានសំបុត្របួលមកលា
ខ្លៅដឿងត្រឡប់ចូលទៅស្រុកកេងជាវិញ មិនដឹងថាជាកលឧបាយ
សំគាល់ថាមែន ក៏សរសេរសំបុត្រមួយច្បាប់ ប្រុងនឹងប្រើបំរើឲ្យគាន់យក
ទៅឲ្យខ្លៅពី លុះច្រកស្រោមបិទស្រេច ខឿលខឿវសុកជាបងដែលធ្វើ
ចៅហ្វាយស្រុកកេងហ៊ានបួលមកសួរ ខឿវសុងក៏យកសំបុត្រនោះសឹក
លាក់ក្នុងដៃអាវ ខឿវសុកជាបងយើញក៏រិះថាខឿវសុងជាប្អូនធ្វើរឡើម
រឡើមកំនឹកពិតល់ក្នុងចិត្តណាស់ តែមិនថាអ្វី ។

លុះខឿវសុង បរិភោគអាហារជាមួយនឹង ខឿវសុក ផឹកស្រាស្រវឹង
ណាស់សំបុត្រដែលទៅក្នុងដៃអាវនោះ ក៏របូតធ្លាក់ពុះទៅក្រោមតុមិនដឹង
ខ្លួន, ចាវខឿវសុក រើសបានក៏ហុចទៅឲ្យខឿវសុក ។ ក៏ហែកស្រោម
មើលឃើញសេចក្តីថា ខ្ញុំចាខឿវសុង សូមតំនាប់ខ្លៅពី ព្រោះខ្ញុំចា

ឃ្លានចរចាខ្ញុំកដល់លោកពីដើមនោះជាពាក្យពិត ឥឡូវលោកលើកពលមកដល់ស្រុកសែឈួនហើយ បើនឹងគិតធ្វើការដូចជាពាក្យដែលមិយាយគ្នានោះ ក៏នឹងឃានដូចសេចក្តីប្រាថ្នា ស្រុកសែឈួនដូចទៅកន្លងកណ្តាប់ដៃលោកហើយ ហេតុម្តេចបានជាលោកមិនគិតធ្វើការនោះ ខឹងលើកខ័ណ្ឌត្រឡប់ទៅស្រុកវិញទេដូច្នេះ ខឹងមិនបង់កម្លាំងពលឥឡូវនេះឥតអំពើទេឬ? សូមឲ្យលោកគិតធ្វើការឲ្យសម្រេចសិន ខ្ញុំនឹងបានខឹងចូលយកអាសាចាត់ការជូនលោកខាងក្នុងស្រុកសែឈួនឯណោះហើយ ។

ខៀវសុកឃើញសេចក្តីសំបុត្រដូច្នោះក៏តយ័ស្មុតចិត្តគិតថា ប្អូនអញម្តេចមកគិតធ្វើការដូច្នេះ ខឹងខាំគ្នាវិនាសខាំងអស់ទេឬ? បើអញខឹងស្ងៀមទុកទៅក៏មិនត្រូវសោះ គួរនឹងយកសំបុត្រនោះទៅបង្ហាញឡៅជឿងឲ្យដឹង ខៀវសុកក៏ស្រួតប្រញាប់ចាប់យកសំបុត្រនោះទៅបង្ហាញឡៅជឿងហើយថា ខៀវសុងប្អូនខ្ញុំបានទៅគិតប្រទូសក៉ាយលោក ឡៅជឿងឃើញដូច្នោះក៏ខឹងខ្លាំងណាស់ ថាខ្លួនយើងបានចិញ្ចឹមកក្បាញ្ជាចាលទុបត្តម្ភខៀវសុងមកយូរហើយ មិនគួរឡើយវាមកប្រែចិត្តគិតក្បត់យើងដូច្នេះសោះ គួរតែវាជួយខំទុកជំនួសយើងជាផ្លែកតញ្ញូតទៅទៀត ហេតុអីវាមកលើកស្រុកសែឈួនឲ្យទៅឡៅពីវិញ មិនគួរសោះ លុះនិយាយហើយក៏ចង្អាប់ឃានឲ្យទៅចាប់យកខ្លួនខៀវសុង ព្រមទាំងកៃយាបុត្រទៅសម្លាប់បង់ រួចប្រឹក្សានឹងនាមីនទាំងពួងថា ឥឡូវឡៅពីនឹងមកគិតប្រទូសក៉ាយយើង

យើង គឺក្រាថ្នាទឹងយកស្រុកសែឈួនជាសិទ្ធិរបស់ខ្លួន ទ័ប្រឹក្សាទាំងពួង
ទឹងគិតយើញប្រការម្តេច ។ អ៊ុយតួនថា ដែលឡៅពីគិតប្រឆូសក៏យ
ដល់លោកនោះក៏ដឹងខ្លួនហើយ ទឹងស្ងៀមទុកយូរមិនបានទេ សុំឲ្យលោក
រៀសរៀរៀង ។ ខ្លួន ទឹងចាត់ការឲ្យទៅរក្សាគយតាមផ្លូវឲ្យមាំមួន កុំឲ្យ
ទាហានឡៅពីកន្ទួងចូលមកកន្លងគយបាន ឡៅធៀងក៏យល់ត្រូវដែង ទើប
ឲ្យមានសំបុត្រទៅកាប់ត្រួតត្រាគយត្រប់ដែនដំបន់ ។

ឯឡៅពីនោះ លុះលើកទ័ពទៅដល់ដែនគយចាំយស៊ីតួន ក៏ឲ្យប់រើ
ចូលទៅច្រាប់អៀវហួយកោផាយឲ្យចេញមក ក្រាថ្នាទឹងធ្វើជាគំនាប់លា
អៀវហួយក៏និយាយទឹងកោផាយថា ឥឡូវឡៅពីគិតប្រការម្តេច បានជា
លើកទ័ពត្រឡប់ទៅស្រុកកេងដ៏វិញ កោផាយថាអ្នកកុំវិតក្តួយ ឡៅពី
គ្រានេះទឹងដល់សេចក្តីស្លាប់ហើយ យើងទឹងបបួលគ្នាយកអាវុធលាក់
បង្កប់កន្លែងដែរ ហើយតែងខ្លួនចូលទៅគំនាប់ឡៅពីកាលណាទឹងដឹងខ្លួន
បើយើងចូលទៅដិតហើយយើញប្រមាទធ្វេសប្រហែសវេលាណា យើងក៏
ត្រូវសម្លាប់ចេញ ស្រុកសែឈួនក៏ទឹងមិនអន្តរាយ អៀវហួយកោផាយ
គិតតូគ្នាហើយ ក៏រៀបរបស់ធ្វើង ។ លើកទាហាន ២០០ នាក់ចេញទៅ
គំនាប់ឡៅពី ។

(នៅមានត)

រឿងល្បែកឡាហ្វុងតែន

លោក ដេង - ដ្រីវ ប្រែរៀបរៀង

(តមក)

៣៨- កង្កែបនឹងកណ្តុរប្រែង

អ្នកណាដែលស្មានថា ខ្លួនឯងអាចបញ្ឆោតអ្នកដទៃបានដោយងាយ
ចំណង់ហ្នឹង ច្រើនតែធ្លាក់មកលើខ្លួនអ្នកនោះ ។

កណ្តុរមួយធំធាត់ ជាកណ្តុរមានចំណិះស៊ីបរិបូណ៌មិនខ្វះខាត បានមក
រត់លេងកំសាន្តទៅមាត់ត្រពាំងមួយ ។ មានកង្កែបមួយ ចូលមកជិតកណ្តុរ
ហើយនិយាយថា: « សូមបងកណ្តុរអញ្ជើញមកលេងឯផ្ទះខ្ញុំបានម្តង ខ្ញុំ
នឹងរៀបជប់លៀងជូនបងឲ្យបានសប្បាយ » ។ កណ្តុរខ្លួលភ្លាមឥតមាន
ចរចាអ្វី ក៏ពេញចិត្តកង់ការឆ្លូតទឹកលេង ដែលជាហេតុនាំឲ្យសប្បាយកង់
រយៈធ្លើដំណើរ ឱនឹងបានជួបប្រទះរបស់ប្លែក ។ ដែលពាក់មិនធ្លាប់បានឃើញ
ទៅតាមត្រពាំង កាលណាចាស់ទៅ ក៏នឹងនិយាយរឿងនេះប្រាប់ចៅ ។
តែកន្ទែងក៏កេងយ ចំនៀមទម្លាប់អ្នកស្រុកនឹងប្លាប់ពាក់ជការនៃអ្នកកង់ទឹក ។
ការដែលធ្វើឲ្យកណ្តុរពិបាកបន្តិច តែទៅត្រង់ដែលពាក់មិនសូវចេះហែលទឹក
ហើយដែលនាំឲ្យគេពិបាកជួយ ។ តែទោះបីយ៉ាងនេះ កង្កែបគង់មាន
ល្បិចយ៉ាងពូកែមួយ ជួយដោះស្រាយគឺ កង្កែបយកចងចូតមកចងជើងវាភ្ជាប់ជា
មួយជើងកណ្តុរ ។ លុះចុះកង់ត្រពាំងបាន៣ទាក់ស្រេចហើយ កង្កែបទំ

ប្រឹងរៀបលាតាញក្មៀវបស់ពុះជ្រមុជទឹក ខុសចាកប្បាប់មនុស្សផ្សេង ។ ទឹងសំដីដែលវាថានទៅយាយ វាតិតប់រុងឲ្យកណ្តុរស្លាប់ដើម្បីស៊ីខៅក្តៅ ។ បើតាមសេចក្តីយល់របស់វាគឺជាមួយដ៏ប្រសើរផុតលេខ ។ វាទឹកក្នុងចិត្តថាមុខជាបានស៊ីហើយ ។ កណ្តុរខំប្រឹងត្រដរហែលតាញរើចមកវិញ បន់ស្រន់អស់ខ្លាខ្លៅត្រកសូមឲ្យជួយ ។ ចំណែកកង្កែបចេះតែស្រែកចំអកឲ្យ កណ្តុរខំប្រឹងខ្លាំង កង្កែបខំប្រឹងតាញ លិចអណ្តែត ។ ។ កំពុងតែតាញចុះតាញឡើង ទេសកាលអ៊ីជួនមានខ្វែងមួយហើរតាមលើ ក្រឡឹងខៅក្រឡឹងមក ស្រាប់តែក្រឡេកឃើញកណ្តុរក្រឡាប់ភ្លាំងភ្លារនាទៃទឹក វាចុះតួយចុះមកតាបតក់យកខៅ ដោយគាំងកណ្តុរនឹងកង្កែបរយោង ។ ខ្វែងត្រេកអរពន្លេក ព្រោះបានគាំងសាច់គាំងត្រី ។

ការគ្នាតហួសពេក ត្រូវប្រាប់ឲ្យទុក្ខដល់ម្ចាស់ដើម ហើយសេចក្តីអាក្រក់ ច្រើនតែវិលត្រាក់មកលើអ្នកដែលឆ្លើម ។

៣៩- បបក មេពពែ និងក្អែងពពែ

មេពពែរៀបចេញទៅរកស៊ីស្មៅ បានបិទទ្វារភ្លាស់ទឹងនុកយ៉ាងស្រួលល្អ ហើយនិយាយផ្តាំកូនថា «ចូរឯងដឹងថែរក្សាខ្លួនឲ្យមែនទែន ប្រយ័ត្នកុំបើកទ្វារ រៀវលែងតែឮសំដីដែលនិយាយមានលក្ខំខ្ញុំ ទឹងមានរបៀបដូចជាពាក្យថា <<ខ្លាចចកទឹងពពួកចចកណាស់>> ។ និយាយប្រាប់កូនស្រេចហើយ ខ្លួលចចកដើរមកកែស្រះនោះ បានឮហើយចាំសំដីហ្នឹងទុក

មេពពែក៏មិនបានឃើញចចក ។ គ្រាន់តែមេពពែចេញផុតទៅក្នុមចចក ធ្វើត្រាប់សំដីមេពពែ ហើយតោលយ៉ាងផ្អែម គោះហៅឲ្យកូនពពែបើកទ្វារដោយសំដីថា « ខ្ញុំចចកណាស់ កូនអើយបើកទ្វារ » ហើយវាស្មានថា បានចូលក្នុមដូចបំណង ។ កូនពពែសង្ស័យ លួចលបមើលតាមប្រហោងក្រោល ហើយគ្រាប់ថា « ចូរអ្នកហុចដើងមានពណ៌ស ឲ្យយើងមើលសិន បើមិនហុច យើងមិនបើកទ្វារទេ » ដើងមានពណ៌សជាសំដីដំបាស់មួយយ៉ាងម៉ាដល់ពួកចចក ព្រោះជាពាក្យដែលចចកមិនដែលឮ ដូច្នេះចចកគ្មានដើងស ។ ពុំដូច្នោះ ចចកស្រាប់តែក្បាច់ខ្លួនត្រឹត ហើយដឹងថាមិនកើតការ ក៏វិលត្រឡប់ទៅចីតន្លែងវិញ ដូចកាលដែលវាមក ។ កូនពពែណានឹងអាចធន់ទៅបាន បើចចកថែមតែពាក្យមួយម៉ាត់ទៀតថា « ខ្ញុំចពួកចចកណាស់ » ដូចកាលដែលវាដើរទៅពួនោះ ។

ការប្រយ័ត្នពីរបែប គ្រាន់បើជាងមួយបែប ហើយបើប្រយ័ត្នឲ្យកាន់តែច្រើនទៅទៀត ក៏មិនមានប្រយោជន៍ ។

៤០ - ស្វាធឹងខ្លារខិន

ស្វានឹងខ្លារខិន នាំគ្នាទៅបុណ្យតាំងវត្ត ។ សត្វទាំងពីរ បំពេញកម្រិតផ្សាយ ដោយចំណែកវៀងខ្លួន ។ ខ្លារខិនអធិប្បាយប្រាប់គេដូច្នេះថា « សូមដំបូងអស់លោក - អ្នកសូមជ្រាប ។ ការមានតម្លៃទឹងសេចក្តីសរសើរអំពីខ្លួនឯ៎ង គេបានស្គាល់ត្រប់ចីតន្លែងធំ ។ អស់ហើយ ព្រះករុណាជាម្ចាស់

ជីវិតលើតួងក៏ទ្រង់សព្វព្រះទ័យចង់តទួនខ្ញុំដែរ ហើយប្រសិនបើខ្ញុំស្លាប់ទៅ ព្រះអង្គក៏ត្រូវការស្បែកខ្ញុំណាស់ដែរ ដ្បិតស្បែកខ្ញុំមានពណ៌ផ្សេង ។ មានខ្មៅអុជ ។ ពក្អិកពក្អាក់អង្កាញ់ខ្មៅ ។ ពណ៌ល្អបែបហ្នឹងបានជាទ្រង់សព្វព្រះទ័យណាស់ យ៉ាងនេះហើយ បានជាគេចូលចិត្តទស្សនាតែកល់គ្នា » ។

ចំណែកស្វាអធិប្បាយថា « សូមអភ័យទោស ! សូមមេត្តាអញ្ជើញមក អស់លោកតូចធំក្មេងចាស់ ខ្ញុំចេះលេងហក់ ។ រយៃបប ការប្លែក ។ ដែលខ្លាវខិនគួរគួនខ្ញុំបានពោលហើយ ការប្លែកហ្នឹងមានតែទំនឹងខ្លួនវាខាងក្រៅទេ ចំណែកខ្ញុំ ។ លេងទឹងទ្រាំជ្រាជ្រា ខ្ញុំចេះកំចាក់ក្បាច់ ចេះចាក់តុកគ្រប់យ៉ាង រត់ចេញរត់ចូលក្នុងវង់មូល ចាំងអស់នេះ យកតែមួយសេនទេ ប្រសិនបើមើលទៅហើយមិនសប្បាយ ខ្ញុំសូមដូនលុយវិញនៅត្រង់មាត់ទ្វារ ។

ស្វានិយាយត្រូវ មិនមែនគេពេញចិត្តទឹងសំលៀកបំពាក់ប៉ុន្មានឡើយ គេពេញចិត្តតែទឹងទ្រាំជ្រាជ្រា : អាមួយបញ្ចេញរបស់វិសេសថ្មីកជានិច្ច អាមួយតែមួយស្របក់ ក៏គេខ្ចិលកល់គ្នាទៅហើយ ។

សព្វថ្ងៃ មនុស្សអ្នកធំ មានបុណ្យសក្តិ យកតែសំលៀកបំពាក់ជំនួសទ្រាំជ្រា ដូចខ្លាវខិននោះ រាប់មិនអស់ឡើយ ។

៤១- អ្នកស្រែម្នាក់ធឹងក្លួន

ចូរអ្នកចាំងឡាយធ្វើការ ចូរអ្នកចាំងឡាយខំប្រឹងប្រែងធ្វើឲ្យមែនទែន:

ការងារនេះហើយច្រើនតែអ្នកចាំដណ្តើយចំពេញមិនបានបរិបូណ៌ ។

មានកុដុម្ពីក៍ម្នាក់ ដឹងថាខ្លួនជិតស្លាប់ ក៏ប្រាប់ឲ្យគេហៅកូនមកជិត ហើយនិយាយប្រាប់គ្នានឹងកូនថា : ចូរកូនពាល់គ្នាកុលក់ក្តើ ដែលផុតកែតឲ្យ ព្រោះមានកំណប់កប់ខុកនៅទីនោះ ។ ផុតមិនចាំកន្លែងទេ តែបើកូនពាល់គ្នាទំប្រឹងរកឲ្យមែនទែន គង់មិនលែងប្រទះមិនមាន ហើយកូនទឹងបានសម្រេចប្រយោជន៍ដូចសេចក្តីប្រាថ្នា ដល់ដូវដែលគេធ្វើស្រែ ចូរកូនទំគាប់ ទំគាស់ ទំដីក ទំកកាយថែមទៀត រឹលទៅរឹលមក ។

លុះផុតស្លាប់ហើយ ពួកកូន។ ក៏បបួលគ្នារើចំការរកកំណប់ ពីខាងនេះ ទៅខាងនោះ ពីខាងនោះ មកខាងនេះ សព្វដីទាំងអស់ ឥតបន្ទោះត្រង់ណា តែរកកំណប់មិនឃើញសោះ ហើយត្រឡប់បបួលគ្នាជាស្រូវទៅវិញ ។ ដល់ដំណាច់ឆ្នាំ ស្រូវហ្នឹងបានផលច្រើនជាងធម្មតា ។

គ្មានប្រាក់ឯណាកប់ទុកសោះ តែផុតជាអ្នកឲ្យតកង់ការពន្យល់កំប្រាប់កូនឲ្យដឹងមុនទឹងស្លាប់ថា : ការងារហ្នឹងហើយ ជាកំណប់ទ្រព្យ ។

៤២- ប្រុសម្នាក់ឆឹងពស់វែក

ថ្ងៃមួយ ជាវេលាថ្ងៃ ប្រុសម្នាក់ដើរមើលត្រួតត្រាដំណាំនៅដុំវិញស្រួន ដើរទៅដើរមក ស្រាប់តែប្រទះឃើញពស់មួយនៅសន្ធឹងស្តូកលើចំការ ត្រជាក់ស្ងឹមកំរើកមិនរួច រឹងត្អឹងដូចស្លាប់ នៅប្រហែល ១៥ នាទីទៀត ទៀងតែក្សត់ជាមិនខាន ។ ប្រុសរើសពស់យកទៅផ្ទះគាត់

មិនគិតខឿយហត់ បងបានសុគុណអ្វីឡើយ គេលាតសន្ធឹងពស់លើផ្ទះ យកក្ងែងមកដុតកំដៅឲ្យ ខំធ្វើឲ្យបានរស់ឡើងវិញ ។ សត្វពស់ត្រូវកំដៅក្ងែង ដឹងខ្លួន ស្រាប់តែមានដំរឹតឡើងវិញ ហើយនាំហឹង យកមកជាមួយផង រាងើបក្បាលបើកពពារ ថ្នមពួនត្រែក ។ រកទាំបុរសក្អាម រត្អាយរង្វេលគេនយ៉ាងខ្ពស់ រួចទំប្រឹងលោលោតទៅរកអ្នកមានគុណ អ្នកស្រង់ជីវិតខ្លួនដូចជាឥតុក ។ បុរសខឹង គំមានវាចាថា » អាសត្វតិរច្ឆាន អកតញ្ញូ ! ហ្នឹងហើយឬជាការតបគុណរបស់ឯងមកដល់អញ ? អាឯងមុខជាស្លាប់ទឹងដៃអញឥឡូវមិនខាន ។ គ្រាន់តែថាប៉ុណ្ណឹងហើយ ខឹងខ្លាំងពេក បុរសកញ្ឆក់ចានពួយថា កាប់តែពីរចុំង តើតឡើងបានជាពស់ប៉ៃ គឺមួយកំណាត់ខាងក្បាល មួយកំណាត់ខាងកណ្តាល មួយកំណាត់ខាងកន្ទុយ ស្លាប់វិលវិញទៅ ។

យើងត្រូវតែធ្វើចិត្តល្អ តែត្រូវធ្វើចំពោះអ្នកណា ? នេះហើយជាកន្លែងដែលត្រូវតែ បើទៅលើមនុស្សអកតញ្ញូ កុំបណ្តាយទុកឲ្យស្លាប់ទឹងសេចក្តីពុតត្បុតទៅបុះ ។

៤៣- ដើមសែន(១) ឆឹងបបុស

ថ្ងៃមួយ ដើមសែនមានវាចាទៅកាន់ថបុសថា « អ្នកឯងជារុក្ខជាតិ-

១- សែន: ជាតិឈើមួយពួកសាច់រឹងជាប ដែលគេសម្រាប់យកទៅធ្វើសំណង់ផ្សេងៗ ផ្នែកវាជាចំណីក្រួចនឹងមាន់ (ជាងដុះ) វាមានកំពស់ពី ២០ ទៅ ៣៥ ម៉ែត្រ ។

ដែលគួរតែបន្ទោសព្រះជាម្ចាស់ ដ្បិត បើគ្រាន់តែចាប់ដង្កូវមួយចំពីលើ
ហាក់ដូចជាទម្ងន់មួយហាប គ្រាន់តែរ្យល់បន្តិចសោះ បក់ចឹកស្ទើរមិនកំ-
រើកអ្នកឯងតែងតែតុនតាយខន់ទោរទៅជាធម្មតា ចំណែកខ្ញុំវិញ ដែលមាន
មុខងើយងើបខ្ពស់ខ្ទឹមស្មើនឹងក្តួកាស(១) មិនមាន់សប្បាយទៅឡើយទេ
ថ្វីដ្បិតតែអាចឃាត់ស្មៅព្រះអាទិត្យបាន ខ្ញុំហ៊ានហួតដល់ចំកម្ទាំងព្រះ
សង្ឃកំរែមទៀតផង ។ រ្យល់ទាំងប៉ុន្មានដែលបក់មកត្រូវអ្នកឯង ហាក់
ដូចត្បុះ ចំណែកខ្ញុំ ទោះបីយ៉ាងនេះក៏ដោយ ហាក់ដូចជាដំណោរដែល
បក់មកត្រសៀក។ ទាំងអស់ ។ ដូច្នេះ ប្រសិនបើអ្នកឯងបានមកជុះទៅ
កន្ទំអំណាចយើង ជាអ្នកជិតខាងនៅក្បែរយើង នោះអ្នកឯងមិនសូវព្រួយ
ពេក ព្រោះយើងនឹងជួយការពារអំពីរ្យល់ព្យុះខ្លះ តែឥឡូវធ្វើដូចម្តេច បើ
អ្នកឯងបបួលគ្នាទៅជុះតែដោយមាត់ស្ទឹង មាត់ចឹង ជាកន្ទែងចំមុខរ្យល់
ព្រះបង្កើតអ្នកឯងមក ដូចជាមិនប្រកបដោយគតិធម៌សោះ ។

បបុសឆ្លើយទៅវិញថា «សេចក្តីមេត្តារបស់លោកចំពោះប្អូ ជា
សេចក្តីមេត្តាចេញមកពីពោះដ៏ស្មោះត្រង់ក៏ពិតមែនហើយ ប៉ុន្តែសូមលោក
លះបង់ការព្រួយបារម្ភខ្នះខ្នែងចោលទៅចុះ ព្រោះរ្យល់ដែលបក់មកប៉ះប្អូ
មិនជាស្ងួតសម្រាំមដូចជាបក់ត្រូវលោកឡើយ ខ្ញុំគ្រាន់តែនុន តែមិនចាក់

១- ក្តួកាសដូរភ្លើទៅជាបន្ទោះសម្បកទ្រេម ដ៏ធំសម្បុរក្រាស្តើយើង មានបណ្តោយប្រមាណ
១.២០០ ក.ម.ហើយមានកំពូលខ្ពស់ៗជាច្រើន មានខ្លះដល់ទៅ ៥.៦៣០ ម៉ែត្រ ។

ចំណែកលោក តាំងពីដើមមកដល់ឥឡូវ យើញតែខំប្រឹងចង់ធំកម្ចាំងឡស់ស្មើរស្មាប់ខ្លួន មិនគាំងហ៊ានឧនបន្តិចផង តែណ្ហើយចុះ យើងចាំមើលពេលហ្នឹង" ។

គ្រាន់តែបបុសនិយាយស្មើរមិនទាន់ផុត ក្រឡេកទៅដើងមេយស្រាប់យើញក្រហមក្រាល សុទ្ធតែដើងឡស់ដែលបក់សំដៅមកដួចគេរត់ ។ ដើមសែនឈរធ្វើព្រងើយ បបុសនុនជាបចុះ រៀលាដែលឡស់បក់រខ្ពើនជាទ្វេគុណមកម្ដងទៀត ស្រាប់តែអាដែងមានក្បាលខ្ពស់ស្មើនឹងមេយ មានឫសចាក់ចុះដល់ថ្មតាល ដួលគ្រែង បះដើងព្រាង ។

៤៤-មេគោក្រមុំ ពពែនឹងចៀម ធ្វើសហការជាមួយនឹងសិង្ហ

មេគោ ពពែនឹងចៀម ចានព្រមព្រៀងគ្នាចូលរួមជាមួយនឹងសិង្ហដើម្បីធ្វើការរកស៊ី ចំណេញភាគជាមួយគ្នា ។ ក្លាន់មួយដើរទៅជាប់អន្ទាក់ពពែ ។ ក៏យកទៅរកអ្នកក្រុមហ៊ុនភ្លាម ។ លុះដួចជុំគ្នាហើយសិង្ហនិយាយថា: "យើងត្រូវចែងចំណែកជា ៤" ។ សត្វទាំងនោះនាំគ្នាយកក្លាន់ទៅកាត់ជា ៤ ភាគ ហើយសិង្ហយកភាគទី ១ មុនគេបង្អស់ព្រោះគេជាស្ដេចចតុបាទ រួចមានពាក្យថា: "ហ្នឹងហើយដែលគេហៅថាអញជាស្ដេច អ្នកណាមិនត្រូវអ៊ូថាអ៊ូឡើយ ឯភាគទី ២ បើតាមច្បាប់ត្រូវតែខ្លាក់មកលើអញទៀត សិទ្ធិហ្នឹង ឯងកាល់គ្នាដឹងប្លេ គេហៅថាសិទ្ធិអ្នកខ្លាំងពូកែ ហើយអញជាអ្នកមានវិទ្ធិជាងគេ ត្រូវបានភាគទី ៣ ថែម

ទៀត ចំណែកកាតទី ៤ បើអាណាហ៊ានតែលួកដៃមកពាល់ អញទំាង
ទាំអាខោះស៊ីមុនគេឲ្យហើយ ។

៤៥- សត្វកង្កែងចូលក្នុងក្រង់ស្រូវ

នាងកង្កែនខ្លួនវែងតូចរឿ ចូលក្នុងក្រង់ស្រូវមួយតាមរន្ធយ៉ាងចង្អៀត
ព្រោះកំពើចនឹងធើចតិឈឺ ។ លុះបានទៅក្នុងទីខោះកាលណា ភគិតតែ
ស៊ីតាមអំពើចិត្ត មើដែងខ្លួចនេះ មានសាច់ទ្រលុកចេះតែស៊ី ចេះតែកកេរ
លួចតំងខ្លាញ់ស៊ីអស់ថែមទៀត ។ ដល់ទីបំផុត មើលចុះ! ភជាត់សាច់
ផ្ដាល់ឆ្អាក់ទ្រយុក ខ្លួនឡើងរួញមូល ។ ទៅបានមួយអាទិត្យ ពេល
ដែលស៊ីឆ្អែតស្កប់ស្កល់ហើយ គ្រាន់តែឮស្រូវដួចមនុស្សដើរមក ម៉ាមេ
លួចតាំងស៊ុះតេចេញតាមរន្ធដែលវាចូលមក តែចេញមិនរួច ភនឹកស្មាន
ថាប្រហែលប្រឡាំរន្ធទេដឹង លុះតេវៅតំមកបានពីរ-បីដុំក្រង់ ភដឹង
ច្បាស់ថា «ប្រាកដជារន្ធហ្នឹងហើយ អញចូលអ៊ីម្ល៉ះ អញចូលមកតាម
រន្ធហ្នឹងទើបនឹងបាន ៦-៧ថ្ងៃ សោះ ហេតុអ្វីក៏ចេញវៅវិញមិនរួច» ។

កណ្ដាមួយ ឃើញកង្កែនចេះតែក្រេសក្រសតិចាកដួច្នោះ ក៏ប្រាប់
ទៅថា: «កាលដែលម៉ាងឯងចូលមក តោះមិនស្ដាំពេញ ដួច្នេះ បើ
ពេលដែលម៉ាងឯងចូលស្គម ពេលចេញក៏ត្រូវឲ្យស្គមដូចគ្នា អញនិ-
យាយប្រាប់រឿងនេះចំតោះម៉ាងឯង តែកំថាដួច្នេះ ចំតោះអ្នកដទៃដែរ ។

(ទៅមានត)

រឿងត្រៃដំបិន

លោក ភ័ក្ត្រ - ប៊ុត ប្រែរៀបរៀង

(តទៅ)

កុមារឡៅសានក្រឡេកទៅឃើញមាសគ្រាប់ភ្លឺព្រាងព្រាយ ច្រាក់ពាសពេញក្តីច្រវាត់ គជ្ឈដ្ឋានដ៏ធំត្បូងភ្លឺចាំងចែងតែកុមារបានចាំជណ្តើរព្រះវរៀមហើយក្រាបបង្គំទូលស្តេចកុដន្តិនាគរាជថា:

"សូមទ្រង់ព្រះមេត្តាប្រោស ទូលព្រះបង្គំជាខ្ញុំមានបងស្លាមបិតាម្តាយជីវិតនឹងស្លៀកពាក់ហើយ ទូលព្រះបង្គំជាខ្ញុំគ្មានគ្រួសារទេ ទូលព្រះបង្គំជាខ្ញុំចង់បានមន្ទីរសមួយដើម្បីកំដរឲ្យបានជាគ្នាទៅទីនោះ.. ។

ស្តេចកុដន្តិនាគទ្រង់ស្តាប់អង្គុលពុតចង្កាព្រះអង្គហើយ ទ្រង់មានព្រះពាក្យត្រាស់ទៅកុមារឡៅសានថា:

"ល្អហើយ យើងឲ្យមន្ទីរសនេះទៅនាង ចូរនាងយកទៅចុះ" ។

លុះវិលត្រឡប់មកដល់គេហដ្ឋានវិញ កុមារឡៅសានក៏យកមន្ទីរសនោះទៅដាក់ក្នុងទ្រុងមួយ ហើយទៅស្លុចត្រីឯស្ទឹងតាមធម្មតា រួចយកត្រីនោះទៅលក់ឯផ្សារ ។ តែដល់កុមារត្រឡប់ពីផ្សារមកវិញ ក៏បានឃើញម្ហូបអាហារមានស្រាប់ដាក់លើតុរៀងៗ ។

ដំបូងកុមារគិតថា ប្រហែលជានាងដែលស្ថិតនៅជិតនោះមានចិត្តសប្បុរសយកភោជនាហារនេះមកឲ្យខ្លួនឯង! ហើយក៏ថ្លែងអំណរគុណចំពោះ

នាង ។ នាងចាំងឡាយមានចិត្តធ្ងល់ពន់ពេក ព្រោះថានាងឥតមានធ្វើ
អ្វីបបួចំណីចាំងនោះសោះឡើយ ។ ដល់ថ្ងៃស្អែក កុមារឡៅសានមិនទៅ
នេសាទត្រីទេ លបចាំឃ្លាំមើលជិតផ្ទះដើម្បីចង់ដឹងថានរណាយកម្ហូប
អាហារមកជាក់លើតុៈ ! ។ គេលនោះ កុមារក៏មិនឃើញមានហេតុគេ
អ្វីសោះឡើយ ម្ហូបអាហារក៏មិនឃើញយកមកជាក់លើតុៈ ។ ថ្ងៃស្អែក
ទៀត កុមារធ្វើដំណើរទៅនេសាទត្រីតាមធម្មតា ។ លុះត្រឡប់មកគេហ-
ដ្ឋានវិញ ស្រាប់តែឃើញម្ហូបអាហារឈ្ងុយឆ្ងាញ់ស្ថិតនៅលើតុៈ ។

កុមារឡៅសានទឹកក្តីចិត្តកាន់តែធ្ងល់ពន់ពេកចំពោះរឿងនេះ តើ
នារីណាមានធម៌សប្បុរសមកចំអិនគោជនាហារឲ្យអញដូច្នេះ ត្រូវតែអញ
រកនារីនោះឲ្យឃើញដើម្បីនឹងថ្វាយអំណគុណចំពោះគេនោះ ។

ថ្ងៃក្រោយទៀត កុមារឡៅសានធ្វើជាដើរទៅស្ទូចត្រី ។ លុះទៅ
ដល់ពាក់កណ្តាលផ្លូវ កុមារវិលត្រឡប់មកកាន់គេហដ្ឋានវិញ លបមើល
តាមប្រហោងជញ្ជាំង ក៏ឃើញមាន់ញីសនោះប្រែកាយារួនជានាងកញ្ញា
ម្នាក់ មានរូបឆោមលោមពណ៌ស្រស់ប្រឹមប្រិយមកចំអិនអាហារនោះ ។
នាងកញ្ញានោះ ពាក់អាវវែងមានពណ៌ស ដល់កុមារឃើញនាងនោះហើយ
ក៏ត្រាំមិនបានក៏ស្រែកថា « សូមអគុណនាងច្រើន . . » ។

ដល់នាងឮពាក្យឡៅសាន ក៏ទះដៃរួនឯង ។ ស្រាប់តែនាងយុវតី
នោះក្លាយទៅជាមាន់ញីសនោះវិញរត់ចូលទៅក្នុងព្រៃ ។

ឡៅសានក៏រង់ចាំពេលស្អែកទៀត ។ ដូចពីថ្ងៃមុនៗ ឡៅសានក៏ធ្វើដំណើរទៅស្ទូចត្រីដូចសព្វមួយដង ។ លុះដើរទៅដល់ពាក់កណ្តាលផ្លូវ ឡៅសានក៏វិលត្រឡប់មកគេហដ្ឋានវិញ ហើយចាំលបមើលតាមប្រហោងទ្វារ ។ ក្នុងពេលនោះ ឡៅសានបានក្រឡេកទៅឃើញមាន់ញីប្រកាឡាខ្លួនជានាងកញ្ញាមានរូបឆោមលោមពណ៌ស្រស់ប្រិមប្រិយ ។ នាងកញ្ញាបង្កាត់ភ្លើងចំអិនម្ហូបអាហារ ។ ឡៅសានបើកទ្វារចូលទៅក្នុងគេហដ្ឋាន ។ ក្នុងពេលនោះ នាងកញ្ញាមិនអាចប្រែកាឡាខ្លួនទៅជាមាន់ញីបានភ្លាមដោយគ្មានឧកាស ។ នាងក៏ទៅឈរស្ងប់ស្ងៀមចំកម្ទេចក្រហមដោយខ្មាសអៀនឡៅសានពន់ពេក ។

ឡៅសានពោលទៅកាន់នាងថា: «នាងអើយ! នាងមានចិត្តសប្បុរសខ្ញុំពន់ពេក នាងបានចំអិនម្ហូបអាហារដ៏ឆ្ងាញ់ពិសាឲ្យខ្ញុំបរិភោគរាល់ថ្ងៃ ខ្ញុំសូមសំដែងក្តីពេលនេះ នូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅចំពោះនាង សូមនាងអាណិតមេត្តាតបមកខ្ញុំវិញ តើនាងជាអ្វី ?» ។

ឃុវនារីក៏តបទៅឡៅសានវិញថា: «កិច្ចការដែលខ្ញុំធ្វើនេះ ជារបស់បន្តិចបន្តួច មិនត្រូវលោកមកអរគុណខ្ញុំទេ ។ នាងខ្ញុំជាបុត្រីកុដន្តីនាគរាជ មហាក្សត្រសោយរាជ្យឯនគរបាតាល ។ លោកបានជួយស្រោចស្រង់ជីវិតប្អូនប្រុសខ្ញុំ ។ ជាការធម្មតា ត្រូវខ្ញុំតបស្នងសងគុណលោកជាបុព្វការី របស់នាងខ្ញុំ ។

ខ្លៅសានទឹងនាងកញ្ញាបានរៀបអាពាហ៍ពិពាហ៍គ្នាទឹងគ្នា ហើយស្ថិតនៅគេហដ្ឋានខ្លៅសាននោះ ។ ប្រជាពលរដ្ឋជាំងឡាយចូលមកឱ្យពរសួរសុខទុក្ខដល់បុរសទឹងនាងជាតរំយោ ។

តែមានកាលមួយថ្ងៃ មានភ្នាក់ងារខាងតុលាការម្នាក់បានយើញនូវសម្រស់ដ៏ល្អប្រសើរនៃនាងជាតរំយោខ្លៅសាន កំនាត់តិមានេះទៅជំរាបលោកចៅក្រមជាចៅហ្វាយនាយ ។ លុះបាន ២-៣ ថ្ងៃតមក គ្រួសារខ្លៅសានក៏ទទួលរងគ្រោះជាខ្លាំង ព្រោះលោកចៅក្រមបានចាត់ការហានឱ្យមកចាប់ខ្លៅសាន ហើយពោលទៅកាន់ខ្លៅសានដោយកែកន់ៗថា:

«កូមិនាំងអស់ធំតូចសុទ្ធតែស្ថិតនៅក្រោមបង្គាប់បញ្ជានៃអញ ! គឺអញជាអ្នកសម្រេចរឿងតូចធំទៅទីនេះ ។ អញអនុញ្ញាតឱ្យឯងបីថ្ងៃ ដើម្បីឱ្យឯងនាំតរំយោឯងមកប្រគល់ឱ្យអញ ។ បើគ្រប់កំណត់ហើយ ឯងមិនយកតរំយោឯងមកឱ្យអញទេ អញកាប់ក្បាលឯង» ។

ខ្លៅសានទាំងក្មេញ មានចិត្តខឹងគោមនស្សជាខ្លាំង ក៏តបទៅលោកចៅក្រមថា:

«ទ្រង់គុណជាម្ចាស់អើយ សូមព្រះគុណអាណិតមេត្តាមកខ្ញុំ ! បើលោកបង្គាប់បញ្ជាឱ្យខ្ញុំធ្វើអ្វីក៏ខ្ញុំធ្វើដែរ តែត្រង់យកតរំយោជាថ្មីមប្រមាត់របស់ខ្ញុំទៅជូនលោក ខ្ញុំមិនអាចនឹងធ្វើបានសោះឡើយជាដាច់ខាត ! » ។

លោកចៅក្រមនោះមុខឡើងក្រហមហើយញញឹមពោលថា :

« ឯងឲ្យអញសង្កត់ចំពូកវៀរលែងតែប្រពន្ធឯង ។ ឯងពោលដូច្នេះ! ល្អហើយ! ល្អហើយ! ឯងជាអ្នកនេសាទ អញឲ្យកំណត់ឯង ៣ ថ្ងៃ ឲ្យឯងរកត្រីធ្ពុនធំ ១ មួយរយម្ភៃ ហើយឲ្យមានពណ៌ក្រហមដូចគ្នា។

ឡៅសាន ក្រោយដែលវិលត្រឡប់មកគេហដ្ឋាន មានចិត្តព្រួយជារឿយជាយ៉ាំងក្រៃពេក ហើយបានតាំពតិមាននេះ មកប្រាប់ភរិយា ។ នាងភរិយាដកឫស្សាមីវិញថា :

« កុំបងព្រួយអ្វី បងមុខជាបានត្រីធ្ពុនធំមួយរយម្ភៃមិនខាន ។ ពោលដូច្នេះ នាងក៏យកក្រដាសធំមានពណ៌ក្រហម រួចនាងកាត់ក្រដាសនោះជាត្រីចំនួនមួយរយម្ភៃ នាងយកទៅដាក់ក្នុងអាងទឹកធំ ។ ក្រដាសតាំងមួយរយម្ភៃកំណាត់នោះទៅជាត្រីធ្ពុនធំមានពណ៌ក្រហម មានជីវិតហែលប្រភាត់ចុះឡើងក្នុងទឹកអាងនោះ ។ ឡៅសានសើចញញឹមស្រស់ មានចិត្តត្រេកអរសាទរឥតឧបមា ក៏យកត្រីធ្ពុនធំតាំងមួយរយម្ភៃទៅជូនលោកចៅក្រម ។ ចានឃើញថាកិច្ចការដែលបានបំពេញហួសវិស័យនេះ បានសម្រេចដូចបំណងឡៅសាន លោកមានប្រសាសន៍ថា: « អញបានដឹងថាភរិយាឯងចេះត្បាញយ៉ាំងចំណាន អញឲ្យភរិយាឯងត្បាញសំពត់ មានពណ៌ខៀវផ្ទៃមេឃ រៃនប្រហែលទំហំផ្ទាំងនេះ អញកំណត់ឲ្យឯងបីថ្ងៃ ឲ្យប្រពន្ធឯងត្បាញឲ្យហើយស្រេច យកមកឲ្យអញ! » ។

ឡៅសានដំកបទៅវិញថា:

«ទ្រព្រះតេជព្រះគុណ! ព្រះតេជព្រះគុណបានឲ្យខ្ញុំបាទកេន្ទីសារៈវត្ថុយកមកជូនព្រះតេជព្រះគុណ ខ្ញុំបាទបានយកមកជូនហើយ ឥឡូវព្រះតេជព្រះគុណឲ្យខ្ញុំបាទកេន្ទីសារៈវត្ថុ ២ ទៀត» ។

លោកចៅក្រមតបទៅវិញថា: «មិនមែនទេប្អូ! ដែលឯងថាឲ្យអញជង្គាប់ឯងឲ្យកេរបស់អ្វីបានតាមចិត្តអញ!»

ឡៅសាន ក្រោយដែលបានត្រិះរិះថា ពោលពាក្យតបទឹងលោកចៅក្រមនេះមានប្រយោជន៍អ្វី ក៏ត្រឡប់ទៅកាន់គេហដ្ឋានខ្លួនវិញ ។ ឡៅសានមានចិត្តខឹងមនុស្សឥតទុបមាច់ពោះលោកចៅក្រម ។ ភរិយានៃឡៅសានថ្នមចិត្តប្តីហើយសួរថា:

«តើបងមានរឿងអ្វី?» ។ ឡៅសានតបទៅភរិយាវិញថា: «លោកចៅក្រមឲ្យនាងអូនត្បាញសំពត់មានពណ៌ខៀវផ្ទៃមេឃ ឲ្យវែងស្មើទឹងថ្នល់ធំនេះ! តើអ្នកណានឹងធ្វើកើត! បានជាបងព្រួយបារម្ភជាខ្លាំង!» ។ នាងភរិយាតបទៅស្វាមីថា: «កុំឲ្យបងព្រួយអ្វីចំពោះរឿងនេះ» ។ ពោលដូច្នេះ នាងភរិយាកំកាឡាខ្លួនជារុក្ខជាតិ «ស៊ីប្រ៊ាំង» (Cyprin) មានពណ៌ស លោតទៅក្នុងស្ទឹងហើយធ្វើដំណើរទៅកាន់ខេត្តបាតាល ។ នាងវិលត្រឡប់មកវិញកាន់ថូទិព្វមួយមក ។ ក្នុងថូទិព្វនេះ មានវត្ថុគ្រប់យ៉ាងអ្នកណាចង់បានវត្ថុអ្វី គ្រាន់តែពោលក្នុងវត្ថុនោះចេញមកឯង ។

ឡៅសានកាន់ថូទិព្វ តាចារណាអស់កាលដំយូរ ហើយមានចិត្តសោមនស្សពន់ពេកណាស់ ។ ដល់ថ្ងៃទីបី ឡៅសានសុំតីថូទិព្វខ្លួវសំពត់មានពណ៌ខៀវឆ្អែមេឃវែងដូចផ្លូវធំ ហើយយកសំពត់នោះទៅជូនលោកចៅក្រម ។ មន្ត្រីនេះបានសួរឡៅសានដោយពាក្យគំហកថា: «តើសំពត់នេះប្រវែងប៉ុន្មាន?» ។ ឡៅសានដំណាបថា: «វែងស្មើនឹងបណ្តោយថ្នល់ធំនេះ» ។

លោកចៅក្រមគោលថា: «មិនមែនទេ! ម្តេចក៏ឯងដឹងថាសំពត់នេះមានបណ្តោយស្មើនឹងថ្នល់ធំ» ។

ឡៅសានក៏ដំណាបទៅមន្ត្រីថា: «បើលោកមិនជឿខ្ញុំ សូមឲ្យលោកចាត់ឲ្យពស់មើល!» ។

មន្ត្រីក៏បង្គាប់ឲ្យគេយកម៉ែត្រមកវាស់មើល ដល់វាស់ទៅ មួយថ្ងៃមួយយប់វាស់មិនទាន់អស់ ។ មន្ត្រីក៏ឲ្យឈប់វាស់សំពត់នោះទៅ ។

មន្ត្រីនោះតបទៅឡៅសានវិញថា: «ចានហើយ! តែស្អែកឯងយកហ្វូងចៀមមានសម្បុរក្រហមមកឲ្យអញ!» ។

ស្អែក ឡៅសានក៏យកចៀមមួយហ្វូងមានសម្បុរក្រហមមកជូនមន្ត្រីលោកចៅក្រមបង្គាប់ឲ្យឡៅសានយកក្រមួមួយហ្វូងមកវិត ។ ឡៅសានក៏យកមកជូនលោកមន្ត្រី ។ លោកចៅក្រមយល់ឃើញថា: បើលោកចង់ជាន់អ្វី ឡៅសានក៏យកតែនោះមកជូនលោកជានិច្ចចិត្តប្រាថ្នា

គំសួរឡៅសានថា:

« អញឲ្យល់ណាស់! ហេតុម្តេចក៏ឯងក្រមេ្ល៎ះ ឯងយកវត្តដែលអញឲ្យ ឯងរកមកឲ្យអញបានខាំងអស់? ប្រហែលជាឯងមានវត្តចិញ្ចឹមមួយ ចូរឯងយកវត្តចិញ្ចឹមនោះមកឲ្យអញ » ។

ឡៅសានខឹកក្នុងចិត្ត មនុស្សនេះមានចិត្តលោភលន់ពន់ប្រមាណ! អញឲ្យនេះ ក៏ការនោះទៀត ចង់បានហើយចង់បានទៀតមិនចេះឆ្អែត! បើអញឲ្យចិញ្ចឹមវាទៅ តើវាសុំវត្តអ្វីពីអញទៀត អញនឹងរកពីណាបាន? ។

ឡៅសានតបទៅវិញថា: « ព្រះគេជព្រះគុណបានសុំខ្ញុំបាទនូវវត្តជាច្រើនយប-យ៉ាង ខ្ញុំបាទបានជូនទូវវត្តជាច្រើនតាមចំណង់លោកសព្វយ៉ាង ម្តេចក៏លោកមកសុំវត្តចិញ្ចឹមពីខ្ញុំទៀត! តើឲ្យខ្ញុំទៅរកវត្តចិញ្ចឹមនោះឯណាបានមកជូនលោកទៀត! » ។

លោកមន្ត្រីយកដៃគោះតុយ៉ាងខ្លាំង ហើយស្រែកដោយចិត្តខឹងជាខ្លាំងថា:

« ម្តេច! អញបង្គាប់ឲ្យឯងយកវត្តចិញ្ចឹមមកឲ្យអញ ឯងត្រូវតែយកមកជាជាងខាត! ឯងមិនត្រូវប្រកែក ឯងធ្វើយតែមួយម៉ាត់ទៀត អញយកឯងទៅដាក់គុកគ្មានឥតត្រាប្រណី » ។

ឡៅសានចេញពីគេហដ្ឋានលោកមន្ត្រីនោះទៅ ក៏បញ្ចេញវាចាដ៏ឃោរឃៅថា:

« អាចំសាច! អាចំសាច! » ។

ពួកមាសានៃលោកមន្ត្រីតូចដ៏នេះ កំប្រញាប់ប្រញាលរត់ទៅដាក់ថៅហ្វាយនាយវា ។ លោកមន្ត្រីមានចិត្តខឹងជាខ្លាំង ហើយកំបង្គាប់ឲ្យចាប់ឡៅសានមកដាក់គុកឯងតែមួយយប់ ។ លុះភ្លឺឡើង លោកមន្ត្រីឲ្យដោះលែងមក ហើយស្រែកដោយសំឡេងខ្លាំង។ ថា:

« ឯងហ៊ានហៅអញថា « អាចំសាច » ! ឯងដែលស្គាល់ចំសាចឬ ដូច្នេះ ឯងត្រូវនាំចំសាចចំនួនមួយរយមកឲ្យអញឲ្យឆាប់ ។ អញកំណត់ឲ្យឯងបីថ្ងៃ បើដល់កំណត់ហើយ ឯងមិនបាននាំចំសាចឲ្យគ្រប់ចំនួនទេ អញឲ្យគេកាត់ក្បាលអាឯង! » ។

ឡៅសានត្រូវខ្លួចបង្គាប់បញ្ជាតាលោកថៅក្រមថា ឱ្យរកចំសាចមួយរយមកជូនលោកថៅក្រម ។ ដល់ឡៅសានត្រឡប់ទៅដល់គេហដ្ឋានខ្លួនវិញ ក្រាប់ទៅភរិយាខ្លួនឲ្យដឹងតាមានេះ ។ ភរិយាឡៅសានស្រែកថា: « តើលោកចង់យកចំសាចនេះទៅធ្វើអ្វី? អើបើលោកចង់បានចំសាច យើងត្រូវតែរកជូនលោក តែត្រង់ថ្ងៃនេះយើងមិនជូនលោកទេ » ។

នាងភរិយាក្រាប់ទៅបួងសួងឲ្យបញ្ចេញខ្លួនត្រួតត្រួកចំនួន ១២០ ឱ្យឆ្លងឈើខម្ពស់ ១.២០០ លីត្រ នាងយកឆ្លងឈើខម្ពស់ ១០ លីត្រ ដាក់ក្នុងត្រួតមួយ ។ ហើយបិទក្រដាសមានពាក្យគ្រប់បែប - យ៉ាងនាខាងក្រៅត្រួត

ទាំងឡាយ ហើយយកប្រេងទៅស្រោចពីលើទ្រុងនោះ ។ ក្នុងមួយរំពេច ស្រាប់តែទ្រុងអង្គើចុះឡើង គ្រវីទាំង ទ្រុងនោះក៏ប្រែជាឮជាបិសាចមួយរយក្បែ មានរូបពងគាបថ្លែកហើយស្រែកថា: «បិសាច! បិសាច! » ។

ឡៅសានក៏នាំបិសាចទាំងមួយរយក្បែទៅគេហដ្ឋានលោកចៅក្រម។ មានមនុស្សជាច្រើនបានតែមកឈួតរ ដើម្បីទិដ្ឋមើលនូវបិសាចទាំងឡាយនោះ ។ លោកចៅក្រមក៏ចាត់ឲ្យភ្នាក់ងារតម្រួតដេញមនុស្សចេញ ហើយឲ្យយកបិសាចទាំងមួយរយក្បែទៅឃុំទាំងទុកនៅក្រោលមួយ ។

លោកចៅក្រមសួរទៅឡៅសានថា: «នេះគេហៅបិសាច តើបិសាចនេះវាបរិភោគម្ហូ? » ។

ឡៅសានដំកបលោកចៅក្រមថា: « បិសាចនេះវាបរិភោគប្រេងតែមួយដងក៏លែងឃ្លានទៀតហើយ វាមិនចេះស្លាប់ទេ ។ លោកគ្រាន់តែចាត់ឲ្យមនុស្សថែទាំរក្សាឲ្យបានស្រួលបួលចុះ » ។

លោកចៅក្រមលែងសួរឡៅសានតទៅទៀត ។ ឡៅសានវិលត្រឡប់ទៅកាន់លំនៅវិញ ។

ក្នុងចិត្ត មន្ត្រីមានសេចក្តីសោមនស្សត្រេកអរហើយក៏គិតថា: « បិសាចនេះប្លែកពន់ពេក តែជាវត្ថុដ៏មានតម្លៃពន់ពេក ។ ពេលសាយណ្ហសម័យ លោកមន្ត្រីបានឲ្យទិញប្រេងជាច្រើន ហើយបំផឹកបិសាចនោះរួចលោកបង្គាប់ឲ្យពាសាលោកមើលថែទាំរក្សាឲ្យបានល្អ ។

ប៊ីសាចតាំងឡាយ ឃ្វានជាខ្លាំងបានធឹកអស់ប្រេងមួយពាន់ព័រយ
លីត្រតែម្តង ។ ដល់ភ្លាស៊ីច្រើនទៅ ពេលយប់អធ្រាត្រ ភ្លៃស្រែកយ៉ាង
ខ្លាំង ។ លោកមន្ត្រីភ្ញាក់ដោយឮសូរសម្រែកប៊ីសាចតាំងនោះ ក៏កាន់
ចន្លៀងចុះទៅមើល ។ តែប៊ីសាចតាំងឡាយនោះ ដល់ឃើញភ្លើងចន្លៀង
នាំគ្នារត់មកដល់ជិត ភ្លើងចន្លៀងតាបន្តេះខ្លួនប្រាណ ។ ប៊ីសាចត្រូវ
ភ្លើងនេះ ក៏រត់ឆ្ងាទៅស្តាំទៅឆ្វេង . . . ក្នុងមួយរំពេច គេហដ្ឋានលោក
មន្ត្រីក៏នេះអស់គ្មានសល់ ហើយក្នុងពេលនោះ លោកមន្ត្រី ភ្ញាក់ងារ,
ទាសាទាស៊ីក៏ខ្លួលមរណភាពក្នុងអគ្គិភ័យនោះអស់គ្មានសល់ ។

ចប់រឿងឡៅសានទីនលោកទៅក្រមតែប៉ុណ្ណេះ ។ នៅមាន
រឿង « មេងគីយាង - ន៊ីយូ » តទៅទៀត ។

(នៅមានត)

ជ័យជំនះដោយយុត្តិធម៌របស់ខ្មែរនៅតុលាការអន្តរជាតិ

អំពីរឿងព្រះវិហារ

(តទៅ)

លោក ហ្វាន អាឈីសុន ជាអតីតរដ្ឋលេខាធិការអាមេរិកាំងដ៏ចំណាន មួយរូប ក្នុងរដ្ឋាភិបាលលោក អៃស៊ិនហាវ័ ។

ជាពិសេសទៅទៀត ភាពដ៏ចំណានរបស់អ្នកតំណាងខាងប្រទេសយើង បានបន្ថែមទៅលើផ្លូវត្រឹមត្រង់របស់ពាក្យបណ្តឹងរបស់យើង ដើម្បីស្វាក់ផ្លូវរឿងរ៉ាវរបស់ប្រទេសថៃយ៉ាងជាប់ជាទីបំផុត ដែលជាហេតុញ៉ាំងឲ្យទៅក្រមសំរេចសេចក្តីទៅតាមយុត្តិធម៌ជាចំបាច់ ។

ជំហរប្រទេសយើង នៅចំពោះមុខតុលាការអន្តរជាតិរឹងជាទីបំផុត ។ ជំហរនេះ បានការពារយ៉ាងអង់អាចនឹងយ៉ាងម៉ឺងម៉ាត់ ដោយក្នុងការពារនៃពេលរដ្ឋាភិបាលរបស់យើង ទទឹងដោយមេធាវីដ៏ចំណាន ។ របស់យើង ដែលបានកំចាត់ការពិបាកចាំងប៉ុន្មានអស់លើង ហើយដឹកនាំមកជូនប្រទេសយើងនូវជ័យជំនះដាច់បរម ។

២) ទៅក្រមតុលាការអន្តរជាតិ បានយល់ស្របតាមសេចក្តីដោះសារបស់យើង ហើយបានទាត់ចោលការតវ៉ារបស់ប្រទេសថៃ ។

ទន្ទឹកណ៍ (Arguments) ដែលសហជីវិន ព្រឿង-កាង លោកជុំងតូ លោកវ៉ីណូ ទទឹង លោក ហ្វាន-អាឈីសុន បានការពារក្នុងនាមនៃពេល-

រដ្ឋាភិបាលប្រទេសកម្ពុជា សុទ្ធសឹងតែជារយោបល់ស្របទៅតាមលក្ខណៈវិចារណញ្ញាណ ស្របទៅតាមគោលច្បាប់ខ្លួនឯងគោលច្បាប់អន្តរជាតិ។

ទង្វើករណ៍ទាំងឡាយនោះដែលឈរលើមូលដ្ឋានច្បាប់ ទទឹងតឹងផ្អែកលើតឹកតាងយ៉ាងជាក់ស្តែង បានគ្របសង្កត់លើសេចក្តីឆ្លើយដោះសារបស់អ្នកតំណាងប្រទេសថៃយ៉ាងធ្ងន់ជាទីបំផុត ដែលជាហេតុញុំាងឲ្យមេធាវីថៃរើមិនរួចគាល់តែសោះ ។

ជ័យជំនះជាបឋម ដែលលេចឡើងខ្ពរលើវេទិកាតុលាការអន្តរជាតិនេះ គឺប្រទេសយើងបានមកដោយសារព្រះរាជកិច្ចដឹកនាំយ៉ាងអង់អាចនៃសម្តេចសហជីវិនដ៏ជាទីគោរពនៃយើង ។ សម្តេចទ្រង់យកព្រះទ័យទុកដាក់ជាទីបំផុត ហើយទ្រង់តាមណែនាំនិងពិនិត្យផ្ទាល់នូវបណ្តឹងរបស់យើងទៅតុលាការអន្តរជាតិ ចាប់តាំងអំពីនីតិវិធីដើមរហូតមកដល់ពេលបច្ចុប្បន្ន ។ ដោយសារព្រះរាជូបត្ថម្ភផ្ទាល់នៃសម្តេចជាម្ចាស់ ខ្ញុំដោយសារការជំនាញយ៉ាងចំណានខ្ពស់នៃអ្នកតំណាងរបស់ប្រទេសយើង ចៅក្រមតុលាការអន្តរជាតិមិនអាចដាក់ទៅតាមការតវ៉ារបស់ថៃ ក្រៅអំពីជូនយុត្តិធម៌ដល់ប្រទេសយើងវេ ។

ក្រោយដែលទ្រង់បានជ្រាបថា តុលាការអន្តរជាតិ កំណត់ក្រមជាលើកទី ១ បានធ្លាល់ជ័យជំនះដល់ប្រទេសយើងហើយ សម្តេចសហជីវិនទ្រង់បានផ្ញើព្រះរាជសារមួយភ្លាម ថ្វាយសេចក្តីសរសើរដល់សហជីវិន



ខ្ញុំឯកឧត្តមប្រាសាទព្រះវិហារ នៅឯការសព្រះរាជបិតាធម្មយោគមហា
នៃសម្តេចព្រះប្រមុខរដ្ឋ នៅថ្ងៃទី ៥ កុម្ភៈ ១៩៦៣

ព្រឿង-កាន ទីឯកមេជាវិទាំង ៣ នាក់ ។

សម្តេចព្រះប្រមុខរដ្ឋ ទ្រង់មានព្រះបន្ទូលថា:

ខ្ញុំបានទទួលដំណឹងយ៉ាងពីរកាយជាទីបំផុត អំពីសាលក្រមជាលើកទីមួយ ដែលសាលាដំបូងអេបានសម្រេចផ្តល់ដ៏យុត្តិធម៌ដល់យើង ។ ខ្ញុំសូមជូនចំពោះលោក នូវអំណរគុណដ៏ស្មោះចំពោះជាវិភាគទានមួយដ៏ធំដែលលោកបានធ្វើដើម្បីសម្រេចជ័យជំនះនេះ ទីឯចំពោះការខំប្រឹងឥតខ្សោយហត់ ចំពោះសមត្ថភាពទីឯជនាញការដ៏ម៉ឺងម៉ាត់របស់លោក" ។

សម្តេចទ្រង់ឋន្តរទៅទៀតថា:

"ខ្ញុំសុំឲ្យលោកថ្លែងការកោតសរសើរនាមរបស់ខ្ញុំ ទីឯកោតនាមនៃពលរដ្ឋកម្ពុជា នូវអំណរគុណដ៏លើសលុប ទីឯសេចក្តីសរសើរយ៉ាងកក្តៅដល់មេជាវីដែលបានពិនិត្យសំណុំរឿងរបស់យើង ទីឯជាដែកតក់យ៉ាងពិស្តារ ។ យើងកំពុងរង់ចាំដោយសេចក្តីពុកចិត្តរឹតតែធំឡើង នូវជ័យជំនះទាំងស្រុងនៃការតស៊ូប្រកបដោយយុត្តិធម៌របស់យើង" ។

បន្ទាប់ទៅនេះ យើងសូមជូនជាតិមានន្ទូវគោលចំណុចធំ ។ នៃសេចក្តីថ្លែងការណ៍របស់គ្នាត់ជារៀងពលរដ្ឋកម្ពុជាខ្មែរយើង សេចក្តីសន្និដ្ឋានរបស់មេជាវីដ៏ចំណាន ត្រមង់ការធ្វើយដោះសាយ៉ាងអង់អាចនៃអ្នកតំណាងប្រទេសកម្ពុជាយើងចំពោះការចោទតស៊ូរបស់ប្រទេសថៃ ។

អំពីជ័យជំនះជាលើកទីមួយ ដែលខ្មែរយើងបានទទួលទៅតុលាការ

អន្តរជាតិឡាអេ ស្តីអំពីបញ្ហាព្រះវិហារ ហើយប្រទេសយើងបានទទួលជ័យ
ជំនះនេះ ដោយសារការប៉ុនប្រសប់របស់តំណាងដ៏ចំណានរបស់កងជំរុំតុ-
ចុល ក្រោមព្រះពរជូបត្តម្ភដ៏អង់អាច ដ៏ស្និតស្នាញនៃសម្តេចសហជីវិនជា
ទីស្នេហានៃយើង ។

សេចក្តីថ្លែងការណ៍ទីមួយលើកែញែកតក់ដែលអ្នកតំណាងរបស់
យើងបានបញ្ជូនឡើងយ៉ាងស្ទាត់ជាប់ តទល់នឹងអ្នកតំណាងនៃប្រទេស
ថៃ នៅចំពោះមុខចាងហ្វាង ទីមួយក្រមនៃតុលាការអន្តរជាតិ ។ ដើម្បី
ទីឆ្លើងឱ្យបងប្អូនអ្នកអានស្រួលងាយ ទីស្តាប់ ហើយឆាប់យល់ផង
យើងសូមធ្វើអត្ថាធិប្បាយយ៉ាងសង្ខេប ដោយបំព្រួញយកតែគោលគំនិត
ធំ ។ ទូវសេចក្តីថ្លែងការ ព្រមទាំងសេចក្តីដកតក់ ទីមួយតទល់នៃ
អ្នកតំណាងរបស់ប្រទេសយើង ដែលទីបំផុតធ្វើឱ្យកម្ពុជរដ្ឋបានទទួលជា
លើកទីមួយ នូវជ័យជំនះដ៏ប្រសើរ ។

នៅក្នុងសេចក្តីថ្លែងការណ៍ ទីមួយសេចក្តីដកតក់របស់អ្នកតំណាង
នៃប្រទេសយើង ។ សូមចែកជាផ្នែកដូចតទៅ៖

១) សេចក្តីថ្លែងការណ៍ (les déclarations) នៃសហជីវិនត្រឿង-
កាង ជាភ្នាក់ងាររបស់កងជំរុំតុចុលខ្មែរយើង ។

២) សេចក្តីឆ្លើយដាស់ (les objections) របស់មេធាវីខាងខ្មែរយើង
ចំពោះការដោះសារបស់ថៃដែលតក់ថា តុលាការអន្តរជាតិគ្មានសមត្ថកិច្ច

ទីឯជំនុំដំរេវឿងព្រះវិហារ ដោយលើកយកសេចក្តីប្រកាសរបស់ខ្លួនចុះ
ថ្ងៃ២០ ខែសីហា ១៨៥០ មកបកស្រាយ ។ ក្នុងការតវ៉ាដំនាស់នេះ មេធាវី
តំណាង៣គឺ: លោក ឌាន-ការីសុន ដែលបានជាដែកជាការាអង់គ្លេស
លោកសាស្ត្រាចារ្យ ប៉ាំង់តូ ទីឯលោក រ៉ូវែរ បានវែកញែកយ៉ាងទូលំ
ទូលាយណាស់ ខាងផ្លូវគោលច្បាប់ ក៏ដូចជាខាងផ្លូវទំនៀតក្រម (Juris prudence) ដែលជាមូលដ្ឋានយ៉ាងមាំនៃទម្លាក់ករណ៍របស់យើង ។

៣) ការសង្កេត (les observations) ដែលលោកមេធាវីប៉ាំង់តូបាន
ថ្លែងយ៉ាងច្បាស់លាស់អំពីកាតព្វកិច្ចនៃប្រទេសថៃ ចំពោះសន្ធិសញ្ញាឆ្នាំ
១៨៣៧ ទីឯអំពីផ្នែកខ្លះនៃយោបលថៃដែលបានតវ៉ាថា គុណការនេះ
គ្មានសមត្ថកិច្ច ។

៤) ហើយក្រោយបង្អស់ គឺសេចក្តីសន្និដ្ឋានរបស់មេធាវីខាងខ្មែរយើង។
នៅក្នុងសេចក្តីដែកតវ៉ាំង់មួល យើងគួរកត់សំគាល់ថា លោក
សាស្ត្រាចារ្យ ប៉ាំង់តូ បានឆ្លើះកកាយបកស្រាយ វែកញែកយ៉ាងល្អិតល្អន់
ជាទីបំផុត ទូវត៌កតាងទីឯទម្លាក់ករណ៍ ដែលលោកបានសំអាងខ្លឹងនៅ
ចំពោះមុខតុលាការអន្តរជាតិ ក្នុងនាមនៃរាជរដ្ឋាភិបាលខ្មែរយើង ។

យើងនឹងតំណូនអត្ថាធិប្បាយនេះយ៉ាងសង្ខេបតាមលំដាប់ដូចតទៅ:

ក) សេចក្តីថ្លែងការណ៍របស់សហដីនៃគ្រឿង-ការ

នៅពេលព្រឹកថ្ងៃ ១១ មេសា ១៨៦១ សហដីនៃគ្រឿង-ការ ភ្នាក់

ជារៀងរាល់ឆ្នាំតែបាលខ្លះ បានថ្លែងជាអាទិ៍នៅចំពោះមុខតុលាការអន្តរជាតិថា: « ខ្ញុំមានកិត្តិយសនឹងតំណាងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជានៅចំពោះមុខសាលាដ៏ខ្ពង់ខ្ពស់ » ។

ក្រោយដែលបានថ្លែងគោរពជម្រាបចៅក្រម ទីឆកយឈ្មោះទីប្រឹក្សារបស់ខ្លួនរួចហើយ សហជីវិនទ្រឿង-កាង បានមានប្រសាសន៍ថា:

« សាលាដ៏ខ្ពង់ខ្ពស់ខ្ញុំសូមក្រាបទូលថ្វាយបង្គំសង្ខេបនូវកំណើត ទីឆហេតុការណ៍វិវាទដែលតុលាការបានទទួលការប្តឹងតវ៉ានេះ » ។

« ដោយមានការតវ៉ាស្ទាក់ញាប់ មានការតាមការនៃប្រទេសកម្ពុជាតាមរយៈខ្លួនយើងណា កាលណាចក្រភៀតាំងអំពីឆ្នាំ ១៨៤៩ នៅតែបន្តបន្ទាន់តាប់ឃាងរំលោភលើទឹកដីមួយផ្នែកនៃប្រទេសកម្ពុជា ឯតែនៅក្នុងខេត្តតំពង់ធំ ដែលនៅជិតោះមានប្រាសាទថ្កល់បែកនៃពុទ្ធភាព គឺប្រាសាទព្រះវិហារ ដែលជាទីតម្កល់ទីតាំងសក្ការបូជា សម្រាប់បណ្តាជនខ្មែរសព្វថ្ងៃរៀងមក » ។

ម្យ៉ាងទៀត នៅឆ្នាំ ១៨៥៤ ប្រទេសថៃបានយកកំលាំងទៅលើធម្មនុញ្ញនៃសហប្រជាជាតិ បានបញ្ជូលកងកម្លាំងតាហានមកនៅលើផ្នែកទឹកដីនេះ ដែលនៅក្រោមអធិបតេយ្យនៃប្រទេសកម្ពុជា ។ ម៉ាងទៀតដោយកម្លាំងទៅទីតាំងការពារលោកយ៉ាងធំ ដែលបានធ្វើឡើងលើបូរណភាពនៃទឹកដីរបស់ខ្លួន ។ ប៉ុន្តែ ការប្រើមធ្យោបាយតាមផ្លូវទូតដើម្បីតវ៉ាទៅប្រទេស

ថៃ តុំបានផ្តល់ឲ្យយើងនូវលទ្ធផលអ្វីទាល់តែសោះ ។

«ហេតុនេះ ដើម្បីទទឹងធ្វើឲ្យប្រទេសថៃគោរពសិទ្ធិរបស់កម្ពុជា ទទឹងឲ្យប្រទេសថៃបំពេញកាតព្វកិច្ចជាអន្តរជាតិរបស់ខ្លួន ប្រទេសកម្ពុជា បានសម្រេចប្តឹងមកសាលាដំទុំដំរះនេះ» ។

«ប្រទេសថៃបានដាក់ការដែកតតក៏ជាបឋមជាពីរសណ្ឋាន (deux exceptions préliminaires) ដែលមេធាវីរបស់គេទទឹងឡើងមកធ្វើអត្ថាធិប្បាយវែកញែកនៅចំពោះមុខតុលាការ ។ យើងសុំឲ្យសាលាដំទុំបាត់ចោលការដែកតក៏នេះទៅ ។ យើងសុំឲ្យសាលាដំទុំថ្លែងទទឹងសម្រេចថា តុលាការមានសមត្ថកិច្ចទទឹងវិនិច្ឆ័យអំពីវិវាទ ដែលបានប្តឹងមកដល់ខ្លួន តាំងថ្ងៃ ៦ តុលា ១៩៥៤ តាមបណ្តឹងចូលមកសាលាដំទុំរបស់ប្រទេសកម្ពុជា» ។

«លោក ឌាន-អាឈឺសុន ទទឹងថ្លែងដូនសាលាដំទុំនូវគោលការណ៍ខ្លះទៅដែលយើងយល់ថា សម្រាប់ជៅបង្កាប់អំពីវិធានការនៃសមត្ថកិច្ចរបស់តុលាការអន្តរជាតិ ។ លោកសាស្ត្រាចារ្យ ប៉ូហ្ស៊ែរ-ចុំងតូ ទទឹងប៉ូល.រ៉ូឌែរ ទទឹងធ្វើយជំទាស់ដោះសាយោបល់របស់ថៃយ៉ាងខ្លាំងខ្លាយ ។

នៅទីបញ្ចប់ សហជីវិនទ្រឿង-កាង បានថ្លែងបញ្ជាក់អំពីនយោបាយសន្តិវិធីរបស់ខ្មែរ ដែលសុំដាក់រឿងព្រះវិហារនេះមកដូនតុលាការអន្តរជាតិវិនិច្ឆ័យ ដោយអនុវត្តទៅតាមមាត្រា ៣៦ ឃ្លាទី ៦ នៃធម្មនុញ្ញ

សហប្រជាជាតិ ។ ក្រោយដែលបានដាក់បញ្ចាក់អំពីសារៈសំខាន់ដ៏ធំបំផុត
នៃរឿងនេះ ដែលខាងឯជល់ប្រយោជន៍ត្រឹមត្រូវរបស់ប្រទេសកម្ពុជាផង
ទឹងជល់លទ្ធផលជាក់ស្តែងនៃការបង្កើតអង្គការនេះផង សហជីវនៃគ្រឿង-
ការ បានសុំអនុញ្ញាតអំពីសាលាដំទុំដំរះឲ្យលោក ឌាន.អាឈឺសុន ឡើង
ថ្លែងយោបល់ ។

ខ) សេចក្តីឆ្លើយដំណាស់របស់មេធាវីខាងខ្មែរយើង
ចំពោះការដកតវ៉ារបស់ប្រទេសថៃ

១) មុនទឹងជូនសេចក្តីឆ្លើយដំណាស់នេះ យើងសូមបញ្ជាក់អំពី
សេចក្តីតវ៉ារបស់ថៃសិន ។

តើប្រទេសថៃអះអាងលើអ្វី ដើម្បីតវ៉ាថា តុលាការអន្តរជាតិគ្មាន
សមត្ថកិច្ចទឹងដំរះរឿងក្រុះក្រហាះនេះ ។

យើងអាចបំព្រួញខ្លឹមសារណ៍របស់ថៃដោយសង្ខេបដូចតទៅ៖

ទីមួយ ប្រទេសថៃបានលើកយកសេចក្តីថ្លែងការណ៍របស់ខ្លួនចុះថ្ងៃ
២០ ឧសភា ១៩៥០ មកបកស្រាយ ។

នៅឆ្នាំ ១៩៦៩ ប្រទេសថៃបានទទួលស្គាល់សមត្ថកិច្ចនៃតុលាការ
អន្តរជាតិ ។

សេចក្តីថ្លែងការណ៍នៃឆ្នាំនេះ បានបន្តការទទួលស្គាល់នេះចំនួន ១០
ឆ្នាំទៀតមុខទៀត (ចាប់ពីថ្ងៃ ៧ ឧសភា ១៩៣០) ។ មកដល់ថ្ងៃ ៤

ឧសភា ១៩៤០ សេចក្តីថ្លែងការណ៍មួយទៀត ជានបន្តការខួលស្គាល់សមត្ថកិច្ចនៃតុលាការអន្តរជាតិចំនួន ១០ ឆ្នាំទៅមុខទៀត ។ បើសិនណាជាគេគិតតាមថ្ងៃ ខែ ឆ្នាំ ចាប់ពីថ្ងៃ ៤ ឧសភា ១៩៤០ កំណត់ពេល ១០ ឆ្នាំ នឹងត្រូវទៅបញ្ចប់ចំថ្ងៃទី ៤ ឧសភា ១៩៥០ ។ ដល់មកថ្ងៃ ២០ ឧសភា ១៩៥០ ប្រទេសថៃចាប់ផ្តើមសេចក្តីថ្លែងការណ៍ខួលស្គាល់សមត្ថកិច្ចនៃតុលាការអន្តរជាតិ កន្លងយ៉ះវេលា ១០ ឆ្នាំតមកទៀត ដោយម្តងនេះប្រើពាក្យអង់គ្លេសថា (Renew) (រ៉ឺញូវ) ដែលខ្ញុំរយើងអាចប្រែថា (ប្រកាសជាថ្មី តាំងជាថ្មី បន្តជាថ្មី ធ្វើឲ្យកើតជារមានឡើងវិញ ។ល។ ហើយតាមភាសាបារាំងថា: (Renouveler) ។

ប្រទេសថៃ ដើរជាន់តែតែងដើរបៃស់ខ្លួនឯង ព្រោះមុនពេលដែលខ្ញុំមិនទាន់ដាក់ពាក្យប្តឹងទៅតុលាការអន្តរជាតិអំពីព្រះវិហារ (គឺមុនឆ្នាំ ១៩៦០) ថៃខួលស្គាល់សមត្ថកិច្ចនៃតុលាការអន្តរជាតិ ដោយអាងលើសេចក្តីប្រកាសរបស់គេចុះថ្ងៃ ២០ ឧសភា ១៩៥០ ។ ដល់មកឥឡូវនេះតុលាការដែលតុលាការបានខួលបណ្តឹងរបស់យើង ប្រទេសថៃបានទៅធ្វើយ ច្រាប់តុលាការថា សេចក្តីប្រកាសនេះមិនបានការទៅវិញ ដោយត្រូវដាក់ទៅជាមោឃៈ អសារឥតការ ព្រោះគេថា សេចក្តីប្រកាស ១៩២៩ បន្ទាប់មក គឺសេចក្តីប្រកាសថ្ងៃ ៤ ឧសភា ១៩៤០ ត្រូវផុតលែតឥតបានការ ចាប់ពីថ្ងៃ ៥ ឧសភា ១៩៥០ ។

ដោយគេយល់ឃើញថា ពេលវេលាបានកន្លងទៅខុសគ្នាចំនួន ១៥ ថ្ងៃ (គឺមកដល់ថ្ងៃ ២០ ឧសភា ជាន់គេធ្វើសេចក្តីថ្លែងការណ៍មួយថ្មី) គេពោលថា សេចក្តីថ្លែងការណ៍ក្រោយបង្អស់នេះមិនបានការទេ ។ ចំពោះការនេះ ប្រទេសថៃ ថាតែម្នាក់ឯងជាង ៣១ ឆ្នាំកន្លងទៅ គាត់ថាបានការដោយគាត់នៅទទួលស្គាល់សមត្ថកិច្ចនៃតុលាការ ដល់ពេលខ្លះជាត់ពាក្យបណ្តឹងភ្លាម ប្រទេសថៃបានក្រឡេះភ្លាមថា មិនបានការទៅវិញ ហើយប្រទេសថៃលែងទទួលស្គាល់តុលាការអន្តរជាតិភ្លាម ដោយបកស្រាយថា សេចក្តីប្រកាសរបស់ខ្លួនធ្លាក់ទៅជាមោឃៈអសារឥតការទៅហើយ ។

ខាងវិញ ប្រទេសថៃបានដោះសាថា តុលាការអន្តរជាតិមិនត្រូវជំនុំដំរៀងមួយ ដែលមិនមែនមានការគោរពឯករាជ្យនៃទឹកដីថៃទេ ។

គឺត្រូវមានរាជប្រទេសជាកំណត់ប្រទេសថៃឯណោះទៅវិញ ដោយពោលថា ប្រទេសកម្ពុជាដែលបានឯកភាពរួចហើយនេះគ្មានសិទ្ធិអ្វីនឹងទៅជាតំណាងប្រទេសជាកំណត់ ដោយសំអាងលើសន្ធិសញ្ញាឆ្នើរឡើងក្នុងសម័យអាណានិគមបានទេ ។ យើងអាចធ្វើការប្រៀបធៀបឲ្យដាច់ស្តាប់ជាងនេះទៀត: តាមគំនិតរបស់ថៃខាងលើ គឺគេចង់និយាយថា បើឧត្តុកស្តាប់ទៅ កូនគ្មានសិទ្ធិនឹងទទួលមតិគំនិតភ្នក ជាប្តឹងទៅតុលាការអំពីរឿងមួយ ដែលមានជាប់រហូតតាំងអំពីតាលដែលឧត្តុកស់ទៅទេ ។

ចំពោះយោបល់ថៃចំណុចពីរ ដែលបដិសេធសមត្ថកិច្ចតុលាការអន្តរ-

ក្បួនបង្ហាញវិស្សមកាលនៃសមាគមនិស្សិតកម្ពុជានៅក្រៅប្រទេស ដែលបានធ្វើឡើងនៅទីក្រុងប៉ារីស ក្នុងឆ្នាំ ១៩៥៦ ។ ក្បួនបង្ហាញនេះ បានដើរតាមផ្លូវធំៗ ក្នុងទីក្រុងប៉ារីស ។

ជាតិនេះ មេធាវីយើងបានឡើងថ្លែងជំទាស់ (objections) ដោយសំអាងលើទង្វើការណ៍យ៉ាងម្តងម៉ាដូចតទៅៈ

១) មេធាវីខាងខ្មែរ បានបញ្ជូញយោបល់ជំទាស់តាមទង្វើការណ៍យ៉ាងជាក់ស្តែង ដើម្បីតតាំងនិក្ខេបបទរបស់ថៃ ។

និក្ខេបបទមួយរបស់ថៃ មានស្តីអំពីការបកស្រាយសេចក្តីប្រកាសរបស់ខ្លួនចុះថ្ងៃ២០ ឧសភា ១៩៥០ ដោយចុចចំពាក្យអង់គ្លេសថា (Renew) ឬប្រកាសជាថ្មី ។ ប្រទេសថៃគេពោលថា ប្រកាសខ្លួលស្គាល់ជាថ្មី យ៉ាងដូចម្តេចកើត បើសេចក្តីប្រកាសដើម (សេចក្តីប្រកាសចុះថ្ងៃ ២០ ឧសភា ១៩៥០) ៅជាអសារឥតការៅហើយ ? ។

មេធាវីដំបូងរបស់យើងតាំង ៣ រូប បានឡើងថ្លែងជំទាស់ដើម្បីតតាំងយោបល់ថៃខាងលើយ៉ាងដាច់ឈាត់បំផុត ។

ទង្វើការណ៍របស់លោក ឆាន - អាឈឺសុន មេធាវីខាងខ្មែរ :-

ក្រោយដែលសហជីវិន ឡើង - កាង បានឡើងថ្លែងការណ៍រួចលោក ឆាន - អាឈឺសុន បានចាប់ផ្តើមជំទាស់ៅទឹងយោបល់របស់ថៃ ដោយដូនទង្វើការណ៍យ៉ាងពូលំពូលាយ (ជាភាសាអង់គ្លេសចំនួន ១៤ ទំព័រ) លោកបានរៀបរាប់រំលឹកឡើងវិញ អំពីកាលបរិច្ឆេទដែលរដ្ឋាភិបាលប្រទេសថៃបានប្រកាសទទួលស្គាល់ជាផ្លូវការ តាមធម្មនុញ្ញនៃសហប្រជាជាតិទូវៅសមត្ថកិច្ចនៃតុលាការអន្តរជាតិ ចាប់តាំងពីឆ្នាំ ១៩៤៩ មក ។ សេចក្តី

ប្រកាសជាហូរហែ (៧ ឧសភា ១៩៣០, ៤ ឧសភា ១៩៤០ និង ២០ ឧសភា ១៩៥០) ជានបញ្ជាក់អំពីការដែលប្រទេសថៃជានទទួលស្គាល់សមត្ថកិច្ចនេះជាឧឡារិកវឿងមក ។ លោក ខាន-អាឈីសុន ជានវែកវែកយ៉ាងវែងអំពីពាក្យអង់គ្លេស (រ៉ឺញូវ) (Renew) ដែលមានកន់សេចក្តីប្រកាសក្រោយបង្អស់ ។

ពាក្យថា រ៉ឺញូវ នេះ ជានសេចក្តីថា «ដាក់ឲ្យទៅជាធរមានឡើងវិញ (REMISE EN VIGUEOR) គឺដាក់ច្បាប់ដែលត្រូវផុតរលត់ទៅ ឲ្យទៅជានការដដែលតទៅមុខទៀត ។ លោកជានលើកយកតឹកតាងជាច្រើនតាមផ្លូវច្បាប់អន្តរជាតិមកបង្ហាញឲ្យយើញថា ប្រទេសថៃជានទទួលស្គាល់សមត្ថកិច្ចនៃតុលាការអន្តរជាតិមែន ។

សេចក្តីប្រកាសរបស់ថៃចុះថ្ងៃ ២០ ឧសភា ១៩៥០ ជានបញ្ជាក់ច្បាស់ចិត្តជឹងជិតរបស់ថៃ ដែលមានចេតនាទទួលស្គាល់សមត្ថកិច្ចនេះបន្ត ១០ ឆ្នាំមកទៀត ។ តុលាការជានធ្លាប់វិនិច្ឆ័យថា «ការយល់ព្រម គឺកើតឡើងព្រមទឹកចិត្តចេតនា មិនមែនកើតមកពីទម្រង់ការជាសម្បកក្រៅទេ» ។ ប្រទេសថៃ មិនអាចយកវឿងប្រទេសអ៊ីស្រាអែល ទំនប៊ុលហ្គារី មកធ្វើជាសំអាងទេ ។ ប្រទេសកម្ពុជាមិនជានដដែលថា សេចក្តីប្រកាសរបស់ថៃចុះថ្ងៃ ២០-៥-១៩៤៩ ទៅជាមោឃៈអសារឥតការនោះទេ ប្រទេសកម្ពុជាដដែលតែពីការដែលប្រទេសថៃទទួលស្គាល់សមត្ថកិច្ចតុលាការអន្តរជាតិតែប៉ុណ្ណោះ ។ (នៅមានត)

ប្រវត្តិសង្ខេបនៃផ្ទៃស្វាយចន្ទី

កាលពីព្រេងព្រឹទ្ធអតីតកាលមានដំណាលថា ក្នុងពេលដល់រដូវកាលជាដំបូង ដែលព្រះឥសូរទ្រង់បញ្ជារុក្ខជាតិផងគ្រប់ប្រភេទដែលទ្រង់ទើបនឹងបង្កើតហើយនោះឲ្យបញ្ចេញផ្កាផ្លែ ដើម្បីទុកជាពូជក្នុងពិភពលោកយើងនេះ គ្រានោះស្វាយចន្ទីបានឃើញថា រុក្ខជាតិជាច្រើនមិនទាន់បានដឹងដល់រដូវកាលបញ្ចេញផ្កាផ្លែរបស់ខ្លួន តាមព្រះបញ្ជាដ៏ខ្ពង់ខ្ពស់កំពេញដំណើរធ្វើទស្សនាការ ស្រែកបង្គំកប្រកាសប្រាប់គ្រប់ទិសទីថា «បងប្អូនរុក្ខជាតិទាំងឡាយអើយ! ឥឡូវនេះ ជារដូវកាលដែលព្រះជាម្ចាស់ទ្រង់បញ្ជាឲ្យយើងនាំគ្នាបញ្ចេញផ្កាផ្លែទុកជាពូជរៀងខ្លួនហើយ! សូមបងប្អូនទាំងអស់គ្នា ប្រញាប់ប្រញាល់បញ្ចេញផ្កាផ្លែឲ្យទាន់ពេលវេលាទៅចុះ» ។ រុក្ខជាតិទាំងអស់ ដោយភ័យខ្លាចក្រែងគ្មានពូជក្នុងពិភពលោកនឹងគេ ក៏ផ្ញើលអ៊ូអារនាំគ្នាបញ្ចេញផ្កាបញ្ចេញផ្លែ តាមសេចក្តីប្រកាសរបស់ស្វាយចន្ទីពុំមានសល់ ។

ឯស្វាយចន្ទីវិញ លុះដើរបង្គំកប្រកាសប្រាប់គេសព្វដំបន់ទិសទីហើយ ក៏រវៀសរវៃត្រឡប់មកវិញ ដើម្បីនឹងបញ្ចេញផ្កាផ្លែទុកជាពូជរបស់ខ្លួន ។ គួរឲ្យអាណិតណាស់! គាត់រវល់តែដើរស្រែកប្រកាសប្រាប់គេ លុះវិលមកវិញ ស្រាប់តែរដូវកាលកៀកដាច់ផុតណាស់ទៅហើយ គាត់ទប្រឹងបញ្ចេញផ្ការួចបញ្ចេញផ្លែយ៉ាងប្រញាប់រួសរាន់ ។ ដោយមើលទៅឃើញថាគ្មានសង្ឃឹមនឹងទាន់រដូវកាល នឹងដោយភ័យខ្លាចក្រែងជាប់

ពួជ គាត់ក៏ខំប្រឹងបញ្ចេញគ្រាប់ពួជទៅមុខ ហើយបញ្ចេញសំបក-សាច់ឲ្យដេញតាមពីក្រោយ ។ ជាគ្រោះល្អដែរ គ្រាប់ពួជបានស្ទុះចម្រើនដឿនលឿនទៅមុខយ៉ាងឆាប់ សមតាមសេចក្តីប្រាថ្នាមែន ប៉ុន្តែគ្រោះអាក្រក់ដោយសំបកដេញប្រកិតជិតពីក្រោយតាមគ្របគ្រាប់ពួជនោះ ឲ្យដុះតាំងអស់មិនបានសោះ ទោះបីគាត់ខំប្រឹងរត់ប្រឹងដេញពេញទំហឹងក៏ដោយ គាត់គ្រប់ក្បាលគ្រាប់តែមិនបានបន្តិច រដូវកាលដែលក្តួជាតិត្រូវផ្លាស់ផ្លែតាមព្រះបញ្ញត្តិនៃព្រះឥស្សរជាម្ចាស់កំផុតរលត់អស់កាលបរិច្ឆេទទៅ ។

ដូច្នេះហើយបានជាផ្លែស្វាយចន្ទី ខុសប្លែកពីផ្លែក្តួជាតិទាំងពួង គឺមានសំបកផ្លែគ្រាប់មិនជិត នៅលឿនត្រលិន ។ គួរឲ្យមើលហើយចង់អស់សំណើច ។

ស្វាយចន្ទីបានជាគ្រាប់នៅក្រៅផ្លែ ព្រោះមានរឿងដូចពណ៌នាមកនេះឯង ។

ផល-ខិត



ពិធីបង្សុកូលនៅក្នុងព្រះវិហារលើភ្នំគូនពេញ ដើម្បីឧទ្ទិសកុសលផ្ទួនជំពោះវិញ្ញាណក្ខន្ធនៃឯកឧត្តម
ភាដៀន្ត្រាសាទ អតីតប្រធានាធិបតី នៃប្រទេសវីណ្ណៀ នៅថ្ងៃទី ២ មីនា ១៩៦៣

ផ្នែកកំណត់ដំណប្រវត្តិការណ៍

ពិធីបង្ហូរកូលទុទ្ទិសកុសលជូនចំពោះវិញ្ញាណក្ខន្ធ នៃឯកឧត្តមពាជេន្ទ្រប្រាសាទ អតីតប្រធានាធិបតីនៃប្រទេសឥណ្ឌូ

កាលពីថ្ងៃសៅរ៍ ទី ២ មីនា ១៩៦៣ ពេលម៉ោង ១៦ នៅឯព្រះវិហារវត្តកុំជូនពេញ តាមព្រះពរជយញ្ជាដ៏ខ្ពង់ខ្ពស់នៃសម្តេចសហជីវិន ព្រះប្រមុខរដ្ឋប្រទេសកម្ពុជា មានធ្វើពិធីបង្ហូរកូលដ៏ឧឡារិកដើម្បីឧទ្ទិសកុសលជូនចំពោះវិញ្ញាណក្ខន្ធនៃឯកឧត្តមពាជេន្ទ្រប្រាសាទ អតីតប្រធានាធិបតីប្រទេសឥណ្ឌូ ដែលទើបនឹងទទួលមរណភាពនៅថ្ងៃទី ១ ខែមីនា ១៩៦៣ ក្រោមអធិបតីភាពនៃសហជីវិនម៉ែន - ឈុំ អនុរដ្ឋលេខាធិការក្រសួងធម្មការនិងសាសនាសិក្សាធិការ ។

លុះប្រតិភូនៃក្រសួងនានាក្នុងព្រះរាជធានីភ្នំពេញ បានអញ្ជើញមកដល់ជុំហើយ សហជីវិនម៉ែន - ឈុំ បានឱមន្តព្រះសង្ឃចាំងពីរគណៈ គឺ មាងមហានិកាយ ១០ ព្រះអង្គ ដែលមានព្រះតេជគុណ ព្រះមុនីកោសលសូ - ហាយ តំណាងសម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណមហានិកាយជាប្រធាន មាងគណៈធម្មយុត្ត ១០ ព្រះអង្គ ដែលមានព្រះតេជគុណអរិយកសប្បបន្ទូ - គធ៌ តំណាងសម្តេចព្រះមហាសុធម្មាធិបតីសង្ឃនាយកគណធម្មយុត្តិកនិកាយជាប្រធាន បង្ហូរកូល ។

នៅក្នុងព្រះវិហារវត្តកំដួនតេញ មានការរៀបចំគ្រឿងសក្ការៈ គឺ
ទៀនធូបទឹងផ្កាដ៏ល្អស្រស់ថ្វាយព្រះតួនរួប ។ ខាងមុខបង្គួច ឈៀងអគ្នេយ៍
មានការដាក់លំរូបឯកឧត្តមអាជ្ញាធរប្រចាសាខ អតីតប្រធានាធិបតីលើតុៈដ៏
ស្អាត តាក់តែងលំអដោយថ្មផ្កាពីរអមសងខាង នៅខាងមុខតុៈ ចំពោះមុខ
រូបឥតមានភួងផ្កា (Couronne) ដ៏វិចិត្រផ្នែកនៅទីនោះ ជាសញ្ញាមរណ-
ភ័ក្តដែលប្រទេសកម្ពុជាធ្លើឡើងដើម្បីគោរពវិញ្ញាណក្ខន្ធ នៃឯកឧត្តម
អតីតប្រធានាធិបតី ។

មុនទីធ្លាទិមន្តព្រះសង្ឃឋង្ឃក្រុល សហជីវិនមែន-ឈុំ អនុរដ្ឋលេខា
ធិការក្រសួងធម្មការ បានថ្លែងសង្ខេបរំលឹកអំពីពិធីដែលត្រូវធ្វើ
ក្នុងពេលនោះ គឺដើម្បីឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខន្ធនៃឯកឧត្តម-
អាជ្ញាធរប្រចាសាខអតីតប្រធានាធិបតីប្រទេសឥណ្ឌា ដែលបានឧទ្ទិសមរណ
ភាពទៅនោះ សូមឲ្យវិញ្ញាណក្ខន្ធនៃឯកឧត្តមឧទ្ទិសនូវកុសលកុសលនេះ
ហើយសូមឲ្យឯកឧត្តមបានតប់ប្រសព្វនៃនឹងសុភមង្គលត្រប់ប្រការក្នុងបរ-
លោក រួចហើយសហជីវិនអនុរដ្ឋលេខាធិការបានសុំឲ្យសហការីតាំង
ឡាយរបស់លោកព្រមទាំងប្រតិភូនៃក្រសួងនានា តាំងចិត្តស្ងប់ស្ងាត់មួយ
នាទី ដើម្បីចូលកាន់មរណសញ្ញាចំពោះសពឯកឧត្តមអាជ្ញាធរប្រចាសាខ ។
តមក ទើបព្រះសង្ឃតាំង២០អង្គ សូត្រធម៌ឋង្ឃក្រុលបញ្ចប់ពិធីនេះ ដែល
បានហើយសព្វគ្រប់នៅវេលាម៉ោង ១០, ៣០ ។

ភគ្គវចនវិយា


ទស្សនាវដ្តី ផ្សាយចំណាំងខាងសាសនា និងអក្សរសាស្ត្រ




ឆ្នាំទី ៣៥ លេខ ៤ ខែ មេសា

ព. ស. ២៥០៥ គ. ស. ១៩៦៣

- ក្នុង ពេញ -



ព្រះវិហារវត្តលង្កាភម មើលពីទិសខាងជើង



ភ្នំពេញសន្ទេយ

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

បេញ្ញារាល់ខែពុទ្ធសាសនបណ្ឌិត្យ

ខ្លឹមសារសាសនា	ម្ចាស់ទៀង	ទំព័រ
– អំពីរឿងអសោក (វិចារណកថា)	លោក ផេង-ត្រីវ រៀបរៀង (ត).	៣៣៤
– រឿងព្រះមហាសីលវីរាជ (ពាក្យកាព្យ)	លោក ហេង-សមអាន រៀបរៀង	៣៤២
– ព្រះអភិធម្មបិដក (គម្ពីរព្រះមហាបដ្ឋាន)	លោក ប៊ូ-ប៊ូ ប្រែរៀបរៀង (ត).	៣៥៧
– មធុរសវាហិណី សម្តេចព្រះធម្មលិខិត	ស្វី-ឯម ឧត្តមប្រឹក្សា ប្រែរៀបរៀង (ត)	៣៦៥
– មហោសារជាតក (ត)		៣៧៥

វគ្គកអក្សរសាស្ត្រ		
– ប្រវត្តិខ្មែរ កំពត ស្រាវជ្រាវ ដោយ ឆឹក-ឆាម		៣៩៤
– ពាក្យខ្មែរប្រែពីបរទេស ដោយគណៈកម្មការជាតិនៃការសិក្សាផ្នែកអក្សរ «ក» (ត)		៣៩៧
– វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះវេជ្ជព្រះគុណ ជឹង-ខាត់ រៀបរៀង (ត)		៣៩៩
– រឿងសាមកុក លោកឧកញ៉ា នូ-ហន ប្រែរៀបរៀង (ត)		៤០១
– ល្បើកឡាហ្វុងតែន លោកផេង-ត្រីវ ប្រែពីភាសាថាំង (ត)		៤១១
– រឿងព្រេងចិន លោក វ៉ាយ-ប៊ុក ប្រែពីភាសាថាំង (ត)		៤២២
– ការដំនុំដំរះដោយយុត្តិធម៌នៃតុលាការអន្តរជាតិពីរឿងក្តីព្រះវិហាររបស់ខ្មែរនៅក្រុងហ្គាហេ(ត)		៤២៨
– ល្បែងចោះប្រមាត់ របស់ក្រុមជំនុំទៀមទំលាប់ខ្មែរ		៤៤៣

វគ្គកកំណត់ខ្ចីនិងប្រវត្តិការណ៍	
– ពិធីប្រគល់សៀវភៅភាសាអាល្លឺម៉ង់ភ័ស្តុតាងពុទ្ធសាសនាចំនួន៦៥ក្បាលដល់ពុទ្ធសាសនបណ្ឌិត្យ	៤៤៥

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃដាវ ៤៣០ៈ០០

ពាក្យឃាត់មិនឲ្យ	ធ្វើការអាក្រក់
ជាការណាមក	ឲ្យធ្វើល្អហើ
ឲ្យងុំសទាត់ចិត្ត	កុំឲ្យហួងសៅ
បីនេះលោកហៅ	ពុទ្ធសាសនា

ប.ព.

វិចារណាកថា

អំពីរឿងអសោក

លោក នេន - ទ្រីវ រៀបរៀង

(តមក)

ខ្ញុំសូមតណិនាត្រង់កេក្បាល តាមសេចក្តីលោក ហ៊ុយ ប៊ែរថា: «ក្នុងទីស្ងាត់ កាលព្រះចៅអសោកបានឧតយើញសាវកព្រះពុទ្ធ (សមណ:) ខោះចាស់ក្តី ក្មេងក្តី ទ្រង់តែងលុតជង្គង់ ទទួលព្រះសីរសំពះដល់ព្រះចៅនៃសមណ: ។ សម័យនោះ ព្រះចៅអសោក មានអាមាត្យដំម្នាក់ឈ្មោះ យស: ជាមនុស្សមិច្ឆាទិដ្ឋិ ។ កាលបើបានយើញព្រះចៅអសោកគោរពព្រះភិក្ខុដូច្នោះ គាត់ពោលរិះគន់យ៉ាងខ្លាំងហើយក្រាបទូលចំពោះស្តេចថា: «ស្រមណ៍ទាំងនេះចេញមកពីវណ្ណ:ផ្សេង ។ ដើម្បីជួសក្នុងពុទ្ធសាសនា ។ (ស្រមណ៍) ពួកនេះ មិនមែនត្រឹមតែជាពួកព្រាហ្មណ៍ ទន់ពួកក្សត្រិយ៍ប៉ុណ្ណោះទេ គឺជាពួកវៃស្យ:ក៏មាន ពួកសូទ្រ:ក៏មាន រហូតដល់ពួកអ្នកសម្លាប់សត្វក អ្នកតម្បាញ អ្នកធ្វើឥដ្ឋ ទន់អ្នកកាត់ក្បាល ហើយមានទាំង

ពួកចណ្ឌាលផង ។ បពិត្រមហារាជ! ហេតុអ្វីព្រះអង្គសព្វព្រះទ័យគោរពស្រមណ៍អស់នោះ?» ។

ឮនទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយ ព្រះអង្គទ្រង់ទៅស្ងៀមមិនពោលថាអ្វីឡើយ ។ តទ្បន់ពីនោះមក មិនឮនប៉ុន្មាន ព្រះអង្គទ្រង់ប្រជុំអស់មន្ត្រីសេនាបតីរបស់ព្រះអង្គ ហើយទ្រង់បញ្ជាថា: «ខ្ញុំត្រូវការក្បាលចាំងឡាយនៃសត្វចាំងអស់ តែខ្ញុំមិនអនុញ្ញាតឲ្យលោកកាល់គ្នាសម្លាប់សត្វយកក្បាលមកឲ្យខ្ញុំទេ ខ្ញុំឲ្យរកតែក្បាលសត្វដែលស្លាប់ស្រាប់» ។ រួចទ្រង់មានព្រះបន្ទូលថា: «លោកនេះ ត្រូវរកក្បាលសត្វនេះមកឲ្យខ្ញុំ លោកនុ៎ះ ត្រូវរកក្បាលសត្វនោះមកឲ្យខ្ញុំ ។ ទ្រង់ព្រះបញ្ជាចំពោះគ្រប់នាម៉ឺនចាំងអស់ហើយ ទើបទ្រង់ថ្លែងបញ្ជាក់ថា: «ខ្ញុំត្រូវការឲ្យយកក្បាលសត្វដែលស្លាប់មកឲ្យខ្ញុំ។ មិនត្រូវការឲ្យយកក្បាលសត្វដ៏ចក្ខានេ» ។ ចំពោះលោក «យស:» ព្រះចាស់អសោកទ្រង់មានព្រះបន្ទូលថា: «លោក! លោកត្រូវរកក្បាលមនុស្សមកឲ្យខ្ញុំ តែជាក្បាលមនុស្សដែលស្លាប់ដោយខ្លួនឯង» ។ លុះអស់លោកមន្ត្រីរកបានក្បាលសត្វគ្រប់មកថ្វាយព្រះអង្គហើយ ទ្រង់បញ្ជាឲ្យម្នាក់ៗ យកក្បាលនោះៗ ទៅលក់នៅផ្សារ ។ ក្បាលចាំងប៉ុន្មានមានតម្លៃអស់ រៀលែងតែក្បាលមនុស្ស ក្បាលនេះធ្វើឲ្យមានការខ្ពើមរអើមដល់អ្នកណាដែលបានឃើញ គេតែងតែងាកមុខចេញ គ្មាននរណាត្រូវការទិញសោះ។ កាល

បើបានឃើញយស: មនុស្សទាំងអស់ នាំគ្នាដេរប្រទេចហើយពោលថា: «លោកឯងជាមនុស្សចណ្ឌាល ជាពស្យ:សើម្តងជាយក្ស ចានជាយកក្បាលនេះមកដូច្នេះ? »។ លុះត្រូវគេដេរប្រទេចដូច្នោះ លោកយស: ក៏វិលមកកេស្តប ហើយក្រាបទូលថា: «ទូលព្រះបង្គំចានយកក្បាលមនុស្សនេះទៅដាក់លក់តែគ្មាននរណាទិញសោះ គេត្រឡប់ជាដេរទូលព្រះបង្គំវិញ»។ ខណៈនោះ ព្រះចាទអសោក មានព្រះបន្ទូលទៅកាន់លោកនោះថា: «បើលោកយកក្បាលនេះទៅដាក់លក់ ហើយគ្មាននរណាទិញ ចូរលោកឲ្យក្បាលហ្នឹងទៅគេដោយមិនចាច់យកថ្លៃក៏ចាន!»។ ទូលព្រះពជបញ្ជាហើយ លោកយស:វិលទៅផ្សារវិញ ហើយស្រែកប្រកាសយ៉ាងខ្លាំងថា: «ខ្ញុំឲ្យក្បាលនេះទេតយកថ្លៃ បើអ្នកណាត្រូវការចូរយកចុះ»។ ឃើញពីដំណាពនោះ មនុស្សទៅផ្សារទាំងអស់ក៏ដេរលោកយស:ជាថ្មីទៀត គ្មាននរណាត្រូវការក្បាលនោះឡើយ។ លោកយស:ខ្មាសគេពន់ពេកវិលទៅកេព្រះពជា ក្រោកដៃប្រណម្យចំពោះព្រះអង្គ ហើយពោលខ្ទរសំដីដូច្នេះថា: «ក្បាលសត្វគេ សត្វណា សេះ ដំរី ជ្រូក ចៀម គឺថាក្បាលសត្វទាំងអស់ មានមនុស្សត្រូវការទិញគ្មានសល់ គេដណ្តើមគ្នាទិញផង ក្បាលសត្វទាំងអស់សុទ្ធសឹងមានតម្លៃ មានតែក្បាលមនុស្សមួយទេដែលត្រូវគេស្អប់ខ្ពើម គ្មាននរណាអាចយកទៅប្រើធ្វើជាអ្វីបានឡើយ សូម្បីឲ្យគេទេ ក៏គ្មានគេត្រូវការយកផង ហើយទូលព្រះបង្គំត្រូវទូល

វង់គ្រោះដោយគេដេរថែមទៀត ក្រៅពីគ្មានអ្នកទិញ! » ។

ព្រះរាជាទ្រង់មានព្រះបន្ទូលសួរចំពោះយស:ថា: «កាលលោកជាក់ក្បាលមនុស្សលក់ ហេតុម្តេចក៏លោកមិនអាចលក់ក្បាលនោះបាន? » ។ លោកយស:ក្រាបបង្គំទូលថា: « មនុស្សពាំងអស់ស្អប់ខ្ពើមក្បាលមនុស្ស គ្មានអ្នកណាត្រូវការទិញ» ។ ព្រះរាជាទ្រង់ដណ្តឹងសួរទៀតថា: «តែក្បាលនោះមួយទេឬ ដែលគេស្អប់ខ្ពើម ឬក៏ក្បាលមនុស្សពាំងអស់ជាទីស្អប់ខ្ពើមដូចគ្នា? » – យស:ក្រាបបង្គំតបថា: « ក្បាលមនុស្សពាំងអស់សុទ្ធសឹងជាទីស្អប់ខ្ពើម មិនមែនតែក្បាលនេះមួយទេ » ។ ព្រះរាជាទ្រង់ដណ្តឹងសួរជាថ្មីថា: ចុះក្បាលរបស់ខ្ញុំ ជាវត្ថុជាទីស្អប់ខ្ពើមដល់មនុស្សពាំងឡាយដែរឬ?» ។ – បានឮព្រះរាជាដូច្នោះ លោកយស:ក៏យំ ហើយមិនហ៊ានក្រាបបង្គំទូលឆ្លើយ លោកនៅស្ងៀម ។ ព្រះរាជាទ្រង់មានបន្ទូលឡើងវិញថា: « ខ្ញុំអនុញ្ញាតឲ្យលោកនិយាយ កុំខ្លាចអ្វីឲ្យសោះ ត្រូវលោកពោលពាក្យពិត តើក្បាលខ្ញុំជាទីស្អប់ខ្ពើមដែរឬ? » ។ – លោកយស:ក្រាបទូលតបថា: « ច្រាកជាមែនហើយ ព្រះសិរីនៃព្រះរាជាក៏ជាទីស្អប់ខ្ពើមដែរ » ។ ព្រះរាជាទ្រង់មានព្រះបន្ទូលតទៅថា: « ឥឡូវ តើលោកយល់ហើយឬនៅ? » ។ – លោកយស:ក្រាបទូលថា: «បពិត្រព្រះមហាក្សត្រ ខ្ញុំលព្រះបង្គំយល់ហើយ! » ។ ព្រះរាជាមានព្រះបន្ទូលទៅលោកយស:ថា: «បើក្បាលមនុស្សមានបណ្តាសក្តីគ្នា បណ្តាសក្តីគ្នា

អ្នកមានសម្បត្តិក្តី អ្នកក្រខ្សត់ក្តី សុទ្ធសឹងជាទីស្អប់ខ្ពើមដូចគ្នាទាំងអស់ ហេតុម្តេចក៏លោកប្រកាន់ឬក ព្រោះតែលោកមានអំណាច មានជាតិ មានវិជ្ជា មានសោភណភាព ? ហើយហេតុអ្វីក៏លោកហាមខ្ញុំមិនឲ្យគោរពស្រមោចទាំងឡាយជាកូនព្រះសាក្យៈ ? » ។ រួចទ្រង់ពោលនូវគាថាយ៉ាងនេះថា:

« មានតែក្សត្រមនុស្សទេ បើកាលណាគេឃើញ រមែងញាំងចិត្តឲ្យស្អប់ខ្ពើម ហើយគ្មាននរណាត្រូវការទេញ ។ ទោះបីឲ្យគេទេ ក៏គេតែងតបជ្រាយចំពោះក្សត្រនោះ គេថែមទាំងមិនហ៊ានមកជិតផង ។ បើយើញក្សត្រមនុស្សពីចម្ងាយ មនុស្សទាំងអស់ តែងមានចិត្តក្តៅក្រហាយ ។ គេនិយមពោលថា: « តែនេះជាប្រផ្នូលអាក្រក់ធំធ្ងន ប្រកបដោយសេចក្តីវេទនាក្រៃលែង ! ក្សត្រគេញៅដោយឈាមធំធ្ងន់នេះជាទីមើលងាយធំធ្ងន គួរខ្ពើមរអើមពន់ពេក ។ ក្សត្រយើងជំហ៊ានតបធំជាទីមើលងាយ គួរយកក្សត្រនេះទៅបូជាធំក្សត្រ « មានតម្លៃខាងសាសនា: » ។ ដែលខ្ញុំឲ្យធំក្សត្រចុះចំពោះពួកស្រមោចទាំងឡាយ អំពើនេះគាប់ប្រសើរណាស់ » ។

ព្រះបាទអសោកទ្រង់មានព្រះបន្ទូលធំលោកយស:តទៅទៀតថា:

« លោកតែងតែប្រកាន់ថាកិក្ខុទាំងនោះ ចេញមកពីវណ្ណៈផ្សេង ។ ហើយថោកតបផង ។ លោកពុំបានយល់ថាចិត្តរបស់កិក្ខុ តេញសុទ្ធតែព្រះធម៌ឡើយ ។ លោកជាមនុស្សល្ងង់ ជាមនុស្សមិច្ឆាទិដ្ឋិ ដួងចិត្ត

លោកកកវល្លក់ធំដ៏វង្វែង ព្រោះការភាន់ច្រឡំ ។ លោកឮថាមានតែ
ពួកព្រាហ្មណ៍ទេ ដែលអាចធ្វើខ្លួនឲ្យរួចចាកកំពប់បាន ពួកវណ្ណៈដទៃមិន
អាចធ្វើបាន ។ មែនពិត បើគេរៀបអាពាហ៍ពិពាហ៍ គួរតែប្រាថ្នាតែជ្រើសរើស
វណ្ណៈចុះ ។ តែប៉ុន្តែ បើកាលណាគេរកព្រះធម៌ តើប្រយោជន៍អ្វីនឹងគិត
ដល់វណ្ណៈ? អ្នកណាដែលស្វែងព្រះធម៌ មិនត្រូវគេប្រឹងគិតដល់វណ្ណៈឡើយ។
គេបានកើតក្នុងវណ្ណៈខ្ពង់ខ្ពស់ ប្រសិនគេមានចរិយាអាក្រក់ គេក៏
ត្រូវខ្លួសសេចក្តីបន្ទោសពីជនពាលអស់ រួចគេហៅអ្នកនោះជាមនុស្ស
ថោកទាប ។ ប្រសិនបើវណ្ណៈមានសភាពថោកទាប តែមនុស្ស
មានគុណធម៌ពិតប្រាកដ គេត្រូវតែគោរព គេរមែងហៅអ្នកនោះជា
មនុស្សខ្ពង់ខ្ពស់ ។ បើគេមានគុណធម៌បរិបូណ៌ហើយ ហេតុម្តេចក៏យើង
មិនគោរពគេ ? ការពុករលួយរបស់ចិត្ត តែងធ្វើឲ្យអាការទាំងគ្រប់ថោក
ទាប ។ គ្មានមគ្គនៃមនោសញ្ចេតនាធ្វើឲ្យរូបកាយមានតម្លៃ ។ ពួកស្រមណ៍
ប្រព្រឹត្តអំពើល្អ លោកត្រូវគោរពវិន័យ លោកបរិបូណ៌ដោយការចេះដឹង:
យ៉ាងនេះហើយ ចានជាគួរតែប្រាថ្នាគោរពលោក គួរតែប្រាថ្នាក្រាបថ្វាយបង្គំ-
ទោនដ៏ជ្រាលជ្រៅចំពោះលោក ។ . . . . លោកឯងមិនបានឮ មិនបាន
ស្តាប់ព្រះឧភតនៃព្រះសាស្តា: ជាព្រះមហាកុរុណាធិគុណ ជាព្រះទសពល: គឺ
ព្រះអង្គហើយដែលទ្រង់ត្រាស់ដឹងនូវមគ្គដ៏ល្អទេឬ ? លោកឯងមិនបាន
ឮនូវព្រះធម៌ដែលព្រះអង្គទ្រង់សំដែងថា: ត្រូវយកលក្ខណៈបីប្រការជា (១)

១— តាមការណ៍ពិត: លក្ខណៈ មានបី គឺ អនិច្ចលក្ខណៈ ១ ទុក្ខលក្ខណៈ ១ អនត្តលក្ខណៈ ១
ហើយមានន័យផ្សេងពីគ្នា ។

វត្តមិនខៀង ទៅប្តូរយកលក្ខណៈជាប្រការជាវត្តខៀងទេឬ?» ។ ព្រះទុក្ខ
នៃព្រះពុទ្ធជាម្ចាស់មិនមានការតន្តប្រឡំត្រង់តែខ្លួនឯណាសោះឡើយ ។
ហេតុដូច្នេះ ទើបខ្ញុំត្រូវតែគោរពព្រះទុក្ខនោះ ។ ប្រសិនបើលោកឲ្យ
ខ្ញុំរើនទុក្ខនៃព្រះលោកនាថ លោកមិនគួរឲ្យខ្ញុំហៅលោកជា
មិត្រវេរស់ខ្ញុំឡើយ ។ កាលណាគេគាបអំពៅ គេយកចឹកក គេចោះ
កាកចោល ។ រូបមនុស្សក៏ដូចជារឿងនេះដែរ ។ មច្ចុកដផ្តាច់ជីវិត
មនុស្ស សាកសពដេកស្តូកស្តឹងលើផែនដី មិនអាចកម្រើកបាន តែរោគ
ព្រះសង្ឃមិនកើត ធ្វើអំពើល្អមិនបាន ។ នេះហើយដែលត្រូវឲ្យយល់
ឮស់ថា កាយនេះជារបស់បែកធ្លាយ ត្រូវតែធ្វើកាយឲ្យទៅជារបស់
មានសភាពស្ថិតស្ថេរ ។ ឧបមាដូចជា: កាលណាភ្ញីនេះផ្ទុះ
បណ្តិតត្រូវតែបញ្ចេញទ្រព្យសម្បត្តិរបស់ខ្លួនពីផ្ទះនោះ ត្រូវតែប្រញាប់
រើយកតន្តែតាំងឡាយចេញពីកំណប់ដែលធ្លាក់ទៅក្នុងទឹក ។ រូបកាយ
នេះមានការវិនាសជាទីបំផុត ត្រូវតែធ្វើរូបកាយឲ្យទៅជារបស់ដែលមិន
វិនាស ។ តែឯមនុស្សខ្លៅមិនចេះសំគាល់ថារបស់នេះត្រូវបែកធ្លាយ
របស់នោះមិនមានការបែកធ្លាយទេ ។ កាលណាកងទុក្ខមច្ចុកដមក
ដល់ភ្លាម អ្នកនោះហាក់ដូចជាត្រូវចូលទៅកន្លែងមាត់សត្វមកវិ ។ ក្នុង
វេលានោះ ខ្លួនក៏យំខ្លាចហើយតត់ស្តូតយ៉ាងខ្លាំងក្រៃលែង ។ កាល
ណាគេចំកញ្ជ្រាយកក្រែមទឹងបីពីទឹកដោះរួចហើយ គោះបើផើងទឹកដោះ

បែកកំដៅយ៉ាង គេមិនសូវពុក្រព្រួយប៉ុន្មានឡើយ ។ រូបកាយយើងក៏ដូច្នោះដែរ កាលណាគេបានពាក់ព័ន្ធរូបកាយនូវបុគ្គលដែលមានសារៈដ៏ពិតប្រាកដហើយ គប្បី បើសេចក្តីស្លាប់មកដល់ គេនឹងមិនមានការស្តាយអ្វី ក៏ប៉ុន្តែបើគេមិនបានធ្វើកុសលកម្ម គេគិតតែក្រអឺតឆ្នើងការខ្ជិលច្រអូសព្រួយបារម្ភសោះ កាលណាមច្ចុរាជមកដល់ភ្លាមដើម្បីបំបែកផើងគឺរូបកាយ គេត្រូវមានចិត្តនោះភាលកាលក្តៅក្រហាយដូចជាត្រូវភ្លើងដែរ ។ សេចក្តីពុក្រប្រៀបដូចជាភ្លើង ផើងឥដ្ឋប្រៀបដូចជារូបកាយមនុស្ស ។ លោកមិនត្រូវហាមខ្ញុំមិនឲ្យធ្វើកុសលកម្ម មិនឲ្យសែ្វងរកតែមានសភាពខៀងខាត់ទេ ។ មានចិត្តរុំព័ទ្ធដុំវិញដោយអន្ទាក់តណ្ហា លោកតែងនឹកថា: « អញមានវណ្ណៈដ៏ខ្ពង់ខ្ពស់ » ។ ចំណែកខ្លួនខ្ញុំ ខ្ញុំកាន់តប់ភ្លើងគឺព្រះឧរៈនៃព្រះទសពល នៃ ព្រះលោកត្រៃ ខ្ញុំយកតប់ភ្លើងនេះគ្រាលបំភ្លឺដើម្បីពិនិត្យរូបកាយរបស់ខ្ញុំ ។ ដូច្នេះ មិនមានការផ្សេងគ្នារវាងអ្នកមានវណ្ណៈខ្ពង់ខ្ពស់នឹងវណ្ណៈថោកទាបឡើយ ។ សែ្បក សាច់ សរសៃឆ្អឹង អាការ ៣៦(១) នៃរូបកាយមានសភាពដូចគ្នាពាំងអស់ មិនថាអ្នកមានវណ្ណៈខ្ពង់ខ្ពស់នឹងអ្នកមានវណ្ណៈថោកទាប ។ អ្នកវណ្ណៈខ្ពស់មានសញ្ញាអ្វីជាគ្រឿងសំគាល់ ? មានតែសំលៀកបំពាក់ដ៏មានតម្លៃរបស់ខ្លួន សំពត់ដ៏តើតឆាយរបស់ខ្លួននឹងរបស់ប្រើប្រាស់របស់ខ្លួនប៉ុណ្ណោះទេ ដែលថ្លៃក ។

១- ក្នុងគម្ពីរបាលីពុទ្ធសាសនាខាងថេរវាទៈ អាការៈមានតែ ៣២ ។

(នៅមានត)

រឿងព្រះមហាសីលវរាជ

(ភាសាភូមា)

លោក ខោង-សម អាន រៀបរៀង

ចាកមហាសីលវរាជាតកក ឯកនិទាន អភិសង្ខេ

– ១ –

ក្នុងអតីតកាល ព្រះចាខមមហាសីលវរាជ ទ្រង់សោយរាជ្យក្នុងភាគ-ណាសីនៃដែនកាសី ជាមហាក្សត្រប្រកបដោយសីល ថ្វាយព្រះជន្មនឹងព្រះពុទ្ធសាសនា មានសេនាមាត្យម្នាក់ជាសំណប់តាប់ព្រះទ័យក្រៃលែង តែសេនាមាត្យនោះចិត្តខ្មៅទ្រុស្តអន្ធពាល ក្បត់ព្រះអង្គ។ ទ្រង់ជ្រាបហៅមកប្រដៅឲ្យឈប់ប្រព្រឹត្តអំពើថោកទាបទាំងនោះ ។

បទពាក្យ ៧

ក្នុងកាលកន្លងជំយូរក្តាត់ មានព្រះមហាក្សត្រទ្រង់ខ្ពង់ខ្ពស់
ព្រះមហាសីលវៈឆ្លើងជាមើ ត្រង់ដែនកាសីដោយសាខរ ។
ប្រជាពលរដ្ឋគ្រប់ទាំងអស់ ទាំងស្ត្រីបុរសក្នុងនគរ
សាមគ្គីព្រមព្រៀងគ្នាឈូឆរ ត្រេកអរស្មោះសរនឹងសីលទាន ។
ប្រទេសកាសីឆ្លើងថ្កុំថ្កា គ្មានអំណាចណាអាចនឹងហ៊ាន
ចូលមកបំផ្លាញរាត្រកុកពន ឲ្យអន្តរាយបានឡើយណា ។

គ្រានោះមានសេនាបតី ឈ្មោះកាឡ-បក្សីមានប្រាជ្ញា
កាន់តាប់ក្រសួងយោសនាការ ព្រះមហាក្សត្រគាប់ព្រះទ័យ ។
ដោយៈលោកបក្សីចេះតែអបអរ រណបរណបយកតាប់ក្រៃ
ធ្វើបុណ្យធ្វើទានស្មើរកល់ថ្ងៃ តម្រូវព្រះទ័យព្រះរាជា ។
បច្ច័យចាត់ចែងបុណ្យតាំងអស់ គឺជារបស់ពួកជនខានា
ធ្វើការនៅក្រោមបទបញ្ជា អង្គាសចូលគ្នាដោយចិត្តស្ម័គ្រ ។
លោកកាឡ-បក្សីមិនចូលទេ គ្រាន់តែជាមេខួលប្រាក់
ខ្នះខ្នែងចាត់ចែងបុណ្យជាក់លាក់ បង្ខំលួចប្រាក់បុណ្យនោះទៀត ។
គំនិតមានយោនរបស់លោក អាក្រក់ស្មោកគ្រោកទំប្រឹងធ្វើត
ចាក់ចង់ទឹងសាសន៍ផ្កាសឯទៀត គំនិតចោលមៀតក្បត់ជាតិឯង ។
ក្បត់សាសនាទឹងរាជបល្ល័ង្ក ចង់តាំងជាស្តេចឥតគោតក្រែង
តឹងពួកបរទេសឲ្យចាត់ចែង ដណ្តើមកន្លែងស្តេចផែនដី ។
ថែមតាំងប្រព្រឹត្តចរិយា ផឹកស្រាហ៊ឺហាដើរលេងស្រី
កញ្ញាណាល្អរូបប្រិមប្រិយ ល្អស្រស់តិស័ក័យក្រៃលែង ។
ព្រោះលោកបក្សីល្បីកោងកាច ចាប់តាំងអំណាចឥតខ្ចាចក្រែង
អំពើថោកទាបតាំងនេះឯង ទិតទំប្រឹងប្រែងស្មើងកល់ថ្ងៃ ។
មានកម្លាំងខ្លាំងដោយជំនួយ ពួកបរទេសជួយអចិន្ត្រៃយ៍
មាស, ប្រាក់, អាវុធច្រើនក្រាស់ក្រៃ បញ្ជូនកល់ថ្ងៃសុទ្ធតែថ្មី ។

មានចារនារីស្រីឆើតឆាយ　　កបកាយបវរល្អលើសស្រី

យកការណ៍ចាន់ពិតតាមក្បី　　ជនក្បត់ផែនដីក្បត់សាសនា ។

ក្បត់ពុជបល្ល័ង្កទីគោរព　　ជាម្ចាប់ត្រជាក់ដោយសីលា

ហើយខានធ្វើសេចក្តីកយការណ៍　　ជូនពុជរជ្ជាតិចាលភ្លាម ។

កុង្រ្គីយក្រសួងសន្តិសុខជាតិ　　ទ្វីឃ្លាតអង្គតមិនរើមកម

ឃើញពិតច្បាកដចាប់ចងភ្លាម　　មិនឲ្យសង្គ្រាមកើតឡើងជាន់ ។

នាំចូលទៅផ្ទាយព្រះចក្រី　　ជាម្ចាស់ផែនដីយ៉ាងរួសរាន់

ខូលពីអំពើបៃដ៏ជាន់　　ពស្តុកចប់ហ្មឺនតាន់ក្តៅក្រហាយ ។

ពីអំពើក្បត់តុខ្មសាសនា　　ធ្វើរដ្ឋប្រហារប្រុងកំចាយ

ព្រះពុជបល្ល័ង្កឲ្យអន្តរាយ　　ទុបាយកលនេះជាតិដៃ ។

ជួយទុបត្តម្ភសម្ភារៈ　　មាសច្បាត់កាំភ្លើងច្រើនគ្រាប់ក្រៃ

កាំភ្លើងតូច-ធំ, កាំភ្លើងវែង　　បញ្ជូនច្រើនក្រៃគ្រប់ចំពាំ ។

ព្រះចៅកាស៊ីទ្រង់ឆ្លាសីលាទាន　　ព្រះអង្គទ្រង់មានព្រហ្មវិហារ

អាណិតមនុស្សសត្វគ្រប់ៗគ្នា　　តូច-ធំម្តេចខ្លាស្អ-អាក្រក់ ។

ព្រះចៅទ្រង់ត្រាស់ថា «មែនពិត　　អំពើទុច្ចរិតដ៏ក្រៃក់

ក្បត់ជាតិឯងនេះសែនអាក្រក់　　ក្រៃក់ប្រៀបដូចជាឆ្កែស្រុក ។

នែលោកបក្ស៊ី! ឃើញទេឆ្កែ　　មានច្រើនហូរហែដើររើរុក

រកស៊ីក្រោមផ្ទះនៃអ្នកស្រុក　　ឃើញគ្នាសំរុកខាំក្រញី ។

អំពើថោកទាបដ៏ស្មោកគ្រោក ដែលលោកគ្រោងការណ៍នេះថ្មី ។
ដូចជាឆ្កែស្រុកដណ្តើមឆ ខាំគ្នាក្រញ៉ាំដូច្នោះឯង ។
នែលោកបក្សី! អំពើក្សត់ ប្រជាពលរដ្ឋឃើញជាក់ស្តែង
ភ័ស្តុតាងមានច្បាស់ស្រឡះខែង ក្នុងទឹកខ្នែងរបស់លោក ។
ហេតុនេះកូរលោកឈប់ប្រព្រឹត្ត អំពើទុច្ចរិតដ៏ស្មោកគ្រោក
តែទំក្តែងក្អាងចាងច្រាំជ្រោក នោះលោកពស្ត្រជូនទៅកតថ្មី ។ ។
ព្រះមហាក្សត្រកាត់ព្រះទ័យ អភ័យទោសពៃរដល់បក្សី
ឲ្យមានសិទ្ធិនឹងមានសេរី ដូចជនប្រុសស្រីក្នុងរដ្ឋ ។
បក្សីថ្មានជួបជុំកូនចៅ តែចិត្តមួម៉ៅពេមនស្អប
មិនថ្មានសម្រេចដូចប្រាថ្នា គ្រោងការណ៍គេដឹងឮសុះសាយ ។
លោកកាឡ-បក្សីអគ្គីយធ្មឹង ត្រុះរះសញ្ជឹងគិតកំពាយ
ព្រះរាជបល្ង្ហង្គឲ្យខ្លាតខ្លាយ សាបសូន្យអន្តរាយប៉ុណ្ណោះឯង ។
គិតហើយពោលថា « ដែនកាសី មានតិញ្ជាស្រី ។ ចិត្តខែងវែង
ពេះយប់ពេះថ្ងៃទំស្វះស្វែង គ្រប់ទឹកខ្នែងដើរស៊ើបការណ៍ ។
បើចាត់ការនេះតទៅទៀត មុខជាក្លាត់ស្បៃតក្សីយដ៏វ
ខ្ញុំឯដែលស្ត្រីទៅក្នុងរដ្ឋ ត្រូវតែអាត្មាត់ចោលស្រុក ។
ទៅពឹងព្រះចៅដែនកោសល ឲ្យរៀបរៅពលចូលលុយលុក
បង្កើតចលាចលក្នុងស្រុក ហើយវាយសំរុកយកកូស័ម ។

- ២ -

ព្រះបាទមហាសីលវៈ: ទ្រង់ហៅសេនាមាត្យក្សត់នោះមកប្រដៅ តែសេនាមាត្យនោះវិនិតតែទទឹងធំធំព្រះអង្គ, លួចរត់ទៅពីឆ្ងាព្រះចៅដែនកោសល ញុះញង់ព្រះចៅដែនកោសលឲ្យលើកទ័ពចូលមកលុកលុយមាតុភូមិវិញ ។

ជនអកតញ្ញូអាក្រក់ក្រៃ ស្មែងរកគោសលតែរំជាជម្មតា
គោះបីគេឲ្យភូមិថ្កើងថ្កា នៅក្នុងទ្វីបាត្រចាំងអស់ ។
យ៉ាងនេះក៏ដោយតង់មិនអាច ធ្វើចិត្តកំណាចអសប្បុរស
ឲ្យបានតែកយសប្បាយស្រស់ ចំពោះរបស់នោះបានឡើយ ។
បក្សីក្បត់ជាតិមាតុភូមិឯង រឹងតែចំណែងខ្លួនគ្មានស្បើយ
ប្រៃគ្រោងការណ៍ថ្នមឯទៀតហើយ មិនឈប់ឈានឡើយអំពើក្បត់ ។
ជនអកតញ្ញូខ្មែរអន្ធពាល ថ្នមធំពាសវាលំណាយវង្ស
ព្រះប្រិយមិត្តាក្សត្រទ្រង់អំណត់ ទន្ទឹមតបតមានមេត្តា ។
ខ្លួនាន់ប្រដៅប្បាប់ក្រមក្រឹត្យ ឲ្យឈប់ប្រព្រឹត្តឥច្ចាចារ
ហើយទ្រង់អភ័យខ្លួរគោសា ឲ្យធ្វើពជការក្រាក់ទៀមាន ។
ព្រះពជហឫទ័យដ៏ត្រជាក់ រកនរណាម្នាក់ប្រដូចគ្មាន
បក្សីអន្ធពាលនៅតែហ៊ាន រុកពនក្បត់ទៀតមិនអៀនខ្មាស ។
ពេលពត្រីស្ងាត់ជិតអង្រែត្រ ជនពាលក្បត់ជាតិត្រូវព្រោតប្រាស

ចោលប្រពន្ធកូនចៅដេរជាស រត់ប្រាសចៅផ្រែកជាតិដទៃ ។
ប្រឹងប្រែងស្ទុះស្ទែងទំដើរដល់ ប្រទេសកោសលគិតរំពៃ
លក់ខ្លួនបំរើជាតិដទៃ ចិត្តគិតមមៃតែរឿងក្បត់ ។
ចូលចៅក្រាបថ្វាយបង្គំតាល់ ព្រះចៅទ្រង់ស្គាល់ពិតប្រាកដ
ព្រះចៅជាម្ចាស់កោសលរដ្ឋ មហាក្សត្រទ្រង់ខ្ពតបើកឆ្ងាវ ។
ថា «លោកបណ្ឌិតកាឡ - បក្សី មកមានការអ្វីបួរបរបា
ប្រាប់មកឆាប់ៗឥឡូវ៉ៃ៉ា មានខ្មែរម្តេចម្តាត់បួចឬធំ ? » ។
រីឯនអន្ធតាលអតតញ្ញា លើកដៃគាំងគួថ្វាយបង្គំ
ទូលថា «ព្រះចៅអំណាចធំ ទូលព្រះបង្គំសុំស្នើការ ។
ដ្បិតព្រះចៅក្រុងពារាណសី ស្តេចទ្រង់ខន្តីរឿនធម៌អាច
ខំខ្មែកបំរុងពុទ្ធសាសនា ដោយគ្មានប្រាថ្នាការលោភីយ ។
សូមទ្រង់បញ្ជាតលតិចតួច ចូលចៅក្រុងកុំប្រណី
រីឯកសម្បត្តិពារាណសី ខ្ញុំឯង្គើងចារមីល្បីខ្លួនឯង » ។
ព្រះចៅកោសលទ្រង់ស្រុះស្រួល មានព្រះសម្រួលឮក្អាកក្អាយ
ថា «លោកបណ្ឌិតពិតប្រាជ្ញប្រាយ យើងចូលកំចាយមិនបានទេ ។
ពារាណសីជាពជនានី នៃដែនគាស៊ីល្បីមានរេហ៍
សេនាច្រើនណាស់លើសលើគេ មិនខន់ខ្លាយពុំលោកបណ្ឌិត» ។
ជនតាលក្បត់ជាតិនិងសាសា បង្គំទូលថា «ព្រះទ្រង់ជ្ញុំ

សូមទ្រង់ពិសោធន៍ទីឯងពិតឥតឡើយ ទីឯងបានជ្រាបពិតមិនរើមភាម ។
សូមទ្រង់ដឹងញ្ជូនពាលខាងក្នុង ចូលទៅរុកពនបច្ចន្តគ្រាម
ទន្ទ្រានលុកចូលដោយភ្លាម ។ ខាងកោនចាប់ឆ្នាមថ្វាយក្សត្រា ។
ព្រះបាទព្រះមហាស៊ីលវ៉ា: ទីឯងប្រាប់ក្រាក់គោដនាហារ
សមតាមចំណង់ដែលក្រាថ្នា រួចស្រេចហើយណាឲ្យទៅផ្ទះ ។
រឿងក្រាបទូលនេះបើមិនពិត សូមថ្វាយជីវិតសម្តេចម្ចាស់
សូមទ្រង់ពិសោធន៍ឃើញច្បាស់ ពិតប្រាកដណាស់ព្រះចក្រី » ។
ព្រះចៅកោសលញញឹមស្រស់ ចាត់ពាដបុរសចូទ្ធិល្បី
ឲ្យចូលទៅឡោមដែនកាស៊ី កាប់ចាក់វាក់ឃើយកមាសប្រាក់ ។
ខាងកាស៊ីចិត្តក្លាហាន ចូលចាប់ចោរបានគ្នានសល់ម្នាក់
នាំចូលទៅថ្វាយព្រះស៊ីលវ៉ា: ព្រះចៅបញ្ជាក់សួរចោរថា ។
« នែអ្នកខាំងឡាយកុំកិតក័យ យើងអត់ទោសពៃឲ្យគ្រប់គ្នា
ម្តេចអ្នកប្រព្រឹត្តអទិន្នាទាន លួចប្លន់ឲ្យមានខ្លាចថាបា? » ។
ក្រុមចោរបង្គំថា « បពិត្រ សូមព្រះទ្រង់ប្រទីស្តេចទ្រង់ជ្រាប
ទូលព្រះបង្គំក្រជុនជាប លួចប្លន់ដកបរៀងពលំថ្ងៃ ។
បើឈប់លួចប្លន់កូនប្រពន្ធ ទីឯកើតទុក្ខប្លន់ពន់ពេកក្រៃ
អត់ឃ្លាយអត់ទឹកជីវិតក្សីយ កែវៃក្រៅពីនេះពុំបាន » ។
ព្រះបាទព្រះមហាស៊ីលវ៉ា: ប្រទានមាសប្រាក់, ឆ្នាំងដើងក្រាន

ស្រូវខ្លាយដំណើប ចាំនំពែងចាន រថសំដែលចានសុទ្ធសឹងថ្ម ។
ប្រចាននង្គ័លនឹងរនាស់ សម្រាប់ក្លែរកស់ដោយក្រចើ
គោញីគោឈ្មោលនឹងដំរី ចក្រក្រន់ចែកស្មើៗគ្នា ។
ព្រះរាជអំណោយប្រចាននេះចេះ ទើបអង្គុសម្តេចចមរោជា
ស្តេចទូន្មានថា «អ្នកពាល់គ្នា ចូរវៀរវៃកាក្រក់ក្រៃ ។
តាំងចិត្តយកថាសរណៈ ទីពឹងពំនាក់នេះក្រៃ
ព្រះពុទ្ធព្រះធម៌ព្រះសង្ឃថ្លៃ ចាប់តាំងពីថ្ងៃនេះកុំខាន ។
ចូរអ្នកតាំងខ្លាយថែរក្សា បញ្ចសីលាល្អកល្យាណ
ជាកម្មប្រសើរអាចនាំក្រុណា ទៅកើតកន្លង់ស្ថានសួគ៌ចិត្រ ។
ក្រុមចោរតាំងខ្លាយលើកហត្ថា បង្គំទូលថា «ព្រះទ្រង់ប្តូរ
ទូលព្រះបង្គំឈប់ប្រព្រឹត្ត អំពើទុច្ចរិតយ៉ាំងនេះហើយ ។
នឹងយកព្រះរតនៈត្រៃ ពឹងពាក់អាស្រ័យមិនមានឡើយ
ចាប់តាំងពីថ្ងៃនេះទៅហើយ មិនឲ្យមានឡើយព្រះតបុណា ។
ព្រះមហាសីលវរៈស្តេចលែងទៅ ដល់ទីលំទៅត្រង់អាគ្នា
ក្រុមចោរកំចិចរយោគ្រា ចូលដល់សីមាភជាន ។
បង្គំព្រះចៅដែនកោសល ថា «សូមកុំធ្វល់ព្រះចក្រី
ពីរឿងព្រះចៅដែនកាសី ស្តេចទ្រង់ខន្តីនឹងសច្ចៈ ។
កាលទូលបង្គំចូលលុយលុក លួចប្លន់ក្នុងស្រុកបច្ចន្ត:

អ្នកស្រុកមួយគ្នាជារាប់ពាន់ ស៊ុះស្អាក់ចាប់ខ្លួលបង្គំបាន ។
នាំចូលទៅក្រាបបង្គំថ្វាយ មហាក្សត្រឆើតឆាយព្រះទ័យក្លៀវក្លា
ប្រទានមាសប្រាក់កែវ-ប៉ាន់ជាន ចាំងឆ្នាំងដើងក្រានសុទ្ធសឹងថ្មី ។
ប្រទានរួចស្រេចស្តេចចូលខាន ឲ្យធ្វើសីលទានជាប្រក្រតី
រៀបចាកអំពើទុច្ចរិតបី ហើយព្រះបក្រឹចមរណៈជា ។
ព្រះអង្គសន្តោសអនុគ្រោះ អស័យឥតមោះគ្រប់ៗគ្នា
បតិត្រព្រះចៅទ្រង់ឫទ្ធា ! សេចក្តីពណ៌នានេះពិតណាស់» ។
ព្រះចៅមិនដឿស្តេចទ្រង់ល្បឿន ពាសោធប្រើនដងមិនផ្តេសផ្តាស
ទាល់តែឃើញពិតប្រាកដច្បាស់ ទើបត្រាស់ឲ្យកេណ្ឌពលសេនា ។

ព្រះចៅដែនកោសល ឧដ្ឋកាមាត្យក្សត់ជាតិមាតុភូមិ លើកទ័ពចូលភយសំរុកលុកលុយដែនកាសី ពេលនោះលោកមេទ័ពនៃកងសេតុត្តរ-កាតដែនកាសី ចេញបង្ក្រាបកងទ័ពនោះបាន ហើយក្រាបថ្វាយបង្គំទូលព្រះមហាសីលៈពីព្រឹត្តិការណ៍នោះ ឧដ្ឋសុំចេញទៅចាប់ព្រះចៅកោសលយកមកគាំងរស់ តែព្រះចៅកាសីមិនព្រមព្រះពាជានុញ្ញាត ដោយទ្រង់មិនចង់ឃើញនូវការបង្ហូរឈាម ហើយទ្រង់ចង់ប្រដៅស្តេចលោកនោះឲ្យមានសីលធម៌ឡើងដោយសន្តិវិធី ឧដ្ឋព្រះបញ្ញាញាណដ៏មុតថ្លាវេសព្រះអង្គ ។

ព្រះចៅជាម្ចាស់ដែនកោសល ទ្រង់លែងខ្លាយខ្វល់ក្នុងចិត្ត
ស្តេចលើកយោធពលសេនា ចូលវាយប្រហារគ្នានប្រណី ។
ពេលនោះមេទ័ពនាមវិចិត្រ មានឫទ្ធិក្លាខ្លាំងដែនកាសី
ឃើញកងទ័ពខ្មាំងចោរអប្រិយ ចូលឫទ្ធដែនដីយ៉ាងក្លាហាន ។
លោកចំការពារពេញកម្លាំង កំចាត់ពួកខ្មាំងខ្ចាត់ខ្ចោះបាន
ហើយឡើងចូលឧសមហាក្សត្រក្បាន ថា «ចោរឈ្មានគាននឫទ្ធដែនដី។
មេចោរគឺស្តេចដែនកោសល លើកទ័ពមកដល់ជាយបុរី
ជាមួយជនក្បត់ផ្ទៃកាសី ឈ្មោះកាឡ - បក្សីអ្នកនាំមុខ » ។
សម្តេចព្រះមហាសីលវៈ ស្តេចគ្មានផ្អើលភ្ញាក់តើតវិតក្ក
ត្រាស់ថា «លោកសេនាប្រមុខ ពួកខ្មាំងលុយលុកកុតពុះពារ ។
ក្រោថ្នាអ្វី ? យកតាមចិត្ត ចូរកុំតបទ្ធិកុំកាំណត
កុំចាំឆ្លងដែនទឹងពួកវា លើកទ្វារឲ្យចូលតាមហឫទ្ធិយ ។
កងទ័ពព្រះចៅដែនកោសល ជាញាំៗហ៊ុយកលហកដ៏យ
ជាក់ទ័ពបែកខ្ញែកគ្នាខ្ចីឆៃ រត់ចូលពួនព្រៃគាំងតូច - ធំ ។
ព្រះចៅកោសលខ្វល់ខ្វាំងណាស់ ទ្រង់ត្រាស់ឲ្យផ្ទុំត្រែប្រដុំ
ឲ្យមានរត់មកគាំងតូច - ធំ ចូលមកប្រជុំជួរក្នុងព្រៃ ។
ជួបជុំគ្នាហើយពិភាក្សា អំពីស្ថានការណ៍សង្គ្រាមដ៏យ
ជាមួយមេទ័ពទ្វាសកងវៃ ឆ្លាប់មានជោគជ័យក្នុងចម្បាំង ។
ពិភាក្សាស្រេចស្តេចកោសល លើកកងរេហ៍ពលចូលតគាំង

ចូលទៅរហូតដល់ពដាំង គ្មានគូប្រធាំងប្លាំងឡើយណា ។
ព្រះចៅកោសលស្តេចអបលក្ខណ៍ ឃើញព្រះសីលវៈនឹងសេនា
ដែលគ្មានកំហុសគ្មានទោសា សេនាមាត្យគាល់ជាសុខសាន្ត ។
ព្រះចៅកោសលនឹងបក្ស ចូលចាប់មន្ត្រីនឹងក្សត្រក្សាន្ត
នាំយកទៅក្នុងវិត្រស្នាន ដឹកដីកប់ក្រាណាទុកត្រឹមក ។
ឯពលរដ្ឋអកស្រែចំការ តាំងពលសេនាក្នុងនគរ
ឃើញពួកក្សត់ជាតិជាន់បង្ក្ត បង្កើតវឹកវរចលាចល ។
ចាប់ព្រះមហាក្សត្រនឹងមេទ័ព ចងយកទៅកប់, ព្រួយកង្វល់
ប្រុងវាយពួកក្សត់ ស្តេចកោសល តែបានគិតដល់ព្រះបណ្តាំ ។
សម្តេចព្រះមហាសីលវៈ ស្តេចទ្រង់សច្ចៈបានផ្តែផ្តាំ
មិនឲ្យតតាំងពក្រែទៅចាំ ជាពជបណ្តាំមានសីលា ។

— ៤ —

កាលព្រះចៅដែនកោសល នឹងអាមាត្យក្សត់ជាតិ ចាប់ចងព្រះមហាសីលវៈ នឹងសេនាមាត្យយកទៅដឹកដីកប់ទុកត្រឹមកក្នុងវិត្រស្នាន តែដោយព្រះបញ្ញាដ៏មុត នឹងព្រះវិរិយភាពរបស់ព្រះអង្គ ។ បានរួចរស់ព្រះជន្ម ត្រមតាំងសេនាមាត្យតាំងអស់ ។

ព្រះចៅព្រះមហាសីលវៈ ទ្រង់មានសច្ចៈនឹងមេត្តា
ព្រះអង្គត្រូវចុះកន្លងអាជ្ញា នៃមហាក្សត្រាដែនកោសល ។

ទ្រង់ព្រះរាជទានដំបូន្មាន ដល់ក្រុមចាហានមិនឲ្យខ្វល់
ថា «លោកមេទ័ពនឹងរៀបពល ចូរលោកតម្កល់ចិត្តឲ្យស្អាត ។
កុំបង្គំនុំគុំព្រះចៅ គោរពលះចិត្តខ្ចៅនឹងអាមាត្យ
ចូរអ្នកតាំងចិត្តឲ្យល្អស្អាត ផ្សាយដល់ព្រះចាន់គោរពចុះ» ។
ដល់ពេលពួកត្រីយន់យប់ស្ងាត់ ហ្វូងចចកសត្វចោលចម្រុះ
ចូលមកច្រាច្ចាស៊ីសាច់មនុស្ស ដែលជនស្រីប្រុសនាំគ្នាចោល ។
ព្រះមហាស៊ីលវ៉ៈក្សត្រា នឹងពលសេនាយើញស្រមោល
ហ្វូងសត្វចចកកំពុងចោល ចូលចាំងគម្រោលលឿនអស្ចារ្យ ។
ប៉ង់ទាំក្រញ៉ាធ័អង្គច្រាណ ព្រះអង្គក៏ចាន់ស្រែកកម្ចាំ
គំរាមចោលចូលព្រៃព្រឹក្សា តែគ្មាននរណាម្នាក់ដេញចាប់ ។
ហ្វូងសត្វចចកសង្ឃឹយគិត ថា «ពិតជាមនុស្សពេលដល់ស្ងាប់
ចាន់ជាស្រែកហើយមិនដេញចាប់ ស្រាប់តែចាត់ស្លាត់គ្មានឮអ្វី» ។
គិតហើយចចកទំប្រង់ត្រៀត រួមគ្នាមកខៀតសាជាថ្មី
ក្លាហានអង់អាចលែងខ្លាចអ្វី ប្រុងនឹងក្រញ៉ាធ័ឲ្យចាន ។
ព្រះចាន់ស៊ីលវ៉ៈនឹងសេនា ទំស្រែកកម្ចាំងាំក្លាហាន
តែហ្វូងចចកមិនងាកច្រាណ ចូលយាំងក្លាហានមិនរេរា ។
នាយក្រុមចចកជាមេធំ ស្ទុះចូលមកចំព្រះរាជា
ព្រះអង្គខកព្យាស៊ីមិនរួញរា ព្រះចម្រយោធាងើយប្រុងចាំ ។

នាយក្រុមមកដល់សង្កត់ទុក ទីធ្លាព្រះហនុ(១)មិនឲ្យទាំ
កម្ចាំធំខ្លាំងដូចដំរីច្រាំ ត្មៃតទាំមិនបានរំបម្រះ ។
រើខ្លួនមិនរួចរំប្រឹងស្រែក សូរស័ព្ទសម្រែកឮខ្លាំងណាស់
ចចកឯទៀតឮសូរច្បាស់ កិតកង្ហរខ្លាំងណាស់ចោលចូលព្រៃ ។
រីឯនាយក្រុមស្តេចក្តៀបរំធ៉ន រំប្រឹងបម្រះរើយកជីវ
ដើរជិតបួនកកាយដោយកិតកង្ហរ គាល់តែខ្លួនដីរួងយ៉ាងជ្រៅ ។
ព្រះអង្គជ្រាបថាដីធូរហើយ ទ្រង់ពុំកន្តើយស្តេចលែងទៅ
នាយក្រុមរួចខ្លួនចោលសំដៅ ដំរធំព្រៃជ្រៅលែងឃាតក្រោយ ។
ឯអង្គសម្តេចឃ្លាមើសាយ រង្គើកព្រះកាយតាមបណ្តោយ
ដីដែលចចកកកាយឲ្យ ទ្រង់យោងឡើងដោយព្រះហត្ថា ។
ហើយកាយដ៏យកលោកវិចិត្រ មេទ័ពមានឫទ្ធិព្រមសេនា
យកបានគាំងអស់ហើយក្បត្រា ព្រមដោយសេនាប្រថាប់ទៅ ។

- ៥ -

ដោយថាមើរបស់ព្រះមហាសីលវៈ ដែលប្រកបដោយសីលាទិគុណ ព្រះអង្គបានយាងចូលក្នុងព្រះពជបន្ទំព្រះចៅកោសល ដោយឫទ្ធានុភាពនៃមហាយក្ស, ក្នុងកត្រីយប់នោះហើយដែលព្រះអង្គធ្វើសង្គ្រាមសន្ធិវិធីជាមួយព្រះចៅដែនកោសល ញុំាងព្រះចៅដែនកោសលឲ្យស្នេហាសន្ធិភាព-ស្គាល់តម្លៃនៃសន្តិភាពសាកល ។

១- ព្រះហនុ បង្កា ។

ព្រះមហាស័ល្យវ៉ៈកងជា កកាយវោនាពីរណ្តៅ
យកបានអស់ហើយទើបព្រះថៅ ស្តេចប្រថាប់នៅព្រៃស្មសាន ។
ជាមួយនឹងក្រុមសេនាមាត្យ គ្មានអ្វីប្រមាថព្រះអង្គបាន
ព្រះអង្គគង់នៅជាសុខសាន្ត សេនាក៏បានសុខសប្បាយ ។
កុងពេលកត្រីនោះមានយក្ស ពីរនាក់កំពុងតែប្រតាយ
ជណ្តើមសាកសពគ្នាប្រញាយ ប្រទង់ប្រតាយមកញាក់រី ។
យក្សជណ្តើមគ្នាមួយសន្ទុះ ក៏អង្គុយចុះផ្ទាល់ផណើ
និយាយគ្នាថា «យើងទាំងពីរ កុំជណ្តើមស៊ីយ៉ាងនេះណា » ។
នាំតែឈ្លោះគ្នាខាតប្រយោជន៍ ហ៊ានហោចសាច់ខ្ចប់ចង់អស់រា
គួរតែយើងចូលគាល់ក្សត្រា ព្រះនាមព្រះមហាស័ល្យវ៉ៈ ។
ព្រះអង្គទ្រង់សីលល្អបវរ ទ្រង់យុត្តិធម៌ល្អអន់គ្មា
ដូច្នេះត្រូវយើងទាំងពីរនាក់ ទៅកាន់សំណាក់ស្តេចឥឡូវ » ។
យក្សទាំងពីរនាក់បានស្រុះស្រួល បបួលគ្នាសែងសាកសពទៅ
កាន់ទីសំណាក់ព្រះបរមរាជ ដល់ហើយចូលទៅថ្វាយបង្គំ ។
ទូលថា «បពិត្រព្រះស័ល្យវ៉ៈ ខ្ញុំនិងបង្កើតក្តម
សូមទ្រង់ចែកសាច់ឲ្យសមរម្យ ដល់ទូលបង្គំទាំងពីរប្រាណ » ។
ព្រះមហាស័ល្យវ៉ៈទ្រង់ត្រាស់ថា «នែមហាយក្សា! យើងនឹងចែកបាន
តែសំពត់យើងទាំងប៉ុន្មាន ដែលចំពោះទាំងប្រាណរាស្មោកគ្រោក។

ស្មោកគ្រោកក្រខ្វក់ចាំងកាយា ព្រមចាំងអាហារគ្មានថប់កោត
ចាំងគ្មានព្រះទ័ន្ធឬទ្ធីជ័យជោគ កាត់សាច់ជូនលោកចាំងពីរក្រាណា ។
ចូរអ្នកចាំងពីរយកវេរបស់ សត្វគ្រប់ចាំងអស់នេះឲ្យបាន
យើងនឹងចែកឲ្យចាំងពីរក្រាណ ឲ្យស្មើគ្នាបានដូចក្រាថ្នា » ។
ក្រងយកទូចាំងពីរស្ទុះហោះស្ទៅ សំដៅតាពណាសីសីមា
នាំយកទឹកស្អាតអប់ដោយផ្កា នឹងកោដនាហារសប្រពៃ ។
ហើយនឹងសាដក - ផ្តិល - តែងចាំនំ ព្រមចាំងព្រះទ័នពជ្យជោគជ័យ
វេរបស់ប្រណីតល្អប្រពៃ មានអ្នកឈ្មោសវៃច្រកបការ ។
ចាត់ចែងផ្ទៃតផ្ទងំទុកតម្កល់ ថ្វាយស្តេចគោសលនោះឯងណា
យកពីរនាំមកថ្វាយក្សត្រា ព្រះមហាសីលវៈមានបារមី ។
ព្រះអង្គស្រង់ទឹកបួចទ្រង់គ្រឿង រុងរឿងឆើតឆាយផ្សាយស្មើ
ស្តេចសោយព្រះស្ងោយដ៏ថ្លៅឯថ្មី សោយរួចបក្រៃទ្រង់ប្រមាន ។
ជល់សេនាមាត្យនៃព្រះអង្គ គង់គាល់ហង់ដោយស្រេកឃ្មាន
ហេតុតែចារមីព្រះអង្គមាន កងពលគាហានឆ្អែតគ្រប់គ្នា ។
រួចស្រេចទើបស្តេចហូតព្រះទ័ន្ធ ដកចេញមកកាន់ហើយពាជា
កាប់សាច់សាកសពមិនរេក ចែកស្មើៗគ្នាចាំងពីរនាក់ ។
យកទូបរកោតឆ្អែតស្កប់ស្កល់ហើយ ពុំនៅកន្តើយខ្លួនបញ្ជាក់
« បពិត្រព្រះមហាសីលវៈ តើមានធុរៈយ៉ាងណាខ្លះ ? ។

(នៅមានត)

ព្រះអភិធម្មបិដក

(គម្ពីរព្រះមហាបដ្ឋាន)

លោក ប៊ូ-ប៉ូ រៀបរៀង

(តមក)

---

១ -យំ ន៊ិដ្ឋេ ធម្មវេទនីយំ តត្ថ កម្មឯណាដែលសត្វគប្បីបានសោយផលនៃកម្មក្នុងអត្តភាពដ៏ប្រាកដ ដែលខ្លួនបានឃើញ គឺបានសោយផលនៃកម្មឯណាក្នុងបច្ចុប្បន្ន ធ្វើកុសលទំនឹងអកុសលឯណា ។ ក្នុងជាតិណា បានសោយផលនៃកម្មនោះក្នុងជាតិនោះ កម្មនោះឈ្មោះទិដ្ឋធម្មវេទនីយកម្ម ។

ឯទិដ្ឋធម្មវេទនីយកម្មមានពីរស្ថាន គឺឲ្យផលក្នុងកាលមិនយូរប្រមាណប្រាំពីរថ្ងៃម្យ៉ាង ឲ្យផលក្នុងថ្ងៃនោះជាតិនោះ ប៉ុន្តែរកតំណាត់មិនបាន ស្រេចតែឲ្យផលក្នុងបច្ចុប្បន្នជាតិ សូម្បីឲ្យផលក្នុងថ្ងៃទំនិរលត់បញ្ចូលក៏ដោយម្យ៉ាង រួមគ្នាជាពីរស្ថាន ។ ដែលឲ្យផលក្នុងប្រាំពីរថ្ងៃចុះមកនោះ ហៅថាចរិមត្តភាពវេទនីយកម្ម ។ ដែលគ្រាន់ថា ឲ្យតែផលក្នុងជាតិ កាលធ្វើនោះ ហៅថាទិដ្ឋធម្មវេទនីយកម្មប៉ុណ្ណោះ ។

២ - ឧបបជ្ជវេទនីយកម្មនោះ មានភាសអធិប្បាយថា កម្មណាមួយដែលបុគ្គលណាធ្វើទុកក្នុងបច្ចុប្បន្នជាតិ ហើយបានសោយផលនៃកម្មនោះក្នុងលំដាប់នៃភពខាងមុខអំពីបច្ចុប្បន្នជាតិ ។

៣ - អបរាបរិយវេទនីយកម្មនោះ បានន័យថាកម្មដែលបុគ្គលធ្វើក្នុងកន្លងបច្ចុប្បន្ន ។ កម្មនោះមិនបានកំណត់ថានឹងឲ្យផលក្នុងកាលណាទេ ស្រេចតែឲ្យផលក្នុងជាតិណាមួយ សូម្បីឲ្យផលក្នុងអរិសានជាតិ គឺជាតិដែលបានសម្រេចព្រះអរហត្តភាព ក៏ចាត់ឲ្យឈ្មោះថា អបរាបរិយវេទនីយកម្ម ។

កាលបើ « សតិ សង្ឃារវត្តិយា » សង្ឃារប្រែវត្តិទៅមានជាតិបណា ផលនៃអបរាបរិយវេទនីយកម្មនោះ ចេះតែប្រព្រឹត្តទៅជាតិនោះ មិនផុតរលត់អស់ឡើយ ។

៤ - កម្មកម្មនោះ គឺកម្មណាជាកម្មធ្ងន់ កម្មនោះឈ្មោះថា គរុកម្ម ។

៥ - ពាហុល្លកម្មនោះ បានន័យកម្មដែលបុគ្គលធ្វើឲ្យច្រើនក្នុងទ្វន្ទសន្ធាន ។

៦ - យថាសន្នកម្មនោះ បានន័យកម្មដែលសត្វតាំងឡាយធ្វើកន្លងវេលាជិតដល់មរណកាល នឹងកម្មដែលសត្វតាំងឡាយធ្វើក្នុងកាលមុនមក ប៉ុន្តែ បានន័យតម្កល់យកកម្មនោះកន្លងពេលជិតនឹងរលត់បញ្ចក្ខន្ធ ។

៧ - កតត្តាកម្មនោះ គឺកម្មដែលសត្វតាំងឡាយធ្វើដោយមិនបានដឹងថាជាកុសលនឹងអកុសល គឺធ្វើទៅតាមធម្មតា បើវង្សត្រកូលរបស់មាតាបិតាធ្លាប់ធ្វើតាំងដើមមកយ៉ាងណា ក៏ធ្វើទៅតាមយ៉ាងនោះ ។

៨ - ឧឧតកកម្មនោះ ជានឧឆ័កម្មដែលនាំឲ្យកើតបដិសន្ធិ ។

៩ - ឧបត្ថម្ភកកម្មនោះ ជានឧឆ័កម្មដែលតាមចំនុកបម្រុងរក្សាការពារ ។

១០ - ឧបបីឌកកម្មនោះ ជានឧឆ័កម្មដែលតាមបៀតបៀន ។

១១ - ឧបឃាដកកម្មនោះ ជានឧឆ័កម្មដែលតាមសម្លាប់ ។

អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា កម្មនោះចែកចេញជា ១១ ប្រការដោយនិយមដូច្នេះ ។

សេចក្តីអធិប្បាយអំពីកម្ម ១១ ប្រការខាងដើមនេះដោយពិស្តារ

១ - ទិដ្ឋធម្មវេទនីយកម្ម គឺកម្មឲ្យផលក្នុងបច្ចុប្បន្ន ។ កម្មនេះបុគ្គលធ្វើក្នុងជាតិណាឲ្យផលក្នុងជាតិនោះ បើមិនបានឲ្យផលក្នុងជាតិនោះទេ ក៏ជាអហោសិកម្ម គឺគ្មានផលក្នុងជាតិដទៃ ។ ឲ្យផលចំពោះតែក្នុងជាតិនោះ ប្រៀបដូចនាយព្រានម្រឹគ ។ ធម្មតានាយព្រានម្រឹតនោះ កាលចូលទៅកាន់អរញ្ញប្រទេសដ៏ព្រៃហើយ តែងគ្រាច់ផ្លាត់ស្នូរស្វែងរកហ្វូងម្រឹត លុះឃើញម្រឹតហើយក៏ដំរង្គើធ្នូបាញ់ព្រួញសំដៅទៅម្រឹតនោះ តាំងចិត្តថានឹងបាញ់ឲ្យត្រូវម្រឹត ។

សចេ ន វិរុជ្ឈតិ បើព្រួញនោះមិនរៀបមិនខុសទេ លឿន

ទៅត្រូវម្រឹគដូចចិត្តក្រាប់ថ្នាហើយ ម្រឹគនោះក៏ដួលដេកលើពសុធា ។ នាយព្រានចូលទៅចាប់ម្រឹគយកមកពន្ធាត់ស្បែក ១ ឈ្នាង ១ ឈ្នាំ កាំកាត្នា វះនឹងគាំចិតហើយកាប់ចំក្រញ៉ាំងធ្វើឲ្យជាដុំតូចនឹងដុំធំ នាំយកនូវមំសៈសាច់ម្រឹគនោះទៅកាន់គ្រឹស្ថានចំអិនចំរើកគាជាអាហារខ្លួនឯង នឹងចិញ្ចឹមបុត្រភរិយា ។ សេចក្តីដែលនាយព្រានបាញ់ទៅនោះ មិនត្រូវម្រឹគទេ ម្រឹគក៏បណ្ដាសនាការពោលបាត់ទៅ លែងមែរមើលក្រោយ លែងក្រឡេកមើលទិសទាំងពួង ។ សេចក្តីនេះមានឧបមាដូចម្តេច ទិដ្ឋធម្មវេទនីយកម្មនោះ បើមិនឲ្យផលដល់អ្នកធ្វើកុសលជាតិនោះទេ ក៏ទៅជាអហោសិកម្ម មិនបានឲ្យផលកុសលជាតិដទៃឡើយ មានឧបមេយ្យដូច្នោះ ។

ឯទិដ្ឋធម្មវេទនីយកម្មនោះ ជាកុសលក៏មាន ជាអកុសលក៏មាន សំដៅយកត្រង់ឲ្យផលកុសលបច្ចុប្បន្នជាតិនោះឯង ឈ្មោះថា ទិដ្ឋធម្មវេទនីយកម្ម ។

តត្រិទំ ឯឧស្សាំ ព្រះអដ្ឋកថាចារ្យនាំយករឿងមកសំដែងទុកឲ្យឃើញផលនៃទិដ្ឋធម្មវេទនីយកម្មជាចំណែកកុសលនឹងអកុសល ដូចតទៅនេះ៖

ផលនៃទិដ្ឋធម្មវេទនីយកម្មជាចំណែកកុសល

ភគវតោ កាលេ ចានព្ភរឿងមកថា កុដិនគរេជគ្រឹះមានមនុស្ស

កំសត់ទុគ៌តម្នាក់ឈ្មោះបុណ្ណៈ ជាទាសៈនៃបុណ្ណកសេដ្ឋី ទៅភ្ជួរស្រែតែរៀងរាល់ថ្ងៃ ។ ឯភរិយាជាអ្នកចាត់ចែងកោជនាហារយកទៅឲ្យបុណ្ណទាសៈជាស្វាមី ។ ថ្ងៃមួយ ព្រះសារីបុត្តត្ថេរចេញពីនិរោធសមាបត្តិ ហើយពិចារណាមើលនូវតិកិច្ចាវារ ឃើញថាភរិយានៃបុណ្ណទាសៈមានសទ្ធាជ្រះថ្លាអាចសង្គ្រោះបាន លុះសង្គ្រោះរួចហើយ បុណ្ណទាសៈនឹងបានធ្វើសេដ្ឋី ឃើញច្បាស់ដូច្នោះហើយ ក៏យុំចីវរកាន់បាត្រទៅកាន់តិកិច្ចាវារតាមមាគ៌ាដែលភរិយានៃបុណ្ណទាសៈដើរមក ។ ឯរំ ឯស្វាភរិយានៃបុណ្ណទាសៈបានឃើញព្រះថេរៈហើយក៏កើតចិត្តសទ្ធាជ្រះថ្លា ទើបបង្អែនអាហារដែលយកទៅដូនស្វាមីនោះប្រគេនជាបិណ្ឌបាតទាន ហើយត្រឡប់មកចាត់ចែងចំអិនអាហារជាថ្មីទៀត ពាល់តែយឺតយូរដំណើរជ្រុលដល់ពេលរសៀលទើបទៅដល់ស្វាមី លុះដល់ហើយប្រាប់ស្វាមីថា បានជាខ្ញុំមកយឺតយូរដល់ពេលវេលារសៀលយ៉ាងនេះ ព្រោះហេតុខ្ញុំយកអាហារដែលយកមកដូនអ្នកនោះ ប្រគេនជាបិណ្ឌបាតទានដល់ព្រះសារីបុត្តេរជាម្ចាស់ រួចហើយត្រឡប់ទៅផ្ទះវិញជណ្តើរបាយជាថ្មីទៀតយកមកដូនអ្នក គោជនាហារដែលខ្ញុំធ្វើទាននោះឈ្មោះថាជារបស់អ្នក សូមអ្នកចូលអនុមោទនាទានទោះចុះ ។ បុណ្ណទាសៈឮពាក្យភរិយាប្រាប់ដូច្នោះហើយ ក៏មានចិត្តជ្រះថ្លានិយាយថា «សាធុ» ប្រពៃហើយ ។ កាលបើគោជនាហារបួចស្រេចហើយទៅភ្ជួរស្រែទៀត អាចម៍បំណះនោះ

តិក្ខាយជាមាសតាំងអស់ ។ បុណ្ណកាសៈនាំយកសេចក្តីនេះទៅក្រាបទូលព្រះមហាសត្វ ។ ក្រោសទ្បែកជបុរសទៅដង្ហែនយកមក ហើយទ្រង់ព្រះសព្រះកជទានដំណែងសេដ្ឋីដល់បុណ្ណកាសៈនោះ ឈ្មោះថាមហាធនសេដ្ឋី ។

បុណ្ណកាសៈបានដំណែងសេដ្ឋីនេះ ដោយផលនៃកុសលកម្មជាទិដ្ឋធម្មវេទនីយ ។ ហេតុនោះ ទិដ្ឋធម្មវេទនីយកម្ម ទើបចាត់ជាបច្ចុយ្យសង្គ្រោះចូលក្នុងគម្ពីរព្រះមហាបដ្ឋានអនន្តរនីយ ។

ទិដ្ឋធម្មវេទនីយកម្មចំណែកខាងអកុសល

អកុសលកម្មេ បន ទិដ្ឋធម្មវេទនីយកម្មំ នេតំ ឆន្នំ តោយាជកស្ស វិយ សាវត្ថិយំ នច្ចោ ជាម តោយាជតោ អហោសិ ។

លំដាប់នេះ សូមសែដ្ឋនាក្នុងកម្មបច្ចុយ្យ អធិប្បាយទៅទិដ្ឋធម្មវេទនីយកម្មខាងអកុសលតទៅ ដំណើរសេចក្តីថា អកុសលកម្មេ បន កំឯក្នុងទិដ្ឋធម្មវេទនីយកម្មជាចំណែកខាងអកុសលនោះ ទិញាតំ នេតិ អកុសលកម្មណាឲ្យផលយើញជាក់ស្តែងក្នុងកាលបច្ចុប្បន្ន អកុសលកម្មនោះឈ្មោះថាទិដ្ឋធម្មវេទនីយកម្ម ។ ឯការដែលឲ្យផលនោះមិនខុសពីទិដ្ឋធម្មវេទនីយកម្មខាងកុសលទេ ប្លែកតែឲ្យផលជាទុក្ខប៉ុណ្ណោះ ។ ចំណែកខាងទិដ្ឋធម្មវេទនីយកម្មជាកុសលឲ្យផលជាសុខ ប៉ុន្តែ ឲ្យផល-

ក្នុងបច្ចុប្បន្នជួចគ្នា ។ ចិដ្ឋធម្មវេទនីយកម្មខាងកុសលនោះ មានអត្ថជួបពោលមកហើយខាងដើម ។ ឯចិដ្ឋធម្មវេទនីយកម្មខាងអកុសលជួចជាអកុសលកម្មនៃនាយនន្ទូគោឃាដក៍ ។

រឿងនាយនន្ទូគោឃាដក៍

សាវត្ថិយំ ឧទ្ទោ នាម សេចក្តីថា មានបុរសម្នាក់ជាអ្នកសម្លាប់គោលក់ជូរចិញ្ចឹមជីវិតខ្លួនព្រមទាំងបុត្រនឹងភរិយា។ នាយគោឃាដក៍នោះមានឈ្មោះថា ឧទ្ទៈ ។ បណ្ណាសវិស្សឆ៍ នាយនន្ទូគោឃាដក៍នោះធ្វើនូវបាណាតិបាតអស់ហាសិបឆ្នាំ ។ ថ្ងៃមួយ នាយគោឃាដក៍នោះគ្មានសាច់បរិភោគជាមួយភោជនាហារក៏កើតចិត្តក្រោធឡើង ឆក់បានកាំបិតស្ទុះចេញទៅខាងក្រោយផ្ទះ ហើយអារអណ្តាតគោទាំងរស់យកមក ឲ្យភរិយាអាំងលើរងើកភ្លើង ។ ចំណែកនាយនន្ទូគោឃាដក៍នោះអង្គុយចាំ ។ សា បចិត្វា ភរិយាអាំងឆ្អិនហើយក៏យកមកដាក់ក្នុងបាននៅជនាហារ។ នាយនន្ទូគោឃាដក៍នោះឆ្ងាប់តែបរិភោគបាយជាមួយសាច់ជានិច្ចកាល ។ បើថ្ងៃណាគ្មានសាច់ គាត់មិនបរិភោគអាហារទេ ។ លុះនាងភរិយាយកសាច់អណ្តាតគោមកឲ្យ នាយគោឃាដក៍ក៏ប្រៀបធៀបចំបរិភោគអាហារក្នុងថ្ងៃនោះ ។ គ្រាន់តែគាត់ពិសាសាច់អណ្តាតគោទៅក្នុងមាត់ក្តាមមិនទាន់ទាំងលេបផង អ្នកលេងយោ ជិទ្ធិត្វា អណ្តាតនៃនាយគោឃាដក៍ ក៏ដាច់ត្រឹមតែរលំហើយធ្លាក់ចុះក្នុងបាននៅជាយ ។ នាយនន្ទូគោ

ឃាដក៍ជានសោយផលដែលខ្លួនធ្វើ ។ សោ វិវេណ្ដោ នាយនន្ទគោ ឃាដក៍នោះជានសោយនូវទុក្ខវេទនាដ៏សាហ៊ស្ទាំងក្លា ស្រែកភ្ញាំងភ្ញាំងដូចជាសម្លេងគោកេង លុះរលត់បញ្ចក្ខន្ធហើយក៏ទៅកើតក្នុងអវីចិមហានរក ។

អ្នកប្រាជ្ញគប្បីចូលចិត្តថា អកុសលទឡ្ហផលដូច្នេះ ក៏ចាត់ជាទិដ្ឋធម្មវេទនីយកម្មខាងអកុសល តើជានសោយផលឃើញជាក់ស្តែងក្នុងបច្ចុប្បន្ន ។

ឯទិដ្ឋធម្មវេទនីយកម្មខាងអកុសលទឡ្ហផលខាងហន់នោះ ពុំមែនមានតែនាយនន្ទគោឃាដក៍ម្នាក់ប៉ុណ្ណោះទេ នៅមានជាច្រើននាក់ទៀត ដូចខ្ញុំយកឈ្មួញប្រហារព្រះសិរព្រះសារីបុត្តមហាថេរ ។ អកុសលកម្មនោះក៏ភាប់ចូលក្នុងទិដ្ឋធម្មវេទនីយ ទៅកើតក្នុងអវីចិ ដោយប្រថពីញែកឡែចខ្នោះស្រួចចុះទៅ ទីឯនាឯចិញ្ចាមានរៃអាំ និយាយប្រមាថមើលងាយតិះដៀលដោយសំដីមិនពិត ក្លែងខ្ញុំម្នាក់ទោសចំពោះអង្គសម្តេចព្រះពុទ្ធជាម្ចាស់ក៏ជានសោយផលនៃអកុសលកម្មជាទិដ្ឋធម្មវេទនីយ ដូចមានសេចក្តីតទៅនេះ ។

(នៅមានត)

សម្តេចព្រះធម្មលិខិត ស្រ៊ុ ឯម រៀបរៀងរៀន

(តមក)

១- សីវលិត្ថេរវត្ថុកថា

សំដែងរឿងនិទានព្រះសីវលិត្ថេរតទៅទៀត ដោយភាសាលីថា ឥតោ កិរ កប្បសតសហស្សមត្តកេ ជាដើម អធិប្បាយថាបានឮរឿង។ មកថា ក្នុងទីបំផុតមួយសែនកប្ប មុនកប្បយើងនេះ មានព្រះសាស្តាតាវមួយព្រះអង្គទ្រង់ព្រះនាមបទុមុត្តរៈ ទ្រង់ត្រាស់ដឹងឡើងក្នុងលោក ទ្រង់ញុំាងសត្វលោកតាំងឡាយ ឲ្យបានត្រេកអរក្នុងវត្ថុគឺអម្រឹតគឺអមតមហានិព្វាន ដោយព្រះធម្មទេសនារបស់ព្រះអង្គ។

មានសម័យមួយនោះ ព្រះមានព្រះភាគទ្រង់គាំងកិក្ខុមួយរូបដែលបានទៅអកិញ្ចាគាំង ៦ ក្នុងអគ្គដ្ឋានទីដ៏ប្រសើរជាងសាវកគាំងពួង ក្នុងទីប្រជុំនៃបរិស័ទព្រមគាំងស្តេចក្នុងនគរហំសវតី ។

កាលនោះ ព្រះបរមក្សត្រព្រះអង្គបានទតឃើញសាវកនោះហើយ ព្រះអង្គមានប្រាថ្នាចង់បានទីអគ្គដ្ឋាននោះ ទើបថ្វាយមហាទានដល់ព្រះភិក្ខុសង្ឃមានអង្គព្រះសម្មាសម្ពុទ្ធជាប្រធាន ហើយក្រាបបង្គំទៀបព្រះបាទានៃព្រះមានព្រះភាគ តាំងប្រាថ្នាយកទីសាវកនោះឯង ។

ឯព្រះបទុមុត្តរសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់ជ្រាបហេតុនោះជាក់ច្បាស់ហើយ ទ្រង់ព្យាករណ៍ទំនាយចំពោះព្រះបរមក្សត្រនោះថា បពិត្រមហាពជ អំណើះតទៅឯអនាគតកាល ព្រះអង្គនឹងបានសម្រេចនូវដំប្រសើរនោះ ក្នុងសាសនានៃព្រះមានព្រះភាគទ្រង់ព្រះនាមសមណគោតមដោយពិត ។

លុះព្រះបរមក្សត្រ បានស្តាប់នូវព្យាករណ៍នោះហើយ ក៏មានព្រះទ័យជ្រះថ្លារីករាយ ចំណាយព្រះពជនូវព្យាធ្លើបុណ្យទាំងឡាយច្រើនប្រការ ជាបជល់អស់ព្រះជន្មក៏ទ្រង់ទៅកើតទៅ បានឡើងទៅកើតក្នុងស្ថានសួគ៌ទេវលោកនាយ សោយនូវសម្បត្តិជាសុខក្សេមក្សាន្ត អស់កាលជាអង្វែងយូរ ។

លុះដល់ចំណោមកាលក្រោយ ទេវបុត្តនោះក៏ច្យុតចុះមកអំពីទេវលោក បានទៅកើតជាសេដ្ឋីបុត្ត ក្នុងនគរពោធិសី បានបំរើគោរពប្រតិបត្តិព្រះបច្ចេកពុទ្ធមួយព្រះអង្គ ដោយបច្ច័យទាំងបួន ជាបជល់អស់ជីវិត ហើយបានឡើងទៅកើតក្នុងស្ថានទេវលោកវិញ បានសោយនូវទិព្វសម្បត្តិដ៏ប្រសើរ លុះមកដល់ពុទ្ធកាលនៃព្រះមានព្រះភាគទ្រង់ព្រះនាមវិបស្សី ក៏បានចុះមកកើតក្នុងត្រកូលដ៏ស្តុកស្តម្ភមួយ មានឈ្មោះពុំប្រាកដ ក្នុងនគរពន្ធុមតី ថ្ងៃជាខាងក្រោយទៀត កុលបុត្តនោះបានស្តាត់ទៅក្នុងលទ្ធិជាសេនាគុត្តាមាត្យ តែងធ្វើនូវកថាជជែកថ្វាយព្រះបរមក្សត្រក្នុង

សម័យនោះឯង ។

កាលនោះ ពួកទេវបុត្រទេវធីតាទាំងប៉ុន្មានដែលស្ថិតនៅក្នុងនគរ
បានតាំគ្នាបួលទៅកាន់សំណាក់ព្រះពុទ្ធវិបស្សីសម្មាសម្ពុទ្ធជាម្ចាស់ បាន
លើកដៃឡើងនមស្សការថ្វាយបង្គំអាកាងាទិមន្តថា: បពិត្រព្រះអង្គដ៏ចំ-
រើន សូមព្រះមានព្រះភាគព្រមទាំងព្រះសង្ឃជាសាវក ធ្វើនូវសេចក្តី
អនុគ្រោះចំពោះខ្ញុំព្រះអង្គទាំងឡាយ សូមទទួលទានមន្តន៍ដើម្បីភត្តាហារក្នុង
ថ្ងៃស្អែក រួចហើយក៏ចាត់ចែងថ្វាយមហាទានសឹងមានចិត្តព្រមព្រៀងគ្នា
ទាំងអស់ បានចំណាយទ្រព្យកសាងធ្វើមហាបរិវេណមួយ លុះបានធ្វើរួច
ស្រេចក៏ចាត់ចរិច្ចាគមហាទានធ្វើបរិវេណនោះ ហើយប្រឹក្សាគ្នាថា កុងកេង
ទានយើងទាំងឡាយ មិនត្រូវពោលថាវត្តនោះមិនមានដូច្នេះឡើយ លុះ
ប្រឹក្សាគ្នារួចហើយ បានចាត់ចែងនូវទេយ្យទានគ្រប់ជំពូក បានរមិលមើល
នូវកេងទានឃើញថាខ្វះខាតស្រស់ទឹងឆ្កឹតឃ្មុំផ្លិត ទើបហៅបុរសទាំងឡាយ
ជាសមាជិកឲ្យបួលមក បានប្រគល់ក្រាក់មួយពាន់កហាបណៈ ហើយ
បញ្ជូនឲ្យទៅកេងដោយពាក្យបណ្តាំថា: អ្នកទាំងឡាយត្រូវតែដើរទៅស្វែង
រកទិញទេយ្យទានស្រស់ទឹងឃ្មុំផ្លិតឲ្យខានតែបាន ហើយនាំយកមកឲ្យឆាប់ ។

ឯបុរសអ្នកបំរើនោះបានទទួលយកក្រាក់មួយពាន់កហាបណៈហើយ
ដើរត្រាច់ទៅតាមផ្លូវទេទីឆ្ងាយក្នុងទីនោះ ។ បានឈរនឹងចាំទៅទៀប
ខ្នោះទ្វារស្រុក ។

គ្រានោះ សេនាគុត្តាមាត្យ ចានយកទង់ទីឆ័ងយ៉ាងប្រមុនទីឆ័ងនាំចូលទៅកាន់សំណាក់ព្រះបរមក្សត្រ ក៏ចានទៅដល់ទ្វារស្រុកនោះដែរ ។

លំនោះ បុរសអ្នកទិញតាំងឡាយ ចានឃើញទង់ទីឆ័ងយ៉ាងហ៊ោយ ក៏និយាយអង្វរសុំទិញថា: បពិត្រអ្នកដ៏ចំរើន សូមអ្នកទទួលយកកហាបណៈមួយអំពីទៀ ហើយលក់ទង់ទីឆ័ងនេះឲ្យមកយើងតាំងឡាយវិញចុះ ។ ឯសេនាគុត្តាមាត្យក៏ពុំព្រមលក់ឲ្យឡើយ បុរសតាំងនោះដេញថ្លៃឡើងតាំងពីតឹកហាបណៈឡើងដល់មួយតានកហាបណៈ ក៏តទំសេនាគុត្តនោះពុំព្រមលក់ឲ្យឡើយ ។

ទើបសេនាគុត្តាមាត្យ ត្រឡប់សួរបុរសតាំងនោះវិញថា: អ្នកតាំងឡាយអង្វរយើងសុំទិញវត្ថុមានតម្លៃតិច ហើយបង្កើនឡើងឲ្យច្រើនហួសប្រមាណ តើអ្នកតាំងឡាយត្រូវការយកវត្ថុនេះទៅធ្វើអ្វី ? បុរសតាំងនោះចានឆ្លើយប្រាប់ហេតុនោះសព្វគ្រប់ថា យើងតាំងឡាយត្រូវការយកវត្ថុនេះទៅចាត់ចែងធ្វើទានឲ្យគ្រប់មុខ ដើម្បីថ្វាយដល់ព្រះកិកុសន្ធមានអង្គព្រះសម្មាសម្ពុទ្ធជាប្រធានដោយពិត ។

ឯសេនាគុត្តាមាត្យ លុះចានស្តាប់ហើយក៏មានចិត្តសោមនស្សជ្រះថ្លាទើបនិយាយថា បើដូច្នោះ ខ្ញុំនឹងឲ្យដល់អ្នកឥតយកថ្លៃឡើយ លុះថាហើយក៏ចានផ្សំដោយវត្ថុតាំងឡាយ មានស្ករក្រាម ទឹកឃ្មុំនឹងជាដើម ព្រមតាំងវត្ថុដទៃទៀតមានដំរេនជាដើម នាំចូលទៅកាន់ភេងាន

នោះឯង ។ ដោយអានុភាពនៃព្រះសាស្តាចារ្យជាម្ចាស់ ពេជ្ឈនិងចឹតយ៉ាប៉ុណ្ណោះកំលុងគ្រប់គ្រាន់ដល់កំកុសង្ឃ ៦ លាន ៨ សែនអង្គ ដែលមានព្រះពុទ្ធជាប្រធានដោយពិត ។

ដល់មកកាលជាខាងក្រោយ ហេតុតែបុញ្ញកម្មនោះ ទើបសេនាគុត្តាមាត្យនោះអន្ទោលទៅមកក្នុងស្ថានមនុស្សនិងស្ថានទេវតា សោយទិព្វសម្បត្តិអស់កាលជាអម្ចឹងយូរ ដល់មកខាងក្រោយទៀត ក្នុងកាលនៃព្រះមានព្រះភាគជាម្ចាស់នៃយើងទាំងឡាយ ព្រះអង្គបានត្រាស់ឋវមាកិសេកសម្ពោធញ្ញាណហើយ ទេវតានោះក៏ច្យុតចុះពីកស្ថានសួគ៌ទេវលោកមកាយ ហើយចាប់បដិសន្ធិក្នុងផ្ទៃនៃនាងទេវីឈ្មោះសុប្បិយា ជាអគ្គមហេសីនៃស្តេចមហាលិច្ឆវីក្នុងកោលិយនគរ ។

ឯកុមារនោះសោត បានឋិតនៅក្នុងផ្ទៃព្រះមាតាកំណត់ ៧ ឆ្នាំ ៧ ខែ ដល់ពេលនឹងប្រសូតទៀត ក៏វង្វេងក្នុងផ្ទៃព្រះមាតាប្រសូតចេញពុំរួច សោយទុក្ខវេទនាជាខ្លាំងអស់ ៧ ថ្ងៃទៀត ។ លុះព្រះរាជកុមារនោះបានប្រសូតចេញចាកផ្ទៃនៃព្រះមាតាមកហើយ ព្រះរាជវង្សានុវង្សទាំងឡាយក៏បានថ្វាយព្រះនាមថា សិរិលិកុមារក្នុងកាលនោះឯង ។

បានឮមកថា សិរិលិកុមារនោះ កាលពីមុន បានកើតជាស្តេចក្នុងអតីតកាលកន្លងទៅយូរណាស់ហើយ បានធ្វើសង្គ្រាមជាមួយនឹងស្តេចជាសត្រូវនឹងខ្លួន បានប្រឹក្សាជាមួយនឹងព្រះមាតារបស់ព្រះអង្គ ដើម្បីនឹងចាប់

យកនគរនោះឯង ។

ឯព្រះមាតាក៏ចាន់ប្រាប់ទៅប្តាយថា បើកូនត្រូវការនឹងចាប់យកនគរនោះឲ្យបានដោយងាយ ត្រូវតែកូនចាត់ពលសេនាទាហានឲ្យបិទខ្ទាសនគរតូច-ធំ កុំឲ្យមនុស្សចេញចូលមកយកស្បៀងអាហារបានឡើយ ទើបកូនអាចនឹងចាប់យកស្តេចជាសត្រូវបានឥតមានលំបាកអ្វីឡើយ ។

ចំណែកស្តេចនោះសោតក៏បានចាត់កងទ័ពឲ្យទៅបិទខ្ទាសតូច ។ នៃនគរតាមការប្រឆាំងព្រះមាតានោះ ហើយអាចចាប់យកស្តេចជាបច្ចាមិត្តឲ្យស្រុះក្នុងអំណាចខ្លួនបាន ដោយទៅប្តាយនោះឯង ។

ដោយកំឡាំងបាបកម្មនោះហើយ បានជាសេចក្តីទុក្ខលំបាកយ៉ាងធំនេះកើតឡើងប្រកាសជជល់មាតានឹងបុត្តដាំងពីនោក់ដោយប្រការដូច្នេះ ។

នៅវេលាមុនដែលព្រះមាតាប្រឆាំងនឹងប្រសូតបុត្តនោះ ព្រះនាងបានទឹកលើកនូវព្រះមានព្រះភាគឿយ ។ ដរាបដល់ថ្ងៃជាគំរប់ប្រាំពីរ ទើបអាចប្រសូតបុត្តនោះបានដោយងាយកងឯកាលនោះហោង ។

លុះព្រះនាងបានប្រសូតបុត្តរួចហើយក៏មានចិត្តត្រេកអរ បានចាត់ចែងថ្វាយមហាទានដល់ព្រះកិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ក្នុងថ្ងៃជាគំរប់ប្រាំពីរនោះដែរ ។

លុះថ្ងៃជាខាងក្រោយ សិរីលិកុមារនោះបានចេញទៅអំពីគេហស្ថានក្នុងកាលដែលខ្លួនមានអាយុប្រាំពីរខ្នាំហើយ បានយើញព្រះសាស្តាចារ្យ

ជាម្ចាស់តំកើតសទ្ធាជ្រះថ្លា ហើយទូលអង្វរសូមផសកង្គំសំណាក់ព្រះអង្គ នាកាលនោះឯង ។ ឯសម្តេចព្រះបរមគ្រូសាស្តាចារ្យជាម្ចាស់ ទ្រង់ប្រគល់សិរិលិកុមារនោះដល់ព្រះសារីបុត្តត្ថេរឱ្យបំបួស ។ នៅវេលានោះ សិរិលិកុមារមានព្រះសារីបុត្តត្ថេរជាព្រះឧបជ្ឈាយ៍ មានព្រះមហាមោគ្គល្លានត្ថេរជាឧភតោចារ្យ ប្រជាជនមិនយូរ ហើយបំបួសជាសាមណេរក្នុងកាលនោះឯង ។

ឯសិរិលិសាមណេរនោះ កំពុងសំរេចព្រះអរហត្តកំពង់ខ្ចប់ចង់ខ្ចូរកិលេសតាំងពីខើបចង់តោរសក់រួចជាដំបូងម្ល៉ះ ចូនញ៉ាំងព្រះពុទ្ធសាសនាឲ្យភ្លឺស្វាងរុងរឿងផ្សាយទៅក្នុងលោក ។ សិរិលិសាមណេរនោះ មានប្រុញ្ញច្រើន ជាអរហន្តប្រសើរលើសជាងសាវ័កពាន់ឡាយដែលចូនខ្ចូរអភិញ្ញាពាន់ប្រាំមួយ ដោយអានុភាពនៃបុណ្យដែលខ្លួនចូនធ្លើមកពីក្នុងអតីតកាលដោយពិត ។

លុះដល់សម័យជាខាងក្រោយតមកទៀត ព្រះមានព្រះភាគ ទ្រង់យាងទៅកាន់ខេត្តវេនវិហារ ដើម្បីធ្លើកិច្ចទស្សនាខ្ចូរព្រះវេតត្ថេរ ហើយព្រះអង្គគ្រាប់ខ្ចូនផ្លូវខ្ចាយជាច់ស្រយាល ជាផ្លូវអត់ចាយ អត់ខឹកពន់ពេកមានចម្ងាយ ៣ យោជន៍ ជាមួយនឹងព្រះសង្ឃជាសាវ័កចំនួនអង្គ ។

ក្នុងខណៈនោះ ខេវតាតាំងឡាយ សឹងមានចិត្តជ្រះថ្លាចំពោះព្រះសិរិលិត្ថេរជាយូរច្រើន ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទ្រង់ធ្លើព្រះ

សីវលីត្ថេរឲ្យជាមគ្គុទ្ទេសក៍អ្នកនាំមុខ ព្រះអង្គឈប់សំណាក់អាស្រ័យក្នុងព្រៃហរិតវដែលខៅតាំងឆ្ងាយ ខិមិត្តប្រគេនដល់ព្រះសីវលីត្ថេរនោះបានសោយបានបរិភោគនូវខេយ្យទានដែលខៅតាំងឆ្ងាយចាត់ចែងប្រគេនព្រះសីវលីត្ថេរដាល់ដាប់រឿន ។ ៧ ដកបដល់សំណាក់ព្រះវេត្តត្ថេរៗ ព្រះសម្ពុទ្ធទ្រង់បានញ៉ាំងពុទ្ធដំណើរនោះ ។ ឲ្យសំរេច ហើយទ្រង់ត្រឡប់មកកាន់វិហារព្រះជេតពនវិញ ទើបទ្រង់តាំងព្រះសីវលីត្ថេរនោះក្នុងអគ្គដ្ឋានដ៏ប្រសើរជាងសាវកតាំងឆ្ងាយ ខាងឯមានលាភដោយវិសេសជាងសាវកតាំងឆ្ងាយដោយពិត ។

ព្រោះហេតុនោះ បានជាព្រះសីវលីត្ថេរលោកបានពោលនូវព្រះគាថាតាំងឆ្ងាយក្នុងអបទានដូច្នេះថា :

បទុមុត្តរោ ជាម ជិនោ សត្ថវាមុ្ហ ចក្ខុមា
ឥតោ សតសហស្សម្ហិ កប្បេ ឧប្បជ្ជិ នាយកោ
សីលវន្តស្ស អសំខេយ្យំ សមាធិ វជិរូបមោ
អសំខេយ្យ ញាណវរំ វិមុត្តិយ អនោបមា

អធិប្បាយថា ព្រះជិនស្រីទ្រង់ព្រះនាមបទុមុត្តរ ព្រះអង្គមានបញ្ញាចក្ខុ ក្តីប្រាស់ក្នុងធម៌តាំងអស់ ព្រះអង្គជានាយកតែងដឹកនាំសត្វឲ្យផ្តួងផុតចាកសំសារទុក្ខ ទ្រង់បានកើតឡើងក្នុងកប្បមួយសែន មុនអំពីកន្លះកប្បនេះ សមាធិរបស់ព្រះសម្ពាសម្ពុទ្ធជាម្ចាស់ដែលទ្រង់មានសីលដ៏បរិសុទ្ធ មាន

ឧបមាដូចតែវាជាមានគុណច្រើនមិនគប្បីពាប់បាន ។ ញាណដ៏ប្រសើរ
របស់ព្រះអង្គក៏មិនគប្បីពាប់ដែរ តាំងវិមុត្តិរបស់ព្រះអង្គក៏នឹងប្រៀប
ឧបមាពុំបាន ។

មនុជាសុរនាគានំ ព្រហ្មានញ្ច សមាគមេ
សមណព្រាហ្មណាកាស្លោ ឆម្នំ នេសេតិ ជាយតោ
សសាវកំ មហាលាភី បុញ្ញវន្តំ ជុតិន្ធរំ
ឯបេសិ ឯតទគ្គម្ហិ បរិសាសុ វិសារទោ

ព្រះលោកនាយកទ្រង់សំដែងធម៌ទេសនាដល់មនុស្សទេវតានឹងនាគ
តាំងឡាយផង ដល់ព្រហ្មតាំងឡាយផង ក្នុងទីប្រជុំដ៏ច្រឡំៗដោយ
ពួកសមណនឹងព្រាហ្មណ៍ជាច្រើន មិនតែប៉ុណ្ណោះ ព្រះលោកនាយកជា
វីរបុរសដ៏អង់អាច ទ្រង់បានតាំងសាវកមួយអង្គអ្នកមានលាភ មានបុណ្យ
មានឥទ្ធិរស្មីក្នុងទីជាឯតទគ្គប្រសើរវាងឯមានលាភ ឥតមានសាវកណា
ស្មើក្នុងទីប្រជុំបរិស័ទ ។

តទាហំ ខត្តិយោ អាសឹ ឧតវេ ហំសវច្ឆយេ
តំ សុត្វា ដិណ្ឌភិក្ខាំ សាវកស្ស គុណំ ពហុំ
ឯមន្តយិត្វា សត្ថារំ ភោជយិត្វា សសាវកំ
មហាទានំ បិ ទត្វាន តំ ឋានំ អភិបត្ថយិ

កាលនោះ ខ្ញុំកើតជាខត្តិយក្នុងនគរឈ្មោះហំសវតី បានស្តាប់ព្រះពុទ្ធ
ដីកានោះរបស់ព្រះជិនស្រី ដែលទ្រង់បានពោលសរសើរទៅគុណនៃសាវក

មួយអង្គនោះមានប្រមាណច្រើន ខ្ញុំបានទទួលព្រះសម្មាសម្ពុទ្ធព្រមទាំងសាវកបរិស័ទមកឆ្ងល់ចង្ហាន់អស់ ៧ ថ្ងៃ រួចហើយថ្វាយមហាទាន ទៀត ទើបខ្ញុំប្រាថ្នាជាសាវកតាំងពីកាលនោះឯង ។

តទា មំ វន្ទិតុំ ចាគេ ឥស្សាធ បុរិសាសភោ
សោ សវេន មហាឥសៀ ឥទំ វចនមព្រវិ
យោ យំ ទានវរំ ទត្វា ហាឥំ បដ្ឋេតិ ទេត្តិយោ
តេន តស្ស ច តំ ហាឥំ ឯវម្បិ សេ្វ ឯាកតេ

កាលនោះ ព្រះមានព្រះភាគជាវីរបណ្ឌិតដ៏ប្រសើរជាឥសីបុរស ទ្រង់បានទតឃើញខ្ញុំដែលកំពុងក្រាបថ្វាយបង្គំព្រះបាទតាំងគួរបស់ព្រះអង្គ លុះព្រះមានព្រះភាគជាអ្នកប្រាជ្ញដ៏ប្រសើរអង្គនោះបានទតឃើញហើយ ក៏ពោលនូវព្រះពុទ្ធដីកានេះដោយព្រះសូរសៀងដ៏ពីរោះដូច្នេះថា: ព្រះបរមកូត្រអង្គណា បានឲ្យទាននូវភត្តដ៏ប្រសើរ ហើយមានប្រាថ្នានូវឋានសាវកណា ឋានសាវកនោះតង់ទង់សំរេចដល់ព្រះបរមកូត្រអង្គនោះ ដោយផលទានដ៏ប្រសើរនោះក្នុងកាលជាអនាគត ដោយពិត ។

(នៅមានត)

(តមក)

សត្ថិ វេហាយសា បក្ខី ឥត្ថិមន្តោ យសស្សិនោ
តេបិ អាទាយ កន្តេយ្យុំ យស្ស ហោន្តិ តថាវិធា

មហោរគ បពិត្រមហារាជអើយ មានបក្សីមួយមានរំពឹងអនុភាពឈ្មោះគ្រុឌរាជ នោះបានមកហើយនឹងយកមហារាជ ស្ដេចទៅដោយខ្នងផ្លូវអាកាស សមនឹងរួចបានហាង ។

សត្ថិ វេហាយសា យក្ខា ឥត្ថិមន្តោ យសស្សិនោ
តេបិ អាទាយ កន្តេយ្យុំ យស្ស ហោន្តិ តថាវិធា

មហោរគ បពិត្រមហារាជអើយ មានយក្ខមួយមានបារមីរំពឹងអានុភាពឈ្មោះសាគតីយក្ខប្រកបនូវមាយាពន្លាច យក្ខនោះអាចមកនាំព្រះអង្គឲ្យរួចចេញអំពីកណ្ដាប់ដៃនៃសត្រូវចាំងនោះបាន ។

អតីតំ មានុសំ កម្មំ ឧក្កំសំ ឧរកិំសកំ
ន តំ សក្កោមិ មោចេតុំ អន្តលិក្ខេន ខត្តិយាតិ ។

ខត្តិយ បពិត្រមហារាជក្សត្រៃប្រសើរអើយ រឿងពីនឹងធ្វើឲ្យបានចំឡែក ផ្ទែកខ្ញុំលែងមនុស្សនោះនេះ ឃើញជាតម្រពេក ខ្ញុំសោតមិនអាចនឹងនាំមហារាជ ដើម្បីទៅកាន់មិថិលានគរនោះបានឡើយ ។

រាជា តំ សុត្វា អបក្កមិ តុណ្ហី អាសិ ព្រះមហាក្សត្រស្ដាប់ពាក្យពោធិសត្វហើយ មិនអាចដើម្បីនឹងស្រដីតបបានឡើយ ក៏

តដំស្ងៀមនៅនោះហាន ។ អថ សេនគោ ចិន្តេសិ ។ លំដាប់នោះ អាចារ្យសេនកៈគិតថា តួរអញនឹងទូលស្តេច ហើយ អាចារ្យសេនកៈទូលថា មហោសថ បពិត្រមហាពាជកក្សត្រថ្លៃប្រសើរអើយ តំនិតអ្នកដទៃឯណា ក៏នឹងមកដោះមហាពាជ ខ្ញុំអស់យើងតាំងពួននោះឥតអង្គឹមានឡើយ ហើយអាចារ្យសេនកសូត្រជាគាថាពីរបទថា ។

អតីវេលសុ ปุริโส មหาเต พุทธกณฺฑเก
ยตฺถ โส ลภเต ฐานំ ตตฺถ โส วิญฺญเต สุขំ
เอวำ อมฺหญฺ จ ภทฺทนฺเต มหาโสเธ
ภทฺทเสฏฺฐิมหนฺตานำ สเทฺธ อมฺเห ปมาทยำ

មហោសថ ម្នាលថ្លៃមហោសថអ្នកប្រាជ្ញប្រសើរអើយ បុរសឥតតាំងខ្លាយឆ្ងាយសំពៅដ៏កណ្តាលមហាសមុទ្រធំមិនយល់ត្រើយ បើបុរសនោះបានទៅចម្ងល់ចូលទីចំណតឯណាជាសុខហើយ រីបុរសនោះ ក៏មានចិត្តត្រេកអរបានតុំនាក់ជាសុខសប្បាយឮដ៏ប្រសេរនោះហាន ។ មហោសថ ម្នាលព្រះមហោសថអ្នកប្រាជ្ញអើយ បួរអ្នកអាស្រ័យជាឋានតុំនាក់នៃយើង មួយអង្គឹនឹងព្រះមហាក្សត្រ ចៅអើយនេះជាអ្នកប្រាជ្ញប្រសើរខ្ញុំតំនិត ប្រកបមានខ្ញុំប្រាជ្ញារយោបល់យល់អាថធម៌សេចក្តីក្រៃលែងជាងយើងតាំងពួន បួរចៅដោះយើងឲ្យរួចអំពីទុក្ខហាន ។

អថ ំ ឯក្កណ្ឌោ មหาสตฺตោ តាយ អฏฺฐ

ភាសិ ព្រះមហាសត្តដ៏ឆ្ងាញ់ឆ្ងាលសង្កត់សង្កិនទូវអាចារ្យសេនកៈ
នោះស្រេចហើយ កំពោលបញ្ជាក់ដោយបទព្រះគាថាថា៖

អតីតំ មានុសំ កម្មំ ទុក្ករំ ទុរភិសម្ភវំ
ន តំ សក្កោមិ មោចេតុំ តុំ បជានសុ សេនកោតិ ។

សេនកៈ ម្នាលអ្នកអាចារ្យសេនកៈអើយ រឿងអំពើលាមកអាក្រក់ឯ
ណាកន្លងមកនុ៎ះ ធំធេងក្រៃពន់ពួន ទើបធ្វើតបធ្វើទូវអំពើនោះយល់កម្រៃពេក
អញនេះមិនអាចដើម្បីដោះអាចារ្យបានឡើយ ។ ឮដំណាលនោះ
ស្តេចស្តាប់ពាក្យពោធិសត្វហើយ ព្រះមហាក្សត្រ តែមិនយល់អំពើ
ធំដោះឲ្យរួចពុំបានឡើយ ស្តេចធំមានព្រះភរជហឫទ័យ ភ័យអំពី
សេចក្តីស្លាប់មកគម្រាម មិនអាចបន្ទូលទូវព្រះមហាសត្វបានឡើយ
ហើយស្តេចគិតដូច្នេះ អាចារ្យសេនកៈនេះមានកាលដឹងនូវទុក្ខយតិចតួច
អញនឹងដណ្តើងលងមើលហ៎ៈ ហើយស្តេចបន្ទូលទូវគាថាដូច្នេះ ។

សុណោហិ មេ តំ វចនំ បសដ្ឋ សេនំ មហាភូរិ
សេនកានានិ បុច្ឆាមិ កឹ កិច្ចំ តេ ឥធ មញ្ញសីតិ

ម្នាលអាចារ្យសេនកៈអើយ ចូរព្រះស្តែងរំលងមើលទូវសេនា គេមក
ចោមយើងនោះ យើងជាមានភ័យច្រើន អញនឹងដណ្តើងព្រះស្តែង ។ ធំង
ដឹងទុក្ខយកលកំចុះ តំធឹងឲ្យបានយើងរួចចេញអំពីភ័យនៃសត្រូវពាំងនេះ
បានទេហ៎ៈ ។ អាចារ្យសេនកៈស្តាប់ហើយគិតថា ដូច្នេះព្រះមហាក្សត្រ

ដណ្តើង១ជាយនៃអញ ពោះអញយល់ក្តី មិនយល់ក្តី អញនឹងធ្វើយ ១ជាយជានមួយថ្វាយស្តេច តែតដូច្នោះហើយ សូត្រជាបទគាថាដូច្នេះថា។

អត្តិ ភ ទ្វារតោ នេម តណ្ហាមូលសេ វិកប្ផនំ
អញ្ញមញ្ញំ វិនិត្វាន ទិប្បំ ហាសញ្ជម ជីវិតំ
មា នោ ភជា ព្រហ្មទត្តោ ចិរំ ទុក្ខេន មារយីតិ ។

ទេវ បពិត្រមហាកដអើយ រ១ជាយមួយនោះ យើងនឹងកាំងទ្វារឲ្យខ្ជាប់ហើយអុជភ្លើង មួយនិសោត យើងនឹងយកជាវល់តែងប្រគាប់សម្លាប់គ្នាទៅវិញទៅមក នោះយល់ជាស្លាប់ធាប់ ប៉ើស្តេចពុទ្ធនិត្រហ្មទត្តភជគាត់ចាប់បាននៅយើងទាំងរស់ ហើយគាត់នឹងឲ្យលំបាកអស់កាលដ៏លង់ទៅហោង ។

ស្តេចទ្រង់ព្រះសណ្តាប់ឮវាក្យនោះហើយ ជាទុក្ខមិនស្រណុកក្នុងព្រះកដហឫទ័យ អាល័យអាណិតតែតទៅបុត្រកវិយាព្រះអង្គឯងទើបមានព្រះបន្ទូលថា ម្នាលព្រះស្តេងអើយ អញតែតដងនោះ ហេតុនឹងចង់រស់មិញឥឡូវនេះវិញ្ញែប្រែក្រឡាប់មកណែងជួរស្លាប់វិញ ក៏ស្រដីឲ្យតែក្តៅចិត្តដូច្នេះតើជាប្រយោជន៍អ្វី? ស្តេចតែតនឹងជណ្តើងសួរអាចារ្យទាំងឡាយមានអាចារ្យបុក្កុសៈជាដើមនឹងឲ្យទ្វើយតាមពាក្យតំឡៅនៃអាត្មា មានសភាតដូចម្តេច។

តែន វុត្តំ តែន ហេតុនោះហោង ឥទំ គាថា ពន្ធំ ការេន ព្រះគាថានេះ កកវតា តីព្រះដ៏មានបុណ្យ វុត្តំ ព្រះអង្គបន្ទូលដូច្នេះ

សារីបុត្ត ម្នៃសារីបុត្តអើយ វ៉ាស្តេចវិទេហរាជបន្ទូលដល្អឹងទៅអាចារ្យ
បុក្កុសៈថា ម្នៃអាចារ្យបុក្កុសៈអើយ ចូរព្រះស្តេងស្តាប់ពាក្យនៃអញណា
ព្រះស្តេងអើយ មើលទៅអស់សេនាគេនោះ គួរកិតភ័យពន្លឹកពេក ព្រះ
ស្តេងអើយ ឥឡូវនេះ ព្រះស្តេងគិតនូវកិច្ចម្តេចឲ្យរួចចេញពីឋាននេះហោង
អាចារ្យបុក្កុសៈទូលថា ។

ទិសំ ខាធិត្វា មិយ្យាម ខិប្បំ ហិ សប្បម ជីវិតំ
មា នោ រាជា ព្រហ្មទត្តោ ចិរំ ទុក្ខេន មារយីតិ ។

បពិត្រមហារាជអើយ គួរយើងស៊ីថ្នាំពិសឲ្យអស់ជីវិតឆាប់ កុំឲ្យព្រះ
បាទបុប្ផនីព្រហ្មទត្តរាជ គាត់យកយើងទៅសម្លាប់បានឡើយ ។

ស្តេចបន្ទូលទៅកាន់អាចារ្យកាមិន្ទថា ម្នៃអាចារ្យកាមិន្ទអើយ អ្នក
គិតដូចម្តេច អាចារ្យកាមិន្ទទូលថា:

វជ្ជយា ពជ្ឈ មិយ្យាម បថាតា បបតេមុសេ
មា នោ រាជា ព្រហ្មទត្តោ ចិរំ ទុក្ខេន មារយីតិ ។

មហារាជ បពិត្រមហារាជអើយ បើតាមដោយខ្ញុំយល់ យើង
យកឡូមកបង់កន្លាប់ហើយ លោតអំពីលើធ្នឹមចុះមកឲ្យបែកបង់ពងក្លាប់
ឆាប់ទៅឯដំណាមហារាជ។ បើព្រះបាទបុប្ផនីព្រហ្មទត្តរាជគាត់ចាប់បាន
យើងតាំងរស់ទៅ គាត់នឹងធ្វើឲ្យលំបាកត្រឡប់មកយើង ។ យើងនឹងមាន
ទុក្ខអស់កាលដ៏យូរលង់ទៅហោង ។

ភជា អាហា ព្រះភជាស្តេចត្រាស់ដណ្តឹងសួរទៅអាចារ្យទេវិន្ទ
ថា:

សុណោហិ មេ តំ វចនំ បស្ស សេនំ មហាភ្ភយំ
ទេវិន្ទធាឯ បុច្ឆាមិ កថំ តេ ន ភយំ សិតំ។

ទេវិន្ទ នែអាចារ្យទេវិន្ទ ចូរអ្នកស្តាប់នូវពាក្យនៃយើង ចូរព្រះ
ស្តេចមើលមើលសេនាគេ គួរតែតក់ឈឺក្រៃពេក អញនឹងសួរដណ្តឹងព្រះ
ស្តេច។ នឹងគិតកិច្ចកលម្តេច ក៏នឹងឲ្យបានរួចចាកចេញអំពីឋាននេះហ៎ះ
ហោង ។ អាចារ្យទេវិន្ទទូលថា មហាពជអើយ ព្រែះមហោសថអ្នក
ប្រាជ្ញនឹងអាចារ្យសេនកៈ មិនអាចដើម្បីនឹងដោះយើងឲ្យរួចដោយនូវសុខ
បានឡើយ គួរតម្បីយើងយកភ្លើងអុជទ្វារ ហើយយកលំពែងមកចាក់កាប់
សម្លាប់គ្នាទៅវិញទៅមកឲ្យបង់ជីវិតផាប់ហោង ។ ឡើយនឹលែងអ្នកជង
នឹងអាចារ្យទេវិន្ទគិតថា រីស្តេចនេះមកដណ្តឹងអស់យើង តើនឹងដឹងអ្វីប
ដូចបុរសយកអំពីលអំពែកមកផ្ទុំ ថ្នាណាក៏នឹងនេះ មានតែវង់ចាំព្រះមហោ-
សថនេះឯង រីអ្នកជវៃមិនអាចដើម្បីនឹងដោះស្រាយឲ្យរួចដោយនូវសួស្តី
នោះអង្គឹមានឡើយ ហើយព្រះអង្គមិនជណ្តើងព្រះមហោសថ មកដណ្តើង
ឯយើង តើនឹងដឹងអ្វី មិនមានយល់នូវ។ ចុយកលអ្វីបន្តិចឡើយ ហើយ
អាចារ្យទេវិន្ទស្រដីសរសើរព្រះមហោសថ ដូចពាក្យអាចារ្យសេនកៈថា
ម្ន៎ះគ្រែងតែប្រាជ្ញាព្រះមហោសថទើបដោះប្រស្នានេះបាន ទើបអាចារ្យ

ខេរិន្ទទូលថា ម ហាភាគ ឯ បពិត្រមហាភាគដ៏ឧត្តម យើងឯងនេះគឺនឹងសូម
អង្វរចៅអ្នកប្រាជ្ញ បើព្រះមហាសត្វអ្នកប្រាជ្ញពុំអាចដើម្បីនឹងធ្វើយដោះ
ដោយខ្លួនសុខស្រួលឯងនោះទេ សឹមយើងធ្វើដោយខ្លួនតាមការអាចរបស់ខ្លួន
នោះហោង ។ ឯស្តេចស្តាប់ពាក្យនោះហើយ ក៏រំលឹកពោសព្រះអង្គដែរ
តោងនូវសត្វអំពីមុននោះ មិនអាចដើម្បីនឹងមានបន្ទូលមួយអង្គុយនឹងតោង-
សត្វនោះវិញទៀតបានឡើយ ហើយព្រះអង្គស្តាប់ពាក្យអាចារ្យខេរិន្ទនោះ
ហើយរឹងមានព្រះហឫទ័យនឹងត្បាចម្រាប់ខ្លួនឯង ទ្រង់ព្រះការនូវថ្លែង
ពិលាបអាណិតអនាថថា ។

យថា កន្ទុលិនោ សារំ អន្ទេសំ នាធិកច្ចតិ
ឯវំ អន្ទេសមានា ន បញ្ញំ នាជ្ឈគមាម្ហសេ

។ បេ ។

កម្មាភំ យថា ទុក្កា អន្តោ ឈាយតិ នោ ពហិ
ឯវំបិ ហទយំ មយ្ហំ អន្តោ ឈាយតិ នោ ពហិ តិ ។

រីអាថ្មៃថ្មាយនេះហើយ ដ៏ដូចបុរសមួយស្វែងរកខ្លឹមចេក ខ្លឹមរកពុំ
បានដូចក្តីចំណង់ប្រាថ្នា មានប្រការនោះមិញ រីយើងនឹងស្វែងរកខ្លួ
អាចប្រស្នាថ្មាយកល នឹងឲ្យបានរួចអំពីភ័យសត្រូវពាំងនេះ ដូចបុរសរក
ខ្លឹមចេកខ្លឹមរកនោះហោង ។ រីខ្លួនអញនេះ ដ៏ដូចដំរីសារ ពុំគួរនៅឲ្យ
ដ៏កូមិប្រទេសឥតតឹកនោះឡើយ រីហឫទ័យនៃអញក៏ពាំរនឹងតបប្រដូច

ស្តីកពោធិ៍ ដែលឲ្យលះបង់ដីនលំគោនមក រមាត់អញ្ជាដ៏វែងរួតស្មួតដូចបុរសឈរនៅមាត់ភ្នើងដំរក្តៅនោះហោង ។ មួយទៀតសោតវ័ត្តដែលជាងមាសចាំងឡាយសោយរំលាយពាក្យនេះនឹងតែឯកុង កំមិនដែលឯក្រៅ មានប្រការនោះម្តេចមិញ រហូតដល់នាគាភ្នាក់នេះឯកុង ម្តេចកំពាមិនដែលឯក្រៅ ។បមាដូច្នោះហោង ។

ព្រះមហាសត្វអ្នកប្រាជ្ញ ស្តាប់ព្រះបន្ទូលព្រះមហាសត្វគ្រានោះហើយ អ្នកគិតថា ស្តេចនេះមានព្រះទ័យលំបាកពេក គោះយោងអញមិនលោមស្តេចហើយ ស្តេចកំនឹងបែកព្រះហឫទ័យក្រៃដែតែបង់ហោង បើដូច្នោះ អញនឹងលោមព្រះមហាសត្វនេះ ឲ្យមានដង្ហើមចេញចូលធូរស្បាយវិញហោង។

តមត្តំ បតោសេដ្ឋោ សត្តា អាហ ។ កិត្តាវេ ភៃកិត្តុ ជនចាំងឡាយអើយ ព្រះបរមសាស្តាជាអម្ចាស់នៃយើង លុះទ្រង់ប្រកាសសំដែងនូវអាចិណ្ណនោះស្រេចហើយ ទើបទ្រង់ពោលនូវគាថាជាបច្ចតាថា ដូច្នេះថា:

តតោ សោ បណ្ឌិតោ ធីរោ អត្តនស្សុ មហោសធោ
វេនេយ្យំ ធុក្កិតំ ញត្វា ឥមំ វចនមព្រវីតិ ។

ព្រះមហាសត្វ អ្នកប្រាជ្ញអាចមានប្រតិភាណ យល់អាចិណ្ណ សេចក្តីលោភយលោភាចាំងពួន ជានយល់ព្រះបាទវិទេហរាជ ជាទុក្ខព្រួយក្នុងព្រះពេជហឫទ័យដូច្នោះហើយ ក៏ទ្រង់ស្រដីលួងលោមនូវស្តេចនោះថា

มา ตุ๋ กายิ มหากฺ ม มา ตุ๋ กายิ ราเชสก

อหิ๋ ตุ๋ เมาจยิ สฺวา มิ กหาตฺถหิ๋ ตุ๋ จงฺโฆ

๗ เปฯ ๗

อทฺ ปญฺญา กามตฺถา อมเตฺว ภวิ ตาธิ เสา

โย ตุ๋ สมฺมาปฏิปชฺเช ขุทฺทา น ปริ เมาจเย ตุ๋ ฯ

มหากฺ ปติ ตฺรสมฺตเขตกฺษตฺรยิ ปฺรเสาร เอย กุ๋ ปิ อมฺหาสฺ มานพฺรหฺมหิ ปฺรเทย ปาร มฺภาจ อณาจ สตฺรา เนาะ เอย ขุ๋ นิ ฉาะ อมฺหาสฺ ใส่ ลมกลุะ กฺนฺ กณฺฑาป ใส่ นิ สตฺรา เนาะ ปิ ฎูจ พฺระ จนฺทฺร ฎิ ปาน จำ ณาป ใส่ นิ พฺระ กหู เนาะ หาง ๗ ราเชสก: ปติ ตฺร กฺษตฺร ปฺรเสาร ไกฺร ลาง ฉาง กฺร สฺตฺร ผง ตำ ง เอย อย กุ๋ ปิ อมฺหาสฺ ขาจ เอย ขุ๋ นิ ฉาะ มหากฺ ฎิ มกลุะ กณฺฑาป ใส่ สตฺรา เนาะ กหุ ตำ ง กฺษตฺรา สุ ริ ยิ ปิ ฎูจ พฺระ อาทิ ตฺย คฺ ตำ ฎิ ปาน จำ ณาป ใส่ นิ พฺระ กหู เนาะ หาง ๗ ปติ ตฺร มหา-

กฺ เอย อมฺหาสฺ กุ๋ ขาจ เอย ขุ๋ นิ ฉาะ มหากฺ ฎิ มกลุะ ฎูจ ดิ กณฺฑาป ใส่ นิ สตฺรา เนาะ ปะ เกฺล สงฺ กฺ กฺนฺ ปุ ญฺ ปิ ฎูจ ดี สาร ฎิ ผุง กฺนฺ กง กำ ล ปาป เนาะ หาง ๗ ปติ ตฺร มหากฺ ปฺรเสาร ไกฺร ลาง ฉาง กฺร สฺตฺร ผง ตำ ง-

เอย กุ๋ ปิ มหากฺ ขาจ เอย ขุ๋ นิ ฉาะ มหากฺ ฎิ มกลุะ ฎูจ ดิ กณฺฑาป ใส่ นิ สตฺรา ปิ ฎูจ ดี สาร ฎิ ผุง กฺนฺ กง กำ ล ปาป เนาะ หาง ๗ ปติ ตฺร มหา-

กฺ กฺษตฺรา สุ ริ ยิ เอย อมฺหาสฺ กุ๋ ขาจ เอย ขุ๋ นิ ฉาะ สมฺ ตฺร มหา-

ភជ ដ៏មកល្អុះកណ្តាប់ដៃនៃសត្រូវ ប៉ាដូចប៉ុន្តែគេបញ្ចូលក្នុងទ្រុងខ្ចាប់នោះ
ហោង ។ បពិត្រក្សត្រថ្លៃប្រសើរអើយ កុំបីអម្ចាស់ខ្ញុំឡើយ ខ្ញុំនឹង
ដោះអម្ចាស់ដ៏មកល្អុះកណ្តាប់ដៃនៃសត្រូវនោះ ប៉ាដូចត្រីដែលចូលក្នុងសំ
ណាញ់ខ្ចាប់នោះហោង ។ បពិត្រក្សត្រថ្លៃប្រសើរអើយ កុំបីអម្ចាស់
ខ្ញុំចុះនឹងភ័យសត្រូវតាំងនេះឡើយ ខ្ញុំនឹងដោះសម្តេចមហាភជ មួយអនេ្ត
នឹងអស់តលសកលយោធាសេនាតាំង ៤ ជំពូកនឹងឲ្យរួចចេញដោយរឹទ្ធិ-
ប្រាជ្ញានៃខ្ញុំហោង ។ បពិត្រមហាភជប្រសើរក្រៃលែងជាងភក្ត្រផង
តាំងឡាយអើយ កុំបីអម្ចាស់ខ្ញុំចុះនូវអំណាចនៃសេនា ព្រះបាទព្រហ្មទត្ត
ភជជាអម្ចាស់នៃអ្នកបញ្ជាលភស្ត្រនេះឡើយ ខ្ញុំនឹងដោះឲ្យអម្ចាស់រត់ទៅ
ដោយទូកកម្លាំងប្រាជ្ញានៃខ្ញុំ ដូចបុរស ១ នាក់គាន់ដំបងដេញបង្ហើលក្អែក
តាំងឡាយឲ្យរត់អស់ទៅនោះហោង ។ ម ហាភជ បពិត្រក្សត្រថ្លៃ
ប្រសើរអើយ រឿងមានឯណាយល់មកដូចខ្ញុំនេះ ក៏នឹងដោះសម្តេចមហា-
ភជ ដុំលុះនឹងចង្អៀតចិត្តក្លាត់លែងខ្លួនភ័យ នឹងសត្រូវតាំងឡាយនេះ
ហេតុប្រកបនូវប្រាជ្ញា ខ្ញុំនេះមកមុខអម្ចាស់ ម្តេចឡើយក៏នឹងឲ្យប្រយោជន៍
នោះសោះខ្លះ ។

ភជាបិ តស្ស វចនំ សុត្វា ឥទានិ មេ ជីវិតំ
លទ្ធន្តិ អស្សាសំ បដិលភិ ។ ស្តេចស្តាប់ពាក្យពោធិ
សត្វនោះហើយ ក៏បានដកដង្ហើមចេញចូលធូរសប្បាយដោយគិតថា

ជីវិតនៃអញនឹងបានរស់ហើយ អស់អ្នកផងសោត សឹងត្រេកអរដោយនូវពាក្យសីហនាទនៃពោធិសត្វនោះហោង ។ លំដាប់នោះ ស្តេចបន្ទូលនឹងព្រះមហាសត្វអ្នកច្រាជថា បណ្ឌិត ម្ចាស់ចៅអ្នកច្រាជអើយ រីឯចៅថានឹងយកអស់យើងតាំងពួនឹងឲ្យរួចទៅដោយនូវទុក្ខយកលអ្វីហ៎: ។ ពោធិសត្វអ្នកទូលថា បពិត្រមហាកជអើយ ខ្ញុំនឹងនាំអម្ចាស់ទៅដោយមហាទុម្មគ្គប្រជាប់ប្រពៃ ចូរអម្ចាស់អណ្តាប់ព្រះកជដំណើរស្តេចនឹងយានទៅនោះហោង ពោធិសត្វអ្នកថាអម្បាលនោះហើយ ទើបអ្នកបង្គាប់មហាយោធា នឹងឲ្យបើកទ្វារទុម្មគ្គនោះ ហើយសូត្រនូវបទគាថា:

ឯថ មាណាវ ឧដ្ឋេថ មុខំ សោធេថ សន្ទិដ្ឋោ
វេនេយ្យោ សហាមច្ចេហិ ទុម្មេធ្លេន កមិស្សតីតិ ។

មាណាវ ម្ចាស់មាណពគ្នាយើងតាំងឡាយអើយ ចូរអ្នកដោះដាលត្រកាលឡើងបើកទ្វារមហាទុម្មគ្គ នឹងសន្ធាក់យន្តតាំងឡាយ យើងនឹងទៅអញ្ជើញអម្ចាស់យើង ឲ្យស្តេចលីលាយាត្រាមួយអន្ទើនឹងអាមាត្យតាំងឡាយ ទៅកាន់មហាទុម្មគ្គនោះហោង ។

តេ ឧដ្ឋាយ ទុម្មេធ្លទ្វារំ វិវរិំសុ យោធាតាំងឡាយនោះក៏ទៅបើកទ្វារទុម្មគ្គដ៏មានពន្ធឹក្តីរុងរឿង ល្អដូចទេវតាប្រជាប់សុធម្មសភាសាល ។

តមត្ថំ បការសោ សត្ថា អាហ ។ តិក្ខត្តុំ ភៃ

កិក្ខុផងតាំងឮយ៉ាយអើយ រីព្រះបរមសាស្តាចារ្យជាអម្ចាស់នៃយើង លុះទ្រង់ប្រកាសសំដែងនូវអាថ៌មានេះស្រេចហើយ ទើបទ្រង់ពោលនូវភាសាជាបទគាថាថា:

តស្ស តំ វចនំ សុត្វា បណ្ឌិតស្សាធុសារិនោ
ឧដ្ឋដ្ឋង្គារំ រីរីសុ យដ្ឋយុត្តេ ច អក្ខទ្ធេតិ

មាណពផងតាំងឮយ៉ាយនោះ ស្តាប់ពាក្យចៅមហោសថអ្នកប្រាជ្ញបង្គាប់ប្រើឲ្យបើកភ្លាមៗ នូវយន្តនឹងរៃរុនុកយន្ត រីមាណពក៏បើកនូវភ្លារស្រេចហើយមកប្រាប់នៃមហោសថ ព្រះមហោសថនោះ អ្នកទទួលបណ្តាំងនៃស្តេចថា:

បពិត្រមហាក្សត្រអើយ ជាកាលគួរអម្ចាស់ចុះទៅអំពីប្រាសាទ នាកាលស្តេចនឹងចុះទៅនោះ អាចារ្យសេនក: ក៏នឹងដោះនូវមួកនាឡចេញអំពីក្បាលនៃអាត្មា ហើយស្រាយសំពត់ចងក្បាលនៃអាត្មាចេញ ។ លំដាប់នោះ ព្រះមហោសថអ្នកយល់អាចារ្យសេនក:ធ្វើដូច្នោះហើយ អ្នកដណ្តើងថា ម្នាលអាចារ្យសេនក:អើយ អ្នកធ្វើអ្វីដូច្នោះ? អាចារ្យសេនក:ថា ម្នាលព្រះមហោសថអ្នកប្រាជ្ញអើយ នាប៉ាហៅនឹងលួនពារចូលទៅក្នុងមហាទ្វារនោះ លុះស្រាយរមួលចងក្បាលឲ្យជាប់ ទើបនឹងដើរទៅក្នុងមហាទ្វារនោះបាន ។ រីពោធិសត្វអ្នកស្រដីប្រាប់ទៅអាចារ្យសេនក: ថា ម្នាលអាចារ្យសេនក:អើយ កុំបីអ្នកគិតថានឹងនពារដូច្នោះឡើយ ថា

បើអ្នកមានដំរីសេះ ចូរអ្នកឡើងជិះលើដំរីសេះទៅហោង ។ រីឯមង្គលនោះ មានកំពស់ ១៨ ហត្ថ ដ៏មានថ្លានោះធំល្មមយកតែដ៏ប្រជាប់ប្រពៃ ចូរអាចារ្យទៅតាមតែស្រណុកចិត្តហោង ។ ព្រះមហាសត្វអ្នកពិចារណាខ្លួនដំណើរនៃព្រះមហាកប្បត្រហើយ អ្នកឲ្យអាចារ្យសេនកៈដើរទៅមុន ស្តេចជាកណ្តាល ឯខ្លួនពោធិសត្វឯងដើរជាឯក្រោយ ។ មានចំណោទថា តើការណា ហេតុអ្វីព្រះមហាសត្វអ្នកធ្វើដូច្នោះហ៊ុ: ? ពាក្យចម្លើយឆ្លើយថា រីពោធិសត្វអ្នកធ្វើដូច្នោះ ហេតុបន្ទំឲ្យស្តេចឧត្តមង្គប្រជាប់ប្រពៃហើយឲ្យស្តេចយាងទៅសន្សឹម ។ ទៅហោង ។ រីឯថ្នាយ ពីក ចំណីផង មានយាគូជាដើម សឹងជាក់ទុកក្នុងមហាឧម្មគ្គនោះច្រើនទំងំប្រមាណពុំបាន ។ មនុស្សម្នាមហាជនខ្លះផឹកស៊ីហើយ រមីលមើលនូវមហាឧម្មគ្គនោះហើយដើរទៅ ។ ឯពោធិសត្វអ្នកដើរតាមក្រោយ ហើយអ្នកតឿនរះព្រះមហាកប្បត្រថា បពិត្រមហាពរអើយ ចូរនាំឲ្យអាមាត្យព្រះមហាកប្បត្រស្តេចឧត្តរមីលមើលមហាឧម្មគ្គ ដ៏ល្អវិចិត្រដូចសាលាគឺវេតារប្រជាប់នៅខាងសួគ៌នាយ ហើយស្តេចយាងទៅហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ។ តត្ថ្រវៃ ភិក្ខុផងពាំងឮឃ្លាអើយ ព្រះបរមសាស្តាជាអម្ចាស់នៃយើង លុះទ្រង់ប្រកាសសំដែងនូវអាចិណ្ណមិនោះស្រេចហើយ ទើបទ្រង់មានបន្ទូលជាបន្តព្រះគាថាដូច្នេះថា:

បុរតោ សេនកោ យាតិ បច្ឆតោ មហោសធោ
មជ្ឈេ ច រាជា វេទេហោ អមច្ចបរិវារិតោតិ ។

រីឯចារ្យសេនកៈដើរទៅមុន ឯព្រះមហោសធដើរទៅតាមក្រោយ ស្តេចវិទេហរាជដើរជាកណ្តាល មាណពតាំង១ឡាយច្រើនចោមរោមជាបរិវារ រីមាណពកំឡោះតើនោះជាសត្វដ៏ធំនៅដំណើរនៃព្រះបាទវិទេហរាជ សឹងដំនាំនូវព្រះវរោជមាតាក្តី ទាំងនន្ទាទេពី នៅបណ្តាលចន្ទកុមារនិងព្រះរាជធីតាព្រះមហាកប្បត្រនោះក្តី អំពីកន្លងទម្ងន់នោះ ទៅខុសពីដំរីធំមហាវិសាលធំនោះ ។ ស្តេចចេញទៅអំពីទម្ងន់មួយអន្ទោងនិងតោជាសត្វ ។ មហាកប្បត្រតាំង ៤ ព្រះអង្គនោះ យល់សេចក្តីព្រះមហោសធអ្នកប្រាជ្ញហើយ សឹងដឹងមានភ័យអំពីស្លាប់មកតម្រាម ហើយស្រែកឲ្យយំដឹងមានសព្ទសម្រែកនោះខ្ទាំងថា យើងមកលុះកណ្តាប់ដៃអ្នកដទៃហើយ កិត្តសង្ឃ៌យឡើយ រំពេលដងតាំងនេះ គឺពាលព្រះមហោសធមកចាប់យកយើងទៅហោង ។ ដោយយើងបានឮមកថា ព្រះបាទបុឡ្ឍន៌ស្តេចទៅចោមរោមស្តេចវិទេហរាជដ៏ត្រៃយស្ងឹងតង្អាកនោះ មានចម្ងាយមួយគាវុត ដោយហេតុនេះស្តេចវិទេហរាជតែងប្លែចហោង ។ ឯព្រះបាទបុឡ្ឍន៌ ស្តេចឮសម្រែកនៃអ្នកតាំងពួននោះឮដំចំណែកពត្រីនោះស្រែកថាសព្ទនោះដូចសព្ទសម្លេងនាងនន្ទាទេពីហ៎ះ ។ ស្តេចតត់តឹងចង់ស្រដីហើយ តែខ្លាចអាចារ្យកេរដ្តព្រាហ្មណ៌តាត់តិះដៀលថា អ្នកស្តេច

មកពោមពេមសត្រូវតែពក្រ ១ កំមេីរលឺកថាសំឡេងព្រះពជទេព័ នាង
នន្ទាទេពីតេីនៅឯណាកំមកថាដូច្នេះ ស្តេចពុំអាចដេីម្បីនឹងបន្ទូលបានឡេីយ
គង់ស្ងៀមនៅហោង ។ មហាសត្តោ តស្មឹ ឋានេ បញ្ចាល-
ចណ្ឌិ កុមារិកំ ។ រីព្រះមហាសត្វអ្នកដំកល់នាងបញ្ចាលចណ្ឌីកុមារី
ឰដ៏លេីហាន់ផ្កតែ្នហេីយ អតិសេកស្រេចទូលថា មហារាជ
បពិត្រព្រះសម្មតិទេពក្សត្រថ្ងៃប្រសេីរអេីយ អម្ចាស់ស្តេចសង្វាតមកដោយ
ខ្លួវក្រែថ្នាងនេះ នាងនេះចូរបានជាព្រះអគ្គមហេសីអម្ចាស់ហោង ។

តមត្ថំ បការសេន្តោ សត្តា អាហ ។ តិក្ខត្តុំ វៃ
ភិក្ខុផងពាំងឡាយអេីយ រីព្រះបរមសាស្តាជាអម្ចាស់នៃយេីង លុះទ្រង់
ប្រកាសសំដែងនូវអាថ៌មិនោះស្រេចហេីយ ទេីបទ្រង់មានបន្ទូលជាបទ
គាថាថា:

ឧដ្ឋិតា ឯក្ខមិត្វា វៃទេហោ ជាវមារុហិ

។ បេ ។

ការិមំ ករោហិ តេ តាយ ករិយា រាជសការិតំ ។

រីស្តេចវិទេហរាជចេញមកអំពីទម្ពន្ធនោះហេីយ ឡេីងទៅគង់លេីទូក
នោះ ព្រះមហាសត្វអ្នកផ្តាំប្រដៅនៃស្តេចវិទេហរាជនោះថា ទេវ បពិត្រ
មហារាជក្សត្រថ្ងៃប្រសេីរអេីយ រីរាល់បញ្ចាលចណ្ឌកុមារដ៏ជាព្រះពជបុត្រ
ព្រះបាទបុប្ផវន្ត ជាក្មេកព្រះបាទជាអម្ចាស់ រីនាងនន្ទាទេវីនេះជាព្រះអគ្គ-

មហេសីថ្លៃនៃព្រះបាទបុប្ផវតីជាក្មេកអម្ចាស់ ។ ប្រណាំបតន៍ព្រះវរពជមាតា ព្រះអង្គម្តេចមិញ ចូរអម្ចាស់ប្រណាំបតន៍ទំនុកបំរុងនៃព្រះមេក្មេកអម្ចាស់ដូច្នោះហោង ។ បពិត្រក្សត្រថ្លៃប្រសើរក្រៃលែងជាងកស្តេចទាំងឡាយ អើយ រៀបបញ្ចាលចន្ទកជកុមារ ជាសម្តេចព្រះរៀមព្រះអគ្គមហេសីអម្ចាស់កើតព្រះមាតាជាមួយ ចូរអម្ចាស់ស្រឡាញ់ដូចព្រះរៀមព្រះអង្គព្រះវរមាតាជាមួយនោះហោង ។ រជេសភ បពិត្រក្សត្រថ្លៃប្រសើរអើយ រីឯបញ្ចាលចន្ទជាព្រះពជបុត្រ ព្រះមហាក្សត្រទ្រង់នូវរូបទុគ្គមនេះ ជាព្រះអគ្គមហេសី ចូរអម្ចាស់ធ្វើតាមចំណង់ព្រះពជហឫទ័យនោះហោង ។

ស្តេចស្តាប់ហើយទូលយកនូវពាក្យគោធិសត្វថា សាធុ សម្ម-ដិច្ចិ ថា ម្នាលញាតិអ្នកប្រាជ្ញអើយ អ្នកថាគាប់ចិត្តហោង ។ តាំ ករោ-ណា ហេតុម្តេចក៏ព្រះមហាក្សត្រអ្នកមិនស្រដីត្រង់នាងសលាកទៅ ថា ហេតុនាងចាស់ព្រឹទ្ធនោះហោង ។ គោធិសត្វអ្នកបិតលើឆ្នេរស្ទឹង ហើយស្រដីបង្គាប់អស់ពាក្យទាំងពួង លំដាប់នោះ ស្តេចមានចំណង់ចង់ទៅឲ្យរួចអំពីទុក្ខ ហើយស្តេចហៅទៅកាន់គោធិសត្វថា ។ តាត ហៃហៅ មហោសថអើយ ហេតុអ្វីក៏មិនចុះមកឲ្យធាប់បន្តិច ? ស្តេចបន្ទូលជាគាថាថា: ។

អាវុយ្ហ ជាវិតរាជោ តំ ឧត្តរមិតិ ត្តសិ
កិច្ចា មុតម្ហិ ទុក្ខិតោ យាមជាតិ មហោសថាតិ ។

តាតវៃចាមហោសថអើយ ចូរឆាប់ម៉ែមាឡើងមកដុះលើខ្លួក ម្តេចក៏ឈរនៅលើក្រាំគ្គនោះមិនចុះមក យើងបានរួចអំពីទុក្ខហើយ យើងនឹងទៅផឡូវនេះហាង ។

ពោធិសត្វអ្នកស្តាប់ហើយទូលថា នេះបពិត្រមហាភដអើយ នាមីហៅដំណើរនឹងទៅជាមួយអាត្មានឹងព្រះចាតអម្ចាស់នោះ ឃល់ពុំគួរពេកហើយពោលថា ។

នេសទម្មោ មហាភដ យោហំ សេនាយ នាយកោ
សេនាន្តំ បរិហាបេត្វា អត្តានំ បរិមោចយេ
និវេសនម្ហិ តេ នេវ សេនាន្តំ បរិហាបិតំ
តំ និន្នំ ព្រហ្មទត្តេន អានយិ សុរដ្ឋវាសិកាតិ ។

មហាភដ បពិត្រមហាភដអើយ រីអញខ្ញុំជានាយក ជាប្រធានអស់សេនាពាំងពួង ថាបើខ្ញុំនឹងទៅក្រាសបង់អស់សេនាពាំង ៤ ដំតូកហើយក៏ដោះរួចតែតាគ្នាឯង រីសេកាតនោះពុំជាតន្ទុនិនៃបុរសផងអំពីបុកណាឡើយ រដ្ឋសក បពិត្រមហាភដក្សត្រថ្លៃប្រសើរអើយ ឯសេនាពាំង ៤ ដំតូកនោះ តីខ្ញុំសូមយកអំពីព្រះចាតអម្ចាស់ទៅធ្វើព្រះរាជមន្ទីរ ខ្ញុំប្រដាប់តីព្រះចាតបុត្តីព្រហ្មទត្តឲ្យនោះ ខ្ញុំនឹងរំលត្តឲ្យចាំយកអស់សេនាពាំង ៤ នោះហាង ។

បពិត្រមហាភដអើយ រីមនុស្សខ្លះដើរមកអំពីផ្លូវឆ្ងាយហើយអត់ឃ្លាន

នៅនោះ អ្នកខ្វះធំកស៊ីហើយព្រួយលំបាក ហើយប្រុងដួងដកលក់ស្រមុកនៅ អ្នកខ្វះឈឺប្តាត់ដង្ហែតធ្វើការ មកមួយអន្ទឹងឯង ខ្ញុំនោះក៏មិនដឹងជា ខ្ញុំចេញមក អស់អ្នកពាំងនេះមកធ្វើការអំណាយ ៤ ខែសឹងមានគុណនឹងខ្ញុំណាស់ មនុស្សម្នាក្តី ខ្ញុំមិនអាចដើម្បីនឹងលះបង់ ចេញអំពីហានេះ ខ្ញុំនឹងត្រឡប់វិលទៅវិញនឹងអស់សេនានៃអម្ចាស់ពាំងពួង ហើយខ្ញុំនឹងត្រឡប់ទៅយកអស់ទ្រព្យពាំងពួង គឺព្រះបាទបុទ្ធនីត្រហ្មទត្តឲ្យនោះ កុំឲ្យមានសំណល់ដល់តែបន្តិចឡើយ កុំបីអម្ចាស់ព្រួយរកយកអ្នកឯណាមួយឡើយ ចូរអម្ចាស់ស្តេចម៉ឺម្ចាទៅនាប់ ។ ហោង ឯដំរីសេះរនេះយានផង គឺអញខ្ញុំជាក់ខុតធំចាំព្រះបាទអម្ចាស់ឮដឹកណ្តាលផ្លូវហើយ ថាបើដំរីសេះរនេះឯណានឿយព្រួយហើយ អម្ចាស់ឲ្យចោលចេញ យកតែដំរីសេះរនេះឯទៀតដែលអាចនឹងមានកម្លាំង ចូរម៉ឺម្ចាឲ្យបានដល់មិថិលានគនោយនោះឯងហោង ។ លំដាប់នោះស្តេចស្តាប់ហើយរោលន្ទូវគាថាថា :

អប្បសេនោ មហាសេនំ កេវលំ ជិក្ខយ្យ បិស្សសិ
ឧព្ភលោ តលវន្តេន វិហញ្ញិស្សសិ បណ្ឌិតាតិ
បណ្ឌិត ម្នាលចៅអ្នកប្រាជ្ញអើយ ចំពោះនេះមានតលសកលយោធានោះតិច ម្តេចក៏ចៅទៅច្បាំងនឹងស្តេចបុទ្ធនី ។ ដ៏មានតលសកលយោធាសេនានោះច្រើន ។ លំដាប់នោះ ពោធិសត្វទូលស្តេចដោយគាថាថា : ។

អប្បសេនោបិ ចេ មន្តី មហាសេនំ អមន្តិនំ

ឯកាតិរាជា រាជានោ អាទិច្ចោវុឌយ្ហមន្តិ ។

បពិត្រមហារាជអើយ រីឯអ្នកមួយមានពលសេកលយោធានោះតិច តែ
មានប្រាជ្ញាឈ្លាសទេ ជាយកលទាំងពួងនោះ តែអាចផ្តាំញ៉ាំអ្នកដ៏មានពល
សេនាច្រើនោះបាន តែបើឥតប្រាជ្ញា ស្តេចមានប្រាជ្ញាក៏អាចផ្តាំញ៉ាំស្តេច
ផងឥតប្រាជ្ញា ដូចព្រះអាទិត្យ១ទ័យប្រពៃរះឡើងមកកំចាត់ងងឹតបង់
ដំសំដែងនូវពន្លឺរស្មីក៏រុងរឿងល្អ ។

ព្រះមហាសត្វអ្នកថាអម្ពាលនោះហើយ អ្នកថ្វាយបង្គំនៃស្តេចឲ្យ
ដំណើរថា ចូរអម្ចាស់ស្តេចយាងទៅ កុំបីបង្អង់យូរឡើយ ។ រីឯស្តេច
នោះ កាលបើបានរួចអំពីភ័យនៃសត្រូវនោះហើយ ស្តេចរំពឹងគន់មើល
តោធិសត្វដោយគតិថាដូច្នេះ ឥឡូវអញបានខាងនេះហើយ ក៏លុះដោយ
ចំណាំប្រាជ្ញាអញមរបូណិ ហើយក៏តើតនូវសោមនស្ស សំដែងគុណព្រះ
មហាសត្វអ្នកប្រាជ្ញនឹងអាចារ្យសេនកៈជាគាថាថា ។

(នៅមានត)

ប្រវត្តិខ្មែរត្រកំពត

ស្រាវជ្រាវដោយ ឌ . គាម

តាមការស្រាវជ្រាវរបស់ខ្ញុំអំពីខ្មែរក្រៅនៅក្នុងប្រទេសកម្ពុជា ខ្ញុំបានអានសៀវភៅខ្លះ ហើយឯនឹងឯកសារខ្លះទៀត ដែលលោក ឌឿ-ក៉ាន់ បានសរសេរជូនមកក្រុមចំនៀមទម្លាប់ខ្មែរ (ពីថ្ងៃ ២២ – ៨ – ៥៣) ។ លោក ឌឿ-ក៉ាន់ ថា បានដឹងឮតាម លោក ហាស់-ភ្លឿង អាយុ ៨៨ ឆ្នាំ និងលោក ខៀប-សំរិទ្ធ អាយុ ៨៥ ឆ្នាំ និយាយច្រាប់ ។ ការធៀបអត្ថបទរបស់លោក ឌឿ-ក៉ាន់ នៅនឹងអត្ថបទមួយជាភាសាបារាំងរបស់លោក ម៉ាដ្រូល (Madrolle) យើញមានភាពខ្លីមួយមានឈ្មោះដូចគ្នាដូច្នេះខ្ញុំសូមដូនប្រវត្តិដូចតទៅនេះ ។

១– តាមឯកសាររបស់លោក ឌឿ-ក៉ាន់ ថា ក្រុងកំពតពីដើមដុះសុទ្ធតែកូនស្មាច់ កូនផ្លាវ នៅតាមមាត់សមុទ្រដែលជាកំពង់សំរាប់ឲ្យអ្នកដំនួញចតទូកនឹងសំរៅ ។ តក្រោយមក មានចិនយួនចាមនៅសន់ខ្លួមនៅជាកំប៉ុត ។ ទន្ទឹងថ្ងៃ នៅតាមបណ្តោយមាត់ព្រៃកៃសមុទ្រដើម្បីលក់ដូរកេសុី ។ កន្លែងដែលចាម ចិន យួន មកសន់ខ្លួមនៅ គេសង្កេតនៅឃើញជាកំប៉ែតកំប៉ុត ទើបគេសន្មត់ហៅថា «ភូមិកំប៉ុត» ។

ចំណេរក្រោយមក ទឹកសមុទ្រកាន់តែថយទៅ ។ ទើបមានដីឡាប់

ដុះនាឡើង ដើមឈើគំមានដុះមកជាលំដាប់ដែរ ហើយខ្មែរ ចិន ចាម ឃួន ជ្វា គំហ៊ានសន់ផ្ទះខ្ពស់ ។ ឡើង ព្រោះអាងថាបើមានខ្យល់មក ឬនដើមឈើគ្រាន់ការពារផ្ទះសម្បែង ។

ពេលដែលមានផ្ទះនៅហើយ អ្នកលក់ដូរធ្វើតៀមលក់ចាយសំរាប់ឲ្យ ឈ្មួញអម្រែកដឹកឆ្ងាយ ពួកឈ្មួញតែងចូលចតខ្លួក ឬឈប់ដំណើរ ដើម្បី បរិភោគចាយនៅកន្លែងនោះ ។ ពេលក្រោយមក ពួកឈ្មួញដើរគោក-ទំកឲ្យឈ្មោះផ្សារកំប៉ិតឬកូមិកំប៉ិតថា « ផ្សារកំពង់ចាយ » ។ តាមប្បញ្ញត្តិ ចាំងពីនេះប្រើច្រឡូកច្រឡំគ្នា ខ្លះហៅថា « ផ្សារកំប៉ិត » ខ្លះហៅថា « ផ្សារកំពង់ចាយ »តែក្រោយមកខ្មែរហួតដល់សព្វថ្ងៃនេះ គេហៅថា ខែត្រ « កំពត » ។

២- តាមលោក ម៉ាឌ្រូល (Madrolle) ថា ទីប្រជុំជននៅតាម ឆ្នេរសមុទ្រ មានដុះសុទ្ធតែដើមផ្លាវ ។ ទីប្រជុំជននេះមានសង្កាត់ជាច្រើន តែកន្លែងដែលឈ្មោះថាកំពតសព្វថ្ងៃនេះ ឈ្មោះថា « កំពង់ចាយ » ។

លោក ម៉ាឌ្រូល ទំនងលោក ឌឿ-ភ័ន ថា « កំពង់ចាយ » ដូចគ្នា តែត្រង់លោក ឌឿ-ភ័ន ថា ផ្សារកំប៉ិត យើញថាខុសគ្នា តែមានឃ្លាមួយ លោក ម៉ាឌ្រូល ថា កំពត ប្រហែលជាមកពីកម្ពុជា (D'autres voient dans Kampot l'origine, ou le dérivé, du nom Kampuchea. . .)

ត្រង់នេះ បើតាមយោបល់ខ្ញុំថា លោក ម៉ាឌ្រូល សន្និដ្ឋានថាមក ពីពាក្យថា កម្ពុជា ដូចជាសមដែរ ។ រឿងនេះខ្ញុំសូមជូនតាមអក្ខរាវិរុទ្ធិថា

កម្ពុជា គេអាចសរសេរសេរៅជាកម្ពុជវដ្ឋ ដល់គេកាត់ដ្ឋចេញៅ នៅសល់តែ កម្ពុជ ។ ពេលដែលក្រុងកំពតកំពុងតែកកើត ខ្ញុំសន្និដ្ឋានថា មានឈ្មួញជាតិសៀមតាមសមុទ្រមកឈប់អាស្រ័យបាយៅត្រង់កន្លែងនោះ។ ភាសាសៀម ពាក្យថា កម្ពុជ អាចថាកម្ពុត ដល់យូរ។ ដោយសេចក្តីធ្វេសប្រហែសបាត់ស្រៈ (ុ) ៅនៅសល់ថា កំពត ។

សរុបសេចក្តីៅយើញថាលោក ឡឺ-ហ្វ័ង់ និយាយថា «ផ្សារកំប៉ូត» ក្លាយៅជាកំពត ឯលោក ម៉ាជ្រូល ថាមកពីកម្ពុជា ក្លាយៅជាកំពត ។

ពាក្យរបស់លោក ឡឺង-ហ្វ័ង់ «ផ្សារកំប៉ូត» សមៅតាម «សូរ» «កំប៉ូត» < «កំពត» ពាក្យលោក ម៉ាជ្រូល «កម្ពុជា» សមៅតាមអក្ខរវិរុទ្ធិ «កម្ពុជ - កម្ពុជា» > «កំពត» ។

ចំពោះរឿងនេះ សូមអ្នកអានពាំងឆ្ងាយជួយវិនិច្ឆ័យផងចុះ ។

ដោយគណៈកម្មការជាតិនៃការសិក្សាផ្នែកអក្សរ «ក»

(តទៅ)

26 — Organique (adj.) អង្គិនៈ : ដែលមានអង្គ ។

27 — Organisation judiciaire civile ou pénale អង្គការតុលាការបវេណី ឬ អាជ្ញា ។

28 — Organiser le service judiciaire រៀបចំក្រុមតុលាការ ។

—P—

29 — Partie civile ភាគីបវេណី (ពក្យ) : អ្នកដែលប្រោះអំពីបទល្មើសមួយ ដែលជាខប្តឹងដល់តុលាការសុំការសោហ៊ុយជំងឺចិត្ត ។

30 — Partie civilement responsable ភាគីទទួលខុសត្រូវខាងបវេណី (ពក្យ) : ភាគីដែលត្រូវបេញសោហ៊ុយខូចខាត បណ្តាលពីបទល្មើស ។

31 — Partie défenderesse ភាគីចម្លើយ (ពក្យ) : ភាគី ក្នុងរឿងបវេណី ដែលជាអ្នកដើរតបតទៅនឹងភាគីចោទក៏ដែរ ។

32 — Partie demanderesse ភាគីចោទក៏ (ពក្យ) ភាគី ក្នុងរឿងក្តីបវេណី ដែលប្តឹងដល់តុលាការបវេណី អំពីភាគីចម្លើយ សូមសម្រេចសេចក្តីបង្គាប់ភាគីនេះ ឲ្យធ្វើដូច្នេះ ដូច្នោះ ឬ កុំឲ្យធ្វើដូច្នេះ ច្នោះ ។ ឧ. លោក សុក-សៅ ភាគីចោទក៏ប្តឹងអំពីលោក ម៉ុក មៅ ភាគីចម្លើយ សូមតុលាការបង្គាប់ដូចនេះ ដូចយ៉ាងថា ឲ្យសងឥវ៉ាក្ខូន គូរប្រាក់ចំនួន ប៉ុណ្ណេះ ប៉ុណ្ណោះ ដោយរាយហេតុឲ្យបានសព្វគ្រប់ ... ; ឬ សូមតុលាការបង្គាប់ដូចនេះ ដូចយ៉ាងថា កុំឲ្យទប់ប្រឡាយទឹករបស់ខ្ញុំ ដោយរាយហេតុឲ្យបានសព្វគ្រប់ ... ។

33 — Partie jointe — ភាគីបន្ទាប់បន្សំ (ពក្យ) : ភាគីដែលមានមុខងារក្នុងរឿងក្តីចរវេណី ត្រាន់តែផ្តួនយោបល ដល់តុលាការកាត់សេចក្តីថាគួរសម្រេចយ៉ាងណា ។ ។ ឧ. ក្នុងរឿងក្តីបរវេណី លោកព្រះរាជអាជ្ញា ជាភាគីបន្ទាប់បន្សំ ។

34 — Partie principale — ភាគីដើមចម (ពក្យ) : ភាគីដែលមានមុខងារ ក្នុងរឿងក្តីអាជ្ញា ចោទប្រកាន់មនុស្សត្រូវចោទ អំពីបទល្មើសអាជ្ញា ដែលខ្លួនបានប្រព្រឹត្ត ។ លោក ស្នងការនរគបាល ជាដើមចម ក្នុងរឿងក្តីលហុ ។ លោកព្រះរាជអាជ្ញាអមសាលាដំបូង ជាភាគីដើមចម ក្នុងរឿងក្តីមជ្ឈិម និងរឿងក្តីឧក្រិដ្ឋ ។

35 — Présomptions égales de paternité — សច្ចធារណ៍ជាឯកឫនុភ្លួលចំពោះបិតុភាព ។ ឧ. កូនដែលកើតលើសពី ១៨០ ថ្ងៃ ក្រោយអាពាហ៍ពិពាហ៍នៃឪពុកម្តាយ ឬ កើតមុន ៣០០ ថ្ងៃក្រោយរលាយអាពាហ៍ពិពាហ៍ ត្រូវមានសច្ចធារណ៍ថា ស្វាមីនៃម្តាយជាឪពុករបស់ខ្លួន ។

36 — Prévenu (n.m.) — អ្នកជាប់ពិរុទ្ធ (ពក្យ) : ជនដែលសុភាពារបុរស បានអង្កេតស៊ើបសួរ ហើយយល់ថា បានប្រព្រឹត្តបទមជ្ឈិមមែន រួចបញ្ជូនទៅសាលាមជ្ឈិមដំបូង ។ ជនដែលសាលាលហុដំបូង កំហៅថាអ្នកជាប់ពិរុទ្ធដែរ ។

37 — Probant (adj) — ជាក់ស្តែង ។

—R—

38 — Réorganiser le service judiciaire — រៀបចំក្រុមតុលាការ ។

—S—

39 — Subjectif (adj) — អត្តវិស័យ : ដែលមានទីដៅខាងក្នុងខ្លួន ។

(នៅមានត)

វិបុលានុក្រមសំស្ក្រឹត-ខ្មែរ

ព្រះមហា ថាំង-ខាត់ រៀបរៀង

(តមក)

អត្ថាល្ងណ គុ. ដែលសាហាវក្រៃលែង ។

អត្ថាម្ល គុ. ដែលថ្លៅក្រៃលែង ។-ភា ស្ត្រី. ភាវនៃ . . . ថ្លៅក្រៃលែង កំដៅក្រៃលែង។

អត្ថាជិស្ងល គុ ដែលភ្លៀវក្រៃលែង ។

អត្ថាជិត គុ. ដែលខ្ពង់ខ្ពស់ក្រៃលែង ។

អត្ថាត្ថាក្យ ភាវនៃ . . . ខ្លាញ់ក្រៃលែង ។ សេចក្តីខ្លាញ់ក្រៃលែង ។

អត្រ, អត្រា ក្នុងទីនេះ ក្នុងលោកនេះ ក្នុងពេ ងនេះ ។ — *ភវន្ត* ប៉ុ. *ភវតី* ស្ត្រី សេចក្តីពោរពេ ។ — *ស្ថ* គុ. ដែលឋិតនៅទីនេះ ។

អត្រ គុ. ដែលមិនការពារ ។

អត្រត្យ គុ. នៅក្នុងទីនេះ ។

អត្រប គុ. ដែលមានខ្មាសមិនមាន ដែលឥតខ្មាស ។

អត្រស្ន គុ. ដែលមានខ្លាចមិនមាន ដែលឥតខ្លាច ។

អត្រាសិត គុ. ដែលតក់ស្លុតមិនមាន ដែលឥតតក់ស្លុត ។

អត្រិ ប៉ុ. ឆាមនៃឬស៊ី ។

អត្ថិរា ស្ត្រី. កិរិយាមិនប្រញាប់ប្រញាល់ ។

អថ ន. កាលនោះ គ្រានោះ ប្រសិនបើ ប៉ុន្តែ ... ។

អថវ៌ិន ប៉ុ. ឈ្មោះបព្វជិតអ្នកបង្កើតវិទ្យាដ្ឋ: តម្ពីរអថវ៌ិវេទ ។ អថវ៌ិវេទ ប៉ុ. ឈ្មោះវេទទី ៤ ។ អថវ៌ាង្គីរស ន.ប៉ុ. អថវ៌ាង្គីរ ប៉ុ. ឈ្មោះតម្ពីរឧបនិទទ ។ អថវ៌ាង្គីរសិ ប៉ុ. ពហុ. តំណាងអថវ៌ាង្គីរ នឹង អង្គីរស គឺ៣ នៃ អថវ៌ាង្គីរ នឹង អង្គីរស គឺ៣ នៃ អថវ៌ិវេទ ។ អថវ៌ាង្គីរស ឬ រសី គុ. ដែលមកពីអថវ៌ាង្គីរ នឹងអង្គីរស ស្ត្រី. បទនៃសាមន៍ ។

អថវ៌ាណ ន.ប៉ុ. អថវ៌ិវេទ ។

អទ ធាតុ. អត្តិ (បញ្ចេញ ជា អាទតិ, បញ្ចូលមី ជា អទស្យ); អទ្យតេ អាទយតិ អត្តុម: បរិភោគ រឹតរាយ ការិត. ចំញ៉ឹម ។

អទ ក ន. អ្នកបរិភោគ ។

អទំម្រ៊ើន គុ. ដែលមិនមានចង្កួម ដែលមិនមានភ្នក (ដំរី) ។

អទក្ស គុ. ដែលមិនរៀងរៃ ដែលមិនរស់រើក ដែលខ្ជិលប្រឡូស ។

អទក្សិណ គុ. ដែលមិនធ្វើទក្ខិណាទាន ដែលធ្វេង ដែលមិនមានពិសោធន៍ ដែលមិនរឹតរាយ ។

អទគ្ធ គុ. ដែលមិនដេះ ដែលរលត់ ។

អទណ្ឌ្យ គុ. ដែលមិនត្រូវទណ្ឌកម្ម មិនមានគិស ។

រឿងសាមកុក

កញ្ញាវិបុលពាជសេនា ទ្ធ - កាន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាឃ្លាំងសាស្ត្រ
អ្នកវាងវៃឆ្លាសចេះជានអាន
ទំនៀមបុរាណយកលំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ឃ្លោ-អ៊ុន

ខ្ញុំណ:នោះចាំងឋនិយាយទៅនឹងខ្លៅតាថា ដែលលោកឲ្យចូលទៅ
ហៅខ្លួនអៀវហ៊ួយនឹងគោជាយវែលានេះ ចើរចេញមកដោយល្អក៏កុំអាល
ទុកចិត្ត ត្រូវតែការពារក្បាលខ្លួនកុំប្រមាទ ថាចើមិនចេញមកដោយល្អទេ
យើងក៏នឹងលើកទាហានចូលទៅចោមរាយយកស្រុកសែឈួនកុំឲ្យដឹងខ្លួន
ទាន់ និយាយមិនទាន់ផុតមាត់ ក៏មានឮសំលក់បុតត្បូងក្លួចបក់ត្រូវដង
ខ្នង់ដ៏យថ្កាក់ដួលចុះ ខ្លៅតាឃើញអស្ចារ្យដូច្នោះ ក៏សួរចាំងឋនថា ហេតុ
នេះនឹងជាគុណឬជាទោស ?

ចាំងឋនថា ឯហេតុតាំងនេះ មកច្រាបដំណឹងគាចថា អន្តរាយនឹងមាន
ចើរអៀវហ៊ួយ គោជាយនឹងចេញមករកលោកនោះ ច្រាថ្នាំនឹងធ្វើគាចជា
ច្រាកដ កុំបីធ្វេសប្រហែសឡើយ ចូរកាំងខ្លួនឲ្យមួនមាំ ខ្លៅតាដឹងហើយ

កំតែងខ្លួនពាក់គ្រោះកាន់តាវុធសម្រាប់ដៃ ហើយបង្គាប់ឲ្យតាហានឈប់តាំងបន្ទាយ ក្បែរជាពួកជាកងរៀងគ្នា ។ ខ្លួលមានមនុស្សចូលមកជ្រាបថា ឥឡូវអៀវហ៊ួយ គោផាយនាំរបស់ជាដំណូនមកជូនលោក ប៉ាងថងកំឲ្យអ៊ុយអៀនទីឯហានតុន ចេញទៅទៅទាំងមុខហើយបង្គាប់ថា តាហានដែលមកជាមួយទីឯអៀវហ៊ួយ គោផាយនោះ ឲ្យចាប់ខុកឲ្យអស់ អ៊ុយអៀនហានតុន កំចេញទៅចាំតាមបង្គាប់ ។

គ្រានោះ អៀវហ៊ួយ គោផាយ កំនាំតាហានមកដល់មុខបន្ទាយឡៅពី ឃើញឡៅពីមិនបានត្រៀមតាហានទាំងពួងដូច្នោះកំគិតថា ឡៅពីនេះត្រូវកូនកលរបស់យើងហើយ កំនាំគ្នាចូលទៅដល់ទាំងកូន ឃើញឡៅពីទីឯប៉ាងថងអង្គុយនៅជាមួយគ្នា កំចូលទៅគំនាប់ថា ជ្រែតខ្ញុំបាទពុំដំណឹងថា លោកទីឯលើកទ័ពត្រឡប់ទៅវិញ បានជានាំរបស់ទាំងអស់នេះចេញមកគំនាប់ ជូនលោកតាមប្រពៃណី ឡៅពីថា អរគុណណាស់ ហើយឲ្យរៀបតុលៀងអាហារអញ្ជើញអៀវហ៊ួយ គោផាយបរិភោគហើយថា អ្នកទាំងពីរបានក្បាច់ផ្លូវស្រុកសែឈួនខុកនេះ ជាសេចក្តីគាប់ប្រសើរណាស់ ចូរផឹកស្រាលេងឲ្យសប្បាយចុះ តែយើងគិតថាទីឯចោការស្វាត់បន្ទាច់ដល់អ្នកទាំងពីរ តែមានពួកតាហាន[illegible]មកជាច្រើន ក្រែងដឹងភ្នែកទីឯនាំឲ្យបែកការ ឲ្យអ្នកចេញទៅ[illegible]ទៅទាំងក្រៅឲ្យអស់សិន យើងបានសន្ទនាទីឯគ្នា ។

អៀវហ៊ួយ គោផាយ ក៏មិនមានសេចក្តីសង្ស័យ ទើបបណ្តេញពួកមាហានចាំងអស់ឲ្យចេញនៅក្រោយបន្ទាយ ។ ខណៈនោះ ឡៅពីកំរៃស្រែកឡើងថា នរណានឹងយកអាសាចាប់អាចោរ ៤ នាក់នេះឲ្យយើងបាន ឡៅ-ហង នឹងតួនម៉ែងក្នុងដូច្នោះ ក៏ស្ទុះចេញមកព្រួតចាប់ខ្លួនអៀវហ៊ួយនឹងគោ-ផាយបាន ។ ឡៅពីថា អញនឹងនាយឯងជាសែជាមួយគ្នា ហេតុម្តេចបានជាឯងចាំងពីរ មកតតបង់ប្រឡូសក៉ាយនឹងអញ ត្រូវជ្នាននឹងឲ្យអញជាបងប្អូនមានចាស់អារម្មណ៍នឹងគ្នា ។

ខណៈនោះ ចាំងថងក៏ឲ្យមាហានត្រួតពិនិត្យរើរម៉ែល ឃើញមានអាវុធនៅក្នុងគាវអៀវហ៊ួយនឹងគោផាយ ក៏បង្គាប់ឲ្យមាហានចាំយកខ្លួនចាំងពីរនាក់ទៅប្រហារជីវិតបង់ ។ ហង់តុង អ៊ុយអៀន កំចាប់មាហានចាំង ២០០ នោះបាន នាំចូលមកជូនឡៅពី ។ កំឡៃឃុំក្បាខុកដោយប្រក្រតី ហើយថាជ្រែតអៀវហ៊ួយនឹងគោផាយចូលមកកាន់យើងមិនមែនជាផ្លូវសុចរិត ត្រូវថ្នាំនឹងប្រឡូសក៉ាយយើង ។ ឲ្យចាប់សម្លាប់តាមពេលសព៌ាហើយ ឯអ្នកឯងរាល់គ្នាមិនបានធ្វើខុសអ្វីនឹងយើងទេ កុំបីមានសេចក្តីកិតក៉ាយអ្វីឡើយ ចូរផឹកស្រាសេងឲ្យសប្បាយចុះ ។ មាហានចាំងនោះគំលើកដៃឡើងតំនាងឡៅពីដោយសេចក្តីប្រតាក់ប្រម្យសោមនស្សចាំងអស់គ្នា ។

ចាំងថងថា ឥឡូវយើងនឹងចង់ឲ្យអ្នកឯងរាល់គ្នាលើកចូលទៅវាយយកបន្ទាយចាំយស៊ីគួន បើបានហើយយើងនឹងឲ្យបំណាច់ឡើងដល់ខ្នាត

ពួកចាំដំនោះក៏ត្រមខ្លួលតាមពាក្យ លុះដល់ពេលយប់ក៏លើកចេញទៅ
ជាកងមុខ ឡៅតីក៏លើកកងខ្ចីតតាមទៅជាក្រោយ លុះទៅដំបន់ថ្មោយ-
ស៊ុគួន ភាហានចាំដំ ២០០ ដែលខ្លួលជាកងមុខក៏ស្រែកចូលទៅថា នាយ
យើងវិលមកវិញហើយ ឲ្យបើកទ្វារខ្លួលទឹងចូលទៅកេណ្ឌភាហានជា
ការប្រញាប់ នោះពួកភាហានដែលក្បែរបន្ទាយ ឃើញស្គាល់ជាពួកម៉ាក
របស់ខ្លួន ក៏មិនមានមន្ទិលសង្ស័យ ន៎ាគ្នាបើកទ្វារខ្លួល ភាហានឡៅតី
ក៏ស្រុះគ្នាចូលស្រុកទៅបាន ពួកភាហានក្នុងបន្ទាយក៏ន៎ាគ្នាតតក់យ៉ាង
មិនអាចតស៊ូ ក៏ន៎ាគ្នាចូលទៅគំទាប់ចុះចូលឡៅតីចាំដំអស់ ឡៅតីក៏
ឲ្យចំណាប់ផ្នាន់ភាហានចាំដំតួងតាមសមគួរ ហើយក៏ឲ្យចាត់ចែងភាហាន
នៅក្បែរបន្ទាយនោះជាមាំមួន ទើបតែងតុលៀងអាហារតាមប្រពៃណី ។

ឡៅតីសេតសុភស្រីដ៏ខ្លាំង ក៏និយាយទឹងថាំងថងថា ទីនេះយើង
វាយបានបន្ទាយថ្មោយស៊ុគួនហើយ ។ ក៏ត្រូវបានសេចក្តីសុខសប្បាយ
ហើយថាំងថងថា យើងមកវាយយកស្រុកគេនៅប្រាប់ប្រាមមិនទាន់ភ-
ាបនៅឡើយ លោកទឹងមកប្រមាថថាជាសុខនោះមិនត្រូវទេ ឡៅតី
ថា កាលគ្រាព្រះចៅដ៏វិជ្ជិអងលើកទៅវាយយកស្រុកព្រះចៅទីវ៉ែអងនោះ
ទៅដល់ដំបន់ណាក៏មានសេចក្តីស្រណុកសុខសប្បាយគ្រប់អន្ទឺ ដែលខ្លួន
យើងវាយបានបន្ទាយថ្មោយស៊ុគួន កន្ទុងចូលមកដល់ទីនេះហើយ ទឹងនៅ
មិនបានឈ្មោះថាជាសុខមែនហើយឬ ? អ្នកមកថាដូច្នេះមិនគួរសោះ ចូរ

ថយចេញទៅឲ្យឆាប់ ។ ចាំនឹងថនឮឡៅពីថាដូច្នោះ កំសត់ណាស់ថា សេពសុកស្រីនឹងខ្ញាំង ថាដោយអំណាចស្រីនឹងមិនដឹងខ្លួនមិនមានទឹកចិត្តអ្វី សើចហើយក៏ក្រោកដើរចេញទៅ ឡៅពីស្រីនឹងស្រាខ្ញាំងណាស់ក៏ដេកលក់ទៅ ។

លុះព្រឹកឡើង មនុស្សចំរើស្ងួច ឃើញឡៅពីស្លាន់ស្រីនឹង ហើយភ្ញាក់ពីដេក ក៏ចូលទៅសួរថា កាលពីម្សិលមិញ លោកបានចរចានឹងចាំនឹងថនតាមអំណាចស្រីនឹងនោះ ចាំនឹងថននឹងមិនតូចចិត្តទេឬ ? ។ ឡៅពីឮដូច្នោះ ក៏ឲ្យមានចិត្តកិតក័យណាស់ ត្រឡប់នឹកឡើងឃើញ ខ្លាចចាំនឹងថនអន់ចិត្ត ក៏ឲ្យចំរើទៅអញ្ជើញមកជួបហើយនិយាយថា កាលពីម្សិលមិញខ្ញុំស្រីនឹងស្រាជ្រុលណាស់ បានជានិយាយនឹងអ្នកដោយពាក្យមិនសមគួរព្រោះគិតមិនខាន់ ខ្ញុំសុំឲ្យអ្នកអត់ទោសកុំឲ្យនឹងសម្បាអ្វីនឹងខ្ញុំឡើយ ចាំនឹងថនថា ពាក្យដែលចរចាម្សិលមិញនោះ មិនមែននឹងខុសតែខាងលោកទេ ចំណែកខាងខ្លួនខ្ញុំបាទ ក៏បានប្រមាទខុសដូចគ្នា លោកក៏ត្រូវអត់ទោសឲ្យខ្ញុំផង ឡៅពីនឹងចាំនឹងថនពាក់ព័ន្ធពីរនាក់និយាយគ្នាដូច្នោះហើយ ក៏នាំគ្នាសើចហើយសន្ទនានឹងគ្នាជាប្រក្រតីទៅ ។

តាំងពីខ្មៅដៀងចៅហ្វាយស្រុកសែលួន ដឹងថាខ្មៅពីវាយយកយាងបន្ទាយចោយស៊ីគួន ហើយសម្ងាប់អៀវហ៊ួយ ពោងាយ ក៏ឲ្យលើកទាហាន ៥ ម៉ឺនទៅតាំងបន្ទាយនៅស្រុកឡុកសៀ រហូតទៅជិល់ខ្សែវហ៊ុយឲ្យងៀមងាំនតាំងផ្ទួរលើកទ័ពទៅស្រុកឡុកសៀ ។

ឯខ្មៅដៀងដឹងថា ខ្មៅតីលើកទាហានចូលវាយយកបន្ទាយចោ៉យ-ស៊ីគួនបាន ហើយសម្ងាប់អៀវហ៊ួយនឹងកោងាយដូច្នោះ ក៏ព័យណាស់ ទើបឲ្យហៅនាម៉ឺនចូលមកប្រឹក្សាការពារការថា វេលានេះ ខ្មៅតីលើកទ័ពមកប្រទូសវ៉ាយយើង វាយយកបន្ទាយចោ៉យស៊ីគួនបានហើយ តើយើងនឹងគិតរក្សាស្រុកប្រការម្តេច ទើបនឹងកំចាត់ខ្មៅតីវិញបាន អ៊ុយគួនថា ដែលខ្មៅតីលើកទ័ពមកគ្រានេះ យើងនឹងគិតរក្សាស្រុកទុកនោះ សូមឲ្យលោកចាត់កងទ័ពលើកទៅតាំងបន្ទាយស្កាត់ នៅស្រុកឡុកសៀ ព្រោះស្រុកនោះជាមាត់ផ្លូវ ត្រូវចូលមកជាច្រកចង្អៀតណាស់ ពោះបើជាទាហានខ្មៅតីនឹងមានថ្មីដៃខ្លាំងពូកែយ៉ាងណា ក៏នឹងរៃកទំលាយចូលមកមិនបាន ស្មៅដៀងក៏យល់ឃើញផង ទើបចាត់ប្រើឡើងចៅ ខ្មៅកុយ ខ្សែវយើមតេងហៀន ឲ្យលើកទាហាន ៥ ម៉ឺនទៅតាំងយប់–ថ្ងៃនឹងតាំងបន្ទាយនៅស្រុកឡុកសៀ ។

ការទាហាន ៤ នាយលើកទៅដល់កណ្តាលផ្លូវ ខ្មៅកុយនិយាយ

ឆ្លើយទៅប៉ៅ ខៀវយើម តេងហៀនថា យើងបានឮលឿតេនិយាយតាំដើមមក
ថា កុងដំបន់តំតមបំនសានោះ មានអាចារ្យម្នាក់ឈ្មោះដាហោតាយិន
មានសតិប្បញ្ញាប្រកបដោយវិជ្ជាការចំណាន ដ៏ឆ្លាស់លក្ខណៈមនុស្ស
មានគ្រោះកាចឬល្អ ហើយនឹងដឹងរស់ដឹងស្លាប់គ្រប់ប្រការ ឥឡូវត្រូវយើង
តេចូលទៅសន្ទនានឹងគ្រូនោះ ឲ្យពាក្រោះមើលខ្លួនយើងនឹងល្អឬអាក្រក់
ខៀវយើមថា ដែលកើតមកជាមនុស្សនេះ ក៏រមែងមានសេចក្តីស្លាប់ទៅជា
ធម្មតា នរណានឹងរួចពាកសេចក្តីអន្តរាយនោះគ្មានទេ ខ្លួនយើងជាជាតិ
ពាហានឹងចេញទៅធ្វើការរណរង្គសង្គ្រាម ដែលនឹងមកតតែតក្តថា ក្រែង
ល្អអាក្រក់នាំឲ្យតក់ស្លុតមិនបានយកចិត្តខ្លួនជាប្រមាណ ហើយនឹងទៅសួរ
ពតិមានមនុស្សអ្នកក្រៅនៅកងក្រៃ ឲ្យដួយលុបលាងចាបគ្រោះចំពោះខ្លួន
នោះ មិនត្រូវការសោះ ។

ខ្លៅកុយថា អ្នកនិយាយនេះតើមិនបានពាប់អានតតិបូកណា មានតែ
ខុសអំពីប្រពៃណីលោកពាំងអស់ ធម្មតាមនុស្សដែលមានសតិប្បញ្ញានោះ
តេរមែងសាកសួរដល់មនុស្សចាស់ព្រឹទ្ធាចារ្យជាមិនាង តួរតែយើងទៅ
តំនាប់ទើបគួរ ឡើងប៉ៅ តេងហៀន ខៀវយើម បានស្តាប់ឡៅកុយនិយាយ
ដូច្នោះ កំស្រុះស្រួលបបួលគ្នាចូលទៅកុងក្តំតមបំនសាន ឃើញដាហោ-
តាយិនអង្គុយលើត្រែ កំចូលទៅក្រាបនមស្សការហើយនិយាយថា ខ្ញុំ
បានគាំគ្នាចូលមកតំនាប់លោកវេលានេះ ក្រុងក្នុងនឹងសុំយកតម្រិះក្រុងក្ស

របស់លោកឲ្យជួយមេត្តាខំទុកបំរុង ព្រោះឡៅដៀងជាទាយចៅហ្វាយ
ប្រើឲ្យយើងខ្ញុំទាំងអស់គ្នានេះ លើកកងទ័ពចេញទៅការពារបច្ចាមិត្រ គឺ
ឡៅពីទៅស្រុកឡុកសៀ ការដែលទឹងទៅធ្វើសង្គ្រាមគ្រានោះ តើទឹងជា
ល្អឬអាក្រក់ប្រការម្តេច សូមឲ្យលោកមានសេចក្តីករុណាពិនិត្យពិចារណា
មើលគ្រោះយាមឲ្យគាន ។

ជីហោគោយិនក៏ឆ្លើយថា ខ្ញុំនយើងជាមនុស្សអ្នកព្រៃមានស្មារតីប្រាជ្ញា
តិចណាស់ ដែលអ្នកទាំងអស់មកសួរដេញដោងឲ្យយើងប្រាប់សេចក្តីអាក្រក់
ល្អគ្រៅខាងមុខនោះ យើងមិនអាចនឹងថាបាន ឡៅកុយក៏សំពះអង្វរជា
ច្រើនគ្រា ជីហោគោយិនអត់មិនបានក៏យកកូនទឹងពិតមកសរសេរជាសេចក្តី
ថា មកទឹងជាឆ្នាំទឹងចូលមកនៅកងស្រុកសែឈួន ចំណែកហង្សមាន
ស្លាបហើរបាន តែមិនអាចនឹងហើរទៅដោយអាកាសវេហាស៍ ឆ្លាក់គ្រាំ
គ្រាទៅលើផែនដី មកវគ្គានស្លាបសោះ តែអាចនឹងហើរហោះទៅសំដែង
អានុភាពទៅលើអាកាសបាន បើអ្នកឯណាដឹងច្បាស់លក្ខណៈដូច្នេះហើយ
ក៏ចូលរិះគិតប្រៃប្រួលដើម្បីទឹងរក្សាខ្លួនឲ្យមួនមាំចុះ ទើបទឹងរួចពាក់អន្តរាយ
ក្នុងគ្រានេះបាន ។

ឡៅកុយតបថា ខ្ញុំបាទដំរកបសួរលោកនេះ ប្រាថ្នាទឹងចង់ដឹងច្បាស់
ហេតុផលក្នុងខ្លួន យើងខ្ញុំទាំង ៤ នាក់នេះទឹងជាល្អឬអាក្រក់ប៉ុណ្ណោះទេ
ដែលលោកមកថាប្រៀបប្រាយឲ្យវែងឆ្ងាយដូច្នេះ ក៏មិនជាប្រយោជន៍ចំ-

រោះដល់យើងខ្ញុំនោះ ជាហោគោយិនថា បណ្ដាបុណ្យទឹងកម្មដែលអ្នក
សួរយើងនោះ កំមិនត្រូវការនឹងប្រាប់ចាន់ទេ ការគាក្រក់ល្អនោះកំរែមឯ
សម្រាប់ខ្លួនរាល់គ្នា នរណានឹងប្រាប់ចាន់ ថាហើយក៏ឆ្លងភ្នែកអង្គុយ
ស្ងៀមទៅវិញ ខ្មៀវយឺមឃើញដូច្នោះក៏ថា យើងមកចរចាជាមួយនឹង
មនុស្សបង់ចរិតដូច្នេះមិនត្រូវទេ មកយើងទៅវិញចុះ ថាហើយក៏នាំគ្នា
ត្រឡប់ទៅឡើងសេះនាំគាហានស្រុតទៅដល់ស្រុកឡុកសៀ ឡៅកុយថា
ស្រុកឡុកសៀនេះជាទីសំខាន់ណាស់ បើបណ្ដាយឲ្យខូចដំបន់នេះហើយ
ក៏ដូចជាខូចដល់ស្រុកសែឈួនតែម្ដង ហេតុនេះត្រូវតែតាំងបន្ទាយខ្ជាប់ខុក
ពីខាងក្រកក្នុងស្រុក ដើម្បីកុំឲ្យកងទ័ពឡៅពីកន្លងចូលមកបាន ។
ឡៅចៅ តេងហៀន យល់ឃើញផងក៏ឃុំនាំគាហាន ២ ហ្មឺនលើកចេញ
ទៅតាំងបន្ទាយស្កាត់ផ្លូវខ្ជាប់តាមក្រកចង្អៀតនោះ ឡៅកុយនឹងខ្មៀវយឺម
ក៏តាំងនៅរក្សាស្រុកឡុកសៀ ។

ឯឡៅពីក៏ប្រឹក្សានឹងចាំងថងថា ឥឡូវនេះយើងចូលទៅកាន់ស្រុកសែឈួន
ខ្លួនគាហានចូលមកប្រាប់ថា ឥឡូវ
ឡៅជៀនឲ្យលើកទ័ពទៅតាំងបន្ទាយក្នុងស្រុកឡុកសៀ ដើម្បីនឹងការ-
ពារក្សាស្រុកនេះខុក ហើយឲ្យឡៅចៅ ខ្មៀវហៀន ចាំង ២ នាយ
នេះឃុំនាំគាហាន ២ ម៉ឺន ទៅតាំងបន្ទាយនៅក្រកចង្អៀតតាមផ្លូវប្រហែល
ចម្ងាយ ៦០០ សិន (២៤ គ.ម.) ឡៅពីក៏សួរគាហានចាំងពួងថា គ្រានេះ

នរណាខឹងអាចយកអាសាទៅវាយបន្ទាយត្រង់ប្រកបរង្គៀតនោះបាន ហង
តុងខួលក៏ច់ខ្លួនយកអាសាថា ខ្ញុំបាទខឹងសុំទៅវាយឲ្យបាន ឡៅតីថា
អ្នកខឹងខួលទៅធ្វើការគ្រានេះកំណួរហើយ ហង់តុងមានចិត្តត្រេកអរ
ណាស់ តំនាប់លាខឹងចេញទៅចាត់ចែងការហាន ខួលអ៊ុយអៀនចូល
មកនិយាយខឹងឡៅតីថា ដែលហង់តុងខឹងយកអាសាទៅធ្វើការនោះកំណួរ
ហើយ តែខ្ញុំបាទឃើញថា ហង់តុងជាមនុស្សចាស់ជាណាស់ សុំឲ្យគាត់
នៅវិញចុះ ខ្ញុំបាទខឹងយកអាសាទៅវិញ ហង់តុងឮដូច្នោះក៏ខឹងណាស់
និយាយថា អ្នកនេះមាក់ងាយប្រមាថយើងពន់ពេកណាស់ អ៊ុយអៀនថា
ខ្ញុំមិនបានមើលងាយប្រមាថអ្នកទេ ខ្លួនអ្នកពូកែមានថ្វីដៃក៏មែនហើយ តែ
ជាខ្លួនអ្នកចាស់ហើយ ឋយកម្ចាស់មិនដូចតាក្មេង ឯឡៃនជ្មៅ តេនហៀន
តាំងពីនោកនេះជាតាហានឯកក្នុងស្រុកសៃឈួនមានថ្វីដៃខ្លាំងពូកែ ហើយ
ស្មុគស្មាញនៅក្មេងមានកម្លាំងច្រើន ក្រែងអ្នកជាមនុស្សចាស់ជាធំថ្លង់ការ
ទៅ បានជាខ្ញុំសូមខ្លួនទៅដំទួសអ្នកកុំឲ្យលំបាក បើខ្ញុំនិយាយការល្អដូច្នេះ
ហេតុម្តេចក៏អ្នកខឹងទៅវិញ ហង់តុងថា អ្នកសំគាល់ថាយើងជាមនុស្ស
ចាស់អស់កម្លាំងពីក្នុងខ្លួនហើយឬ បើខ្លួនអ្នកនៅក្មេង ចូរមកល្បាំងលេង
នឹងថ្វីដៃយើងមើល អ៊ុយអៀននឹកខឹងណាស់ថា អ្នកនឹងខ្ញុំ មកតស៊ូគ្នា
មើលក៏មកចុះ ហង់តុង ក៏ហៅបាវឲ្យទៅយកលំពែងមកនឹងតយុទ្ធគ្នា
នឹងអ៊ុយអៀន ។ (នៅមានត)

រឿងល្បែកឡាហ្វុងតែន

លោក ដេង - ទ្រីវ ប្រែរៀបរៀង

(តមក)

៤៦_ អ្នកជួសជុលស្បែកជើងនឹងសេដ្ឋី

អ្នកជួសជុលស្បែកជើងម្នាក់ ច្រៀងពីព្រលឹមទល់ប្រលប់ដោយធ្វើការបណ្តើរ គួរឱ្យស្អប់មើលនឹងពីកេះស្តាប់ពេក គាត់ចេះពាយខ្ទុកល្អស្តាប់ជាងគេឯងកាល់គ្នា ។

នៅក្បែរខ័ណ្ឌនោះ មានមនុស្សម្នាក់ទៀតមានសភាពផ្ទុយពីអ្នកខាងលើ មានទ្រព្យច្រើន ច្រៀងតិច ដេកមិនកំសូវលក់ គឺជាសេដ្ឋី ។

ប្រសិនបើទៀបភ្លឺ សេដ្ឋីចង់ងុយដេក ជាងជួសជុលស្បែកជើងច្រៀងពាល់តែលោកលើក រកដេកមិនកើត ហើយលោកគួញភ្នែរថា ហេតុអ្វីក៏ព្រះជាម្ចាស់មិនព្រមធ្វើឱ្យគេមានលក់ដេកនៅឯផ្សារ ដូចជាគេលក់ចាយទឹកត្រប់សព្វថ្ងៃ ។ លុះព្រឹកឡើងភ្លឺច្បាស់ សេដ្ឋីឱ្យហៅជាងជួសជុលស្បែកជើងមកកន្លែងប្រាសាទលោក ហើយជណ្តើងសួរថា: «ម្ចាស់ព្រះស្តែន! ឯងចំណេញបានប៉ុន្មានក្នុងមួយឆ្នាំ?» ។

ជាងជុលស្បែកជើងឆ្លើយផងសើចផងថា: «លោកម្ចាស់! ខ្ញុំបាទមិនមានទម្លាប់ខាងគិតកប់ឱ្យដឹងបានប៉ុន្មាន ។ ដូចជាលោកម្ចាស់សួរនោះទេ ខ្ញុំបាទមិនដែលបានសន្សំខុកពីមួយថ្ងៃទៅមួយថ្ងៃឡើយ ខ្ញុំបាទគិតធ្វើដូចម្តេចឱ្យតែជាប់ឆ្នាំ ខ្ញុំក៏បានជាប់ឆ្នាំដែរ តាមពាក្យគាប៉ុណ្ណឹង គឺថាធ្វើ

មួយថ្ងៃ ទទួលបានរូចមួយថ្ងៃ » ។

សេដ្ឋីសួរទៀតថា : « ចុះមួយថ្ងៃឯងរកបានប៉ុន្មាន? » ។

ជាងជុលឆ្លើយដំកបថា: « ជួនកាលច្រើន ជួនកាលតិច ហើយមកទាស់បន្តិច កុំអីតែមានសល់ទេ: ទាស់ត្រង់មួយខ្នាំត្រូវឈប់ច្រើនតេបង្ហាញតែដោយពាក់ពីបុណ្យច្រើនពេក ពីបុណ្យមួយទៅបុណ្យមួយ ហើយលោកគ្រូចេះតែឡើងគ្រែទេសន៍កល់អាទិត្យ » ។

សេដ្ឋីអស់សំណើចនឹងជាងជុលនិយាយត្រង់គ្មានលាក់ ក៏មានពាក្យថា « អញចង់លើកឯងជាក់លើបល្ល័ង្ក ហ៊ឺ យកប្រាក់ខាយអេគុយ[1] (Ecus) នេះទៅចុះ ត្រូវថែរក្សាឲ្យស្រួល ទុកវាគ្រាន់ប្រើប្រាស់កន្លងពេលដែលត្រូវការ » ។

ជាងជុលស្បែកជើងត្រេកអរពេក គិតស្មានថាម្តងនេះ គាត់បានប្រទះសម្បត្តិទៅលើផែនដី ដែលមានមកតាំងពីបឋមកប្ប សម្រាប់ឲ្យមនុស្សទាំងអស់ប្រើប្រាស់នោះ ហើយប្រញាប់ប្រញាល់ទាំងញាញ៉ាញាញ៉ាត្រឡប់ទៅផ្ទះវិញ រួចយកប្រាក់ទៅកប់លាក់ទុកក្រោមផ្ទះ មិនកប់តែប្រាក់ថែមកប់ទាំងការសប្បាយផង ប្រាត់ប្រឿងអស់រលីង តាំងពីបានប្រាក់មកពេលណា ការដេកលក់ក៏ថយចេញពីផ្ទះប្រាត់ មានតែសេចក្តីព្រួយការសង្ស័យនឹងការកេតកំយុតប្រយោជន៍មកជាគ្នាវិញ មួយថ្ងៃៗក្តៃសំឡឹងសំឡក់ទៅតែប្រាក់ ពេលយប់ខ្នាលោតគុប ថាខ្មាស្លួចប្រាក់ ។

១– អេគុយ: តម្លៃប្រាក់បុកណានៃប្រទេសបារាំង ត្រូវជា ៦០ សេន ។

ខាងក្រោយមក ឃើញថាឆ្មាយហត់ខាន់ពេក គាត់ស្ទុះរត់ទៅផ្ទះសេដ្ឋី ហើយដាក់បថាៈ សូមលោកម្ចាស់មេត្តាឲ្យចម្រៀងនឹងដំណេកលក់ មកខ្ញុំ ចុះវិញ ហើយត្រឡប់យកប្រាក់លោកម្ចាស់ទៅវិញចុះ »។

ប្រាក់មិនផ្តល់សុភមង្គលទេ
ប្រាក់ជាអ្នកបំរើល្អ
តែជាម្ចាស់អាក្រក់ ។

៤៧- សត្វលានឹងម្ចាស់

សត្វលារបស់អ្នកសួនបន្លែម្នាក់ ចេះតែគ្មញ្ញាក្បែរនឹងភសាររបស់ពថា ហេតុអ្វីក៏គេឲ្យអញក្រោកតាំងពីមុនមាន់រងាវកល់ថ្ងៃរកតែដេកពុំបាន មាន់រងាវពីយប់មែន តែអញភ្ញាក់ពីមុនមាន់រងាវទៅទៀត តើព្រោះហេតុអ្វី ? ព្រោះតែប្រញាប់ដឹកស្មៅទៅផ្សារ ។ រឿងហ្នឹងហើយជាការសំខាន់ដែលនាំឲ្យអញខានដេកពួន ។

សេរីបានឮលាឆ្លើយថ្លង់ៗ អាណិត កំយកឲ្យទៅនៅនឹងម្ចាស់មួយទៀត គឺអ្នកធ្វើស្បែកដើងលក់ ។ លុះនៅបានបន្តិច ណាឆ្នូ ណាស្មុយនឹងកូនស្បែក ធ្វើឲ្យលាព្រួលពិបាកចិត្តទៀត ក៏គិតថា « អញខឹក ។ ទៅស្តាយម្ចាស់ដើមអ្វីម៉្លេះទេ បើគាត់គាល់យតែងាកបែរទៅខាងនេះខាងនោះ អញលួចជ្រុចស្តែមួយម៉ាត់ពីរស៊ីបាន គាត់ក៏គ្មានថាអ្វី ទៅឯកន្លែងនេះគ្មានលេសអ្វីសោះ ប្រសិនបើលួចបានខ្លះ មុខជាត្រូវនឹងដំបងមិនខាន »។

សេរីយកវាទៅឲ្យទៅទីឯអ្នកធ្វើឆ្នាំងវិញ ។ ក្នុងកន្លែងនេះ លាតែងតែដេកក្រោយគេបង្អស់ទៅរៀត លាចាប់ផ្តើមរៀត ។ សេរីទីឯពេកនិយាយថា: « ចុះអ្វីរៀតហើយ ! អាសត្វចង្រៃនេះ ធ្វើឲ្យអញរវល់តែទីឯក ជាឯស្តេច ១ យេនតរទៅរៀត ក៏ស្មានថា មានតែកម្លាំងឯងទេ ដែលមិនស្លាប់បានសុ ១ឬ ? ដូច្នេះអញមិនរវល់តែទីឯរឿងវាទៅហើយឬ ? » ។

សេរីថាត្រូវ មនុស្សទាំងអស់ច្រើនតែដូច្នេះឯង គឺច្រើនតែមិនត្រេកអរទីឯកាសនាបេសៗខ្លួន ។

៤៨- ព្រះអាទិត្យនឹងព្រះពាយ

ព្រះពាយនឹងព្រះអាទិត្យ យើញអ្នកដំណើរម្នាក់ មានសំលៀកបំពាក់ត្រជាក់គ្រាន់ ដើម្បីការពារទីឯ ១ល្អត្រមាំងតំណៅថ្ងៃ ។ ពេលនេះចួលកន្លងសេះវេះវេរហើយ ឃាតជាអ្នកដំណើរទាំងឡាយប្រយ័ត្នឲ្យមានគ្រឿងប្រដាប់សព្វគ្រប់: ភ្លៀងរួចបើកថ្ងៃ មានឥទ្ធនូសម្រាប់ឲ្យដំណឹងដល់អ្នកដំណើរជាមុនថា បើចេញដំណើរ ត្រូវឲ្យមានអាវភ្លៀង ព្រោះវេរនេះ ភ្លៀងធ្លាមិនខៀង ។ ព្រះពាយពោលថា: « បុរសនេះគិតស្មានថាគេមានរបស់គ្រប់គ្រាន់សម្រាប់ការពារទីឯគ្រោះថ្នាក់ តែគេមិនដឹងថាអំណាចខ្ញុំចក់តែមួយវិប រវើកឡើងអស់មិនដឹងសោះ ខ្ញុំចង់ធ្វើឲ្យគាវភ្លៀងហ្នឹងខ្លាតទៅបាត់ឥឡូវ ។ យើងធ្វើលេងល្បងមើល ប្រហែលសប្បាយព្រះអាទិត្យចួលចិត្តផងឬទេ ? ព្រះអាទិត្យធ្វើយថា: « បើដូច្នេះ តួរក្លាល់គ្នា

វិញ តើយើងគាំងព័រនាក់ អ្នកណាអាចធ្វើឲ្យអាវក្រៀងនៃអស្ចារ្យនេះ
របើកចេញពីស្មាបាន? ចូរព្រះពាយផ្ដើមធ្វើមុនចុះ ខ្ញុំបើកដៃឲ្យព្រះពាយ
ធ្វើឲ្យងងឹតបាត់តទ្ធឹង្ហឹតាំងអស់ » ។

ព្រះពាយហេតុតែចង់ឈ្នះព្រះអាទិត្យ កំគាំងដំឡើងឫទ្ធិកើត
ជាខ្យល់បក់មក កើតជាព្យុះសង្ឃរា បក់របើកដំបូលផ្ទះដែលនៅចំពីមុខ
ខ្លួនឯងអស់ ចំណែកខាងផ្ទៃទឹកវិញ កប៉ាល់ ទូក តូច-ធំលិចលង់ ស្លាប់
មនុស្សអស់ជាច្រើន មកតែពីចង់ឲ្យអាវក្រៀងអស្ចារ្យនេះបើកចេញពីខ្លួន
ប៉ុណ្ណោះ ។ អស្ចារ្យនេះខំប្រឹងទប់មិនឲ្យខ្យល់ព្យុះបក់បូលកន្ទងអាវក្រៀង
បាន ព្រះពាយខំបក់ខាងពេល រឹតបក់ណាស់ តេកំខំប្រឹងទប់អាវក្រៀង
ខ្លុកយ៉ាងជាប់ ប្រឹងបក់ដល់ពេលសន្សៅតែមិនរបើក ។ ព្រះអាទិត្យ
ចេញក្រែតពីពពក បញ្ចេញរស្មីចាំងទៅលើអស្ចារ្យនេះដែលខើបនៅសើម
ថ្នី។ ចាំងចូលរហូតកន្ទងអាវ ឃុបបន្តិចអស្ចារ្យនេះចាប់ចែកញើស ស្ទុះអត់
ទ្រាំមិនបាន ពាល់តែដោះអាវចេញពីខ្លួន ធ្វើប៉ុណ្ណឹងទៅមិនពាន់អស់ខំ-
ហឺនព្រះអាទិត្យធង ។

សឹមៗប្រសើរជាងកុងកាំង ។

៤៩- ស្លឹកត្រចៀកទន្សាយ

មានសិង្ហមួយ មិនដឹងជាម្រឹតណាបានធ្វើឲ្យរបួសដោយស្នែង កំប្រ-
ឡោតខឹងយ៉ាងខ្លាំង ។ ដើម្បីកុំឲ្យមានរឿងយ៉ាងដូច្នេះទៀត សិង្ហ

ចេញច្បាប់បញ្ញត្តហាមមិនឲ្យសត្វមានស្នែងចាំងប៉ុន្មាន អាស្រ័យនៅក្នុងព្រៃជាទីហានរបស់ក់ ។ ឥឡែ - ញ៉ាឈ្មោល គោឡើងក ងាំគ្នាផ្ទាស់កន្ទែងមួយរំពេច ក្តាន់ ច្រើស រមាំង ក៏ត្រូវផ្ទាស់កន្ទែងរៀងខ្លួន ។

មានខន្ធកយមួយ ដែលឃើញស្រមោលស្នឹកត្រចៀកខ្លួនឯង ស្រាប់តែភ័យខ្លាច ក្រែងអ្នកគាន់អាជ្ញាថា ស្នឹកត្រចៀកជាស្នែងដែរ ព្រោះវែងដូចស្នែង ក៏គោលក្រាប់ចង្រឹតថា «ខ្ញុំសូមលាបងចង្រឹតហើយ ខ្ញុំត្រូវដើរចេញពីទីនេះ ព្រោះស្នឹកត្រចៀងខ្ញុំដូចជាស្នែងដែរ» ។

ចង្រឹតឆ្លើយថា: «អីបងឯងថា ស្នឹកត្រចៀកជាស្នែង? បងឯងថាខ្ញុំជាក្អមមិនដឹងអ្វី! អាហ្នឹងគឺជាត្រចៀក ដែលព្រះបានបង្កើតមកដ៏ពិតប្រាកដ» ។

ខន្ធកយឆ្លើយតបទាំងភ័យថា «ទៀងតែគេថាស្នែងហើយបង! ហើយជាស្នែងដ៏វែងផង ខ្ញុំដេកគិតជញ្ជឹងយូរណាស់ដែរហើយ នៅតែយល់ច្បាស់ដោយខ្លួនឯងថា ប្រាកដជាស្នែង បើដូច្នេះ ត្រូវតែដើរចេញកុំឲ្យខុសទំនឹងអាជ្ញា ។

៥០- មេឆ្កែជើមធឹងមិត្រភាព

មេឆ្កែមួយឈឺគោះដឹតសម្រាលកូន មិនដឹងរកកន្ទែងឯណានឹងសម្រាលបាន ទើបនិយាយអង្វរសុំកន្ទែងមិត្រភ័ក្តិ ដោយទើសចាស់ មិនដឹងថាដូចម្តេច ក៏ព្រមឲ្យមេឆ្កែនេះសម្រាលកូនក្នុងកន្ទែងរបស់ខ្លួន ។

ចានប្រហែលកន្លះវា មេឆ្កែជាមិត្តត្រឡប់មកវិញ ដ្បិតមេឆ្កែនោះសម្រាលកូនរួចហើយ ។ មេនេះសុំអង្ករកន្លះវាទៀត ព្រោះកូនដើរមិនទាន់ចានស្រួល ។ មិត្តវាយល់ព្រមឲ្យម្ដងទៀត ។ លុះថ្ងៃសន្សាំ២មក ដល់ នាងមេឆ្កែជាមិត្ត ត្រឡប់មកសុំផ្លុះ ភន្លែងនឹងវែត្រលប់ទៅវិញ ។ ពេលនេះ មេឆ្កែសម្រាលកូនចប់ភ្លេញឆ្មេញសស្វាចហើយគំហែងថា «បើមីហង៍ឯងហ៊ានតែបណ្ដេញអញឲ្យចេញទៅក្រៅ អញនឹងចេញទៅក្រៅមីហង៍ឯងជាមួយនឹងកូនអញឥឡូវ ។ ដ្បិតកូនវាធំៗអស់ហើយ ។

បេះដែលគេឲ្យដល់មនុស្សអាក្រក់កំណាច រមែងតែនាំឲ្យស្ដាយក្រោយ ព្រោះបើចង់ទារយកមកវិញ មានតែបាក់ទឹងចិត្ត គឺជាត្រូវតែកើតក្តី ត្រូវតែឈ្លោះប្រកែកគ្នាជាជម្មតា ហើយបណ្ដាយឲ្យមនុស្សក្រំ-ណាចឈានបានមួយដំហានហើយ មិនយូរមិនឆាប់ទេ មុខជាកើតមានដំហានទៀត បន្តិចជា ៤ឥឡូវ ។

៥១- មនុស្សក្រំណាញ់ធឹងកំណាប់ទ្រព្យ

មានបុរសម្នាក់ ជាអ្នកវង្សខ្សត់ខ្លា មានទ្រព្យច្រើន តែតប់រុងតុកយកទៅប្រើប្រាស់ដល់ជាតិក្រោយ មានទ្រព្យដូចជាគ្មាន មានហើយយកទៅកប់តុកក្នុងដី មិនកប់តែទ្រព្យកប់ចាំងតំនិតផង ចាំងថ្ងៃចាំងយប់តែងបណ្ដាយឲ្យចិត្តមច្ឆរិយៈលុកលុយក្នុងសន្ដាន តុកទ្រព្យដូចជាវត្ថុដ៏គោរព ដែលគេត្រូវលើកទឹកពុំក្ដេច ចាំងទៅចាំងមក ចាំងស៊ីចាំងធឹក

គ្មានចន្លោះពេលណាដែលបុរសនោះមិនគិតទៅទ្រព្យ ដែលកប់ទុកក្នុងដី គាត់ចេះតែទៅពិនិត្យមើលញឹកញាយពេក ទាល់តែអ្នកជិតដិះឃើញ ហើយសន្សំយកទៅដាក់មើល ឃើញកំណប់ហើយ លួចយកដោយស្ងាត់ទៅលាក់ចាត់ ។ ថ្ងៃក្រោយ បុរសកំណាញ់ទៅមើលកំណប់ទៀត ស្រាប់តែបាត់ ឃើញតែកន្ទេងទេ បុរសយើងតាំងស្រែកទ្រហោយំបរនទៀលដោយដី ហែកហួរខ្លួនច្រាណ ។

មានអ្នកដំណើរម្នាក់ដើរមក កំសួរអំពីរឿងយំស្រែក ។ បុរសកំណាញ់ឆ្លើយច្រាប់ថា: « គេលួចយកកំណប់របស់ខ្ញុំបាត់ » ។ អ្នកដំណើរសួរទៀតថា «កំណប់អ្នកឯងឬ? គេលួចយកពីកន្លែងត្រង់ណា?» ។ បុរសកំណាញ់ចង្អុលច្រាប់ថា ត្រង់ដុំថ្មហ្នឹងលោក ។ -ឥឡូវស្រែកកំពុងតែតបម្យ៉ាងឬអ្វី ? បានជាអ្នកឯងយកមកកប់ទុកឆ្ងាយម្ល៉េះ ? ប្រសិនបើជាទុកបន្ទប់ដំណេកអ្នកឯងផងមិនបានឬ? ប្រយោជន៍អ្វីបានជាថ្លាស់ទីកន្លែង? បើទុកទៅផ្ទះ អ្នកឯងយកប្រើប្រាស់តាមត្រូវការមិនស្រួលឬ ? ។ -ឧ ព្រះអើយ ! គ្មានន័យណាចាយកលំពេលទេ? ដូចលោកនិយាយនេះ ថាស្រួលណាស់ឬ? ច្រាក់ដែលបានមក ដូចជាចេញទៅវិញឬ? ខ្ញុំមិនដែលឃាល់ច្រាក់ហ្នឹងទេលោក ! ។ - សូមអត់ទោស បើដូច្នេះទៅគេតទុក្ខធ្វើអ្វី? បើអ្នកឯងមិនឃាល់ដដែល ចោះថ្មមួយដុំទុកត្រង់កន្លែងហ្នឹងទៅគំដូចគ្នាដែរ ។

៥២- ស្វាធំឯផ្សែត

មនុស្សជាន់ដើមនិយមលេងស្វាកំដើម្បីយកលុយ ។ ថ្ងៃមួយ ប៉ុស្តិ៍
អ្នកចង្វាក់ចាននាំស្វា ឆ្ពៃដំរសៅឆ្នេរសមុទ្រ ។ ដួនតាលមិនល្អ ឃ្យល់
បក់សំពៅលិចទៅក្នុងសមុទ្រ កុំតែចាននាងផ្សែតជួយ មនុស្សពាំងអស់ត្រូវ
ស្លាប់គ្មានសល់ ។ តាមក្នុងរឿង ព្រោះផ្សែតស្រឡាញ់មនុស្ស តែង
ស្រង់អ្នកលង់ទឹកយកមកដាក់លើខ្នងនាំមកខាង ។ ផ្សែតឃើញស្វា ស្មាន
ថាជាមនុស្សដែរ កំឡែងខ្នងហែលនាំមក ។ ខេសកាលអី ផ្សែតសួរ
ស្វាថា: «អ្នកឯងអាស្រ័យនៅក្រុង «អាថែន» ដែរឬ ? ។

ស្វាធ្វើយក្រាប់ថា: «ចា៎ ! គេស្គាល់ខ្ញុំច្រើនណាស់នៅក្រុងនោះ
បើអ្នកមានកិច្ចធុរៈអ្វី មករកខ្ញុំចុះ ដ្បិតបងប្អូនខ្ញុំសុទ្ធតែអ្នកមានមុខមាត់
ប្អូនដ៏ដួនមួយខ្ញុំម្នាក់ធ្លើរចៅក្រមផង» ។

ផ្សែតសួរទៀតថា «ខ្ញុំអរគុណហើយ ! ចុះកំពង់«តីរេ» អ្នកឯង
ធ្លាប់ប្រទះដែរឬ ? បើតាមខ្ញុំស្មាន អ្នកឯងប្រហែលទៅលេងកំពង់-
នោះញយ ? »

ស្វាធ្វើយក្រាប់ថា: «ខ្ញុំទៅលេងរាល់ថ្ងៃ អ្នកហ្នឹងត្រូវជាមិត្រភេរបស់
ខ្ញុំផង គឺជាអ្នកស្គាល់ឃ្លាហើយ» ។ ម្ដងនេះ អាស្វាយកឈ្មោះកំពង
ជាឈ្មោះមនុស្ស ។ មានមនុស្សច្រើន និយាយផ្ដេសផ្ដាសដូច្នេះ ដោយ
យកនេះជានោះ យកនោះជានេះ ហើយដួនកាលមិនដែលបានឃើញ កំ

និយាយកើតដែរ ។

សត្វផ្សេតឮអាស្វាថាដូច្នោះ សើច រួចដាកក្បាលសំឡឹងពិនិត្យយូរ ទើបស្គាល់ច្បាស់ថាវានាំយកខុសមនុស្ស ទៅត្រូវលើសត្វតិរច្ឆានវិញ ។ ផ្សេតខំលាក់ស្វាចោល ហើយវិលត្រឡប់ទៅរកស្រែដំមនុស្សវិញ ។

៥៣- ឆ្មានឹងកន្ត្រែង

ឆ្មានឹងកន្ត្រែងធ្វើដំណើរ ២ នាក់ទៅផ្លូវឆ្ងាយ ។ សត្វទាំងពីរសុទ្ធតែអាជើងទំលឹងតាងតែផ្លូវខូចដូចគ្នា ។ ដើម្បីរកស្បៀងអាហារតាមផ្លូវ ពាក់គ្នាលួចមាន់ លួចទា លួចប្រហុក លួចត្រីគេស៊ីរៀងខ្លួនតាមតែអាណាឆ្នាតយ៉ាងណាក៏ធ្វើយ៉ាងនោះ ។ ផ្លូវដូចជាឆ្ងាយណាស់បើដើរស្រួម ។ ។ ដើម្បីធ្វើផ្លូវឲ្យមានសភាពហាក់ដូចជាជិត គោងអាងាប់ពីរដងដែកគ្នាលេងតែអង្គុត ។ ដងែកនេះ មិនតឹបត្តិចបន្តិចឡើយ ដងែកខ្លាំងស៊ើរដូចជាគេចាស់គ្នា ប្រសិនបើអ្នកណាដែលឮ ទីឯចង់មកជួយឃាត់ បើមិនដងែកខ្លាំងដូច្នេះទេ វាចេះតែងងុយដេក ។ កំពុងតែដងែកគ្នា ស្រាប់តែឮសូរគេដើរនៅក្បែរខាង ។ កន្ត្រែងសួរទៅឆ្មាថា: « បងឆ្មាឯងអួតថាពូកែឆ្នាតណាស់ តើបងឯងឆ្នាតជាងខ្ញុំទៅទៀតឬ ? ខ្ញុំមានចំណេះមួយរយមុខក្នុងស្បែង » ។

ឆ្មាឆ្លើយថា: « ខ្ញុំមានតែមួយគត់ទៅក្នុងស្បែងខ្ញុំ ប៉ុន្តែមួយហ្នឹងស៊ើគេមានមួយពាន់ » ។

និយាយដូច្នោះហើយ អាចាំងពីរចាប់ប្រឡែងដណ្តែតគ្នាលេងតទៅ
ទៀត អាមួយថាឯងចេះ អាមួយថាឯងចុះ ។ អាចាំងពីរកំពុងតែថាឯង
ឯងចេះ ឯងចុះ ស្រាប់តែមានឆ្កែមួយហ្វូងមកដល់ ។ អាទិលចាំង
ពីរបាត់មាត់ឈឹង ។ ឆ្នាច្រាប់កន្ត្រោងថា « រើយអាសំឡាញ់ ! ខំប្រឹង
កកាយស្បែងឯងរកចំណេះដោះខ្លួនចុះ ខំប្រឹងឲ្យមែនទែន យើងជាន់
នេះកុនហើយ ចំណែកអញ។ មានហើយ » ។ គ្រាន់តែថាដូច្នោះ
ភ្លាម ឆ្នាលោតផ្លោតឡើងដើមឈើ ទៅទៅពួនឯមែកស្រេច ។ កន្ត្រោង
ខ្សែឡាតិតចុះតិតឡើងមួយរយេត្រឡប់ តែឥតប្រយោជន៍ ក៏រត់ទៅចូលក្នុង
រូងមួយ ឆ្កែចេះតែតាមខាន់ ចូលបានរូងមួយជ្រៅ ឆ្កែកកាយមិនបានសោះ
គេយកក្តីងំពក់ ឆ្កែនៅឃ្លាំចាំក្នុងត្រែកស្បែរខាងនឹងមាត់រូង ។ ដោយ
ថប់ធឹងផ្សែង កន្ត្រោងចេញមកវិញ ហើយលោតមិនបានពីរ-បីដងហាន
ផង ឆ្កែទាំក្រញីស្លាប់ ។

ចំណេះច្រើនតែមិនប្រាកដ នាំឲ្យខូចការ ការល់តែនឹងគិតរើស តើ
ត្រូវយកណា ចោលណា បើយើងប្រើតែមួយ ហើយឲ្យប្រាកដ គ្រាន់
បើជាង ។

(នៅមានត)

៦- រឿងព្រេងចិន

(តមក)

រឿង មេងគីយាង-នីយ៉ូ

6ème Meng Kiang-Niu

រឿងព្រេងជាតិហាន់

ព្រះចៅអធិពជនៃសន្តតិវង្ស «ស៊ីន» បានសោយរាជ្យជាលើកដំបូង ទ្រង់ព្រះនាមជេ-ហ្វាង-ទី ។ ព្រះចៅអធិពជអង្គនេះ មានព្រះពជហឫទ័យកាចសាហាវចំពោះប្រជារាស្ត្រ ។ ទ្រង់បានសម្រេចថាឲ្យប្រជារាស្ត្រស្ថាបនាទ្វារកំពែងធំមួយជុំវិញប្រទេស ដើម្បីការពារកុំឲ្យបច្ចាមិត្តចូលមកលុកលុយ ។

នៅក្នុងប្រទេសត្រង់ទីតមជនបទ គេបានឃើញមនុស្សដ៏ខ្លាំង មានកំឡាំងកំហែង ត្រូវគេដឹកនាំយកទៅធ្វើកំពែងធំនេះ។ កិច្ចការហត្ថកម្មនេះ បានប្រព្រឹត្តទៅជាដរាបគ្មានឈប់ឈរសោះឡើយ ។ យប់ថ្ងៃ ពួកនេះគាន់តែសង លីដង្ហិនឥដ្ឋ ហើយមានចៅហ្វាយនាយយកតំណាក់ជាយផង ដេរផងគ្មានក្រាប្រណី ។ គេឲ្យម្ហូបអាហារបន្ទិចបន្ទួចបរិភោគមិនស្កប់ស្កល់ផង ។ ពួកនេះ ស្ទើរតែតាក់សំពត់រហែកដាច ហើយមានស្លាប់ជាច្រើនក្នុងមួយថ្ងៃ ។ ។

បណ្តាពួកនេះ មានយុវនារីម្នាក់នាមកំង៍ស៊ីលាង៍ មានកិរិយាជាទារីល្អស្រស់ប្រឹមប្រិយ នាមនាង មេងគីយាង-នីយ៉ូ ។ ក្នុងគ្រានោះ នាង

មិនបានដំណឹងអ្វីពីស្វាមីនាងសោះឡើយ ។ នាងព្រួយបារម្ភជានិច្ច
រហូតនាងគិតក្នុងចិត្តថា ម្ដេចសម.ាមីនាងនៅក្តៅបាយយ៉ាងណាទៅ!
នាងមានចិត្តខ្មោចមនស្សយ៉ាងខ្លាំងចំពោះព្រះចៅអធិកជនេះ ដែលគ្រប់គ្រងប្រើ
អំណាចហួសប្រមាណ ធ្វើ.. នាងគ្រាប្រណីដូច្នេះ ។

មានកាលមួយថ្ងៃ គម្លាតត្រៃនាងតិណបៃតងស្រងាំត់ស្រស់ ប្ដូច
ខ្លាំងឡាយរីកស្គុះស្គាយតាសពេញអរញាក់ នាងម៉ងគីយាង-ទីយូ
គ្រាច់ទៅតាមចម្ការមួយ នាងបានឃើញត្រចៀកកាំងគួរហិចហើរ
សប្បាយលើនភាល័យ ហើយនាងច្រៀងថា:

ទិវាយរ-	ដូរព្រៃព្រឹក្ស
ជាតិបុប្ផាទឹក	រីកស្រស់ស្រាយ
ត្រចៀកកាំយំ	សព្វសប្បាយ
សុភមង្គលផ្សាយ	កន្ទឹមសំបុក ។
ត្រចៀកកាំគូ	ហើរត្រសង
លើមេឃាទ្ធង	ស្រើសោកខ្ពុក
ចារម្ភព្រួយរ-	លួយក្រៀមមុខ
ទកណែនបុក	ទឹកស្វាមី ។
ប្ដូនផ្កាំតាមទឹក	ទឹកនឹងប្ដូល
ប្ដូនផ្កាំតាមខ្យល់	ខ្យល់មិនស្ដី

ប្អូនផ្តាំតាមផ្លូវ មិនដឹងក្តី
ប្អូនផ្តាំតាមដី ស្វាត់សូន្យឈឹង ។

កាលកំអវណ្ណតត្រសែតលឿនទៅមុខ រហូតដល់សរទៈវស្សា ។ នាង
មេងគីយាង-ទីយូ មិនបានពត៌មានអ្វីពីស្វាមីសោះឡើយ ។ នាងបានដឹង
ថា នៅកំពែងធំខាងជើងបង្គស់នៃអធិរាជាណាចក្រ មានអាកាសត្រជាក់
ពន់ពេក ។ ក្នុងពេលនោះ នាងបានធ្វើភេសាវទឹងវស្សែតជើងសម្រាប់
ពាក់រដូវរងា នាងបម្រុងនឹងយកទៅជូនស្វាមី ។ តែ... ទុកម្នាអើយ!
តើអ្នកណានឹងយកប្រជាប់ប្រជាទោះទៅជូនស្វាមីនាង ។ នាងនឹកស្វាមី
ជាខ្លាំង ហើយ មានកាលមួយថ្ងៃ នាងតំរេកភេសាវទឹងវស្សែតជើងនោះ
ទៅជូនប្តីដោយខ្លួនឯង ។

នាងមេងគី-យាង ទីយូ ធ្វើដំណើរចេញពីគេហដ្ឋានទៅ តំទៅហមន្ត-
រដូវ ។ ក្តៅជាតិខាំងឡាយគ្មានស្ងឹកទេ រាលទេ ហើយទៅតាមផ្លូវ
ដែលនាងដើរ នាងជួបជាស្តុតទៅម្ខាក់ឯងកំព្រាវង្វាតតិចតួចពុំខាក់សោះ
ឡើយ ។ ដំណើរទោះត្រូវធ្វើរវែងឆ្ងាយណាស់ ហើយនាងមិនដឹងជា
កន្លែងណាដែលស្វាមីនាងស្ថិតទៅ តែនាងខំព្យាយាមសាកសួរតេតាម
ផ្លូវហើយក៏ដើរទៅបន្តិចម្តងៗ ។

មានសាយណ្ហសម័យមួយ ដោយនាងមិនបានទៅដល់ទីក្រុងដែល
នាងក្រឡេកទៅឃើញ នាងក៏មានចំណងចង់ទ្រទៅក្នុងព្រះវិហារតូច

មួយដែលមានរុក្ខាលតាវល្លិ៍ដុះព័ទ្ធជុំវិញនៅទីនោះ ។ ដោយនាងអស់កំឡាំងពន់ពេក នាងក៏អង្គុយលើសិលាវែងសណ្តូកដើង កំនត្រាលក់ទៅ នាងយល់សប្តិថាស្វាមីនាងបានវិលត្រឡប់មកវិញហើយ ។ នាងមានចិត្តសោមនស្សឥតឧបមា ។ នាងបានសួរស្វាមីនាង តើជីវភាពរបស់ឋនដែលនៅទីនោះបានប្រព្រឹត្តទៅដោយសុខដុមរម្នាឬ ? តែព្រលឹងនៃស្វាមីនាងបានតបនាងថា ខ្ញុំនស្លាប់ទៅហើយ ។ នាងកំយំខ្លួញសោកអាឡោះអាល័យស្វាមីនាង ....,

ដល់ព្រឹកស្អែក នាងភ្ញាក់ពីនិទ្រាឡើង នាងមានចិត្តសង្វែយពន់ពេក ហើយព្រួយឯកាអម្តាខ្លាំង ។ នាងមិនដឹងជានឹងគិតយ៉ាងណាចំពោះសុបិនន័មិត្តរបស់នាង ។ នាងមានចិត្តភ័យខ្លាចខ្លាំង ចំពោះអាកប្បកិរិយាដ៏កាចសាហាវយង់ឃ្នងនៃព្រះចៅអធិកជ ដែលធ្វើឲ្យគ្រួសារជាច្រើនវង្សពុក្ខភោសវេទនាជាខ្លាំង ។

នាងមេងគ័យាង-ឌីយូ ក៏បន្តដំណើរទៅទៀត ។ នាងដើរតទៅទៀតតាមផ្លូវឆ្ងាយដាច់ស្រយាល ។ មានមួយថ្ងៃ នាងឈប់សម្រាកទៅគោដន៏យដ្ឋានមួយកន្លែង ដែលមានយាយចាស់ម្នាក់កាន់កាប់ ។ យាយចាស់បានឃើញនាងមានខ្លួនបែកញើសជាបន្ទោរ ប្រញាក់ដោយផង់ធួលដ៏ដូច្នោះក៏សួរនាងថា នាងអញ្ជើញទៅណាមកណា ? នាងក៏បានជូនពត៌មានទៅយាយចាស់សព្វគ្រប់ប្រការ ។ យាយចាស់ក៏មានចិត្ត

អាណិតអាសូរនាងពន់ពេកណាស់ ។

យាយចាស់ក៏ពោលទៅកាន់នាងថា: «មិនដាក់គួរសោះ! កំពែងដំស្តិតនៅឆ្ងាយដាច់ស្រយាលពីនេះតទៅទៀតណាស់! នាងនៅក្មេងខ្ចីយ ហើយ ធ្វើដំណើរឆ្ងាយដាច់ស្រយាលបែបនេះគួរឬ? ពីនេះតទៅមានភ្នំធំៗ ជាច្រើន មានព្រៃក្រាស់ជ្រៅ មានជ្រោះថ្មតាជាច្រើនដែលនាងត្រូវឆ្លង! » ។ តែនាងមេឃគ័យាង -ទីយូបានដាក់បយាយចាស់ទៅវិញថា: « យាយ ខ្ញុំមានធនូ:ចង់យកទៅអាវរជាទៅដូនប្តីខ្ញុំ » ។ យាយចាស់ក៏ជូនដំណើរនាងបន្តិចជាការគួរសម ក៏វិលត្រឡប់មកកាន់តេជាដ្ឋានវិញ ។

នាងមេឃគ័យាង ទីយូ ក៏បន្តដំណើរតទៅទៀត ។ នាងបេះតែដើរមិនឈប់ឈរត្រង់ទៅមុខ ។ បន្តិចទៀត នាងត្រូវឆ្លងកាត់ភ្នំមួយ ។ ក្នុងពេលនោះ មានក្រយោងក់ត្រជាក់ មេឃក៏មានពពកមានពណ៌ប្រផេះស្រអាប់ ។ នាងត្រាច់ជាច្រើនម៉ោងដោយមិនឃើញមានខ្នុមណាមួយសោះឡើយ ។ នៅជុំវិញ នាងឃើញមានតែដុំសំណា នៅចំទៀក្នុ មានស្មៅដុះពាសពេញនឹងឈើបន្ទាជាច្រើន ។ យប់ឯងឹត នាងដើរមិនឃើញផ្លូវដើងសោះឡើយ ។ នៅដើងភ្នំនោះ មានទន្លេមួយមានទឹកហូរខ្លាំង ។ តើនាងនឹងទៅទិសណា? តាំងពីចេញដំណើរមក នាងមិនទាន់បានបរិភោគអាហារម្តងសោះឡើយ ។ ពេលយប់ នាងនិទ្រាផ្ទាំរចង្រ្កម់អស់ខ្នុងច្រាណ ។

នាងគោលចំពោះខ្លួនថា: «ទេស្វាមីអញ ព៉ន់ហ្សឺលាង មានការលំបាកជាជាងអញទៅទៀត! ស្វាមីត្រូវធ្វើលុំបាកធ្វើការក្នុងស្រុកដែលមានតែខឹកកកខ្លាំងត្រជាក់ពន់ពេកណាស់ .....» ។ ដល់ខឹកសត្វគ្រប់នាងក៏និទ្រាលក់ទៅ ។

លុះនាងភ្ញាក់ពីនិទ្រា ព្រះសុរិយោរះឡើងហើយបញ្ចេញរស្មីដ៏ភ្លឺត្រចះត្រចង់ ។ នាងក្រឡេកទៅឃើញ ភ្នំ ជ្រោះភ្នំ សំលៀកបំពាក់នាង សុទ្ធតែពាសពេញទៅដោយខឹកកក ។ តើនាងនឹងរកផ្លូវបន្តដំណើរតទៅទៀតបានឬ? ។

ក្នុងមួយរំពេចនោះ មានសត្វក្អែកមួយហើរចុះមកចំពីមុខនាង ។ ក្អែកនោះយំពីរដង ហើយក៏ហើរពីមុខនាងទៅ ។ នាងក៏ដើរតាមក្អែកនោះ គិតក្នុងចិត្តថាក្អែកនេះ ពាបង្ហាញផ្លូវអែញ! ហើយនាងក៏ច្រៀងថា:

សិសិរៈ	ខឹកកកខ្លាំក	ជុំមួលជួន់
គីយាងនិ-	យ្យូគោរខន់	ន៏កស្វាមី
យកគោអាវ	ព៉ន់ហ្សឺលាង	សាត្វាតថ្មី
សូមបានជួប	អ្នកប្រុសប្តី	តាមប្រាថ្នា ។
ក្អែកសប្បុរស	ហើរចន្លោះ	នភាល័យ
ម៉ាងានួន	ពិសម័យ	តែវស្នេហា
ទៅគាន់ចំ	ក៉ំពែងធំ	តាមប្រាថ្នា
ជួបប្រុសថ្លៃ	ថ្លើមចិន្តា	សែនសប្បាយ ។

(នៅមានត)

ជំយជំនះដោយយុត្តិធម៌របស់ខ្មែរនៅតុលាការអន្តរជាតិ

អំពីរឿងព្រះវិហារ

(តមក)

បន្ទាប់ពីលោកឌាន - អាឈីសុនមក លោកប្រ៉ូហ្សេរជុំនឹតូ បានឡើងថ្លែងយោបល់ក្នុងនាមនៃប្រទេសកម្ពុជា ដោយប្រើទឡ្ហីករណ៍ដ៏រឹងប៉ឹង ទឹងយ៉ាងខ្លាំងខ្លាយជាទីបំផុត ដែលយើងសូមបំប្រួញជូនដូចតទៅ។

ចម្លើយជំទាស់ (Objections) ជ័រ ដែលលោកសាស្ត្រាចារ្យ ជុំនឹតូបានបញ្ចេញយ៉ាងច្បាស់ ដើម្បីទាត់ចោលទឡ្ហីករណ៍របស់ថៃ ។

លោកសាស្ត្រាចារ្យប្រ៉ូហ្សេរជុំនឹតូ បានចាប់ផ្តើមអត្ថាធិប្បាយយ៉ាងខ្លាំងខ្លាយ ដើម្បីវែកញែកបដិសេធនិក្ខេបបទ (Thèse) របស់ថៃ ។ លោកបានដំកបតុលាការថា ទឡ្ហីករណ៍របស់ប្រទេសថៃជាទឡ្ហីករណ៍គ្មានតម្លៃ ព្រោះទឡ្ហីករណ៍នោះ ត្រូវជួបប្រទះការជំទាស់យ៉ាងជាច់ណាត់ ៣ យ៉ាងដូចតទៅ ៖

១- សាលក្រមដែលតុលាការបានសម្រេចអំពីរឿងប្រទេសអ៊ីស្រាអែលប្តឹង ចំពោះប្រទេសប៊ុលហ្គារីនោះ មិនអាចលើកយកមកធ្វើជាសំអាងដើម្បីវិនិច្ឆ័យសេចក្តីតវ៉ាជាបឋមរបស់ថៃ ដែលសុំបដិសេធសមត្ថកិច្ចតុលាការបានទេ ។

២- សេចក្តីប្រកាសឆ្នាំ ១៩៥០ របស់ថៃ មិនមែនជាអំពើមួយ ខាងនីតិវិធីទេ (acte de procédure) ។

៣- លក្ខណៈដ្ឋាន ដែលសេចក្តីប្រកាសឆ្នាំ ១៩៥០ ចានធ្វើ ឡើងមិនមែនជាចៃដន្យ បំភ្លាត់ការដែលប្រទេសថៃចានខ្លួលស្គាល់ សមត្ថកិច្ចនៃតុលាការអន្តរជាតិចានទេ ។

លោកសាស្ត្រាចារ្យចុំង្គូចានវែកញែកសេចក្តីដំណាស់ពាក្យ ៣ នេះ យ៉ាងវែង ដែលយើងសូមដកខ្លឹមសារយ៉ាងសង្ខេបដូចតទៅ ៖

អំពីសេចក្តីដំណាស់ទី ១

លោកចុំង្គូ ចានថ្លែងយ៉ាងអង់អាច ថាលោកហាក់ដូចជាភ្ញាក់ ព្រើត កាលណាលោកឃើញមេធាវីថៃ ចានលើកយកឈ្មោះអ៊ីស្រាអែល ទឹងប៊ុលហ្គារីនោះមកធ្វើជាសំអាង ។ លោកចានដកឧទាហរណ៍ មួយយ៉ាងកំប្លែងថា កាលសម័យមុន (Moyen âge) មានមេធាវីអង់-គ្លេសមួយ ចានធ្វើសេចក្តីអធិប្បាយបកស្រាយលក្ខន្តិក:មួយចំពោះមុខ រាក្រមនៃសភា ។ រាក្រមចានស្រែកច្រាបវិញថា « លោកមិន ចាច់ធ្វើអត្ថាធិប្បាយអំពីលក្ខន្តិក:ទេ ព្រោះយើងស្គាល់លក្ខន្តិក:នេះច្រើន ជាងអ្នកឯង ដោយខ្លួនយើងជាអ្នកធ្វើលក្ខន្តិក:នេះ » ។ កន្លងឧទាហរណ៍ នេះ លោកចុំង្គូ ចង់និយាយអំពីសាលក្រមដែលតុលាការអន្តរជាតិ ចានសម្រេចអំពីរឿងអ៊ីស្រាអែល ទឹងប៊ុលហ្គារី ។ សាលក្រមនេះ

ដូចគ្នានឹងលក្ខន្តិកៈកងទ័ពជាតិវៀត មិនបាច់ធ្វើអត្ថាធិប្បាយទេ ព្រោះចៅក្រមនៃតុលាការជាអ្នកធ្វើស្រាប់ហើយ ។ តែដោយប្រទេសថៃ បានលើកយករឿងនេះមកធ្វើជាសំអាង លោកត្រូវតែបកស្រាយសាលក្រមនេះឱ្យបានច្បាស់ដែរ ។ លោកចុំង្គូបានមានប្រសាសន៍ថា : ដោយលើកយករឿងអ៊ីស្រាអែល នឹងប៊ុលហ្គារីនោះ មកធ្វើជាសំអាង ប្រទេសថៃបង់ភាញហេតុផលផ្លូវច្បាប់ពីរយ៉ាងជាប់ឡែកពីគ្នា ៖

- ម្យ៉ាង ថៃបានសង្កេតថា សេចក្តីប្រកាសរបស់ខ្លួនចុះថ្ងៃ ២០ កញ្ញា ១៩២៩ ដែលបន្តឡើងនៅថ្ងៃ ៣ ឧសភា ១៩៤០ នោះត្រូវផុតលត់អស់អត្ថភាពទៅហើយ តាំងអំឡុងតុលាការអចិន្ត្រៃយ៍ (La cour permanente) បានរលាយទៅ (យើងសូមបញ្ជាក់ថា តុលាការអន្តរជាតិសព្វថ្ងៃនេះ ពីដើមឈ្មោះថាតុលាការអចិន្ត្រៃយ៍) ។

- ប៉ុន្តែ ម្យ៉ាងទៀត ថៃបង់ភាញពីសាលក្រមនូវគោលច្បាប់មួយដូចតទៅនេះ ។ ប្រសិនណាជាគេអាចពុកឱ្យទៅជាធរមានទូវកិច្ចព្រមព្រៀងសព្វថ្ងៃមួយ ដោយគ្រាន់តែប្រែប្រួលកម្មវត្ថុ ក៏ប៉ុន្តែគេមិនអាចធ្វើឱ្យមានជាធរមានឡើងវិញ នូវកិច្ចព្រមព្រៀងមួយដែលផុតលត់ទៅហើយនោះបានឡើយ» ។

លោកសាស្ត្រាចារ្យចុំង្គូ ចាប់ធ្វើយភ្លាមអំពីហេតុផលទីពីរនេះដែលថៃបានលើកយកមកធ្វើជាសំអាងដើម្បីបដិសេធថា សេចក្តីប្រកាស

របស់ខ្លួនចុះថ្ងៃទី ៦០ ខែសីហា ១៩៤០ វិតជាបានការទៅវិញ ។

១- លោកមានប្រសាសន៍ថា ការបកស្រាយសាលក្រមនេះ មិនអាចពន្យល់ហេតុផលផ្លូវច្បាប់ដូចពោលខាងលើទេ ។ ថៃបានគាត់យកភាគយ៉ាងខ្លីនៃឃ្លាដែលមាននៅក្នុងសាលក្រមនោះមកត្រជាង ដោយមិនព្រមអានឃ្លានោះពាំងមូលសោះ ។ ចំណែកឃ្លានោះពាំងមូល នៃសាលក្រមឆ្នាំ ១៩៤៨ ដែលស្តីអំពីរឿងអ៊ុំស្រាអែល ន៍ធប៊ុលហ្គារី បានឱយយល់ច្បាស់ អំពីការប៉ុនប៉ងយ៉ាងច្រើនក (Intention certaine) ដើម្បីធ្វើឱ្យមានជាធរមានឡើងវិញ ខ្លួវច្បាប់ដែលមានពីមុនមកហើយ ។

២- អំពីការដែលប្រទេសថៃបានពន្យល់ហេតុផលថា សេចក្តីប្រកាសរបស់ខ្លួន ៗជាអសារឥតការ លោកសាស្ត្រាចារ្យបានមានប្រសាសន៍ថា អាកប្បកិរិយាយ៉ាងជាក់លាក់របស់ថៃ បានបញ្ជាក់ឱ្យឃើញថា សេចក្តីប្រកាសឆ្នាំ ១៩៤៩ ន៍ធប្រកាសជាថ្មីពីឆ្នាំ ១៩៤០ បានចងប្រទេសថៃជាប់ ។ ប្រទេសថៃបានប្រកាសខ្លួនឯង «ខ្លួលស្គាល់ជាជាប់ខាត ខ្លួសមត្ថកិច្ចនៃតុលាការអន្តរជាតិ (មាត្រា ៣៦ ឃ្លាទី ៥) ប្រទេសថៃបានត្រមខ្លួលស្គាល់យ៉ាងនេះ ចំនួន ១៤ ឆ្នាំកន្លងទៅហើយ (ពីឆ្នាំ ១៩៤៦ ដែលគេលនោះតុលាការអចិន្ត្រៃយ៍ បានផ្លាស់ថាជាតុលាការអន្តរជាតិ រហូតមកដល់ខែ ខែសីហា ១៩៦០) ហើយតុំដែលមានតក៏ថា លែងខ្លួលស្គាល់សមត្ថកិច្ចតុលាការទាល់តែសោះ ។ ដូច្នេះ ការ

ព្រះមហាក្សត្រីយានីសីសុវត្ថិកុសុមៈនាគវង្សបរមរតនៈ ព្រះវររាជបុត្រីនៃព្រះបាទសម្តេចព្រះសីសុវត្ថិមុនីវង្ស ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ក្នុងព្រះរាជពិធីបុណ្យចម្រើនព្រះជន្មាយុ ៨៤ ព្រះវស្សា ថ្ងៃទី ៣ ខែមករា ឆ្នាំ ១៩៦៣

បកស្រាយជាបន្តជាប់រហូតមកយ៉ាងនេះ ត្រូវតែចងអាកប្បកិរិយាថៃជាប់
មិនឲ្យក្រឡាប់ផ្កាប់ផ្សេងៗយ៉ាងណាឡើយ ។ តឹកតាងដែលលោក
សាស្ត្រាចារ្យចុំងតួ ចានពាក្យអំពីសាលក្រមចុះថ្ងៃ ១៨ វិច្ឆិកា ១៩៦០
អំពីរឿងប្រទេសដីគាក់ហ្គា ទល់ទឹងឡើហុងឌុយក៏ស មកធ្វើជាសំអាង
ចានធ្វើឲ្យមេធាវីថៃធ្វើយតបមកវិញមិនរួចពាល់តែសោះ ។ លោកចុំងតួ
ចានសួរទៅចៅក្រមអន្តរជាតិថា : « លោកចាងហ្វាង លោកចៅក្រម
បើទឹតក្រមរបស់តុលាការមានយ៉ាងនេះហើយ តើយើងអាចពន្យល់ផ្លូវ
ច្បាប់ដោយសំអាងលើទឹតក្រមនេះចានឬមិនចាន ? » ។

លោកចុំងតួចានបន្តថា ប្រសិនណាជាប្រទេសថៃ ពុំព្រមទទួល
ស្គាល់តុលាការអន្តរជាតិ ប្រទេសនេះត្រូវតែបញ្ជាក់ទៅលោកអគ្គលេខា
ធិការនៃសហប្រជាជាតិថា ខ្លួនឈប់ទទួលស្គាល់សមត្ថកិច្ចនៃតុលាការ
នេះ ចាប់ពីថ្ងៃ ២៦ ខែសីហា ១៩៥៤ មក កាលបរិច្ឆេទដែលសាលក្រម
រឿងអ៊ីស្រាអែលទឹងប៊ុលហ្គារីចេញមក ។ តែប្រទេសថៃគ្មានចានធ្វើ
យ៉ាងនេះពាល់តែសោះ ។ ដូច្នេះ តាមផ្លូវច្បាប់ ប្រទេសថៃនៅទទួល
ស្គាល់សមត្ថកិច្ចតុលាការឡាអេ ហើយការលើកយកសាលក្រម ពីរឿង
អ៊ីស្រាអែលនេះមកធ្វើជាតឹកតាងមិនចានការទេ ។

អំពីសេចក្តីជំទាស់ទី ២

លោកសាស្ត្រាចារ្យចុំងតួចានថ្លែងថា ប្រទេសថៃទើបនឹងអះអាងថា

សេចក្តីប្រកាសរបស់ខ្លួនចុះថ្ងៃ ២០ ឧសភា ១៩៥០ សាបសូន្យគ្មានដាច់ខ្យែ
ខ(pas d'existence propre)(បើយើងពោលឲ្យចំថា គ្មានជីវិតខ្លួនឯងទេ)
ការអះអាងនេះ ត្រូវចំសេចក្តីដំណាស់ទី ២ ដែលខៅក្នុងនេះ លោកទំង
រៃកញែកបកស្រាយតំនិតច្បាប់ (nature juridique) ឬឬសតល់តាមផ្លូវ
ច្បាប់នៃសេចក្តីប្រកាសរបស់ថៃឆ្នាំ ១៩៦០ ។

ក្នុងតំនិតដែតូសត្រូវបេស់យើង សេចក្តីប្រកាសឆ្នាំ ១៩៥០ នោះ
មានគោលចំណងជាច់ណាត់ ធ្វើឲ្យសេចក្តីប្រកាសចុះថ្ងៃ ២០ កញ្ញា
១៩៦៩ មានកម្លាំងជាធរមានឡើងវិញ (Renouveler) ។ បើពោល
ម្យ៉ាងខៀតថា សេចក្តីប្រកាសក្រោយនេះ មានគោលចំណងធំ ត្រង់
បន្តការខ្វួលស្គាល់ខ្លួនតាមក្រមតុលាការអន្តរជាតិចំនួន ១០ ឆ្នាំបន្ទាប់មក ។
លោកសាស្ត្រាចារ្យចាំងតូបានពាក្យសេចក្តីថា គោលតំនិតរបស់ថៃខាង
លើ បានធ្វើឲ្យពាក្យអង់គ្លេសថា (Reneuv ឬ Renouveler) គឺធ្វើឲ្យ
មានឡើងវិញ មានអត្ថន័យផ្លូវច្បាប់មួយយ៉ាងជាក់លាក់ ដែលមិនអាច
នាំឲ្យមានការភាន់ច្រឡំបាន ហើយពាក្យនេះមានន័យប្លែកអំពីពាក្យ
សាមញ្ញធម្មតា ។ សាមញ្ញនៃពាក្យថា « ធ្វើឡើងវិញ » ឬ(Renouveler)
នេះ លោកឌានអាឈីសុន បានរៃកញែកនឹងដូចៗខាហារណ៍យ៉ាងច្រើន
ខាងដើមហើយ ។ តាមលោកសាស្ត្រាចារ្យចាំងតូ ពាក្យថាធ្វើឡើង
វិញ ឬ (Renouveler) តាមភាសាសាមញ្ញធម្មតា (langage commun)

អាចប្រើសម្រាប់បញ្ជាក់អំពីរបៀបតាំងច្បាប់ផ្សេង ។ ដែលលោកបានចំព្រួញជា ៣ យ៉ាងដូចតទៅ ៖

១ - អត្ថន័យទីមួយនៃពាក្យថា ធ្វើឡើងវិញ (renouveler un acte peut signifier prolonger l'existence de cet acte) ។ ការធ្វើឡើងវិញនូវច្បាប់មួយ អាចមានសេចក្តីថា បន្តច្បាប់នោះឲ្យនៅមានជាធរមានតទៅទៀត ។ ត្រង់នេះ ពាក្យថា (renouveler) មានន័យថា (prolonger) គឺបន្តទៅទៀត ។ លោកបានលើកយកឧទាហរណ៍ជាច្រើនអំពីសន្ធិសញ្ញាអន្តរជាតិ ដែលមានន័យថា ផុតពីឆ្នាំនេះទៅនោះទៅ បើគ្មានការតវ៉ាអ្វីទេ សន្ធិសញ្ញានោះ នឹងត្រូវនៅជាធរមានក្នុងកំឡុងមួយឆ្នាំតទៅទៀត ។ ល ។ ត្រង់នេះលោកចង់បញ្ជាក់ថា សេចក្តីប្រកាសរបស់ថៃ ចុះថ្ងៃ ២០ ឧសភា ១៩៤០ មិនត្រូវចំអត្ថន័យនេះទេ ព្រោះសេចក្តីប្រកាសនេះ មានន័យខុសគ្នា ពីសេចក្តីប្រកាសឆ្នាំ ១៩៤០ ។ សេចក្តីប្រកាសឆ្នាំ ១៩៤០ បានធ្វើនៅថ្ងៃ ២០ ឧសភា មុនសេចក្តីប្រកាសឆ្នាំ ១៩៤៩ ត្រូវផុតរលត់ចំនួន ៤ ថ្ងៃ (ព្រោះសេចក្តីប្រកាសឆ្នាំ ១៩៤៩ ត្រូវផុតរលត់នៅដល់ថ្ងៃ ៧ ឧសភា គឺគ្រប់ ១០ ឆ្នាំតត់) ដូច្នេះ សេចក្តីប្រកាសឆ្នាំ ១៩៤០ អាចបកស្រាយបានថា ជាសេចក្តីប្រកាស បន្ត (prolonger) សេចក្តីប្រកាសចាស់គឺឆ្នាំ ១៩៤៩ ។

ចំណែកសេចក្តីប្រកាសឆ្នាំ ១៩៤០ មិនមែនដូច្នោះទេ គេចាំបាន

ថា គឺនៅថ្ងៃ ៧ ឧសភា ដែលសេចក្តីប្រកាសឆ្នាំ ១៩៤០ មានជាធរមានចុងក្រោយ ។ បើកាប់យកចំនួន ១០ ឆ្នាំ សេចក្តីប្រកាសនេះ គឺត្រូវផុតរលត់ចំថ្ងៃ ៦ ឧសភា ១៩៥០ ដ៏ខ្លី មុនថ្ងៃនេះ ក្រឡាបញ្ជីតុលាការបានសរសេរមកច្រាប់ថា សេចក្តីប្រកាសរបស់ខ្លួនឆ្នាំ ១៩៤០ នឹងត្រូវផុតរលត់នៅដើមថ្ងៃ ១ ឧសភា ១៩៥០ ហើយ (គេបានចាំងច្រាប់ថានៅថ្ងៃ ២ ឧសភាផង)៖ ហេតុនេះ ដល់ថ្ងៃ ២០ ឧសភា ដែលថៃបានធ្វើសេចក្តីប្រកាសឆ្នាំ ១៩៥០ ប្រទេសថៃមិនមែនមិនដឹងការសោះឡើយ ដែលត្រូវផុតខាងលើនេះទេ (៦ ឧសភា) ។ នៅពេលដែលថៃបានធ្វើសេចក្តីប្រកាសនៅថ្ងៃ ២០ ឧសភា ១៩៥០ សេចក្តីប្រកាសមុនបានផុតរលត់ទៅហើយ ការណ៍នេះប្រទេសថៃបានដឹងច្បាស់ណាស់ហើយ ដូច្នេះ ថៃមិនមែនបន្តការប្រកាសមួយដែលអស់អាវុធការទៅហើយទេ ។ ការដែលប្រទេសថៃអាចធ្វើបានហើយដែលថៃបានធ្វើ គឺញ៉ាំងឲ្យសេចក្តីប្រកាសនោះ មានធរមានឡើងវិញ (Il n'est pas de question de prolonger un acte devenu caduc . . . . mais de le remettre en vigueur) ។

២- អត្ថន័យទី ២ នៃពាក្យថា « Renouveler » « Renouveler un acte peut signifier remettre en vigueur un acte qui a pris fin » ធ្វើច្បាប់មួយឡើងវិញ អាចមានន័យថា ធ្វើច្បាប់មួយដែលផុតរលត់ទៅហើយឲ្យជាធរមានឡើងវិញ ។

ត្រង់នេះ លោកសាស្ត្រាចារ្យចុំង៉តូ ក្រោយដែលបានដួងអត្ថ-
ន័យសេចក្តីស្រាយពាក្យថា «ធ្វើឡើងវិញ» ឬ «renouveler» តាម
វចនានុក្រមបាក់ឆ៊ងឆ៊ងអង់គ្លេសយ៉ាងខ្លីខ្លាយមក លោកបានធ្វើយ
ចង់សេធសេចក្តីតក៏ជាបម្រមបេស់ថៃដែលពោលថា «រក្សាខ្លួនតិចួមួយ
ដែលមានហើយ» maintenir un engagement existant: ថៃបានយក
គោលតំនិតនេះមកសំអាង ដោយចង់និយាយថា គេមិនអាចនឹងបន្តកិច្ចមួយ
ដែលអស់អាសេតការទៅហើយទេ ។ លោកសាស្ត្រាចារ្យចុំង៉តូ បាន
ធ្វើយដំបាស់ថា មិនមែនដូច្នោះទេ ការដែលប្រទេសថៃបានធ្វើសេចក្តី
ប្រកាសថ្ងៃ ២០ ឧសភា ១៨៥០ ប្រទេសនេះបានដឹងច្បាស់ថា សេចក្តី
ប្រកាសចាស់ផុតលេត់តាំងពីថ្ងៃ ៦ ឧសភា ១៨៥០ ។ ដូច្នេះ សេចក្តី
ប្រកាសក្រោយនេះ មិនមែនគ្រាន់តែជាកិច្ចមួយញ៉ាំងឲ្យសេចក្តីប្រកាស
ដើមជាធរមានឡើងវិញប៉ុណ្ណោះទេ សេចក្តីប្រកាស ១៨៥០ ជាកិច្ចមួយ
ថ្មី តាមអត្ថន័យទី ៣ នៃពាក្យថា ធ្វើឡើងវិញ ឬ (renouveler) ។

៣- អត្ថន័យទី ៣ នៃពាក្យថា «renouveler» ។

«renouveler un acte peut signifier établir un acte nouveau»
ធ្វើច្បាប់មួយឡើងវិញ អាចមានន័យថា ធ្វើច្បាប់មួយថ្មី ។

ត្រង់នេះ លោកសាស្ត្រាចារ្យ បានធ្វើអត្ថាធិប្បាយអំពីពាក្យ
«renouveler» តាមវចនានុក្រមលីត្រែ (Le Dictionnaire littré) ដោយ

ទាញ។ ពាក្យណែនាំយ៉ាងជាក់ស្តែង ដើម្បីបញ្ជាក់ថាពាក្យ (Renouveler) ឬ ធ្វើឡើងវិញ អាចមានន័យថា «ធ្វើជាថ្មី» ហើយលោកបានបញ្ជាក់ថា សេចក្តីប្រកាសឆ្នាំ ១៩៤០ ជាកិច្ចថ្មីមួយដែលប្រទេសថៃបានធ្វើ ។ ម្យ៉ាងទៀត សេចក្តីប្រកាសនេះ បានចុះកិច្ចសន្យានៃអគ្គលេខាធិការដ្ឋាននៃសហប្រជាជាតិតាមបទបញ្ជានៃអង្គការនេះ ។ ការចុះកិច្ចសន្យានេះ ហើយដែលមានលក្ខណៈរឹតតែត្រឹមត្រូវតាមលក្ខន្តិកៈនៃតុលាការយុត្តិធម៌តាមបទបញ្ជានៃសហប្រជាជាតិទៅទៀត ។ ការនេះបង្ហាញឲ្យឃើញជាក់ថា សេចក្តីប្រកាសរបស់ថៃឆ្នាំ ១៩៤០ ជាឯកសារមួយថ្មីយោងទៅតាមលក្ខន្តិកៈថ្មីនៃតុលាការអន្តរជាតិ (Cour internationale de Justice) ទើបគោរពទៅតាមទំនៀមទំលាប់ថ្មី (គឺការឡើងដំណឹងតាមផ្លូវប្តឹង ដែលមានចែងខៅក្នុងមាត្រា ៣៦ ឃ្លាទី ៤ នៃលក្ខន្តិកៈតុលាការអន្តរជាតិ ដែលជំនួសសាលាជំនុំអចិន្ត្រៃយ៍ (Cour permanente) ។

អំពីសេចក្តីជំទាស់ទី ៣

លោកសាស្ត្រាចារ្យជុំនិតូ បានបន្តការដកស្រង់ទៅទៀត ដើម្បីទាក់ទងលទ្ធកម្មរបស់ថៃ ទើបដើម្បីអះអាងថា តុលាការអន្តរជាតិមានសមត្ថកិច្ចទើបជំនុំជំរះរឿងព្រះវិហារនេះ ។

ក្នុងផ្នែកចម្លើយទី ៣ នេះ លោកបានពោលថា ៖

«ការសំរេចចិត្តយ៉ាងច្បាស់ក្រឡែត ជាហេតុមួយយ៉ាងជាប់ណាត់

ដើម្បីបញ្ជាក់អំពីសមត្ថកិច្ចនៃតុលាការ (Consentement clair et non équivoque) » ។

លោកជុំនតូ បានដោះសាខ្លួនយ៉ាងប៉ុនប្រសប់ជាខ្លាំងបំផុត ដោយលោកលើកយកតែខ្លឹមចិត្ត នឹងពាក្យរបស់ថៃមកធ្វើជាសំអាង ។ លោកបានពោលថា ប្រទេសថៃមានគំនិតចង់ឲ្យតែសេចក្តីប្រកាសរបស់ខ្លួនទៅជាបានការ ។ ដូច្នេះ ប្រទេសថៃបានធ្វើសេចក្តីប្រកាសឆ្នាំ ១៩៥០ ដោយសុទ្ធចិត្ត (de bonne foi) ដើម្បីទទួលស្គាល់នីតិក្រមនៃតុលាការអន្តរជាតិ ។ គោលការណ៍ «សុទ្ធចិត្ត» នេះហើយដែលជាមូលដ្ឋានធំនៃកិច្ចការពាក់ព័ន្ធផ្លូវអន្តរជាតិ ។ ហើយតាមគោលគំនិត «សុទ្ធចិត្ត» នេះហើយ ដែលរដ្ឋាភិបាលប្រទេសកម្ពុជាបានបញ្ជាក់អំពីការ ដែលប្រទេសថៃបានទទួលយល់ព្រមនីតិក្រមនៃតុលាការអន្តរជាតិ ព្រោះតាមការណ៍ពិត ការទទួលយល់ព្រមនេះបានចេញច្បាស់ឡើង តាមគំនិត ២ យ៉ាងដូចតទៅ :

១) សេចក្តីប្រកាសរបស់ថៃជាក់ច្បាស់នឹងគ្មានការកាន់ច្រឡំ (clair et non équivoque)

២) សេចក្តីប្រកាសនេះ គ្មានប្រទះនូវគុណវិបត្តិណាមួយ ដែលនឹងអាចរំលុបបាត់ចោលទៅបានទេ (n'est entaché d'aucun vice) ។

ក្រោយដែលលោកបានធ្វើអត្ថាធិប្បាយអំពីគោលគំនិតពីរយ៉ាងខាង

លើនេះយ៉ាងចូលចុលយ៉ាងវែងឆ្ងាយ ដោយមានសំអាងលើឧទាហរណ៍ដ៏ជាក់ស្តែង លោកសាស្ត្រាចារ្យ ប៊ុំងតូ បានតាញសេចក្តីបញ្ចប់ត្រង់ចម្ងើយដំទាស់(objections à la thèse thailandaise) យ៉ាងនេះថា:

« លោកចាងហ្វាង អស់លោកហៅក្រម នៅទីបញ្ចប់នៃសេចក្តីសង្ខេបនេះ ខ្ញុំសុំសន្និដ្ឋានថា សេចក្តីប្រកាសរបស់ថៃឆ្នាំ ១៩៤០ នោះ តាមទម្រង់កិច្ចក្តី ឬតាមដំណើរនៃគំនិតក្តី ឥតមានប្រឡាក់ប្រឡូសនូវគុណវិបត្តិឯណាមួយ ដែលនឹងទៅជាឧបសគ្គមិនឲ្យកិច្ចនោះមានហេតុផលខាងផ្លូវច្បាប់ ឬនឹងធ្វើទៅជាអសារឥតការ នៅកាលបរិច្ឆេទដែលប្រទេសកម្ពុជាបានដាក់ពាក្យបណ្តឹងចូលមកប្តឹងសាលាដំនុំដំរះនេះទេ ។ ក្នុងករណីទាំងអស់ ប្រទេសកម្ពុជាបានដឹងច្បាស់ថា បណ្តឹងរបស់ខ្លួនចូលមកតុលាការអន្តរជាតិនេះ មិនអាចនឹងចាត់ទុកថាជាអំពើមួយជាអមិត្តភាពចំពោះរដ្ឋជាបុងប៊ងចម្ងើយទេ » ។

ជាពិសេស លោកសាស្ត្រាចារ្យ ប៊ូហ្ស៊ុងប៊ុំងតូ បានធ្វើឲ្យហៅក្រមភ្ញាស់ ដោយលោកបានបដិសេធយ៉ាងជាច់ស្រឡះ នូវយោបល់របស់ថៃដែលតវ៉ាថា គុណការអន្តរជាតិនេះគ្មានសមត្ថកិច្ចក្នុងរឿងព្រះវិហារ ពីព្រោះសេចក្តីប្រកាសរបស់គេឆ្នាំ ១៩៤០ ដែលធ្វើយទៅជាក់សេចក្តីប្រកាសដើមគឺ ១៩៤៩ នោះ ត្រូវលាយសាបសូន្យជាមួយនឹងអង្គការគុណការចាស់ គឺសាលាដំនុំដំរះអន្តរជាតិជាអចិន្ត្រៃយ៍ ។ លោកសាស្ត្រាចារ្យ



លោកមេឆារីឆ្មាំងតូ ជាតិជាវាំងក្នុងរឿងក្តីប្រាសាទព្រះវិហារ ថតនៅពេលព្រះបូជនីយសពក្នុងនៃសម្តេចព្រះប្រមុខរដ្ឋ ឯភ្នំព្រះវិហារ នៅថ្ងៃ ទី ៥ ភុម្ភៈ ១៩៦៣ ។ ឯផ្ទាំងក្តារមានចារឹកអក្សរខាងលើ គំរៀមច្បើយកមកដាក់ដោយចិត្តឯង ។

ប៉ុន្តែគួបានបង្ហាញយ៉ាងច្បាស់ជាខ្លឹងផ្តាតថា សេចក្តីប្រកាសឆ្នាំ ១៩៤០ ជាកិច្ចមួយដ៏ចំពោះអង្គការតុលាការថ្មី (តុលាការអន្តរជាតិ) ហើយដែលបញ្ជាក់យ៉ាងច្បាស់ថា ប្រទេសថៃខ្លួលយល់ព្រមទទួលតាមនូវតុលាការថ្មីនេះជាដាច់ខាត ។

នៅមានការចង្អៀងជាមួយទៀត ដែលប្រទេសថៃរំជួលដែរតែក៏ចំពោះតុលាការអន្តរជាតិ ដើម្បីចៀសវាងនូវតម្រូវនៃអង្គការនេះ គឺការតែងថា ប្រទេសកម្ពុជាមិនអាចនឹងខ្លួលហេតុផលអំពីសន្ធិសញ្ញាឆ្នាំ ១៨៣៧ ដែលបានធ្វើឡើងរវាងប្រទេសចាក់នឹងប្រទេសស្យាម (សៀម) ទេ ។ បើយើងពោលម្យ៉ាងទៀតថា ប្រទេសថៃ គេពោលថាប្រទេសកម្ពុជានៅក្នុងសម័យអាណាព្យាបាល (Protectorat) តុំមែនជារដ្ឋមួយទេ នឹងតុំមានដីកៅតនៅក្នុងសង្គមអន្តរជាតិទេ ។

ចំពោះចំណុចនេះ លោកសាស្ត្រាចារ្យ ប៉ុន្តែគួ បានវែកញែកយ៉ាងច្បាស់លាស់ជាខ្លឹងផ្តាត អំពីការដែលប្រទេសចាក់នឹងបានចុះហត្ថលេខាលើសន្ធិសញ្ញាអន្តរជាតិ ដែលមិនមែនធ្វើឡើងតែក្នុងនាមរបស់ខ្លួនទេ គឺជាតំណាងនៃប្រទេសកម្ពុជាផង ។ នៅក្នុងរបបអាណាព្យាបាលប្រទេសកម្ពុជា នៅមានរូបភាពជារដ្ឋមួយយ៉ាងច្បាស់ ។ ដើម្បីទទួលបញ្ជាក់តំនិតនេះ លោកសាស្ត្រាចារ្យ ប៉ុន្តែគួ បានលើកយកសន្ធិសញ្ញាចុះថ្ងៃ ១៥ តុលា ១៨៦៧ រវាងចាក់នឹងសៀម ដែលស្តីអំពីជំហរនៃយោបាយ នឹង

ការគំរាមគ្រាំដែនប្រទេសកម្ពុជា មកបកស្រាយដើម្បីធ្វើជាតឹកតាង ។

តាមមាត្រា ៣ នៃសន្ធិសញ្ញា ឆ្នាំ ១៨៦៧ ព្រះចៅសៀមទ្រង់មិនត្រូវ ខ្លួលនឹងហាមដល់មហាក្សត្រវៀតនាមកទៀត មិនឲ្យខ្លួលអំពីប្រទេស កម្ពុជាខ្លួនសួយសារអាករ ឬវត្ថុអ្វីដទៃទៀត ដែលជាក់ខន្ធនឹងការបិតនៅ ក្រោមបង្គាប់អំពីប្រទេសកម្ពុជាទេ ។

ចំណែកអធិការជាក់ឯសែស ក៏បានសន្យាថា មិនរឹបអូសយកពជា-ណាចក្រនេះ ដើម្បីបញ្ចូលទៅនឹងដែនដីរបស់ខ្លួនទៅក្នុងនេះសុំនទេ ។

ដូច្នេះ ចំពោះមុខប្រទេសថៃ ប្រទេសកម្ពុជាពិតជាបិតនៅក្នុងរបបអា ណាព្យាបាល (régime de protectorat) ដែលខុសគ្នាយ៉ាងណាស់អំពីរបប រឹបអូសទៅជាដែនដី (régime d'annexion) ។

នៅមានមាត្រាចុងក្រោយបង្អស់នៃសន្ធិសញ្ញានេះទៀត ដែលមាន ប្រយោជន៍ដ៏ធំចំពោះយើង គឺមាត្រា ៧ ។ តាមមាត្រានេះ « រដ្ឋាភិបាល ចក្រឯងបានសន្យាថា នឹងសុំឲ្យប្រទេសកម្ពុជា គោរពខ្លួនបបញ្ជាតិនៃសន្ធិ សញ្ញាខាងលើនេះ » ។

ដូច្នេះ គេអាចពន្យល់សេចក្តីសន្ធិដ្ឋានអំពីសន្ធិសញ្ញានេះថា:

១) ប្រទេសថៃ បានខ្លួលស្គាល់របបអាណាព្យាបាលលើប្រទេស កម្ពុជា

២) ប្រទេសថៃប្រគាំងនឹងការរឹបអូសយកទៅធ្វើជាដែនដី

៣) ហើយប្រទេសថៃ បានខកខួលការសន្យាអះអាងថា ចាក់ដីមិនយកទៅធ្វើជាដែនដី ដោយរំលងអួសទេ ។

ដូច្នេះ យើងអាចតាញសេចក្តីបញ្ជាប់បានថា ប្រទេសចាក់ដីបានធ្វើសន្ធិសញ្ញានេះ មិនមែនកន្ងែងតាមរយៈខ្លួនប៉ុណ្ណោះទេ គឺកន្ងែងតាមនៃប្រទេសកម្ពុជាផង ។

ម្យ៉ាងទៀត មាត្រា ៦៦ នៃសន្ធិសញ្ញា ១៨៣៧ បានបញ្ជាក់ច្បាស់អំពីរដែលតាក់ងន្ធនធ៌អត្ថន័យ ព្រមទាំងការកំណត់ព្រំដែន ការគាងាអះអាងព្រំដែន និងការហាមមិនឲ្យជាក់ទ័ពនៅព្រំដែនខន្ទេមកុង ។

នៅកន្ងែងរឿងនេះ យើងត្រូវបិតនៅចំរឿងរ៉ាវអំពីព្រំដែនរវាងប្រទេសកម្ពុជានិងប្រទេសថៃ ។ ជូរច្នេះ គេត្រូវមានការជាប់ពាក់ងន្ធនធ៌សន្ធិសញ្ញាខាងលើ ដែលប្រទេសចាក់ដីបានធ្វើឡើងជាចាំបាច់ក្នុងប្រទេសកម្ពុជា ។

ក្រោយបានធ្វើយដោះសាតាំចាលសេចក្តីដាស់របស់ថៃ អំពីខឡឹកណ៌ខាងលើនេះលោកសាស្ត្រាចារ្យជុំនិងតូ បានតាញសេចក្តីបញ្ជាប់អំពីសេចក្តីប្រកាសរបស់ថៃឆ្នាំ ១៩៥០ ដែលបញ្ជាក់ច្បាស់ថា ប្រទេសថៃបានខកខួលស្គាល់ដោយសុទ្ធចិត្ត នូវនីតិក្រមរបស់តុលាការអន្តរជាតិ (Juridiction de la cour internationale de Justice) ។

(នៅមានត)

ទំនៀមទម្លាប់ នៃទេមរជាតិ
ខ្មែរគួរថ្មីឃ្នាត សិក្សាពេញទី ។
ព្រោះទេមរជាតិ ជាជាតិសោភ័
ក្នុងទ្វីបអាស៊ី តាំងពីព្រេងនាយ ។
ប. ព.

ល្បែងចោះប្រមាត់

កន្លែងប្រទេសកម្ពុជា អ្នកភូមិកំពង់ភ្នក ស្រុកសូទ្រនិគម ខេត្តសៀមរាប ជាភូមិនៅមាត់ទន្លេសាប គេតែងលេងល្បែងមួយដែល ហៅ« ល្បែងចោះប្រមាត់ » ថ្លែងពីស្រុក-ភូមិឯទៀត ។

ល្បែងនេះ គេលេងក្នុងរដូវវស្សា តាំងពីពេលជាក់ចំណួនៅខែលើនឹងថ្ងៃចេញវស្សា គឺពីថ្ងៃ ១ រោច ខែភទ្របទ ទៅលើនឹងថ្ងៃ ១៥ កើត ខែកត្តិក រៀងរាល់ឆ្នាំ ។

វិធីប្រៀបលេង: មានពួកពីរ ១ សម្រាប់ដេញ សុទ្ធតែប្រុស ១ សម្រាប់រត់ សុទ្ធតែស្រី ទំហំនឹងចំណុះពួកម្ខាងម្ខាងគ្នា ហើយចំណុះមានកម្រិតត្រឹម ៤ នាក់ ទៅ ១០ នាក់ យ៉ាងច្រើន ។ បើមានអ្នកលេងច្រើន គេផ្គូផ្គងជាគូ។ គឺពួកប្រុស ១ ស្រី ១ ជាមួយគូ ។

ល្បែងនេះគេលេង កន្លែងដែលមានតែកក់ ជម្រៅត្រឹមកជ្រលងក្បាល ។ ពេលផ្តើមលេង អ្នកលេងចាំងពីរពួក គេចុះពួកពេញ ។ ចំណុះតែរៀងខ្លួន ហើយពួកខាងប្រុសធ្វើជាអ្នកលេង ។ ទៅរកពួកខាង

ស្រីដែលជាគូនឹងខ្លួន លុះខាងប្រុសអុំលេង ។ ទៅជិតខ្លួនខាងស្រីប្រុស ។ ស្រែកសួរថា « ចោះប្រមាត់ » ស្រី ។ ។ ជួនកាលឆ្លើយថា « ចោះក៏ចោះ » ជួនកាលឆ្លើយថា « ទេ » ជួនកាលឥតឆ្លើយតប ។ ខាងប្រុសបានឮតាក្យថា ព្រមក្តី មិនព្រមក្តី ប្តូរស្មើមក្តី ក៏ស្រែកព្រមគ្នាថា « ដេញ ។ » ។ ឮតែថាដេញប៉ុណ្ណោះ ខាងស្រីក៏អុំខ្លួនរត់ ខាងប្រុសក៏ប្រឹងអុំតាម ។ ការដេញតាមនោះ ជួនកាលក៏ទាន់ ជួនកាលក៏ទេ ស្រេចលើកម្ចាស់រឿងខ្លួន បើខាងប្រុសដេញទាន់ ក៏លោតទៅគោងទាញខ្លួនខាងស្រីឡើងចូលបាត់ព្រោងព្រាត ។ ពេលនោះ ខាងស្រីតែលែងប្រកាន់ថាខ្លួនគេក្រមុំហើយ គេចេះតែប្រឡែងប្រឡូកគ្នាកន្ធឹតប្រុស។ ដេញញៀចស្រី ។ ត្រាតែអស់ចិត្តអស់ថ្នើម ហត់រឿងខ្លួន ទើបគេនាំគ្នាស្តាខ្លួនឡើង ហើយគេនាំគ្នាអុំលេងតទៅទៀតសារជាថ្មី ។ កាលដេញទាន់គេតទៀត គេញៀចគ្នាជាថ្មីទៀត ។ បើលេងពេលព្រឹកត្រាតែដល់ពេលថ្ងាយ បើលេងពេលយប់ត្រាតែតាក់កណ្តាលអធ្រាត្រ ទើបខាងប្រុស គេបើកឲ្យខាងស្រីទៅផ្ទះរឿងខ្លួន ។

ល្បែងនេះ ជាទំនៀមរបស់អ្នកស្រុក ដូចមានឈ្មោះខាងលើ គេលេងដោយស្មោះត្រង់ ឥតមានប្រកាន់ថាខុសត្រូវអ្វីឡើយ តែតែពីនាំគ្នារីករាយ សប្បាយជាកំសាន្តម្យ៉ាងប៉ុណ្ណោះ ។

ល្បែងនេះកប់ចូលក្នុងតំបន់ហាត់ប្រាណ ឲ្យពង្រឹងកាយឡើងសាច់ដុំមានសុខភាពបរិបូណ៌ ។

ពិធីប្រគល់សៀវភៅជាភាសាអាល្លឺម៉ង់ស្តីពីពុទ្ធសាសនា បំផ្លួង ៦៥ ក្បាលជូនពុទ្ធសាសនៈបណ្ឌិត្យ

គណៈប្រតិភូវប្បធម៌អាល្លឺម៉ង់ដែលមានលោក ហង់ហ៊ែរវែរ ហ៊ែរ ម៉ាន់-ក៏ត់ហ្សង់ រដ្ឋមន្ត្រីក្រសួងកិច្ចការវប្បធម៌ ទីឯយុត្តិធម៌នៃទីក្រុងសេរី ទីឯភាណិជ្ជកម្ម ឈ្មោះហម្ប្ឺរជាប្រធាន ព្រមទាំងសមាជិករបស់លោក ដូចមានឈ្មោះតទៅៈ

លោក គុនតេរ ហ្វ្រែត បណ្ឌិតខាងអក្សរសាស្ត្រ

– ហ្វ្រេដេរិក គ្នរ »

– ភីលវែរ ហែលីហ្ស៊ឺ »

– ហាលមាន ថាស្សែរ ទីប្រឹក្សាកិច្ចការបរទេស

– អែរណេះ ភីលស្ថិត បណ្ឌិតខាងអក្សរសាស្ត្រ

– ហ៊ែរវែរ ហាវតែល »

– ហ្គ្លីនោ អូស្សែរ បណ្ណារក្សវិទ្យាសាស្ត្រ

– ហែនរេ ចេស្សែរ បណ្ឌិតខាងអក្សរសាស្ត្រ

នាងកញ្ញា ហ្ស៊ីសេឡា ស៊ុយយេបួរ អ្នកប្រែភាសា

នៅវេលាម៉ោង ៩ ព្រឹកនៃថ្ងៃទី ២៨ មីនា ១៩៦៣ បានអញ្ជើញមកកាន់ក្រសួងធម្មការ ដើម្បីទាំយកសៀវភៅ ៦៥ ក្បាលមកជូនចំពោះក្រសួង



ឯកឧត្តម ហង់-ហ៊ែរ នៃរ ប្រធានគណៈប្រតិភូវប្បធម៌អាឡឺម៉ង់ ផ្ញើនសៀវភៅ
ចំពោះសហជីវិន ម៉ែន-ឈុំអនុរដ្ឋលេខាធិការក្រសួងធម្មការ ក្នុងឱកាសពិធីធ្វើអំណោយសៀវភៅ
ភាសាអាឡឺម៉ង់ស្តីពីពុទ្ធសាសនា នៅថ្ងៃទី . ២៨ មីនា ១៩៦៣

ធម្មការ ដែលនៅទីនោះ មានសហជីវិន ម៉ែន-ឈុំ អនុរដ្ឋលេខាធិការក្រសួងធម្មការ ព្រមទាំងបុគ្គលិកទាំងអស់នៅរង់ចាំទទួលជាកិត្តិយស ។

នៅពេលដែលលោកប្រធានគណៈប្រតិភូអាល្លឺម៉ង់ត្រមទាំងសមាជិកអញ្ជើញចូលក្នុងសាលអានសៀវភៅនៃមន្ទីរពុទ្ធសាសនបណ្ណិត្យហើយ លោកប្រធានបានថ្លែងសង្កថា រៀបពាប់ពីពុទ្ធសាសនានៅប្រទេសអាល្លឺម៉ង់ នឹងថាមានជនជាតិអាល្លឺម៉ង់ត្រហែល ៦០.០០០ នាក់ ជាពុទ្ធសាសនិកដែលជាទីចាប់អារម្មណ៍យ៉ាងក្រៃលែងៗបន្ទាប់មក សហជីវិនអនុរដ្ឋលេខាធិការក្រសួងធម្មការ បានថ្លែងសុន្ទរកថាតបវិញ ដោយលោកបានបញ្ជាក់អំពីការលូតលាស់ ខាងព្រះពុទ្ធសាសនា នៅប្រទេសកម្ពុជាយ៉ាងទូលំទូលាយ ហើយដែលយើងចុះផ្សាយជាបន្ទាប់នេះ ។

ជាទីអាសាន លោកប្រធានគណៈប្រតិភូវប្បធម៌អាល្លឺម៉ង់ បានជូនសៀវភៅទាំង ៦៥ ក្បាល ចំពោះសហជីវិនអនុរដ្ឋលេខាធិការជាទិដ្ឋភូរួមខាងសម្ព័ន្ធភាពខាងពុទ្ធសាសនានៃប្រទេសទាំងពីរ ។

យើងសូមបញ្ជាក់ថា សៀវភៅ ៦៥ ក្បាលនេះ ចេះតុម្ពជាភាសាអាល្លឺម៉ង់ ស្តីពីពុទ្ធសាសនានឹងជីវភាពជនជាតិអាល្លឺម៉ង់បច្ចុប្បន្ន ហើយ ៤ ក្បាល ស្តីពីមគ្គវៃផ្នែកសាសនាព្រាហ្មណ៍ ។

សុន្ទរកថា

ដែលសហជីវិន ម៉ែន - ឈុំ អនុវរដ្ឋលេខាធិការក្រសួងធម្មការ
ថ្វែងនៅឧកាសពិធីទូលសៀវភៅស្តីពីពុទ្ធសាសនា ពីតណប្រតិភូ
សហព័ន្ធអាល្លឺម៉ង់ខាងលិច នៅថ្ងៃទី ២៨ មីនា ១៩៦៣ ។

ឯកឧត្តម ប្រតិភូជាទីគោរពចាំង ឡាយ

មុនដំបូង ខ្ញុំបាទសូមអនុញ្ញាតថ្វែងនូវសេចក្តីកតញ្ញូតាធំធ្ងន់អំណរគុណ ដ៏ស្មោះស្ម័គ្រយបស់ខ្ញុំបាទ ចំពោះឥស្សរជនជាន់ខ្ពស់ចាំង ឡាយ ដែលអញ្ជើញមកកាន់ទីនេះ ហើយដែលមានសោមនស្សចេតនាចង់ជួយលើកតំ-កើងពិធីដែលនឹងប្រព្រឹត្តទៅក្នុងពេលឥឡូវនេះ ជាពិធីដែលតំណាងឲ្យ ឃើញនូវមិត្តភាពខាងវប្បធម៌ វិទ្យាសាស្ត្រ និងសាសនាដែលសាធារណៈ សហព័ន្ធអាល្លឺម៉ង់មានយ៉ាងជាក់ច្បាស់ដល់ព្រះពុទ្ធសាសនិកជនក្រុងកម្ពុជា ។

ឯកឧត្តម ប្រតិភូជាទីគោរពចាំង ឡាយ

ថ្ងៃនេះ នៅចំកណ្តាលមន្ទីរដ៏ធំនៃពុទ្ធសាសនបណ្ឌិត្យដែលជាកន្លែងដ៏កល់ព្រះត្រៃបិដក កងនាមនៃព្រះពុទ្ធជ្ញាតិជាល និងកងនាមផ្ទាល់របស់ខ្ញុំ ខ្ញុំបាទសូមគោរពអស់ពីដួងចិត្តចំពោះឯកឧត្តមនិងប្រតិភូជាទីគោរពចាំង ឡាយដែលហែហមឯកឧត្តមមកកាន់ប្រទេសរបស់យើងខ្ញុំ ជាប្រទេសកាន់ព្រះពុទ្ធសាសនាយ៉ាងមាំមួន រឿងនេះដែលតាំងនៅមានជាអចិន្ត្រៃយ៍ហួតដល់សព្វថ្ងៃ ក៏ដោយសារតែព្រះមហាករុណាគុណនៃព្រះមហាក្សត្រចាំង ឡាយ ជាទីគោរពរបស់យើងខ្ញុំដែលទ្រង់តែងតែយកព្រះពុទ្ធហឫទ័យ



សហជីវិន ម៉ែន-ឈុំ អនុរដ្ឋលេខាធិការក្រសួងធម្មការ ថ្លែងសុន្ទរកថា នៅឯកាសពិសេសគណៈប្រតិភូរ៉ាប្បធម៌អ ឡឺម៉ង្គយកសៀវភៅ
ភាសាអាឡឺម៉ង្គមកធ្វើអំណោយជូនពុទ្ធសាសនបណ្ឌិត្យ នៅថ្ងៃទី ២៨ មិនា ១៩៦៣

ខុកដាក់ចំពោះព្រះនភពដ៏ជាទីគោរពនៃព្រះពុទ្ធបរមគ្រូ ។

នៅក្នុងលោក ស្ថេរត្រង់ទីកន្លែង អ្នកមេគំនិត អ្នកប្រាជ្ញ នឹងអ្នកប្រាជ្ញ ខាងប្រវត្តិសាស្ត្រពាំងឡាយ សុទ្ធសឹងបានពិនិត្យសិក្សាព្រះពុទ្ធសាសនា ដែលពោលតែនូវទុគ្គមតតិខាងសន្តិភាព ខាងការរួបរួម នឹងខាងយុត្តិធម៌ សាកល ។ ក្នុងផ្នែកនៃការពិនិត្យនឹងការស្រាវជ្រាវពាំងនេះ អ្នកប្រាជ្ញ អាល្លឺម៉ង់ពាំងឡាយ ពិតជាមានស្នាដៃខាងវិទ្យាសាស្ត្របស់ខ្លួនស្ថិតលទ្ធ-ផលនៃកិច្ចការបានបំពេញហើយក្នុងវិស័យវិទ្យាសាស្ត្រពុទ្ធសាសនា នឹងទុគ្គមតតិដែលឯកទុគ្គមនឹងអស់លោកបានពេញចិត្តនឹងប្រគល់ជូនយើងខ្ញុំជាកស្តុតាងដ៏ពិតប្រាកដស្រាប់នេះ ។ ឯកទុគ្គមប្រតិកូជាទីគោរពាំង ឡាយ ! ខ្ញុំបាទមានកិត្តិយសដ៏ធំក្រៃលែងប្រកបដោយសេចក្តីសប្បាយឥតចប្រមា នឹងខ្លួនអំពីឯកទុគ្គមនឹងអស់លោកទូរសៀវភៅពាំងនេះ ។

ក្នុងនាមនៃព្រះពុទ្ធសាសនិកជន នឹងក្នុងនាមផ្ទាល់របស់ខ្ញុំបាទ ។ សូមថ្វាយចំពោះឯកទុគ្គមនឹងប្រតិកូជាទីគោរព នូវអំណរគុណយ៉ាងខ្លាំងក្លានឹងយ៉ាងស្មោះត្រង់ព្រមទាំងនូវកតញ្ញូតាដ៏ជ្រាលជ្រៅផង ។

ខ្ញុំសូមឯកទុគ្គមនឹងអស់លោក មេត្តានាំយកនូវអំណរគុណនឹងកតញ្ញូ-តានេះ ទៅថ្វាយជូនដល់ព្រះពុទ្ធសាសនិកជនអាល្លឺម៉ង់ជំនួសយើងខ្ញុំ ព្រមទាំងសូមមេត្តានាំយកនូវសេចក្តីគោរពរបស់យើងខ្ញុំ ទៅថ្វាយដំកបដល់អ្នកប្រាជ្ញនឹងអ្នកប្រាជ្ញខាងប្រវត្តិសាស្ត្រអាល្លឺម៉ង់ពាំងឡាយផង ដែលបានខំ

យកចិត្តទុកដាក់ពិនិត្យសិក្សាខ្ចីវិទ្យាសាស្ត្រពុទ្ធសាសនា ឧដ្ឋានដ៏ឧត្តមគតិ
សម្រាប់ជាប្រយោជន៍ដល់មនុស្សលោកនោះ ។

សូមឯកឧត្តមឧដ្ឋប្រតិភូជាទីគោរពជឿជាក់ថា ស្នាដៃរបស់អស់លោក
ចាប់ពីពេលនេះតទៅ ឧដ្ឋត្រូវយកទៅដាក់តាំងតែក្បែរស្នាដៃបរទេសពាំង
ឡាយដែលមានសភាពដូចគ្នា ក្នុងបណ្ណាល័យនៃពុទ្ធសាសនបណ្ឌិត្យប្រ-
ទេសកម្ពុជា សម្រាប់មហាជនខ្មែរឧដ្ឋបរទេសអាន អ្នកអានពាំងឡាយពិត
ជាឧដ្ឋជក្រស់ជង់ជងយកពីក្នុងសៀវភៅអស់លោក ខ្ចីវិត្តជាតុដ៏មានតម្លៃ
ដើម្បីធ្វើឲ្យងាយស្រួល ឬដើម្បីបង្ក្រប់ខ្ចីការស្រាវជ្រាវ ឬការពិនិត្យសិក្សា
នៃអាគ្នាជាមិនខាន ។

ជំនឿឧដ្ឋលទ្ធិពុទ្ធសាសនា បានផ្សាយទៅកាសពេញលោក ។
ដោយអាស្រ័យលទ្ធិពុទ្ធសាសនានេះ ទើបលេចមានសកលភាពជសន្តិភាព
សាកលមួយ ។ ដូច្នេះ ក្នុងនាមនៃពជរដ្ឋាភិបាលប្រទេសកម្ពុជា ក្នុ
នាមព្រះសង្ឃឧដ្ឋពុទ្ធសាសនិកវៃ ឧដ្ឋក្នុងនាមផ្ទាល់របស់ខ្ញុំ ។ សូមថ្លែង
ជាថ្មី ចំពោះឯកឧត្តមប្រតិភូជាទីគោរព ឧដ្ឋចំពោះរដ្ឋាភិបាលសហពន្ធអា-
ល្លឺម៉ង់ ខ្ចីវិអំណរគុណជាំស្មោះស្ម័គ្រឧដ្ឋកតញ្ញូតាដ៏ជ្រាលជ្រៅនៃយើងខ្ញុំ ។

ខ្ញុំសូមថ្លែងខ្ចីវិអំណរគុណម្តងទៀត ចំពោះឯកឧត្តមឧដ្ឋប្រតិភូជាទី
គោរព ហើយសូមជូនពរសព្វសាធុការមហាប្រសើរ សូមឲ្យឯកឧត្តមឧដ្ឋ
អស់លោកសំណាក់អាស្រ័យនៅក្នុងប្រទេសយើង ប្រកបដោយសេចក្តី
សប្បាយរីករាយ ។

ពុទ្ធសាសនបណ្ឌិត្យ


ទស្សនាវដ្តី ផ្សាយធំណាំងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ៣៥ លេខ ៥ ខែ ឧសភា

ព. ស. ២៥០៥ គ. ស. ១៩៦៣

- ភ្នំពេញ -



អក្ខរសិទ្ធិយោង

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ
បេញ្ញវន្តខ្មែរពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង

ផ្នែកសាសនា	*ទំព័រ*
– អំពីរឿងអសោក (វិចារណកថា) លោក ផេង-ដ្រើវ រៀបរៀង (តបច់) . .	៤៥០
– រឿងព្រះមហាសីលវីរាជ (ភាសាភាឡ) លោក ហេង-សមអាន រៀបរៀង (តបច់). .	៤៥៨
– ព្រះអភិធម្មបិដក (គម្ពីរព្រះមហាបដ្ឋាន) លោក ប៊ូ-ប៊ី ប្រែរៀបរៀង (ត). . .	៤៧៥
– មធុរសវាហិណី សម្តេចព្រះធម្មលិខិត ល្វី-ឯម ឧត្តមប្រាជ្ញ ប្រែរៀបរៀង (ត) . .	៤៨៣
– មហោសវជាតក (តមក)	៤៩១
ផ្នែកអក្សរសាស្ត្រ	
– កិត្តិយសនិងសុភមង្គល (វិចារណកថា) លោក ផេង-ដ្រើវ រៀបរៀង (តបច់) . .	៥០៧
– អក្សរសាស្ត្រខ្មែរ សិលាចារឹក ដយ-ឧន្ទ ស្រាវជ្រាវ ដោយ ន-គាម . . .	៥១៥
– វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះភេជព្រះគុណ ប៉ាង-ទាត់ រៀបរៀង (ត) . .	៥២៦
– រឿងសាមកុក លោកឧកញ៉ា នួ-កន ប្រែរៀបរៀង (ត)	៥២៨
– ល្បើកប្បាហ្វុងតែន លោកផេង-ដ្រើវ ប្រែពីភាសាចាវ៉ាំង (ត)	៥៣៥
– រឿងព្រេងចិន លោក វ៉ាយ-ប៊ុក ប្រែពីភាសាចាវ៉ាំង (ត)	៥៤១
-ការដំនុំដំរះដោយយុត្តិធម៌នៃតុលាការអន្តរជាតិពីរឿងក្តីព្រះវិហារបស់ខ្មែរនៅក្រុងឡាហេ(តបច់)	៥៤៥
– បៀប-ក្រុក-ព្រះពក្កុសន្ធោ លោក ផល-ទិត្យ រៀបរៀង	៥៤៩
ផ្នែកកំណត់ទំនឹងប្រវត្តិការណ៍	
– អំពីការតាំងមន្ត្រីសង្ឃ	៥៥៩

B.S. ៨៥ ១០-៦៧-



ព្រះវិហារវត្តពោធិវាស ស្ថាមាត់ស្ទឹងសង្កែ ត្រើយខាងកើតទល់មុខផ្សារយាត់ដំបងជាព្រះវិហារល្អ
ជាង ព្រះវិហារដទៃក្នុងខេត្ត

ពាក្យឃាត់មិនឲ្យ	ធ្វើការអាក្រក់
ជាការលាមក	ឲ្យធ្វើល្អភៅ
ឲ្យធ្វើសមាធិចិត្ត	កុំឲ្យហ្មងសៅ
បីនេះលោកហៅ	ពុទ្ធសាសនា

វិចារណាគាថា

អំពីរឿងអសោក

លោក ដេង - ជ្រឹង រៀបរៀង

(តទៅ)

បណ្ឌិតប្រកបដោយសេចក្តីព្យាយាម ត្រូវតែខន់លំពោនគោរពស្រមណ៍ពាំងឲ្យាយ ទឹងធ្វើខ្លួនកុសលកម្មជាប្រយោជន៍នៃអាត្ម នេះហើយដែលគេហៅថាបានខ្លួនត្រូវតែដែលមានសភាពខៀងខាត់ ។ ហេតុអ្វីក៏ខ្ញុំគោលរៀបរាប់ខ្លួនរឿងនេះ ? ព្រោះរូបកាយនេះប្រព្រឹត្តទៅយ៉ាងរហ័សដូចជាផ្នែកចន្ទោរ ដូចជាពពុះទឹក ដូចផ្កាឡាប់ ដូចជាដើមចេក រូបកាយមិនមានត្រាប់ដំមាំមួនទេ ។ ប៉ុន្តែ បើរូបកាយមិនស្ថិតប៉ាវនេះ ធ្វើកុសលកម្ម ត្រូវតាំងនៅអស់មួយរយកប្ប មានសភាពមាំមួនដូចជាភ្នំព្រះសុមេរុទឹងដូចជាមហាប្រឹថពី ។ ដូច្នេះ បណ្ឌិតត្រូវតែស្វែងរកឲ្យបានខ្លួនត្រូវតែមិនចែកឡាយ មិនវិនាស » ។

(១) ក្នុងគម្ពីរបាលីពុទ្ធសាសនាងចេរាគាថា: អាការៈ មានតែ ៣២

៣) អំពីទានចុងក្រោយបង្អស់នៃព្រះចៅអសោក តម្ពីរមហាវង្ស
ពោលថា «ផ្លែស្រម៉ដួយចំហៀង» សេចក្តីប្រែព្រះតេជព្រះគុណ តឹម-អាន
ថា« ផ្លែកន្ធត់ព្រៃមួយចំហៀង» សេចក្តីនៃលោក ហ៊ុយ-ថែរ ថា» ផ្លែ
ស្វាយមួយចំហៀង» ។

ចំពោះផ្លែស្រម៉ ទឹងផ្លែកន្ធត់ព្រៃ យើញថាមានការស្រដៀងគ្នា
អាចផ្លាស់ប្តូរគ្នាបាន ព្រោះស្រម៉ទឹងកន្ធត់ព្រៃ សុទ្ធសឹងជារុក្ខជាតិដុះនៅ
ក្នុងព្រៃដូចគ្នា ហើយសណ្ឋានផ្លែក៏ប្រហែលគ្នាខ្លាំង គ្រាន់តែរស់ជាតិ
ផ្សេងគ្នាបន្តិច គឺមួយចត់ល្វីង មួយផ្អែមល្វីង គឺថាពុំមានស្មៅជាផ្លែកន្ធត់ឆ្ងាយ។
ដូច្នេះ ខ្ញុំសន្និដ្ឋានថា គេអាចកន្ទុច្រឡំយកមួយជាមួយបាន ។ តែឯផ្លែ
ស្វាយវិញ មានការផ្សេងគ្នាយ៉ាងធំរវាងផ្លែស្រម៉ទឹងកន្ធត់ព្រៃ គឺគ្រន់
ត្រាយក៏ខុស ទំហំក៏ខុស ហើយរស់ជាតិក៏ខុសខ្លាំង ។ ហើយមួយយ៉ាង
ទៀត ផ្លែពីរខាងដើម ជារុក្ខជាតិដុះនៅតែក្នុងព្រៃ ស្វាយជារុក្ខជាតិស្រុក។
អំពីរឿងនេះ យើងគួរពិចារណាដែរ ថាហេតុអ្វីក៏ផ្សេងគ្នាខ្លាំងម្ល៉ះ? ។

ចំណែករឿងដែលថា តើខាងណាសមជាង : ខាងកន្ធត់ព្រៃទឹងស្រ
ម៉ឬខាងផ្លែស្វាយ? សូមអ្នកអានពិនិត្យជួយវិនិច្ឆ័យផង ។

សេចក្តីកត់មហាវង្សទឹងសេចក្តីប្រែរបស់ព្រះតេជព្រះគុណ តឹម-អាន ថា
ព្រះចៅអសោក ទ្រង់សព្វព្រះរាជហរទ័យចំណាយព្រះរាជទ្រព្យ ជូជាចំ
ពោះព្រះពុទ្ធសាសនាឱ្យបានមួយរយកោដិដង្ហឹងមាស ព្រោះទ្រង់ជាន

ស្រាប់ថា អនាថបណ្ឌិកសេដ្ឋីបានចំណាយទ្រព្យធ្វើទានក្នុងព្រះពុទ្ធ
សាសនា អស់មួយរយកោដិដំឡឹងមាស ចំណែកព្រះអគ្គ ដោយបូកបួម
តាំងអស់ទៅ ទើបនឹងបានតែ ៩៦ កោដិដំឡឹងមាស ។ ដើម្បីចំណាយ
ឲ្យគ្រប់ជា ១ រយកោដិ ទើបទ្រង់ព្រះបញ្ជាឲ្យនាយឃ្មាំងយកព្រះរាជទ្រព្យ
ចំណាយឲ្យបានគ្រប់ដូចព្រះរាជបំណង តែជាអកុសលក្នុងទុតាសនោះ
ព្រះបាទអសោកទ្រង់ប្រឈួនធង់ ។ ដោយទ្វាចអំណោះអត់ពីព្រះអគ្គទៅ
ព្រះរាជាអគ្គក្រោយឡើងទ្រង់រាជ្យ ត្រូវខ្វះខាតគោគទ្រព្យក្នុងការកសាង
វដ្ត ទើបមានខាម៉ឺនខ្វះដៃលមិនសូវជ្រះថ្លាក្នុងព្រះពុទ្ធសាសនា បានទៅ
ក្រាបទូលចំពោះព្រះអគ្គមហាសេសម្បទី ជាព្រះរាជមាយាទថា បើទ្រង់
បណ្តោយឲ្យព្រះអយ្យកោ ចេះតែចំណាយព្រះរាជទ្រព្យដូច្នេះ ព្រះអគ្គ
មហាសេដៃលត្រូវទ្រង់រាជ្យក្នុងពេលក្រោយ នឹងខ្វះខ្សត់ខ្លាយដោយគោគ
ទ្រព្យជាប្រាកដ ។ ព្រះអគ្គមហាសេសម្បទី ដោយទ្រង់ឃើលឃើញដូច្នេះ ទើប
បញ្ជាដល់នាយឃ្មាំងថា ត្រូវឈប់យកទ្រព្យក្នុងព្រះឃ្មាំងថ្វាយចំពោះព្រះ-
អយ្យកោទៀត ហើយក៏ឲ្យរាជចំរើយកតែផ្លែស្រមឹកក្នុងដៃត្រមួយចំហៀង
ទៅថ្វាយដល់ព្រះអយ្យកោ ។ ឯសេចក្តីបង្ហាញលោកហ៊ុយ-ថែរ មិនឃើញ
មានពាក្យរៀបរាប់ដូចខាងលើនេះទេ គ្រាន់តែជាក់សេចក្តីថាព្រះបាទអ
សោកទ្រង់ប្រឈួនខ្លាំង ពួកអាមាត្យមុខមន្ត្រី ដោយយល់ឃើញថាទ្រង់
ចំណាយព្រះរាជទ្រព្យអស់ច្រើនហើយ ក៏យកតែផ្លែស្វាយមួយចំហៀង

ទៅថ្វាយតែប៉ុណ្ណោះ ។

អំពីរឿងថ្វាយផ្លែឈើតែមួយចំហៀងនេះ តម្ល័រមហាវង្ស សេចក្តីប្រែគឺម-អាន ទំព័រសេចក្តីប្រែរបស់លោកហ៊ុយ-ថែរ មិនឃើញមានចង្អុលប្រាប់ហេតុសោះ ។ បើថ្វាយផ្លែតាំងមូលចំពោះព្រះចាខអសោកទៅ តើវាខ្លីឆ្ងាតប៉ុន្មាន ហេតុដូចម្តេចក៏ថ្វាយតែផ្លែមួយចំហៀង? ឃោបល់ផ្ទាល់របស់ខ្ញុំថាជាបញ្ហាមួយដែរ ដើម្បីបញ្ជាក់ថ្វាយចំពោះព្រះចាខអ-សោក គឺថាឲ្យព្រះអង្គជ្រាបអំពីអំណាចរបស់ទ្រង់ ។ ឥឡូវនេះអំណាចរបស់ព្រះអង្គប្រេះធាហើយ ពុំមែនទៅតង់វង់មាំតាំងដូចផ្លែឈើតាំងមូលនោះទេ ជាអំណាចដែលត្រូវគេចំបែកបាន់ហើយ គឺថាទឹកត្រូវវិនាសក្នុងពេលដ៏ខ្លីណាមួយជាពុំខាន ។

ខ្ញុំសូមលើកយកសេចក្តីរបស់លោកហ៊ុយថែរមកផ្សាយដូនដូចតទៅ :

ព្រះចាខអសោកជាធម្មិកជ ទ្រង់ប្រឈួនយ៉ាងធ្ងន់ ។ ព្រះកជទ្រព្យតាំងអស់របស់ព្រះអង្គ ទ្រង់បានថ្វាយជាទានដល់សង្គមពុទ្ធសាសនា ។ ទ្រង់បង្គំឲ្យមន្ត្រីយកទ្រព្យផ្សេងដទៃទៀតមកថ្វាយដល់ព្រះអង្គទៀត តែមន្ត្រីតាំងនោះឈប់ត្រូវការថ្វាយដល់ព្រះអង្គ ។ ទ្រង់បានទតឃើញផ្លែស្វាយមួយចំហៀង ។ ទ្រង់សព្វព្រះកជហរទ័យប្រគេនផ្លែស្វាយមួយចំហៀងនេះដល់ព្រះសង្ឃ ។ ទ្រង់ប្រជុំអស់នាម៉ឺនមុខមន្ត្រីរបស់ព្រះអង្គហើយមានព្រះបន្ទូលថា : ថ្ងៃនេះ តើអ្នកណាជាស្តេច ហើយត្រូវគេគោរពបញ្ជា

វេស់អ្នកណា?» ។ ទាំមុខទាំងអស់ក្រាបបង្គំទូលថា : «មានតែព្រះមហាក្សត្រនេះហើយដែលគ្រប់គ្រងព្រះរាជាណាចក្រនៃព្រះអង្គ ក្នុងជម្ពូទ្វីបទាំងមូល គេត្រូវគោរពព្រះបញ្ជារបស់ព្រះអង្គ» ។ ឧកាសនោះ ព្រះបាទអសោកទ្រង់សំដែងនូវគាថាដូចតទៅ : អស់លោកគោលថា ខ្ញុំជាព្រះមហាក្សត្រ ហើយថាគេត្រូវគោរពបញ្ជាការខ្ញុំ ។ អស់លោកគោលយ៉ាងនេះ គឺដើម្បីបញ្ឆោតខ្ញុំទេ ។ សំដីដែលអស់លោកនិយាយគឺជាពាក្យកុហក ។ អំណាចខ្ញុំស្ងាប់ហើយ ខ្ញុំអស់សមត្ថភាពនឹងចាត់ការអ្វីហើយ ។ មានតែផ្លែឈើមួយចំហៀងនេះទេ ដែលខ្ញុំត្រូវជាធំបណ្តាច់លើ ។ អំណាចជាវត្ថុជាទីស្អប់ខ្ពើម ។ ឧតួរឲ្យអនិច្ចា! អំណាចនេះត្រូវគេមើលងាយក្រៃពេក! អំណាចប្រៀបដូចជាខ្មេវដែលហូរភ្លាក់ចុះពីកំពូលភ្នំឥតបង្អង់ ។ ខ្លួនខ្ញុំជាព្រះចៅកជាធំជាងមនុស្សទាំងឡាយ ទុគ្គតភាពស្រាច់តែមកដល់ខ្ញុំភ្លាមដោយមិនដឹងខ្លួន ទុគ្គតភាពដែលមនុស្សទាំងអស់ត្រូវតែភ័យខ្លាច បានមកប៉ះលើរូបខ្ញុំមួយរំពេច ។

កាលបើគោលគាថានេះហើយ ទ្រង់សែ្តង្សើថា: « ព្រះតេជៈនៃព្រះលោកនាថពេញហៅត្រូវពិត មិនមែនទុសត្រង់ណាឡើយ! » ។ រួចទ្រង់សំដែងនូវគាថាតទៅទៀតថា :

សុភមង្គលដ៏ឃោរឃៅក្តីត្រចះត្រចង់អស្ចារ្យ ឧត្តមត្រូវលោយលុំភ្លាក់ចុះទៅខ្ពើមបំផុត ។ សុភមង្គលនឹងសេចក្តីក្រេកឡើយនៃមនុស្សលោក ឧត្តមត្រូវតែ

រលាយរំលាំចុះមិនខាន តើជាវត្ថុដែលមនុស្សពាំងអស់តែងតែយកខ្លាច ។
ព្រះពុទ្ធនៃព្រះគោតម ពិតជាប្រកបដោយសារៈ ។ ក្នុងថ្ងៃទាំងឡាយ
កន្លងផុតទៅ កាលណាខ្ញុំយល់ឃ្លាសក្នុងចិត្តថាត្រូវបញ្ឈប់អ្វីហើយ ខ្ញុំគ្រាន់
តែបន្ថែញនូវបញ្ហាការនោះ សំដីខ្ញុំ មិនមែនទៅតើលាភីរឥតប្រយោជន៍
ឡើយ ។ សូម្បីតែយក្សនីឆេត្តាក៏ត្រូវខួលនូវបញ្ហាការរបស់ខ្ញុំ ។
ត្រប់ពាំងអស់ ឮដខាងក្នុងសមុទ្រពាំងបួន អ្នកណាដែលបានឮបញ្ហាការ
របស់ខ្ញុំហើយ ត្រូវតែយកទៅអនុវត្ត គ្មានណាម្នាក់ហ៊ានរើងទើងឡើយ ។ ដូច្នេះ កាលណាខន្ធហូរទៅប៉ះនឹងភ្នំដ៏ធំ ទឹកបែកពពុះ
ហូរច្រាលមកត្រាយ ។ ខ្ញុំរលាយរំលាំចុះដូចថាភ្នំមួយដ៏ធំ តើរើងទើង
នឹងខ្ញុំ តេមិនយកបញ្ហាការខ្ញុំទៅអនុវត្ត ។ ពីដើមមិនមានអ្នកណាម្នាក់ហ៊ាន
ទប់នឹងបញ្ហាការរបស់ខ្ញុំ ។ មិនដែលមានការប្រឈូតប្រឈល់សោះឡើយ
ខ្ញុំបានបំបាក់បំបែបពួកទាំងអស់ ខ្ញុំបានមើតស្មូតច្បាស់របស់ខ្ញុំលាត
សន្ធឹងត្រូបលើមហាប្រឹថពីពាំងមូល គ្មាននរណាអាចរើងទើងនឹងខ្ញុំបាន
ប្រុសស្រីចាស់តូច គ្មាននរណាដែលមិនគោរពខ្ញុំ ។ ហើយប្រសិនបើលោក
មានអ្នកណាហ៊ានរើងទើងនឹងបញ្ហាការខ្ញុំ ខ្ញុំត្រូវតែបង្ក្រាបដោយអាវុធ ។
អ្នកណាដែលមានទុក្ខ ខ្ញុំត្រូវលួងលោមព្រមពាំងជួយជង ខ្ញុំសង្គ្រោះ
រហូតដល់អ្នកជម្ងឺនឹងអ្នកចិញ្ចឹលក្រ ឥតរើសមុខ ។ តែឥឡូវ សុភមង្គល
របស់ខ្ញុំដល់នូវទីបំផុតហើយ ទុគ្គតភាពមកដល់មួយរំពេច ហើយខ្ញុំជា

មនុស្សប្រកបដោយរាគចក្តីទុក្ខវេទនា ។ ប្រសិនបើខ្ញុំជាស្តេចអសោក ពិតប្រាកដមែន ហេតុអ្វីក៏ខ្ញុំធ្លាក់ក្នុងរាគចក្តីទុក្ខវេទនាយ៉ាងនេះ? ខ្លួនខ្ញុំប្រៀបដូចជាដើមអសោកដែលត្រូវគេកាត់ឬសចោល ហើយគេសាប់រំលុំទៀត : ផ្កា ស្លឹកនឹងមែកចាំងឆ្ងាយ ស្ងួតក្រៀមអស់ហើយ ។ រីឯអំណាចប្រៀបដូចជាការស្រមើយ (ឃល់សប្តិ) រីឯអំណាចនេះមិនស្ថិតវែងរេ ។

រួចព្រះបាទអសោក ទ្រង់ទតឆ្ពោះទៅលោកគ្រូពេទ្យដែលអង្គុយនៅខាងព្រះអង្គ ហើយទ្រង់ស្រែកថា : ត្រូវអៀនខ្មាសអំពីខ្លួនអំណាចដែលតាំងនៅតែមួយស្របក់ ដូចជាផ្សែកបន្ទោរដែលវិនាសភ្លាមនៅពេលដែលវាបញ្ចេញឲ្យឃើញពន្លឺ ដូចជាស្លឹកត្រែកដីរ ដែលបក់ជាន់ចុះ មិនដែលឈប់នៅទីឯ ដូចជាអណ្តាតភ្លើង ដែលលៀនភ្លឺបន្តែតែងតែឈប់ឈរ ដូចជាទឹកសន្សើមពេលព្រឹក ដែលស្ងួតបាត់ នៅពេលដែលប្រទះនឹងព្រះអាទិត្យ! ពីដើមខ្ញុំបានឮគេពោលវាចាដូច្នេះថា :

គេកាន់ត្រាប់តែងទ្រព្យសម្បត្តិបានដោយកម្រណាស់ ទ្រព្យសម្បត្តិរមែងរីងហួត ហើយមិនស្ថិតនៅអស់កាលដ៏យូរអង្វែងឡើយ ។ ដូច្នេះហើយ ដែលបណ្ឌិតគួរគប្បីយល់ឲ្យជាក់ច្បាស់ ខ្លួនមិនត្រូវវង្វេងប្រកបក្រអឺតក្រអោតឡើយ ។ កុំធ្វើជីវិតបច្ចុប្បន្នរហូតដល់ជីវិតអនាគត ត្រូវតែស្វែងរកនូវអត្ថប្រយោជន៍ ប្រកបដោយ

សារៈ ។ កាលបើគេមានសម្បត្តិច្រើន គេត្រូវខំរក្សាទុកសេចក្តីប្រ-
ណែន ព្រោះការមែងវិនាសទៅវិញ ដោយហេតុមួយយ៉ាងប្រការ ។ អ្នក
មានទ្រព្យ កាលនៅរស់ ប្រៀបដូចជាសត្វតស៊ីដែលមានដំណើរបន់បែន
ក្រវិកក្រវក់ ។ ជនណាដែលមានការពិចារណាក្នុងពេលដែលគេនៅ
តេញកំឡាំងយ៉ាងស្វាហាប់ ត្រូវតែប្រញាប់ប្រញាល់ស្វែងរកធម៌ឲ្យមាន
ក្នុងអាត្មា ។ កាលណាគេមានជម្ងឺ គេមានព្រះធម៌ក្នុងខ្លួនស្រេច ព្រោះ
គេមិនខឿនថាខឹងនៅរស់តទៅឡើយ ។ ចំណែកគ្រួសារនឹងបងប្អូន
ជាំងឡាយ កាលបើយល់ច្បាស់ថា អ្នកឯងមុខជាស្លាប់ហើយ អ្នកឯង
មានសម្បត្តិយ៉ាងណាក៏ដោយ អ្នកឯងមិនអាចយកសម្បត្តិនោះមកធ្វើទាន
តាមចិត្តខ្លួនបានឡើយ ។ ទ្រព្យសម្បត្តិជាំងឡាយដែលគេរកបាននៅ
ពេលនៃសេចក្តីវិនរឿង កាលណាបើគេបានដួចនឹងបុញ្ញក្ខេត្រហើយ គួរ
គប្បីតែចំណាយធ្វើជាទានយ៉ាងរហ័ស « កាលណាអ្នកនៅមានកំ-
ឡាំង មុនពេលដែលជម្ងឺមិនទាន់មកញាំញី ត្រូវអ្នកធ្វើកុសលកម្មជា
និច្ច ព្រោះទ្រព្យសម្បត្តិតែងតែនាំមកជាមួយនូវសេចក្តីទុក្ខ ។ កាលណា
អ្នកឯងជិតស្លាប់ អាពុកម្តាយ ប្រពន្ធទំនួន រមែងតែជំទាស់ចំពោះហេតុ
ដែលអ្នកត្រូវការបង់យកទ្រព្យធ្វើទាន ពោះបីទ្រព្យនោះជារបស់អ្នកក៏អ្នក
មិនអាចយកទៅចំណាយជាទានបានដូចបំណងឡើយ ។ នៅពេលដែល
អ្នកឆ្ងាក់ក្នុងសភាពជាខ្មួលហើយ អ្នកមិនអាចធ្វើអ្វីតាមអំពើចិត្តបានទេ» ។

រឿងព្រះមហាសីលវរាជ

(ពាក្យកាព្យ)

លោកមោង - សំអាន រៀបរៀង

ចាកមហាសីលវរាជាគត ឯកនិបាទ អហិង្សាសត្ត

ខ្ញុំលព្រះបង្គំសូមឆានា ។ ព្រះចមរយោធាស្តេចទ្រង់គ្រាស់

« អ្នកនាំអាមាត្យទៅខុកផ្ទះ កុំឲ្យសល់ខ្លះពោះតូច - ធំ ។

ហើយអ្នកនាំយើងទៅឲ្យដល់ ព្រះចៅកោសលក្នុងបន្ទំ ។

ឃុនាំអាមាត្យទាំងតូច - ធំ ដល់ផ្ទះជួបជុំក្រុមគ្រួសារ ។

ហើយឃុមកឃាត់ព្រះសីលវៈ ចូលក្នុងដំណាក់ទីសយនា

ព្រះចៅកោសលជាបច្ចា - មិត្រនៃក្សត្រាក្នុងយប់ខោះ ។

ស្តេចហូតព្រះខ័ននាន់យ៉ាងខ្លាំង ក្លងចុងចំត្រង់កហើយគោះ

ព្រះចៅកោសលមុខដូចខោះ កិតកល្យធីតពោះញ័រញាក់ច្រាណ ។

ក្រោកឡើងក្រាបថ្វាយបង្គំថា « បពិត្រក្សត្រាព្រះទ័យក្សត្តិ

ព្រះអង្គយាងចូលដល់សយង្ហាន តើយាងមកបានដោយសារអ្វី ? » ។

ព្រះមហាសីលវៈច្រាប់សព្វគ្រប់ ពីដើមដល់ចប់ផុតសេចក្តី

ព្រះចៅកោសលក្បាក់ស្មារតី ត្រេកអរមេត្រីស្មោះចំពោះ ។

ខ្ញុំលថា « បពិត្រក្សត្រឧត្តម ខ្ញុំលព្រះបង្គំមនុស្សមានទោស

សូមសម្តេចម្ចាស់ទ្រង់សន្ទោស អត់ទោសដល់ខ្ញុំលបង្គំផង ។

ខ្ញុំសូមព្រះបង្គំអនុញាតលាទៅ ចិត្តខ្ញុំអាក្រក់ល្អក់សៅហ្មង
មិនដឹងព្រះគុណព្រះអង្គផង គុណធ្ងន់កន្ទុងឥតឧបមា ។
សូមប្រទានយកកុកកុឡជាតិ ស៊ីខ្លាចសត្វធាតុជាអាហារ
តាំងជីវិត-ស្គាល់គុណព្រះករុណា ទ្រទ្រង់សីលាស្អាតផូរផង់ ។
ចាប់ពីថ្ងៃនេះខ្ញុំសូមបង្គំ លែងចងគំនុំនឹងព្រះអង្គ
សូមតាមបំរើដោយស្មោះត្រង់ ចំពោះព្រះអង្គមួយដងវែក ។
ខ្ញុំសូមលាហើយក៏ថ្វាយបង្គំ ទៅព្រះអង្គផ្ទុយ៉ាងស្មោលស្មុគ្ន
ព្រះចៅកោសលស្តេចអន់ចិត្ត ធ្វើតាបជាងពិតប្រាកដឮស្តាប់ ។
ព្រឹកឡើងព្រះចៅដែនកោសល ប្រដុំរេហ៍ពលហើយទ្រង់ត្រាស់
ថា «អ្នកតាំងឡាយស្តាប់ឲ្យច្បាស់ ព្រះចៅជាម្ចាស់ដែនកាសី ។
ព្រះនាមមហាសីលវៈ ស្តេចទ្រង់សច្ចៈនឹងទ្រឹទ្ធី
ទ្រង់រក្សាសីលជាប្រក្រតី សីលប្រាំ ប្រាំបីស្អាតផូរផង់ ។
ហេតុនេះអស់លោកអ្នកតាំងឡាយ ចូរថ្វាយជីវិតនឹងព្រះអង្គ
ថ្វាយខ្លួនបំរើដោយស្មោះត្រង់ ធ្វើតួធង់គោរពព្រះចក្រី» ។
ប្រកាសរួចស្រេចស្តេចកោសល តម្កល់អញ្ជលីទទួលសិរសី
សូមទទួលទោសព្រះចក្រី នៅមុខមន្ត្រីពលសេនា ។
ទទួលទោសស្រេចស្តេចកោសល បំរើតង់តាល់ព្រះចេស្តា
ជាមួយមន្ត្រីពលសេនា ហើយក្រាបទូលថា «ព្រះមហាក្សត្រ ។

ចាប់តាំងពីថ្ងៃនេះតទៅ បើមានសត្រូវចិត្តគាំងកាច
ចូលមកបៀតបៀនតាំងអំណាច ខ្ញុំលះបង់អាចហ៊ានឆាន ។
ខ្ញុំលួសអាសាចេញតតាំង កំចាត់ពួកភ្នាំងត្រប់វេលា
មិនឲ្យចូលដល់ត្រាំកាក មិនឲ្យកើតជាទ្រង់កង្វល់ ។
ព្រះមហាស័លវៈទ្រង់ត្រាស់ថា « អរគុណហើយណាស្តេចកោសល
តើទ្រង់ភ្ជាប់ឬប្តូរភ្ជាប់ស្គាល់ លោកនាយពលចម ប្រ. វិចិត្រ ។
ជាមេទ័ពធំដែនកាស៊ី ក្លាខ្លាំងល្បាញល្បីកបដោយឫទ្ធិ
ពោះយក្ខពោះគ្រុឌក្លាចវិចិត្រ មិនហ៊ានតប្ដូតចេស្តា ។
បើខ្ញុំជាមនុស្សល្មើកចង់ជាន ដែនតំាងប៉ុន្មានកន្លះលោកា
ប្រើតែមេទ័ពចេញតតាំ ស្តេចកន្លះលោកថ្វាយអាករ ។
ស្តេចគ្រប់ដែនដែលមានឫទ្ធិក្រៃ ខ្លាចខ្លាចថ្វីដៃមិនហ៊ានត
ខ្ញុំមិនត្រូវការសួយអាករ ជាមេបង្អឹមសន្តិសុខ ។
បពិត្រព្រះហៅដែនកោសល សូមទ្រង់កុំឆ្ងល់ឲ្យតែក្ត
បើធ្វើឲ្យគេរង់គោសក្ខុក្ខ យើងមិនបានសុខយូរប៉ុន្មាន ។
ព្រោះរដ្ឋតាំងអស់ពោះតូច-ធំ តែងតែទិតទំប្រឹងប្រែងច្រណា
សួយប្រទេសគេទាំងតែបាន រុងរឿងថ្កើងថ្កានគ្រប់ៗគ្នា ។
ជាតិណាក្លាក់ចុះអំណាចគេ ជាតិពោះទំគ្នេរមិនរេក
រកៗបាយកលគ្រប់វេលា ដកខ្លួនពីទាស់គេពោះបាន ។

បើហេតុដូច្នោះព្រះចមរចៅ ទ្រង់ចង់តែនៅជាសុខសាន្ត
សូមទ្រង់កុំធ្វើឲ្យរំខាន អន្តរាយសុខសាន្តណាកូម៉ៅ ។
ដូចមានភាសិតសម្តែងថា សុខា សង្ឃស្ស សាមគ្គី(១)
ជាសុភាសិតព្រះមុនី មានក្នុងតម្រាព្រះសាសនា ។
បានសេចក្តីថា ការមូលមិត្រ ស្រុះស្រួលគំនិតជាគ្រួសារ
រវាងជាតិមនុស្សក្នុងលោកា មិនឲ្យប្រែធាជាន់កាយ ។
នឹងជាបច្ច័យឲ្យកើតបាន សន្តិភាពសាន្តត្រាណាបានសប្បាយ
ផុតពីញុះញង់ប្រជូសវ៉ាយ កំចាត់កំចាយមនុស្សនឹងមនុស្ស ។
សូមព្រះមហាក្សត្រជាស្តេចទ្រង់ជ្រាប សន្តិភាពចំណងជនស្រីប្រុស
ជាកំពូលស្នេហ៍នៃជាតិមនុស្ស ក្នុងលោកចិត្តស្រុះស្រួលស្នេហា » ។
ព្រះអង្គខ្ញុំខ្ញាន់ជាសាកល ព្រះចៅកោសលនឹងសេនា
ខ្ញុំលប្រតិបត្តិតាមទន្ទឹរ ប្តេជ្ញាលុះត្រាអវសាន ។
សម្តេចព្រះមហាសីលវៈ យាងចូលតំណាក់សយនដ្ឋាន
ព្រះអង្គផ្ទំនៅជាសុខសាន្ត ទាំងក្រសួងបានដេកសប្បាយ ។
រីឯព្រះចៅដែនកោសល ព្រះអង្គនឹកដល់ត្រាអន្តរាយ
ថា « អញលំបាកយ៉ាងព្រះកាយ ទាំងក្រសួងជិតខ្វាយរងទុក្ខា ។
នេះព្រោះបក្សីអប្រិយក្រៃ ពាលក្សត់ចង្រៃញុះញង់ណា
បង្កើតសង្គ្រាមក្នុងរដ្ឋា មនុស្សរងទុក្ខាជាប្រក្រតី ។

១- ជាតធម្មបទដ្ឋកថា ខុទ្ទកនិកាយ

វិនាសមាសប្រាក់សព្វធនធាន វិនាសថ្នល់ស្ពានគោក្របី
ខន្ធីលខោស់កស់ក្តារដើ តាំងសេះដំរីធីងមាន់ទា ។ល។
អីហ្ន៎! អំពើញុះញង់ខេះ អាចញុំាងប្រទេសឲ្យវេទនា
ស្ងាប់ពស្តេចដកាពលយោធា សូន្យទាំងទ្រព្យតេជ្រមាសប្រាក់។
ហេតុនោះបានជាព្រះពុទ្ធម្ចាស់ ព្រះអង្គទ្រង់ត្រាស់ទេសន៍បញ្ជាក់
អំពីបិសុណាវាចៈ ក្លាខ្លាំងអនត្ថផលមា» ។
ទ្រង់ទីតយើញហើយព្រះបមះចៅ បើកបន្ទូលទៅកាន់សេនា
ថា «វើយប្រញាប់ធាប់ៗក៏ លើកពលសេនាមានថ្នូរដៃ ។
ចូលទៅចាប់ចងគាឡ-បក្សី អន្ទាលអប្រិយចោរចង្រៃ
យកមកឲ្យធាប់ទាន់នៅថ្ងៃ កាត់កប្រល័យថ្ងៃនេះឯង ។

- ៦ -

លោកគាឡ - បក្សី មេក្សត់ជាតិព្រមទាំងសហការីទាំងអស់ត្រូវព្រះចៅដែនកោសលប្រហារជីវិតបង់ ដោយលោកជាមេញុះញង់បង្កើះកើនសង្គ្រាម ។

រីឯបក្សីគាលក្សត់ជាតិ កំពុងនឹកឃ្លាតប្រឹតប្រឹងប្រែង
ប្រមូលញាតិមិត្រឲ្យដើរស្វែង គ្រប់ទីកន្លែងគ្មានចន្លោះ ។
ចាប់ផ្តើមពីរសៃដែលឆ្ងាប់ល្បី បំរើដែនដីដោយស្មគ្រស្មោះ
ដែលលោកគ្មានទោសបន្តិចសោះ គ្មានសល់ចន្លោះលោកណាឡើយ ។

ចាប់យកមកចងចំងាំច្បាស់ ប្រហារដាវតែច្បាកដរហ័យ
ពួកក្បត់ចាំងអស់ពុំកន្តើយ ខំប្រឹងបន្តើយនូវគ្រោងការណ៍ ។
គឺដើរលួចប្លន់យកធនធាន គ្រប់ផ្ទះអ្នកមានក្នុងស័ក្តិ
ថែមចាំងប្រព្រឹត្តអនាចារ ចាប់យកធីតាមហាសេដ្ឋី ។
ធីតាមន្ត្រីពស្ត្រប្រជា មានរូបសោភាស្រស់ប្រិមប្រិយ
ចាប់ចាំងអំណាចកាចតិរិយ រួមរសមេត្រីឥតគោតក្រែង ។
ពួកក្បត់កំពុងតែប្រព្រឹត្ត អំពើខុចរិតចាំងនេះឯង
ដោយមានបក្សីជាតួស្នែង ជាអ្នកចាត់ចែងនឹងប្រហារ ។
ស្រាប់តែពេជ្ឈឃាតដែនកោសល ដើរចូលមកដល់ដំរកបថា
« ខ្ញុំបានទទួលព្រះអាជ្ញា តាមហាក្សត្រាដែនកោសល ។
ឲ្យចាប់ពួកសោកដើងឆើត ។ ជាមេបន្តើតចលាចល
មនុស្សជាតិចាំងអស់ជាសាកល ជ្រួលជ្រើមរលាស់ខ្លាំងសៅ » ។
ថាតែប៉ុណ្ណោះចាប់ចងក្តាម មិនឲ្យពាក់តាម នាំសំដៅ
ចូលកជធានីថ្វាយព្រះចៅ កោសលតន់ខ្ពស់លើទៃនទី ។
មានសេនាមាត្យបុរោហិត តវិបណ្ឌិតរដ្ឋមន្ត្រី
តន់ខ្ពស់ត្រៀបគ្រាពេលកត្រី កន្លងដែនកាសីដ៏ខ្ពុំការណ៍ ។
ព្រះចៅទ្រង់ទតក្រុមពេជ្ឈឃាត នាំក្រុមក្បត់ជាតិចូលតាមការណ៍
ព្រះអង្គទ្រង់បើកព្រះឧស្ការ ត្រាស់ថា « ចូរមកកុំកិតភ័យ ។

នែលោកបក្សីវែកស្តែប្រជា ឥឡូវកូនវេទនាតែចួលក្រៃ
ត្រាតែកូនប្រពន្ធទៅខាងណែ កំតែកំយល់ស្រែកគាំងប្រុសស្រី ។
នេះគ្រោះតែរូបលោកឯងមួយ ឲ្យកើតទុក្ខព្រួយប្រទេសពីរ
ប្រទេសដែនខាងជ្រលងភ្នំ ទំការពារទ័ពគ្រប់គ្នា ។
ដូច្នេះពួកក្បត់គ្រប់គាំងអស់ អ្នកកុំនៅរស់ធ្ងន់ពស់ជា
ស្លាប់ចុះណាអ្នកកល់ ។ គ្នា ឲ្យប្រជាស្តែប្រជាបានសុខសាន្ត ។
ខឹងកុំឲ្យមនុស្សជាសាកល កើតចលាចលនាំវែងន
ព្រោះមនុស្សឥឡូវស្មែហ៍សាន្តត្រាណ ចង់បានគ្រប់គ្នាគាំងប្រុសស្រី ។ ។
បន្ទូលរួចស្រេចស្តេចគោសល សួរនោយចមពលដែនកាសី
ថា « លោកមេទ័ពឫទ្ធីល្បី តាត់ពេសបក្សីបែបយ៉ាងណា ? » ។
លោកប៊ូ.ចៃត្រូលប្រញាប់ « សូមទ្រង់សណ្តាប់ព្យាប់មាត្រា
បានចែងរួចហើយព្រះករុណា ព្យាប់ត្រូវប្រហារដាវែនបង់ » ។
បក្សីដើងថាខ្លួនឱដ៏ស្ងាប់ ក្នុងពេលឆាប់ ។ មិនបង្អង់
កំពូលពិត ។ តាមត្រង់ ។ ថា « សូមព្រះអង្គប្រោសប្រណី ។
ទូលព្រះបង្គំខ្ញុំសពិត ។ ពេសអស់ដាវែនក្បត់ដែនជ
មុនឱដ៏សម្លាប់សូមប្រណី តាណិតបក្សីមន្ត្រីថាស់ ។
សូមចួលទៅតាល់ព្រះករុណា ព្រះមហាសីលវៈជាអម្ចាស់
បង្គំលាស្លាប់ក្រុកដូច្បាស់ ខ្ញុំមន្ត្រីថាស់ដែនកាសី ។

ព្រះចៅគ្រាស់ថា «មិនបានទេ ព្រោះឯងជាមេក្បត់ចក្រី
បង្កើតសង្គ្រាមឈាមតាសដី ស្លាប់ពស្ត្រីប្រុសស្រីតាំងពផការ។
ព្រះចៅកោសលស្តេចទ្រង់គ្រាស់ បង្គាប់ច្បាស ។ ឲ្យប្រហារ
រើយ ។ ពេជ្ឈឃាតចាប់ចងក៏ យកទៅប្រហារកាត់សរសៃ ។
ពេជ្ឈឃាតព្រហើយសុះប្រញាប់ ចះចូលទៅចាប់ចងឋក្ស៊ី
ព្រមតាំងពួកបក្សសហការី អូសគ្មានប្រណីទៅប្រហារ ។

-៧-

ព្រះចៅដែនកោសល ឡើងគាល់ព្រះមហាសីលវៈដើម្បីថ្វាយបង្គំលាទៅប្រទេសវិញ ព្រះមហាសីលវៈបានថ្វាយដំបូន្មានដល់ព្រះចៅដែនកោសល អំពីគោលនៃបញ្ចសីលកំពន់ឆ អានិសង្សនៃបញ្ចសីលា ។

ព្រឹកឡើងព្រះចៅដែនកោសល ព្រមតាំងរេហ៍តលកងយោធា
ឡើងគាល់សម្តេចជម្ពូបតី ថ្វាយបង្គំលាទៅបុរី ។
ដល់ហើយព្រះចៅអគ្គមហេសី សម្តេចនរនាថដែនកាសី
ទូលថា «បពិត្រព្រះនរបតី សូមទ្រង់ប្រណីប្រថុសមេត្តា ។
ខ្ញុំលព្រះបង្គំលាព្រះអង្គ ព្រមតាំងចតុរង្គតលសេនា
ត្រឡប់ចូលទៅកដសីមា គ្រប់គ្រងរក្សាពស្ត្រប្រជា ។
ឯរដ្ឋកោសលនឹងកាសី ចងស្ពានមេត្រីដិតស្និទ្ធគ្នា
ពង្រឹងមិត្តភាពគ្រប់វេលា ឲ្យរឹងរឹតគ្នាជាអង្វែង ។

ព្រះមហាសីលវ៉ៃទ្រង់គ្រាស់ថា សូមមហាក្សត្រកុំគិតក្រែង
លើកខ័ន្ធទៅចុះហើយចាត់ចែងធ ស្នងស្នងប្រឹងប្រែងរកសន្តិភាព ។
ឲ្យប្រជាជនជាសាកល បានយល់បានស្គាល់សេចក្តីសុខ
លុះផុតលត់ម្លៃនៃសន្តិភាព មនុស្សគោះខ្ពស់ភាពស្រេកចង់បាន ។
ពាំនាំកុំប្រព្រឹត្តបញ្ហាវេរ ជាកម្មវេទាស្មុគ្នាជាប់ប្រាណ
សូមទ្រង់សណ្តាប់ស័ព្ទឲ្យបាន ដោយប្រឹតប្រឹងប្រាណឲ្យផុតផុត ។
១- អំពើបាណាតិបាត នេះណានេសាទចង់ចិត្តចង់
តិរ្ថាគមនុស្សដោយចំណង់ ឲ្យស្លាប់បាត់បង់ខ្លួនជន្មា ។
ឃាតករនោះឯងតែងនេះក្តៅ យ៉ាកយ៉ាប់មួមេីនេះទៅនា
សញ្ជ័យនរកចូរខំពុក រងទុក្ខវេទនាយូរយារវែង ។
ខំរយបាលចាប់ចោះទៅ ក្នុងភ្នក់ភ្លើងជ្រៅនេះក្សីណាក្សយ
កេីតឡេីងវិញក្លាមប្រឹងកែទៀ ភាលូនលឿនវែងទៅខាងក្រៅ ។
ខំរយបាលបានឃេីញជាក់ ស្ទុះចោមរោមចាក់ខំដែកក្តៅ
ប្តូខឹងលំពែងរុញចោះទៅ បួលក្នងរណ្តៅទៅពុះពុះក្ខ ។
លុះអស់ចុបកម្មទេីបរោះ ពីនរកនោះក៏មិនសុ ។
កេីតជាមានាំខែអ្នកស្រុក ច្រំាយជាតិទុក្ខច្រាកដជាក់ ។
ទេីបកេីតជាមនុស្សអាក្រក់ក្រែ តែងតែងខ្លីជេីងដៃខ្វិនគមគាត់
កេីតឃ្លង់ដំបៅស្រែងតែកខ្វាក់ លំបាកឥតអាក់អាយុខ្លី ។

ប្រសិនជាបានបុណ្យស្រគុំយស ថ្កុំថ្កើងខ្ពង់ខ្ពស់ក្នុងលោកិយ
កម្មតាមមកផ្តល់អាយុខ្លី មិនបានទៅស៊ុំស្វាប់ឋានំបាត់ ។
នរណាខ្មាសបាបឋ្លាចបាប រៀរចាកដកបង់រៀតសត្វ
មិនហ៊ានបៀតបៀនបង្កំបាត់ សម្លាប់បង់បាត់ផ្តាច់ដីវិត ។
នរនោះបានកើតទៅលើស្ថាន សួគ៌ទិព្វថ្កើងថ្កានមានអាស្ចា
ឈ្មោះបាតុម្មហារាជាធិបតី មានទេពធីតាតាល់កាលំថ្ងៃ ។
សោយសម្បត្តិទិព្វសុខសប្បាយ តាំងរូបកាយល្អល្អះក្រៃ
ប្រាំរយឆ្នាំទិព្វប្បវត្ត ត្រកូលថ្លាថ្លៃមានសម្បត្តិ ។
មានកម្លាំងខ្លាំងក្លាលើសលន់ ចិន្តាទោរទន់ប្រណីសត្វ
ប្រពន្ធកូនទៅទៅមិនព្រាត់- ប្រាសចាកខ្លួនក្លាត់សុខដល់ចាស់ ។
កើតមកជាមនុស្សពុំក្សីណាក្សយ ជីវិតប្រល័យត្រឿងសហ័ស
មានមនុស្សបំរើតាំងក្មេងចាស់ សុខសប្បាយណាស់រកទុក្ខគ្មាន ។

២- តិអទិន្នាទាន:

នរណាលួចប្រាក់ទ្រព្យធនធាន
ដើរលួចដើរបន្ទំពីគេកុតកាន រឹបជាន់ឈ្មោះពាន់ក្នុងឃោរឃៅ ។
នរនោះស្លាប់ទៅធ្លាក់រហូត ចុះដល់ឋានសួគ៌ត្រូវរកជ្រៅ
និរយបាលចាប់ចងទៅ ចាក់ទងដែកក្តៅឈឺខ្លោចផ្សា ។
ហើយទើបតួកខ្លះយកបន្ទាត់ ដែកក្តៅមកផ្ចាត់សព្វកាយា
ខ្លះយករណារក្តៀងមកអារ ពុះពីសរសៅដុតខ្លួន ។

រយៈជាច់សាច់ឈាមសស្រាក់ ស្រែកយំឥតអាត់តយកាំងកាន់
ខៅកន្ធែនរកពុះពុកទ័ណ្ឌ កំណាត់មួយពាន់ផ្ទាំរដោះ ។
កន្ធែមួយពាន់ផ្ទាំនៃស្ថានត្រៃ- ត្រីផ្សេចមួយថ្ងៃនរកនោះ
យូរអង្វែងណាស់ទើបរដោះ ពីនរកនោះមកកើតបាន ។
ជារប្រេតកំពស់ដើមត្នោតលៃ រឯពុកមោសរៃរាប្រមាណ
អត់ឃ្មុយអត់ទឹកស្គាំងស្គមក្រាណ គ្មានបានអ្វីធ្វើចំអែតផ្ទៃ ។
ក្រាំរយៈជាតិទើបចាប់កំណើត មកកើតជាមនុស្សក្រីក្រក្រៃ
ដើរសូមទានតែអចិន្ត្រៃ លំបាកយ៉ាកក្រៃខ្មៅខ្ទីគេ ។
ប្រសិនទានណាបញ្ជាគ្នាត ចិត្តផ្សងផ្ដំស្អាតគិតរិះរេ
រៀបចាកអំពើលួចប្រត្យេគ ដៃលមិនធ្វើទេក្នុងលោក ។
ទរនោះរមែងតែងតែបាន ខៅកើតខៅស្ថានត្រៃត្រឹង្ស
មានទេពអប្សរបរិវារកញ្ញា តង់តាល់ត្រៀបត្រាខៅរហង់ ។
សោយសម្បត្តិទិព្វជាសុខសាន្ត មួយពាន់ផ្ទាំបានច្យុតបាត់បង់
មកកើតជាក្សត្រកត្រូវផ្ដង់ ឬសេដ្ឋីធំបុណ្យក្តីធ្លាន ។
សម្បូណាមាសប្រាក់តែងពេជ្រ ចោរចូលកំទេចយកពុំបាន
ប្រតិទ្ធកូនចៅតាំងប៉ុន្មាន ឋានសុខសាន្តគ្រាណាគ្មានតិតក្រែង ។
៣- តីកាមេសុមិច្ឆា ទរណាព្រហើនចិត្តវង្វែង
លួចប្រតិទ្ធកូនគេឥតក្រែង ឬផិតប្តីឯងតែងរងទុក្ខ ។

នរនោះលុះស្លាប់ជាត់ជន់ទៅ ធ្លាក់ចុះទៅនៅស្ថាននរក
ឈ្មោះសង្ឃាតៈវង់ទោសទុក្ខ ក្តៅដែនឆេះគគុកក្តៅរាល់ថ្ងៃ ។
និរយបាលឈរចាំយាម ក្រឡែកឃើញភ្លាមស្ទុះប្រហារ
ដេញចាក់ឲ្យឡើងដើមរកា ដែកមានបន្ទាស្រួចដុះជ្រោង ។
មេស្រីផងប្តីឡើងមុនប្រុស មុតខ្លួនសព្វសុសស្រែកយំដោង
ហើយហុចដៃឲ្យគាប្រុសគោង ចាប់ហោងទាញឡើងយំសស្រាក់ ។
ខាងក្រោមមានឆ្កែ-និរយបាល ជាច្រើនត្រអាលទាំត្រចាក់
ខាងលើមានត្មាតចឹកកន្ត្រាក់ ធ្លុះភ្លាក់ដល់ដីខ្លួនដេកផ្ងារ ។
ចង្កឹមឆ្អែចំពុះសត្វត្មាត សុទ្ធតែដែកស្អាតស្រួចមុតថ្លា
ត្រចាក់ទាំចឹកដួលដេកផ្ងារ នេះក្តៅការយាធ្ងារវេទនា ។
នរកនោះអាយុវែងវៃក្រៃ ពីរពាន់ឆ្នាំនៃស្ថានយាមា
ទើបបានមួយថ្ងៃស្ថានសង្ឃាត៍ អស់កម្មវេរទើបរដោះ ។
មកកើតបានជាសត្វតិរច្ឆាន គេត្រៀវគ្មានបានសប្បាយសោះ
ត្រប់ប្រាំរយជាតិទើបរដោះ ពិតរៀវនោះទើបទន់ឆ្ងាន ។
កើតជាមនុស្សរៀងប្រាំរយជាតិ ទើបក្លាយខ្លួនហ្មាតជាប្រុសប្រាណ
ឬស្រីប្តីក្សត់ឥតសាមាន្យ ប្រាំរយជាតិបានជាមនុស្សម្នា ។
បើនរណាមានប្រាជ្ញអាចរិះរេ រៀវចាកកាមេសុមិច្ឆាចារ
នរនោះនឹងបានកើតសួគ៌ា ឈ្មោះស្ថានយាមាទិព្វថ្លាថ្លៃ ។

វស្ស៍តន្ទីភ្លឺចិញ្ចាច ចរំភ្លេងត្រដាបរង៉ែរឿងវិក្រៃ
ស្រីខេតអប្បរគោលកាលថ្ងៃ ធើតនោមល្អក្រៃកាយចរិសុទ្ធ ។
ស្ថានយាមាអាយុថ៍ខាន់ ឆ្នាំទំព្ងត្រប់គ្រាន់ទើបចុះប្បត
មកចាប់កំណើតជាកដបុត្រ កវិយាបរិសុទ្ធកបកាយល្អ ។
៤- គឺមុសាវាទជាតិ នណាចិត្តស្ម័ត្រគោលកូតកវ
ឲ្យកើតចលាចលវឹកវរ ភាគទ្ធបបេរអ្នកដទៃ ។
នរៈនោះភ្លាត់ចុះកោតនរក វង៉ែគោសវង៉ែខ្ពុតអចិន្ត្រៃ
និរយបាលកាត់ដើងដៃ រឿងកាលថ្ងៃ។ ដួលដេកទៅ ។
កាត់មាត់អណ្តាតឈាមស្រោកស្រាក់ ហើយពាក្យគ្រាក់ចុះចាលទៅ
ចូលក្នុងរណ្តៅឆេះសន្ធៅ វង៉ែគោសខ័ណ្ឌទៅខ្ពុតមួមឹត ។
កោរភាយុយូរយារវិក្រៃ មួយតាន់ថ្នាំនៃស្ថានតុសិត
ទើបបានមួយថ្ងៃនរកតិត អស់កម្មអតីតទើបរដោះ ។
មកកើតជាប្រេត-អសុរកាយ ក្រហាល់ក្រហាយគ្មានចន្លោះ
ក្លិនឆេះអណ្តាតចេញមាត់ស្មោះ ស៊ីឈាមស៊ីខ្ទុះជាអាហារ ។
អស់កម្មទើបកើតមកជាមនុស្ស ជាន់ជាស្រីប្រុសមាត់ទេចនា
ល្ងិតល្ងង់ល្ងីល្ងើអាប់ឧញ្ញា ដល់គោលវាចាស្តុយសក្តិសិទ្ធិ ។
នណាវៀចាកមុសាវាទ មិនឲ្យឃ្លៀងឃ្លាតចាកពាក្យពិត
នរៈនោះជាន់កើតស្ថានតុសិត វង៉ែរឿងថ្លៃឆ្ងល់ស្មើសាយ ។

ចួនពាន់ឆ្នាំទិព្វទើបច្យុតចុះ　　មកកើតជាមនុស្សរូបឆើតឆាយ
ជាពហូសូត្រក្រោកច្រាជច្រាយ　　ល្បីល្បាញខ្លួនខ្លាយក្នុងលោកិយ ។
៩ - តតិយសុភមេរយោ　　នរណាធឹកស្រាទឹកអប្រិយ
ស្រវឹងប្រមឹកចិត្តតិរ្ថិយ　　រវៃងឹងស្មារតីក្លេចធម្មា ។
នរនោះលុះស្វាប់ច្យាត់បងំទៅ　　ធ្លាក់នរកជ្រៅស្ថិតនៅទា
ស្ថានច្យាតនរកពុក្កុមហិមា　　ពុនទំពុកយូរយោរណាស់ ។
ដោយហេតុប្រមឹកចិត្តវង្វេង　　ធឹកខឹកខន់ដៃដងពុះពេញខ្លះ
នេះថ្នមប្រមាត់នេះក្រពះ　　ស្រែកយំខ្ទាំងណាស់ឥតឧបមា ។
ច្រាំបីពាន់ឆ្នាំនិម្មានតី　　ច្យានមួយភក្រ្តីស្ថានច្យាតា
អស់កម្មទើបកើតជាយក្ខា　　ថ្នមនុស្សលើលាភគតវង្រៃ ។
នរណាមានច្រាជដ៏ក្លៀវក្លា　　រៀរសេពសុភនិដ្ឋមេរ័យ
នរនោះនឹងកើតស្ថានសួគ៌ថ្លៃ　　ខ្ពស់ក្រៃឈ្មោះនិម្មានតី ។
ស្ថិតខ្ពស់នៅលើច្រាង្គច្រាសាទ　　វិចិត្រស្អាងស្អាតសុទ្ធតែស្រី
ស្រីទេពអប្សរស្អប្រិមប្រិយ　　តង់តាលប្រក្រតីមិនដែលខាន ។
សោយសុខជាយូរទើបច្យុតចុះ　　មកកើតជាមនុស្សខ្ពស់ឆ្ពើងឆ្ពាន
មានច្រាជអង់អាចយ៉ាងក្លាហាន　　ដោះប្រស្នាច្យានក្នុងលោកា ។
ព្រះចៅកោសលក្រាបអតិរាទ　　សម្តេចនរនាថលើលោកា
ខួលប្រតិបត្តិតាមទង្ហារ　　ហើយលើកសេនាចូលបុរី ។

សេចក្តីសង្ខេបរឿង

បទកាកគតិ

១) ព្រះមហាសីលវៈ ខន្តីសច្ចៈ ទ្រង់សីលធម៌គាថា
ពលរដ្ឋប្រុសស្រី មេត្រីស្នេហា នាំគ្នារក្សា
សីលទាំងប្រុសស្រី ។ ចេះរួបរួមគ្នា ទាំងកស្ត្រប្រជា
នាហ្នឹងកុងរ្បីយ ស្រឡាញ់គ្នាស្និទ្ធ រួមរឹតមេត្រី
ទាំងប្រុសទាំងស្រី រួមគ្នាជិតស្និទ្ធ ។ ប្រទេសកាសី
រុងរឿងល្បាញល្បី គ្រប់ទិសទ្វាយជិត ក្រោមកិច្ចដឹកនាំ
ទត្តមពិត ។ ប្រទេសទ្វាយជិត ទូបទ្វាចចេស្តា ។
ព្រះមហាសីលវៈ ជាមហាវីរៈ ក្សត្រធ្នើមលោកា
ព្រះអគ្គចេញច្បាំង តតាំងចេស្តា ជាមួយក្សត្រា
ប្រទេសកោសល ។ ទ្រង់ធ្វើសង្គ្រាម គ្មានបង្អង់ឈាម
ឲ្យចលាចល ចម្បាំងឈ្នះស្រេច ទើបស្តេចកោសល
ទនសិរសោជល់ ផែនដីបង្គំ ។ ព្រះមហាសីលវៈ
ព្រះទ័យស្មោះស្ម័គ្រ ស្នេហ៍ភក្ត្រតូច-ធំ ពូន្មានប្រដៅ
ព្រះបៀឲ្យចំ លះបង់គំនុំ គុំគួនញាប់ខ ។
ឲ្យថែរក្សា បញ្ញសីលា ចានផ្លូវផង់ស្អាត
ឲ្យចេះស្រឡាញ់ មិនឲ្យប្រមាទ បៀតបៀនញាប់ខ

ជាតិមនុស្សដូចគ្នា ។

๒) ព្រះចៅគោសល ស្តេចលើកសាកល សេនាយោធា
ចូលមកសំរុក លុយលុកពុះពា ញាំញីការ
ពាក់ណាស័ ។ លុះបរាជ័យ គោសលតិតព័យ
សំរេចដល់ដី ក្រែញក្រោបអតិភព នរនាថការ
ថ្វាយខ្លួនទឹកដី ថ្វាយពលសេនា ។ ហើយបានតាំងចិត្ត
លះបង់ពុទ្ធរិត តាំងចិប្រការ លែងដើរកេតក្បាត
ក្បាច់ប្រហារ បង្កើតចលា. ចលរលើផែនដី ។
ព្រះចៅប្រព្រឹត្ត អំពើសុចរិត សព្វត្រប់តាំងបី
បញ្ញសីលា រក្សាប្រក្រតី តាំងប្រុសតាំងស្រី
មេត្រីស្មោះសរ ។ ព្រះចៅប្រព្រឹត្ត អំពើសុចរិត
បរិសុទ្ធបវរ ទើបស្តេចទ្រង់ត្រាស់ តម្រាស់ស្មោះសរ
ឲ្យប្រជាករ ទីឯអ្នករាជការ ។ ប្រព្រឹត្តតាំងអស់
មិនឲ្យបន្ទោះ សល់ទានលោកណា ដោយព្រះគំនិត
យល់ពិតច្បាស់ថា អាចញាំងលោកា ឋានសន្តិភាព ។
ព្រះចៅគោសល ជាឆ្នើមលើពល សេនាខ្ពស់ខាប
ព្រះទ័យមិនក្លាញ់ ស្រឡាញ់សន្តិភាព យសស័ក្តិខ្ពស់ខាប
ទ្រង់កប់ស្មើគ្នា ។

៣) លោកកាឡ - បក្សី សេនាបតី លោកលន់មហាមា
ប្រាថ្នាសម្បត្តិ មហាក្សត្រសោភា បង់តាំងខ្លួនជា
ស្តេចត្រង់ផែនដី ។ ចំបះចំបោរ បង្កើតទ័ពចោរ
កូងអញ្ជើ ឲ្យដើរពេតត្បាត ញាប់ប្រុសស្រី
ញាប់ញ័រផែនដី កាសីរដ្ឋា ។ បក្សីអន្ធតាល
ថ្កើមធំតាសព្រាល ចាត់កុក្រព្រះមហា ក្សត្រដែនកោសល
លើកពលសេនា ចូលបំផ្លាញរដ្ឋា ប្រហារប្រុសស្រី ។
បង្កើតសង្គ្រាម បង់តែឈាម ជាតិខ្លួនឯងឱ្យ
ឲ្យជាតិវេទនា កំព្រាបាត់ប្តី បាត់កូនប្រុសស្រី
បាត់យាយបាត់តា ។ បក្សីអបលក្ខណ៍ ក្សត់ព្រះសីលវៈ
ក្សត់ជាតិសាសនា ដល់ខ្លួនអន្ធកយ រូបកាយមតា
ស្លាប់ដូចឆ្កែឆ្កា អាហារឆ្កែតាត ! ។

ភាសិត

លោកហួសខ្នាត

ទាំងតដើម ។

ព្រះអភិធម្មបិដក

(គម្ពីរព្រះមហាបដ្ឋាន)

លោក ប៊ូ-ប៉ូ រៀបរៀង

(ភាគ)

ទើបដំនុំប្រឹក្សាគ្នាថា «យើងទាំងឡាយនឹងធ្វើដូចម្តេច ទើបញ៉ាំងទោសឲ្យកើតឡើងដល់ព្រះសមណគោតមបាន» តំឃល់ឃើញត្រមគ្នាថា «ទើបតាក់អាស្រ័យនាងចិញ្ចាមានវិការនោះឯង ទើបអាចញ៉ាំងទោសឲ្យកើតឡើងបាន» លុះឃល់ឃើញត្រមគ្នាដូច្នេះហើយ ក៏តិតសំគាល់ខុសតែក្នុងចិត្ត មិនស្រដីប្រាប់អ្នកណាឡើយ ។

អបរភាគៈ ចំណេរបន្តិចតាលខាងក្រោយមក មានមួយថ្ងៃ តិត្តិយាភមំ កន្តា នាងចិញ្ចាមានវិការបរិភោដ៏ឆៅឯអាកមនៃតិរ្ថិយទាំងឡាយនោះ លុះដល់ហើយក៏លើកដៃឡើងសំពះហើយអង្គុយនៅក្នុងទីដ៏សមគួរដល់ខ្លួន ។ តិរ្ថិយទាំងឡាយឆ្លើតលមាយាគ្មានអ្នកណាចរចាជាមួយនាងចិញ្ចាមានវិការសោះ នៅស្ងៀមឈឹងទាំងអស់គ្នា ។ នាងចិញ្ចាមានវិការគិតតែក្នុងចិត្តថា «លោកម្ចាស់ទាំងឡាយបែបនេះ ក្រែងខឹងនឹងអញឬអ្វី ឬបានជាធ្វើអាការយ៉ាងនេះ មិនស្តីនិយាយនឹងអញសោះ» នាងគិតរួចសួរថា : «បពិត្រលោកម្ចាស់ទាំងឡាយ ! លោកទាំងឡាយឮឈ្មោះនឹងខ្ញុំដោយហេតុអ្វី ឬបានជាមិនចរចានឹងខ្ញុំសោះយ៉ាងនេះ?

តិរ្ថិយពាំងនោះទ្វេីយថា: «យើងកល់គ្នាឥតក្រោធទីងអ្វីនឹងនាងទេ ចុះវេលានេះនាងមិនដឹងទេ ឬថា: យើងពាំងឲ្យាយពុំបានសេចក្តីសុខ ព្រោះហេតុតែអាស្រ័យនូវព្រះសមណគោតម ព្រះសមណគោតមលោកមៀតបៀនឲ្យយើងលំបាកក្រៃលែងតេសេចក្តីសប្បាយចិត្ត ។

នាងចិញ្ចមានវិកាសួរថា: កឹ កកេមិ ចុះខ្ញុំនឹងធ្វេីដូចម្តេចទេីបលោកពាំងឲ្យាយសប្បាយចិត្ត ?

តិរ្ថិយពាំងនោះទ្វេីយថា: សចេ ឥច្ឆសិ បេីនាងចង់ឲ្យយើងបានសប្បាយកែកយ ចូរគិតញុំងទោសណាមួយឲ្យកេីតដល់ព្រះសមណគោតម ព្រោះថា អ្នកដទៃមិនអាចញុំងទោសឲ្យកេីតដល់ព្រះសមណគោតមបានឡេីយ មានតែនាងម្នាក់ឯងប៉ុណ្ណោះ ទេីបអាចញុំងទោសឲ្យកេីតដល់ព្រះសមណគោតមបាន ។

សាធុតិ សម្បដិច្ឆិត្វា នាងចិញ្ចមានវិកាទទួលពាក្យពួកតិរ្ថិយថា ប្រពៃហេីយ ខ្ញុំនឹងធ្វេី ។ នាងនេះទទួលពាក្យតិរ្ថិយរួចហេីយក៏លាទៅ ។ កាលមហាជនស្តាប់ព្រះសទ្ធម្មទេសនានៃព្រះបរមសាស្តាចប់ហេីយ ត្រឡប់ចេញទៅផ្ទះវិញ ទៅពេលព្រលប់ នាងចិញ្ចមានវិកាចេញមកពីត្រែះស្ថានអាក្នាដេីរតាមមាគ៌ាដួចនឹងមហាជន ។ សួរនាងចិញ្ចមានវិកាថា : កុហិំ គច្ឆសិ នាងទៅទីណាក្នុងពេលនេះ ?

នាងចិញ្ចមានវិកាបរិព្វាជិនីទ្វេីយថា ខ្ញុំទៅកាន់វត្តព្រះជេតពន ។

លុះដល់វេលាព្រឹកឡើង ជនតាំងឡាយចូលទៅកាន់ព្រះវិហារ នាង
ចិញ្ចាមានវិការខោះ កំដើរត្រឡប់មកពីព្រះជេតពនមហាវិហារវិញ ។
ជនតាំងនោះសួរថា: នាងមកពីណា ? នាងចិញ្ចាមានវិការក្រាបថា:
ខ្ញុំវិលទៅផ្ទះខ្ញុំវិញ ។ ជនតាំងឡាយឮដូច្នោះ កំមានចិត្តគិតសង្ស័យ
នៃកល់គ្នា ។ កន្លងពីនោះមកមិនយូរប៉ុន្មាន នាងចិញ្ចាមានវិការក្រាប
ជនតាំងឡាយថា: យើងនៅនៅក្នុងព្រះគន្ធកុដីជាមួយនឹងព្រះសមណ-
គោតមក្នុងវត្តជេតពន ។

កន្លងពីពេលនោះមកប្រមាណជាពីរឬបីថ្ងៃ នាងចិញ្ចាមានវិការយក
ឈើដុំខ្នងដៃខ្នងជើងធ្វើហើមប៉ោងឡើងដូចជាដៃនឹងជើងនៃស្ត្រីមានគត៌ ។
លុះយូរមកទៀត នាងនេះយកកំណាត់សំពត់ចងរុំពោះឲ្យឡើងប៉ោងធំ
ធ្វើអាការហាក់ដូចស្ត្រីមានគត៌ត្រប់ខែដិតនឹងប្រសូតបុត្រ ទើបទៅកាន់-
សំណាក់នៃព្រះពុទ្ធអគ្គ ដែលកំពុងតែដំទៅកណ្តាលជនតាំងឡាយជា
សប្បុរសដើម្បីនឹងស្តាប់ព្រះសទ្ធម្មទេសនា ។ ទៅពេលដែលព្រះពុទ្ធ
ជាអម្ចាស់កំពុងត្រាស់ទេសនាធម៌ដល់ពុទ្ធបរិស័ទ្ធតាំងបួននោះអស្ចារ្យ
នាងចិញ្ចាមានវិការស្រែកដេរព្រះមានព្រះភាគថា « បពិត្រព្រះសមណ:
ប្រសើរ ព្រះអង្គចូរពិចារណាមើលទុក្ខអាការដ៏គួរបុះ ឥឡូវនេះ ខ្ញុំព្រះអង្គ
មានគត៌ត្រប់ខែហើយ ព្រះអង្គមិនដឹងទេឬអ្វី ព្រះអង្គធ្វើអាការហាក់ដូច
ជាមិនបានដឹងសោះ ព្រះអង្គមិនបានដឹងនូវការជួយសង្គ្រោះខ្ញុំព្រះអង្គដែល

មានឥតមានថាចិញ្ចាមានវិការផងទេ ដ៏ឯតែខាងការត្រេកត្រអាលនឹងខ្ញុំព្រះអង្គ
ម្យ៉ាងប៉ុណ្ណោះ ឯការដែលខ្ញុំព្រះអង្គនឹងប្រសូតបុត្រនោះ ទ្រង់ប៉ះក្តៅចោល
ក្តៅជាមិនដឹងទៅវិញ បើទ្រង់មិនទទួលដឹង មិនជួយចំទុកបម្រុងខ្ញុំព្រះ-
អង្គទេ ក៏តាមព្រះទ័យចុះ ប៉ុន្តែគួរនឹងបង្គាប់អ្នកទុបជ្ឈាក គឺព្រះបាទ-
បសេនទិកោសល នឹងអនាថបិណ្ឌិក ឬ ចុលអនាថបិណ្ឌិកជាដើមឲ្យធ្វើ
ផ្ទះឬកេងសម្រាប់ខ្ញុំព្រះអង្គប្រសូតបុត្រឲ្យផុតពីសេចក្តីទុក្ខលំបាក នេះ
បង្គាប់អ្នកណាក៏គ្មាន មានតែខាងត្រេកត្រអាលនឹងខ្ញុំព្រះអង្គមួយមុខ-
ប៉ុណ្ណោះ លុះខ្ញុំព្រះអង្គមានគតិ ក៏ទ្រង់សៀមឈឺងមិនសាកសួរថា ចិញ្ចា-
មានវិការនេះយ៉ាំងណាទៅហើយ ។

កាលនាងចិញ្ចាមានវិការដេរតែរដៀលព្រះមានព្រះភាគដូច្នោះ ប្រៀប
ដូចជាបុគ្គលប្រទូសរកយព្រះចន្ទ៍ទេវបុត្រក្នុងអាកាស នាំយកទូរដុំលាមក
បូលទៅក្នុងមាត់ ។

អថ សត្ថា កង្ខំលាំងនោះ សម្តេចព្រះបរមសាស្តា មានព្រះពុទ្ធ-
ដីកាថា «ម្នាលនាងបរិព្វាជី នាងមានឈ្មោះថាចិញ្ចាមានវិការ ពាក្យដែល
នាងនិយាយចោទតថាគតមិនបានប្រាកដដល់អ្នកដទៃទេ អ្នកដទៃឥតបាន
ដឹងរឿងនេះសោះ ដ៏ឯតែនាងនឹងតថាគតពីនាក់ប៉ុណ្ណោះ តថាគតបាន
ធ្វើដូចពាក្យនាងថាក្តី មិនបានធ្វើដូចពាក្យនាងថាក្តី គ្មានអ្នកណាដឹងនូវ
ហេតុផលនេះទេ មានតែសម្តេចអមរិន្ទ្រាទេវរាជ ទ្រង់នូវព្រះនេត្រទិព្យ

ទើបអាចដឹងច្បាស់ឃើញច្បាស់នូវព្រឹត្តិហេតុ ដែលនាងពោលនឹងតថាគតនេះ » ។

តស្មឹ ខណេ តស្មឹ ខណៈនោះ បណ្ឌុកម្ពលសិលាអាសនៈនៃស្តេចវេដីរថ្កាណិសក្រិន្ទទេវរាជ កំពុងអាការវិបលាសក្តៅ ហើយនឹងមិនជាទីសប្បាយព្រះហឫទ័យ អាវជ្ជន្តោ សម្តេចអមរិន្ទ្រទ្រង់ចិន្តនាការកំណត់ព្រះហឫទ័យថា ហេតុអ្វីបានជាបណ្ឌុកម្ពលសិលាអាសនៈកើតវិបលាសយ៉ាងនេះ ទ្រង់ព្រះតម្រិះដូច្នេះហើយ កំទ្រង់ជ្រាបថា នាងចិញ្ចាមានវិកាពោលពាក្យប្រមាថមើលងាយអង្គសម្តេចព្រះមានព្រះភាគដោយឥតដឹងអាក្រក់ត្រគោះចោះចុក មិនសមគួរសោះ ត្រូវតែអញចុះទៅរំលាយបំបាត់នូវសេចក្តីសង្ស័យ ដែលកើតមានឡើងក្នុងកណ្តាលចរិសំខាងមួនលុះទ្រង់ជ្រាបយ៉ាងនេះហើយ កំស្តេចចុះចាកតាវត្តឹង្សពិភពមកតាន់ដេតពនមហាវិហារ លុះដល់ព្រះដេតពនហើយ ទើបបណ្តាលដោយទេវបុត្តជាមុសិកជាតិកណ្តុរចូលទៅកាត់មណ្ឌល នៃចេសនឹងកំណាត់សំពត់ឲ្យដាច់ភ្លាក់ចុះមកចំពោះមុខនៃចតុបរិសទ្ធ ។ ខ្សែចេសនឹងដុំកំណាត់សំពត់ កាលដាច់ហើយ កំភ្លាក់ចុះលើខ្នងដើមនៃនាងចរិញ្ចាដ៏ ។ មហាជនខាងឯាយ តាំងគ្នាប្រហារនាងចិញ្ចាមានវិកា ។ ខណៈនោះ ផែនពសុធាដែលឥតចិត្តហាក់ដូចជាមានចិត្ត បើកឱ្យចន្ទោះដល់នាងចិញ្ចាមានវិកា ។ នាងចិញ្ចាមានវិកាក៏ភ្លាក់ចុះទៅក្នុងចន្ទោះពសុធា ទៅកើតក្នុងនរកឈ្មោះមហា-

អរិយៈ ។ ផលនៃអកុសលដូច្នេះ គំរាបបញ្ចូលក្នុងទិដ្ឋធម្មវេទនីយកម្ម ។

ឯអកុសលកម្មដ៏ជាទិដ្ឋធម្មវេទនីយនោះ ដូចជាព្រះទេវទត្តនឹងព្រះ-
កោកាលិកៈជ្រើ គឺចាត់ជាទិដ្ឋធម្មវេទនីយកម្មខាងអកុសល ។ កម្មដែល
ឈ្មោះថាទិដ្ឋធម្មវេទនីយ៍ខាងពីរចំណែក គឺកុសលនឹងអកុសល ។ បើ
កុសលកម្មឲ្យផលឃើញជាក់ស្តែងក្នុងបច្ចុប្បន្ន ក៏ចាត់ជាទិដ្ឋធម្មវេទនីយ-
កម្មខាងកុសល ។ បើអកុសលដែលបុគ្គលធ្វើឲ្យផលឃើញជាក់ស្តែង
ក្នុងបច្ចុប្បន្ន គឺចាត់ជាទិដ្ឋធម្មវេទនីយកម្មខាងអកុសល ។

ហេតុនោះ អ្នកប្រាជ្ញគប្បីធ្វើមនសិការកំណត់ខុកក្នុងចិត្តថា អកុសល
កម្មដ៏ធ្ងន់នោះ បើបុគ្គលណាធ្វើទ្វាំងក្បា គឺថាប្រទូសកាយដល់មាតាបិតា
ប្រទូសកាយដល់សមណព្រាហ្មណាចារ្យ ប្រទូសកាយដល់អ្នកមានសីល
ហើយ ក៏អាចឲ្យផលឃើញជាក់ស្តែងជាទិដ្ឋធម្មវេទនីយ៍បាន ។ ចំណែក
ខាងកុសលកាសិវិញក៏ដូចគ្នាដែរ បើធ្វើទានលះបង់ជីវិត រក្សាសីលមិនតិត
ជាជីវិត ទំនៀលត់បញ្ចូកុន្ត ស៊ូលះបង់ ប្តូរនឹងសីល តិតតែខាងធ្វើសីល
ឲ្យស្អាតបរិសុទ្ធហើយ ក៏អាចឲ្យផលជាទិដ្ឋធម្មវេទនីយកម្មបាន ។

ប្រការមួយទៀត អាចិណ្ណកុសលកម្ម គឺអកុសលកម្មដែលបុគ្គល
ធ្វើសន្សំពុកអស់កាលជាទិច្ចកាលថ្ងៃ ក៏ជាទិដ្ឋធម្មវេទនីយ៍ ដូចជាព្រះ
ពុទ្ធជាតុមារស្តេចទៅកាន់ព្រះរាជឧទ្យាន បានទស្សនាការយើញជន
ពាំងឡាយ មានសេចក្តីគោរពក្នុងព្រះបវរពុទ្ធ ក៏មានសន្ធានក្រោធញាស់

ចរតដសារឡៃដេញព្រះបាច្ចេកពុទ្ធ ។ ក្រៃឡែកមើលកំរឹតតែគ្រោធខ្ញាំនឡើង
ទើបធក់យកថ្ងាក្រនៃព្រះបាច្ចេកពុទ្ធនោះ មកចោះលើប្រថពី ហើយជាន់ឈ្លី
នឹងជើង រួចនិយាយនឹងព្រះបាច្ចេកពុទ្ធថា បើព្រះសមណៈខឹងនឹងយើង
តើខឹងធ្វើអ្វីដល់យើងកើត ។ កន្លះណៈនោះ ព្រះហឫទ័យរបស់ពុទ្ធភ-
កុមារបណ្តាលឡៃក្តៅក្រហាយមានរសចក្តីលំបាកយ៉ាងខ្លាំង ស្រែកខឹក
ណាស់ ខឹកកន្លងគុណ្ឌីកំរឹងស្លុតអស់ គួរឡៃអស្ចារ្យពេក ។ ពេលបុរស
ពាំងឡាយនាំគ្នាគ្រាចរង្គាត់ស្ទុះសែងរកខឹកដែលមានកន្លងាង កន្លះនឹង
ភាជន៍ជាក់ខឹកដែលមានកន្លព្រះពាជទ្រព្យាន ។ ខៅខឹកខ្នែងដែលធ្លាប់តែ
មានខឹកពេញពោរបរិបូណ៌ពីកាលមុននោះ កំប្រែខ្វែងជារឹងស្លុតហួតខឹក
អស់ខៅរៃឡៅគ្រានោះ ។ ព្រះពាជកុមារស្រែកខឹកខ្លាំងណាស់ រកខឹក
សោយមិនបាន កំអស់ព្រះឥន្ទាឃុសង្ឃារហើយខៅកើតក្នុងអវិចិមហានរក
ដោយហេតុអកុសលកម្មជាទិដ្ឋធម្មវេទនីយ៍ ឲ្យដល់ឃើញជាក់ស្តែងក្នុ
បច្ចុប្បន្ន ។

ម្យ៉ាងទៀត អកុសលកម្មនៃព្រះបាទកលាពុកជដែលប្រទូសរកយ
ដល់សម្តេចព្រះពុទ្ធអង្គជាម្ចាស់នៃយើង កាលព្រះអង្គសោយព្រះជាតិជា
ទន្តិវាទិតាបសបរមេពោធិសត្វនោះ កំពាត់ជាទិដ្ឋធម្មវេទនីយកម្មខាង
អកុសល ។

ហាត្ថិមារកៈព្រានដំរី ដែលប្រទូសរកយដល់សម្តេចព្រះពុទ្ធអង្គ កាល

សោយព្រះជាតិជាស្តេចកុញ្ជរឈ្មោះឆទ្ទន្ត អកុសលកម្មនោះ ក៏ឈ្មោះជាទិដ្ឋធម្មវេទនីយ៍ ។

អ្នកប្រាជ្ញគប្បីចូលចិត្តថា អកុសលកាលដែលបុគ្គលធ្វើកន្លងជាតិនេះ ហើយឲ្យផលក្នុងជាតិនេះ ក៏ឈ្មោះថាទិដ្ឋធម្មវេទនីយកម្មខាងកុសលដ៏អស់ ។

ប្រការមួយទៀត អាចិណ្ណកុសលកម្ម គឺកុសលកាលដែលបុគ្គលធ្វើសន្សំទុកអស់កាលជានិច្ចរាល់ថ្ងៃ ដូចជាអនាថបិណ្ឌិកមហាសេដ្ឋីថ្វាយបិណ្ឌបាតរាល់ថ្ងៃ។ល។ តែអស់ទ្រព្យសម្បត្តិមិនអាចថ្វាយអាហារបិណ្ឌបាតឲ្យប្រណីតបាន ក៏នៅតែ១សម្លាប់ថ្វាយអាហារបិណ្ឌបាតមិនដាច់ ថ្វាយបានតែបិណ្ឌបាតសៅហ្មងជាមួយនឹងទឹកជ្រក់ជាគំរប់តែប៉ុណ្ណោះ ។ លុះខាងក្រោយមក ទៅតាដែលអាស្រ័យនៅខាងក្នុងក៏ជាគំរប់បួន នាំយកទ្រព្យមកជាក់ពេញឃ្លាំង ប្រមូលផញ្ជួនទ្រព្យសម្បត្តិរបស់អនាថបិណ្ឌិកមហាសេដ្ឋីឲ្យមូលមកពេញឃ្លាំងដូចដើមនោះ ក៏អាស្រ័យអាចិណ្ណកុសលកម្ម គឺការធ្វើសន្សំកុសលកាលជានិច្ចមិនដាច់ ។

ហេតុនោះអ្នកប្រាជ្ញគប្បីធ្វើមនសិការកំណត់ទុកក្នុងចិត្តថា ផលនៃកុសលកាលដ៏ជាអាចិណ្ណកុសលនោះ អាចឲ្យផលជាទិដ្ឋធម្មវេទនីយ ដូចបរិយាយមកនេះ ។

ទិដ្ឋធម្មវេទនីយកម្ម សង្ខេបប៉ុណ្ណោះ ។

(នៅមានត)

សម្តែចព្រះធម្មលិខិត ល្អ - ឱម ។ភ្ជុមប្រឹក្សាប្រៃរៀបរៀង

(តមក)

១- សីវលិត្ថេរវត្ថុកថា

តតោ ជិនស្ស វចនំ សោតុកាមា មហាជនា
នេវមាណវកន្ទញ្ច ព្រហ្មានោ ច មហិទ្ធិកា
សមណព្រាហ្មណាចាបិ ឆមស្មឹ សុកតញ្ញូលី
ឯមោ តេ បុរិសាជញ្ញ ឯមោ តេ បុរិសុត្តម
ទុក្ខំយេន មហោឃានំ ទិដ្ឋិំ សព្ពាហកប្បិតេ
សោតុកាមា ឥលន្តស្ស ព្យាករោហិមវោមុនិ ។

លំដាប់នោះ មហាជនពាំនឹងឮក្តី ទេវតាមាណពនឹងគន្ធព្វពាំនឹងឮក្តី ព្រាហ្មណ៍ពាំនឹងឮក្តី ដែលមានរិទ្ធិច្រើន មួយទៀតសមណៈទាំងព្រាហ្មណ៍ពាំនឹងឮក្តី ដែលមានប្រាថ្នាចង់ស្តាប់នូវព្រះពុទ្ធដីកានៃព្រះជិនស្រី សឹងធ្វើអញ្ជលីដោយប្រពៃ ក្នុងកិរិយានមស្សការដូចនេះថា : បពិត្រ ព្រះអង្គ ជាបុរសអាជានេយ្យដ៏ប្រសើរ យើងខ្ញុំពាំនឹងឮសូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គជាបុរសដ៏ឧត្តម យើងខ្ញុំពាំនឹងឮសូមនមស្ការ ចំពោះព្រះអង្គ មហាជន ដែលមហាកន្ទ្រើយ៍ជាន់បរិបូតគ

ហើយកំណត់ច្រំពីរថ្ងៃ យើងខ្ញុំច្រំជាថ្នាចដំដឹងនូវផលទាននោះ សូមព្រះមហាមុនីច្រំព្យាករណ៍ផលទាននោះ ដល់យើងខ្ញុំចាំងឱ្យស្តាប់ឥឡូវនេះឯង ។

តតោ អវោច ភគវា សុណាថ មម ភាសិតំ
អបមេយ្យម្ហិ តុទ្ធស្មឹ កុណាម្ហិ សុបតិដ្ឋិតា
ឧក្កំណា នាយកំ បត្វា អប្បមេយ្យដលាវហា
អបិបេសមហាភោគោ ហិតំបត្តេតិមុត្តមំ
លាភំ វិបុលាលាភីនំ យថាកិច្ចសុខសម្បទោ
តថាហំបិ ភវេយ្យន្តិ លច្ឆតេ តំ អនាគតេ

លំដាប់នោះ ព្រះមានព្រះភាគច្រំត្រាស់ថា អ្នកចាំងឱ្យចូរស្តាប់នូវភាសិតរបស់តថាគត (ដូចមានតទៅនេះ) ឧក្កំណាទាន ដែលតាយកបានដំកល់ប្រពៃហើយ ក្នុងព្រះពុទ្ធដ៏មានគុណមិនគប្បីកប់ អាចឱ្យតាយកចាំងឱ្យបាននូវផលានិសង្សច្រើនធំធេបមាពុំបានឡើយ ម្យ៉ាងវិញទៀត ព្រះបរមគ្រូត្រៃយ៍នេះ ច្រំមានភោគច្រើន ប្រសិនបើច្រំថ្នាំនូវទីសាវកដ៏ឧត្តមដូច្នេះថា សូមខ្ញុំព្រះអង្គជាអ្នកមានលាភជាងពួកភិក្ខុអ្នកមានលាភច្រើន ដូចភិក្ខុមានឈ្មោះថា សុខសុន (នេះ) ដោយប្រការយ៉ាងណា សូមខ្ញុំព្រះអង្គបាននូវដំណែងនោះក្នុងកាលជាអនាគត ដោយប្រការដូច្នោះចុះ ។

សតសហស្សេ ឥតោ កប្បេ ទុគ្គតិកុលសម្ភវោ
គោតមោនាម នាមេន សត្ថា លោកេ ភវិស្សតិ
តស្ស ធម្មេសុ ទាយាទោ ទុរសោ ធម្មនិម្មិតោ
សិរិវឌ្ឍនាម នាមេន ហោស្សតិ សត្ថុ សាវកោ

ព្រះបរមគ្រូទ្រង់ព្រះនាមថាគោតមៈ ដោយនាមទ្រង់កើតក្នុងសក្យត្រកូល ក្នុងព្រះវង្សនៃព្រះចាតុរន្តចក្កពត្តិក្នុងសែនកប្ប ពាប់អំពីកប្បនេះសឹងនៅមានប្រាកដក្នុងលោក ឯព្រះបរមក្សត្រិយ៍អង្គនេះកើនឯងបានជាទុរសជាធម្មទាយាទក្នុងធម្មនិម្មិត តាំងជាបុត្រដែលព្រះធម៌តាក់តែងរបស់ព្រះគោតមសម្ពុទ្ធអង្គនោះ មាននាមថាសិរិវឌ្ឍនាមដើម ហើយជាសាវកនៃព្រះបរមសាស្តាចារ្យផងសឹងមានប្រាកដ ។

តេន បុញ្ញកម្មេនេវ ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវតឹស្សបគោ អហំ

ដោយបុញ្ញកម្មនោះផង ដោយការដំកល់ចេតនាតាំងខ្លួយផងលុះខ្ញុំបានលះកង់កាយជារបស់មនុស្សហើយ បានចូលទៅកើតក្នុងភពឈ្មោះតាវតឹង្សទេវលោកនាយ ដោយពិត ។

តត្ថោ អបរស្មឹ សមយេ ពារាណសីបុរុត្តមេ
សេដ្ឋិបុត្តោ អហំ អាសឹ អឌ្ឍប្បត្តោ មហាធនំ
សហស្សមត្តេ បច្ចេក នាយគោបិ ឯមច្ចយឹ

មនុវេន អន្តចានេន សន្តប្បសិំ សចានវរ

លុះសម័យជាខាងក្រោយ ខ្ញុំបានឮគេអំពីស្តេចឈ្មោះតាវតឹង្សនោះ
ហើយ មកកើតជាសេដ្ឋីឈ្មោះតគរណសិ ជាបុរីដ៏ឧត្តម បានដល់នូវ
ភាពជាអ្នកមានទ្រព្យសម្បត្តិច្រើនក្រៃលែង ហើយបានទំមន្តព្រះបច្ចេក-
នាយកតាំងឡាយប្រមាណមួយពាន់អគ្គដែលមានផ្លែដ៏ឆ្ងាកក្នុងកាលតាំងពួន
ឬផ្អែមស្កប់ស្កល់ ដោយបាយទឹងទឹកឆ្ងាញ់ពីសាពន់ពេក ។

តតោ ចុតោ ឯកាមន្តេ អនុភោសឹ មហាយសំ
ទេវបុរេ មហិទ្ធិកោ ចាសាឌេ តេជាមយេ
ឯកនវុតិ៩តោ កប្បេ វិបស្សី លោកនាយកោ
ឧប្បជ្ជិ ចារុទស្សនោ សព្វធម្មវិបស្សកោ

សម័យមួយទៀត ខ្ញុំបានឮគថាកអត្តភាពជារបស់មនុស្សនោះហើយ
បានទៅសោយយសសម្បត្តិយ៉ាងធំចម្បងក្នុងកាមាវចរសួគ៌តាំង ៦ ជាន់
សឹងមានស្រីទេពអប្សរចាមរាមជាបរិវារ ស្ថិតនៅក្នុងប្រាសាទកែវតាំង
ប្រាំពីរប្រការ ជាសុខក្សេមក្សាន្ត គ្រានោះ សម្តេចព្រះលោកនាយក
ព្រះនាមវិបស្សី ទ្រង់បានគ្រាស់ដឹងនូវសម្បត្តិសព្វញ្ញុតញ្ញាណ កើត
ប្រាកដ ក្នុងកប្បកៅសិបមួយពាប់អំពីកន្លះកប្បយើងនេះ ។ ទ្រង់បាន
ពិចារណាឃើញនូវធម៌តាំងពួន ព្រះអង្គបញ្ចេញនូវទេវុណ្ណារស្មីផ្សាយទៅ
ក្នុងលោក ។

តទាហំ ពន្ធុមតិយា កុលសង្ឃាតសេដ្ឋិនោ
ធនញ្ជយោ បត្តិយោ បុត្តោ អាសិំ កម្មន្តចារតោ
តទា អញ្ញតរោ បុត្តោ វិបស្សិស្ស មហេសិនោ
បវិវេណំ អកាសេសិំ មហន្តំ បរិតារិយុំ
និដ្ឋិតេ បិ មហាទានំ ឆទិំ ទជ្ជកសំយុត្តំ
ឧវទន្តិមភុញ្ជេវ វិចិនញ្ច ន អទ្ទសំ
តទា កត្តំ កហោត្វាន ឧវទន្តិមភុម្បិច
កម្មសាមិឃរំគន្ត្វំ តមេសន្តោ មមន្ទសុំ

កាលនោះ ខ្ញុំបានកើតជាបុត្តនៃត្រកូលមានឈ្មោះមន្ទ្រាកដ តែញាតិ
តែងអាណិតរាប់អានជាបុត្តតាមតាទទឹងបិតាបានច្រើនហើយ ជាអ្នកទ្រុស
ខ្លាយក្នុងការងារពុំដែលជាប់ មានបុត្តដទៃទៀតមានឈ្មោះគោត្រកំមិន
ច្រើនដ បានចាត់ជាងឲ្យធ្វើទីបរិវេណ យ៉ាងធំមិនច្រើនដ ថ្វាយដល់
ព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមវិបស្សី ដែលព្រះអង្គស្វែងរកគុណដ៏ប្រសើរ
ក្នុងកាលនោះឯង ។ កាលបើទីបរិវេណបានធ្វើស្រេចហើយ បុត្តនោះ
ក៏ចាត់ចែងឲ្យទូរមហាទានដ៏ប្រកបដោយបរិច្ចាគ ឯមនុស្សទាំងឡាយបាន
ពិនិត្យមើលមានកំឃើញនៅខ្វះទង្គិស្រស់ទង្គិចឃ្មុំស្រស់ពុំមានឡើយ
គ្រានោះ បុរសទាំងឡាយដែលដើរស្វែងរកទង្គិចឃ្មុំនោះ បាន
ឃើញខ្ញុំកាន់ថាសទង្គិស្រស់ទង្គិចឃ្មុំស្រស់ គ្រាប់ពេកាន់ព្រះដំណាក់

នៃព្រះបរមគ្រូត្រៃយ៍ជាម្ចាស់ផែនដី ។

សហាសព្ភមបិ ឧត្តាន ឧលកិ សុចតំ ទូយំ
តតោ ឃរំ វិចិន្តេសិ ឧទិតំហោសុតិំវរកំ
យថា តមេ ជនា សព្វេ សក្ការេន្តិ តថាគតំ
អហំ ការំ ករិស្សាមិ សសំឃេ លោកនាយកេ
តថាហមេវ ចិន្តេត្វា ឧដិមឌុញ្ច ឃកតោ
យោជេត្វា លោកនាថស្ស សសំឃស្ស អថាសិតំ
តេន កម្មេន កតេន ចេតនាបណិធីហិច
ហិត្វាន មានុសំ ឌេហំ តាវតឹសមតច្ឆហំ

បុរសេដ៏ឆ្លាយបានឮប្រាក់មួយពាន់កហាបណៈហើយ ក៏នៅតែពុំបានទូរខៃធនធីតឃ្មុំនោះ ព្រោះខ្ញុំពុំព្រមលក់ឲ្យ លំដាប់នោះខ្ញុំបានគិតពិចារណាយ៉ាងនេះថា: វត្ថុនេះមិនមែនជាវត្ថុហោកខាបទេ ។ បណ្តាជនដ៏ឆ្លាយដ៏អស់នេះ គេបានធ្វើសក្ការបូជាព្រះតថាគតយ៉ាងណា អាត្មាអញនឹងធ្វើសក្ការបូជាសម្តេចព្រះលោកនាយក ព្រមដ៏ព្រះសង្ឃសាវកយ៉ាងនោះដែរ ។ លុះខ្ញុំបានគិតពិចារណាយ៉ាងនេះហើយ ក៏ប្រមូលផ្សំទៃធស្រស់នឹងទឹកឃ្មុំស្រស់ជាមួយគ្នាហើយបានថ្វាយទូរខៃធនធីតឃ្មុំនោះដល់ព្រះលោកនាថ ជាម្ចាស់ព្រមដ៏ព្រះសង្ឃសាវកក្នុងកាលនោះឯង ។ ដោយអំពើដែលខ្ញុំបានធ្វើនោះឯង ដោយសេចក្តី

ប្រាថ្នា ដែលខ្ញុំបានដំកល់ចេតនាតាំងឡាយនោះផង ខ្ញុំក៏បានលះបង់ កងកាយជារបស់នៃមនុស្សហើយ បានអន្ទោលទៅកើតក្នុងស្ថានសួគ៌ ឈ្មោះតាវតឹង្សពិត ។

បុនាហំ ពាកណាសិយំ កជា ហុត្វា មហាយសោ
សត្តតិសត្តតយុទ្ធោ ទ្វាទសវារតោរយី
តទា តមស្សិនោ រុទ្ធោ ឯតាហំ រក្ខិតោ អាហុ
តតោ តស្ស វិចារេន ចាបតិ្ត និរយំ ភុសំ

ខ្ញុំបានកើតជាស្តេចក្នុងនគរពាកណាសីទៀត ហើយមានយសបរិវារ ហើពលច្រើន បានលើកកងទ័ពទៅព័ទ្ធស្តេចសោយរាជ្យក្នុងនគរគូចជាសត្រូវ ហើយចាត់រៀបពលមិនឲ្យបើកចំហទ្វារនគរ មិនឲ្យមនុស្សចេញចូលយកស្បៀងអាហារក្នុងកាលនោះឯង ។

បន្ទាប់ពីនោះមក ខ្ញុំបានក្រោធខឹងនឹងតាបសមួយរូប ហើយបានចាត់មនុស្សឲ្យឃុំឃាំងតាបសនោះអស់មួយថ្ងៃ ដល់ខ្ញុំធ្វើមរណកាលទៅ បានទៅកើតក្នុងនរកសោយទុក្ខដ៏ក្រៀវក្រាលោយវិបាកនៃកម្មនោះឯង ។

បច្ឆិមេ ភវេ ជាតោ តោ ហំ កោសលិយេ បុរេ
សុបប្បាសា ច មេ មាតា មហាលច្ឆី មេ បិតា
ខត្តិយេ រុញ្ជកម្ហេន ទ្វារវេចស្សភាសា
សត្តមាសវសេ ភិសិ មាតុកុច្ឆិម្ហិ ឧក្កិតោ

សត្តាហំ ទ្វារមុទ្ឃាដិំ មហាឧក្កុសមប្បវត្តោ
មាតា មេ ឆន្ទនាទេន ឱវាទាសិ សុទុក្ករំ តា

ដល់មកកន្លែងតាជាទីបំផុតនេះ ខ្ញុំបានមកកើតក្នុងកោលិយបុរី ព្រះមាតារបស់ខ្ញុំមានឈ្មោះថាសុប្បវាសា ព្រះបិតារបស់ខ្ញុំមានឈ្មោះថា មហាលិច្ឆវីដោយពិត ។ ខ្ញុំដល់នូវសេចក្តីទុក្ខលំបាកនៅក្នុងផ្ទៃនៃព្រះមាតាអស់កំណត់ ៧ ខែ ៧ ថ្ងៃ ព្រោះហេតុថាបាបកម្មដែលខ្ញុំបំពេញព្រះនគរដោយបុញ្ញកម្មរបស់ខ្ញុំជាក្សត្រិយ៍ ។ ខ្ញុំវង្វេងនៅក្នុងទ្វារកំណើត ៧ ថ្ងៃ ឆ្អែតដោយសេចក្តីទុក្ខយ៉ាងធំ ឯមាតានៃខ្ញុំទៀត ក៏ដល់នូវសេចក្តីទុក្ខដ៏ក្រៃលែងយ៉ាងនេះ ដោយកិរិយាឲ្យនូវឆន្ទៈ គឺប្រាប់នូវពាក្យបំពេញព្រះតម្រិះដល់ខ្ញុំ ។

(នៅមានត)

(តមក)

លំដាប់នោះ ស្តេចឈ្មោះព្រះចុន្ទវរិទេហកជ ស្តេចទៅឰដ៏លង្ហែក
ចន្ទោះនៃយោជន៍ ១ នោះ តំដល់ស្រុកដែលព្រះមហាសត្វអ្នកវណ្ណាប់ទុក
នៅ ។ រីអស់មនុស្សម្នាមហាជន កាលណាបើបានឃើញព្រះមហាសត្វត្រ
ហើយ សឹងត្រេកអរយកដំរី សេះ រទេះ សឹងទ្រេសមានកម្លាំងមក
ថ្វាយស្តេច ។ ឰដំរី សេះ រទេះណាដែលឋយកម្លាំងអស់ដើង ឲ្យត្រឡប់
មកវិញហើយស្តេចយកអស់ដំរី សេះ រទេះ មានកម្លាំងខាំងនោះ ស្តេច
ឲ្យយកហោង ។ រីស្តេចយាត្រាដោយឆាប់ ។ មានឋម្ងាយផ្លូវនោះអនេក
១០០ យោជន៍ ដោយនៅ១ ថ្ងៃយកលនោះហោង លុះព្រឹកឡើងវិញ ស្តេច
ចូលទៅកន្លងមជ្ឈិមប្រទេសព្រាហ្មណ៍នោះហោង ។ ពោធិសត្វអ្នក
ឈើលាទៅកាន់ទ្វារទុម្មុគ្គ ហើយអ្នកដោះព្រះខ័នស្តាយអំពីអាត្មា ហើយ
អ្នកកាយកប់សុបព្រះខ័ននៅឯខ្សាច់មហាទុម្មុគ្គនោះហោង ។ កាលណា
បើអ្នកទុកដាវនៅនោះហើយ អ្នកចូលទៅដោយទុម្មុគ្គ អ្នកឡើងទៅស្រង់
ទឹកអប់ត្រឡប់គន្ធតំដោរ ស្រេចបរិភោគអាហារដ៏ត្រកាលមានតុជាវស
នោះផ្សេង ។ ហើយអ្នកចូលទៅផ្ទះសម្រាន្តឮដំបន្ទុំប្រសើរ ហើយអ្នកគិត
ថា រ័ចំណង់ចិត្តប្រាថ្នាខ្ញៃអញ ក៏លុះសំរិទ្ធបរិបូណ៌ហើយហ្ន៎ អ្នកគិត
ដូច្នោះហើយ អ្នកផ្ទំទៅហោង ។ លំដាប់នោះ ព្រះចាតុម្មហារាជ
ព្រហ្មទត្តកជ ស្តេចតំណាក់ប់រងប្រុងប្រយ័ត្នឮវាតលត្រប់គ្នា ទំនងសេនា

ទាំង ៨ ដំណក ចូលទៅចោមរោបការនគព្រះគោធិសត្វនោះ លុះអស់
ចំណែកពាក្យនោះហោង ។

តមត្ថំ បការសេដ្ឋោ សត្ថា អាហ អាថ ជមេឯណាពុំ
ពាន់ប្រាក់ជ បពព្រះជាលីឯណាពុំពាន់ចែងប្លាស់ លុះព្រះបានត្រាស់
ហើយ មានព្រះបន្ទូលនឹងកំពូផងនូវបពព្រះគាថាថា : ។

រក្ខិស្សា ភាសិណំ រត្តិំ ចុលនេយ្យោ មហាឥសោ
ឧនេដ្ឋំ អរុណាភិមុំ ឧបការមុទាភមិ
អារុយ្ហ បវរំ ឆាកំ ឥសវន្តំ សដ្ឋិហាយនំ
ភជា អភេទ បញ្ចាលោ ចុលនេយ្យោ មហាឥសោ
សន្ថុតោ មណិចម្មេន សមាធាយ ថាណិធា
មេសិយេ អដ្ឋភាសិត្ថ បុថុកុម្ភេ សមាភតេតំ ។

តិក្ខត្តុំ ម្នាលតំពូផងពាំងឡាយអើយ រីព្រះជាតពុទ្ធនិព្រហ្មតត្ត-
ភជ អាចមានតម្លាំងរហ៍ពលសតលយោធាសេនាផងច្រើន តំាចោមរក្សា
ព្យាបាលនគារនគព្រះមហោសថអ្នកប្រាជ្ញអស់ពាក្យនោះ លុះព្រឹក
អរុណព្រះអាទិត្យនឹងរះឡើង បពាក្យអើយ ព្រះជាតពុទ្ធនិព្រហ្មតត្តជ
មានរហ៍ពលសតលយោធាសេនាផងច្រើន ជាអម្ចាស់នៃអ្នកបញ្ចាល
ពស្ត្រពាំងឡាយ ស្តេចឡើងគង់លើប្រាជ័រព្រះទីនាំងដ៏ប្រកបនូវតម្លាំង
មានតាយុ ៦០ ឆ្នាំហើយទើបឋយកម្លាំងបន្តិច ស្តេចបន្ទូលបង្គាប់នឹង

សេនាអាគ្នាព្រះអង្គថា បពិត្រអើយ ព្រះចាតុច្បន្ទ ស្តេចទ្រង់គ្រឿងប្រដាប់ក្រោះក្រាយផងតាំងឡាយ សឹងតែវាមណីរត្ន ព្រះហស្តស្តេចទ្រង់នូវកង្វេរជ្រះត្ន ស្តេចបន្ទូលទៅកាន់សេនាយោធាដែលឆ្លាប់ដឹងនូវសំណឹកឈ្មោសប្រវៃ នៃសិល្បសាស្ត្រតាំងឡាយ ឲ្យមកជំនុំព្រមឮដឪវនេះហោង ។

ឥទានិ តេ សុវូរតោ ឧសេដ្ឋតុំ អាហ អាចរ្យតាំងឡាយ គប្បីសំដែងអំពីសេនាតាំងនោះដោយសរូបជាបទគាថាថា : ។

ហត្ថារោហា អនីកដ្ឋេ រថិកោ បត្តិការកោ
ឧទាសនម្ហិ កតហត្ថេ ឯលវេធេ សមាគតេតំ ។

នែយដំរី នាយសេះ នាយរេះតាំងឡាយ សេនាថ្មើរជើងនូវកំណាន់ខ្មាន់ការតាំងឡាយ សឹងដឹឈ្មោសបេះសិល្បសាស្ត្របញ្ញាមុតមែនស្ទាត់ត្រង់ក្តាត់ ក៏មកជំនុំព្រមគ្នា ។

ក្យណោះ ព្រះចាតុច្បន្ទព្រហ្មទត្តរាជ ស្តេចបានបង្គាប់សេនាដើម្បីទឹងឲ្យកាន់យកនូវជ័រតែនៃស្តេចវិទេហរាជ ហើយគោលថា ។

មេសេ ត កុញ្ជរេ ឧត្តិ ឥលវន្តេ សដ្ឋិហាយនេ
មច្ចុត្ត កុញ្ជរ ឯករំ វេទេហោ ន សមាបិតំ

។ ល ។

ឥតិសេហិ បុរក្ខតោ ឯត្ថ មោក្ខោ ត តោ តវ

ឧកាវន្តេ ន ឧសប្បមិ យេន តុំ មិនិលំ វាតេតិ ។

តុម្ហ មោះ កវន្តា ម្នាលអ្នកតាំងឡាយដ៏ចំរើនអើយ ចូរអ្នកតាំងឡាយ បវដ៌រំតាំងឡាយចូលទៅ ដ៌រនោះ ដ៏មានក្តុកនោះឆ្ងល ដ៏មានកម្ទាំងនោះច្រើនមានអាយុ ៦០ ឆ្នាំហើយ ទើបថយកម្ទាំងបន្តិច រីឯដ៌រប្រសើរនោះ ចូរញើញាំបុកបែន១បការនតវដែលគេប្រងាប់ប្រពៃ រីយោជាតាហានកម្ទ៉ាះតាំងឡាយ ដ៏កាន់គ្រឿងអាវុធដ៏មានដងនោះពិចិត្រដ៏មានក្បាលនោះតាក់ទូវមួកដ៏ប្រពៃ ដ៏មានដៃកាន់ទូវធសរថ្នាហានក្តាបាប់ចាញ់ទៅទូវកំាសរតាំងឡាយ ដ៏មានមុខថ្ងាសមុតដូចមុខតន្ទាកដ៏ស្រួចឆ្ងើម អាចបាញ់ខំលាយកំពាយឆ្ងើងស្មងដងគាំចិត រីអស់កាំសរតាំងនោះចូរឲ្យជ្រុះចុះដូចទឹកភ្លៀងដ៏បង្អោរចុះមក ។ រីកូនស្តេចឥងតាំងឡាយចូរបន្ទូវដ៌រសរ១ទួមធំអាចប្រទះមុខដ៌រតាំងឡាយ ឬលំពែងតាំងឡាយដ៏មានត់ជ្រះប្រពៃលាបទូវប្រដ៌មានស្មើភ្លឺជ្រះល្អ បីដូចជាយានរ៉ូដ៏មានស្មើឮដកណ្តាលអាកាស រីយោជាសេនាដ៏មានកម្ទាំងខ្លាំង កាន់ទូវគ្រឿងអាវុធតាំងឡាយ សឹងពាក់គ្រោះក្រាយ សំដីកអាយចំអេងដូចគ្រុឌប្រាកដមានសភាពយល់មុខដូច្នេះ ពុំដែលពត់ន្ទត់ទន់ឆ្ងសគ្រាមឡើយ សឹងមានចិត្តខោះមោនមនះនិពន្ធ អាចស្ទុះជាបរាំវនេអញ ពុំដែលថុបថយដល់តិចឡើយ ព្រោះវិរេហាជអើយ គាត់ទន់ឆ្ងរួចទៅឯណាឡើយ ខ្លាចតែគាត់មានស្លាបហើរទៅកណ្តាលអាកាស ដូចសត្វបក្សីនោះ ក៏ទន់ឆ្ងហើរ

ហោះស្មោះទៅកាន់តរមៃចិលានោះបានអេះ ឃោងអញនេះ អញសឹងឲ្យស្រឹតស្រាលរើសសឹងតែពូកែ តាហានក្លាហានបានដឹងចិត្តនោះ មាន ៣ ម៉ឺន ៤ ពាន់ កំណាន់ឃោងតាំងនោះ អញជ្រើសរើសកេងកន្ទុយមួយ។ អញពុំដែលឃលៀងឃោងឯណាក៏ឧន់ស្មើឃោងអញនេះឡើយ ហើយក៏អាចផ្ចាញ់អស់ឃោងតាំងឡាយ តែឯដើរលើផែនដែនេះហោង ដើរសអញតាំងនេះ មានតុកងប្រកបល្អខ្លួកម្ចាំងខ្លាំង អាយុ ៦០ ឆ្នាំហើយទើបថយកម្លាំង នាយដើរតាំងឡាយ សឹងចនវៀរជន្លង់ដ៏ខ្លាប់សំកប់ពាជកុមារ សឹងទ្រង់ត្រឿងប្រដាប់សំពត់ដណ្តប់ខ្លើងដរតដើរតាំងឡាយ ល្អដូចទេវតាទេវបុត្រប្រាកដមានទៅឮដ៏ត្រៃយត្រឹងស្មូតិ ឯពពួកឃោងស្តាយដាវតាំងនោះមានពណិដូចត្រៃថ្មអានខាត់ខ្លូវប្រេងនោយលៀងទេវតាមានជម្ងារនោះកបស្មើ តឹងាងផងតាំងឡាយគ្នើមក គោសរូសប្រពៃឲ្យក្រៀលលេចបាន ៧ ដង ហើយទើបមកគ្គំដងាដាវមួយ។ ដំប្រកបខ្លូវដងមាសដ៏ច្រាសលែងមានស្មើម ល្អប្រពៃព្រោងព្រាយសង្ខោសន្ធៅដូចរស្មីព្រះអាទិត្យនាថ្ងៃត្រង់ តឹឃោងតាំងឡាយដឹមានកម្លាំងខ្លាំងអស្ចារ្យ សត្រូវដងនានាខ្លួបខ្ចាច ករកាន់ដាវនោះហើយ ហូតចេញអំពីស្រោម នោះយលំពណិពាលថ្លាដូចព្រះអង្គ្រនៅប្រកត់ព្ងដ៏ស្រែពប់មេឃក្រាស ឃោងខ្លះសោតមានដៃកាន់ខ្លូវែល កាន់ដាវខ្លូវសេសោស្លូត ស្ទុះខ្លើងទៅឮដ៏កណ្តាលអាកាសបាន ខាន់ដួតាំងឡាយសោត ចេះ

កាន់ជស្ហាត់ដំនាញពេកក្តាត់ អាចបាញ់កំចាត់ស្ទាប់មនុស្សគាំងឡាយ
ដែលដំរលើកស្បាលដើរដំរុះឲ្យជ្រុះចុន ។ ឯតាទិសា ហិ ទិដ្ឋិលា
វេតិ អម្ភោ វេនេហ ។ វេនេហ ម្នាលព្រះវិទេហរាជដើយ
តើយោងជាអញគាំងនេះសឹងមានថ្ងៃដំខឿចំណេះប្រាកដដូច្នេះ មកចោម
ព័ទ្ធព័ទ្ធជុំវិញ តើព្រះស្តេចនឹងរួចទៅនោះឥតអង្គុីមានឡើយ ហើយ
ព្រះស្តេចនឹងទៅកាន់ទីឋានគរដោយអាទុកាតស្តេចឯណា កំអញមិន
យល់ទូវអាទុកាតស្តេចនោះសោះ តើព្រះស្តេចនឹងរត់ទៅឯណាបាន ឡើយ
បពិត្រអើយ រីព្រះបាទបុឡនីព្រហ្មទត្តរាជ ស្តេចទ្រង់នូវកង្វេតជ្រែត្ត
មហាក្សត្រទោកបដើរព្រះទីនាំង ចូលមក នឹងតំរាមព្រះបាទវិទេហរាជ
ដូច្នេះថា ឥឡូវនេះ អញនឹងចាប់យកព្រះបាទវិទេហរាជ ឲ្យសុះនូវក្តីយ
ជីវិត ស្តេចបង្គាប់អស់សេនាគាំងឡាយថា ម្នាលគ្នាយើងគាំងឡាយ
ចាប់យកព្រះបាទវិទេហរាជនូវមេហោសថ បុត្រគហបតីបានមកហើយ
ចូរយកដីងមកពុះទំលុះទម្លាយកំចាយទ្រូង ចូរចាក់កាប់សម្លាប់ កុំបីឲ្យរួច
ឡើយ ព្រះបាទបុឡនីចូលទៅកាន់ទីមកានគរ ត្រានោះហាក់ដូចនឹង
សង្កត់ចំហោង ។ លំដាប់នោះ ទេវនិវិត្តបុរសធនគាំងឡាយ យកបុរស
ដែលបំរើគាត្មាដោយគតិតថា អ្នកឯណានឹងគាចដឹងជាម្តេច អ្ងើរហើយ
សឹងនាំគ្នាចូលមកស្តាប់ព្រះបន្ទូលនៃព្រះបាទបុឡនី ហើយកំចូលទៅ
ចោមរោមជាបរិវារនោះហោង ។ តស្មឹ ខណេ ពោធិសត្តោ

សិរីសយនា វុដ្ឋាយ ។ ក្សត្រិណោះ តោធសត្វមហាបុរសត្ត
វិសេស ដោះឡើងអំពីលែ្វងមានសិរីសួស្តី មកស្រង់ជំរះព្រះអង្គ ហើយ
អ្នកចរិកោតកោដនាហារត្រកាល មានទុជារសពិសាអំពីព្រឹក ហើយអ្នក
ទ្រង់នូវគ្រឿងប្រដាប់ដ៏ពួង ស្មៀកសំពត់កាលិកពស្ត្រ មានតម្លៃមួយ
សែនតម្លឹង ហើយយកសំពត់ភ្លុកមកស្ពាយឆៀងស្មាខាងបណ្តាយ
ហើយអ្នកកាន់ផ្តិតដ៏មានដងដ៏ពិចិត្រត្នៃដ៏ ៧ ប្រការ ហើយពាក់នូវសុ-
ពណ៌ិបាទុក អ្នកយកស្រិពីរនាក់ល្អដូចស្រីសួគ៌ មកឱ្យត្រាំសបក់ផាត់
ស្រេចហើយ អ្នកបើកបង្ហួចប្រាសាទន៏ដ៏បង្ហាញអាត្មា ឱ្យឈប់ចំពោះ
ព្រះភក្ត្រព្រះបាទបុទ្ធ៏ អ្នកដើរទៅវិញទៅមក សក្តទេវរាជលីលា
មានដំណើរលំអដូចសម្តេចឥន្ទ្រាធិរាជលីលាខាហានសួគ៌ មុខតួរពិតពិល
រមិលមើល ។ ឯព្រះបាទបុទ្ធ៏ត្រហ្មទត្តរាជ ស្តេចទតយល់លំអស្រីសួស្តី
នៃពោធិសត្វនោះ តុំអាចដើម្បីទំនឹងមានព្រះទ័យត្រេកអរសាទរទំនឹងពោធិ
សត្វនោះដល់តិចឡើយ ហើយបរដំរីព្រះទីទាំងដោយទ្រង់ត្រអាលចូលមក
ដោយគិតថា អញទំនឹងចាប់យកព្រះមហោសថឥឡូវនេះឯង ។ ព្រះ
មហោសថអ្នកប្រាជ្ញគិតថា ព្រះបាទបុទ្ធ៏ម៏ម៉ាចូលមកនេះ ដោយ
ទុកព្រះទ័យថា ព្រះបាទវិទេហរាជសមបានអញហោង ស្តេចមិនជ្រាប
សភាពជាអញឱ្យចាប់យកអស់បុត្រកិរិយាទេហ្ន៎ ថាបើដូច្នោះ អញទំនឹង
បង្ហាញអាត្មា ឱ្យស្តេចយល់មុខអញល្អដូចពពិលមាស ហើយអញទំនឹង

សំដែងប្រាប់ស្រដីមួយអន្ទេនឯងស្តេចនេះ ។ បពិត្រអើយ ព្រះមហាសេដ្ឋ
អ្នកបិតខេមាដ៏ហានស័ទាបភ្លាបវែរបង្ខិច ហើយអ្នកបើកព្រះសូរមធូរមូល
ក្រទតែកេះស្មោះជាដម្បូងភៅកាន់ស្តេចនេះថា ។

កិំ បុ សន្តរមានោវ ជាកំ បេសេសិ តុញ្ជុំ
បហដ្ឋរូបោ អាតមសិ លទ្ធន្តោស្មីតិ មញ្ញសិ
ឯមវេតំ ឆឌុបាទិំ ខុរបរ្យំ បដិសំហរ
ឯមវេតំ សុកំ ឥច្ចិ វេឌូរិយមណិសន្និភន្តិ ។

មហារាជ បពិត្រព្រះភូមិន្ទនរិន្ទនរោជព្រះបាទនរបតិស្រីសម្ភតិ-
ខេតមហារាជកត្តុត្រៃលោកប្រសើរអើយ ម្តេចឡើយកំស្តេចត្រអាលម្ល៉ឺម្ចាស់
ប្រញាប់បន្ទូលថ្លាដ៏ព្រះទីនាំងប្រសើរ បហដ្ឋរូបោ សមព្រះអង្គទ្រង់
ព្រះអំណរសោទរទុកព្រះពជហឫទ័យថ្លៃថ្លាស្មោះស្មានសន្ធឹងថា នឹង
បានដូចភ្នានព្រះចំណង់ប្រាថ្នាលុះដល់បរិបូណ៌ ទើបស្តេចលីលាចូលមក
ដូច្នោះ ចូរមហារាជឱ្យតម្រោះឆ្នូរជាំមានចង្កួយទ្រនួយល្អ ។ ក្រែងរាមិន
អាចនឹងកោងកុះអាក្រក់ ព្រះអង្គឱ្យភ្ញាន់តម្ងើងកាន់ប្រចងប្រាងមកនោះ តើឱ្យ
ជាញ់នរណា នាគាំទ្រាបស្ទាបពុងផ្ងងស្ងួយគប្រកបំពង់ក មហារាជអើយ
នាជាវព្រះអង្គឱ្យហូតត្រៃថ្លៃដ៏ពន្ធឹកមកនោះ តើព្រះអង្គនឹងឱ្យគាប់នរណា
ឯដែកនោះសោត គិតឱ្យជាងកោសរួសឱ្យក្រៀលរាលេបស៊ី ៧ ជង់ទើប
យកមកផ្គុំដំជាជាវគេនប៉ែនកង់ផ្ងងយង់ល្អ ព្រះអង្គឱ្យប្រកស្រោមពុក

ស្តាយខ្លាចវាស្ទឹមអាក្រក់ បពិត្រក្សត្រថ្លៃប្រសើរអើយ រ៉ាសេលោនោះ ព្រះអង្គឲ្យជាងធ្វើនឹងសែ្បកចំឡែកមហិមាបានដោយទូវពិទូរតន៍ប្រពៃ ព្រះអង្គឲ្យកាន់សម្ងួចស្ងួចមកថ្វាយ ឥតការស្តាយវានឹងថាស់ អាក្រក់ ព្រះអង្គឲ្យរុំខ្ទុកវា មហាវាជអើយ ព្រះអង្គឲ្យយកគ្រឿងអាវុធទាំងពួងមកសែ្អកនោះ នឹងមានប្រយោជន៍អ្វីដល់ព្រះអង្គឡើយ វាជាអសារឥតការទេ ព្រះមហាសថអ្នកដំបូនលេងជាល្បែងមួយសារឮទៀតថា ព្រះមហាវាជ ព្រះអង្គតង់ថ្លៃនៅនេះហ៎ះ? ខ្ញុំចង់អញ្ជើញព្រះអង្គស្តេចលីលាត្រឡប់ចូលទៅកុង ព្រះនគរព្រះអង្គបន្ទិចមើលហ៎ះ ឲ្យប្រណីព្រះអង្គចង់នឹងព្រួយនឿយព្រះរាជហឫទ័យ កលម្តេចឥឡូវអើយ ។

សោ តស្ស វចនំ សុត្វា អយំ មហាបតិបុត្តោ មយា សទ្ធឹ កោធ្បឹ ករោតិ អជ្ជ តេ ភគ្គំ ជានិស្សតីតិ តំ តជ្ជេន្តោ អាហ

ព្រះចាតុបុរិន្ទមហាក្សត្រស្តាប់ពាក្យមហាសថអ្នកប្រាជ្ញទូលទៅថាល្បែងដូច្នោះហើយ ស្តេចគិតក្នុងព្រះរាជហឫទ័យថា មហាសថបុត្តគហបតីនេះ ម្តេចក៏មកស្រដីធ្វើជាល្បែងមកកាន់អញដូច្នេះនេះហ៎ះ ឥតធ្វើហាក់ដូចជាមិនដឹងខ្លួននោះសោះ ក៏អញនឹងធ្វើទុក្ខភាពវាឲ្យនេះឯង ទើបស្តេចត្រាមព្រះមហាសថ ហើយពោលទូវបទគាថានេះថា ។

បសន្ទមុខវណ្ណោសិ បិហិតបុព្វញ្ច កាសតិ

ហោតិ ខោ មរណកាលេ ឆឌ្ឍិតសី វណ្ណោ សម្ប្បជាតំ
ហៃថៅមហោសថអើយ ថៅមានរស្មីមកនោះរុងរឿងស្រឡះថ្ងាល្អ
ដូចអ្នកយកតពីលមាសគិតអ្នកទាត់ប្រពៃយល់ញញឹមប្រឹមប្រើយ៍ ស្រដី
គួរស្រឡាញ់ បទធម្មតាថៅនឹងស្លាប់ហើយកាយល់សរឿរ មានមុខ
សម្បុរនោះល្អច្នេះឯង អញនឹងលែងអង្គាល់ឡើយ អញនឹងកាត់យក
ក្បាលថៅដំកល់អង្គុយមើលមុខជាល្អនោះហើយ កំដរស្រាជ័យបានតំ-
សាន្តចិត្តអញបានះហាន ។

កាលព្រះមហាសត្វស្រដីដំបូងនឹងព្រះបាទពុទ្ធទ័នោះ អស់ពួក
សកលយោធាផង យល់ព្រះកន្ត្រតោធសត្វស្រស់ល្អនៅទាបង្អួចនោះថា
ទ្រមហោសថអ្នកប្រាជ្ញអើយ ល្អអ្វីអម្បាយ កំមហាក្សត្រអម្ចាស់យើង
បន្ទូលអ្វីនឹងព្រះមហោសថ ចូរអ្នកកល់គ្នាទៅឲ្យទៀបនឹងស្តាប់តាក្យអ្នក
ចាំងពីរស្រដីថាអ្វី ទើបបបួលគ្នាចូលមូលមកចង្អុំនៅទៀបមហាក្សត្រ ។
តាជិនមេវ ជាតាតំ ។ ព្រះមហោសថអ្នកប្រាជ្ញស្តាប់ព្រះបន្ទូលព្រះ
បាទពុទ្ធទ័នោះហើយ អ្នកគិតថា មហាក្សត្រនេះមិនដឹងប្រាជ្ញាព្រះមហោ-
សថទេហ្ន៎ អញអ្វីទៅឲ្យសម្ងាប់បានដូចចំណងព្រះពជហប្ញទ័យនោះ អ្នក
គិតដូច្នោះហើយ អ្នកទូលមហាក្សត្រថា បពិត្រមហាពជអើយ ព្រះអង្គ
ស្តាប់តាក្យខ្ញុំណា ឯតំនិតព្រះអង្គគិតនោះ ភវែបតអស់ហើយ បពិត្រ
មហាពជអើយ នាព្រះតំនិតព្រះអង្គគិតនោះក្តី អាចារ្យគេវដ្តព្រាហ្មណ៍

គិតនោះក្តី តែដង្កើមចេញពីព្រះឧស្ន ព្រះអង្គគិតស្មានថាខ្ញុំមិនដឹង ខ្ញុំដឹង
ព្រះគំនិត ព្រះអង្គនោះទើងបានជាអ្នកឡើយ ក៏បែកអស់ហើយ ទំ
បកាសេ ឆ្នោ សត្តា អាហា កិក្កវេ ហៃតិក្ខុងងំតាំងឡាយ
អើយ កាលព្រះមហាសត្វអ្នកប្រាជ្ញទូលព្រះបាទបុណ្យទីថា បពិត្រ
មហាពាជអើយ នាគាក្សកំពុងព្រះអង្គ ទើងអាចារ្យគេវាដ្ឋព្រាហ្មណ៍
ចូលទៅក្នុងក្រឡាបខ្ញុំសុខុមពាំងពីរនាក់ហើយ តែងរិះគិតថាទើងយក
សម្តេចព្រះពាជបុត្រីហ្លួងព្រះបាទវិទេហាពាជឲ្យបានដូចគ្នាទគំនិត ហើយ
ទើងកាត់ករយកក្បាលព្រះបាទវិទេហាពាជ ហើយទើងកាត់យកក្បាលខ្ញុំ
ងង ប៉ងអង្គុយលើកងីកស្រាជ័យបាន ឯដំរិះគិតក្តី ចំណង់ប្រាថ្នាព្រះអង្គ
នោះក្តី ក៏មិនលុះសោះសូន្យទេ ព្រះគំនិតព្រះអង្គនោះ កិច្ច ក៏បែកអសារ
ទទេហើយ បពិត្រមហាពាជអើយ នាព្រះអង្គទើងយកព្រះបាទវិទេហាពាជ
អម្ចាស់ខ្ញុំនោះកាត់ករទើងបានទេណា បពិត្របាទវិទេហាពាជអ្នកដំរលើ
ប្រាជ្ញាគំនិត ព្រះមហាសត្វស្មើអ្នកគង់លើខ្នងសេះអាជានេយ្យ មានកម្លាំង
ខ្លាំងស្មើខ្យល់ ហោះផ្លោះកណ្តាលអាកាស តើព្រះអង្គគង់លើប្រាជ្ញា
គំនិតបានទេ គំនិតប្រាជ្ញាអាចារ្យគេវាដ្ឋព្រាហ្មណ៍ដូចសេះខ្លាក់ ចចក
ចាស់ដើរផ្លោះ ។ កណ្តាលដី តើព្រះអង្គទើងតាមទាន់ព្រះបាទវិទេហាពាជ
ទេហៈ ។

តិណ្ណោ ហិ យ្យោ កជា កង្ខំ សាមុទ្ទោ សបរិដ្ឋនោ

ហំសកនំ យេថា ឧន្លោ អនុផរំ បតិសន្ថតីតិ ។

បពិត្រមហាឧបាសក ព្រះបាទវិទេហរាជនៅអាមាត្យសេនាបតី ពលសេនាយោធាជន ស្តេចចម្ងល់ស្ងើចគង្វាលស្ទាគ្រាម លើហាដល់ត្រើយនាយមួលមិញ្ញាហើយ ថាបើព្រះអង្គនឹងតាមព្រះបាទវិទេហរាជអម្ចាស់ខ្ញុំ មហារាជសមព្រះអង្គនឹងបានដល់នូវអន្តរាយកណ្តាលផ្លូវតែម្តង បពិត្រព្រះអង្គគង់លើប្រាជ្ញាអាចារ្យកវីវដ្តព្រាហ្មណ៍ ដូចកលអ្នកជិះលើក្អែកចាស់ ព្រះបាទវិទេហរាជជិះលើប្រាជ្ញាខ្ញុំ ដូចរាជហង្សមាស គឺមានកម្លាំងធាប់ស្មើឬស់ ហើរមានកណ្តាលអាកាស កម្លាំងក្អែកចាស់ ក៏ហើរទៅតាមម្តេចមានបាន នឹងភ្លាក់មកមានកណ្តាលដើ អន្តរាយប្រាកដមិនលែងឡើយ ។

គោធិសភូអ្នកនាំទូតហារណ៍មកទៀត ទូលព្រះបាទបុឡឱនូវពាក្យសីហទាឋគតាតដូចកេសរាជសីហ៍ ពុំភ្លឹកម្រឹតចាំងភ្លាយ ហើយពោលនូវបទគាថាដូច្នេះ ។

សិង្គាលោ រត្តិការេ ជុលិំ ឧស្សាន កាសុកំ
មំសបេសីតិ មញ្ញន្តោ បរិព្យុឡ្ហោ មិគាធមោ
វិតិវត្តាសុ រត្តីសុ ឧក្កន្តស្មិំ ឧបក្កមេ
កាសុកំ ជុលិំតំ ឧស្សា អាសាឯំ្ញ មិគាធមោ
ឱរមេវ តុវំ ភទ្ទ វេឧមាំ បរិភាវយ

អាសាជំន្ធោ តម័ស្សរសិ សិង្គាលា តាំសុកំ យថាតំ។

បពិត្រមហាពរាជអើយ នាព្រះអង្គមកចាមចាប់ព្រះចុទ្ធវិនេហពរាជអម្ចាស់ទ្បីនេះ ទើបបានអង្គាល់ខ្លួយ ពាទើងអសារវតតការនេណាមហាពរាជបពិត្រមហាពរាជអើយ ព្រះអង្គនេះដូចចចកឯង កាលណាបើព្រះអាចារ្យអស្តង្គតហើយ ព្រះចន្ទូជុសខ្លួង មានពន្ធូវែងត្រចះជ្រះកណ្តាលថ្ងាយពណ្តាកយស្អ ឃកគ្នាបណ្តើរហែរទៅយល់ផ្កាចារអម្ចាលទ្រយាន។ ទុកចិត្តស្មានថាជាដៀតសាច់គោហាលក៏អរមហិមា បបួលគ្នាមកចាមចាំដុំវិញដើមចារ ខន្ធើងថាជលំណាកខើងរុះចុះមកខើងអាលយកធើ លុះព្រឹកព្រហាម ព្រះអាចារ្យទ្រង់យខ្លួង ឯចចកបបួលគ្នាឈរមើលរហាំរហមខ្លួង ឃលំតែផ្កាចារច្រាលស្ងាចទេ រឹងក្តីច្រាថ្នាខោះ ពាពុំសម្រេចធុញជាច់អាល័យហើយនៃ កំបបួលគ្នាដើរហែរចេញទៅអសារវតតការនេណាកំចចកចចើងចាំបរិភោគអសារម្តចមិញ មហាពរាជអើយ នាព្រះអង្គចចើងចាំរចាមព្រះចុទ្ធវិនេហពរាជអស់កំឡុងពត្រីនេះ លុះតែព្រឹកខ្លួងក៏ព្រះអង្គមិនបានព្រះចុទ្ធវិនេហពរាជខ្លួយ ដូចព្រះតំនិតខោះហើយអសារវតតការនេដូច្នោះរហាង ។

ពជា តស្ស តំ អច្ចយ្ហីតវចនំ សុត្វា ចិន្តេសិ

ព្រះចុទ្ធបុត្តិ ស្តាប់ ពាក្យតោងសត្វស្រដីសីហានាវតភ្លឹកភ្លាំកតតក្នុងព្រះទ័យថា មហាសច្ចបុគ្គលហាចតិនេះ រុកពនហានស្រដីណាស់

ក្តាត់ហៈ នាដោយមហោសថស្រដីនេះ សមព្រះបាទវិទេហរាជតែជ្រាប-
កដមិនខេឡើយ មហាក្សត្រតិតដូច្នោះហើយ កំភ្លាល់ទឹងព្រះមហោសថ
មហិមាក្រៃពេក ក៏រិះគិតយល់ទៅស្រព្រះពោធិសត្វថា នាមហោសថនេះ
តែជនឹងទឹងអញហើយ កាលមុនតាយឡើយនោះ អញទៅចោម
មិបិលានតរប៉ុនច័ងបំណងជ្រាបថ្នាទឹងចាប់ព្រះបាទវិទេហរាជហើយអេះ
ស្រាប់តែវាមកបង្ហើលឲ្យផ្ទើលអស់តលសកលយោធាពាន់ ១៨ អក្ខោតិនី
ខ្លះស្តេច ១០១ ឲ្យតិតភ័យតេ សំពត់មិនបិតទៅចង្កេះ សេះ ដំរី គ្រឿង
សាវុធភ្លាត់ភ្លាយចោលបង់មៀត ឥឡូវនេះសត្រូវមកលុះកណ្តាប់ដៃអញ
ហើយ កំពប់ដាយឲ្យតែរួចទៅនោះហោង ។ អនត្ថការសោ ។ វាធ្វើ
ឲ្យបង់ប្រយោជន៍អញច្រើន នាអញគិតកន្ត័ចិត្ត អញនឹងសម្លាប់ព្រះបាទវិ-
ទេហរាជហើយនិងមហោសថផង រំសេចក្តីបំណងជ្រាបថ្នាទៃព្រះបាទវិទេ-
ហរាជនោះវាបានសម្រេចហើយ ឥឡូវទៅតែមហោសថ អញអើយទៅ
ទុកឲ្យវាមានជីវិតរស់ទៅក្តី អញធ្វើទុក្ខឲ្យល្អិតបង់មៀតទៅ ទើបមហា-
ក្សត្រចង្អាំចទៅសេនាឲ្យសម្លាប់ព្រះមហោសថដោយនូវបទគាថាថា ។

ឥមស្ស ហត្ថាទេ ច កណ្ណានាសញ្ច ឆិន្ទថ
យោ មេ អមិត្តំ ហត្ថគតំ វេទេហំ បរិមោចយិ

។ ល ។

ឯវន្តំ វិតុទិត្វាន វេទយិ សព្ពមិ សត្តិយោ

យោ មេ អមិត្តំ ជាតុកតំ វេធេហិ បរិមោចយីតិ។

ម្នាលសេនាតំាងឆ្កាយអើយ លោកដែលដូចមហោសថហ៊ុំ នា
ព្រះចាតវិទេហកជាសត្រូវនឹងអញនេះ ចូរមកលុះតណ្ហាច់ដៃអញ
ហើយ ស៊ីវាំងនាយឆ្មៃតន់រួចចេញទៅវិញ តើតប្បីចូរអ្នកតាំងឆ្កាយតើច
កមហោសថបុត្តគហបតី យកមកកាត់ដៃតាំងសងខាង ចិតស្ទឹកត្រចៀក
ទឹងច្រមុះ ពុះច្រែង ដាំតឹកក្តៅទឹងខ្លះ បន្ទុះសាច់ស្ងោរឡើងកេលដូចសាច់
ម្រិត ចូរសំរុះចឈើអណ្តាត។ ឡើងដែលមានសត្រូវចូលមកលុះតណ្តាច់
ដៃនៃអញហើយឲ្យរួចទៅវិញ ម្នាលសេនាតំាងឆ្កាយ ចូរអ្នកចាប់មហោ
សថនោះមកសង្កត់ក កាត់យកក្បាលលាត់សែ្បកមកស្ងោរតណ្តាលដី
សន្ធឹងតឹងឲ្យណាស់ ដូចគេស្ងោរសែ្បកគោតាំងឆ្កាយ យកលំពែងធំ។
ចាក់ច្រំលំអតឲ្យស្លុតបង់មែ្យតទៅ ព្រះចាតវិទេហកនេះ ជាសត្រូវ
អញលួងមកលុះតណ្តាច់ដៃហើយ វាឲ្យដំណើរសត្រូវតន់រួចទៅហ៊ុំ។

ព្រះមហោសថអ្នកស្តាប់ព្រះបន្ទូលព្រះចាតុឡនីហើយ អ្នកពុំភ្លឹក
ភ្លាំងតិតខ្លាចដល់តិចឡើយ អ្នកទ្រង់ព្រះសំណើចក្អែក។ ទើបអ្នកទ្រង់
ព្រះតិចាវណាថា នាមហាក្សត្រនេះជ្រាបថសភាពតែព្រះចាតវិទេហកដ
រួចទៅមិបំណានតរមិនដឹងដើមអញឲ្យដំណើរអស់ព្រះរាជបុត្រីបុត្រា នូវព្រះ
រាជទេពី ព្រះមាតាទៅជាមួយនឹងព្រះចាតវិទេហកជអម្ចាស់អញចេញ
ទៅដល់មិថិលានតរនោះឡើយ ទើបមហាក្សត្រឲ្យលំគុំឲ្យសម្ងាច់អញ

យល់មហាក្សត្រឮល់ទឹងអញមហ៊ាមា មិនខេខ្លៃយ លើកទ័ពអស់ស្តេច ១០១ នូវពល ១៨ អក្ខោកិនីចំលាយចូលមកយកអញបាន ដោយនូវព្រះ ភជាជាមហាក្សត្រនោះឯង កំឥឡូវនេះ បន្ទាយអញតូចមានពលសេនា តិច ទឹងផ្តាំញ៉ាំមហាក្សត្រនោះពុំបាន នាអញទឹងផ្តាំញ៉ាំមហាក្សត្រនេះ ដោយនូវកម្លាំងសាហាវសោះសាពុំបានខ្លៃយ អញផ្តាំញ៉ាំតែទឹងប្រាជ្ញា ចារើ។ ចាយកលវិញាទើបបាន កំអញទឹងរំរេកនូវ។ ចាយកលម្តេចអេះ ព្រះមហាសថអ្នកថប៉ះទៅច្នោះកូវ ហេតុតែព្រះចារើព្រះអង្គបានសាងនោះបរិបូណ៌ ទឹងបានជាតុទ្ធឆ្លុះបណ្តាលប្រាជ្ញាសារពេជ្ឈញាណ អ្នករំរេកទៅដូច្នោះហើយកូវ ប្រាជ្ញាចារើមកបំភ្លឺយល់ប្រុះសុសសារតើ ។ ចាយកលទឹងផ្តាំញ៉ាំមហាក្សត្រនេះបានខៀងប្រាកដ ទើបអ្នកគិតថា អញអ្វីទៅឲ្យសម្លាប់បានដូច្នោះ មិនដឹងប្រាជ្ញាអញមហាសថ អញ ទឹងចោទ។ ចាយកលមួយដោយប្រាជ្ញាចារើអញ ឲ្យជ្រាបក្នុងព្រះហឫ-ទ័យមហាក្សត្រ ឲ្យទន់ចិនលំនោនទៅវិញ ហើយអញទឹងធ្វើឲ្យមហា-ក្សត្រនេះ លុះទៅដម្បីវែនាជាខ្ញុំក្នុងសោកនោះមហិមាសន្ធប់ក្រាបទៅ

(នៅមានត)

អក្សរសាស្ត្រខ្មែរ	ខ្មែរគួរចែកផ្លូវ
ឲ្យបានខ្ជាប់ខ្ជួន	តង់រង្គៀតត់មក
ព្រោះអក្សរជាតិ	គោលជាតិប្រាកដ
អក្សរលត់	ជាតិក៏រលាយ

ប. ព.

(វិចារណាកថា)

កិត្តិយសនឹងសុភមង្គល

លោក ផេង-ជ្រៀវ រៀបរៀង

ភាពវុឌ្ឍរឿង ភាពល្បីឮខ្ទរខ្ទារ ដោយសារស្នាដៃប្រកបដោយអត្ថប្រយោជន៍សាធារណៈនៃខ្លួនហៅថា « កិត្តិយស » ជាភាពដែលមនុស្សត្រូវការយ៉ាងខ្លាំងពន់ពេក ។ ប៉ុន្តែកិត្តិយសមានប្រយោជន៍ក្នុងលោក សម្រាប់មនុស្សប៉ុនេះ? តាមការពិចារណា កិត្តិយសមិនប្លែកគ្នាពីសេចក្តីសុខឡើយ សេចក្តីសុខមានខ្លាក្នុងលោកតាសតេញ ស្រេចនឹងអ្នកត្រូវការរំប្រឹងស្វែងរកប្រមូលមកចុះ បើខ្លួនចេះរកបាន ។

ដូចជនណាម្នាក់តើតជ្រះថ្លាយល់ត្រូវ ចំណាយទ្រព្យផ្គាល់ខ្លួនកសាងសាលារៀនសាធារណៈ ឬកសាងមន្ទីរពេទ្យជាប្រយោជន៍សា-

ជាណោះជាអាទិ ជនខ្លះមានកិត្តិយសជាប្រាកដ អ្នកផងតែងគោរពសរសើរទឹងមានការពប់រកទឹងពប់អាន ។ អ្នកខ្លះបានទទួលឋានៈជាមន្ត្រីអ្វីមួយក្នុងកិច្ចការពេជការ ក៏មានឈ្មោះថាអ្នកមានកិត្តិយសដែរ ។ល។

សម្តេចព្រះនរោត្តមសីហនុ ទ្រង់យុវរាជ ព្រះប្រមុខរដ្ឋប្រទេសកម្ពុជា ព្រះអង្គទ្រង់ចារឹបូរណ៌ដោយកិត្តិយសដ៏លើសលប់ ព្រោះព្រះអង្គបានទ្រង់ស៊ូប្តូរព្រះជន្ម ដើម្បីតាមការយកឯករាជ្យរបស់ជាតិ មកជូនមាតុភូមិទឹងជាតិខ្មែរ យើញថាអំពើរបស់ព្រះអង្គនេះជាមហាកម្មដ៏អស្ចារ្យ ដែលទឹងរកឥស្សរជនខ្មែរណាមកប្រៀបផ្ទឹមទឹងព្រះអង្គពុំបាន មិនតែប៉ុណ្ណោះ ព្រះអង្គទ្រង់ជាស៊ុម៉ង្គសម្រាប់ផ្សារប្រជាជាតិខ្មែរ ដែលមានការប្រែធាតុទឹងពេលមុនរវាងគ្នាទឹងគ្នាខ្លះនោះ ឲ្យមានការរួមគ្នា ស្រុះស្រួលទឹងគ្នាឡើងវិញ ហើយព្រះអង្គទ្រង់ជាព្រះអគ្គមគ្គុទ្ទេសក៏ឆ្នើមត្រូវសំយ៉ាងអស់ផង ដើម្បីធ្វើឲ្យជនជាតិខ្មែរមានសន្តិសុខទឹងសន្តិភាព ដែលជាប្រភពនៃសេចក្តីថ្កុំថ្កើងរុងរឿងនៃប្រទេស ។ល។

សួរថា : ត្រូវតែមនុស្ស សុទ្ធសឹងមានកិត្តិយសឬយ៉ាងណា? -កិត្តិយសជាលទ្ធផលឬជាអាទិសង្ឃ នៃអំពើប្រកបដោយសាធារណប្រយោជន៍ ។ ដូច្នេះ មនុស្សខ្លះខន់ខ្លាយពេក ដែលមិនអាចទឹងធ្វើខ្លួរអំពើជាសាធារណប្រយោជន៍បាន ក៏គ្មានកិត្តិយសទេ មនុស្សនេះរស់នៅត្រាន់តែរកស៊ីដើម្បីជីវិតខ្លួនប៉ុណ្ណោះ ក៏ប៉ុន្តែ បើជាគេយល់ការណ៍

ប្បាស់ គេអាចរកកិត្តិយសរួមបានដែរ តាំងគេប្រមូលកំឡាំងតូច។ ដែលខ្លួនមាន យកមកធ្វើជាមហាកម្មអ្វីមួយជាសាធារណប្រយោជន៍ គំនិតមែបនេះអាចបណ្តុះកិត្តិយសសម្រាប់ខ្លួនបាន ។ ដូច្នេះ បានជាបច្ចុប្បន្នសម័យសម័យសង្គម ឃើញមានមន្ទីរពេទ្យនឹងសាលារៀនផុសដូចផ្សិត ខៅគ្រប់ភូមិស្រុក ដែលផ្តល់កិត្តិយសដល់អ្នកភូមិស្រុកនោះ។ គ្រប់គ្នា ។

ស្តីថា កិត្តិយសដែលគេខុកជាវត្តជាទីប្រសើរ ហើយដែលមនុស្សក្រវៃការចង់បានស្តីរគ្រប់ប្រាណ សុខសឹងបរិសុទ្ធល្អទាំងអស់ ឬក៏មានការខ្សែខ្វះដែរ? តាមសេចក្តីសង្កេតនិងការពិចារណា ឃើញថាកិត្តិយសមិនមែនសុខតែបរិសុទ្ធទេ មានកិត្តិយសការខ្សែដែរ ។

ក្នុងករណីយ៉ាងណាដែលកិត្តិយសជាវត្តការខ្សែ? ក្នុងករណីដែលសាម័ខ្លួនមិនអាចបំពេញអំពើអ្វីមួយជាសាធារណប្រយោជន៍បាន ហើយខៅលួចបន្ទុំយកស្នាដៃអ្នកដទៃមកជាក់ថាជារបស់ខ្លួន ដោយអាងតែខ្លួនមានសក្តិធំជាង ឬដោយសារតែសាម័ខ្លួនមិនមានសមត្ថភាពនឹងបញ្ចេញស្នាដៃខោះឲ្យលេចខ្លឹង រួចខ្លួនបន្ទុំលួចមកបញ្ចេញថុកជាក់ថាជារបស់ខ្លួន ។ មានកិត្តិយសម្យ៉ាង ហៅថាកិត្តិយសដុនជាប ។ ស្តីថាកិត្តិយសនេះដូចម្តេច? កិត្តិយសនេះបានតើតខ្លឹង ដោយអំណាចការពោលបង្ហាប់គេថ្នក់ដោយសារគ្រោះតែចង់បានពេក ខៅសុំគេត្រង់។ តែម្តង ខោះបើបានដឹងប្បាស់ថាខ្លួនមិនមានភាពគួរនឹងទទួលក៏ដោយ ដូចជាមួលបង្កាច់ថា

ឈ្មោះនោះគ្មានសមត្ថភាព បើឲ្យខ្លួនកាន់តំណែងនេះវិញទេ៎បសម ។

មានកិត្តិយសម្យ៉ាងទៀត ហៅថា កិត្តិយសខ្ចោចផ្សា ។ សួរថា កិត្តិយសនេះដូចម្តេច? មានដំនឹងយោរយៅខ្លះ ដោយអំណាចចង់បានកិត្តិយសម្យ៉ាងពេក ហ៊ានយកដីរំតអ្នកដទៃទៅក្តី ដូចថាជួលគេឲ្យសម្ងាត់អ្នកនោះទៅ ហាន:នោះនឹងចន្ទោះ ម្ល៉ោះហើយទៀងតែភ្លាត់មកលើខ្លួនជាប្រាកដ ។ ចំពោះរឿងកិត្តិយសកាលនេះ គេសង្កេតឃើញមានជាហូរហែតាំងពីអតីតកាលមក ។ ឧទាហរណ៍ ក្នុងព្រះពុទ្ធសាសនា : មានកិកុមួយអង្គឧស្សាហ៍ណាស់ តែងបំពេញនូវតព្រះមហាកស្សបពលំ ថ្ងៃ ទឹកធាន់ក្តី ទឹកស្រន់ក្តី ទ័សេទាសនៈនៃព្រះមហាកស្សបក្តី លោកកិកុអង្គនោះដងខុកនឹងចោសសំអាតប្រគេនជានិច្ច ។ មានកិកុមួយអង្គទៀតត្រូវជាសិស្សព្រះមហាកស្សបដែរ ជាមនុស្សកំជិល មិនដែលដួយធ្វើអ្វីសោះ តែបែរជាបានខ្លួលសេចក្តីសរសើរ នឹងការពាប់អានពីសំណាក់ព្រះមហាកស្សបពន់ពេក ។ សួរថា ហេតុអ្វីក៏ដូច្នេះ? ឆ្លើយថា កិកុកំជិលមិនធ្លាប់អ្វីមែន តែចេះកលល្បិចក្នុងការបន្ទំលួចស្នាដៃរបស់កិកុទ្ធស្សាហ៍ថាជារបស់ខ្លួន គឺថាបើកិកុនោះដងទឹកជាក់ពាងពេញហើយយើញដូច្នោះ ខ្លួនស្ទុះភ្លែតទៅនិមន្តព្រះមហាកស្សបមកស្រន់ទឹក ការធ្វើយ៉ាងនេះជារឿងកលល្បិច ព្រះមហាកស្សប ដោយស្មានថាជាកិកុកំជិលធ្វើម្ល៉ោះហើយ លោកតែងសរសើរប្រាប់គេប្រាប់ឯង ខ្លួនក៏ខ្លួលកិត្តិយស

ការឡៃនេះរហូតមក ។

មានមួយថ្ងៃ តាក្តុទស្សាហ៍ ដោយធុញច្រាន់ខឹងអំពើលាមកនៃតាក្តុកំដិល ក៏ឈប់ដងខ្ចីតដាក់ពាង ទុកឲ្យពាងនៅហូតហែងគ្មានទឹកមួយដំណក់ ។ ចំណែកតាក្តុកំដិល ដោយស្មានថាគេដងដាក់ហើយ ព្រោះឆ្ងាប់តែដូច្នេះ ក៏ទៅនិមន្តព្រះមហាកស្សបមកស្រង់ទឹក ។ លុះនិមន្តមកដល់ លោកមិនឃើញមានទឹកមួយដំណក់ក្នុងពាង ទើបរឿងពិតក៏ផ្ទុះលេចឡើង ។

តាំងបច្ចុប្បន្ននេះ រឿងតាក្តុយសការឡៃក៏មិនមែនមានចំពោះតែប ខ្លះព្រោះតែចង់ចាន់ហាន:អ្វីមួយដ៏ខ្ពង់ខ្ពស់ ទំនុកចុះសុំគេក៏មាន ខ្លះព្រោះតែចង់ឲ្យលេចឮឈ្មោះខ្លួនថាខំទៅនិយាយអង្វរឬកំហែងឲ្យគេជួយផ្សាយឈ្មោះខ្លួនតាមវិទ្យុផងក៏មាន ។ល។ សួរថា គេធ្វើយ៉ាងនេះរាប់បម្រើនដល់សាមីជនឬទេ? ឆ្លើយថា ព្រោះតែមានការបម្រើន ទើបមនុស្សភាគច្រើននិយមធ្វើ ។ តាមការសង្កេត យើញថា គេធ្វើដូច្នេះ គឺគេចាន់តិត្តិយសមែន តែជាតិត្តិយសដែលបណ្ដិត្យរមែងស្អប់ខ្ពើម ។ ចំពោះរឿងនេះគួរឲ្យអៀនខ្មាស់ណាស់ បើមិនខ្មាស់អ្នកដទៃ គួរតែខ្មាស់ខ្លួនឯង ព្រោះអំពើខុសវិត គ្មាននរណាដឹងច្បាស់ជាងខ្លួនឯងឡើយ ។

តទៅនេះ ខ្ញុំលើកយកសុភមង្គលមកដោះស្រាយម្តង ។ ភាពសុខកាយសប្បាយចិត្ត ឈ្មោះថាសុភមង្គល ។ មនុស្សនិយមត្រូវការ

ចង់បានសុភមង្គលនេះដូចជាកិត្តិយសដែរ ។ តាមការសង្កេតនឹងសេចក្តីត្រិះរិះ យើញថា សុភមង្គលខុកដូចជាបុប្ផមានក្លិនក្រអូបដែលគេជាតិតែងចោមរោម ឬដូចជានារីមានរូបសម្បត្តិដ៏ឆើតឆាយដែលមាណពចាំងឲ្យតែងតឹងដើរមកហើយលេបចំកមាត់ផ្ទុះ ។ កាលណាបានឃើញ នេះឧបមាយ៉ាងណា មនុស្សត្រូវគាំរសុភមង្គល មានឧបមេយ្យដូច្នោះ ។

សួរថា មនុស្សសត្វថ្វយល់ថា សុភមង្គលកើតមកអំពីអ្វី ? តាមការសង្កេតនូវអាកប្បកិរិយានឹងការប្រព្រឹត្ត យើញថាមនុស្សសត្វថ្វ ចូលចិត្តថាសុភមង្គលកើតតែពីកោគទ្រព្យ គឺកោគទ្រព្យនេះហើយដែលផ្តល់សុភមង្គលដល់មនុស្ស ។ កោគទ្រព្យនឹងអាចនិម៉ិត្តអ្វី ។ ឲ្យមនុស្សបានតាមសេកក្តីប្រាថ្នា គេនិយមខុកកោគទ្រព្យជាកន្លែងបក់កន្លែងចោយ គេនិយមខុកកោគទ្រព្យជាទ្បូចង់ដំបងវាយឯង គេនិយមខុកកោគទ្រព្យជាឆ្នាំងឆ្អិនឯង ។ ការនិយមនេះ គួរហើយ តែមិនជាសមរម្យទេ ។

សួរថា ការនិយមនេះ ជាសេចក្តីពិតឬយ៉ាងណា ? បើតាមអ្នកសម្ភានិយម កោគទ្រព្យពិតជាប្រកបនៃសុភមង្គលមែន ព្រោះអ្វីៗទាំងអស់ជាអាទិ៍ តីផ្លះ ប្រាសាទ យានយ៉ានប្រណីត សំលៀកបំពាក់ល្អ អាហារឈ្ងុយឆ្ងាញ់ គ្រឿងអលង្ការ។ល។ កើតតែពីកោគទ្រព្យ ។ ដូច្នេះហើយបានជាក្នុងលោកបច្ចុប្បន្ន គេឃើញមនុស្សស៊ុះស្មុសរម្ងើមពេកណាស់ ដើម្បីស្វែងរកកោគទ្រព្យ ។ មានមនុស្សខ្លះ តីកាគច្រើនតែ

ម្ដង ស៊ូប្ដូរស្ទាប់ប្ដូរសេះចំពោះគោគន្ធ្រៀ គេរកគោគន្ធ្រៀដើម្បីរស់ ខ្លះរស់ដើម្បីស្ទាប់ទៅវិញក៏មាន។ ការខំប្រឹងស្វែងរកគោគន្ធ្រៀគឺជាការណ៍យកចិត្តរបស់មនុស្សពិតប្រាកដ តែត្រូវស្វែងស្វែងដោយមធ្យោបាយណា ដោយវិធីដូចម្ដេច? ត្រង់ចំណុចនេះហើយដែលត្រូវដោះស្រាយ ។ យើងឃើញគេមានផ្ទះឡូ យើងឃើញគេមានរថយន្ត យើងឃើញគេមានសំលៀកបំពាក់ល្អ ។ យើងឃើញគេបរិភោគអាហារឆ្ងាញ់ យើងឃើញគេចូលកំសាន្តក្នុងរោងរង្គសាលរាត្រី ។ល។ យើងប្រាថ្នាចង់ឲ្យដូចគេ ចំណង់នេះជាការគាប់ប្រសើរណាស់ហើយ តែចូរប្រយត្នការប្រតិបត្តិ ។ គួរឲ្យអៀនខ្មាសពេកណាស់ ព្រោះតែត្រូវការសុភមង្គល ហើយទៅប្រព្រឹត្តការមិនគប្បី ជាអំពើដែលអ្នកប្រាជ្ញតែងស្អប់ខ្ពើម (ចោរកម្មត្រូវបែបយ៉ាង ស៊ីសំណូក) ។

គួរគិចារណាឲ្យសព្វ ។ ជាការថោកទាបពេកណាស់ ព្រោះតែចង់បានសុភមង្គលដល់ខ្លួនឯងដល់ត្រួសារ ហើយទៅធ្វើឲ្យអ្នកដទៃឲ្យដល់ខ្លួវការសង្រេងសង្រៃ ។ ជាការថោកទាបម្យ៉ាងទៀតដែលយកសុភមង្គលទៅដាក់ក្តីយស ដែលខ្លួនមិនមានសមត្ថភាពនឹងត្រូវជាន ហើយជាការថោកទាបជ្រុនថ្នមបំផុត ចំពោះអ្នកដែលហ៊ានលក់តំលៃ-យសឲ្យដល់មនុស្សដែលមានសភាពមិនគប្បីខ្លួល ។ បមាដូចជាត្រីរស់មានតែមួយ ហើយមានមនុស្សច្រើនត្រូវការចង់ចរិភោគ យើងមិនលក់ឲ្យ

មនុស្សច្រើន យើងសប្បាយចិត្តនឹងលក់ឲ្យដល់មនុស្សម្នាក់ដែលហ៊ានឲ្យ
ថ្លៃច្រើន យើងស៊ូបរណ្តាយខុកឲ្យមនុស្សច្រើនវេទនា ព្រោះតែចង់បាន
សុភមង្គល ត្រោះតែចង់បានសុភមង្គលផ្លាល់ខ្លួនហួសប្រមាណ ។ កុំស្មាន
ថាការមានសុភមង្គលតែម្នាក់ឯងអាចតាំងនៅបានជាស្ថាពរ ការស្មាននេះ
គឺកាន់ច្រឡំពិត ការប្រកាន់ខ្ជាប់នេះ ប្រហែលនឹងជួបប្រទះនូវអ្វីមួយជា
ប្រកតនៃសេចក្តីអន្តរាយក្នុងអនាគត ។

សូមដកបញ្ជាក់ថា ទ្រព្យសម្បត្តិក្តី យសសក្តិសម្បត្តិក្តី បរិវា-
សម្បត្តិក្តី នឹងចាត់ទុកជាប្រកតនៃសុភមង្គលក៏មិនច្រាកដ នឹងបដិសេធ
ថាមិនមែនទៅវិញក៏មិនច្រាកដ ។ ការត្រិះរិះនឹងពិចារណាឲ្យវែង
ឆ្ងាយទៅ ហុចឲ្យយល់ថាសុភមង្គលបរិសុទ្ធ គឺនៅត្រង់ការសុខចិត្ត ។
ឧទាហរណ៍ បើយើងជាមហាសេដ្ឋី បើយើងជាមហាវជ្ជបុរស តែ
ចិត្តយើងមិនស្កប់ មានពលិភោគជានិច្ចកាល នឹងឲ្យឈ្មោះថាយើង
មានសុភមង្គលក៏មិនបាន យើងជាមនុស្សសាមញ្ញទេ តែមានចិត្តស្កប់
រីករាយនឹងតែដែលយើងមាន ឥតព្រួយបារម្ភក្រែងអ្នកណាលបធ្វើខុសក្តី
មិនមានការភ័ន្តច្រឡំហួសប្រមាណ ត្រង់នេះហើយទើបហៅថាសុភមង្គល ។


ដូចេ្នះគួរគប្បីសន្និដ្ឋានថា សុភមង្គលជាអាទិសង្ឃឹមនៃភោគទ្រព្យ
នៃយសសក្តិ ឬនៃបរិវារក៏មិនមែន នឹងថាជាអាទិស្សរនៃការក្រេះហេម
រហាមក៏មិនមែន គឺពិតជាអាទិស្សរនៃការសុខចិត្តជាច្រាកដ ។

សិលាចារឹកជ័យ-ឧត្តុ

ស្រាវជ្រាវដោយ ទុ. តាម

អក្សរសិទ្ធិត្រប់ឃ៉ាង

សិលាចារឹកជ័យ-ឧត្តុជាភាសាខ្មែរ ដែលខ្ញុំបានប្រទះឃើញជាសិលាចារឹកគង់សម័យដែលប្រទេសខ្មែរយើងប្រើមហាសក្ករាជ ។ នៅលើផ្ទាំងសិលាចារឹកនោះ ឃើញមានការលចរឹងច្បាស់ត្រប់គ្រាន់ ។ សិលាចារឹកនោះ គេចារនៅក្នុងគ្រិស្តសតវត្សទី ១៨ ។ សិលាចារឹកនៅសតវត្សនោះមិនសូវជាពិបាកអានប៉ុន្មានទេ ពាក្យពេចន៍ក៏ភាន់តែមានលំនាំចិតចូលមកតែអក្សរសាស្ត្រខ្មែរសម័យបច្ចុប្បន្ន។ គេសរសេរឬចារមិនគិតយកក្បួនអក្ខរាវិរុទ្ធិណាជាគោលទេ គេសរសេរឲ្យតែអានបាន ចំណាំបាន ។ ខ្ញុំសូមដកស្រង់ខ្នះខ្នែរសម័យនោះសិន មុនទំព័រលោកអ្នកអានអត្ថបទរបស់លោកជ័យឧត្តុ:



ក. ព្យញ្ជនៈនឹងស្រៈដែលប្រើនៅសិលាចារឹកជ័យ.ន.ទ្ធ

ស្រៈដែលមានប្រើនៅសិលាចារឹកនោះ ឃើញថែកៗគ្នា មិនសរ-
សេរដូចគ្នាទេ ដូនកាលគេសរសេរដូច្នេះ ដូនកាល គេសរសេរដូច្នេះ
១. ត្បៀ ដូនកាលសរសេរជា ពោយ ។

២- ស្រៈ អ្ន ច្រើនតែសរសេរជាមួយស្រៈ ៀ ១. មោក ជា មក
ជោង ជា ជឹង ។

៤- ស្រៈអ្ន សរសេរដូច្នេះ ១. សេិលសាស= សិល្បសាស្ត្រ
តេិប =តិប ។

៣- ស្រៈអ្ន សរសេរដូច្នេះ ខ្ញុ ដូច ខ ខ្ញុ ១. ស្រែតិ =ស្រដី
ព្យែតើម្ន = ពីដើម ។

៤- ស្រៈ អ្ន សរសេរជា ខ ខ្ញុ ជាដើន ឬ ខ្ញុ ១. សិងប្ងូល=
សឹងប្ងូល ត្បង= ជឹង ។

៥- ស្រៈ អ្ន សរសេរជា ឺ ខ្ញុ ជា ខ ខ្ញុ ១. ប្ញឹណា=ប្ញឹង
គិបិ= គឺបិ ។

៦- ស្រៈអ្ន គេសរសេរដោយយកដើនព្យញ្ជនៈ ឬ ជំនួស ឬសរ-
សេរនឹងស្រៈអ្ន ១. ឬប= រូប ម្ួយ=មួយ ។

៧- ស្រៈ អឿ ជួនកាលគេសរសេរ ើ ខ្លះ ជួនកាលសរសេរដូចសព្វថ្ងៃ ។. លើក=លើក ប្រើន=ប្រើន ។

៨- ស្រៈ អឿ ឃើញមានសរសេរដូចសព្វថ្ងៃនេះដែរ តែកន្លែងខ្លះមិនសរសេរដូចសព្វថ្ងៃទេ ។. ក្បឿង=ក្បឿង ។

៩- ស្រៈ អេ សរសេរជា ៉ ។. បិញ=បេញ បិក=បេក

១- សញ្ញាឥន្ទវិស្សាយុត្តិខ្លះនៅសិលាចារឹក ដ៏យ ន ឬ

១- មូសិកខន្តនៅក្រោមព្យញ្ជនៈ មានន័យថាព្យញ្ជនៈនោះជាស្រៈទៅវិញ ។. ជាប្តងឬ=ចារបង តែជួនកាលទៅជាស្រៈអ្ន ។. ពុំនួក=ពំនាក់ ។

២- សំយោគសញ្ញាមានន័យពីរយ៉ាងគឺ:

ក- ជំនួសព្យញ្ជនៈជំ ។. សំឃ=សង្ឃ

ខ- ជំនួសបន្តក់ ។. ពាក៌=ជាក់

ខ្ញុំសូមជូនពាក្យពាំងព្យញ្ជនៈ ទំនស្រៈដែលខ្ញុំបានចម្លងផ្ទាល់ខ្លួនខ្ញុំនៅវត្តសាខអង្គរវត្ត ។ ខ្ញុំមិនបានចម្លងសព្វគ្រប់ទេ ខ្ញុំចម្លងតែកន្លែងណាដែលមានស្រៈស្រដៀងទំនស្រៈសម័យបច្ចុប្បន្ន ទំនលំនាំព្យញ្ជនៈ ។

សូមលោកជ្រាបថា ពាក្យដែលខ្ញុំយកមកជាឧទាហរណ៍នេះ ខ្ញុំបានចម្លងចេញមកពីវត្តសាខអង្គរវត្តនៅថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ ១៩៦៣ កាល

ថ្ងៃនៃក្រែងគ្រាយ ត្រូវឆ្ងាយឯកូនស្លុ...

កាន់ក្រែងក្រាបក្រាន សម្រាប្រាប់ភ្លាំងៀ...

ខ្លួនក្រមប្រាកស្លាង អាណាខ្លាគ្រាយ...

អាណាខ្លួនាយ៉ា ម្ដងម្ដងលាលា

ឱ្យដូចមលិដក្រែ: ឆ្លុះទាំងមលិដជ្ជា.....

ដែលខ្ញុំទៅមើលច្រាសាទបូកណា ។ បើលោកអ្នកបានអញ្ជើញទៅ
ទស្សនាច្រាសាទបូកណានៅខែត្រសៀមរាប សូមលោកឆ្លៀតឧកាសទៅ
មើលសិលាចារឹកជ័យ-ន្ទ្ធកុំខាន ។

ដើម្បីឲ្យស្រួលដល់លោកអ្នកអាន សូមលោកអ្នកជ្រាបថា ច្រាសាទ
អង្គរវត្តចែកជា ៣ កន្លែងគឺ:

១- ព្រះពាន់: កន្លែងដែលមានព្រះពុទ្ធរូបច្រើន

២- ចាតាណា: កន្លែងនៅខាងលើគេបំផុត

៣- ព្រះរៀងថ្នាក់ក្រោម: ឬ ភេនទង ។

លោកអ្នកទៅដល់ច្រាសាទអង្គរវត្តហើយ សូមលោកអ្នកអញ្ជើញ
ទៅព្រះរៀងថ្នាក់ក្រោម ឬភេនទង សូមលោកចូលតាទិសខាងកើត ត្រង់
កន្លែងដែលមានព្រះពេតិយឬជាយក្រៀម ។ សិលាចារឹកជ័យ-ន្ទ្ធនេះ
នៅលើជញ្ជាំងខាងលិច ភេនទងខាងកើត ។

សិលាចារឹកជ័យ-ន្ទ្ធ សរសេរតាមសិលាចារឹកឯកវរិត្ត

ព្រហ្មភីតិ

(១) សព្ពមសសូស្តិ ត្រីសព្ទត្រីមង្គលា ពហុលព្រះដៃយ្យា តេស្ស
សាត្ថិអតិវេក ។ (១) នា ១៦២៣ ស្នូកនេះ ត. . មសែញ នៃច្បាប់ទស

១= នៅសិលាចារឹកជ័យ ន្ទ្ធ គេមិនប្រើឈ្មោះទេ គេប្រើលេខសូន្យ (០) ជំនួសឈ្មោះ ។

២- លេខរៀងដែលខ្ញុំយកមកប្រើនេះដើម្បីឲ្យស្រួលដល់លោកអ្នកអាន ។

កេដមាឃមៃ ខិតារថ្ងៃព្រះហស្សតិ៍ ។ ពិតមែនឯងនា គោយ្យតាថា ព្រះបាឡី លើកសរសេរពុទ្ធ បទមុះហ្មឺត្រាំហ្មត់ត ។ (២) អញ្ជឹមថ្ងៃ បុក្ខា ព្រះកត្តិកាសង្កើត្ត ស្ថិតត្រាសយល ... ស្តែចគុណតិតផ្ទញមាវែង ។ បទុំមក្រពុំស្អាត ថ្ងាយព្រះបាទូសង្កើតថ្ងៃលុតលើកទស្សកវក្រៃ ផ្ទងប្រពៃ តាកសិរស្សើ ។ ខ្ញុំមក្រាប្បីក្រោមព្រះបាទូ អត្តិពលវរវន្ទ័ តិតថ្ងៃវៅព្រះគ្រើ វត្តវត្រៃយត្រើកាល្អ ។ (៣) វ្រុំរឿងបាលំពេជ្ជ ត្បិចត្រៃស្រេចរិចូនា ធ្វាកវ្ងៃជាក្តីងាបរបូរបួនខន្តប្បហាត៍ ។ តាមថ្ងូងស្ងើងត្រូប្បីតាណ្ឌិ ល្អ ឥស្ថាវ្ងៃទ្រុះច្រកត្ត កេតផ្ស...ពោធិសត្ត ព្រះគុងស្ថិតឈ្មោះមារជោង ។ ថ្ងៃព្រះសាវម្ម៉ីនោ ព្រះត្រើអារសោតហោង ត្រស់ធម្មិទ្ធាំសត្តុជោង ក្នុងតន្ទូងកាល្យនែះខោះ ។ (៤) ខ្ញុំក្រាបក្រោមព្រះបាទូ អត្តិពលវរវន្ទ្ធា ប្រណំព្រះសាស្តាបញ្ចាពុទ្ធាត្រែតត្រៃ ។ តេជះអញ្ជឹថ្ងៃ ទសករតាយ ឥសហ្រាមៃ ផ្ទំមផ្ទងតំម្បងថ្ងៃ ចិត្រមូលមៃមែនប្រាថ្នា ។ តិតថ្ងៃព្រះ ចេត្តីបុលាម៉ីត្រៃត្រង់ឆ្ងាសាងខុកព្រះរកស្សា ឥសទេព្តាថ្ងៃបង្គំម ។ (៥) ថ្ងៃព្រះប្រត្តិមា មាសនោទាស្ថាណអស្រំម ព្រះត្រៃសណ្តាំត ជាតុំខុកនៃសត្តុជោង ។ ថ្ងៃព្រះពុទ្ធរូប ឯព្រះសធូបចែត្តីហោង ថ្ងៃត្រូប ព្រះជ្បីជោង ព្រះសាធតុងព្រះគោយា ។ តេជះអញ្ជឹថ្ងៃ សង្ឃកាច កាយកប្បហាត្តា លុតលើកឥសអគ្គា ថ្ងៃវន្ទាសូរេចហោង ។ (៦) ថ្ងៃ ហៀឡុំចូលផ្តង សូមឲ្យតិងឥសអារជោង ជាតិ្តសញ្ញាណហោងកុំកំម្បាំង

ភ្លាំងក្ងេចលៀ ។ កេតចានក្រាំម្ដិលឆ្នាំ ក្រាជ្ញ ចាំមហៀចេះធ្លុយ ឥសអយ្យៀធម្មិគ្រុបហៀ ត្រៃបីជតរត្ថមត្ថ័ទេ ។ ឥត្ថុំសូរឆ្ពោងតលតំច ថ្ងេងភាកពេជ្រស្រេចឯង គោះធ្លើរគោនឯងគ្យេតោះប្រស្នាអ្ស្រត័ល សាល្យ ។ (៧) សូមុចេះចបត្រៃកេខ សៀលសាសសេតំអ្ងាតខេសពាល ឆុតនាប័្ជាឥសចាយ្យៀ តូចព្រះបរមេសូរនៃ ។ សូមខ័នព្រះគ្រីអាយ្យៀ មានបរិតារប្រេនគ្រាសត្រៃ ជាវយពាំនហ្មឹណានៃ ល្អប្រពៃត្យេគ្រាថ្ងា ។ (៨) សេពូជ័ន្តគ្រីគោបួស ហ៊ូងឥលផ្ទួស្ស្ដេថ្ងៃថ្ងា សំនាក័ព្រះ សាស្ដា ឋានព្រះពុទ្ធខំនាទុក្ខ ។ ព្រះគ្រីអាយ្យៀក្យាថា អ្នកនែះនា-ត្រស័្ដឯម្ដុក្ខ ជាព្រះពុទ្ធស្ងេស្ដុក្ខ ត្រស័្ដធម្មិទុក្ខនាំម្ដសត្វនៃ ។ ខ្ញុំ សូមនោះរំងែមោក ជាពន្ធកសតើជ្ងថ្ងៃ អង្គខ្ញុំនែះឯងនៃ ត្យេនាម្ដ-ហោរំដែយន្ត ។ រំខាងជាកនៃ្យ ឈ្មោះពំរនៃមឹងបែនស្ដួន រួបនោម្ដ ននេអនអន យេលស្ដាកសម្ដចរ័ត្តត្រ័ ។ (៩) លះព្រះបាទ្ងកជ្ងា ឲ្យ សក្ការំនៃ្យខ្ញុំ ដែនន្ធនស្ដាធ្លូតៀ ហៀឲ្យនៃ្យត្រៃក្ដុំហោង ។ តលៅនៃ្យ ជ្ងួងឃ្ងុំម ហ្នាហ្មឺនធំឯកឯងហោង លុះជាយម្ដាជរ៉ោង នោះឯង ហោងសាងត្រីសូរ ។ ឯមឹងបែននោះនាយេសសក្ដតាត្យេគុំខ្ងួរ ឈ្មោះ នោះយេលថរបួរ ជាដុំតាវេត្ងសុពណ្ដិ ។ (១០) រ៉ៀម្ដុកនែះខ្ញុំត្ងៀរ ត្យេរ មិលយេលឥសចយ្យៀ ជាតនែះព្ងួខ្ងួតារ កេតខុក្ខត្រាតជាតាយាត ។ ជាតនែះត្ងុំបរបួរ ក្រាសត្ងុំមួលច្រើនឃ្លាឃ្លាត គោះកេតសត្ង ។ ជាត

កុំគ្រាយ្ហាតតលតេចលៀ ។ វិបាកនែះដោងគ្នា មោកច្រើនគ្រាពុំគ្រាសេរ្ចើយ អំម្ដេជាតនែះហៀ ខ្ញុំរៀត្រងវិបាកប្រាន ។ (១១) ពោះលែងជាតនែះពោះ រៀលមោកនៅកេតរួមស្ងាណ្ណ ត្រងខ្លួតអស្រូវប្រាន កុំគ្រាមានកិតកៃរៀ ។ កាលអ្ងិតនឹងព្រះតន្ត សោតលេសលុនខ្លួនឥន្ទ្រី ហៀកព្រះចាយតៀ ខ្លួកជាតនិចិនឯកូន ។ រៀកូនខ្ញុំពីរអង្គ អាពុកថ្ងន ធ្លើបុទ្យដូន ប្រកុបម្ដាយនឯងកូន អ្នកតម្ងុនឯងនោម្យស្ងាណ្ណ ។ (១២) ហៀសាងព្រះងាកបែក ចាកដណ្ដែកបែកអង្គប្រាន ខ្លាតខ្លាយអន្ទនចាកឥសប្រាន ជាកំនាត ។ ឯខ្លាះចាកស្លូង ព្រះកេសដោងភ្លាកចំញាចាតព្រះចាខ្លួជាកុំនាត ព្រះហស័ចាត័តាច័ខ្លាតខ្លាយ ។ ទំកេតរៀស្យប្រមូលចោះជ្ញាបច្ចូលមូលប្រប្ញាស្យ បេតមាស្យឥសខ្ញុំហ្សាជាពន្រាយល្អមានខ្លេង ។ (១៣) រៀកប័ឥសខ្ញុំហ្សា មុយចាយ ៣០ ព្រះអង្គ សាងព្រះបទពាំផ្ដង គ្លរគ្រុបអង្គរុបតូបខ្ញុំ ។ ហៀបួសខ្លោងចាយតៀ ព្រះសាងថ្ងំនោះខ្លោងផ្ដុំមខ្លោងរួបខ្ញុំតូបខ្ញុំ ជាឧត្តមផ្ទសស្រេចហោង ។ ស្រតៀតែខ្ញូនែះ ពុំរៀបរែះពាតេម្ងោង ធ្លើបុទ្យនោះច្រើនហោង បួសប្រាំម្ងៃគោងនិងនែះនា ។ (១៤) កាលបុះព្រះមាសមូល សាងត្រីសូរនោះម្យគ្រា សិទ្ធព្រះស័ហិងនាំ បុះព្រះមាសប្រាកច្រៃនដោង ។ ធ្លើបុទ្យតាមុទ្ទនា សងសាលាវិហារហោង បំម្លីសកូនគ្រុបដោង ប្រាសខ្ញុំហោងបញ្ចុះស័ម្ម ។ និងតតៀស្មោគាន ចាំមពុំបានបទ្ធច្រើនគ្រា ឲ្យគាខ្លាះបានគ្រា

តៀតគន្ធាតិត្តជាចង្ស ។ (១៥) ស្រតិ្សតៀតចាកាត ពុំរៀបចប៌ាតេមផ្តង
បេតិតឥ្សានសយិ នោះច្រើនហ្នាស័ចាំម្តុំពុំបាន ។ តៀតិតធ្លៃបុន្យនា
និងគន្ធាច្រើនសព្វស្ថាន និងចាំមនោះពុំបាន បន្តុតៀស្ថានច្រើនតួងនា ។
សូតព្យានែរគោហៀ សូតបង៌ហៀចុះគោវល្បា សូតវ្តែចិតសនែរនា សូត
សិម្មទូមសំម្រេចហោង ។

បទតួដុង៌លេលា

(១៦) នែរបទតួដុង៌លេលា លេីតតៀតាត្យា ជាល្បាខ្ញុំហ្តាស ។
លាតឥសលោគោសម្តុំមួយ លាតៃស្យអន្តរាយ ត្រាតត្រាយប្តាសគ្នា ។
ខ្ញុំក្រាបខ្ញុលព្រះពុទ្ធា ព្រះហៀខ្ញុំលា ត្រង៌នាខុកសោក ។
ខ្ញុំលាត្រង៌កុំណេីត្រថាក តេត្រមោតឥសលោក សេីចតៀលសព្ពាន ។
(១៧) ខ្ញុំលាសព្វជាតវៀរស្ថាន ក្តីអាស្រូវប្តាន កុំមានលៀនា ។
ខ្ញុំលាត្រង៌ឥតប្តាជ្ញា ធ្លុលខ្លោវមោហា ខ្ចាសតេអៀនប្រៀន ។
ខ្ញុំលាត្រង៌ឥតរបៀន ចូលដំពុំស្ងៀម ពុំចេះធ្លៃថា ។
ខ្ញុំលាពិសក្សាធភេគ្គា ប្តាសបុត្រកិយ្យាំ ស្វាប៌ទាសប្តាន ។
(១៨) ខ្ញុំលាវិជាកចូក៌ន ជាពុតកុង៌ប្តាន ស្រេីកឃ្លានខោះផង ។
ខ្ញុំលាឥសជាប៌តៀរហោង ចំតុកជ្យារផង បួនតំពៅស្លាស ។
ខ្ញុំលាត្រង៌តុំនិតឡោយ លាខ្លិលកុំស្លាស ហៀស្នាតិ្យតេីច ។
ខ្ញុំលាពុំចេះកលតិច សេីលាសាលាការស្រេច ពាតពេជ្ជខោះនា ។

(១៩) ខ្ញុំលាត្រង់ឥតប្រាជ្ញា ពុំចេះកាសា ស្រស់ត្បិទង់ឥន្ទ្រ ។
ខ្ញុំលាត្រង់ឱ្យត្រូវនេះទេ ត្រមោចឯងឯង ឥតប្រៀនខ្ចូក្បា ។
ខ្ញុំលាឥតព្រាប្បកោគ្គតា ពាសប្បៀពាសប្បៈ ពុំមានតលម្អក ។
ខ្ញុំលាត្រង់ចិត្តប្រតិយោគ៌ ស្រុតខ្សាអាក អនេះអៀនចិត្តឥន្ទ្រ ។
ខ្ញុំលាត្រង់ពាកស្រាលស្រេ ស្រស់ត្បិតួចឥន្ទ្រ មមែហត្ថតនា ។
(២០) ខ្ញុំលាត្រង់ធោតកាសា ស្រស់ត្បិទៅថា ពាក្យហាឥតកាយ្យ ។
ខ្ញុំលាត្រង់ភ្នែវអនុភាល ស្រស់ត្បិសារធារ ឥតនេះយោកពាក ។
ខ្ញុំលាត្រង់ទាតុកយាក្ស ខ្លួរយេសត្បិជាក ពុំព្រៃស្សសោច្ឆ ។
ខ្ញុំលាត្រង់លង្ឃកំប្រាយ ធ្លុលធ្លាក្យមាយ ជ្រុងោឥតកាយ្យ ។
(២១) ខ្ញុំលាស្នាត្បិសារធារ ស្រស់ត្បិកំចកាយ្យ ពុំចាំនោះហាង ។
ខ្ញុំលាពុំនោលស្ងួរសង ស្រស់ត្បិពាកឆ្គង ពុំត្រូវចិត្តឥន្ទ្រ ។
ខ្ញុំលាឥន្ទ្រស្អប់សត្វតំ ត្រង់ទាខ្លាសឥន្ទ្រ ។ លានោះហាង ។
ខ្ញុំលាឥសវៃវោង ពៀរត្រង់ចុំណង្ស កុំយលល្បែនា ។
(២២) ខ្ញុំលាឥស្សក្តិមោហា វង្វើងឃ្លាតឃ្លា ក្មេចក្លាំងប្រមាទ្ធ ។
ខ្ញុំលានោះសត្វាជាតិ ស្រស់ត្បិប្រមាទ ពិយាដ្ឋសត្វវោង ។
ខ្ញុំលា សាវ៌ត្តិក្តីឆ្គោង តិតខ្ញុសរំលង ទេត្តិយេញឯក្រោយ ។
ខ្ញុំលាត្រង់ក្តីខ្ញុំលោយ តិត្តខ្ញុសហ្សក្រោយ ទេត្តិយេញក្តីតាប្ប ។

ខ្ញុំលាត្រូវនាំអាកាព្យ៌ រស្យនោតុំស្ងាប់ ជាខុក្ខម្មកឯង ។
(៤៣) ខ្ញុំលាត្រូវនាំវង្វែង ស្រស់ឥតត្រេង ចាំរំក្រាយលៀ ។
ខ្ញុំលាជាតនេះឃេញហ្ស គំត្រយលអត្រួយ តុំនកល្បនា ។
ខ្ញុំលាត្រូវក្តីមោហា ប្រមាទូមៀចា គ្រូចាធ្យាយផ្ទាង ។
ខ្ញុំលាត្រូវក្តីធ្ងាំមន្តោង ប្រមាទូសឃើផ្ទាង ព្រះពុទ្ធព្រះធម៌ ។
ខ្ញុំលាត្រូវក្តីសាហាវ ស្រស់ឡាល អនអៀនព្រះវៃ ។
(៤៤) ខ្ញុំលាតុំប្រកួបនៀ នោអំម្ចាស់ថ្លៃយ ប្រពៃទ្រង់ធម្មិ ។
ខ្ញុំលាត្រូវចំត្រសហារ សាហាវឥស្ចាយ្យ បន្ទូនក្រចាន ។
ខ្ញុំលាមនុស្សនាបៀនច្រាន ស្រស់ជង់ខាន្ធ ញុះញង់ចិចូ ។
ខ្ញុំលាត្រូវក្តីអស្រូវ ស្រស់ចិចូ កែះតៀលប្រមាទូ ។
(៤៥) ខ្ញុំលានោះសត្វាជាត្ត សាត្ងើបង់ឃ្លាត បង់ខានលាកយស ។
ខ្ញុំលាត្រូវនាហៅដ្ឋឡស្ស យស្សសក្ខរបស្ស ក្លាតក្លាយចាតបង់ ។
ខ្ញុំលាត្រូវគ្បែញុះញង់ បង់ខានចំណង់ បង់ខុសឃ្លាតន្ទា ។
ខ្ញុំលាត្រូវកៃយ្យវែក ត្រមោចកុំក្រា ឥតគ្នាតាមក្រោយ ។
ខ្ញុំលាត្រូវខ្លាចកុំស្ងាប់ តិតកៃស្ងៃប្រែក្រោយ តតៃស្ងចុំប្រប្ស ។

(នៅមានត)

វិបុលានុក្រមសំស្ក្រឹត-ខ្មែរ

ព្រះមហា ចាំង-ខាត់ រៀបរៀង

(តមក)

អទុគ្គ គុ. ដែលមិនមានឆ្មេញ ។

អទុត្ត គុ. ដែលមិនឲ្យ ។ អទត្តា ស្ត្រី. កិរិយាមិនព្រមរៀបការ ។ –ទាន ឧបុំ. ទានដែលបុគ្គលមិនបានឲ្យហើយ ។ -ផល ឧបុំ. ផលដែល... មិនឲ្យហើយ ។ អទត្តាទាយិនិ បុំ. ជនកាន់យកវត្ថុដែលជនមិនបានឲ្យហើយ ចោរ ។

អទន ឧបុំ. កិរិយាបរិភោគ អាហារ ។ អទនី-ភូ ធ្វើឲ្យទៅជាអាហារ ។

អទប្ប គុ. ដែលបរិបូណ៌ ពេរពោក ។

អទំភ បុំ. កិរិយាមិនប្រវិញ្ចាន់ ។ អទំភិនិ គុ. ដែលមិនប្រវិញ្ចាន់ សុចរិត ត្រង់ ។

អទ្ធយោ ក្រិ.វិ ដោយមិនអាណិត យ៉ាងសាហាវ ។

អទ្ធរិទ្ទ គុ ដែលមិនក្រីក្រ ដែលមានទ្រព្យ ។

អទ្ធប៌ គុ. ដែលមិនឆ្មើងឆ្មៃ ដែលសុភាព ។

អទ្ធភ៌ គុ. ដែលឥតពិធីទត់ ។

អទជ្ជន នបុ. កិរិយាមិនមើល ។ គុ. ដែលមើលមិនឃើញ ។ អទស្សន-ភូ ព្រះ
ឬបរមាមើលមិនឃើញ ។ -បទ បុ. ផ្លូវដែលផុតពីចក្ខុទ្វារ ។

អទស្សនីយ គុ. ដែលមិនគប្បីមើលឃើញ ។ នបុ. ធម្មជាតដែលបុគ្គលមិនគប្បីមើល
ឃើញ ។

អទិដ្ឋ គុ. មិនបានឃើញ ។

អទូគមិស្ស គុ. ដែលមិនបិតនៅក្នុងអាយុ ១០ ឆ្នាំ ដែលមិនទាន់ដល់អាយុ ១០ ឆ្នាំ ។

អទុ សិ នវិ. នោះ ឯនោះ អ្នកនោះ អ្នកឯនោះ ។ អហោ- មូល គុ. ដែលមាន
ឬសឯនោះ ។

អទាតុ ក. ន. អ្នកមិនឲ្យ មនុស្សកំណាញ់ ។ អ្នកមិនសងថ្លៃឲ្យគេ ។

អទាន គុ. ដែលមិនឲ្យ ដែលមិនចុះប្រើង (ដំរី) ។ នបុ. កិរិយាមិនឲ្យ ។

អទានវិ បុ. អ្នកមិនមែនទាន ។

អទាន្ត គុ. ដែលមិនទាន់ទូន្មានហើយ ។

អទាភ្យ ដែលកំចាត់បង់មិនបាន ។

អទាយាទ គុ. ដែលមិនមែនជាទាយាទ ។

អទារ គុ. ដែលមិនមានភរិយា ។

រឿងសាមកុក

ឧកញ៉ាវិបុលកោដវេសនា ឆួ - ភាគ ប្រែរៀបរៀង

(តទៅ)

ឮរឿងសាមកុកទុកជាឃុំទូសាស្ត្រ
អ្នកជាងវៃឆ្លាសបើបានអាន
ទំនងបេះឧញ្ញាយកលចំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ឃ្លោ-អ៊ុន

ខ្ញុំតាំងយើញដូច្នោះក៏ឃាត់ហាមថា ដែលមកធ្វើការនេះគឺខ្ញុំតែងតែកំឡាំងអ្នកជាងពីរ បើខ្លាំងនឹងខ្លាមកប្រកាំគ្នាដូច្នេះ ការរបស់យើងនឹងមិនខូចអស់រលៀងទេឬ យើងសូមឲ្យលើកចោលទៅចុះ ។ ជាំងថងថា អ្នកជាងពីរកុំវៃគ្នាឡើយ អ្នកជាងពីរស្មុគស្មាញតែមានថ្លៃដូចគ្នា ចើនឯងឲ្យទៅតែម្នាក់ឯង ក៏មានចិត្តមិនសប្បាយម្ខាង ។ ត្រូវឲ្យទៅជាងពីរនាក់ចុះដើម្បីនឹងបានយកបន្ទាយឲ្យបានម្នាក់ ។ បើនរណាបានយកបានមុនក៏នឹងត្រូវបានសេចក្តីគាប់ប្រសើរជាងគេ ហើយចែងភាហានឲ្យហាងតុងទៅបានយកបន្ទាយឡេងហ្ម៎ ឲ្យម៉ុយអៀនលើកភាហានទៅបានយកបន្ទាយតេងហៀន ជាំង ២ នាក់តំនាប់លាខ្ញុំពីហើយក៏ចេញទៅរៀបចំពលភាហាន ក្រោយនោះជ្រាំងថងនិយាយថា នាយភាហាន ២ នាក់ដែលលើកពលចេញទៅ ឥឡូវនេះ មុខជាមិនបានប្រក្រតី ក្រែងទៅតើតវៃគ

ត្នាគណ្ដាលផ្លូវដោយឮថាបាទកំមិនដឹង សូមឲ្យលោកលើកតាហានជាកង ដំខួនជូនទៅតាមស្ដាប់ការដើម្បីឲ្យយើញខុសត្រូវផង ឡៅពីគំយើញត្រូវផង ទើបប្រមូលតាហានខុកឲ្យចាំផងទៅរក្បាលខ្នាយមួយបែក ចំបែកនាំចេញទៅជាមួយនឹងខ្លួនឡៅពីជាន់តជំនួយមួយបែក ។

ហឯគុនកំបង្គាប់តាហានឲ្យដាំចាយស៊ីឲ្យរួចពីព្រឹកនឹងលើកទៅខាងដើងគ្នាខាងស្ដាំដៃ ។ណៈ កាលហឯគុនបង្គាប់តាហានឲ្យដាំចាយនោះ អ៊ុយអឿនដឹងកិត្តិសព្ទក៏មានអំណរណាស់ ទើបបង្គាប់តាហានរបស់ខ្លួនឲ្យដាំចាយស៊ីឲ្យរួចព័យាមមួយ ហើយក៏លើកចេញទៅមុន តាំងពីតណ្ដាលអង្រាត្រ ប្រមាណជាកូស្វាងឲ្យដល់ លុះទៅដល់តណ្ដាលផ្លូវកើតគិតថា ចើយើងនឹងទៅកាយយកបន្ទាយ តេង ហៀន តែមួយគឡូវនេះ សេចក្ដីគាប់ប្រសើរកើមិនដាប្រមាណ ឈ្មោះសំឡេងកើមិនជាល្បីឮខ្ចរទៅខាងមុខគួរតែនឹងលើកទៅកាយយកបន្ទាយឡេងចុះ ជាចំណែកហឯគុនឲ្យបានជាមុនសិន រួចសឹមត្រឡប់ទៅកាយយកបន្ទាយតេងហៀងជាក្រោយ លុះគិតដូច្នោះហើយ កំច្រាប់តាហានឲ្យលើកបកទៅផ្លូវស្ដាំដៃ ច្រាំថ្មនឹងដណ្ដើមយកមុខងារហឯគុន លុះលើកទៅដិតបន្ទាយកំកយតាហានឲ្យឈប់ត្រៀមខ្លួនដើម្បីនឹងចូលច្បាំង ។

មំរើសេះយកសេចក្ដីទៅច្រាប់ឡេងចុះ ។ ដឹងដូច្នោះគំរៀបចំតាហានខុក ហើយចាត់តាហាន ១ កងឲ្យលើកត្រឡប់ទៅចាំកាយតំ

ក្រោយ ។ ឥឡូវ អ៊ុយ អៀន ទំដើរស្រួតទៅ មិនទាន់ក្តីស្រាងក៏នឿយណាស់ ស៊ូនឹងឥឡូវ ខ្សែង ប៉ុន្តែ មិនបាន កំពាញ់ថយបែកខ័ណ្ឌទៅ ។ អ៊ុយអៀន ឃើញឥឡូវតាំងពួងបែកកំញាក់សេះតែ ។ ខ្សែងប៉ុន្តែ បានការកំប៉ាយសេះតាមដេញទៅចម្ងាយប្រហែល ៩០ សិន (៦ គ.ម.) ។

កាល អ៊ុយ អៀន លើកទៅខោះ គេងហៀនដឹងក៏លើកឥឡូវទៅ ចាំស្លាក់នៅលើកំពូលភ្នំ ខណៈ អ៊ុយអៀន បែកតែទៅ គេងហៀនក៏បាសេះបន្តោះឥឡូវចុះពីលើភ្នំដេញតាមទៅ អ៊ុយអៀន បង្ខិបសេះតែដោយកម្លាំង សេះខោះហុលជាន់លើថ្មអិលដួលចុះ អ៊ុយអៀនក៏ភ្លាត់ធ្លាក់ពីលើខ្នងសេះ ។ គេងហៀនបានការ ក៏បំបោលសេះសង្ខុញទៅ លើកលំពែងខ្សែងទឹងចាក់ ខណៈហងតុង លើកឥឡូវទៅដល់ប្រទះគ្នា ឃើញ គេងហៀន ដេញ អ៊ុយហៀន ប្រកិតដំណាស់ លើកលំពែងខ្សែង ហងតុងក៏ស្រែកដោយសម្លេងខ្លាំងថា អញ្ជើញហងតុងឥឡូវនៅឯងនៅទាន់នេះ នរណាតូចបូលមកតស៊ូគ្នា ខ្សែងប៉ុន្តែក៏ដាកទៅតទឹង ហងតុង បាន ៥ ភ្លែង តទល់តុំបានកំញាក់សេះតែ ហងតុងបានចំណាប់ក៏បំបោលសេះដេញឥឡូវទៅចូលទៅ ឥឡូវខ្សែងប៉ុន្តែក៏បែកបាក់ខ្ចាត់ខ្ចាយទៅអស់ ខ្សែងប៉ុន្តែ ទឹងចូលបន្តាយមិនទាន់ ឃើញហងតុង ដេញខ្លាំងពីក្រោយ ក៏ឥឡូវសេះដាកមកតបាន ១០ ភ្លែង ឃើញ

ឥហានហាន់តុងជាប់តាមមកច្រើនណាស់ ប៉ះពាល់ខ្លួនដុំវិញ កំពាញសេះ
រត់តម្រង់ចូលបន្ទាយ តេង់ហៀន ខ្លួលឡៅតីលើកទ័ពដ៏ខ្លួនមកជាកង
ក្រោយ ចូលដណ្តើមយកបន្ទាយ តេង់ហៀន ជាន់មុន ឡេង់ចៅ ក្រឡេក
ទៅឃើញឡៅតីពាក់ក្រោះមាសឈរពីក្រោយ គួនប៉ង់ឈរឆ្ងែង ឡៅ
ហាន់ឈរខាង់ស្តាំស្រែកមកថា អញ្ជើញដណ្តើមយកបន្ទាយជាន់ហើយ
ឯងនឹងរត់ទៅខាង់ណា ឡេង់ចៅពាល់ប្រកន់ដឹងថាកចូលបន្ទាយមិនជាន
កំញាក់សេះវិលទៅតាមប្រកក្ខំ ឌឹងរត់ដម្រង់ទៅស្រុកឡុកសៀ ។

ឥឡូយអៀនថ្ងស់ការ ពាញ់ប្រៀបគេខ្លាំងណាស់ ក៏គិតថាឌឹងធ្វើការ
កែខ្លួនឲ្យជាត់ខ្មាស ហើយតំលើកតាហានខន្ធ្រានដេញតាមឡេង់ចៅទៅ
តាមផ្លូវដែលបែកទៅនោះ ស្រួតរូតទៅស្ទាក់ពីមុខ ហើយឲ្យតាហានយក
ព្រួចធ្នង់សន្ធឹងកំងផ្លូវ សេះឡេង់ចៅចាលទៅប៉ះលើព្រួកដួលចុះឆ្លាក់ឡេង
ចៅពីលើសេះ ក៏នាំគ្នាស៊ុះចូលទៅព្រួតចាប់ខ្លួនបានចង់នាំមក កាលឡៅតី
បានបន្ទាយ តេង់ហៀន ហើយក៏ឲ្យចាវែកអក្សរទៅខង់សេចក្តីថា កុំឲ្យ
នរណាធ្វើខុកខុបម្នាក់ឲ្យអន្តរាយដ៏វែងឡើយ បើនរណាហើយ
មិនស្តាប់ឌឹងយកខ្លួនធ្វើទោសប្រហារជីវិតតាមគ្នា លុះចាវែកអក្សរហើយ
ក៏លើកខង់ដោតឡើងនៅមុខបន្ទាយ ហើយក៏និយោយឌឹងតាហានឡេង់ចៅ
ឌឹងតេង់ហៀន ដែលចាប់បាននោះមកថា អស់អ្នកកាល់គ្នាដែលជាឈ្លើយ
យើងនេះ បើនរណាមានចិត្តគិតចង់នៅធ្វើការជាមួយឌឹងយើងចូរនៅ

ចុះ បើនរណាខឹងចង់រៀបចៅស្រុកវិញ គ្រោះទឹករលឹកដល់មាតាបិតាញាតិ
គាបង្អួនក៏ឲ្យរៀបចៅចុះ មនុស្សពួកនោះបានទុកាសដូច្នោះហើយ ណា
ដែលនឹកដល់ចុត្រកំយោបង្អួនក៏គំនាប់លាឡៅពីចៅ បណ្តាមនុស្សដែល
មានចិត្តស្រឡាញ់ ក៏នាំគ្នាសរសើរឡៅពីខ្លួនខ្លាចៅពេញក្នុងស្រុក ។

ហង់តុងបានដំយ៉ាងនេះហើយ ក៏ចូលទៅគំនាប់ឡៅពីដំកបថា ឥឡូវ
អ៊ុយអៀនធ្វើខុសថ្នស់ការធំឯបញ្ជាមិត្រមែកវត់មកដូច្នេះ លុះនឹងមិនយក
ទោស បើអំណោះតទៅមុខ ការសង្គ្រាមក៏រមែងមានដម្រាប់ជាខម្ងាប់
ដូច្នេះឲ្យខុសនឹងច្បាប់មេព័ទ ឥហានតាំងពួងនឹងយកតម្រាប់តាម សុំឲ្យ
លោកប្រហារជីវិតវាចេញទើបត្រូវ ឡៅពីក៏ប្រើឥហានឲ្យទៅកេហៅខ្លួន
អ៊ុយអៀន ខ្លួលអ៊ុយអៀនចង់ឡែងចៅនាំចូលមកគំនាប់ឡៅពី ។ ថា
ខ្លួនអ្នកឯងមានទោសជាខមួនជួនណាស់ តែគ្រានេះ ហាក់តែអ្នកឯងធ្វើការ
កែខ្លួនចាប់ឡែងចៅបានទ ជាយើងត្រូវលើកទោសចោល ពីថ្ងៃនេះតទៅ
មុខបើនឹងធ្វើការអ្វីកុំគាបប្បីធ្វើឲ្យខាស់ខែងវ្វែងគំនិតគ្នា កុំធ្វើការវែកយកតែ
មុខរបស់ខ្លួនលើកខ្លួនថា គ្រាន់បើជាងគេដូចជាគ្រានេះ ដែលអ្នកឯងរួចពី
សេចក្តីស្លាប់នោះ មិនពីព្រោះហង់តុងទៅជួយទេឬ? ឥឡូវត្រូវតែទៅគំនាប់
ហង់តុងតាមប្រពៃណី អ៊ុយអៀន កំគំនាប់ហង់តុងសុំទោស ឡៅពី
ក៏ឲ្យចំណាប់ភ្នាន់ដល់ហង់តុងជាច្រើន ហើយក៏ឲ្យឥហាននាំយកខ្លួន
ឡែងចៅចូលមក ឡៅពីក៏ចុះទៅស្រាយចំណងដែលចង់នោះចេញ រួច

ឲ្យរៀបតុលៀងអាហារហើយសួរថា អ្នកឯងនឹងស្នាក់ត្រង់ណាក៏នឹងយើង
ឬប្រការម្តេច ?

ឡេងចៅដាបថា ដំរីតូចបានដល់ស្វាប់ហើយ លោកមានសេចក្តី
ករុណាពុកអាយុឲ្យរស់នៅត្រានេះ ព្រះគេជព្រះគុណនឹងរកទីបំផុតគ្មាន ខ្ញុំ
បាទនឹងសូមធ្វើការស្នងគុណលោកតទៅ ដែលនឹងមានចិត្តគិតប្រែពីលោក
ទៅវិញគ្មាន ឥឡូវខៀវយឹម ឡៅកុយ ដែលមកតាំងបន្ទាយនៅស្រុក
ឡុកសៀនោះហើយនឹងខ្ញុំបាទជាមនុស្សចិត្តមួយនឹងគ្នា បើលោកករុណា
លែងខ្ញុំបាទឲ្យទៅ ខ្ញុំបាទក៏នឹងទៅនិយាយបញ្ចុះបញ្ចូលអ្នកតាំងពីរឲ្យមក
ស្វាមីភក្តីនៅនឹងលោក ដើម្បីនឹងជួយគិតការតទៅឲ្យបានស្រុកឡុកសៀ
មកជាកំណាន់របស់លោក ឡៅពីមានសេចក្តីត្រេកអរ ក៏ឲ្យអាវសំពត់នឹង
ផ្ទាន់ទៅឡេងចៅហើយថា អ្នកឯងនិយាយពុកទៅមុខ កុំឲ្យត្រឡប់ពាក្យ
សំដីឲ្យមនុស្សខ្សោយ ហើយក៏បើកឲ្យឡេងចៅទៅស្រុកឡុកសៀ ។

អ៊ុយសៀនដំកបឡៅពីថា ដែលនឹងបើកខ្លួនឡេងចៅឲ្យត្រឡប់ទៅ
វិញវេលានេះ ខ្ញុំបាទយល់ឃើញថា បើវាទៅហើយមិនមែនត្រឡប់មក
វិញទេ ឡៅពីថា ខ្លួនយើងមានចិត្តអាណិតជួយដំរីតេត មិនត្រូវនឹងធ្វើ
តេឲ្យវិនាស បើតេមិនតិតដល់គុណកិតាមបុណ្យចុះ នឹងឃាត់ឃាំង
យោងពុកប្រយោជន៍អ្វីឲ្យតេទៅចុះ ឡេងចៅតំនាប់លាឡៅពីហើយក៏
តម្រង់ទៅស្រុកឡុកសៀ ហើយនិយាយប្រាប់ឡៅកុយថា បានធ្វើ

សង្គ្រាមតនឹងខ្លៅពីជាសន្ធឹកសន្ធាប់ណាស់ សម្លាប់ទាហានឯកខ្លៅពី
ស្លាប់អស់ ១០ នាក់ សត្រូវមានកម្លាំងច្រើនលើសលុបខ្លាំងពុំឈ្នះ
បានដាច់ខាតខ្លួនមកតែម្នាក់ឯង ខ្លៅកុយសំគាល់ថាពិតកំពឹតតែតម្លាំង
ណាស់ ទើបចាត់ប៉ើខ្សែគាន់សំបុត្រទៅដល់ខ្លៅដឿងសុំកងទ័ពឲ្យលើក
មកជួយ ។

ខ្លៅដឿងដឹងក្នុងសំបុត្រថា តេងហៀនស្លាប់ បន្ទាយប្រកបដ្ឋៀត
តំបែកបានទៅសត្រូវ ខ្លៅដឿងខ្ញុតព្រួយណាស់ ក៏ឲ្យហៅនាហ៊ឹន
ភ្នាក់ងារចូលមកប្រឹក្សាពជការ ខ្លៅឈុនជាកូនដំបងថា ខ្ញុំបាទនឹងសុំ
លើកទាហានទៅរក្សាស្រុកឡុងសឿងកុំឲ្យអន្តរាយ ខ្លៅដឿងសួរថា
ខ្លួនឯងលើកទ័ពទៅគ្រានេះក៏ស្រួលណាស់ហើយ តែថានឹងបាននរណា
ទៅតំដរជាមីប្រឹក្សាជាមួយផង គឺអ៊ុយយ៉ាយខ្លៅដឿងសុំខ្លួលអាសា
ទៅជាមួយ ខ្លៅដឿងមានអំណរណាស់ថា បើដូច្នោះចូលឲ្យអ្នកចាត់
ទាហានឯង ៦ នាយចេញទៅជាមួយផង ដ៏អ៊ុកចាត់លុយគង ដ៏ឡាន
២ នាក់ជាទាហានឯង នឹងពួកកូន ២ ម៉ឺនឲ្យទៅខ្លៅឈុនស្រេចហើយ
ក៏លើកទៅដល់ស្រុកឡុកសៀ ។

(នៅមានត)

រឿងល្បែកឡាហ្វុងតែន

លោក ង៉ែន - ន្រ្តីរៃប្រៃរៀបរៀង

(តទៅ)

៥៤- ភ្នែកនៃនាយហៅហ្សាយ

មានក្តាន់មួយក្រូវគេដេញ ក៏រត់មកសុំគោជ្រកនៅទីធ្លាក្រោលជាមួយផង ហើយនិយាយអង្វរពួកគោថា: «នែបងទាំងឡាយ! សូមបងមេត្តាកុំឲ្យដាំណឹងនេះដល់គេឯងឲ្យសោះ អំពើដែលបងទាំងឡាយបានធ្វើដើម្បីជួយលាក់ខ្ញុំនៅពីនេះ មិនមែនគ្មានប្រយោជន៍ឡើយ ហើយមិនទាំងឲ្យមានការស្តាយក្រោយទេ ព្រោះខ្ញុំមានស្គាល់ភ្នែងមានស្មៅខ្ចីលាស់ល្អជាងភ្នែងឯទៀត» ។

ពួកគោបានសន្យាជួយចំចែចំចាំងរឿងនេះ មិនឲ្យអ្នកណាដឹង ។ ក្តាន់លាក់ខ្លួនពួនអាក្រានៅត្រង់ភ្នែតមួយជាសុខ ។ ពេលល្ងាច គេយកស្មៅខ្ចីទឹងមកដាក់ឲ្យគោជាការរាល់ថ្ងៃ ។ គេទៅ គេមក ពួកឈ្លបាទាំងប៉ុន្មានដើរមួយរយដុំ មេតម្រួតក៏ដែរ គ្មាននរណាម្នាក់បានឃើញក្តាន់សោះ ។ ក្តាន់មានសេចក្តីត្រេកអរចំពោះគោពន់ពេក ហើយនឹកថា ចាំពេលណាស្រួល គឺពេលដែលគេចេញក្សេមស្រែទឹងលួចគេចេញទៅព្រៃ ។ គោមួយទំពាអៀនបណ្តើរនិយាយថា «ជួបសព្វថ្ងៃនេះស្រួលហើយ តែប្រយ័ត្នកុំឲ្យតែមនុស្សក្អែក ។ រយមកត្រួតម៉ែល ខ្ញុំមាន

សេចក្តីថ្លាមេដួងចន្ទគ្មានឯងម៉ុះទេ ខ្លាចក្រែងតែមនុស្សហ្នឹងមក តាំងពីដើមដល់ពេលនេះល្អហើយ តែបងឯងកុំអាលទុកចិត្តឲ្យសោះ» ។

គ្រាន់តែគោនោះនិយាយហើយក្ងាម ម្ចាស់ទ្រព្យមកដល់ ដើរពិនិត្យមើលហើយស្តីបន្ទោសកូនឈ្លបថា «ហេតុអ្វីក៏ដូច្នេះ? ចុះស្មៀកក៏តិចម្ល៉ះនៅក្នុងក្រដាសនេះនែ! បងម្ល៉ឹងនេះចាស់លួយអស់ហើយ ចូរឯងទៅយកចំបើងថ្មីធាប់ៗមក តាំងថ្ងៃនេះទៅ ត្រូវទំប្រើងថែសត្វតាមនេះឲ្យស្អាតគួរសមមែនទែន អញមិនចង់ឃើញសោះកន្ទិកកន្ទក់ ចុះបើបាសសរសៃតិងតាងចេញ តើរកឯណាយកថ្មីគ្មានទៅ! គ្មានចេះរៀបចំនឹមនឹងវាមុនទុកឲ្យល្អសោះ» ។ កំពុងតែមើលមើល ស្រាប់តែក្រឡេកទៅឃើញក្បាលមួយ ចេញពីក្បាលគោធម្មតា តេកស្គាល់ច្បាស់ជាក្តាន់ជាក់ ។ ដំបងមួយម្ខាក់សំពង់ក្តាន់ស្ងាប់ទៅ ។

គ្មានអ្វីតូចតែជាងកែកនាយទៅហ្វាយឡើយ ។

៥៥- អ្នកស្រែ កូនធឹងសត្វលា

មានអ្នកស្រែម្នាក់ ធឹងកូនប្រុសអាយុ ១៥ ឆ្នាំ ដឹកលាមួយទៅលក់នៅបុណ្យពិពណិ (Foire) ។ ដើម្បីកុំឲ្យលាស្គម ឲ្យនៅជាត់ល្អ លក់បានថ្លៃ ឪពុកធឹងកូនន៎ាគ្មានដេរដាសលា ហើយសែនដូចគោមរយ៉ា ។ ឧ ប្តូលអកុសល! ប្តូលល្ងីល្ងើគ្មានដឹងអ្វីសោះ ។ អ្នកខ័ ១ ដើរមកប្រទះ

អស់សំណើច ហើយពោលថា: «ចុះបុរសខាងនេះនាំគ្នាលេងកំផ្លែងអ្វីដូច្នេះ? កុងបណ្តាអាខាងបី អាមួយដែលល្ងីល្ងើជាងគេ មិនមែនអាដែងដែលគេតិតខុកមកនោះទេ» ។

ឮសំដីតែប៉ុណ្ណោះ អ្នកស្រែជំនួនភ្ញាមអំពីភាពល្ងង់ខៃអាគ្នា ក៏ស្រាយលាឲ្យដើរដូចធម្មតា ។ លាបានដើរស្រួល គាំងស្រែកលេងសប្បាយ ។ អ្នកស្រែមិនបានជាគិត ក៏ឲ្យកូនដំរើលា ហើយខ្លួនដើរតាមក្រោយ ។ ទេសកាលអ្វី ស្រាប់តែមានឈ្មួញជំនាត់ដើរមក ។ ទស្សនីយភាពនេះ នាំឲ្យគេចាស់ចិត្ត ។ ម្នាក់ដែលចំណាស់ជាងគេស្រែកឲ្យអាកូនថា: «ខែ! ចុះចេញកុំឲ្យគេនិយាយថាទំនុកអ្នកតំរើដែលបណ្តើរអ្នកចំរើតុកចង្កាប្រផែះ! ឯងត្រូវដើរតាមក្រោយ ហើយចាស់ដៃទើបសម» ។

អ្នកស្រែនិយាយថា «អស់លោកខាងឆ្ងាយ! ខ្ញុំនឹងធ្វើតម្រូវចិត្តលោក» ។

អាកូនចុះដើរដើ ហើយឥតុកដំម្តង ។ ស្រាប់តែមានស្រីក្រមុំ៣នាក់ដើរមកទៀត ខាងម្នាក់ពោលថា: «ខ! គួរឲ្យខ្មាស់អ្វីម្ល៉ះទេ ចូរមើលចុះ ទៅជាឲ្យបងកំព្រាះនេះដើរបកដើងអស់ ចំណែកតាចាស់ម្យ៉ាងទៀតនេះអង្គុយដូចសង្ឃភជផ្លែប្តីនៅលើខ្នងលា ហើយទឹកស្មានថាគាត់ជាមនុស្សត្រឹមត្រូវ» ។

អ្នកស្រែតោលតបថា: «ចំណាស់ខ្ញុំនេះ ឈប់មានការធ្វើឫកតាខៀតហើយ ម្ចាលនាងក្រមុំ សូមអញ្ជើញទៅចុះ ហើយសូមជឿស្តាប់ខ្ញុំផង» ។

ខាងក្រោយការតោលចំអកចំអន់-ចំអកឡកឡឺយគ្នាទៅវិញទៅមក អ្នកស្រែដោយស្មានថាខ្លួនខុស គឺហៅកូនឲ្យឡើងដំរែពីក្រោយ ។

បរទៅបានប្រមាណ ៣០ ជំហាន ត្រូវក្រុមទី ៣ តោលរិះគន់ខៀត ។ អ្នកម្នាក់ស្តីឲ្យថា: «បុគ្គលទាំងពីរនាក់នេះសុទ្ធសឹងជាមនុស្សឆ្កួត បើដំរែយ៉ាងនេះ លាមុខជាមិនអាចត្រាំបានឡើយ មុខជានឹងស្ងាប់ដោយការដំរែនេះមិនខាន ។ អ៎ា ម្តេចក៏ផ្តុំគ្នាតំសត់យ៉ាងដូច្នេះ នេះចំជាគ្មានអាណិតអាសូរដល់សត្វចំរើចាស់ជរាសោះឬ? នេះប្រាកដជាយកតែស្បែកលាទៅលក់ឯបុណ្យតិចណាជាមិនខាន» ។

អ្នកស្រែលាន់មាត់ថា «ឧត្តុង្គោអើយ! អ្នកណាដែលមានចិត្តចង់ធ្វើតម្រាតាមចំណង់មនុស្សគ្រប់ៗគ្នាអស់ ចំជាមនុស្សឆ្កួតសុទ្ធសោធ។ ប៉ុន្តែ ត្រូវល្បងធ្វើតាមមួយបែបនេះទៀតចុះ ក្រែងលោយើងសម្រេចដល់ត្រើយ»។

អ្នកស្រែនឹងកូនក៏ចុះចេញពីលា ។ សត្វនេះបានធូរកម្លាំង ដើរតែឯង បែបអ្នកជំ ពីខាងមុខបុរសនឹងកូន ។

ស្រាប់តែមានការជើងវិលម្នាក់ដើរមកជួបទៀត ហើយស្រែកឲ្យថា «តើរបៀបសម័យ គេឲ្យលាដើរគោងអើយ ហើយម្ចាស់ដើរទាំងវេទនា

ដូច្នេះឬ ? អ្នកណាដែលកើតមក ដើម្បីឲ្យគេតឹងតែង់ឡាំង តើជាសត្វលាឬជាម្ចាស់លា ? ដូច្នេះខ្ញុំសូមឲ្យដំបូន្មានថាត្រូវយកលាដាក់ក្នុងហិបទុកគោរព ហើយទាំងគ្រាពង្រីចស្បែកដើងរៀងខ្លួន រួចរក្សាលាទុកឲ្យនៅល្អស្រួលហើយ » ! . . .

អ្នកស្រែឆ្លើយថា : « ខ្ញុំដាលាកំពិតមែនហើយ ខ្ញុំនឹងមតាម ខ្ញុំយ៉ាមខ្លួចលោកគាត់ថាលោកនិយាយត្រូវ តែពីពេលនេះទៅ បើបេះគេបន្ទោសខ្ញុំក្តី គេសរសើរខ្ញុំក្តី ឬគេនិយាយដូចម្តេចក្តី គេមិននិយាយអ្វីក្តី ខ្ញុំត្រូវធ្វើតាមតែចិត្តខ្ញុំ » ។

៥៦- មនុស្សពាលនឹងមនុស្សស្បថប្រុរស

មានអាពាលម្នាក់ដេញាចោលអ្នកសម្បថប្រុរសនឹងថ្ម ។ អ្នកនេះដាកមកហើយគោលថា : នែ ! សំឡាញ់ ឯងធ្វើនេះពិតជាត្រូវល្អហើយ ចូរយកប្រាក់ប៉ុណ្ណេះទៅចាយចុះ ឯងប្រសប់មែន ធ្វើតិចបានចំណេញច្រើន រីតតែងគោលថា : ត្រប់ការងារខ្ញុំឯងអស់ រមែងតែបានផ្លែផ្ការ ។ ខ្ញុំ+ មនុស្សខ្មោះមកខ្មៀតហើយ គេមានប្រាក់ច្រើនសម្រាប់ឲ្យឯង ប្រសិនឯងចោលគេខ្មៀតទៅ មុខជានឹងបានផ្លែផ្ការមិនខាន » ។

ដោយញាំមនឹងបានចំណេញ អាពាលយើងស្ទុះត្រែតចោលម៉ាងឯ

ថែមទាំងដេរផង ។ ពេលនេះ គេមិនឲ្យរង្វាន់ជាប្រាក់ ឬតអ្នកចំរើ
គេ រត់ឈូរមក ចាប់អាតាលជាប់ហើយលែងក្បាល ឆ្អឹងដំនឹរ ឥឥ្ឌន
ប៉ុន្មានដំបងគ្រប់ៗគ្នា ធ្វើឲ្យអាតាលដិតដល់ថ្ងៃអន្លា ។

៥៣- ខ្លាឃ្មុំនឹងតាចាស់

តាចាស់ម្នាក់ នឹងខ្លាឃ្មុំមួយទៅរួមសុខទុក្ខជាមួយគ្នាកន្លងហាន:ជាមិត្រ
សំឡាញ់ ។ តាចាស់ធ្វើការងារបស់គាត់ ឯខ្លាឃ្មុំទៅរកចាប់សត្វយក
មកធ្វើជាអាហារ ហើយភូតែខាងដេញ:យមិនឲ្យទំពាមសំឡាញ់ឯ ។

ថ្ងៃមួយ តាចាស់ដេកលក់ មានរុយមួយហើរមកទំច្រមុះតា ។ ខ្លា
ឃ្មុំយើញហើយក្តៅចិត្ត ទំដេញៗទៅហើរមកៗ ខ្លាឃ្មុំនឹកក្នុងចិត្តថា «អញ
ចាប់តាឯងឲ្យបានឥឡូវ» ខ្លាឃ្មុំចិត្តស្មោះត្រង់ ស្ទុះចាប់ថ្មមួយដុំ គុបប៉ុងលែក
ក្បាលតាចាស់ខ្ទេចតាំងរុយផង ។

គ្មានអ្វីនាំឲ្យមានគ្រោះភ័យជាងមិត្រសំឡាញ់ល្ងង់ឡើង ។

បើមនុស្សស្រួលសប្បុរសជាសត្រូវគ្រាន់បើជាជាង ។

(នៅមានត)

(តទៅ)

រឿង មេងគីយាង-ឌីយ៉ូ

6ème Meng Kiang-Niu

រឿងត្រួងជាតិហាន់

នាងមេងគីយាង-ឌីយ៉ូ ក៏បន្តដំណើរទៅទៀត ។ លុះកាលចូលព្រៃ លុះព្រៃឡើងទៅលើភ្នំ, កាត់ជ្រោះបព្វតា . . . នាងដើរ . . .នាងទំដើរទាល់តែដល់កំពែងធំត្រួងចិនតាមុខ ។ នាង កាលក្រឡេកទៅឃើញកំពែង នាងមានចិត្តគក់ស្ញូតរន្ធត់ឥតឧបមា ។ កំពែងធំនោះ មើលទៅប្រហែលដូចជាពស់ថ្ងាន់ធំលួនលើកំពូលភ្នំ ។ ទៅលើតំរែតំរង់ឡាយគ្មានរុក្ខជាតិមួយដើម មានតែស្មៅរំលៀវលៀ ក្រោចបាតបត់ ឆាំឡូលក្រៃជាត់រងាមត ។ ពួកកម្មករម៉ែរដេរជាសទៅដើរតំពែងនោះ ។

នាងមេងគីយាង-ឌីយ៉ូដើរសួរសៀរតាមដើរមហាកំពែង ហើយសាកសួរគេថា តើស្វាមីនាងនាមវ៉ាងហ្ស៊ីលាង ស្ថិតនៅទីណា ធ្វើការនៅកន្លែងណា? គ្មានអ្នកណាតបមកនាង គ្មានអ្នកណាស្គាល់ នាងក៏ត្រាច់ដើរសួរគេអស់កាលដ៏យូរ ។ នាងបានក្រឡេកទៅឃើញមនុស្សដែលធ្វើការទៅទីនោះមានមុខស្លឹតស្វាំង មានពន្លកាយស្គម ។ ជួនកាល នាងជួបប្រទះនឹងសាកសពដេកទៅលើផែនដី ។ នាងក៏កាន់តែថប់ព្រួយបារម្ភយ៉ាងខ្លាំង ។ នាងគិតក្នុងចិត្តថា គ្មានអ្នកណាស្គាល់ស្វាមីនាង! នាងក៏ស្រក់ទឹកភ្នែក

យ៉ាងខ្លាំងស្រាកស្រាលឡើយស្អាមនាង ។ តែមិនយូរប៉ុន្មានខាងក៏ជាន
ដឹងទៀតមានដំណឹងតក្រាកដថា : ស្អាមនាងខលួសអនិច្ចកម្មទៅហើយហើយ
សាកសពគេយកទៅកប់ក្រោមមហាកំពែងត្រង់កន្លែង ដែលគាត់ធ្លាក់
ពីលើមកស្លាប់នោះ ។

នាងបានដំណឹងដ៏អាក្រក់នោះភ្លាម បេះដូងនាងដូចប្រេះជាច្រើនចំណែក
ភាគ នាងយំខ្លាំងស្រែកឮក្រៃលែងលួសអួលអាក់អាល់តែដួលសន្លប់ផ្ទាត់ស្មា-
រតី ។ អ្នកចាំងក្បាយក៏មកជួយថែទាំនាងឲ្យនាងភ្ញាក់ស្មារតីឡើង ។
លុះនាងភ្ញាក់បានដឹងខ្លួនឡើង នាងយំខ្លាំងថែមទៀត . . . នាងយំយ៉ាង
ខ្លាំងពាន់ប្រមាណជាលើតែមហាកំពែងរលំនោះចម្ងាយ ២០០ គីឡូម៉ែត្រ
ហើយមានឮសំលេងកំបុកគ្នើរៗរាប់ខនឹងឮឲ្យរបេះពីមហាកំពែង . . . ។

ដំណឹងខុសពីធម្មតាផ្សាយទៅតាមសេញ្ញាថា : « ស្រីនៃការសោយ
សោកនាងមេងគីយាង-ឌីយូធ្លើឲ្យរលំមហាកំពែង» ។ តទៅទៀត ដំណឹង
នោះផ្សាយទៅដល់ព្រះចៅអធិកជចិន ព្រះអង្គទ្រង់ស្តេចយាងទៅកាន់ទី
នោះ ទ្រង់បានទតទៅឃើញនាងមេងគីយាង-ឌីយូ មានរូបឆោមលោម
ពណិស្រស់ច្រមុះប្រិយ ទ្រង់ក៏ចង់យកធ្វើជាព្រះស្នំព្រះអគ្គ ។ នាងមេង
គីយាង-ឌីយូ មានចិត្តស្អប់ព្រះចៅអធិកជពន់ពេក ។ នាងគិត
ក្នុងចិត្តថា មិនព្រមខលួសធ្វើជាព្រះស្នំព្រះចៅអធិកជសោះឡើយ ។
តែនាងមានគំនិតឈ្លាសយល់មួយបែបទៀត ទើបនាងក៏ប្រែក្រឡាចិត្តលែង

ស្តេចព្រះចៅអធិកជទៅវិញ នាងក៏ក្រាបបង្គំទូលតបទៅព្រះចៅអធិកជ
វិញដោយសូរសំឡេងផ្អែមល្ហែមថា :

« ខ្ញុំម្ចាស់ចង់ធ្វើព្រះសុំនៃព្រះអង្គដែរ តែសូមព្រះអង្គទ្រង់ព្រះពាជ-
ឧញ្ញាតឲ្យខ្ញុំម្ចាស់សូមតាតើព្រះអង្គបីយ៉ាង » ។

ព្រះចៅអធិកជទ្រង់មានព្រះបន្ទូលថា :

« តើសំណូមពរនោះយ៉ាងណាទៅ ? សូមនាងប្រាប់មកយើង » ។

នាងមេងគីយាង-ឌីយូ ក្រាបបង្គំទូលព្រះចៅអធិកជថា :

សូមទ្រង់ព្រះមេត្តាប្រោស សំណូមពរទីមួយសូមព្រះអង្គមានព្រះ
ពាជបញ្ជាឲ្យយកសាកសពស្វាមីខ្ញុំម្ចាស់ដាក់ក្នុងម្សៅមានតួជាមាសតម្រប
ជាប្រាក់ ។ សំណូមពរទីពីរ គឺខ្ញុំម្ចាស់សូមឲ្យរដ្ឋមន្ត្រីទីឆ្នើមទៅនៃព្រះ
អង្គ ចូលទៅជួបជុំមកក្នុងពិធីបុណ្យសពនេះ ដោយស្លៀកពាក់កាន់ទុក្ខជាំង
អស់គ្នា ។ សំណូមពរទីបី គឺខ្ញុំម្ចាស់សូមឲ្យទ្រង់ស្តេចយាងរៀបសពដោយ
ព្រះអង្គឯង រហូតដល់ស្ថូបដ្ឋាន ដោយទ្រង់ស្លៀកពាក់សរសៃដើមកញ្ចា
ហើយព្រះហស្តកាន់ដំបងកាន់ទុក្ខ » ។

ព្រះចៅអធិកជទ្រង់យល់ព្រមតាមសំណូមពរនាង ។

ពិធីបុណ្យសពស្វាមីនាងនាមក៏ដ៏ហ្វ្រីលាង កំពុងប្រព្រឹត្តទៅតាម
ប៉ំណាងនាងតាំងអស់៧ថ្ងៃ ។ ព្រះចៅអធិកជ ទ្រង់ស្តេចយាងព័ទ្ធ
ម្សៅសព រដ្ឋមន្ត្រីតាំងឡាយទីនីមេទ័ពដើរតើរក្រោយក្បួនដង្ហែ ។ ព្រះ

ទៅអធិពរទ្រង់ទឹកក្នុងព្រះឱយថា មុខជាទឹងឯងមេងតីយាង-ទីយូ
ធ្វើជាព្រះស្តេចព្រះអង្គមិនខាន ។

ក្រោយដែលឯងបំពេញកិច្ចរួចជាស្រេច នាងមេងតីយាង-ទីយូ
សែនឲ្យស្វាមី រួចនាងយំខ្លួញសោកលើផ្ទៃស្វាមីអស់កាលយ៉ាងយូរ រួចនាង
រៀបត្រឡប់ខ្លួនមកក្រោយ នាងលោតទៅកន្លងទឹកទន្លេដែលហូរដែតស្តួប-
ដ្ឋានខោះ ។ ព្រះទៅអធិពរ ទ្រង់ព្រះក្រោធជាខ្លាំង ទ្រង់មានព្រះពរ
បញ្ជាឲ្យពួកអាមាត្យលោតទៅចាប់នាងស្រង់ពីទឹក តែមុនទឹងពួកនេះទៅ
ដល់នាង ។ ប្រែកាឡាខ្លួនទៅជាត្រីមានតណាសដូចប្រាក់ ។ ត្រីនោះក៏
ហែលទៅកន្លងទឹកសមុទ្រភ្លាត់ទៅ ។

ចប់រឿងនាងមេងតីយាង-ទីយូតែប៉ុណ្ណោះ ទៅមានរឿងទី ៧ គឺ:
រឿងបឹងអូលីវ៉ាយេតទៅទៀត ។

បិត្តល្មោភលោភតណ្ហាប្រាជ្ញាអន់
មិនជិនឆ្អន់គាប់បិត្តតែម្រាប
ឃើញស្រីល្អកបនោមពាំយ៉ាងស្អាត
ទំលង្វាតគោរព អាប់រស្មី ។

ជំយិងដែលដុះដោយយុត្តិធម៌របស់ខ្មែរនៅតុលាការអន្តរជាតិ

អំពីរឿងព្រះវិហារ

(តមក)

នៅថ្ងៃបញ្ចប់ថ្ងៃទី ១៥ មេសា ១៩៦១ ដែលតុលាការអន្តរជាតិ ចាន់បញ្ចប់នីតិវិធីដែលដែកតក៏ដេញដោលមាត់ទេ ក្រោយដែលលោកទី ប្រឹក្សាអានអាឈឺសុន ចាន់ឡើងដោះសាតបន្តើយតាត់ចោលខ្លួនសំអាង របស់ ថៃតែងរឿងអ៊ីស្រាអែល-ប៊ុលហ្គារីមក លោក ត្រឿង-គាង ភ្ញាក់-ផ្អើលរកដង្ហើតិចាលខ្មែរយើង ចាន់ឡើងបញ្ជាក់សេចក្តីសង្កេតជាខ្លួនឯ ។

លោក ត្រឿង-គាង ថ្លែងជាអង់ថា:

លោក ចាន់ហ្គាន ន៏ងអស់លោកចៅក្រម ចំពោះប្រទេសដូចជា កម្ពុជានេះ ច្បាប់អន្តរជាតិ (Droit international) បើសិនជាយើង តិចិត្តតែផ្លូវបច្ចេកទេសនៃរឿងនេះ យើញហាក់ដូចជាបិតនៅឆ្ងាយបន្តិច តួន តែលជាបឋមគោះ ពីព្រោះច្បាប់នេះចាន់ធ្វើឡើងដោយប្រជាជាតិដែល រស់នៅតួនវង្វែអារ្យធម៌ ន៏ងវប្បធម៌ ផ្សេងពីប្រទេសកម្ពុជា ។

តំប៉ុន្តែ ដោយមកជាប់ពាក់ព័ន្ធប្រទះច្បាប់អន្តរជាតិយ៉ាងជ្រាលជ្រៅ នៅតាមផ្លូវខ្លួន រដ្ឋបុរសនីតិជនខ្មែរ (Juriste Cambodgien) តុំមានភ្ញាក់ ផ្អើលដល់បន្តិចសោះ ព្រោះថាក្រុមញាតិនៃប្រជាជាតិមានតែមួយទេ ។ គោលការណ៍ធំ ៗ ដែលរៀបចំចាត់ចែងច្បាប់អន្តរជាតិ មានសម្ងួនជាប់នៅ



សម្តេចព្រះប្រមុខរាជ្យ ទ្រង់កំពុងសន្ទនាយ៉ាងរីករាយជាមួយនឹងសម្តេចព្រះសង្ឃនាយកទាំងពីរគណៈ ក្នុងឧកាសព្រះរាជទ្យនិវេសកម្មនៅប្រាសាទព្រះវិហារ នៅថ្ងៃទី ៥-២-៦៣



សម្តេចព្រះនរោត្តម - ស៊ីហនុព្រះប្រមុខរដ្ឋទ្រង់កំពុងមានព្រះបន្ទូលជាទីសណ្តាប់ធ្នាប់អង្គរួច
នាំ នឹងប្រជាពលរដ្ឋជាច្រើនលើអំពីទីធ្លាភាពផ្សែង ។ ឯភ្នំព្រះវិហារ ក្នុងឱកាសព្រះរាជបូជនីយ
យោសកម្មនៅថ្ងៃទី ៥-២-៦៣ នាភ្នំនេះ ។



សម្តេចទី នឹងឯកឧត្តមអ្នកឧកញ៉ាសុគន្ធបាលនាយករដ្ឋមន្ត្រី កំពុងស្តេចយាងទតប្លុកណាគ្រាសាទសិលាព្រះ
វិហារភ្លុងទាសព្រះភជ្ជផនយោធ ថ្ងៃទី ៥-២-៦៣

ក្នុងអារ្យធម៌យ៉ាងចាស់ទុំនៃអាស៊ីយើង ។

តើគោលការណ៍អ្វីខ្លះ ដែលរឿងបច្ចុប្បន្ននេះ ត្រូវបានចាត់ឡើង? ។

គោលការណ៍នោះ យើងយល់ថា មានពីរយ៉ាង: គឺគោលការណ៍ខាងការគោរពសំដីដែលបានតាលឡើង និងគោលការណ៍ខាងភាពជាបន្តអចិន្ត្រៃនៃរដ្ឋ (Respect de la parole donnée et continuité de l'Etat)។

ការគោរពជាស់សំដីដែលបានតាលឡើង ជាមូលដ្ឋាននៃច្បាប់ខ្មែរ តោះបើនៅក្នុងការគាត់ខងជាផ្លូវសាធារណៈ តែដូចជាក្នុងការគាត់ខងផ្លូវឯកជនដែរ ។

បទបញ្ញត្តិមួយនៃអត្ថបទឯកសារបុរាណាចារ្យរបស់យើង ដែលអាដេម៉ាឡឺក្លែរ (Adhémar Leclere) (les codes Cambodgiens 18 19...) បានបញ្ជាក់ហើយស្រេចថា: « ព្រះមហាក្សត្រ ទឹងមន្ត្រី ត្រង់មានព្រះបន្ទូលតែមួយ ទឹងមានសំដីតែមួយ ។

ជំនៀងនៃសំដីនេះ បានទាំងជំរៅនៃគំនិត គឺទឹកចិត្តដែលបានបញ្ជាក់ឲ្យឃើញច្បាស់ឡើងនោះ មានប្រៀបធំជាងទម្រង់ការខាងក្រៅ ។ តាំងពីសតវត្សទី ១៦ មក ច្បាប់ខ្មែរមានចែងអំពីកិច្ចសន្យារវាងឯកជនដែលកើតឡើងដោយសារតែសេចក្តីសម្រេចចិត្តរបស់ខ្លួន ដូចជាខាងការលក់ ខាងការជួល ខាងការខ្ចីជាដើម (Jean Imbert: Histoire des Institutions khmères) ។ ហេតុដូច្នេះ ការដែលប្រទេសកម្ពុជាបានតាំងថា

តុលាការអន្តរជាតិមានសមត្ថកិច្ចនឹងដំនុំដំរេរឿងនេះ គឺមិនមែនគ្រាន់តែធ្វើ
ឡើងដើម្បីប្រយោជន៍នៃហេតុ របស់ខ្លួនតែប៉ុណ្ណោះទេ គឺជាកិច្ចមួយស្រប
តាមធម្មជាតិនៃទម្លាប់របស់ប្រទេសជាតិខ្លួនឯង ។

នៅមានគោលការណ៍មួយទៀត ដែលច្បាប់ខ្មែរបានដាក់ទង់ជាខ្លាំងណាស់ដែរ គឺគោលការណ៍អំពីភាពជាអចិន្ត្រៃយ៍នៃរដ្ឋ (Permanence de l'Etat) ។ ច្បាប់ខ្មែរ បានទទួលអនុវត្តគោលការណ៍ តាំងពីយូរយារណាស់ហើយទាំងក្នុងប្រទេស នៅគ្រាដែលមានផ្ទាស់ប្តូរព្រះមហាក្សត្រម្តងៗ ។ តែប៉ុន្តែ យើងសុំឲ្យគោលការណ៍នោះអនុវត្តក្នុងផ្លូវអន្តរជាតិផង ។

តាំងពីបុរាណកាលយូរយារណាស់មកហើយ ប្រទេសយើងជារដ្ឋមួយហើយរហូតមកដល់សព្វថ្ងៃ រដ្ឋរបស់យើងនៅមានដីរែកាពជាអចិន្ត្រៃយ៍ឥតឈប់មានសោះ ។ ទោះបីមានប្រទេសខ្លះនៅពុងបូតា បានបង្ខំឲ្យយើងដួយសួយសារអាករយ៉ាងណា ឬទោះបីជាយើងបិតនៅក្នុងអតីតសហគាពវណ្ណចិនយ៉ាងណាក៏ដោយ តែប្រទេសយើងនៅមានលក្ខណៈជារដ្ឋមួយជានិច្ច ,, ។

ដើម្បីទំនងបញ្ចប់គំនិតនេះ សហជីវិន ខ្ញើ-តាងបានលើកយកឯកសារច្បាប់អន្តរជាតិមកធ្វើជាគតិតាង ។

បន្ទាប់មក លោកបានខ្ចីនយោបល់ថា តាមផ្លូវនីតិសាស្ត្រក៏ដូចជា



ក្មួនចាស់ម្នាក់កំពុងចាប់ទាញដោយពោរពេញចិត្ត នូវព្រះហស្តដ៏ទន់ត្រជាក់នៃសម្តេចឪ មកជាប់លើក្បាល
ខ្លួនដើម្បីសិរីសួស្តី ក្នុងឱកាសព្រះរាជទ្បូងតំណែងជាថ្មីនៅថ្ងៃទី ៩ - ៦-៦៣

តាមផ្លូវសុភនិច្ឆ័យ គេមិនអាចយល់ច្បាន់ថា តើហេតុដូចម្តេចបានជាប្រទេសថៃ ដែលបានទទួលស្គាល់ កាតព្វកិច្ច (Obligation) របស់យើងក្នុងរបបអាណាព្យាបាល ហើយទៅជាមិនត្រូវទទួលស្គាល់សិទ្ធិ (Droits) របស់យើងក្នុងរបបនេះទៅវិញ ។

ក្រោយដែលបានបញ្ជាក់អំពីការណ៍ដែលសន្ធិសញ្ញាជាមួយប្រទេសអាណាព្យាបាល មិនត្រូវលោយសាបសូន្យ នឹងក្រោយដែលបានថ្លែងអំណរគុណដល់គុណការដែលបានទទួលស្គាប់ ដោយយកចិត្តទុកដាក់អំពីសេចក្តីដែករបស់យើង សហជីវិន ព្រឿង-កាង បានថ្លែងដំទៀតដឿជាក់ដល់គតិយុត្តិធម៌នៃគុណការអន្តរជាតិ ដែលដំរះសេចក្តីរឿងរបស់យើងនេះ ។

អភិជ្ឈាលោភហួសលេបក្បាលឆ្លោ
ឃើញជ្រលងធំកងកក្បាលត្រងាល
បង់តែបាន គ្មានរំខានរាងចាល
ជិល់បាតាលទើបភ្ញាក់ ខ្ជិលហួស។

បៀម-ក្រុក ព្រះភក្ត្រសង្ខ

សហជីវិន ៨ល - ឯិត្យ នៅពុទ្ធសាសនបណ្ឌិត្យ

រថយន្តផ្សាយសៀវភៅរបស់ពុទ្ធសាសនបណ្ឌិត្យ ចូលមកឈប់នៅចំមុខផ្ទះតាជួបនឹងយាយម៉ា ។ អ្នកផ្សាយសៀវភៅ បានស្រែកហោសនាដោយខ្លឹមសារសើរគុណសម្បត្តិគ្រប់យ៉ាង នៃសៀវភៅតាំងលក់ផ្សាយ ដែលជាក់យកមកផ្សាយ ។ ប្រជាជនតាំងកុះកុរចាស់ ទាំងក្មេងមកមើលគ្នាយ៉ាងច្រើនកុះករ ។ តាជួបឮ សំឡេងខ្លួ ។ គ្រាំមិនបានក៏ចេញមកមើលជាមួយនឹងគេដែរ ។ តាត់ឆាកមកឃើញរថយន្តនោះច្បាស់ ទើបតាត់ដឹងថា ជារថយន្តផ្សាយសៀវភៅរបស់ពុជតារ តាត់មិនហ៊ានចូលមកឈរជិតដូចគេទេ ព្រោះខ្លាចក្រែងចិត្តតាត់ប្រែមកចុះចូលនឹងធម៌ច្បាំង តាត់ឈរនៅឆ្ងាយពីគេចាំងពួង ។ បន្តិច មិត្រអ្នកផ្សាយរបស់យើង កាន់សៀវភៅគំរូមួយក្បាលដើរតម្រង់មកតាត់ ហើយនិយាយពន្យល់តាត់ឲ្យជួយជាវសៀវភៅនោះ យកមកខុកសិក្សាព្រោះជាសៀវភៅល្អ សម្រាប់ឧបាសក ឧបាសិកា មានធម៌សព្វគ្រប់ត្រឹមត្រូវ រៀបរៀងដោយអ្នកប្រាជ្ញចេះដឹងច្បាស់លាស់ . . . ។ តាជួប ស្តាប់មិនចូលចិត្តសោះ ព្រោះតាត់ខ្លាចប្រកាន់ថា សៀវភៅពុជការសុទ្ធតែជាធម៌ថ្មីរបស់ចុងច្រាំង តាត់ប្រកែកមិនព្រមជាវ ។ មិត្រយើងច្រើនពន្យល់តាត់ជារឿនរៃបប យ៉ាងម៉ុនប្រសប់ទៅទៀត ទីបំផុត តាជួប

ប្រថុយជាវសៀវភៅគិហឹប្បដិបត្តិ ១ ក្បាលនោះ ដោយការខុញខាល់ខឹង
ពេហាមិត្រយើងខ្លាំងពេក ។ តាត់កាន់សៀវភៅជាប់ តែមិនហ៊ានបើកសៀវភៅនោះមើលទេ ព្រោះតាត់ភ្លាច់ឮគេច្រាប់ថា ក្នុងសៀវភៅភជការសុទ្ធតែមានយ័ន្តជាក់ស្តែហ៍តូចតែណាស់ បើអ្នកណាមួយបើកមើលខ្មៀនតែត្រូវស្នេហ៍ចុះចូលធម៌ជាក់ជ័មិនខាន ។ លុះត្រឡប់ទៅផ្ទះវិញ យាយម៉ាឃើញតាកាន់សៀវភៅ ក៏ស្រែកចាំងតិ៍យថា យី! តាទិញសៀវភៅហ្នឹងឬ? ។ តាដួបឆ្លើយថា អើ! គេចេះតែខូចចិត្តឲ្យទិញខ្លាំងពេក អញគ្រាំមិនបាន ប្រថុយចាយលុយទិញចោលមួយក្បាលទៅហើយ ព្រោះអញគ្រាន់តែឮគេអួតសាណាស់ អញទិញនេះ ច្រាប់ថាឲ្យតែគេទៅផុតទេ! ។ យាយម៉ា: យី! ម៉េចក៏តាហ៊ានទិញ តាមិនដឹងទេឬ ពួកសៀវភៅធម៌ថ្មី ជាធម៌បេះជាក់ជ័ ហើយសៀវភៅនីមួយ ។ សុទ្ធតែមានតួយ័ន្តមេស្នេហ៍ធំ ។ ណាស់ តាឯងប្រយ័ត្នត្រូវស្នេហ៍ទៅចុះចូលធម៌ជាក់ជ័ មុខជាចុះនរកជាន់ហ្នឹងហើយ! លោកអើយ! ។ តាដួប: ចុះនរកអី បើអញមិនចាំងខ្លួនបើកមើលផង ។ យាយម៉ា: ខែ! តាឯងកុំបើកមើលឲ្យសោះណា! យកទៅចោលឯណាឲ្យឆ្ងាត់ទៅ! កុំខុកខាំចង្រៃណាស់ ។ តាដួបប្រឹងយកទៅកប់ចោល ប៉ុន្តែនឹកស្តាយ ដោយឃើញសៀវភៅទៅថ្មីស្អាតល្អ ក៏លាក់កាន់ចូលទៅក្នុងផ្ទះ បើកហិបញាត់សៀវភៅនោះទៅជាតហិប រួចបិទដាក់ទៅវិញមិនឲ្យយាយដឹងសោះ ។

ពីរបីថ្ងៃក្រោយមក យាយម៉ាំនិយាយទំនងគាត់ថា តាអើយ! ឥឡូវ
លោកគ្រូព្រះធម៌ទើបនឹមត្តមកគង់ក្នុងវត្តយើងនេះ ខ្ញុំគិតសុំតាឯងទៅរៀន
ធ្វើសមណធម៌ (សំណាក់ធម៌) ទំនងគេមុនហើយ ។ តាជួបៈ អើ! ទៅ
ក៏ទៅចុះ ចាំថ្ងៃក្រោយឯងឈប់ សឹមអញ្ជើទៅម្តង ។ យាយម៉ាសប្បាយ
ចិត្ត គាត់ប្រើកូនស្រីទៅផ្សារ ទិញខៀនគោលទំងន់ធូប ព្រមទាំងផ្លែឈើ
នំនែកឡេង ។ ជាច្រើនផង ។ ស្អែកឡើង ជាថ្ងៃ១រោស៨ ១៥កើត
គាត់គាន់ចេស់ទាំងអស់នោះទៅវត្តជាមួយទំនងយាយតាឯទៀតជាច្រើនទាក់
ដើម្បីយកទៅប្រគេនលោក ។ ដល់ទៅវត្ត គេនាំគ្នាទៅថ្វាយបង្គំ
លោកគ្រូព្រះធម៌ ដែលគង់ក្នុងកុដិមួយជាប់ដោយឡែកតែមួយអង្គឯង ។
គេលជួបជុំគ្នា គេក៏នាំគ្នាសូត្រនមស្ការ ស្មូតានសីលតាមទំនៀម ។
លោកគ្រូព្រះធម៌ សូត្រសិក្ខាបទមួយម្តង ។ ប្រជានទៅ១ថ្នាសក១ថ្នាសិកា
ទាំងនោះ ពួក១ថ្នាសក១ថ្នាសិកាទាំងនោះ ក៏នាំគ្នាសូត្រនួលតាមរៀង
ខ្លួន ខ្លះសូត្រញាប់ន្តាន់ ខ្លះសូត្រមួយ ។ ខ្លះសូត្រខ្ទាំង ។ ខ្លះសូត្រវិប ។
សំឡេងក្នុងទីនោះ កំសាន់ឡើងដូចជាយ៉ុំយកថ្លា ។ យាយម៉ាំមិនសូវ
ចេះចាំចប់ចុងចប់ដើមច្បាស់លាស់ដូចគេទេ គាត់សូត្រវិប ។ បន្ទុំហើយ
ហើតេនៅដដែរទាំងចប់ គាត់ក៏ចប់ដែរ ។ លុះកិច្ចសមាទានចប់សព្វគ្រប់
ហើយ យាយតាខ្លះ មានការប្រញាប់ ក៏ថ្វាយបង្គំលោកគ្រូរួចទៅផ្ទះ
វិញ ខ្លះទៀត នៅចាំចាត់ចែងជម្រើលោកឆាន់ ហើយនាំគ្នាបរិភោគ

ចាយដែលសេសសល់អំពីលោក ។ ឯយាយម៉ាំ ក៏ទៅបរិភោគនឹងគេដែរ លុះបួចហើយ គាត់ក៏លំទោនចូលទៅជិតលោកគ្រូព្រះធម៌ លើកដៃប្រណម្យទូលថា: សូមព្រះគេជព្រះគុណមេត្តាសង្គ្រោះប្រោសសត្វខ្ញុំផង ខ្ញុំកុណា មកសុំរៀនធ្វើសមណធម៌ពីព្រះគេជព្រះគុណជាមួយនឹងគេ សូមព្រះអង្គប្រទានធម៌ណាឲ្យសមគួរដល់ខ្ញុំកុណា ដើម្បីយកទៅរៀនធ្វើក្រែងបានសម្រេចមគ្គផលនឹងគេខ្លះ ។ លោកគ្រូព្រះធម៌ សំឡឹងទៅយាយ ហើយលោកមានថេរដីកាថា: អម្ពា! ល្អហើយយាយ! បើយាយមានចិត្តជ្រះថ្លាក្រៃថ្នាំរៀនសមណធម៌នោះ មិនអីទេ អាត្មាជួយសង្គ្រោះបាន យាយយកព្រះនាមព្រះពុទ្ធមួយអង្គទៅធ្វើបរិកម្មកាន់តាបុះ ប៉ុន្តែត្រូវរៀបគ្រែព្រះធម៌ មានចាយសី ចាស៎ា ខៀនជូប ឲ្យសព្វគ្រប់ក្នុងតុន្តែងជាប់ដោយខ្លែកតែម្នាក់ឯង លុះដល់ពេលយប់ស្ងាត់ ត្រូវយាយចូលទៅអង្គុយឲ្យស្រួល នមស្ការថ្វាយបង្គំព្រះ រួចការនាថា អរហំ ។ . . . ឲ្យជាប់កុំឲ្យជាប់ ហើយបើឃើញរហតុកេចំឡែកយ៉ាងណា ។ ព្រឹកឡើងកុំប្រាប់អ្នកណាឲ្យសោះ ត្រូវប្រញាប់មកឋតធម៌នឹងអាត្មា ព្រោះធម៌កង គេមិនត្រូវឲ្យមនុស្សឯទៀតក្រៅពីខ្លួនឯងដឹងផងទេ សូមអញ្ជើញយកទៅចុះ ។ យាយម៉ាំសប្បាយចិត្តណាស់ នាំយកព្រះនាមថា អរហំ . . . . នេះទៅផ្ទះវិញ ចាត់ធឹកមុខញញឹមញញែម ។ ទៅដល់ផ្ទះ គាត់ប្រាប់តានីងកូនចៅឲ្យរៀបចំតាមបង្គាប់លោកគ្រូព្រះធម៌ ។ កូនចៅកកន្តែងដាំមិន

ចាន កំនាំគ្នារៀបចំកន្ត្រកស្រូវឲ្យគាត់ ។ លុះដល់តេលយប់ យាយមាំ ទៅអង្គុយស្ងាត់ម្នាក់ឯង នមស្ការថ្វាយបង្គំព្រះរួច តាំងប្រឹងស្មឹងស្មាធិបវិតក្កវានាថា អរហំ . . . អរហំ . ។ អរហំ គាត់តាវនាបណ្តើរ គាត់ចង់ឃើញអ្វី ។ អស្ចារ្យ ហើយចេះតែនឹកចង់ឃើញស្ពានសួគ៌ ហាន នេក ។ ល ។ រហូតដល់ងួចង្គុយ ទើបគាត់សម្រាន្តសម្រាកបន្តិច ហើយ ក្រាក់ឡើងប្រឹងស្មឹងស្មាធិបវិតក្កវានាទៅទៀត ។ គាត់ធ្វើតែរបៀប យ៉ាងនេះ លុះដល់ពេលដំណក្តី ស្រាប់តែឮសូរសំពួយ៉ាងអស្ចារ្យគួរឲ្យ រំភើបក្នុងខ្លួន ដែលគាត់ដូចជាភ្ញាក់ឮផង មិនភ្ញាក់ឮផង ។ សំឡេង នោះ ដំបូងលាន់ឮយ៉ាងតូចឆ្ងាយថា «រៀប» ហើយបន្តាប់គ្នានេះ ឮសំ-ឡេងធំមួយទៀតថា «ក្រុក» ។ គាត់ឮមិនច្បាស់ថា តើសំឡេងនោះ លាន់ឮមកពីប្រភពទិសណាទេ ប្រុងស្មារតីចាំតិទ្យស្តាប់ទៅទៀត តែ លែងឮអ្វីសោះ ។ ព្រឹកឡើង គ្មានប្រាប់អ្នកណាឲ្យដឹងឡើយ គាត់ រៀបខ្លួនប្រាណប្រញាប់ប្រញាល់ទៅវត្ត ហើយចូលទៅថ្វាយបង្គំ រៀប រាប់ចូលតាមដំណើរដែលឮសូរសំពួអស្ចារ្យព័យប់នោះដល់លោកគ្រូ ។ លោកគ្រូសញ្ញឹងមួយសន្ទុះ ក៏មានថេរដីកាថា មិនអ្វីទេយាយ ! កើត ហើយ ! យាយកើតធម៌ហើយ ! យាយបានព្រះតក្កសន្ធោមួយព្រះអង្គ ហើយ សូមយាយប្រឹងប្រែងឲ្យពេញទំហឹងតទៅទៀតចុះ ។ យាយមាំ ត្រេកអរណាស់ ទឹកឃើញថា ខ្លួនគាត់ធ្វើធម៌ជាប់កើតណាស់ គាត់ថ្វាយ

បង្គំហើយត្រឡប់ទៅវិញ ។

លុះដល់យប់ទី៧ គាត់ក៏ចូលទៅអង្គុយប្រឹងស្មឹងស្មាធ៍នៅតែនឹងដដែលតាមរបៀបដូចពីយប់មុនទៀត ។ យប់នេះ ដល់ពេលជិតភ្លឺសំឡេងដែលគាត់ឮពីយប់មុនខោះបានលាន់ឡើងទៀត ប៉ុន្តែឮជួនគ្នាពីរដង គឺឮថា «ចៀប-ក្រុក! ចៀប-ក្រុក!» ។ យាយមាំតែតែពិការសង្ស័យខ្លាំងឡើង តែគាត់នៅតែលាក់លៀមខុក ចាំយកទៅបកធម៌ដូចពីថ្ងៃមុនៗទៀត ។ ព្រឹកនេះ លោកគ្រូព្រះធម៌ឃើញយាយមកថ្វាយង្ហែបង្គំសុំបកធម៌តាមដំណើរគឿងគាត់ទៀត លោកជញ្ជឹងបន្តិច ហើយមានថេរដីកាថា ល្អណាស់លោកយាយ! លោកយាយរៀនធម៌ចេះតែកើនបម្រើនទៅមុខ ឃើញបានព្រះកុសន្ទោតីព្រះអង្គហើយ! ប្រឹងទៀតទៅកុំរួញរាបន្ទរបន្តួយ ហើយបើឃើញយ៉ាងណាគេទៅ សឹមប្រញាប់ប្រញាល់មកបកទៀតចុះ ។ យាយមាំតែតែជោរចិត្តត្រេកអរតែកយ៉ាប្លឹងសិទ្ធមា គាត់ញញឹមញញែមតែម្នាក់ឯងដោយនឹកឃើញថា កូនជាតិនៃគាត់មានកតញ្ញូ រៀនធ្វើសមណធម៌ធាប់បានណាស់ ។ គាត់ដើរក្តីអង្គុយដេកក្តី និយាយជាមួយខ្ញុំឯតែក្តី ទឹកមុខគាត់ស្រស់ប៉ែប្រែជាខុសពីមុនតែគាត់ធឹងកូនចៅត្រមាំងអ្នកជិតខាងតើតសង្ស័យ ហើយជួយអប់អរជំនួស

លុះដល់យប់ទី៨ គាត់ចូលទៅអង្គុយធ្វើសមណធម៌ទៅក្នុងដំបូងដដែល ដូចពីយប់មុនទៀត ។ ចំណែកណាស់! [illegible] យប់នេះ

គាត់គ្រាន់តែចូលទៅអង្គុយមួយសន្ទុះ សំឡេង «ចៀប-ក្រុក» ដូចពីមុន
ក៏លាន់ឡើងភ្លាម ចិត្តគាត់ដឹងតែរំភើបអស្ចារ្យខ្លាំងឡើង ប្រឹងធ្វើតទៅ
ទៀត មិនយូរប៉ុន្មានគាត់ក្អកទៀត គាត់ចេះតែភ្ញាក់ផ្អើលៗម្តងៗថា «ចៀប-
ក្រុកៗ» ជារៀងហូរហែរទៅ ។ ដល់ពេលដឹងក្តីស្រាប់តែសំឡេង
«ចៀប-ក្រុក» លាន់ឡើងរំពងព្រមគ្នាទ្រហឹងអឺងអាប់ ។ ហេយមាំ
ភ្ញាក់ព្រើត សង្ស័យណាស់ ខំផ្អៀងស្តាប់ទៅ ដូចប្រុកដដាក្នុងឆាងក្រោម
ខ្នងគាត់ មិនអស់ចិត្ត ក៏បង្កើបកន្ទេលដែលក្រាលអង្គុយ ក្រោលភ្លើងមើល
ទៅក្រោមតាមចន្លោះរនាបស្រាប់តែស្រងាកចិត្តដោយឃើញកូនមាន់មួយ
សំបុកមានរមែតពុងក្រាប ខ្លះនៅជាតង ខ្លះទៀតញាស់ហើយ ក៏ឃើញ
ភ្លើងក៏ងាំគ្នាស្រែកថា ចៀបៗ ហើយមេក៏ស្រែកថា ក្រុកៗថែមម្តងទៀត
ទឹកមុខយាយមាំ ក៏ប្រែក្លាយទៅជាស្រទោនស្រប់មួយរំពេចហាក់ដូចជាទឹក
ស្ពាយលាយខ្ទឹងការមួរមៅក្តៅក្រហាយ គាត់អស់សំណើចតាំងមុខស្ងួត
លាន់មាត់ទាំងគោមនស្សថា «នេះ ឋានជាតួតែឋកធម៌មែន» ។ ព្រឹក
ឡើងគាត់ធ្វើទឹកមុខស្មើ ទៅយាយប្រុងប៉ាន់ក្មួនទៅតាំងអស់គ្នាថា អញ
ឈប់ធ្វើសមណធម៌ថែបនេះទៀតហើយ មើលទៅមិនស្រួលទេ! ។ តាំងឯ
ក្មួនទៅក៏យកក្រែងមានទុបសគ្គគ្រោះថ្នាក់យ៉ាងម៉េច ។ ក៏ប្រញាប់ដណ្តើសួរ
ថា មិនស្រួលយ៉ាងម៉េច? យាយ ។ យាយមាំឆ្លើយមិនបាន ក៏ញញឹម ។ និយាយ
ថារវៃលេមានឬ? អញ្ជើញទៅឮសំឡេងថា «ចៀប-ក្រុក» ប្រឹងលាក់យក

ទៅបកនឹងលោកអស់តាំពីព្រឹក លោកថា អញបានព្រះកុសន្ធោ ១ អង្គ ២ អង្គហើយ តាឯងទៅមើលចុះ ទៅខាងក្រោមកន្លែងសមណធម៌ មិនអ្វីគឺសំបុកកូនមាន់សោះ ម៉េយ៉ាងហ្នឹង តើវាយ៉ាងម៉េចទៅ ? ។ តានឹងកូនទៅចេញទឹកមុខចង់អស់សំណើចគ្រប់គ្នា ខ្លះណាន់មាត់ថា ខុមែនហើយសំបុកមាន់នោះ ខ្ញុំដាក់ឲ្យក៏ពងយូរហើយមិនបានជាតិសោះ ម៉ើលទៅប្រហែលជាសំឡេង «ចៀប-ក្រុក» នោះ គឺកូនមាន់ពងម្ខាយស្រែកតង ចេញមកហើយយំភ្ញាក់ថា «ចៀប» មេក៏ស្រែកឆ្លើយថា «ក្រុក» ហ្នឹងហើយដល់យប់ក្រោយៗមក កូនមាន់ក៏តែតែញាស់ច្រើនឡើងៗ បានជា «ចៀបក្រុកព្រះកុសន្ធោ» នោះ តែតែបានច្រើនឡើងហ្នឹងឯង ។ អ្នកចាំស្តាប់ក៏ផ្តុំសំណើចតឹលឡើងពាំងអស់គ្នា នាំឲ្យយាយស៊ីចាន់ឆ្នាសជាមួយនឹងតែដែរ ។ តាត់និយាយបញ្ចប់ធម៌ហ៊ាន់ស្រងឹតស្រងាត់ថា អញលែងទៅរៀនធ្វើសមណធម៌នឹងលោកគ្រូហ្នឹងទៀតហើយ ! ។

តាជួប តាត់ជាប់ប្រកាន់ជំនឿក្នុងលោកគ្រូព្រះធម៌ដែរ តាត់ក៏ប្រែជាខេះខិតខំនិតដោយចេះតែរឭកយើញព្រឹត្តិការណ៍ «ចៀប-ក្រុក ព្រះកុសន្ធោ» នេះជារឿយៗ ។ ថ្ងៃមួយ តាត់ចូលបើកហិបយកបេះផ្សែងៗ តាត់រើទៅប៉ះសៀវភៅដែលទិញពីថ្ងៃមុន ។ ចិត្តតាត់ស្រាប់តែចង់បើកសៀវភៅនោះសោកម៉ើល ប៉ុន្តែចិត្តមួយទៀតវាធ្វើភ័យខ្លាចឡើងៗ តាត់អង្គុយគិតម្នាក់ឯងមិនដាច់ស្រេចមួយសន្ទុះ ទីបំផុត តាត់ក៏សម្រេច

ចិត្តថា ត្រូវតែបើតសាកមើលម្តងចុះ តើសៀវភៅហ្នឹងវាយ៉ាងម៉េចខ្លះ ។ គាត់ប្រុងស្មារតីយ៉ាងមាំ ដើម្បីកុំឲ្យត្រូវស្នេហ៍ជាក់ឯ ពាក្យវែនមតាត់ឆ្នេចវែក្នុកយ៉ាងដិត បើកសៀវភៅជាស្រេច ទើបបើកក្នែកទ្វាកខ្ទុះមើលទៅអក្សរ ។ គាត់ប្រឹងសង្កេតពាក្យមួយ ។ ដកបដិតអស់មួយទំព័រ ស្រាប់តែលាន់មាត់ជា ណ៎ា ! ធម៌អញឆ្ងាប់ចេះហើយទេតើ ចុះអ្នកណាហ៊ានថាធម៌ថ្នឹធម៌ជ្រាក់ឯទៀវិញ ! ។ គាត់សំឡឹងទៅទៀតយើញអក្សរមានសណ្ឋានដូចជាគួយ័ន្ត ទឹកត័យតើត តែលុះពិនិត្យមែនទែនទៅ ស្រាប់តែលាន់មាត់ទៀតថា ឧ ! អក្សរតែមួយគូ គេគ្រាន់តែជាត់បន្តុបបែរបុះបែរឡើងជាក្បាច់ក្បូរវិចិត្រសិល្បៈល្អមើលប៉ុណ្ណឹងទេតើ មានយ័ន្តជាត់ស្នេហ៍ដូចជាគេជ្រាប់ឯណា ! អើរ៉ុយ ! ពាក្យមនុស្សវែងជាងផ្លូវមែន ។ គាត់បើកត្រួស ។ តាំងតែពីទំព័រខាងដើមរហូតដល់ចប់ ហើយស្ទុះត្រាតទៅតាន់តាំងសៀវភៅបើកស្រេច ញញឹមញញែមដើរទៅរកយាយ ។ យាយម៉ាដាតមកយើញដូចជាខ្ជាត់ចិត្តតណុក ទឹកយើញថា « តាពិតជាត្រូវស្នេហ៍សៀវភៅហើយ » គាត់ស្រែកសួរតាំងត័យថា កយ៉ាងម៉េចទៅហើយតា ! ។ តាជួបស្រែកច្រាប់ថា យាយអើយ ! យើងយល់ខុសទៅហើយ ! សៀវភៅនេះមានធម៌ជ្រាក់ឯណា ! ធម៌ព្រះពុទ្ធដែលយើងឆ្ងាប់ចេះហើយគ្រប់គ្នាទេតើ ! យាយមើលណ៎ា នេះធម៌ថ្វាយបង្គំព្រះ នេះធម៌ស្មាគានសីល នេះធម៌ផ្សេង ។ ទៀតប្រើនមុខណាស់ មានប្រែជាសម្រាយស្រេច យើង

គ្រាន់តែរៀនចាំ យើងអាចយល់ន័យបានសព្វគ្រប់ ។ មិនតែប៉ុណ្ណោះ មានចាំងរបៀបរៀនធ្វើបវេកម្មការនៅសមណធម៌ លោកអ្នករៀបរៀងបានធ្វើបរិយាយយ៉ាងច្បាស់លាស់ផង មិនមែនឲ្យធ្វើស្មាន ។ ដូចយាយឯងគ្រាន់តែឮសំឡេង «ចៀប-ក្រុក» ក៏បានព្រះកក្កុសន្ធោមួយព្រះអង្គនោះទេ ។ យាយម៉ាញញឹម សុំឲ្យតាអានស្តាប់ តាត់ចាប់ចិត្តណាស់ លុះថ្ងៃបន្តបន្ទាប់មក តាត់លែងដឿអ្នកណាទៀតហើយ ប្រឹងរៀនតែតាមសៀវភៅគិហិប្បដិបត្តិនោះប៉ុណ្ណោះ ដោយឲ្យតាអានប្រាប់មួយម៉ាត់ ។ លុះត្រាតែគាត់ទន្ទេញចាំ ទើបឲ្យតាអានប្រាប់តទៅទៀត បើមានពេលច្រើនទេ តាត់ឲ្យតាអានសៀវភៅនោះឲ្យស្តាប់សាជុះសាឡើងជាញឹកញាយ គាត់បានយល់ច្រើន ហើយយូរមក តាជួបយាយម៉ាអាចសូត្រធម៌បានច្រើនជាងគេកង់កូមិនោះ ប៉ុន្តែព្រឹត្តិការណ៍ដែលគាត់ចំក្ងេចចោលមិនបាននោះ គឺគាត់បង់សៀវភៅខ្លួនឯង ដោយនឹកឃើញថា: ចៀប-ក្រុក ព្រះកក្កុសន្ធោ ។

-ចប់-

អំពីការតាំងមន្ត្រីសង្ឃ

កាលពីថ្ងៃទី ១៥ ខែមករា ឆ្នាំ ១៩៦៣ ចានតាំងលោកគ្រូ ខុង-សាលី នាមធាយ បវរបុណ្ណា ព្រះជន្មចាន ៦៤ ឆ្នាំ វស្សា ៤ ជាគ្រូសូត្រស្តាំ វត្តអម្ពនទិយោកម ឃុំតាមក្រសោប ស្រុកកោះកុង ខែត្រកោះកុង ។

កាលពីថ្ងៃទី ១៥ ខែមករា ឆ្នាំ ១៩៦៣ ចានតាំងលោកគ្រូ សេង វៀង នាមធាយ អមរោ ព្រះជន្មចាន ៦២ ឆ្នាំ វស្សា ៣ ជាគ្រូសូត្រឆ្វេង វត្តអម្ពនទិយោកម ឃុំតាមក្រសោប ស្រុកកោះកុង ខែត្រកោះកុង ។

កាលពីថ្ងៃទី ១៥ ខែមករា ឆ្នាំ ១៩៦៣ ចានតាំងលោកគ្រូ យី-ចំ ថា នាមធាយ សមាចារោ អាយុ ៦៦ ឆ្នាំ វស្សា ៧ ជាគ្រូសូត្រស្តាំវត្តអម្ពវន ឃុំតាមក្រសោប ស្រុកកោះកុង ខែត្រកោះកុង ។

កាលពីថ្ងៃទី ១៥ ខែមករា ឆ្នាំ ១៩៦៣ ចានតាំងលោកគ្រូ ឈុំ-ឈឿ នាមធាយ ជម្មទិន្នោ អាយុ ៦១ ឆ្នាំ វស្សា ២ ជាគ្រូសូត្រឆ្វេង វត្តអម្ពវន ឃុំតាមក្រសោប ស្រុកកោះកុង ខែត្រកោះកុង ។

កាលពីថ្ងៃទី ៦ ខែកុម្ភៈ ឆ្នាំ ១៩៦៣ ចានតាំងលោកគ្រូ អ្ងួន-ហ៊ឹម នាមធាយ វត្ថុគោ អាយុ ៦៦ ឆ្នាំ វស្សា ៥ ជាគ្រូសូត្រស្តាំ វត្តជ្រៃមាស-សាគរ ឃុំត្រែកដំបង ស្រុកមុខកំពូល ខែត្រកណ្តាល ។

កាលពីថ្ងៃទី ៦ ខែកុម្ភៈ ឆ្នាំ ១៩៦៣ ចានតាំងលោកគ្រូ សៅក-គោកត នាមធាយ អគប្បិយោ អាយុ ៦៥ ឆ្នាំ វស្សា ៥ ជាគ្រូសូត្រឆ្វេង

វត្តជ្រៃមាសសាគរ ឃុំព្រែកដំបង ស្រុកមុខកំពូល ខែត្រកណ្តាល ។

កាលពីថ្ងៃទី ៦ ខែកុម្ភៈ ឆ្នាំ ១៩៦៣ ឆ្នាំ ឧ-ប៉ាម នាមធាយោ មុនីកេសរ អាយុ ៣៨ ឆ្នាំ វស្សា ១៨ ជាគ្រូសូត្រស្តាំវត្តសិរីជយមង្គល ឃុំគោហេ ស្រុកមុខកំពូល ខែត្រកណ្តាល ។

កាលពីថ្ងៃទី ៦ ខែកុម្ភៈ ឆ្នាំ ១៩៦៣ ឆ្នាំ សាន់-ឈាង នាមធាយោ ឥន្ទបញ្ញោ អាយុ ៣១ ឆ្នាំ វស្សា ១០ ជាគ្រូសូត្រធ្នូង វត្តសិរីជយមង្គល ឃុំគោហេ ស្រុកមុខកំពូល ខែត្រកណ្តាល ។

កាលពីថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ១៩៦៣ ឆ្នាំ ខាន់-ម៉ុត នាមធាយោ មន្ទន្តេ អាយុ ៤៣ ឆ្នាំ វស្សា ២២ ជាចៅអធិការវត្តអង្គត្រគៀត ឃុំកន្ទោក ស្រុកកំពង់ចាម ខែត្រកណ្តាល ។

កាលពីថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ១៩៦៣ ឆ្នាំ ហ៊ុម-ប៊ែន នាមធាយោ ធម្មសុវណ្ណ អាយុ ៤៦ វស្សា ២៦ ជាចៅអធិការវត្តសុវណ្ណ-សនាគម ឃុំចោងមោង ស្រុកទឹកផុស ខែត្រកំពង់ឆ្នាំង ។

កាលពីថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ១៩៦៣ ឆ្នាំ កួន-ប៊ុង នាមធាយោ ឥន្ទបញ្ញ អាយុ ៣៣ វស្សា ៩ ជាគ្រូសូត្រស្តាំវត្តវ៉ែន ឃុំវ៉ែនតាឯក ស្រុកសូទ្រនិគម ខែត្រសៀមរាប ។

កាលពីថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ១៩៦៣ ឆ្នាំ ឃួវ-ឆន នាមធាយោ សុវណ្ណជោតិ អាយុ ៣០ វស្សា ៩ ជាគ្រូសូត្រធ្នូងវត្តវ៉ែន ឃុំវ៉ែនតាឯក ស្រុកសូទ្រនិគម ខែត្រសៀមរាប ។

កាលពីថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ ១៩៦៣ ចាន់តាំងលោកគ្រូសៀ-ដុង នាមឆាយា សង្ការសថារី អាយុ ២៩ ឆ្នាំ វស្សា ៨ ជាចៅអធិការវត្តសាលាម្នាង ឃុំត្រតាំង ស្រុកកំពង់សោម ខែត្រកោះកុង ។

កាលពីថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ១៩៦៣ ចាន់តាំងលោកគ្រូ ជា-ប៊ែត នាមឆាយា ឥន្ទវត្តោ អាយុ ៤៦ ឆ្នាំ វស្សា ២៦ ជាចៅអធិការវត្តសិរីវ័ន ឃុំ ត្រា ស្រុកសំរោង ខែត្រតាកែវ ។

កាលពីថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ១៩៦៣ ចាន់តាំងលោកគ្រូ ស-សាមឿន នាមឆាយា មុទិវរោ អាយុ ២៩ ឆ្នាំ វស្សា ៤ ជាគ្រូសូត្រស្តាំ លោកគ្រូ ឆេ-សុខ នាមឆាយា វិជិរប្បញ្ញោ អាយុ ២៤ ឆ្នាំ វស្សា ៤ ជាគ្រូសូត្រឆ្វេង វត្តសិរីវ័ន ឃុំត្រា ស្រុកសំរោង ខែត្រតាកែវ ។

កាលពីថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ ១៩៦៣ ចាន់តាំងលោកគ្រូ ស្វ-ម៉ឺម នាមឆាយា តវុធម្មថេរ អាយុ ៧៧ ឆ្នាំ វស្សា ៥៦ ជាចៅអធិការ, លោកគ្រូ ម៉ិច-សេង នាមឆាយា សុវណ្ណថេរ អាយុ ៥៤ ឆ្នាំ វស្សា ១៩ ជាគ្រូសូត្រស្តាំ, លោកគ្រូ ទឹម-ម៉ាង នាមឆាយា ធម្មថេរ អាយុ ៥០ វស្សា ១ ជាគ្រូសូត្រឆ្វេង វត្តចំការខ្លាច ឃុំស្ពានថ្ម ស្រុកកណ្តាលស្ទឹង ខែត្រកណ្តាល ។

កាលពីថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ១៩៦៣ ចាន់តាំងលោកគ្រូ ជាង-ហុង នាមឆាយា សុវណ្ណត្តេរ អាយុ ៣៣ វស្សា ១២ ជាចៅអធិការ, លោកគ្រូ តុង-វ៉ង់ នាមឆាយា មុនិសត្តេរ អាយុ ៣១ វស្សា ១០ ជាគ្រូសូត្រស្តាំ វត្តពោធិព្រឹក្ស ឃុំក្តឿងកាយ ស្រុកកះញែក ខែត្រព្រៃវែង ។

ភាវនាសុទ្ធិយា


ទស្សនាវដ្តី ផ្សាយជំនាំងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ៣៥ លេខ ៦ ខែ មិថុនា


ព. ស. ២៥០៥ គ. ស. ១៩៦៣

- ភ្នំពេញ -



ព្រះសាក្យមុនីចេតិយ ស្ថិតនៅត្រង់ទិសឦសាន្តនីយ អាយស្មាយយោនកម្ពុជា ភ្នំពេញ

នៅទីនេះហើយដែលគេតំកល់ព្រះបរមសារីរិកធាតុព្រះសម្មាសម្ពុទ្ធ



អង្គសន្និសីទ

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

បេញ្ញារាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

មាតិកា

	ទំព័រ
ផ្នែកសាសនា	
– រឿងមនុស្សស្លាប់ តើគេហៅទីនេះជាអ្វី (វិចារណកថា) លោក ផេង-ត្រីវ៉ា រៀបរៀង (ត)	៥៦២
– ព្រះអភិធម្មបិដក (គម្ពីរព្រះអភិធម្មបិដក) លោក ប៊ូ-ប៊ី ប្រែរៀបរៀង (ត)	៥៧២
– មធុរសវាហិណី សម្តេចព្រះធម្មលិខិត ល្វី-ឯម ឧត្តមប្រឹក្សា ប្រែរៀបរៀង (តចប់)	៥៧៨
– មហោសថជាតក (ត)	៥៨២
ផ្នែកអក្សរសាស្ត្រ	
– តើពុកម្តាយមានឧបការគុណលើកូនខ្មែរឬមិនខ្មែរ? (វិចារណកថា) លោក ផេង-ត្រីវ៉ា រៀបរៀង	៥៨៤
– អក្សរសាស្ត្រខ្មែរ សិលាចារឹក ជ័យ-ឧទ្ទ ស្រាវជ្រាវ ដោយ ឧ-គាម	៦០៥
– វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះវេគដ៏ប្រសើរគុណ ជាំង-ខាត់ រៀបរៀង (ត)	៦១៦
– រឿងសាមកុក លោកឧកញ៉ា ឆួ-កាន ប្រែរៀបរៀង (ត)	៦១៨
– ល្បែងឃ្លាហ្វុងនៃន លោកផេង-ត្រីវ៉ា ប្រែពីភាសាចាក់ង (ត)	៦២៥
– រឿងចិញ្ចឹងអូសីរៃយ៉ះ លោក ភ័ក-ប៊ុក ប្រែពីភាសាចាក់ង (ត)	៦២៩
– សំបុត្រទីមួយមេសំលោកខេរ៉ូ ទៅបុត្រីលោក តាមខាងលក្ខ្មី (សៀវភៅនៃធម្មជាតិ) លោកឈន-អៀម ប្រែពីភាសាអង្គេស	៦៣៣
– ប្រកាសប្រឡងប្រជែងចំរៀបចំសៀវភៅខ្មែរ	៦៣៩
ផ្នែកកំណត់ទំនីនប្រវត្តិការណ៍	
– បុណ្យបញ្ចុះសីមាវត្តឧណ្ណាមលោម	៦៤៧

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃដាវ ២៣០ ០០

ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការណែនាំ ឲ្យធ្វើល្អវិញ
ឲ្យជម្រះចាត់ចិត្ត កុំឲ្យហួងហែង
បើនេះលោកហៅ ពុទ្ធសាសនា

ប.ព.

វិចារណកថា

រឿងមនុស្សស្លាប់កើតឡើងវិញជាតិ

លោក ដេង - ប្រឹវ រៀបរៀង

អំពីរឿងដដែងជាតិនេះ នៅប្រទេសដទៃ ខ្ញុំមិនបានដឹង តែនៅប្រទេសខ្មែរយើង របៀបនេះមានច្រើន សូម្បីក្នុងគម្ពីរពុទ្ធសាសនា ក៏មានរឿងដដែងជាតិនេះដែរ ។

តើអ្នកដែលកើតឡើងហើយ បានដដែងជាតិរបស់ខ្លួន ដោយអាស្រ័យការកសាងកុសលអ្វី? ក្នុងគម្ពីរពុទ្ធសាសនា លោកអ្នកប្រាជ្ញហាក់ដូចជាពុំសូវដែលឮសំដែងអំពីសង្សដដែងជាតិនេះ ច្រើនឮសំដែងតែនូវចលនាចិត្តដែលរៀបស្ងាប់នោះយ៉ាងណា ឃើញអ្វី ចិត្តគាងអ្វី ទើបប្រែតាកតមួយទៅកតមួយទៀត ។

មុនទីដឹងដោះស្រាយ តាកាក្យដាយ៉ាងណា ។ នូវបញ្ហានេះ ខ្ញុំសូមយករឿងស្តីពីមនុស្សដដែងជាតិ មកពណ៌នាសិនដូចតទៅ:

រឿងជីងជាតិ (លោកគ្រូសោម)

ដំណាលថា មានលោកមួយអង្គ បួសនៅវត្តអង្គសីង្ហ ស្រុកចាំទី ខេត្តតាកែវ ជានគ្រូសូត្រ ព្រះនាមសោម (រឿងនេះមានមកយូរឆ្នាំហើយ ខ្ញុំដឹងរឿងនេះតាមសំដីរបស់ឈ្មោះកង - សុឹម នៅភូមិសំប៉ាន ស្រុកគោរធំ ខេត្តកណ្តាល ទិយាយប្រាប់) ។ ចំណែកព្រះនាមលោកគ្រូចៅអធិការមិនដឹងជាឈ្មោះអ្វី ។

លោកគ្រូសោម នៅសម័យនោះមានសទ្ធាជ្រះថ្លា ជានកសាងអង្គព្រះមោគ្គល្លាន ដំកល់នៅកែ្សរបល្ល័ង្កព្រះដ៏វែងក្នុងព្រះវិហារ លើកព្រះហស្តប្រណាមព្រះពុទ្ធអង្គ ។ ក្នុងពេលកំពុងសាង លោកគ្រូសោមឃើញថានៅខ្វះព្រះចាន់ខ្លាង លោកនឹមន្តនៅរកឥដ្ឋជានមួយដុំមក ដើម្បីបង្ហើយព្រះចាន់នោះ ។ កំពុងតែកាន់ ស្រាប់តែដុំឥដ្ឋ ធ្លាក់មកត្រូវព្រះចាន់លោកបណ្តាលឲ្យមានរបួស ។

ដោយវេលាទឹងញាំាលជម្ងឺព្រះចាន់ លោកគ្រូសោមអាក់ខានខ្លាំការកសាងបង្ហើយព្រះចាន់ព្រះមោគ្គល្លាននោះទៅ ។ អាតានលោកគ្រូសោមកាន់តែធ្ងន់ឡើង ។ គាល់តែធ្វើឲ្យលោកសុគត ។

ក្នុងពេលនោះថា ពួកទាសកដើងវត្តអង្គសីង្ហនឹងលោកគ្រូចៅអធិការ កំពុងសង់មេរុដើម្បីធ្វើបុណ្យបូជាព្រះសពលោកគ្រូចៅអធិការមុន ។ ឃើញទុកាសល្អ ពួកសិស្សត្រណាលោកគ្រូសោមក៏ជានសុំអនុញ្ញាតសង់-

ណាក់លោកគ្រូចៅធិការ ដើម្បីយកសពគ្រូបង្កើនជាក់ចូជាកន្លែងមុនោះ
ផង លោកគ្រូចៅអធិការ មុនដំបូងយល់ព្រមតាមសេចក្តីសុំ តែថ្ងៃជា
បន្ទាប់មក មានប្រពន្ធចៅហ្វាយស្រុកម្នាក់ឈ្មោះលោកស្រីខៀវ ចាន់ថា
បញ្ជុះបញ្ចុលសុំលោកគ្រូចៅអធិការអនុញ្ញាតឲ្យគាត់យកខ្មោចប្តីជាចៅ –
ហ្វាយស្រុកនោះ មកជាក់ចូជាកន្លែងមុនផង ដោយសូកប្រាក់ ១រយរៀល ។
ចានប្រាក់សំណូក លោកគ្រូចៅអធិការបដិសេធសពលោកគ្រូសោម
ចេញ ដោយបង្គាប់ឲ្យសិស្សលោកគ្រូសោមយកសពគ្រូបង្កើនទៅចូ-
ជាខៅជ្រុងវិហារខាងត្បូង មិនត្រូវឲ្យចូជាកន្លែងមុជាមួយព្រះសព ។

ខាងក្រោយមក សិស្សគ្រូណាលោកគ្រូសោម ចានកសាងព្រះចេតិយ
មួយដើម្បីដាក់ឆាតុគ្រូបង្កើនខ្លួន ខៅកន្លែងវត្តអគ្គសីដ្ឋិនោះ ជាខាងលិចដើម
រោងជើងនៅកែប្រថ្នូរគាត់មុខវត្ត ។

មិនឆ្ងាយពីវត្តអគ្គសីដ្ឋិប៉ុន្មាន មានភូមិមួយជារបស់ឈ្មោះស៊ូ អ្នក
ស្រុកនិយមហៅ «អាចារ្យស៊ូ» ។ កន្លងជាច្រើនខែពីការបូជាសព
លោកគ្រូសោមមក ប្រពន្ធអាចារ្យស៊ូមានទម្ងន់ចង្កឹតែស៊ីចាយចាត្រ ។
ពេលដែលនាងនោះជាក់ចាត្រលោកសង្ឃប្រុងហើយ តែងតែសំពះលោក
សុំចាយចាត្រខ្លះមកវិញ ។ រៀបរាប់នេះ មានជាពាល់ថ្ងៃពាល់តែអាចារ្យស៊ូ
ដឹងក៏ប្រាប់ថាកុំធ្វើដូច្នេះ បើចង់ស៊ីចាយចាត្រ ត្រូវដាំចាយរួចដួសយក
១ឆ្នាំលះទៅដូរទឹងលោកឯវត្តទើបសមគួរ ។

ខមួន់ត្រប់ខែ ប្រតន្ធអាចារ្យស៊ូសម្រាលបានកូនប្រុស ។ តែលដែលកូនគោះមានអាយុប្រមាណបីឆ្នាំ ចេះសំដីខ្លះ កុមារនេះ (មិនស្គាល់ឈ្មោះ) ព្រហាមឡើងតែងកាន់ត្រឡោកទៅសុំទឹកត្នោតពីអាពុកមាដែលមកត្រង់ទឹកត្នោតនៅមុខផ្ទះ ដើម្បីញ៉ាំជាយស៊ូ ។

មានមួយព្រឹក អាពុកមាកំពុងនៅបុងត្នោត កុមារយើងកាន់ត្រឡោកមួយ អង្គុយក្បែរគោះ ដើម្បីសុំទឹកត្នោតញ៉ាំជាយ ។ មិនដឹងជាអផ្សុកដោយចាំយូរពេក ឬយ៉ាងណា ស្រាប់តែអាពុកមានៅបុងត្នោត បានឮសូរអ្នកណាស្រែកបន្តុំៗនាតដ៏ពិរោះនៅខាងក្រោម គាត់ឈ្លោកមើលមកឃើញក្មួយស្រាត កាន់ត្រឡោកកំពុងតែសូត្រ ។ ទឹកធ្លាប់ពេក អាពុកមានៅសួរអាចារ្យស៊ូថា ឯងបង្រៀនអាក្មួចនេះនូវបន្តុំនាតពីកាលណា? អាចារ្យស៊ូឆ្លើយថា មិនដែលបានបង្រៀនម្តងឡើយ ជនតាំងពីរៀនធ្លាប់តាន់ពេកអំពីរឿងនេះ ។ អាចារ្យស៊ូបានប្រាប់បងថ្លៃថា ម្តងនោះអាបងកាត់តុងអានសាស្ត្រា «នេះគឺ» ហើយមើល «ខុស» ស្រាប់តែអាក្មួចនេះស្រែកប្រាប់ថា «ឯងចេះខេ» រួចអាបងមកសួរខ្ញុំ។ តាំងពីត្បូយើញថាវាប្រាប់នោះត្រូវ ហើយវាមិនតាំងខាន់ដែលរៀនអក្សរសោះតែខ្ញុំមិនចាប់ក្តីអំពីរឿងអ្វីឆោយទឹកស្មានថាប្រហែលវាចាំលេង លោជួនជាត្រូវកើមិនដឹង ។

អាចារ្យស៊ូនេះ មានម្តាយនៅឯស្រុកកំពង់ចក ឃុំព្រៃល្អា ស្រុកព្រៃកប្បាស ខេត្តតាកែវដែរ ។ មុនប្រតន្ធគាត់មានខមួន់កុមារនេះ ម្តាយ

ឈឺហើយបានផ្តាំឲ្យឈ្មោះស៊ូទៅ គាត់ក៏បានទៅសួរម្តាយមួងជាតិដែង ហើយត្រឡប់មកវិញ រួចតែងតែឈប់សម្រាកនៅមុខដើមពោធិមុខវត្តអង្គស្មឹងដើម្បីដកថ្ងៃ ។

លុះកុមារនេះបានអាយុប្រមាណជាបួនខែ ក៏តែងតែសុំអាពុកវាថាចង់ទៅលេងវត្តអង្គស្មឹងជាញឹកញាយ តែអាពុកគ្មានឧកាសនឹងជូនទៅ ។ មានមួយថ្ងៃ ម្តាយអាចារ្យស៊ូឈឺម្តងទៀត ហើយផ្តាំឲ្យគាត់ទៅ ។ បានឃើញអាពុកវៀបចំរនេះនឹងទៅតំពង់ចកដើម្បីសួរម្តាយ កុមារយើងសុំអាពុកទៅផង ។ អាពុកឃាត់ថាកុំទៅអីព្រោះផ្លូវឆ្ងាយ ក៏ប្រាប់អាពុកថាចង់ទៅលេងវត្តអង្គស្មឹង ។ ឮដូច្នោះ អាពុកក៏ព្រមឲ្យទៅជាមួយ ។

មកដល់វត្តអង្គស្មឹងកាលណា ក៏សុំឲ្យអាពុកឈប់បន្តិច អាពុកក៏បញ្ឈប់រនេះនៅក្រោមដើមពោធិដដែល ។ ឯកុមារជាកូនក៏ចុះដើរតម្រង់ទៅវត្ត ធ្វើឫកដូចជាខ្លួនមនុស្សធំ ហើយទៅសួរលោកសាមណេរមួយអង្គថាលោកគ្រូធំមិនទៅណា ? ខណៈពេលនោះ លោកគ្រូទៅអធិការនៃមន្តទៅមុខវិហារមើលគេការឈើ លោកសាមណេរនោះមានតុក្ខដីតាថាលោកគ្រូធំមិនទៅ ។ កុមារយើងជារបៀបមនុស្សចាស់សួរទៅលោកសាមណេរថា: ចុះកុដិត្រង់នេះ (កុដិរបស់លោកគាលពីជាតិមុន) គេរុះយកទៅណាទៅ ? ចុះសាលាទៅត្រង់នេះ ម្តេចមិនឃើញ ? ។ ល ។ លោកសាមណេរមានតុក្ខដីតាធ្វើយថាលោកមិនបានដឹង ព្រោះលោកទើប

តែនឹងបួស ។

កុមារនេះដើរមកមុខវិហារ ប្រទះលោកគ្រូចៅអធិការ កំពុងយកដង្កៀរបៀបមនុស្សចាស់ ហើយនិយាយស្តីបន្ទោសលោកគ្រូចៅអធិការបណ្តាយថា: មិនគួរលោកគ្រូមានព្រះទ័យអាក្រក់ស្អប់ខ្ញុំព្រះករុណាសោះព្រោះតែចង់ចាន់ប្រាក់ពីលោកស្រីខ្ញុំ ១០០រៀល ហ៊ានតែឲ្យយកសពខ្ញុំព្រះករុណាទៅបូជាត្រៀមរុំ ឯត្បូងវិហារវិញ លោកគ្រូធ្វើដូច្នេះសមឬ? រុំហ្នឹងជាស្នាដៃខ្ញុំព្រះករុណាទេតើ ។

ឮសំដីរបស់ក្មេងនោះថាដូច្នោះ លោកគ្រូចៅអធិការនឹកឃើញថាខ្លួនកំពុងលួសសាកសព ហើយសុំទោសថា: ខ្ញុ! សាមណេរអើយ! តាមតែឯងអត់ទោសឲ្យគ្នាផងចុះ ធ្វើម្តេចគ្នាឃាតជាខុសហើយ ។

ដំណឹងនេះសាយភាយពេញទាំងវត្តមួយរំពេច ចំណែកសិស្សតណាលោកគ្រូសោមព្រមទាំងលោកសង្ឃដទៃក៏ផ្តើលមក ព្រោះដឹងច្បាស់ថាលោកគ្រូសូត្រសុគតទៅ មកកើតជាកុមារក្មេងអាចារ្យស្លិ ។ មិនផ្តើលតែលោកសង្ឃ ផ្តើលទាំងឧបាសក ឧបាសិកាដើងវត្ត ព្រមទាំងបងប្អូនលោកគ្រូសោមផង ។ ទើបគេសុំឲ្យក្មេងនោះពោលរៀបរាប់តាំងពីពេលដែលលោកសុគតរហូតដល់ពេលចូលបាច់តំណើត ។ ក្មេងនោះនិយាយប្រាប់ថា: „ខាងក្រោយដែលលោកសុគតទៅ ព្រលឹងលោកមិនទាន់ទៅចាប់តំណើតឯណាឡើយ គឺនៅគ្រាច់រឹលរលៀតក្បែរៗហ្នឹង

ពេលថ្ងៃចេញទៅលេងទីនេះទីនោះ ដល់យប់ត្រូវវិលត្រឡប់មកសំណាក់
តន៍ចេតិយដែលគេដំកល់អដ្ឋិលោក ការប្រព្រឹត្តបែបយ៉ាងនេះអស់រយៈ
ពេលជាច្រើនថ្ងៃ ។ ថ្ងៃមួយ ព្រលឹមលោកទៅទៅលេងក្រោមដើមពោធិ
មុខវត្តកែវឆ្នូវនោះ ខ្ពួលពេលនោះ អាចារ្យស៊ូជាអាពុកសព្វថ្ងៃ វិលមក
ពីស្មូរម្ហាយឈើទៅកំពង់ចក ហើយមានទាំងចេកទុំពីស្មើខ្នងផង(អាពុកខ្ពួល
ថាតែម្នេន) ។ អាចារ្យស៊ូមកដល់ទីនេះ(ចង្អុលដើមពោធិ)ក៏ឈប់ទៅ
ម្ខាប់ពោធិដើម្បីមួចជើង ។ ឃាននេះដោយខានឃាននោះ ស៊ូហាក់ដូចមានចិត្ត
ស្រឡាញ់ហើយចង់ស៊ុចេកទុំនោះផង ព្រោះឃ្លានដោយខានឃាននោះមក
យូរហើយ តែអាចារ្យស៊ូមិនយើញឲ្យស៊ុសោះ ។ ពេលដែលអាចារ្យ
ស៊ូបន្តដំណើរទៅផ្ទះ លោកក៏ដើរតាក្រោយទៅជាមួយ ។ ទៅដល់ផ្ទះ
ពេលព្រលប់ អាចារ្យស៊ូយកចេកទុំទៅដាក់កៀនមាត់ទ្វារកែវជណ្តើរ
ហើយប្រាប់កូនគាត់ឲ្យយកចេកស៊ី ចំណែកលោកចង់ស៊ុចេកស៊ើរស្ងាម
មើលតែមាត់គេ។ ក៏មិនទឹកនាហុចមួយមកឲ្យ ដល់ពេលចាយក៏ដូច្នោះ
ទៀត គឺគាត់ទាំងតែកូនប្រពន្ធគាត់ខ្ពួលទាន ឥតមានហៅលោកដែល
ឈរទៅក្បែរនោះសោះ ។ ពេលយប់ទៀត គេនាំគ្នាចូលដេក ក៏គេមិន
ហៅ ហើយពេលនោះមានភ្លៀង ខ្លួនលោកទៅក្រៅមុង រងាជាខ្លាំងពេក
លុះអត់ទ្រាំពុំបាន ក៏ប្រថុយលបបើកមុងទៅប្រជ្រៀតដេកជាមួយលោក
អាចារ្យស៊ូនឹងប្រពន្ធគាត់ ។ ពីពេលនោះទៅ ការដឹងរឿងអ្វីក៏វិនាសអស់

រលើងរហូតដល់ពេលដែលខ្ញុំនកើត ។

លុះបានដឹងច្បាស់ថាកុមារជាកូនលោកអាចារ្យស៊ូ ជាគ្រូបង្រៀនខ្ញុំមក ចាប់កំណើត ព្រោះអ្វីទាំងប៉ុន្មាននៅក្នុងវត្តអង្គសិង្ហ ក្មេងខោះដឹងទាំងអស់ ពួកគិតគូសាមណោរជាសិស្សលោកគ្រូសោមព័ជាតិមុន គិនាំគ្នាមកឈ្លបរកាន់គ្រូបង្រៀនគ្រូគ្រប់អង្គ មានខ្មៀនជួបផង មកធ្វើវត្តវាន្ទាកូនក្មេងដឹងជាតិ ចំណែកក្មេងនេះអត្តិយធ្វើព្រងើយ ហាក់ដូចខ្ញុំជាតួលោកគ្រូសោមដូច្នោះ។ មានសិស្សលោកគ្រូសោមម្នាក់ បានធ្វើជាភ្នាក់ងារពាក្យ (ជាស្មៀន ?) តិដៀនមកដល់ខ្ញុំនោះ ឃើញមានលោកសង្ឃនៃ១ចាសកជុំ។តិឈប់ចូលមើល ស្រាប់តែឃើញលោកសង្ឃកំពុងវាន្ទាកូនក្មេងថាជាគ្រូបង្រៀនខ្ញុំ ទើបពោលដោយឥតដឿថា ហេតុម្តេចក៏ព្រើលៗនាំគ្នាវាន្ទាកូនក្មេងយ៉ាងនេះ ។ កូនក្មេងនោះឮ តិងាកឆ្ពោះទៅអ្នកនោះ បើកភ្នែកធំ សំឡក់ចំហើយច្រាប់ថា: អាឯងដោះអាវ រកគេមើលខ្លួនអាឯងមើល តើមានអ្វីខោះ? អ្នកនោះដឹងខ្លួន តិលោតផែលខ្លើងលើសេះដើរតាមៗ ។ ចាន់ជាតាត់នេះមិនហ៊ានទៅ ព្រោះខ្លួនជាកូនសិស្សលោកគ្រូសោមដែរ ហើយចាន់គ្រូលោកគ្រូសោមពាយបែកខ្លាំង មានតាំងស្មាមទៅរហូតដល់សព្វថ្ងៃ ។

បន្ទាប់ពីខោះមកទៀត ពួកបងប្អូនជាគ្រហស្ថរបស់លោកគ្រូសោមនាំគ្នាលើកក្មេងនោះបញ្ជិះសេះទៅផ្ទះតំណើតឯភូមិ ។ ចាន់ដល់កាលណា តុមារយើងធ្វើឫកដូចមនុស្សចាស់ស្ងួចំពោះប្អូនស្រីរបស់ខ្លួន អំពីមេ

គោ អំពីស្រែដែលជាកេរ្តិ៍តាពុកម្ដាយបានចែកឲ្យលោក តើឥឡូវវៅណាអស់ទៅ ? សួរអំពីស្រះទឹកដែលលោកឲ្យដីគាលនៅជាលោកគ្រូសោមហេតុម្ដេចក៏បណ្ដាយឲ្យរលាប់ខូចអស់ ? ឬនឆ្លើយថា: នុ៎ះលោកបង អើយ! ដោយហេតុមកពីទំលក្រ ក៏លក់ចាយអស់ទៅហើយមេគោនោះ ឯស្រះទៀតក៏ដូច្នោះដែរ តាំងតែអត់ពីលោកបងទៅ គ្មានអ្នកណាជួយថែរក្សាការពារ ហើយទួនរលៀតែរកទួលទាន បានជាស្រះនោះខូចដូច្នេះអស់។

សារុបសេចក្ដី សំដីដែលកូនអាចារ្យស៊ូថាចាំងប៉ុន្មាន គឺត្រូវចាំងអស់ឥតខុសត្រង់តែខ្លែងណាឡើយ ទើបគេសន្និដ្ឋានថាពិតជាលោកគ្រូសោមមកចាប់ជាតំជាកូមារនោះមែន ។

រឿងហៅរៀបដឹងជាតិ

កាលខ្ញុំនៅធ្វើជាហៅហ្វាយស្រុកតៀនស្វាយ មានស្ត្រីម្នាក់ឈ្មោះទាងជូជាប្រពន្ធឈ្មោះផ្ទូ នៅចុងស្ពានកំពង់ខ្លូ ។ ណ្ហកណ្ហាលស្ទឹងកើតកូនមកគ្មោះប្រុសចាំង ២ មួយមិនដឹងជាតិ កូនមួយទៀតដឹងជាតិកូននេះ ឪពុកម្ដាយឲ្យឈ្មោះរ៉ែច ហៅរ៉ែចអាយុបាន ៦ ឬប លេងនៅមុខផ្ទះបៀតចំភ្លើមថ្នល់ ស្រាប់តែឃើញនាងតេមនីឈ្មោះនេត មកពីស្រុកកុំស្រួច ដើរមកដល់មុខផ្ទះហៅរ៉ែច ។ ស្រែកច្រាប់ឪពុកម្ដាយពាថា ឪពុកម្ដាយខ្ញុំមកហើយ ឪពុកម្ដាយក៏ឆ្ងល់បានសួរហៅរ៉ែច ។ ថាកាលជាតិមុន ខ្ញុំឈ្មោះអីម ប្រពន្ធ

ឈ្មោះលាប់ នៅឃុំព្រែកឫស្សី (កៀនស្វាយ) ទៅសួរផុតកម្លាយនៅក្នុង
ស្រុក ខ្ញុំលឈឺស្ទាប់ ខ្ញុំនឹងដើរមកគ្នាតែនាក់ ដល់មកចុងស្ពានតំពង់ខ្ញុំល
ខ្ញុំលក្រៀងធំ ខ្ញុំក៏ទាំគ្នាចូលទៅសុំផ្ទះនាងដូនៅ ផុតកម្លាយបានដឹងដោយ
ចៅរដ្ឋបាលដូច្នេះ ក៏នាំចៅរដ្ឋមកឃុំព្រែកឫស្សី ស្រុកកៀនស្វាយ ចៅរដ្ឋ
ចង្អុលឈ្មោះនាងលាប់ថាជាប្រពន្ធរបស់ខ្ញុំ ហើយស្គាល់ឈ្មោះបងប្អូន
ខាងប្រពន្ធសឹងគ្រប់ឈ្មោះ ឯរបស់ទ្រព្យរបស់ចៅរដ្ឋ ។ ក៏ស្គាល់ ដល់
អាយុគេញុបួសជាសាមណេរ ផុតកចង់ឲ្យបួសនៅវត្តកោះក្រប៉ ចៅរដ្ឋ
មិនព្រម រត់ទៅបួសជាសាមណេរនៅវត្តពោធិល្បៅ កណ្តាលស្ទឹង ។

រឿងនេះ ខ្ញុំបានយកខ្លួនក្មេងនោះតាំងពីអាយុ ៨ ខួបមកសួរបញ្ជាក់
ហើយបានសួរបងប្អូនខាងនាងលាប់ក៏ខ្លួលថាពិតមែន ។

ឧកញ៉ាបុណ្ណចន្ទមង្គល ឧត្តមមន្ត្រីវិត្រត

(ចម្លងពីសៀវភៅ "វិជ្ជា ៨ ប្រការ ទំព័រ ១២៧ ជាសេចក្តីប្រែរបស់
លោកបុណ្ណចន្ទមង្គលពីសៀម)

(នៅមានត)

២- ឧបបជ្ជវេទនីយកម្ម

អត្ថសាធកា បន សត្តមា ជវនចេតនា ឧបប-ជ្ជវេទនីយា នាម តំ អនន្តរភវេ អនន្តរអត្តភាវេ វិបា-កំ ឆេតំ តំ បឋមំ កុសលបក្ខេ អដ្ឋសមាបត្តិ-សេន អកុសលបក្ខេ បញ្ចានន្តរិយកម្មវសេន វេទិ តព្វន្តិ ។

លំដាប់នេះ សូមវិសជ្ជនាកង៏កម្មបច្ច័យ អធិប្បាយនូវឧបបជ្ជវេ-ទីយកម្មតទៅ ដំណើរសេចក្តីថា យំ កម្មំ កម្មឯណាដែលបុគ្គល ធ្វើហើយ ឲ្យនូវផលកង៏ជាតិមុខអំពីជាតិនេះ កម្មនោះឈ្មោះថា ឧបបជ្ជវេទនីយកម្ម ។

អធិប្បាយថា ឧបបជ្ជវេទនីយកម្មនោះ ឲ្យនូវឆឹឆេតនាជាគំរប់ ប្រាំពីរឲ្យសម្រេចនូវប្រយោជន៍ ។ បុគ្គលធ្វើនូវកុសលក្តី នូវអកុសលក្តី ដោយចេតនាប្រកបកង៏ដោយចិត្តប្រាំពីរ ចេតនានោះឯងឲ្យសម្រេច

ន្ទូវផលកន្ធអត្តភាពកន្ធតពីដាល់ដាប់អំពីតពជាបច្ចុប្បន្ននោះ ។ កុ-
សលបក្ខេ បើកន្ធ១បបដ្ឋវេទនាយកម្មខាងកុសល បាននឹងសមាបត្តិ
ប្រាំបីប្រការ ។ ឯខាងអកុសលវិញ បាននឹងអនន្តរិយកម្មប្រាំប្រការ ។

សមាបត្តិប្រាំបីប្រការនោះ គឺរូបជ្ឈានបួន បាននឹងបឋមជ្ឈាន ១
ទុតិយជ្ឈាន ១ តតិយជ្ឈាន ១ ចតុត្ថជ្ឈាន ១ ។ អរូបជ្ឈានបួន បាន
នឹងអាកាសានញ្ចាយតនជ្ឈាន ១ អាកិញ្ចញ្ញាយតនជ្ឈាន ១ វិញ្ញាណ-
ញ្ចាយតនជ្ឈាន ១ នេវសញ្ញានាសញ្ញាយតជ្ឈាន ១ រួមជាសមាបត្តិប្រាំ
បីប្រការ ។

បឋមជ្ឈាននោះ ប្រកបដោយអង្គប្រាំ គឺវិតក្ក ១ វិចារ ១ បីតិ ១
សុខ ១ ឯកគ្គតា ១ ។

ទុតិយជ្ឈាន មានអង្គបួន គឺវិចារ ១ បីតិ ១ សុខ ១ ឯកគ្គតា ១ ។

តតិយជ្ឈាន មានអង្គបី គឺបីតិ ១ សុខ ១ ឯកគ្គតា ១ ។

ចតុត្ថជ្ឈាន មានអង្គពីរ គឺឯកគ្គតា ១ ឧបេក្ខា ១ ។

កន្ធទីនេះ មិនបានអធិប្បាយអំពីអង្គឈាននោះ ។ ព្រោះហួស
វិស័យនៃបច្ចុប្បន្នសត្វដែលកើតមកខាងក្រោយ សូម្បីគ្រាន់តែបាន
ឮបានស្តាប់ហើយ ក៏មិនយល់មិនចូលចិត្តផង ហេតុនេះសូមលើកទុក ។

ប្រការមួយទៀត អង្គនៃឈាននោះ ។ សាធុជនឮស្តាប់បានស្តាប់
មកហើយ ។ ជារឿយៗជារឿនដដែរៗគ្រាហើយ តម្រូវចូលចិត្តថា បុគ្គលអ្នក

ជំរើនឈាន បើឈានមិនសាបសូន្យទេ កុងលំដាប់នៃចុតិចិត្តនឹងបាន
ទៅកើតក្នុងព្រហ្មលោក ។ បឋមំ បឋវីតំ ភាវេត្វា បើបុគ្គល
បានចំរើនបឋមជ្ឈានឲ្យប្រណីតល្អិតសុខុម លុះក្រយដំរែតនឹងបានទៅ
កើតក្នុងព្រហ្មលោកជាន់មហាព្រហ្ម ។ មជ្ឈិមំ ភាវេត្វា បើបុគ្គល
ចំរើនបឋមជ្ឈានមិនសូវល្អិតសុខុមទេ គ្រាន់តែបានយ៉ាងកណ្តាល លុះក្រយ
ដំរែត នឹងបានទៅកើតក្នុងព្រហ្មលោកជាន់ព្រហ្មបរោហិត ។ ហីនំ
ភាវេត្វា បើបុគ្គលចំរើនបឋមជ្ឈានយ៉ាងទន់ខាប យ៉ាងគ្រោតគ្រាត
លុះក្រយដំរែត នឹងបានទៅកើតក្នុងព្រហ្មលោកជាន់ព្រហ្មបារិសជ្ជា ។

អ្នកប្រាជ្ញតប្បីសន្និដ្ឋានថា បុគ្គលដែលបានចំរើនរូបជ្ឈានជាប់ជា
និច្ច ឈានមិនដាច់ទេ ដល់វេលាក្រយដំរែត នឹងបានទៅកើតក្នុងរូបព្រហ្ម
តាមភូមិនៃឈានដែលខ្លួនបានចំរើន គឺថា បើចំរើនបឋមជ្ឈាន ក៏នឹង
បានទៅកើតក្នុងរូបព្រហ្មបឋមជ្ឈានភូមិយ៉ាងនេះជាដើម ។ បុគ្គលដែល
បានចំរើនអរូបជ្ឈានជាប់ជានិច្ច ឈានមិនដាច់ទេ ដល់វេលាក្រយដំរែត
នឹងបានទៅកើតក្នុងអរូបព្រហ្ម ។ អ្នកដែលបានចំរើនរូបជ្ឈានក្តី អរូប-
ជ្ឈានក្តី ជាប់ជានិច្ច មិនសាបសូន្យបាតឈានទេ លុះដល់ក្រយដំរែត
ទៀងតែបានទៅកើតក្នុងរូបព្រហ្ម ឬ អរូបព្រហ្មតាមលំដាប់នៃកតបុញ្ញាប់
អំពីកតជាបច្ចុប្បន្ន ។ ផលនៃសមាបត្តិទាំងប្រាំបីនេះ បានជាឧបបជ្ជវេ-
ទនីយកម្មខាងកុសល ។

កុសលកម្មឯណា មានផលនាំសត្វអ្នកធ្វើឲ្យទៅកើតទៅស្ថានសួគ៌ កន្លងភពខាងមុខបន្ទាប់អំពីភពជាបច្ចុប្បន្ន កុសលកម្មនោះឈ្មោះថា ឧបបជ្ជវេទនីយកម្មខាងកុសល ។ ប៉ុន្តែ កុសលកម្មផ្សេង ។ ក្រៅពីអ្នកចំរើនឈាននោះ ជួនកាលឲ្យផលនាំសត្វទៅកាន់ស្ថានសួគ៌កន្លងភពជាលំដាប់ ជួនកាលមិនបាននាំសត្វទៅកាន់ស្ថានសួគ៌ទេ ។

ចំណែកឧបបជ្ជវេទនីយកម្មខាងអកុសលវិញ បានន័យអន្តរិយកម្មធំធ្ងន់ប្រាំ គឺបុគ្គលអ្នកធ្វើអន្តរិយកម្មធំធ្ងន់ប្រាំ ឬ ធ្វើតែអន្តរិយកម្មណាមួយ លុះស្លាប់ទៅហើយ មិនបានទៅកើតកន្លងស្ថានសួគ៌ទេ ទៀងតែទៅកើតកន្លងស្ថាននរកជាប្រាកដ ឈោកអាចរាប់ណាត់ខុសយ៉ាងណាទៀងតាត់ដូច្នេះ ហេតុនោះ បានជាពោលថាអន្តរិយកម្មធំធ្ងន់ប្រាំឈ្មោះឧបបជ្ជវេទនីយកម្មខាងអកុសល ។

ឯអន្តរិយកម្មធំធ្ងន់ប្រាំនោះ គឺបុគ្គលសម្លាប់បិតាបង្កើត ១ សម្លាប់មាតាបង្កើត ១ សម្លាប់ព្រះអរហន្ត ១ ធ្វើលោហិតុប្បាទកម្ម ១ ធ្វើសង្ឃភេទកម្ម ១ ។ កម្មធំធ្ងន់ប្រាំនេះឈ្មោះថាអន្តរិយកម្ម ព្រោះហេតុឲ្យផលកន្លងលំដាប់នៃភពជាបច្ចុប្បន្នគ្មានភពឥតមានទៀតទេ គឺឲ្យផលកន្លងលំដាប់នៃជាតិ ។

បិតុឃាត ការសម្លាប់បិតានោះ សំដៅយកបិតាអ្នកញ៉ាំងខ្លួនឲ្យកើត គឺបិតាបង្កើត ។ ឯមាតុឃាត គឺសំដៅយកការសម្លាប់មាតា

ជាទំកើតនៃខ្លួន គឺមានាបង្កើត ។

អរហន្តយាដ សំដៅយកការសម្លាប់មនុស្សជាព្រះអរហន្ត ។

លោហិតុប្បាទ សំដៅយកបុគ្គលដែលញុំាងព្រះលោហិតក្នុងព្រះសរីរកាយនៃព្រះពុទ្ធជាម្ចាស់ឲ្យពុះពងឡើង សូម្បីតែប្រមាណមួយចំអុតរុយប៉ុណ្ណោះ ។

ឯលោហិតុប្បាទនោះ មិនឲ្យសំដៅយកព្រះលោហិតដែលហូរចេញពីសរីរកាយនៃព្រះពុទ្ធទេ គប្បីចូលចិត្តថា សម្តេចព្រះពុទ្ធម្ចាស់មានព្រះវរកាយប្រាសចាកការបែកធ្លាយ បើទុកជាអ្នកដែលមានឫទ្ធិប្រើនតតែប្រឹងស្តុកយក់យព្រះអគ្គនីឆ៍ដំបងយ៉ាងធំប៉ុនភ្នក់ក៏ដោយ ក៏ព្រះសរីរកាយមិនបែកចាក់ដែរ ព្រះលោហិតក៏មិនហូរស្រក់ចេញ ដូចសម្តេចព្រះពុទ្ធជាម្ចាស់របស់យើង គាលព្រះទេវទត្តប្រមៀលផ្ទាំងសិលាឲ្យធ្លាក់ត្រូវព្រះបាទសម្តេចព្រះបរមសាស្តាគ្រានោះ ព្រះសរីរកាយមិនបានបែកធ្លាយបន្តិចសោះ គ្រាន់តែឡើងពុះពងព្រះលោហិតប៉ុណ្ណោះ ។ ពាក្យដែលថាព្រះលោហិតហូរចេញល្មមតែរុយមួយផឹកឆ្អែតនោះ គឺកាលដីវកកោមរកត្បុះព្រះបាទហើយបន្ថែមក្បាព្រះកេតឲ្យស្រះជា ។

សង្ឃភេទ សំដៅយកការញុំាងសង្ឃឲ្យបែកចេញពីគ្នាដោយហេតុប្រាំប្រការ សមដូចព្រះពុទ្ធដីកាត្រាស់ទីឆ៍ព្រះឧបាលីថេរៈថា ឃញ្ចមេ ឧបាលិ កម្មំ លោហិ ម្លុ ឧបាលិ សង្ឃភេទំ បែកចេញពីគ្នា

រមែងបែកចេញដោយហេតុថ្កុំប្រការ ហេតុណាមួយ ។

ឯហេតុថ្កុំប្រការនោះ គឺអបលោភនកម្ម ១ សូត្រថាលីឡ្យទុស ចាកធម្មវិន័យដ៏ជាព្រះតថាគតវចនៈ ១ ព្យាបាទយកន្ធវស្ថាក ១ អនុសាវនកម្ម ១ ពោលរបស់មិនមែនធម៌ថាជាធម៌ ១ ត្រូវជាហេតុនៃសង្ឃបែកចេញគ្នាថ្កុំប្រការ ។

អនន្តរិយកម្មទាំងថ្កុំនេះ មានតែបុគ្គលជាបុថុជនទេដើរបាចនិងធ្វើបាន ។ ឯព្រះអរិយបុគ្គលមិនដែលធ្វើអនន្តរិយកម្មទាំងថ្កុំនោះទេ ព្រោះហេតុព្រះអរិយបុគ្គលនោះ ដោយហោចទៅសូម្បីតែស្រមោចឡូនិងស្រមោចក្រហម ក៏លោកគ្មានចិត្តគំនិតនឹងសម្លាប់ផង លោកតែងផ្សាយមេត្តាដូចជាកូនសត្វសត្វ ។

បុគ្គលអកតើអនន្តរិយកម្មណាមួយហួចហើយ តែថាអញនឹងហាមថ្កុំ ឬកំដរពន្លូវផលនៃអកុសលកម្មនោះ ទើរធ្វើព្រះស្តូបព្រះចេតិយសុទ្ធតែមាសពេញសាកលចក្រវាឡហើយទើរថ្វាយទានដល់ព្រះភិក្ខុសង្ឃដែលមកតើរពេញក្នុងសាកលចក្រវាឡ ឆាយ ស្ប កេជា ដំរាយ ៧ លុះអស់ជីវិតន្ត្រើយហើយ តែងទៅកើតក្នុងនរកមិនខានឡើយ ។ ហេតុនោះ អនន្តរិយកម្មទាំងថ្កុំទើបចាត់ចូលក្នុងទុបបជ្ជវេទនីយកម្មខាងអកុសល សម្តេចព្រះបរមទេសគលត្រាស់ទេសនាសង្គ្រោះចូលក្នុងកម្មបច្ច័យ ដូចវិសជ្ជនាមកនេះ ។

ទុបបជ្ជវេទនីយកម្ម សង្ខ្យបុំណ្ណះ ។

សម្តែចព្រះធម្មលំទំតល្អី - ឯមប្រៃរៀបរៀង

(តមក)

សាវត្ថិនោមាំ ឯក្ខន្តោ តុន្ទេន អនុតមវ្ជិតោ
ឯក្ខច្ចនិសវយេ បព្ជ្ជិ អនគារិយំ
ឧបដ្ឋាយោ សារីបុត្តោ មោគ្គល្លានោ មហិទ្ធិកោ
តោសេ ចំកេបយន្តោ មេ អនុសាសិ មហាមតិ
តោសេសុ ជំដ្ឋមានេសុ អរហាត្តមចាបុណី
ឆេវតា ច មនុស្សា ច បច្ចយានុបនន្តិមេ

ខ្ញុំបាននេញ្ជៅពីនគរសាវត្ថី តំព្រះសម្មាសម្ពុទ្ធជាម្ចាស់ព្រះអង្គ ទ្រង់មេត្តាអនុគ្រោះហើយ ខ្ញុំបានបួសក្នុងព្រះពុទ្ធសាសនា ក្នុងថ្ងៃដែលខ្ញុំចេញមកនោះឯង ។ ព្រះសារីបុត្តត្តេរជាព្រះឧបដ្ឋាយ៍ខ្ញុំ ព្រះមហាមោគ្គលនត្តេរ លោកមានវិទ្ធិច្រើនមានប្រាជ្ញាច្រើន កាលកោរសក់ចាំងភ្លាយហើយលោកប្រៀនប្រដៅធម៌ដល់ខ្ញុំ កាលបើសក់ចាំងភ្លាយជាច់ភ្លាក់ចុះអស់ហើយ ខ្ញុំក៏បានសម្រេចអរហាត្តកំចាត់បង់នូវកិលេសចាំងពួងបាន ទេវតា នាគ និងមនុស្សចាំងភ្លាយតែងនាំនៅនូវបច្ច័យចាំងភ្លាយដល់ខ្ញុំពិត ។

បទុម្មុត្តរនាមញ្ច វិបស្សិំ ច វិនាយកំ
សម្ពុទ្ធយិ បមោទិតោ បច្ចុយេហិ វិសេសតោ
តតោ តេសំ វិសេសេន កម្មានិ វិបុលុត្តមំ
លោកំ លភាមិ សព្ពត្ថ វនេ ភាមេ ផលេ ផលេ ។

ខ្ញុំមានចិត្តរីករាយ ជានបូជាព្រះលោកនាយកដ៏វិសេស ទ្រង់ព្រះនាម បទុម្មុត្តរផង ទ្រង់ព្រះនាមវិបស្សីផង ដោយបច្ច័យតាំងពីរយៈដ៏ប្រពៃគ្នា ។ ដោយផលបូជានោះឯង ខ្ញុំតែងជានខ្លួរលាភបរិបូណ៌ដ៏ឧត្តមគ្រប់ទីតាំងពួន គឺ: ទីព្រៃ ទីស្រុក ទីគោកនិងទីទឹក ដោយផលដ៏វិសេសនៃបុញ្ញកម្មតាំងពីរយៈនោះពិត ។

វេភារឧស្សុនន្តាយ យនា យាតិ វិនាយកោ
តីសតិក្ខុសហាស្សេហិ សហាលោកគ្គនាយកោ
តនាឧភតិតេហិបិ មមត្ថាយ មហាមតិ
បច្ចុយេហិ មហាវីរោ សសំឃោ លោកនាយកោ
ឧបដ្ឋិតោ មយា តុន្នោ កត្វា វេត្តមច្ឆសំ
តតោ ផេតវិំ កត្វា ឯតឆត្តេ ឋបេសិ មំ
លាភីនំ សិរិលីអគ្គោ មម សំសេ្សសុ កិត្តយិ
សព្ពលោកហិតោ សត្ថា កិត្តិយសរវិសារទំ

សម្តេចព្រះលោកនាយកដ៏វិសេស ប្រសើរលើសក្នុងលោក ព្រះអង្គ

តែងដឹកនាំសត្វ ព្រះអង្គបានយាងទៅជាមួយនឹងភិក្ខុសង្ឃចាំងឡាយ ចំនួនអង្គ ដើម្បីទ្រង់ចតរវៀត្តត្នោតឥតកាលឯណា សម្តេចព្រះសង្ឃរាលោកនាយក ជាអង្គព្រះសម្ងាសម្ពុទ្ធព្រះអង្គមានប្រាជ្ញាច្រើន មានញាយាមដ៏ប្រសើរគឺខ្ញុំបានបំរើហើយ ដោយបច្ច័យចាំង ៤ ដែលទៅតាចាំងឡាយបាននាំយកមកហើយ ដើម្បីប្រយោជន៍ដល់ខ្ញុំក្នុងកាលនោះឯង ព្រះអង្គយាងទៅបានឃើញរវៀត្តត្នោ លុះដល់ព្រះបរមគ្រូទ្រង់យសសាស្តាចារ្យ ព្រះអង្គតែងមានព្រះទ័យ ប្រាថ្នាខ្លួប្រយោជន៍ដល់សត្វលោកចាំងអស់ ព្រះអង្គបានត្រឡប់មកអំពីទីនោះមកកាន់វិហារព្រះជេតពន្ធវិញ ព្រះអង្គបានសរសើរខ្ញុំផ្សាយទៅក្នុងបរិសទចាំងឡាយ ព្រះអង្គទ្រង់តម្កល់ខ្ញុំជាឯតទគ្គៈ ទ្រង់ត្រាស់ថា ម្នាលភិក្ខុចាំងឡាយ បណ្តាសិស្សចាំងឡាយរបស់តថាគត ឯសីវលិត្នោះ ជាភិក្ខុប្រសើរលើសជាងភិក្ខុចាំងឡាយ បានខ្ញុំលាភក្នុងសាសនាព្រះតថាគតពិត ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតោ
ជាតោវ ពន្ធនំ ឆេត្វា វិហរាមិ អជាសវោ
ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តោ កតំ ពុទ្ធស្ស សាសនំ
បដិសម្ភិទា ចតស្សោ វិមោក្ខា បិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា្វ កតំ ពុទ្ធស្ស សាសនំ

តំលេសតាំងឡាយ គឺខ្ញុំបានដុតរំលាយហើយ កពតាំងឡាយតាំងអស់គឺខ្ញុំបានដឹកនាំលើងអស់ហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈធម៌ឡើយ ប៉ដូចជាដំរីដ៏ប្រសើរបានកាត់ចំណងអស់ហើយ ។ ដំណើរដែលខ្ញុំមកក្នុងសំណាក់ព្រះពុទ្ធដ៏ប្រសើរដោយវិសេស គឺខ្ញុំបានមកហើយដោយប្រពៃពិត វិជ្ជាតាំងឡាយប៉ក៏ខ្ញុំបានសំរេចហើយ សាសនារបស់ព្រះភុទ្ធជាម្ចាស់ ក៏ខ្ញុំបានធ្វើឲ្យសំរេចហើយ ។ គុណធម៌តាំងប្រាំប៉នេះ គឺបដិសម្ភិទាបួន វិមោក្ខបួនក៏ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ អភិញ្ញាតាំងប្រាំមួយក៏ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ព្រះពុទ្ធសាសនាក៏ខ្ញុំបានធ្វើឲ្យស្រេចហើយ ។

ព្រះសីវលីត្ថេរដ៏មានអាយុ លោកបានពោលសំដែងព្រះគាថាតាំងឡាយនេះ ដើម្បីប្រយោជន៍មានប្រការដូច្នេះឯង បពិត្រសម្បាសតាំងឡាយ បើអ្នកតាំងឡាយ បានស្តាប់នូវអានុភាពនៃបុណ្យដ៏ប្រសើរធំយ៉ាងនេះផង នូវសិរីសម្បត្តិនៃបុគ្គលដ៏មានសិរីធំយ៉ាងនេះផង បើមានសេចក្តីប្រាថ្នាធំក្នុងចិត្តហើយ ត្រូវតែលះបង់សេចក្តីឯលប្រមូសចេញឲ្យស្រឡះ ហើយប្រព្រឹត្តធ្វើកុសលឲ្យច្រើនទើបបានសំរេចព្រះនិព្វាន អាចរំលត់នូវកពធំធងកោតតាំងភ្លឹងបានដោយពិត ។

សំដែងរឿងនិទានព្រះសីវលីត្ថេរជាគំរប់ដប់កន្លះយកវាភ្ជាតវគ្គទីបី ក៏ចប់សេចក្តីជាសន្ទោះតែប៉ុណ្ណោះឯង ។

(តមក)

លើកដំរីធំប្រាប់ជាមួយអញកាលនេះឯង ព្រះមហាសត្វអ្នកនិរាសលួងយល់ខ្លួនប្រាប់ជាមួយនឹងតិរច្ឆានោះហើយ ទើបអ្នកខ្លួលមហាកុរុត្រដោយខ្លួនហេតុនោះដល់គាថាជាដំបូងថា :

សព្វេ មេ មាតុលា នេ ច កាឡាឆាសព្ភូ ឆេឆសិ
ឃំ បញ្ចាលចន្ទសុ វេនេហោ ឆេទយិសុតិ

។ ល ។

សុខាវហោ ទុក្ខទ្ទោ វេនេហាសុ យសស្សិនោ
មតិន្តេ បដិហញ្ញាមិ ឧសុំ បលសតេន ច ។

បពិត្រមហាកដើយ ! ថាបើព្រះអង្គនឹងកាត់ដៃ ចិតត្រចៀកច្រមុះ ខ្ញុំឯងឲយហើយ សមព្រះបាទាវិទេហាកដអង្គាស់ខ្ញុំឯងឲយ ព្រះអង្គអ្វីទៅទំនេរឡើយ អ្នកឲ្យកាត់ព្រះហស្ត កាត់ព្រះបាទ ចិតត្រព្រះកាណ ចិតត្រព្រះនាសា ចៅបញ្ចាលចន្ទកុមារ នាងបញ្ចាលចន្ទី នាងនន្ទាទេពីព្រះមាតាឯនាយអស់ណាព្រះអង្គ បពិត្រមហាកដកុរុត្រប្រសើរអើយ ! ថាបើព្រះអង្គកាត់ជើង ដៃ ចិតត្រចៀក ច្រមុះខ្ញុំហើយ អាសូរនាងនន្ទាសម្តេចព្រះប្អូនព្រះអង្គ ។ ស្តាយហើយស្តាយព្រះបាទ ព្រះហស្តនាងសស្ងួលមូលរៀវស្អាង សមបុងធំធំកំបុតត្រង្គុតទេហ៎ ព្រះស្រោតចាំងពីរ

ស្រៀវស្រាប់សមនឹងព្រះកត្តិមិញកំបុតហោង ព្រះនាសាសសូលល្អដូច
ខេវគា ដូចខងតង្វេរបុនឹងត្រងិលកំបុតខេហ៎ះ ។ រីមហាពជព្រះអង្គ
កាត់ដើង កាត់ដៃ ចិតត្រចៀក ច្រមុះខ្ញុំហើយ ព្រះជុតវិនេហពជ
ព្រះអង្គនៅចំនេរអង្គាល់ឡើយ អ្នកកាត់ព្រះបាទ ព្រះហស្ត ចិតព្រះ
កាណ៌ ព្រះនាសាមហាក្សត្រទាំង ៤ ព្រះអង្គដូច្នោះហោងមិនខេឡើយ ។

សចេ មំ សញ្ញ អាតមំ ស្វសេ កត្វា បដិសន្ធតិ

មួយវិញទៀត មហាពជអើយ បើព្រះអង្គដោតខ្ញុំលើឈើសូល ដូច
ព្រះទេស្តបន្ទូលនោះ ពុំនោះនឹងស្មេរពេលខ្ញុំហើយ កំព្រះជុតវិនេហពជ
អម្ចាស់ខ្ញុំ អ្នកនឹងឲ្យស្មេរពេលចៅបញ្ចាលចន្ទីតុមារ នាងបញ្ចាលចន្ទី
នឹងនាងនន្ទាព្រះអគ្គមហេសី ព្រះមាតាព្រះអង្គដូច្នោះឯង តុអាសូរសម្បូរ
នាងនន្ទាសទៀមតំហ្នងបំព្រងផ្លូវផង់ សមនឹងពងរលាកលួយខ្ទោចផ្ទា
អស់ហោង ។

សចេ មំ វិតុទិត្វាន វេចយិស្សតិ សត្ថិយា

មហាពជអើយ ពោះយោបីព្រះអង្គនឹងតាសាចខ្ញុំច្រំពាត់នឹងលំពែង
ព្រះជុតវិនេហពជអម្ចាស់ខ្ញុំព្រះអង្គ កំតាសាច់សម្តេចព្រះពជបុត្រាបុត្រី
ព្រះពជខេពី ព្រះមាតាប្រាកដ កុំព្រះអង្គសន្ទុះឡើយ ។

ឯវំ នោ មង្គលំ វហោ ។ ល ។ បដិហន្តុវ

មហាពជអើយ ព្រះអង្គស្តាប់ខ្ញុំទូលឲ្យសព្វព្រះពជហឫទ័យ

អម្បាលគំនិតខ្ញុំនឹងព្រះបាទវិទេហរាជអម្ចាស់ខ្ញុំ ទៅគិតនាឋានស្មាត់តែអម្ចាស់ខ្លួនខ្ញុំតាំងនោក់ឯង សឹងសំរឹទ្ធិបរិបូណ៌ហើយ បពិត្រព្រះសម្មតិទេព អើយថាបើព្រះអង្គធ្វើទុក្ខខ្ញុំ ឮទៅដល់នគរមិថិលានាយថា ឥឡូវនេះព្រះបាទបុឡ្ខនស្តេចឲ្យកាត់ដើង កាត់ដៃ ចិតត្រចៀក ច្រមុះ ពុំនោះថា ឲ្យចាក់ដោត ស្មោរ ពេល ខ្ញុំឯងាយហើយអម្ចាស់ខ្ញុំអ្នកនឹងអត់អង្គាល់ឡើយ នឹងឲ្យកាត់ព្រះហស្ត កាត់ព្រះបាទ ចិតព្រះនាសា ចិតព្រះស្រោត ពុំនោះសោត ឲ្យដោតចាក់ពេលស្មោរព្រះរាជបុត្រតាំងពីរនូវអាយ៌អគ្គមហេសី នឹងព្រះវរមាតាព្រះអង្គពុំលែងឡើយ ទោះប៉ព្រះអង្គនឹងធ្វើខ្ញុំម្តេចៗក្តី ព្រះបាទវិទេហរាជអម្ចាស់ខ្ញុំឲ្យធ្វើទុក្ខអស់មហាក្សត្រតាំង ៤ ព្រះអង្គជូរញ្ជោះដែរ ថាបើព្រះអង្គកាត់ដៃខ្ញុំឯងាយ ក៏អម្ចាស់ឲ្យកាត់ព្រះហស្តនាងឯងាយ បើកាត់ដើងខ្ញុំឯងាយ សមកាត់ព្រះបាទនាងឯងាយ បើចិតត្រចៀកច្រមុះខ្ញុំឯងាយ ក៏ចិតត្រចៀកនាងឯងាយ បើដោតខ្ញុំឯងាយ ក៏ដោតនាងឯងាយ ស្មោរពេលខ្ញុំឯងាយ ក៏ស្មោរពេលនាងឯងាយដូរញ្ជោះហោង ។ បពិត្រមហាកដអើយ ព្រះបាទវិទេហរាជនឹងខ្ញុំមិនវិស័យព្រះអង្គទ្រង់ព្រះករុណាយកខ្ញុំជាកូនអំពីក្មេងអាយុ ៧ ឆ្នាំ សព្វព្រះរាជហប្ញទ័យមហិមា ស្មើរកើតអំពីព្រះឧទរ ឯនាងទុម្មេធវិជវរអយ៌អគ្គមហេសីសោត យកខ្ញុំជាប្អូនស្មើឯកឧទរមួយ ព្រះអង្គតាំងពីរឯងាយប៉ុណ្ណា ព្រះអង្គឯងាយសម្ងាប់ខ្ញុំហើយ អស់ក្សត្រតាំង ៤ ព្រះ

អគ្គិឯនាយ សមនឹងសុគតអស់ហោង ។ បពិត្រមហាភដអើយ នាគំនិត
ខ្ញុំរិះគិតថ្វាយព្រះបាទវិទេហភដនាហានស្ងាត់នោះដូច្នោះហោង ។

បពិត្រមហាភដអើយ ឧបមាដូចជាជាងស្បែក យកស្បែកមក
ស្ងោរមួយរយដងឲ្យទន់ល្អ ហើយរចនាធ្វើជាសេលេ សម្រាប់ការពារ
កាំលំពែងក្បាអាត្មា នាគណ្ហាលសង្គ្រាមតុំឲ្យត្រូវខ្លួនគោះមានប្រសើរ
ម្តេចមិញ បពិត្រមហាភដអើយ ខ្ញុំនាំសារតើសុះទាំងពួងហៅជាមសុះ
ប្រសើរ មកថ្វាយព្រះបាទវិទេហភដ ខ្ញុំបន្ទោកុំគួរសោកតុំឲ្យព្រួយព្រះ
ហប្ញទ័យដល់តិចឡើយដោយប្រាជ្ញាខ្ញុំ ឧបមាដូច្នោះហោង ។ មួយទៀត
សោតខ្ញុំយកប្រាជ្ញាខ្ញុំទៅរាំងទាស់ឃាត់ប្រាជ្ញាព្រះអគ្គខ្ញុំអ្វី ទំនឹងឲ្យបានដឹង
ព្រះហប្ញទ័យចេតនាប្រាថ្នាមហាភដដូច្នោះហ៊ុន ? បពិត្រមហាភដអើយ
នាថាមខ្ញុំស្មើសេលាងាងស្បែកស្ងោរ ១០០ ដងដឹទន់ស្ងួតមហិមា ប្រាជ្ញា
ព្រះអគ្គិដូចគាំបាញ់មកត្រូវសេលោនោះក្តី ទំនឹងទៅព្រីអ្វីសេលោនោះ
ទៀយ ។

ព្រះបាទបុត្តិ ស្តេចស្តាប់ពាក្យព្រះមហាសថហើយ គិតក្នុងព្រះភដហប្ញទ័យឯងថា នាព្រះមហាសថបុត្រគហបតីនេះ តើកស្រដី
ម្តេចដូច្នោះហ៎ះ ឥឡូវដោយគិញឃើញស្រដីថា បើអញសម្លាប់កូនព្រះ
បាទវិទេហកស្តេចនឹងសម្លាប់កូនប្រពន្ធអញឯម៉ិចលាន តនាយដូច្នោះ បើ
អញធ្វើទុក្ខកូនឯអាយម្តេចមិញ ក៏ព្រះបាទវិទេហភដធ្វើទុក្ខកូនប្រពន្ធអញ

ឯនាយវិញ្ញេហោង នាអញ្ញាឱ្យចាំរក្សាកូនប្រពន្ធមហាមាត្រ ក៏ដាមកលួចចាប់យកទៅត្រង់ណាអញមិនដឹង មហាសថវាធ្វើជាស្រដីៗថាយកលមកតវាកូនខ្ញុំ ហេតុតែខ្លាចតាយនឹងស្វាប់មកដល់ ឃើញថាខ្លួនឯងស្វាប់ហើយ វាសេះសៅងស្រដីរវើរវាយដូច្នោះទៅហោង ។ ឆម្ងួតាអ្នកនឹងស្វាប់ហើយស្រដីដូច្នោះឯង អញមិនជឿពាក្យមហាសថដល់តិចឡើយ ដើម្បីចមនុស្សនឹងស្វាប់វាស្រដីរវើរវាយដូច្នោះឯង ។

មហាសត្តោ អយំ មំ កយេ ករេតីតិ មញ្ញតិ ជាជាបេសុញ្ញមិ ឧដ្ឋិ ចិន្តេត្វា អាហ

កាលនោះ ព្រះមហាសត្វតិតក្នុងព្រះហឫទ័យថា នាព្រះមហាក្សត្រនេះ ធ្វើយល់ហាក់ដាក្រអែសទេ ពុំជឿនៃពាក្យអញ សមស្តេចនេះសន្និដ្ឋានក្នុងព្រះកដហឫទ័យថា អញនេះតាយនឹងមរណសង្គ្រាមហើយបានជាស្រដីដូច្នេះហ៎ះ បើដូច្នោះអញនឹងទូលមហាក្សត្រនេះឱ្យជាក់ច្បាស់ជាក្សត្រីតាំង ៤ ព្រះអង្គ ទើងព្រះចុងវិទេហភដ្ឋចទៅដល់មិចិលានគរហើយ ក៏ព្រះមហាក្សត្រជឿពាក្យអញហើយ ទើបនឹងមានព្រះហឫទ័យនោះខន់មកកាន់អញបាន ព្រះមហាសថអ្នកតិតដូច្នោះហើយ ទើបអ្នកទូលដោយគាថាវេះថា :

ឥច្ឆ បស្សុ មហារាជ សុញ្ញំ អន្តេបុរំ តវ
ទិវេរា ច កុមារា ច តវ មាតា ច ទេវិយា

ឧម្មគ្គា ដ៏ហរិត្វាន អេនេហាសុប្បដាធិតាតិ ។

បពិត្រកុសត្រៃថ្លៃប្រសើរអើយ សមព្រះអង្គមិនដឿងកុសល ខ្ញុំសូមយាត់ព្រះអង្គឲ្យទៅមើលឯព្រះពុទ្ធមន្ទីរសិនចុះ ម្ល៉ះសមស្វាត់ដ្រង់អស់ហោង ។ មហាពុទ្ធអើយ ខ្ញុំឲ្យអស់យោធាឲងដ្រួតទៅនាំសម្តេចព្រះពុទ្ធបុត្រាបុត្រី ព្រះអគ្គមហេសីពីព្រះពុទ្ធមន្ទីរ ដោយខ្លួនខ្ញុំក្តីឲងឡើងមកថ្វាយព្រះបាទវិទេហពុទ្ធធំ ខ្ញុំផ្សំមូលព្រមល្មមតាយប់មិញនាពុត្រ ឲ្យដំណើរស្តេចទៅកាន់មិថិលានគរនាយហើយ ។

តំសត្វា ភគា ចិន្តេសិ មហាកុសត្រស្តាប់ពាក្យនោះហើយ ក៏គិតក្នុងព្រះហឫទ័យថា អេះមហោសថនេះ ស្រដីពាក្យនេះខ្លាប់ត្រែមហិមាក្តាត់ហ៎ះ កំយប់មិញសោត អញឮដូចគាឲនខ្លាឯងយំខាងឆ្នេរស្ទឹង រីមហោសថនេះវាមានប្រាជ្ញាចេះ១ថាយកលក្តាត់ណា មានកាលវាយល់ឆ្ងល់ប្រាជ្ញា១ថាយកលមែនពិតដឿងហ៎ះ តែឆ្ងល់ស្រដីដូចគាលអញទៅចាមមិថិលានគរ ពស្តុតល ១៨ អក្ខោភិនី ហើយស្តេច ១០១ ក៏ពបង្ហើលឆ្ងល់១ថាយកលប្រាជ្ញាឆ្អែលតែសំពត់មិនតិតជាប់ចង្កេះ សេះ រទេះ ដំរីគ្រឿងអាវុធស្វាប់បង់អស់ នោះមិនគឺប្រាជ្ញាមហោសថហ៎ះ ម្តាយអញកូនប្រពន្ធអញក្តី ថាន់លុះតណ្តាប់ដៃពាក្រាតដងឆ្ងល់មិនដេឡើយ ព្រះបាទពុទ្ធមន្ទីមហាកុសត្រពើឆ្ងល់មើលប្រាជ្ញាព្រះមហោសថដូច្នោះកុំ ព្រះអង្គសោយសោកាណាល់អំពល់ខ្លួនពុទ្ធនោះមហិមាច្រើនក្រៃ បទអាល័យទៅ

ក្សត្រ ៤ ព្រះអង្គ ទំដម្រង់ព្រះស្មារតីធ្វើពុំសោកឡើយ ហើយឲ្យហៅ
អាមាត្យមកប្រើ បន្ទូលជាគាថាដូច្នេះ ។

ឥដ្ឋំ អនិដ្ឋមុំ មយ្ហំ កម្មាន វិចិត្តាឥ ន
យថា ឥមស្ស រាជនំ សច្ចំ ភ យទិ ភ មុសាតិ

ហៃអាមាត្យនាប់ឡើង ចូរព្រះស្តេងទៅ។ សួរតិចារណាមើល
ព្រះពជមន្ទីរអញជាមែនពិត ដូចពាក្យមហោសថនោះ ឬវ៉ាស្រដីកុំតកវ
ទេហ៎ះ ។

ឯពជអាមាត្យស្តាប់ព្រះបន្ទូលមហាក្សត្រហើយ ម៉្លោះទៅនិងពួក
បរិវារជារាប់ពន់ព្រះពជមន្ទីរ បើកទ្វារចូលទៅកូរស្ទាត់ជ្រង់អស់ យល់
តែមនុស្សតែមនាក់ឡើយឡែតចំពុនចំលែ តែនឹកឃ្លាព្រះពជមន្ទីរ សឹងមាន
ដើងរួបរឹតចុកមាត់ ចង់ព្យារឿងសព្វចន្លាស់ទឹកហើយដើរទៅមើលឯពេង
ត្រួតនោះ យល់សឹងតែបំណែកកាដន៍សស្វាចក្រែរណែលទៅនោះ
មើលទៅគោដនាហារដែលធ្លាយនោះ ចាក់ប្រាយកយស្វាចសាចរំពេច
ពេញពាំងពេងត្រួត បើកទ្វារឃ្លាំងមើលទៅតនាមាសប្រាក់ សឹងចាក់
កើបយកអស់ ដើរទៅមើលឯល្វែងក្រឡាបទ្ធបរមសុខប្រជាប់មានស្រី
សួស្តីនោះមិញ បើកចេញស្រឡះស្ងាត់ទេ ដូចផ្ទះសាធារណ៍ពាំងឡាយ
បង់ម្ស៊ៀត ពពួកក្អែកពាំងឡាយហើរប្រញាប់ ចូលមូលទៅដោយទ្វារ
ទ្វារបង្ហិច ឬពជពិតពលោកអប្រិយ៍តតសួស្តី ដូចកូមិសមសាន្ត ដូច

ស្រុកមានឆ្នេរសមុទ្រធំគេវត់ចោលចង់មើលគេរហាង ។ ទើប
អាមាត្យម៉ម្ចាំលមកក្រាបទូលមហាសត្រូវបទតាថាដូច្នេះថា :

ឯវមេតំ មហារាជ យថា អាហ មហោសធោ
សុញ្ញំ អន្តេបុរំ សព្វំ តោតមតនកំ យថាតំ ។

មហារាជ បពិត្រមហារាជសត្រូវដ៏ប្រសើរអើយ ! មែនពិតដូចពាក្យ
មហោសថទូលព្រះអង្គនោះឯង បពិត្រមហារាជអើយ រាជមន្ទីរក្តី
បុរាណព្រះអង្គសូន្យអស់មិនយល់ជាព្រះរាជមន្ទីរពិតពិលោក មានស្រី
សួស្តីឡើយ កំពាអប្រើយដូចស្រុកនៅត្រើយសមុទ្រគេវត់ចោល ក្អែក
ត្មាតចាំងឡាយហើរគគិកមកចឹកស៊ីជាចំណីអាហារ តុំនោះសោតដូចព្រៃ
សមសាន្តហាន់ស្ងាត់នោះហោង ។

តំ សុត្វា រាជា ចតុន្នំ ឧបាសិកានំ តោសិតត្តស្ស
អតិរិយ កុជ្ឈ ។ ព្រះបាទបុប្ផន័មហាសត្រូវ ឮពាក្យអាមាត្យ
ទូលដោយនូវប្រការទាំងអម្បាលនោះហើយ កំញ៉ាវន្ធត់អស់ទាំងព្រះអង្គ
ទីងគង់លើដំរាំស្រណុកឡើយ ដោយនូវហេតុសោកសត្រូវទាំងបួនព្រះអង្គ
នោះ កិរិយាលន័ងពោធិសត្វនោះមហិមា ពុំទាំងព្រះកត្តុំដួលក្តៅកង
ព្រះហឫទ័យ ដូចអ្នកយកភ្លៀងភ្លៀងលើកន្ទុយនាគរាជ ហើយទ្រង់
ព្រះចិន្តាថា អញជាពុក្ខមន់ម៉្លេះ នេះមិនបានដែរក្រែលែងន័ងមហាសត្ថ
បុត្រនេះឡើយ អញអ្វីទៅឲ្យវាមានអាយុរស់ដូច្នោះ ព្រះមហោ

សព្វអ្នកប្រាជ្ញអាចដឹងអធ្យាស្រ័យ យល់ត្រះជាខុទ្ទកនិកាយមហាកប្បត្រនេះឡាល់
ពន់ប្រមាណ អ្នកកំតំតជាមហាកប្បត្រនេះឡាល់ខឹងអញណាស់ហើយហ៎ះ
អញប្រាំហាសឯណាជាន ដ្បិតស្តេចនេះជាធំលើអស់ស្តេចទាំង ១០១
មានយសបរិពារពេលសកលរោជាជាច្រើន ឥឡូវនេះស្តេចឡាល់មហិមា
មានកាលមកដោយខ្លួសមានចិត្តក្តីមនោមានះ ជាមហាកប្បត្រមកបៀត
បៀនអញជាខហើយ អញខឹងខុកឥឡូវសមខឹងស្មាប់អញប្រាកដ ឯ
ព្រះមហាសថអ្នកត្រែរ៉ះសិហានាទតុំក្តីកដូច្នោះហើយ ទើបអ្នកតំតកង
ប្រាជ្ញាឈ្នះយល់មួយរំពេចនោះ អ្នកថាមហាកប្បត្រនេះ សព្វព្រះហឫ-
ទ័យខឹងព្រះនាងនន្ទាជាអគ្គមហេសីនោះណាស់ ឥឡូវនាងនន្ទាលីលា
ទៅហាននឹងយ អញខឹងស្រដីសរសើរតាមដំណើរអំពីលំអរូបនាងនន្ទា
ដោយខ្លួប្រាប្រាជ្ញាអញនេះ ខូលមហាកប្បត្រឲ្យសព្វព្រះហឫទ័យក្បាត់រលឹក
តំតទៅប្លួននាងនន្ទា ហាក់ដូចមហាកប្បត្រកាលមិនដែលយល់នាងដល់
ម្តងនោះ ម្តេចទៅអេះ ម្ទេះហើយអញសរសើរលំអនាងជាក់ប្រាកដ
ហាក់ដូចយល់ ហាក់ដូចតង់ខាងបណ្តាយ ហើយព្រះមហាកប្បត្រខឹងឆ
រលឹកខឹកដល់ទៅនាងនន្ទា ខឹងផ្សាខ្ញាចក្នុងព្រះនរកព្រះហឫទ័យអាល័យ
ក្រៃពេក ទើបស្តេចតំតថាទេហ៎ះ អញសម្លាប់មហាសថឯណាជាន
ឡើយ បើអញសម្លាប់មហាសថហើយ សមនាងនន្ទាទៅស្រីតែប្រសើរ
អញ ក៏គេនឹងសម្លាប់នាងនោះហោង អញគួរស្នេនក្បាខុកមហាសថ

នោះ ខ្ញុំបាទអញចូលនាងនន្ទាមកជាអគ្គមហេសីវិញ ដ្បិតស្តេចគាប់ព្រះទ័យដោម ថ្នមវិញមកកាន់អញមិនលែងឡើយ មហាក្សត្រនឹងសោកនាងជាអគ្គមហេសីហើយ នឹងធ្វើអ្វីអញដល់តិចជាន់នោះគ្មានសោះឡើយ ព្រះមហាសត្តតែងដូច្នោះហើយ ខ្ញុំបាទឈរលើប្រាសាទស្អាតយកនូវព្រះបាស្តដ៏មូលសសួលដូចបណ្តូលលាមាសពេជ្រចេញពីលង្វែកសំតត់រត្នកម្ពលដំកល់ចង្អុលណែនូវ នាំឲ្យដំណើរនាងនន្ទាទៅមកខ្លួនប្រាប់ជាសណ្តាប់ព្រះជាតិចុងក្រោយនូវបទគាថាដូច្នេះ :

ឯតោ កតា មហាភាគ ជាវ័ សព្វង្គសោភនា
តោសុម្ភជលកសុសេ្ឋណី ហំសកត្តរកាណិនី

។ បេ ។

ជាតជាស្សុកល្យាណី បឋមា តំម្ពវុត្តនី
ជាតំនីឃា ជាតំរសេ្ឋ ជាតំលោមា ជាតំលោមគាតិ។

មហាភាគ បពិត្រមហាភាគដអើយ ឯនាងនន្ទាខ្ញុំព្រះស្តេរឬប្រសើរជាព្រះអគ្គមហេសីព្រះអង្គនោះ មហាភាគដអើយ នាងល្អជ្រួកចំឡែតលែងក្សត្រីស្រីនាងឡាយ រស្រីធនបន្តិចល្អម្ភ ដងខ្លួនអាក្រក់ បើខ្លួនល្អហើយដៃជើងអាក្រក់ ល្អសក់ដោះសណ្តាយ ល្អដោះដំណើរឆ្គង ដំណើរល្អមហើយ សម្បុរអាក្រក់វិញ ឯត្រង់នាងនន្ទាខ្ញុំព្រះអគ្គមហេសីព្រះអង្គនោះ មិនដូច្នោះឡើយ មហាភាគដអើយ ល្អណាស់ សឹងមានព្រះអង្គ

កបន្ទូលក្តណា ល្អតាំងអស់ជាមួង មិនខ្វះត្រង់ណាជាអាក្រក់ដល់ ១
ចម្រៀកសក់នោះគ្មានឡើយ យល់ហាក់ដូចគូនម្រឹតទើបកើតលៃមួយ
ភយល់ទ្រមែកំដែង ល្អមុខគួរតែស្រឡាញ់ មហាក្សត្រអើយ បើនិងតន់
រមៀលមើលអំពីចមួយនាងមានលំអដូចកើងនេះលើកុំ នាងត្រីមានស្មើ
អណ្តាតកើងនោះខ្ពស់ បើរមៀលមើលពីចមួយទៀនោះ កំយល់សន្ទៀ
រុងរឿង លំអនាងគួតណានាដូច្នោះ តុំនោះសោតឧបមាដូចតំពាំង
ឫស្សីលំតង់កំពុងលូតខ្លឹផុសអំពីដីឡើង ភយល់ល្អក់ល្អៅល្អម្តេចមិញ
មិនយល់ជានាងមានចំណាស់មានព្រះរាជបុត្រតិរហើយ កបមានលក្ខណា
ឯកងអង្គនោះ៥ប្រការ នាងល្អសម្បុរ ល្អព្រះកេស ល្អសរីសាច់
ល្អធ្មេញ ហៅថាបញ្ចតិឥតល្បាណី ។ បឋមា តិម្ពរុត្តមិ នាងមាន
ព្រះសុជន់តាំងពីរនោះក្បោះក្បាំសមនឹងព្រះទរពុំខ្ពើយពុំសណ្តាយ ជាក់
ឆ្នាក់ពុំត្រនាក់ខ្សែត្បាញឡើយ បីដូចអ្នកយកផ្ទៃមុខមាសប្រពៃដំកល់
ឲ្យដ៏ក្តារមាស ។ ជាតិលោមា ជាតិលោមកា ។ នាងមាន
រោមធ្មារខន់ តក្តែបំព្រង មានព្រះអង្គនាងល្អ កបន្ទូលអម្រាមកំពស់
អម្រុង ។ ជាតិឆិឃា ជាតិរស្សា មហាក្សត្រអើយ នាងមិនខាប
ពេកមិនខ្ពស់ពេក ។ ហាត្ថលតា នាងមានព្រះហស្តតាំងពីរនោះមូល
សសូលល្អ កបន្ទូលអម្រាមរៀវសូង ដូចខង់លតាមាសកើតនាព្រៃចិត្ត-
លតាវ័ន ។ កោសេយ្យវាសនា មហាក្សត្រអើយ នាងវែងត្រង់

ព្រះពស្ត្រគោសេយ្យពស្ត្រ សឹងបាក់ធ្លាក់ចេញទាំងសូត្រចេសមាសប្រពៃ
ហើយនៃ ប្រដាប់ប្រដាព្រះអង្គសឹងវត្ថុពិចិត្រដោយមាស បពិត្រក្សត្រ
ប្រសើរអើយ នាងនន្ទាសម្តេចព្រះប្អូនគេស្រឡះ ប៉ុន្តែព្រះអង្គទេមិនល្អ
ឥតប្រមាណ ចំណង់បើបានទ្រង់គ្រឿងប្រដាប់សំពាប់ មហាភរហើយ
រឹងជាល្អមួយសាក្រែមហាល្អ មហាភរអើយ ខ្ញុំទើបបានយល់ជាល្អ
ប្រាកដចម្លែកចំណង់ចិត្តព្រះអង្គ ។ គោសុម្ភជលកសុសេត្ត-
ណី បពិត្រមហាភរអើយ ថាបើនឹងរមិលមើលបង្គុយនាងសោត
នាងមានបង្គុយនោះកបខ្ពស់ល្អដូចក្តារមាសគឺតដំជាងខ្នងប្រពៃ
មានប្រក្រតីស្រដីសមនូវសម្លេងនោះមធ្លូមូលផ្អែមក្រឡុពីកេះដូចសម្លេង
ភរហង្ស ព្រះមហោសថអ្នកវៀយល់បង្គុយនាងនោះកាលឯណា ថា
កាលនាំនាងចូលទៅកន្លែងគង្គ នាងកំតរសាយទាំងព្រះសុក័តធ្លាក់ចេញ
អស់អំពីព្រះអង្គ តង់ស្រឡះត្រចះល្អឥតប្រមាណ នាខ្ញុំតន់ទៅឯដំ-
ណើរនាងនោះដ្រទន់ញ៉ែងញ៉ង ឥតធ្ងន់ឈ្ងង់ល្មមឈមយល់សិរី មាន
សំដីនោះពីកេះ ។ ហំសកត្តរកោណិដ្ឋ ចបមាបីដូចកូនភរហង្ស
ដើរចេញទៅកាន់ម្តាយហើយយំ មានសម្លេងនោះមូលមធ្លូវផ្អែមពីកេះ
បពិត្រមហាភរអើយ នាព្រះបាទនាងនន្ទាភាំងពីរ ថាបើនឹងរមិលមើល
ទៅផ្ទៅល្អដូចដើងព្រាប ខ្នងរមិលមើលពីដងខ្លួនទៅចង្កេះនោះស្រឡៃ
រៀវល្អដូចកុណ្ឌីមាស មិនស្តើងពេកមិនក្រាស់ពេក ព្រះនាងមានរឹមព្រះ

(ខៅមានត)

អក្សរសាស្ត្រខ្មែរ	ខ្មែរធ្លាប់ចែចួន
ឲ្យបានខ្ជាប់ខ្ជួន	គង់វង្សគង់មត់
ព្រោះអក្សរជាតិ	ពោលជាតិប្រាកដ
អក្សរសេត់	ជាតិក៏រលាយ

ច. ព.

(វិចារណាកថា)

ខ្មែរកម្ពុជាយើងខ្ញុំបានគុណលើកូនមែនឬមិនមែន

លោក ផេង-គ្រីវ៉ រៀបរៀង

កូនកើតពីជនណា ? កូនកើតពីជនពីរនាក់គឺភេទប្រុសនឹងភេទស្រីដែលប្រស្រីយភាក់ខន្ធគ្នាដោយសមគ្គិសង្វាស ។ ជនពីរភេទនេះហើយជាអ្នកបង្កើតកូន ។

ដូច្នេះ កូនកើតពីសត្វពីរប្លែដែលមានភេទផ្ទុយគ្នា ។ តាមសាសន-ភោហារ ពាក្យថាជន ឬ សត្វនេះ សំដៅយកមនុស្ស តិរច្ឆាន ខេត្តា ប្រេត ឧរគ អាសុរកាយ ។

តួនអត្ថបទនេះ ខ្ញុំនឹងដោះស្រាយនូវបញ្ហាស្តីពីបទុកាគុណនៃមាតាបិតាដែលមានសភាពភាក់ខន្ធនឹងសត្វពីរក្រុមគឺ មនុស្សនឹងតិរច្ឆាន ព្រោះ

សត្វពីរក្រុមនេះស្ថិតនៅលើផែនដីធំ មានរូបកាយអាចមើលឃើញបាន ផង ។

មនុស្សកំបង្កើតកូន តិរច្ឆានកំបង្កើតកូន ។ សួរថា: មនុស្សចង់បង្កើតកូន ឬកូនមកកើតឯងជាធម្មតាតាមសភាពរបស់វា? ចំពោះសំនួរនេះ គឺពិបាកឆ្លើយជាដាច់ស្រេច: មនុស្សខ្លះចង់បានកូន ទៅជាមិនបានក៏មាន មនុស្សខ្លះមិនចង់បានកូន ទៅជាបានក៏មាន ខ្លះចង់បានកូនប្រុស ហែរទៅជាបានកូនស្រីក៏មាន ខ្លះចង់បានកូនស្រី ហែរទៅជាបានកូនប្រុសក៏មាន។

បើតិរច្ឆានវិញ មានឆ្កែជាដើម ខ្ញុំមិនមែនបានបរចិត្តវិជ្ជាទេ តែខ្ញុំអាចសន្និដ្ឋានបានថា តិរច្ឆានប្រាកដមានចិត្តជាអត្ថាក្រឹត ទៅពេលប្រតិបត្តិការរវាងញីឈ្មោល ហើយកូនកើតមក តាមធម្មជាតិរបស់វា ។

សួរថា កូនកើតមកឯង។ តាមធម្មជាតិដែលបានតាក់តែងមក ពោះបីចង់បាន ក៏មិនបាន ពោះបីមិនចង់បាន ក៏ត្រូវបាន ហេតុម្តេចបានជាមាតាបិតាតាមការគុណពីកូន? បើកុំតែខ្លួនរួមរ័ត្នា ធ្វើម្តេចកូនកើតមក? បើកូនកើតមក ព្រោះសេចក្តីស្នេហារបស់ខ្លួន ត្រូវតែខ្លួនបីបាច់ថែរក្សា ត្រូវតែខ្លួនចិញ្ចឹមឲ្យមានជីវិតគង់ ហេតុម្តេចមកតាមការគុណធ្វើអ្វី ? គឺជាការធម្មតាទេតើ ? មេតិរច្ឆានបង្កើតកូនដូចមនុស្សដែរ តែមិនដែលឃើញមេតិរច្ឆានណាមួយតាមការគុណពីកូនម្តងសោះ ចំណែកស្នេហាដូចគ្នាបង្កើតកូនក៏ដូចគ្នា ម្ចែកអ្វីតែមាតាបិតា ដែលត្រូវតែការគុណពីកូន

ប្រុស-ស្រី ?

ចំពោះបញ្ហាគុណឬទុបការគុណដែលមានតាបិតាត្រូវមានទៅលើបុត្រធីតានោះ បើយើងមិនពិចារណា ឬពិចារណាមិនដិតដល់ ក៏យើញថាហាក់ដូចជាធម្មតា មនុស្សក៏ដូចតិរច្ឆាន តែបើយើងរំពឹងគិតឲ្យជ្រៅ គង់យើញថាមានការប្លែកគ្នាយ៉ាងខ្លាំង ។ គាស់តគ្នងហិតោប្រទេសមួយតន្ទែង តោលថា: ការបរិភោគអាហារ១ ការដេក១ ការសេពកាម១ ទាំងបីនេះ មានខ្លះទៅគ្រប់សត្វក្នុងលោក ឯការប្លែករបស់មនុស្សពីសត្វតិរច្ឆានទៅត្រង់ធម្មសញ្ញា គឺថាមនុស្សមានធម្មសញ្ញា តិរច្ឆានគ្មាន ។ ត្រង់ចំណុចនេះហើយ ដែលត្រូវលើកយកមកពិចារណាដោះស្រាយថា ហេតុម្តេចក៏មាតាបិតាមានគុណទុបការលើបុត្រធីតា ។

តាំងពីដំនាន់ណា ។ មក ជាយូរលង់ណាស់មកហើយ ពោះនៅប្រទេសណាក៏ដោយ ទាំងខាងអឺរុប ទាំងខាងអាស៊ី ទាំងខាងអាហ្វ្រិក ទាំងខាងអាមេរិក គេតែងនិយមពុកមាតាបិតាជាបុព្វការីរបស់កូន គឺថាអ្នកមានគុណទុបការយ៉ាងធ្ងន់អស្ចារ្យលើកូន ។ មិនតែប៉ុណ្ណោះ មានក្បួនតម្រាជាច្រើនដែលពោលទូវគុណនុពុកម្តាយ តើធំប៉ុណ្ណា ធ្ងន់យ៉ាងណាផង ថែមទៀត ។ គម្ពីរលេខិពុទ្ធសាសនាចែងថា គុណមាតាបិតាមានទៅលើបុត្រធីតាធំណាស់ ក្រាស់ណាស់ ជ្រៅណាស់ ខ្ពស់ណាស់ លោកថាទឹកមហាសមុទ្រធំ ក៏មិនធំស្មើនឹងគុណមាតាបិតា មហាសមុទ្រជ្រៅ ក៏

មិនត្រូវស្មើនឹងគុណមាតាបិតា ផែនដីក្រាស់ ក៏មិនក្រាស់ស្មើនឹងគុណមាតាបិតា ភ្នំព្រះសុមេរុខ្ពស់ ក៏មិនខ្ពស់ស្មើនឹងគុណមាតាបិតា ភ្នំព្រះសុមេរុធ្ងន់ ក៏មិនធ្ងន់ស្មើគុណមាតាបិតា ។ កូនតម្កើមង្គលត្ថទីបនី មានសេចក្តីមួយកន្លែងថែងថា មាតាបិតាមានគុណលើកូនខ្លាំងណាស់ ហើយបើកូនចង់តបគុណវិញ ក៏មិនអាចតបគុណនោះឲ្យបានសព្វគ្រប់ឡើយ តុំថាឡើយត្រឹមតែតបគុណតាមសភាពធម្មតា មានការចិញ្ចឹមថែរក្សា ដូនជាយដូនខំកនឹងសំលៀកបំពាក់ជាដើម សូម្បីកូនយកបិតាដាក់លើស្មាស្តាំ មាតាដាក់លើស្មាឆ្វេងរបស់ខ្លួន ហើយចិញ្ចឹមរហូតទៅ ទោះបីមាតាបិតាបន្ទោបង់នូវមូតនឹងលាមកលើខ្លួនក៏ដោយ ក៏ឈ្មោះថាកូនសងគុណមាតាបិតាមិនរួចឡើយ ។

ព្រះសាក្យមុនីសម្មុទ្ធបរមគ្រូ កាលដែលព្រះអង្គបានត្រាស់ដឹងហើយ ។ ដែលព្រះមាតាព្រះអង្គសុគតទៅកើតជាទេព្តា ព្រះអង្គតែងនឹករលឹកដល់គុណព្រះមាតាព្រះអង្គ ។ រំពឹងលៃតនឹងយកធម៌ណាទៅទេសនាសងគុណព្រះកន្ទោង លុះពិចារណាសព្វគ្រប់ ព្រះអង្គឃើញតែព្រះអភិធម្ម ជាធម៌ជ្រាលជ្រៅយ៉ាងល្អិត ដែលល្មមនឹងយកទៅទេសនាសងគុណបាន ។ ព្រះពុទ្ធអង្គស្ងួហោះទៅគាន់ស្ថានសួគ៌ទេសនាសងគុណព្រះមាតាព្រះអង្គ ។ តាមការពិចារណា ឃើញថាព្រះពុទ្ធមិនមែនជាបុគ្គលខ្វាក់ខ្វាយឡើយ គឺព្រះអង្គជាខត្តិយវង្សធំ ជាព្រះពុទ្ធធំ ហើយជា

មេសាសនាឯកផងនៅក្នុងលោក អ្នកសន្តិភាពតែងគោរពនិងនិយមខុកសាសនារបស់ព្រះអង្គ ជាសាសនា ដែលដឹកនាំមនុស្សឆ្ពោះទៅរកសន្តិភាពដែលមនុស្សស្រែកឆ្អែនៗ ចង់បានតែសព្វថ្ងៃ ហើយមិនបានជាស្កាតរនោះ ។

ខ្ញុំដឹងជាអ្នកជ្រាបច្បាស់របស់ចិន បានបង្កើតសាសនាដ៏ប្រពៃមួយឈ្មោះ ព័ក្ខូនត្រូវតែគោរពមាតាបិតា ក្ខូនត្រូវចិញ្ចឹមមាតាបិតា ព្រោះមាតាបិតាមានគុណធ្ងន់ណាស់ ចិននិយមគោរព ខ្ញុំដឹង ខុកដូចជាព្រះដែរ មិនតែចិនទេ សូម្បីអឺរុបក៏និយមខុកសាសនាខ្ញុំដឹងថាជាត្រឹមត្រូវដែរ ។

លោកប៉ាស្ទ័រ (Pasteur) ជាតិជាវ៉ាំង ជាអ្នកវិទ្យាសាស្ត្រដ៏មានល្បីឈ្មោះម្នាក់ក្នុងលោក ដែលបានរកឃើញនូវឱសថសម្រាប់ចាក់បង្ក្រាបជម្ងឺឆ្កែឆ្កួតមុនគេ គឺលោកមានគុណលើមនុស្សលោកដោយស្នាដៃដ៏ប្រសើររបស់លោកនេះផង លោកក៏និយមខុកខ្លាំងណាស់ថាជាអ្នកមានឧបការគុណលើកូនដែរ ។ នៅទីសាសដែលលោកសូត្រសុន្ទរកថាចំពោះដួងវិញ្ញាណលោក ។ ថ្លែងដាគាទិថា : (ô ! mon père ô ! ma mère, c'est à vous que je dois tout) បានសេចក្តីថា : « ឱលោកឪពុក ! ឱលោកម្តាយ? ខ្ញុំជាកូនត្រូវដំណាក់លោកឪពុកលោកម្តាយគ្រប់សព្វគ្រាំងអស់ ប្រៀបសេចក្តីថា លោកឪពុកលោកម្តាយ មានឧបការគុណលើខ្ញុំជាកូន រកអ្វីប្រៀបគ្មាន» ។

ក្នុងបច្ចុប្បន្ននេះទៀត សម្តេចព្រះនរោត្តម សីហនុ ព្រះប្រមុខរដ្ឋ

កម្ពុជា តែកាលណាខ្ញុំប្រាប្តិដ៏អ្វីមួយជាកុសល ព្រះអង្គតែងនឹក
រលឹកមិនដែលភ្លេចម្តងណាសោះ ខ្ញុំឧបការគុណនៃអតីតព្រះមហាក្សត្រ
នៃខ្មែរពាំងឡាយ ហើយខ្ញុំតែងនឹងសូមថ្វាយព្រះពរជាកុសល ចំពោះព្រះអតីត
ព្រះមហាក្សត្រពាំងនោះ ។ ហេតុអ្វីក៏ព្រះអង្គបែរតែងនឹករលឹក ហើយថ្វាយ
ព្រះពរជាកុសលមិនដែលខាន ? ដោយហេតុតែព្រះអង្គយល់ច្បាស់ថាព្រះ
អតីតព្រះមហាក្សត្រ មានមហាឧបការគុណលើព្រះអង្គពន់ពេក មិនត្រឹម
តែព្រះវរបិតានៃព្រះអង្គប៉ុណ្ណោះទេ សូម្បីព្រះអេយ្យកោក៏មានព្រះគុណ
លើព្រះអង្គដែរ ព្រោះព្រះអេយ្យកោ ជាព្រះវរបិតានៃព្រះវរបិតានៃព្រះអង្គ ។
ពាំងនេះសឲ្យឃើញថា ព្រះអង្គខុកខឹពុកម្តាយ ជាអ្នកមានឧបការគុណ
លើកូនជាពិតប្រាកដ ។

តាមការដឹងនឹងការស្រាវជ្រាវ ឃើញថា មនុស្សភាគច្រើនណាស់
ស្ទើរតែពាំងអស់ ដែលយល់ច្បាស់ថាមាតាបិតាមានគុណលើកូន តែខ្ញុំពុំ
អាចនឹងលើកយកអត្ថបទស្តីពីគុណមាតាបិតា មកលាតត្រដាងឲ្យសព្វ
គ្រប់ក្នុងទីនេះបាន ក្រែងតែសរសេរជាសៀវភៅក្បាលទើបចប់ ។

ឥឡូវស្រាប់តែបានឮថា អ្នកបញ្ញាវន្តនឹងអ្នកវិទ្យាសាស្ត្រសម័យខ្លះ មាន
ជាអាទិ គឺសាស្ត្រាចារ្យខ្លះ បានប្រៀនប្រដៅសិស្ស បានពន្យល់សិស្សថា
ខឹពុកម្តាយមិនមានគុណលើកូនទេ កូនស្អាប់ខឹពុកម្តាយក៏បាន មិនស្អាប់ក៏
បាន គោរពក៏បាន មិនគោរពក៏បាន ហើយមិនចាប់តបស្នងនឹងគុណ

ចំពោះឪពុកម្តាយទេ ដែលឪពុកម្តាយចិញ្ចឹមកូននោះ គឺជាការណ៍យកច្ចប្បេស់លោកទេ បង្កើតកូនហើយ ត្រូវតែចិញ្ចឹមដូច្នេះ ព្រោះកូនមានតការណ៍យកិច្ចត្រូវចិញ្ចឹមកូនពាក្យ ដែលនឹងឱ្យកូនប្រព្រឹត្តជាបដិសោមមកវិញឪពុកម្តាយវិញ ឥតអង្គើមានទេ ឡើយ ធ្វើដូច្នេះ ឈ្មោះថាប្រធាំងនឹងធម្មជាតិ ដើម្បីបញ្ជាក់ច្រើស្តីថ្នាំនេះ ពួកសាស្ត្រាចារ្យអស់នោះ តាញយកតំរាប្តូនមកជាឧទាហរណ៍ ថាសូមឱ្យពិនិត្យតំរាប្តូនមើល មានឆ្កែជាដើម ។ ឆ្កែបង្កើតកូន ហើយចិញ្ចឹមកូនដោយទឹកដោះពេញជាងពប លុះកូនឆ្កែធំហើយ មិនដែលឃើញកូនឆ្កែនោះរកចំណីអ្វីមកចិញ្ចឹមមេដល់ម្តងទេ ឡើយ ។ ដូច្នេះ ការប្រព្រឹត្តបញ្ច្រាសគ្នានេះ មានតែបណ្តោយ គឺម្តាយចិញ្ចឹមកូន ។ ចិញ្ចឹមកូនក ។ ចិញ្ចឹមកូនក យ៉ាងនេះតទៅ ។

ដើម្បីពិចារណាខ្លួនក្រែងស្តីថ្នាំរបស់អ្នកបញ្ញាវន្តនឹងអ្នកវិទ្យាសាស្ត្រសម័យនេះ ខ្ញុំសូមលើកយកការសិតក្នុងហិតោប្រទេសដែលថា : « ការបរិភោគ អាហារ ១ ការដេក ១ ការសេពកាម ១ ពាំងបីនេះ មានខ្លួនៅគ្រប់សត្វពាំងអស់ ឯមនុស្សប្លែកពីតិរច្ឆាន តែត្រង់មានធម្មសញ្ញា » មកដោះស្រាយម្តងទៀត ។ កូនមនុស្សកើតមក យំការកស៊ី កូនឆ្កែក៏ការកស៊ីដែរ យើញថា ចំពោះការបរិភោគ មនុស្សនឹងឆ្កែឥតប្លែកគ្នាទេ កូនមនុស្សស៊ីឆ្កែតការកដេក កូនឆ្កែស៊ីឆ្កែតក៏ដេកដែរ យើញថាចំពោះការដេក មនុស្សនឹងឆ្កែឥតប្លែកគ្នាទេ កូនមនុស្ស ធំពេញរូបដឹងក្តី ត្រូវការកប្រពន្ធ

ប្តូរតំណៅលួចស្រឡាញ់ស្រីដោយចិត្តឯង កូនឆ្កែ លុះធំពេញវ័យតំត្រូវស្វែងរកញីដែរ ឃើញថា ចំពោះការសេពគាម មនុស្សនឹងឆ្កែឥតប្លែកគ្នាទេ។ បើយកតែបីរនេះមកពិចារណា ឃើញថាឪពុកម្តាយមិនមានឧបការគុណលើកូនឡើយ ។

តែកុងកាសិតនោះ មានចែងទៀតថា : មានតែធម្មសញ្ញាមួយទេ ដែលធ្វើឲ្យមនុស្ស មានសភាពប្លែកពីតិរច្ឆាន ។ តើកាសិតហ្នឹង មានសភាពត្រឹមត្រូវនឹងសម័យឬទេ ? ចំពោះរឿងនេះ គួរពិចារណាដែរ ។

សួរថា យ៉ាងដូចម្តេចហៅថា «ធម្មសញ្ញា» ? ធម្មសញ្ញា ជាចេតសិកមួយយ៉ាងដែលធ្វើឲ្យស្គាល់ធម៌ ឲ្យដឹងច្បាស់នូវធម៌ ឲ្យដឹងទុសនឹងត្រូវ ឲ្យដឹងគុណនឹងទោស ឲ្យដឹងបុណ្យនឹងបាប ឲ្យដឹងគួរនឹងឆ្គង ឲ្យដឹងកូនឪពុកម្តាយ ឲ្យដឹងថានេះជាមនុស្ស នេះជាតិរច្ឆាន ។

សួរថា ឆ្កែមានធម្មសញ្ញាកង់ខ្លួនឬទេ? ឆ្លើយថា បើតាមការសង្កេតជាកល់ថ្លែ ឆ្កែមិនមានធម្មសញ្ញាទេ មានតែសភាវគតិ ។ គឺសភាវគតិនេះហើយ ដែលធ្វើឲ្យឆ្កែស្គាល់ម្ចាស់ ស្រឡាញ់ម្ចាស់ ចេះចាំផ្ទះ ព្រុះប្រទាំងនឹងអ្នកគ្រៀវផ្ទះ ចេះការពារកូនក ចេះបំបៅកូនក ចេះរកចំណីមកឲ្យកូនក ចេះទាំពែងឲ្យកូនក ឆ្កែណាដូចឆ្កែណា គឺដឹងយ៉ាងនេះដូចគ្នា តែប្រយ័ត្នវ័យដូចបំបៅកូនកន្លងផុតហើយ មេនឹងកូនឈប់ស្គាល់គ្នា សូម្បីអាស្រ័យទៅកន្លងពីជាមួយគ្នាក៏ដោយ ។ តាមការសង្កេតម្យ៉ាងទៀត ឃើញថា មិន

ត្រឹមតែមេនឹងកូនឈប់ស្គាល់គ្នាទេ មេត្រឡប់ទាំកូនតិមាន កូនទាំមេក៏មាន ហើយលុះធំត្រង់ផ្នាំ កូនឈ្មោលប្រព្រឹត្តសេពសន្ធវៈនឹងមេវិញមេឯតធន៌ អាឈ្មោលជាបានោះ ដូចជាមិនដែលឃើញជួយការៈអ្វីម្តងសោះ កាលបើបំផើមហើយ ខុកជាចប់តំបូរបង់ ។ ដល់រដូវម្តង ។ ក៏ប្រព្រឹត្តសេពសន្ធវៈលើឆ្កែញីជាកូនពាជាធម្មតា ។

ចំណែកធម្មសញ្ញាវិញ ធ្វើមនុស្សឲ្យស្គាល់ ឲ្យយល់ថា នេះគួរធ្វើ នេះមិនគួរធ្វើ : ម្តាយចាប់តាំងពីបានដឹងក្បាស់ថាមានកូនមកស្ថិតនៅក្នុងផ្ទៃវេលាណា មានសេចក្តីស្នេហាទៅលើកូនភ្លាម តែចង់ធ្វើយ៉ាងណាឲ្យកូនបានសុខ លុះកូនចេញចាកផ្ទៃហើយ មាតាបិតាសុះសូតមកម្ល៉ាងសមត្ថភាព ធ្វើយ៉ាងណាឲ្យកូនជាតំណប្រាសចាកពេគាព្យាធិ កូនធំបន្តិចកាន់តែស្រឡាញ់បន្តិចរហូតទៅ រួចដុំនំគ្នាតិតរកអនាគតដ៏ប្រសើរឲ្យកូនទៀត ។ ទឹកចិត្តឪពុកម្តាយជាខ្លះបែក្លាបន្តិច ទៅពេលដែលកូនប្រុស-ស្រីមានគូស្រករហើយ តែខ្លះជាយ៉ាងនេះ ក៏សេចក្តីស្នេហានៃមាតាបិតាទៅលើកូន នៅតែមានជាដរាប ឃានជាបុពណៈច្រើនទំយាយថា : « ម្តាយនឹកកូនដូចចង្វាប្រចឹក កូននឹកម្តាយដូចត្រីប្រាក់ក្រាយ » ។

តទ្បូវត្រូវដោះស្រាយ ថាតើឪពុកម្តាយមានគុណលើកូនត្រង់កន្លែងណា ? បើម្តាយចិញ្ចឹមកូនតាលទៅតិចួច ត្បែកចិញ្ចឹមកូនវាដូចមនុស្សដែរ ។ ដូច្នេះការចិញ្ចឹមមិនមានអ្វីប្លែកពីការចិញ្ចឹមមនុស្សនឹងតិរច្ឆានឡើយ ។

បើយ៉ាងនេះ ហេតុម្តេចក៏ឪពុកម្តាយតាមមាត ថាត្រូវឲ្យកូនតបស្នងសងគុណខ្លួន? ចំពោះបញ្ហានេះ គួរតបស្សួរថា : ពេលដែលដឹងថាមានកូនមកចាប់ផ្តែ តើចិត្តគ្នាយដូចម្តេចចំពោះកូន ចិត្តមេត្តែដូចម្តេចចំពោះកូន? ឆ្លើយថា នរណាអាចមើលចិត្តឃើញជាយ៉ាងណាបាន ព្រោះចិត្តជានាមធម៌ ។ ចម្ងើយនេះឃើញថាសមគួរហើយ ចិត្តប្រាកដជានាមធម៌មែន មិនមានជនណាអាចមើលឃើញបានឡើយ ។ តែចិត្តជាម្ចាស់លើរូប បើចិត្តមានបំណងយ៉ាងណា កំតង់សំដែងមាការឲ្យឃើញបានតាមទ្វារទាំង ៥ ទ្វារណាមួយជាមិនខាន : ខឹង ក្អែកឡើងក្រឡេត មុខក្រហមងាំមាត់ បញ្ចេញឆ្នេញ ។ ល ។ ព្រួយ មុខស្រងូត ក្អែកសំឡើងចុះក្រោម ជួនកាលមានទឹកក្អែកធង សប្បាយ ក្អែកភ្ញីចាំង កន្ទុយក្អែកចាញ់ឡើងលើ មុខស្រស់ មាត់ញញឹម ។ ល ។

គេសង្កេតឃើញថាម្តាយកូនសម័យនោះ ខំដើរកំប្រុង ខំដើរកំប្រុង ខំបរិភោគអ្វីតែងប្រយ័ត្ន ។ ល ។ ព្រោះទឹកក្រែងមានគ្រោះថ្នាក់ដល់ពាក្យទៅកូនវិញ ។ ចំណែកមេត្តែដូចជាមិនឃើញមានការប្រុងប្រយ័ត្នអ្វីម្ល៉ឹងសោះ ភ្លាត្អើ ស៊ីអ្វី គឺនិយមថៅតាមធម្មតារបស់ពាលហើយតេលដែលកូនកើតមក អាណាស្ងាប់គឺស្ងាប់ថៅ អាណារស់គឺលូថៅដោះថៅ តាមសភាវគតិរបស់ពាល ឯម្តាយមិនដូច្នោះ គឺតែងមានសេចក្តីរំតើបញ្ជាប់ញ័រចំពោះកូន គាលណាកើតមក មានសុខភាពមិនបរិបូណ៌ តែងមាន

មានសេចក្តីសប្បាយតែពាយចំពោះកូន កាលណាបានដឹងថាកូនកើតមកប្រកបដោយលក្ខណៈសព្វគ្រប់ ហើយត្រមង់មានសុខភាពបរិបូណ៌ផង ។ សួរថា : ចិត្តម្តាយយ៉ាងដូច្នេះ ព្រោះហេតុអ្វី ? ឆ្លើយថា : ព្រោះម្តាយមានធម្មសញ្ញា ។ ចិត្តមេឆ្កែយ៉ាងដូច្នោះ ព្រោះហេតុអ្វី ? ឆ្លើយថា : ព្រោះគ្មានធម្មសញ្ញា ។

ចាប់ពីត្រឹមកូនចេញចាកផ្ទៃរហូតដល់ធំ ចិត្តមាតាបិតាមានទៅលើបុត្រយ៉ាងណា ! អស់លោកអ្នកអាចជ្រាបស្រាប់ តើគិតយ៉ាងណាឲ្យកូនមានសុខភាព គិតយ៉ាងណាឲ្យកូនមានស្បែកពាក់ល្អ គិតយ៉ាងណាឲ្យកូនមានទីដេកទៅល្អ គិតយ៉ាងណាឲ្យកូនជាមនុស្សមានកេរ្តិ៍ឈ្មោះល្អ មានសុភមង្គល មានកិត្តិយស ជួនកាលខ្លួនឯងស៊ូត្រាំអត់ ធ្វើយ៉ាងណាឲ្យតែកូនបាន ឲ្យតែកូនសប្បាយនឹងខ្លួនសំខ្លុ ។ ល ។ តើរឿងអស់នេះមេឆ្កែមានដែរឬទេ ? តាមការសង្កេតហាក់ដូចជាគ្មាន ព្រោះតិរច្ឆានជាសត្វមួយក្រុមដែលគ្មានកម្មសិទ្ធិ ជាសត្វ ក្រុមដែលលះចោលសាសនាកប់បញ្ចូលកូនតួកអបាយភូមិ ជាភូមិប្រកបដោយទុក្ខច្រើនជាងសុខ ។ ដូច្នេះគុណនឹងមិនគុណ មៅត្រង់មានធម្មសញ្ញានឹងមិនមាននេះឯង ។

(នៅមានត)

សិលាចារឹកជ័យ-ឥន្ទ

ស្រាវជ្រាវដោយ ឯ. គាម (ត)

២៦) ខ្ញុំលាត្រង់កែយក្តីថប្ប កំតញ្ចាំរចុំប្រប៉ី រន្ធត្តឥស្សអង្គ ។
ខ្ញុំលាគ្បែរចោមជាតភ្នំ កំតកែហ៊ូន្យហ៊ូង ឥតគ្នាជួយហោង ។
ខ្ញុំលាសត្វ។ ជាតដោង កេតជាសែនតួង លាត្រង់សត្រូវ ។
ខ្ញុំលាក្បាលខ្លែកស្លកស្លូវ ដើងសូកូអាស្រូវ ឆ្មេញចុកខ្វាក់ថ្នូង ។
២៧) ខ្ញុំលាវែរស្រែងឃ្លុង ដំបោរឥសអង្គ ជាខ្លុងអ៊ូតស្បែរ ។
ខ្ញុំលាកែតហ៊ូងឥត្តត្រែរ ប្រប្បូអាក្រកហ្យ កើនក្តាស្បែរដែរដោង ។
ខ្ញុំលាឥសខ្ញុំនោះហោង សាត្បូត្តាំធ្លោង ហោរអកុសល ។
ខ្ញុំលានោះកុំក្រាយល តែ្យជាតនែះតល រៀងខោងមុក ។
២៨) ខ្ញុំលាកំយ្យាអាក្រក នោស្ដានអ៊ូត្តសុក្ខ ជាខ្លុងឯងហោង ។
ខ្ញុំលាចេហាមានត្រាត្បូរដោង អក្រកនោះហោង កុំក្រាយលល្បែ ។
ខ្ញុំលាសត្វជាតហ្យែ ត្រង់ខ្លុងឥតស្បែយ កុំក្រាយលហោង ។
ខ្ញុំលាស្រែចសត្វត្រែចដោង កេតសត្វជាតហោង កុំក្រាយលល្បែ ។
២៩) ខ្ញុំលានែះជាបង់ហ្យែ ចាប្បតៀរខុំស្ងៀ កុំមានល្បែនា ។
ខ្ញុំលាវែរតែ្យវែរ កេតហ៊ូងតាល្នា ថ្ងៃស្អែរហ៊ែស្រែចដោង ។
ចេ៊ាកេតខុសនិងចំណង លាត្រង់នោះហោង កុំកេតមោកល្បែ ។

បទកាកគតិ

๓๐) បទតែមនែះក្តី ហោរាកគតិ តោយថាឡើយ លើកជាសំនួម
ខ្ញុំមសូមប្រាជ្ញ សូមចិត្រសាស្ត្រ កាត់អំម្នោយទាន ។ អញខ្ញុំនែះនៃ្យតាម
តែមរឈ្មោះដៃ្យ រៀរៃកៃ្យបូកទាន សូមបានត្រាស័ត្រែច សាត្រៃជ្ញតាញ្ញាណ
សូមបានទិញ្ញាណ ន្ទាំឥសសត្វផោង ។ ๓๑) ជាតមុត្តប្រើនកៃ្រ កេតជា
អសកៃ្យ ន្ទាំនៃ្យកាលៃ្យហោង ខ្ញុំសូមប្រាថ្នា សាត្ថិទានផោង តាមតោយ
គន្ធង៍ព្រះស័អារមែត្រ ។ តោះតៃ្យប្រាថ្នា សុំឥសអគ្គ័ សែចបញ្ចូតន្ត្រី សួត
ថ្លែមបែះតូង តុងតោះឈាមថ្មី កែ្លកឆ្អែងខ្ញុំត្តៃ្យ ៗទានតៃ្យហោង ។ ๓๒) ខ្ញុំ
សូមប្រាថ្នា ត្រៃកអសោត្ថិ ចិត្តាស្មោះផោង តូចព្រះជាធរ ឲៃ្យទានប្រែត្ត
ហោង ឆ្ងៃសែចឈាម្ចាផោង ឥសឥតសំណល ។ ខ្ញុំសូមប្រាថ្នា ឲៃ្យទានកា
ស្មាខេត្តាជួយយល សូមឥសឥន្ទព្រឹហ្ម ជ្រោមជ្រែងបនយស កេតគោ-
លាហល ជួយបំពេញទាន ។ ๓๓) ខេត្តាខុំលាភ័ ព្រះខាន្ធយលជាក
ស្តេងជាប្រធាន យោកព្រះខាន្ធនោះ អារ័សែចឲៃ្យទាន ប្រែតឆ្ងៃតោយ
ឃ្លាទន្លែតប្រាទនោះហោង ។ ខ្ញុំសូមប្រាថ្នា ទូលព្រះភគ្គព ត្រាស័ធម្មិកន្ធង
ខ្ញុំសូមតូចព្រះ សីអាយ្យៃឯងហោង រំយ៉ៃ្យធិតផោង នោះនៃ្យខេត្តាបាន ។
๓๔) ខ្ញុំថ្លៃ្យបខុំម្ចា សំតែចតគ្គាវ ស្រោចស្រង់ប្រាសប្រាន ខ្ញុំកានបុក្តា
វន្ទាស្រែចបាន ឥប្បតាបួសប្រាន សូតតាមកជ្ជហោង ។ ខ្ញុំបួសនែះនៃ្យ

សំម្ភាក័ព្រះវៃត្រៃ សណ្ដាំគុំផោង ខ្ញុំសូមឲ្យតែងឯ កំនេតសព្វហោង តាម
តែងតន្ទង ខែឲ្យព្រះពុទ្ធគ្រាស៍ ។ ៣៥)ជាតនែះខ្ញុធ្លាយ ពុំមានពន្រាយ
ជាកដៀងស្ដែងធ្លាស ខ្ញុំសូមជាតក្រែ្យ រៀងតូចព្រះគ្រាស៍ ប្រាថ្នាបុខ្យ
ច្បាស ឥតអ្នកធ្ងឹមផោង ។ ខ្ញុំសូមប្រាថ្នា ចេះឆ្លៀប្រិស្នា តោះស្រាយសារ
ស្ដង តូចព្រះនាគ្គសេន ឆ្លៀប្រិស្នាផោង ខ្ញុក្រែងមាលីនហោង តោះឥតដុំ
ពាក័ ។ ៣៦)តោះឆ្លៀប្រិស្នា សារឿប្រាថ្នា ព្រាពួជនយស្សសេក កុំម្បីមាន
ក្រហ ពៅវាកតលអ្នក ខៀតមកពុំនាក័ ជាកំមួងលៀ ។ សូមកែត
មកឯង តោះផលពីព្រែង បូកនជាត្រែយ សិងចូលមកជួយ ពុំឲ្យព្រួយ
លៀ តឹតត្រែងនាហោយ ខេញ្ចាំពេញ ។ ខ្ញុំសូមប្រាថ្នា ជាតក្រែយ
មោកនាំ កុំត្រាកុំនែញ សូមចំត្រែខ្ញុំជា សាញ្ចាំពំពេញ តែ្យសូមអ្ងៀមញ
ឲ្យព្រានឥតលុស្ស ។ ៣៧)ម្បីសូមប្រាថ្នា តូចព្រះកាលជា ឆ្នេញដែប
វស្ស ឆ្លៀប្រិថ្នាផោង នន្ទីយក្ខនិវាស ប្រាជ្ញាស្រែចស្រស្ស តោះចាម្ច
ថ្ងៃ ។ ហៀតិនោះស្រែច ការអាយូស្សស្ដែច រ៉ែចជាប្រពៃ នាំខុទ្ទិយគ្គ
សំណាស្សខ្ញុជ្រៃ ជាបរិតោះវែន ក្រញាក្រាខ្ចប់ភ្លាច ។ ៣៨)រៀងមោកពី
នោះ ចាប់ស្ដែចម្ប្យឈ្មោះ អកុំតិចជ ហៀឈ្មោះស្ដែចម្ប្យ ឈ្មោះរ៉ែកេចកជ
ព្រះនិកឯងអាច ហោរម្ចាជយក្ស ។ នែះស្រែតាតិ ពុំបានរៀបចប់ តិ
តែមមកនាំ បើស្រែតិឥស្ស ច្រើនហ្មាស្សសព្វគ្រា បង្ហើយបានជា ឧប្បាកជ
ឯងឯ ។ ៣៩)ខ្ញុំសូមអំនត ចិត្រល្អស្រែតត តូចព្រះតោម ព្រះវរបិត្តា

ឡៃឃ្លាំងតតៃគ្នី ព្រះអង្គអតៃត្ស ជនស្សន្ធំតត ។ ៤០) ខ្ញុំសូមប្រាប្ញា តួច
ព្រះកាស្ត្យ តើតជាមហោសុច្ចិ ឈ្មោះឥសូគ្រោ (ចារ្យជាល) ផ្ទាញ់កែវត្ត
ប្រាប្ញាច្រើនត្តាត ឈ្មោះព្រះភុលណ្យ ។ ខ្ញុំសូមទ្បាន កាត់អំម្ចោយ ជាន
ដូចព្រះមុនហ្ម៎ ព្រះវៃសន្តរ នោនាង៍មេទ្រី ឲ្យជានជាលិ ក្រស្នាខោះ
ហោង ។ នាង៍បែនខោះនៃ តើត្រង៉ាតនៃ្ស តាមតើតតៃ្សជោង ដូចនាង៍
បញ្ញា . . . តួចអំម្រាជោង ខ្ញុនាង៍មេទ្រី ។ ៤១) សង្ឃឹតាមសត្តជាត
តើតភ្ញុតេលឃ្លាត រុបបញ្ញាតន្ត្រី ហើយល្អតតង្ហិម នោមនាយធ្យៃ ឡាបខ្ញុំ
សុមាតស្ស៊ី តតអ្នកតើតតល ។ ខ្ញុំសូមសត្តជាត កេតកុំត្រាឃ្លាត ចិនៃ្សមខ្ញុល
ខោះខោវកេតស្ងួត ខ្ញុំសូមឡៃយល ខោះកេតត្រៃល នោអាយកេត្រះជោង ។
៤២) ជាតនែះខ្ញុំឃ្លាត ខ្ញុំសូមសត្តជាត កុំឃ្លាតតលម្ត៎ង ខោះកើតជាសត្ត
ជាមនុសក្តិហោង ខ្ញុំសូមកើតជោង តួចខ្ញុំប្រាថ្នា ។ ខ្ញុំសូមចោង្គណ
ញ្ញាតដៅឥសកួន សំលេញកំយ្យា ចោង៍រសនាង៍បែន សូមកើតមូលគ្នា
ខ្លួនខ្ញុំនែះន៎ា សូស្សរោវឥមទង ។ ៤៣) ខ្ញុំសូមមានម្ចាជ ឫទ្ធិអំម្ចាជ អនុ-
ភាព្ភតោយចង ខ្ញុំសូមសើលជុប ធុតតួចព្រះអង្គ ព្រះឥសូវស្តង្រែង ជុប
នាង៍កត្តតៃ្ស ។ សូមម្ចាជឫទ្ធាឃ តួចកាលព្រះនាព្យ ចុះចាកអំព្យ សួគ្គិមោក
តើតជា ព្រាមួទេវ្ញ ធ្លាឥសតិរដ្ឋ អាសុរលុក្ខា ។ ៤៤) ខ្ញុំសូមមួយទំ តួច
ព្រះចាន្ទត្រៃ ត្រីវក្រំនា ខ្ពោះទៅកៃលាស្ស ព្រះឥសូព ចានតួចប្រាថ្នា ចំណ្ឌា
ចោតចង ។ ចានសើលសាសស្រេច រៃលមោកជាស្តេច តួចចំត្រចំណង

អ្នកបានមេហួរ ប្រាំបួនព្រះអង្គ អញ្ជើសេកបានទ្រង់ ស្មើយកជម្បែនឆ្នាំ ។
៤៩)ខ្ញុំសូមកុំល្ងំ អនុភាពវែងខ្លាំង សើលសាសនុតចាំម្ន ដូចព្រះហនុ
មាន បួនទាឡាំ កេតមោកជាកុំ ល្ងំព្រះកម្មវិញ ។ សូមមានសំការ
បម្ងៃយត្រកាល ចេះសើលសាសសេព្ត ចេះការសង្គ្រាម តួចព្រះកម្មវិញ
សើលឆវែងឯក ឥតអ្នកស្មើផង។៥០)សែងជាតនេះគោបើសែមោកនោ
កើតផ្លែស្តេចហោង បានតួចចៅកេត មាសាហោះផ្សង ទៅសួគ្គិទ្យាហោង
ជាកូនព្រះឥន្ទ្រ ។ ហ្សែមោកជាស្តេច សាងនគរស្រេច នោខាងតំរែន ព្រះ
ពិស្សន្ទូកាយ្យ សែលហ្វើងទៅវិញ អ្នកកេតឯងមិញ សោយកជនោអាយ ។
ខ្ញុំសូមសំម្ងំង ពាក្យេះបូកផ្សែង ព្ទខ្លួនខ្ញុំហ្លួ្យ ពាកតួចកវែក ក្រសួចត្រែហ
សាយ ប្រាជ្ញាពន្ទ្រាយ ចេះតែងឥតខ្លះ ។ ៥៧)ខ្ញុំសូមទ្រាំពួធន មាស
ប្រាកវត្ថុតន តែវម្ងំជោតជ្រះ ខេរែនត្រែកាលា ចែមត្រាំហតេញផ្លះ ពួក
ឆ្កានមនះ តួចជោតកសេស្ដ ។ ខ្ញុំសូមបវោរ ឥសត្រីត្រង្ងាវ ត្រកាលប្រឹម
ប្រើ រុបស្អេសេសលន ខនក្លួនមានត្រើយ សំម្លូរខ្យែក្ដែ តួចផ្ដាស្ងាកេត ។
៥៨)សូមចេះញាតគុណ ធុតធាប័សើសលន មែនចបត្រែកេរ សន្ទូប
ត្រុបតង្គ មិរសុង្ខព្រះនេត្រ ខ្យលតិចសរង្សែត ត្រានវស្សាដរ ។ សាធ្យាយ
ត្រកាល ក្រងមពិស្ដារ ត្រែកត្រុបឥន្ទ្រែ ត្រីហត្រួចកាន្ទា ចិន្ដាសួគ្គិត្រើ
ភ្ញែកក្ដេចស្មាតិ្យ ប្រែងប្រែងពុំបាន ។៥៩)ស្នេហាត្រុបត្រាន ជារុយជាពន្ធ
ពុំតិតភ្លាកប្រាន លុះតែតលស្រាយ នោះនែនខែពួបាន តះហ្វើងប្រែប្រាន

ត្តំបូតសាបាយ ។ សូមខ្ញុំប្ញសត្រី ជារួយតន្ទក្តី ប្រើនវៃកតន្ទ្រាយ ប្រប្រះទ្មាម្ទស្ងៀង៍ល្អ សិង៍បេះតំប្រាយ ស្រេតតោះស្រាយ ពាក្យពេះតត្តន្តោង ។ ๕๐) សូមសែះតំម្រ៉ា តោក្រុបីក្តី ល្អខ្ញាំង៍កខ្នោង រវែះកូបអាន ត្រែយាន មាសផោង៍ ខូតសាំមួង៍ហោង៍ តោយតែយាត្រា ។ ល្អត្រុបប្រតាប បះតារស្រេចស្រាប កាន់ត្រើង៍ត្រុប្ញត្តា សម្រាប្ញត្តំហែ តោក្យតែយាត្រា តូចកុតនលា លេលាស័កសែង៍ ។ ๕๑) សូមឋានប្រាសាទ ប្រាំបួនល្អស្អាត បិតមាសព្រាសខែង៍ តាង៍ឃ្យាយឆេតឆ្ងាយ ពន្រាយយលស្តេង៍ តាំមថ្ម្ញង៍ ឆ្នះចែង៍ ល្អត្រុបប្រកាយ៌ ។ មានផ្ទ្ញរជុំវិញ បីជានទ្វាកតេញ រ្ជិចត្រុប្ញតិស្តារ មានជាន់ទ្យាយ ស្ងៀង៍ក្ញាត្រុប្ញទ្វារ មាត្យលៀកតភាណ ចាំម្នដេង៍តេរកាច្ច ។ ๕๒) តោះទង៍មានផ្ទះ បិល្ងស្រលះ សីង៍មានមុក្ខ-តេច ខទង៍កេង៍ជ្រែក បង្គ្គនផ្ទ្ញរស្រេច ពង៍ជុំខាន្ទកាច៍ កេង៍តំរ៉ៀសែះ ។ មានចន្ទូធាយ្យា មុន្ទប្ញសាលា ឆ្ងូង៍ស្តាំមសិង៍ស្រោះ ផ្ទ្ញរតាំមសិង៍ជ្ញា ចាំប៉ាំបានបែះ ក្ងៀង៍ត្តូចក្រែះ ពាក្យតោរស្រេចហោង៍ ។ ๕๓) ឆ្នាំមមី តេញបុម្ញី ខែបាផល្គុនខោះ ឋានជាឧតញា សុរិន្ទ្រាធិរាជ្ជ លុះតលន្ទាំវក្ខ តេញបុម្ញី ខែពិសាក្សខោះ ឋានជារាចហ្ញាំ ចាំកូស្ស ๔ ។

លោកជ័យ-ខន្ធ ជាមន្ត្រីមួយរូបនៅក្នង៍រដ្ឋការនៃព្រះចាខធម្មិកជា ព្រះពជសម្ភារ ។ រឿង៍នៃក្យត្រអង្គ៌នេះ ខ្ញុំមិនចាច់ដំកបខេ ។

បណ្ឌិតជ័យ - ខ្ទូ ចាន់តែងក្បួនច្បាប់ច្រើនទៀត ។ ទៅសម័យបណ្ឌិតជ័យ ខ្ទូ យើងអាចដឹងថា ជាសម័យសម្បូរអ្នកច្រៀងខាងអក្សរសាស្ត្រខ្មែរ គួយើងដូចព្រះចាន់ស្រីធម្មជា ឬព្រះកជសម្ភារ ដែលតែរៀបនឹងធ្វើតតព្រះអង្គទៅលើបុនគ្នាត ទុកជាដំរិតាសានទៅនឹងព្រះកត្តុ ក៏ព្រះអង្គមិនតក់ព្រះទ័យតែងជាពាក្យកាព្យចំលាក់មកឲ្យតេជ្ឈឃាជ ។ នេះជាកស្តីតាងសំរាប់ឲ្យយើញថា សម័យនោះអ្នកច្រៀងខាងកាព្យឃ្លោងពូកែណាស់ ហើយអក្សរសាស្ត្រខ្មែរយើងក៏ចំរើនណាស់ដែរ ។

ការពិនិត្យស្រាវជ្រាវខ្ទូរសិលាចារឹករបស់បណ្ឌិតជ័យ ខ្ទូ ទៅយើញថាលោកនេះបានធ្វើបុណ្យសម្បូរណាស់តំកុលតាតទៅក្នុងព្រះពុទ្ធសាសនា ដូចមានពាក្យជាកសិលាថា: វត្តាស្រែចបាន ១ចង្ក្រាយ៍បួសប្រាណ សូត្រកម្មវាចហោង ។ សេចក្តីប៉ុណ្ណេះសំរាប់ឲ្យយើញម៉្យាងទៀតថា ទៅសម័យនោះព្រះពុទ្ធសាសនារុងរឿងណាស់ នាម៉ឺនជាច្រើនរហូតដល់ទៅព្រះមហាក្សត្រក៏ធ្វើបុណ្យសម្បូរដែរ ។ យើងដឹងថាបណ្ឌិតជ័យ ខ្ទូ បានបួសតែមិនដឹងជាបួសទៅត្រាំណា ខ្ញុំស្តាយណាស់ដោយមិនបានស្រាវជ្រាវជូនលោកអ្នកឲ្យសព្វគ្រប់ តែថាលោកជ័យ ខ្ទូ បើយើងពិនិត្យតាមសិលាចារឹកទៅ គឺលោកបួសមុន គ. ស. ១ ៧០០ ទំរាំផុតបណ្ឌិតជ័យ-ខ្ទូ បានរៀងហាខន្ធរៈសក្តិជាឧកញ៉ាសុខន្ទ្រាធិបតី ។

សិលាចារឹកនេះយើងមិនចាប់សង្ស័យថា គេចារដើម្បីសាសនា

ណាទេ ពិតជាខុសចំពោះព្រះពុទ្ធសាសនាពិត ។ សូម្បីតែគ្មានពាក្យ
ថាសរណគមន៍ តែយើងទៅមានពាក្យដទៃទៀតដែលយើងស្គាល់ថាជា
សិលាចារឹកផ្នែកខាងព្រះពុទ្ធសាសនា ព្រោះសេចក្តីផ្តើមនៃអត្ថបទនេះ
គេមិនខុសស្តាវ ខ្លះព្រះខាងសាសនាព្រហ្មញ្ញទេ ។ សិលាចារឹកនេះចាប់
ផ្តើមឡើង គេនិយាយតែពីសទ្ធាចិត្ត ។

អត្ថបទក្នុងសិលាចារឹកនេះ បើយើងពិនិត្យដោយម៉ត់ចត់ យើញថា
មានលក្ខណៈពេញគ្រប់គ្រាន់ខាងអក្សរសាស្ត្របស់ខ្មែរយើង :

๑- បុលាខាងអក្សរសាស្ត្រនៃសិលាចារឹកជ័យ ឆន្ទ

សិលាចារឹកជ័យ ឆន្ទ ប្រកបដោយចលនាពុទ្ធនិយមពេញគ្រប់
លក្ខណៈ ។ មានពាក្យជាច្រើនដែលសម្តែងយើញថាជាពុទ្ធនិយម ។
ខ្ញុំមិនចាប់ស្រង់ពាក្យនោះមកជូនទេ ព្រោះថាលោកអ្នកអានសុទ្ធតែជា
អ្នកកាន់ព្រះពុទ្ធសាសនាជាប់ដឹងយល់ពាក្យព្រះពុទ្ធសាសនាអស់ហើយ ។

๒- បុលាអក្សរសាស្ត្រខ្មែរនៅសិលាចារឹកជ័យ ឆន្ទ តាមទេមរនិយម

សិលាចារឹកនេះ បើយើងពិនិត្យទៅ នាំឲ្យយើងជឿនូវសាវតារមួយ
យ៉ាងសំខាន់ដែលគ្មានអ្នកណាខឹកក្តងជាប់ទៅមាល់តែសោះ គឺរឿងធម៌-
រាជ ប្តូនមិលា ។ ដូចខ្ញុំបានដំកបមកហើយថាសម័យនោះមានអ្នកប្រាជ្ញ

ខាងអក្សរសាស្ត្រខ្មែរតូចកែ ។ រហូតដល់ទៅចងក្រងក្បួនច្បាប់ខុតដល់មកសព្វថ្ងៃនេះ ដូចជាធម្មិល្យា ឬ រឺជាដើមដែលតើតទៅក្នុងសម័យនោះ ធម្មិរឺជាគឺជាធម្មិកាព្យរៀបរាប់អំពីព្រះត្រ័យលក្ខណ៍ ដែលគេសូត្រទៅពេលដែលមានមនុស្សឈឺ ឲ្យមានតើតធម្មសំវេគឡើង ។ តែខាងអ្នកនិពន្ធខ្មែរបានតែងឡើងជាភាសាខ្មែរ ហើយឈ្មោះថាធម្មិល្យា ខុតសំរាប់សូត្រឲ្យរំដោះបាបពៀរវេរកុំឲ្យជួបនឹងសេចក្តីអាក្រក់ជាដើម សូមលោកអ្នកអានកាព្យតាំងពី « នេះបពិត្រភូដង្គ្រលេលា លើកដោយកាព្យា ជាល្បាតាំងឡាយ . . . ដល់ . . . បើតើតខុសនឹងប៉ំណាង លាត្រង់នោះហោង កុំតើតមកឡើយ » ។

បើយើងសន្មតទៅតាមកាព្យមួយឃ្លានេះ ក៏អាចសន្និដ្ឋានបានថា ឋណ្ឌិតជ័យ នន្ទ នេះឯងជាអ្នកនិពន្ធធម្មិល្យា ព្រោះយើងឆ្ងាប់ឮថាស់ ។ សូត្រធម្មិនេះនៅពេលដែលមានមនុស្សឈឺដាប ។

៣- សោភណាភាពនៃសិលាចារឹកជ័យ នន្ទ

សិលាចារឹកនេះ មានសោភណាភាពគួរឲ្យចាប់ចិត្តដល់អ្នកអាន ដែលឆ្ងាប់ប្រព្រឹត្តតាមធម្មិល្យា បើលោកអ្នកបានអានន្ទូវអត្ថបទនេះ ប្រហែលជាលោកអ្នកទឹកស្មាន ថាជាធម្មិមានមកយូរណាស់ហើយ ឬ គឺសឹងថាជាពុទ្ធវចនៈដាស់តឿនធង ។ អត្ថបទនេះ ឋណ្ឌិតជ័យ នន្ទ តែងយ៉ាងសង្ខេប ៣ បទពាក្យកាព្យ :

ក- បទព្រហ្មគីត

ខ- បទភូជង្គសេលា

គ- បទកាកគតិ

បើយើងយកបទកាព្យទាំងនោះមកត្រួតពិនិត្យតាមដើងកាព្យ បើញ្ញាថាដើងកាព្យដូនគ្នាស្មើរតែត្រូវដើងកាព្យ ទុកណាជាឃ្លាតបន្ថែមបន្ថយ គឺតងំយើងបំភ្លេចចោលខ្លះ ព្រោះថាបណ្ឌិតដំយ នន្ទ តែងអត្ថបទជាពាក្យកាព្យពេលនោះ លោកតែងតាមសំដីខ្មែរពេលនោះខ្លះ ។ ពុងដូនខ្លះមិនបានសេចក្តី តែបណ្ឌិតដំយ នន្ទ យកកាព្យនោះមកប្រើជាក់ជាស្តែយនៃពុងដូន ។ ដូនកាល ពាក្យខ្លះមិនត្រូវទៅតាមពាក្យខ្មែរបច្ចុប្បន្នទេ តែលោកជាក់មកដើម្បីយកដូន ដូចឃ្លាថា: «កុំព្រាក់នែញ សូមប៉ត្រខ្ញុំជា សាង្ខាប៉ំពេញ គ្រែសូមអ្វីមិញ ឲ្យទ្រានឥតលុស្ស» ។ ពាក្យថា នែញ តឺណាញ់ តែលោកមិនសរសេរថា «ណាញ់» លោកមែរជាសរសេរជា «នែញ» ទៅវិញ ដើម្បីឲ្យស្រួលចាប់ពុងដូន "បេញ" និង "មិញ" ។

សិលាចារឹកជំយ នន្ទ សរសេរតាមអក្ខរាវិរុទ្ធសព្ទប្លែ

បទព្រហ្មគីត

១) សុភមស្តុស្ស- ស្តីស្រីសត្វមង្គ- លោព្រះជយាដោយ សង្ខាតំរែក ។

នា ១៦២៣ ស័ក នែះឥ . . . ម្សាញ់ នៃខ្ញុំទេស ពេចមាឃមែ ទិពារ
ថ្ងៃព្រះហស្បតិ ។ ពីដើមនេះឯណា ដោយគាថាព្រះចុលី លើក
សរសើរពុទ្ធិ បទមួយនីព្រហ្មគីត ។ ៤) អញខ្ញុំថ្វាយបុប្ផា ព្រះកេតវ
សពិដ្ឋ ស្ថិតត្រាសយាល. ស្តេចតង់តីតផ្កាញ់មាវនៃ ។ បទុមក្រពុំ
ស្អាត ថ្វាយព្រះចាទសពិដ្ឋថ្ងៃ លុតលើកទសការក្រៃ ផ្តង់ប្រពៃជាក់
សិរសី ។ សូមក្រាបក្រោមព្រះចាទ អកិរ៉ាទវរវន្ទិ តិតថ្វាយទៅព្រះ
ស្រី រតនត្រ័យស្រីកាលា ។ ៣) រុងរឿងបល្ល័ង្គពេជ្រ តិចត្រស្រេច
រចនា ឆ្លាក់ឆ្លៅជាកីផ្កា ចរិបូណិបួនដណ្តប់ហត្ថ ។ ជាំគ្បួងសឹងត្រប់
ពណិ ល្អអស្ចារ្យនុះច្រវត់ កើតផ្សូ . . . ពោធិសត្វ ព្រះតង់ស្តិតឈ្មះ
មាវធង ។ ថ្វាយព្រះសាក្យមុនី នូវព្រះសិអាយិសោតហោង ត្រាស់
ជមិនាំសត្វធង កុងគន្ធង៍កាលនេះណា ។ ៤) ខ្ញុំក្រាបក្រោមព្រះចាទ
អកិរ៉ាទវរវន្ទា ប្រណម្យព្រះសាស្តា បតាពុទ្ធារត្នត្រ័យ ។ តេជៈអញ
ខ្ញុំថ្វាយ ទសការកាយអស់ហឫទ័យ ភ្លុងធង៍កំបង់ថ្ងៃ ចិត្តមូលមែនៃ
ប្រាថ្នា ។ តិតថ្វាយព្រះចេតីយ ចូរឱ្យមុណីត្រៃត្រឹង្សា សាង់ខុក
ព្រះកេសា អស់ខែពាក់ថ្វាយបង្គំ ។ ៥) ថ្វាយព្រះបដិមា មាសនៅនា
ស្ថានអាស្រមណ៍ ព្រះគ្រុំយសរណគមន៍ ជាំនាក់នៃសត្វធង ។
ថ្វាយព្រះពុទ្ធរូប ព្រះស្លូបចេតីយហោង ថ្វាយគ្រប់ម្រះដីវធង ប្រាសាទ
ដងព្រះគោហា ។ (នៅមានត)

វចនានុក្រមសំស្ក្រឹត-ខ្មែរ

ព្រះមហា ទ៉ាង-ខាត់ រៀបរៀង

(តមក)

– ក ស្ត្រី – ភូ នបុ. ការនៃដំនដែលបុគ្គលមើលកើត ការនៃដំន ដែលអាក្រក់មើល ។ អទស្សាឝ្ឝន នបុ. ថ្នាំលាប (ភ្នែកក្រៅ) ដែលបុគ្គលមើលមិនឃើញ ។

អទ្ទ្ឝភ្ត្រី ស្ត្រី. ឈ្មោះភរិយានៃឥត្ថិ ។

អទ្ទ្ឝ គុ ដែលមើលមិនឃើញ ដែលមិនទាន់ឃើញ ថ្មី, ពិសេសប្លែក ដែលមិនអនុញ្ញាត ។ នបុ សំណាង, បុណ្យកុសល ។ – កម៌ន គុ. ដែលមិនមានកិរិយាធ្វើនូវអ្វីៗដែលបុគ្គលមិនទាន់ឃើញ ដែលមិនបានល្បងមើល ។ – ការិត គុ. ដែលញុំាងវត្ថុដែលបុគ្គលមិនទាន់មើលឃើញឲ្យធ្វើហើយ ញុំាងបុគ្គលឲ្យពិសោធមើលហើយ ។ – បុរុម. គុ (សន្ធិសញ្ញា) ដែលមានបុរសគឺខ្លួនមិនឃើញហើយ ដែលមិនមានអាជ្ញាកណ្តាល ។ – រូប គុ. ដែលមានរូបគឺបុគ្គលមិនឃើញហើយ ។

អទ្ទ្ឝទ្ឝ នបុ. កិរិយាឲ្យគឺបុគ្គលមិនឃើញហើយ កិរិយាមិនទទួល កិរិយាមិនលេចឡើង ។

អទេយ្យ គុ. ដែលបុគ្គលមិនគប្បីឲ្យ ។

អទេវ គុ. ដែលមិនមែនជាទេវតា ដែលជាអសុរៈ ប៉ុ. អសុរ ។ - មាតក គុ. ដែលមិនមែនជាបន្ទាយកើតឯង ដែលជាបន្ទាយគេធ្វើកសង់ ។

អទេសិ គុ. ដែលមិនមែនជាប្រទេស ដែលមិនមែនជាទីហិនល្អ ។ - កាលេ - កាលមិ ក្រ. វិ. ក្នុងទីនឹងកាលមិនគួរ ។ - កាលជ្ញ គុ. ដែលមិនដឹងទីនឹងកាលគួរ ។ - ជ្ញ គុ. ដែលមិនស្គាល់ប្រទេសគួរ ។

អទេសិក គុ. ដែលមិនមានមាតុភូមិ ដែលមិនមានឪពុក ដែលមិនមានអ្នកតំ ។

អទេស្យ គុ. ដែលមិនសៅក្នុងទីហិន ដែលជាតំមុខ ។ (វត្ថុ) ដែលបុគ្គលមិនគប្បីបង្ហាញជាន ។

អទេហពន្ធ ប៉ុ. កិរិយាមិនចងខ្លួនរាងកាយ ។

អទេហភេទ ឧប៉ុ. កិរិយាមិនបែកធ្លាយខ្លួនរាងកាយ ។

អទ្ទឝ្យ ឧប៉ុ. កិរិយាមិនទុក្ខព្រួយ សេចក្តីក្តៅហាន ។ គុ. ដែលមិនទន់ខ្សោយ ដែលក្តៅហាន ។

អទ្ទិវ គុ ដែលមិនមែនជាទេវតា ដែលមិនមែនព្រះឥសី ។ - កត គុ. ដែលព្រះឥសីមិនធ្វើហើយ ។

រឿងសាមកុក

ទកញ្ញាវិបុលពន្ធសេនា ជ្ជ - ភក្ត ដ ប្រែរៀបរៀង

(តមក)

> រឿងសាមកុកទុកជាឃ្យុទ្ធសាស្ត្រ
> អ្នកតាំងវៃឆ្លាសបើបានអាន
> ខំដំឡេះឧបាយកលចំណាន
> តាំងមានសន្តានស្នេហាជាតិ ។
>
> ——— ឃ្យូ-អ៊ិន ———

ឡៅកុយ ខៀវយឹម ដឹងថា ឡៅឈុនលើកទ័ពមក ក៏ចេញទៅទទួលឲ្យចូលទៅក្នុងស្រុក ហើយកឹតណានាក៏យករឿងដែលគេងហាងបក-ជយ័ទីងឡៅពីនោះឲ្យស្តាប់គ្រប់ប្រការ ដ៏អ៊ីថា ឥឡូវសត្រូវលើកកន្ទែងចូលមកទីងដីតដល់ដើងកំផែងហើយ ឡៅពីក៏មានចិត្តកំរើបខ្លាំងណាស់ ដែលទីងតស៊ូដោយថ្លៃដែនោះឃើញថាមិនបាន នរណាទីងតជាកលធ្វើយប្រការម្តេច ទើបទីងកំចាត់សឹកឡៅពីបាន ។

ឡៅងប៉ូថា ដែលទីងតតំចាត់សត្រូវគ្រានេះ ខ្ញុំឃើញថាស្រុកឡុកសៅនោះ តាំងនៅកន្លែងខ្ពស់ជាងដើងកុំ ដែលសត្រូវតាំងនៅនោះប្រៃនឯស្មើងក្បែរស្រុក ទៀតក៏ហូរខ្លាំង ខ្ញុំគិតថាទីងលើកទាហានទៅដីតត្រែតខំលុះទៅត្រង់បន្ទាយសត្រូវ បង្ហូរទឹកឲ្យហូរចាក់ចុះទៅពន្លិចបន្ទាយសត្រូវ ឲ្យស្លាប់ទាហានតាំងនោះឲ្យអស់ហើយ យើងក៏ទីងបានជ័យដំនះដោយងាយ ដ៏អ៊ីយល់ត្រូវឯង ក៏ឲ្យឡៅងប៉ូលើកទាហានទៅធ្វើការដូចថា

ហើយក៏ឲ្យដើរឡាន់ លុយតង លើកតាហានទៅ កង់ទៅការពារមនុស្សដែលធ្វើការនោះឲ្យមាំមួន ។

ឲ្យពីក៏ចាត់ឲ្យអ៊ុយអៀន ហង់តុងទៅរក្សាបន្ទាយប្រគាបឆ្នៀតដែលវាយបាននោះ ហើយគំលើកទៅតាំងទៅគយប៉ាយស៊ីកួន ហើយតាំងណាគ្នាទីឆ្ងាំងថង ដែលទីឆ្ងាតធ្វើការតទៅ ខ្លួលបំរើសេះមកប្រាប់ថា ឥឡូវស៊ីនគួនឲ្យមានសំបុត្រទៅ ដល់ខៀវឡូ ឲ្យលើកតាហានមកវាយយកបន្ទាយហែប៉ាំងគួន ឲ្យពីឮដូច្នោះក៏មានសេចក្តីត្រយ៉ាងណាស់ ទើបប្រឹក្សាទីឆ្ងាំងថងថា បើខៀវឡូលើកមកវាយយកបន្ទាយហែប៉ាំងគួនហើយ ក៏ទីឆ្ងាចង្កូវយើងអស់ ទីឆ្ងាមុខក៏មិនរួច ថយក្រោយក៏មិនបានទីឆ្ងាតប្រការម្តេច ប៉ាំងថងទីយាយទីឆ្ងាបេងតឹតថា ខ្លួនអ្នកឮតស្រុកសែឈួន ដីឆ្ងាដែលទឹឆ្ងាត់ទីឆ្ងាជេញស្ងាញស្ងាត់ណាស់ ព្រោះជាស្រុកកំណើតរបស់អ្នក អ្នកចូលទៅនៅរក្សាបន្ទាយហែប៉ាំងគួនទើបស្រួលបេងតឹតក៏ខ្លួលពាក្យហើយថា ខ្ញុំបាទសុំយកហ៊ុកដុនទៅផង ព្រោះហ៊ុកដុននោះមានថ្វីដៃ ពីដើមជាតាហានឲ្យទៅតៀវ ឲ្យពីក៏ត្រមអនុញ្ញាតទើបចាត់បេងតឹតឲ្យឃុំតាហានលើតទៅរក្សាបន្ទាយហែប៉ាំងគួន ។

ប៉ាំងថងក៏លាឲ្យពីថយទៅទីសំណាក់ មានតាហានម្នាក់ចូលទៅជំរាបប៉ាំងថងថា មានមនុស្សម្នាក់ មានការមកកេះលោក ឈរចាំនៅមាត់ទ្វារ ប៉ាំងថងក៏ដើរចេញទៅ ខ្លួលឃើញអ្នកនោះរូបកាន់ធំខ្ពស់ ៥ ហត្ថ មុខទឹង

ក្នែកស្ងាហាប់ណាស់ ក៏សួរថា អាចារ្យឈ្មោះអ្វី មកពីណា អ្នកនោះ
ក៏មិនឱនិយាយតប ដើរចូលទៅជេកលើគ្រែខាងក្នុង ចាំងថងក៏ចូល
ទៅសួរលោកខ្មែត អ្នកនោះប្រាប់ថា ឲ្យបង្អង់បន្តិចសិនចុះ ព្រោះខ្ញុំ
កំពុងហាត់ខ្មីយណាស់ បន្តិចខ្មែតសឹមប្រាប់កិច្ចការស្រួកខេសដែលធំ
ឲ្យស្តាប់ ចាំងថងមានសេចក្តីសង្ស័យណាស់ ក៏ប្រើមនុស្សឲ្យទៅរៀប
អាហារនាំចូលមក លុះមនុស្សបំរើលើកអាហារចូលមក នៅមិនទាន់
អញ្ជើញឲ្យចំរើកោត ក៏ស្រាប់តែអ្នកនោះក្រោកពីលើគ្រែទៅអង្គុយស៊ីបាយ
ខ្លួនឯង លុះស៊ីឆ្អែតហើយ ក៏ត្រឡប់វិលទៅជេកលើគ្រែដដែលនោះវិញ
ចាំងថងតែតែសង្ស័យណាស់ ក៏ប្រើមនុស្សឲ្យទៅប្រាប់ហួតចេង ។

លុះហួតចេងដើរមកដល់ទ្វារ ចាំងថងក៏ចេញទៅទទួល ហើយ
ពណិនាឲ្យស្តាប់ ហួតចេងថា បើបែបភាពយ៉ាងនេះ ប្រហែលជាផែ
អៀវហើយ ។ ក៏នាំគ្នាដើរចូលទៅខាងក្នុង ផែអៀវឃើញហួតចេងមក
ដល់ ក៏ត្រេកអរណាស់ ក្រោកឡើងទះដៃសើចហើយថា ហួតចេងអ្នក
ឯងមកទៅ ។ នេះហើយឬ ? សព្វថ្ងៃមានសេចក្តីសុខទុក្ខប្រការម្តេចខ្លះ ? ។
ហួតចេងទ្វើយតបទៅតាមដំណើរ ចាំងថងសួរថា អ្នកនេះឈ្មោះអ្វី ? ។
ហួតចេងប្រាប់ថា អ្នកនេះឈ្មោះផែអៀវ ពួកស្រុកកុងហាន ជាមនុស្ស
មានសតិបញ្ញាច្រើនណាស់ តាំងនៅក្នុងទីប្រឹក្សាឡៅដៀង ប្រកបដោយ
សេចក្តីខ្មែងត្រង់សុចរិតនឹងនិយាយការអ្វីក៏មិនបានខ្សេះខ្សោះដូចមនុស្ស-

តាំងពួន ខ្លាដៀងមិនត្រូវចិត្ត ព្រោះដឹងថាមិនគួរសម កំទើងប្រគាន់
តាត់គាល់ចេញ បណ្តេញឲ្យបានសេចក្តីខ្មាស មិនឲ្យនៅក្នុងស្រុក ចាំង-
ចងក៏មានចិត្តគ្រេកអរណាស់ទើបសួរថា អ្នកមកនេះមានការណ៍អ្វី ។

ផែអៀវទ្វើយថា យើងមកគ្រានេះប្រាថ្នាចំណឹងជួយជីវិតអ្នក តែថាយើង
នឹងប្រាប់តែម្តងពុំបានច្រាន ឲ្យខ្លាតាមកកេរយើងសិនសឹមប្រាប់ឲ្យដឹង
ហួតចេងក៏ឲ្យចំរើតៅអញ្ជើញខ្លាតាមក ខ្លាពាក៏សួរថា អ្នកនឹងប្រាប់
សេចក្តីអ្វី ? កំបូរអាណិតប្រាប់ឲ្យបានដឹងបន្តិចមកចុះ ។ ផែអៀវសួរថា
តាហានលោកដែលតាំងនៅបន្ទាយប្រកបន្ទៀតនោះចំនួនប៉ុន្មាន ខ្លាពា-
ថា មានតាហានឯកនៅនោះ តែហាងតុងនឹងអ៊ុយអៀន ២ នាក់ ហើយ
នឹងកូនតាហានប្រមាណ ១ ម៉ឺនប៉ុណ្ណោះទេ ។

ផែអៀវថា លោកកំឡាប់ឆ្លើសគ្រាមមកប្រាកដថាមានសតិបញ្ញា
ហេតុម្តេចខ្លួនលោកជាមេទ័ពក៏មិនដឹងផែនទីជាមុនសិន មើលតៅលោក
ធ្វើការនេះ នៅស្រាលណាស់ លោកសំគាល់ថា តាំងនៅទីនោះស្រួល
ល្អហើយឬ ? ទីនោះមានស្នឹងមួយកុងនៅដិតណាស់ ទីតាំងបន្ទាយនោះ
ជាកន្លែងទំនាប បើសត្រូវនឹងទំលាយទឹកឲ្យហូរធ្លាក់ចាក់មកលិចបន្ទាយ
ហើយនឹងលើកតាហានមកតំទ្ពីក្រោយថែមទៀត តាហានលោកនឹងមិន
នាំគ្នាស្លាប់តាំងអស់ហើយឬ ? ។

ខ្លាពាក្តីផែអៀវមិយាយដូច្នោះ ក៏ភ័យស្ទុតចិត្តគិតតៅឃើញមែនផែ

អៀវបា តែឲ្យវាខ្ចីយើញថ្កាយសម្រាប់អ្នកបុរាណរះឡើងខាងទិសបស្ចិម
មានវស្សីក្តីថ្ងៃណាស់ តែបានថ្កាយ ១ ដួង ស្មើសមៅខាង យើញកាច
ទឹងមានអន្តរាយដល់លោកជាក្រុងឯង ចូរលោកប្រុងប្រយ័ត្នឲ្យមាំមួន
ឲ្យវាំងក័តំនាប់ផែអៀវបើដូចទំប្រើក្បាច់ ហើយកំឲ្យមនុស្សស្រួតសៅក្បាច់
ហាងតុងទឹងអ៊ុយអៀន ឲ្យបង្ខំថាហានមានជាក់យាមតយល្បាតរក្សាបន្ទាយ
កុំឲ្យសត្រូវដើរព្រែកចំណាយទឹកឲ្យលិចបន្ទាយនោះបាន ហាងតុងទឹងអ៊ុយ
អៀនបានដឹងសេចក្តីទឹងហើយ កំដួយគ្នាចេញត្រួតត្រា តយល្បាត
លាតត្រដែលប្រយ័ត្នការរក្សាបន្ទាយនោះមាំមួនណាស់ ។

លុះដល់ពេលកណ្តាលអធ្រាត្រកងកៃ នោះមានភ្លៀងរំលោច ឡើង
ចេញលើកពល ៥ ពាន់ស្រួតសៅដល់ទីនោះទឹងតាំងជីកបង្ហិរទឹក កំពុងតែ
ពយគ្នាជាលំដាប់ចាប់ធ្វើការនោះ ខ្លួលអ៊ុយអៀនយុំាហានចេញសៅ -
តយល្បាត យើញកំស្រែកហោឡើង ឡើងចេញសំឡេងដូច្នោះក៏ភ័យ -
ណាស់ ពួកហានទាំងនោះក៏បែកបាក់ព្រាត់ព្រាយរត់ទំលាយទ័ពជាន់
គ្នាស្ទាប់ជាច្រើនឡើងចេញតឹបំបោលសេះរត់សៅដួបទឹង អ៊ុយអៀន ស្គាក់
ជាប់ កំត្រឡប់ចូលតយុទ្ធគ្នាបាន ៥ ភ្លេង អ៊ុយអៀនកំចាប់ខ្លួនឡើងចេញ
បាន ទឹងវាន់ លុយតងយុំាហានជាតងក្រោយ បានឮសំឡេងស្រែក
ហោឡើង កំបរសេះដេញសៅហានស្រួតសៅជួយឡើងចេញ ជួបប្រទះទឹង
ហាងតុងស្គាក់តាមុខ កំចូលប្រយុទ្ធគ្នាទឹងហាងតុងបាន ២ ភ្លេង តទល់តុំ.

ជានកិច្ចយៅ ។ អ៊ុយអៀនកំចង់យកឡែនចៅៅជូនឡៅតាឯបន្ទាយ
ចៅយស៊ីគួន ឡៅតាឃើញឡែនចៅក៏ជេរថា អាចោរខូរយសគ្មាន-
សេចក្តីសត្យសោះ ហើយបង្អាប់ខាហានតាំងួនឡែនចៅៅប្រហារដើរតែ
រួចក៏ឲ្យរង្គាន់បំណាច់ដល់អ៊ុយអៀនជាច្រើន ។

ខណៈនោះ មាំលៀនកិច្ចលមកជួបចង់ឡៅតាតំនាច់ហើយនិយាយថា
ស្រុកកេងជីវិតនៅជាសុខតាមធម្មតាមិនមានអន្តរាយអ្វីទេ តែឡូវចុងបេង
ប្រើខ្ញុំចាតឲ្យនាំសំបុត្រមកជូនលោក ហើយក៏ហុចសំបុត្រនោះៅឲ្យ-
ឡៅតា ។ តាំហែកស្រោមមើលឃើញសេចក្តីថា ក្នុងផ្នាក្បូរនេះ ខ្ញុំតិនត្រ-
ឃើញផ្កាយ ១ ជួនច្រាកដត្រង់ស្រុកឡុកសៀ នៅខាងបស្ចិមទិសនោះ-
កាចណាស់ មុខជានឹងខូចមេតព័ឌនាយកងដែលលើកមកគ្រានេះជា
ច្រាកដ សូមឲ្យលោកប្រុងប្រយ័ត្នការ រក្សាពួកក្រុមឲ្យមាំមួនកុំប្រមាទ
ឡៅតាដឹងក្នុងសំបុត្រដូច្នោះហើយ ក៏និយាយនឹងមាំលៀនថា ដែលចុង
បេងឲ្យសំបុត្រមកដូច្នេះក៏ដឹងហើយ យើងក៏ចានប្រុងប្រយ័ត្នការមិនហ៊ាន-
ប្រមាទទេ ឲ្យអ្នកស្រុតត្រឡប់ៅច្រាប់ចុងបេងចុះ មាំលៀនតំនាច់-
លាឡៅតាត្រឡប់ៅស្រុកកេងជីវិញ ។

ឡៅតាក៏ប្រឹក្សានឹងចាំងបងថា ចុងបេងមានសំបុត្រដល់ខ្ញុំថា អន្ត-
រាយនឹងមានដល់នាយទ័ពកងនេះ លុះយើងនឹងរំងៅធ្វើការតៅទៀត
ក្រែងអន្តរាយនឹងមានពិត ចុងបេងក៏នឹងបន្ទោសយើងចាន ហេតុនេះគួរ-

យើងលើកទ័ពត្រឡប់ទៅស្រុកគេងដ៏វិសេស ទឹងបានប្រឹក្សាពិគ្រោះទឹងពុទ្ធ-
ចេង ជាអ្នកធំ ជាំងថងមកនឹកតែក្តីចិត្តថា ពុទ្ធចេងឲ្យសំបុត្រមកទាំងនេះ
ដោយចិត្តប្លុស្សា ព្រោះយើញថា យើងមកធ្វើការមុខជាយកស្រុកសែ-
ឈួនបាន ទឹងមានសេចក្តីតាប់ប្រសើរជាច្រើន បានជាគេតែងធ្វើសំបុត្រ
មកទាំងតែការតែមិនឲ្យធ្វើការបាន ទើបនិយាយទឹងឡៅពីថា សត្វថ្ងៃនេះ
ខ្ញុំចាក់ដឹងហើយ ការដែលមើលលើអាកាស យើញផ្កាយមួយកាចមែន
តែថាហេតុនោះគ្មាក់ទៅលើឡើងឬប៉ាឡើងទេ ដែលផ្កាយដួងនោះប្រាកដ
សត្វថ្ងៃ ទឹងបានដល់ពួនលោកទឹងបានធ្វើឆ័ត្រឆ័ទ្រស្រុកសែឈួនទៅ ហេតុ
អ្វីលោកមកសង្ស័យថាទឹងមានអន្តរាយ ហើយគិតទឹងលើកទ័ពត្រឡប់
ទៅស្រុកវិញដូច្នោះ ខ្ញុំចាក់មិនយល់ត្រមង់ទេ សូមឲ្យលោកបង្ខំលើត
ខាហាន ស្រួតទៅធ្វើការវាយយកស្រុកសែឈួនចុះ ឡៅពីក្តៅជាំងថង
ថាដូច្នោះក៏ឿ ទើបឲ្យលើកខាហានត្រឡប់ចូលទៅជិតបន្ទាយប្រក-
បន្ធឿត ដែលសហគ៌តុងអ៊ុយអឿនកក្នាទៅនោះ ។

(នៅមានត)

រឿងល្បែកឡាហ្វុងតែន

លោក ដេង - ទ្រីវ ប្រែរៀបរៀង

(ត)

៥៨- អ្នកបវរទេះជាប់ផ្ទុង

វរទេះមួយផ្ទុកសុទ្ធតែស្បៀងបរទៅ ធ្លាក់ដង្កូកជាប់ផ្ទុង បរទៅទៀតមិនរួច ។ កន្លែងនេះនៅកណ្តាលវាលស្រែ ឆ្ងាយពីផ្ទះអ្នកស្រុកពេក អ្នកម្ចាស់រទេះ រកអ្នកណាជួយមិនបាន ខំប្រឹងរុញតែម្នាក់ឯង រុញទៅរុញមក មិនរួច ទឹងពេក ស្រែកដេរទ្បែតែរួចពីមាត់ ជួនដេរប្រហោងជួនដេរសេះ ដេរទេះ ថែមទាំងដេរខ្លួនឯងផង ។ លុះធ្វើដូចម្តេចមិនរបើក គាត់ទឹកមុខវាវៃដល់ខ្លាំងណាស់ ក៏ស្រែកហៅអ្នកដែលមានកម្លាំងអាចជួយលោកបានឲ្យមកជួយ: ខ្ញុំ! ខេត្តា លោកមានមាត់ទិត្ត ក្រុងចៀកទិត្ត មេត្តាជួយខ្ញុំផង អាណិតជួយទាញរទេះខ្ញុំឲ្យរួចផុតពីតក់ទេះ ។ អង្វរដូច្នេះហើយ ស្រាប់តែឮសំឡេងស្រែកតាំរលើអាកាសមកថា: ខេត្តាចង់ឲ្យមនុស្សលោកប្រឹងប្រែងដោយខ្លួនឯងជាមុន ទើបខេត្តាជួយជាក្រោយ ចូរឯងពិនិត្យមើលឲ្យជាក់ ខ្លួនអ្នកដែលទប់រទេះមិនឲ្យរំលិចនឹងទៅបានតើនៅខាងណា? ចូរកាយអាតក់ចង្កែដែលរុំកាំទឹងដុំចេញពីតង់ឲ្យស្រឡះ ចូរយកចបចំពុះខុង ឯងប់ដុំថ្មដែលទាំងឲ្យទើសតង់ចេញ យកសម្រាមមកចាត់

ត្រង់តក់ឲ្យច្រើន តើឯងបានធ្វើដូចខេត្តប្រាប់ហើយឬ? ។ អ្នកម្ចាស់រះខេះទ្វើយថា បាទ! ខ្ញុំបានធ្វើរួចស្រេចអស់ហើយ ។ ដូច្នេះខេត្តចុះមកជួយអ្នកឯងម្តង ចូរចាប់រំពាត់កាន់ឡើង ។ - ខ្ញុំបានចាប់រំពាត់កាន់ហើយលោក ។ យ៉ាស្រួលខេតើ! រះខេះអញស្រាប់តែលឿនៗដូចចិត្ត លោកខេត្តចំជាពូកែមែន! ។ ខេត្តនិយាយទៀតថា: ឯងយើញារះខេះត្រមាំងសេះឯងបរចេញពីកន្លែងនេះយ៉ាងស្រួលឬខេ? ចំប្រឹងខ្លួនឯងផងទើបខេត្តជួយ ។

៥៩ - អ្នកកាប់ឫស ធំជាវិស្សកម្ម

អ្នកកាប់ឫសម្នាក់ចាត់ពូថៅ រកមិនយើញសោះ ស្តាប់ទៅគួរឲ្យអាណិតពេក ព្រោះគាត់គ្មានពូថៅដទៃជំនួស ហើយសម្បត្តិទ្រព្យគាត់ទាំងអស់ ទៅតែលើពូថៅមួយហ្នឹង ។ ដោយមិនដឹងគិតធ្វើដូចម្តេចទើរកឲ្យបានមកវិញ បុរសកំសត់យំស្រែក ហើយអំពាវនាវសុំខេត្តជួយរកពូថៅឲ្យ បើលោកជួយរកពូថៅបានឲ្យខ្ញុំវិញខ្ញុំ ដូចជាតើតម្លឹងទៀត ។ ព្រះឥន្ទបានឮដូច្នោះ ក៏ប្រើវិស្សកម្មឲ្យហោះចុះមក ហើយឲ្យប្រាប់ថា ពូថៅមិនបាត់ទេ ខ្ញុំដូចជាបានប្រទះទៅកែ្សរើនេះ ប៉ុន្តែខ្លួនស្គាល់ពូថៅឬស់ឬទេ? ។ ព្រះវិស្សកម្មបង្ហាញពូថៅមាសមក ។ បុរសកំសត់ទ្វើយថា: «មិនមែនរបស់ខ្ញុំទេ លោក!» ។ ព្រះវិស្សកម្មញ

ពួរចាប់ប្លុកមកខ្មៀត ។ បុរសកំសត់មិនព្រមខ្ចូល ។ ទីបំផុត លោកហុចអាឈើមក ។ បុរសកំសត់ចេញមុំដីថា: ជាប! អាហ្នឹងហើយ បើលោកមេត្តាឲ្យខ្ញុំ ។ ត្រេកអរណាស់ ។ ខេត្តប្លុកប់ថា: អ្នកឯងត្រូវជាន តាំងបី ដោយអំណាចចិត្តខ្មៀងត្រង់ ។ ន! បើលោកមេត្តាឲ្យ ខ្ញុំព្រមខ្ចូលដោយសេចក្តីត្រេកអរនឹងសេចក្តីតញ្ញូ ។

រឿងនេះមិនជាត់ស្ងាត់ កំបែកសុះសាយឮគ្រាប់គ្នា ។ មានពួកអ្នកតាប់ទុសដែលជាត់ពួរចាប់ដែរ កំស្រែកអំពាវនាវដល់ស្តេចខេត្តឲ្យជួយផង ។ ព្រះរាស្ត្រម្នាហោះចុះមកខ្មៀត ប្លែបបញ្ឆោតពួរចាប៣សជាដំបូង ។ ពួកអាខ្ចប់ស្មានថាខេត្តនោត ទើបធ្វើយថា ជាប! អាហ្នឹងហើយលោក! ។ ព្រះរាស្ត្រម្នាមិនឲ្យពួរចាប ទៅជាសំពងក្បាលដោយពួរចាប់យ៉ាងខ្លាំង ។

នុំកឲ្យសោះ ត្រូវត្រេកអរនឹងរបស់ដែលខ្លួនមាន នេះហើយជាការណ៍ពិត ទីងមិនខ្ចប់ប្រយោជន៍ផង ។ តែមនុស្សយើង ច្រើនតែចូលចិត្តនិយាយកុហក ដើម្បីឲ្យជាន់របស់ល្អជាងមុន ។ ប្រយោជន៍អ្វី ដែលនិយាយដូច្នេះ ខេត្តមិនចេះនោតទេ ។

៦០ - សត្វក្រសារ

ថ្ងៃមួយ ក្រសារដើងវែង កវែង ចំពុះវែង ដើរបរណ្តាយតាមមាត់ស្ទឹងមួយ មានទឹកថ្លាល្អជូចថ្ងៃ ។ ត្រីតារហូទឹងត្រីផ្ងោង ងើបឡើង

ហែលមួយភាន់ដងៗទៅវិញ ទៅមកក្បែរមាត់ច្រាំង បើក្រសាចឹកយកមក
ធ្វើជាអាហារ គឺសឹងតែបានតាមចិត្ត ព្រោះត្រីនោះហែលមកជិត ។ ភាង
តែក្រសាមិនចឹក ដ្បិតភាំឲ្យឃ្លានបន្តិចសិន ពស់មានរបៀបមានទំាងៗ
លុះគេលកខ្លួនបន្តិចទៅ សេចក្តីស្រេកឃ្លានក៏កើតខ្លាំង បក្សីដើរទៅ
អើតឈ្លោកទៅមាត់ស្ទឹង ឃើញតែត្រីចង្រៃហែលចេញពីក្នុងទឹកមក
ចំណីនេះក្រសាមិនត្រូវចិត្ត ត្រូវដេញចាំទៀត ព្រោះក្រសារើសចំណីផង
ហើយពលាន់មាត់ថា: អើយាំងអញជាក្រសា ស៊ីត្រូវឆ្អែជាអាហារថោក
ៗដែ? តើគេខុកអញជាអ្វីទៅ បើស៊ីចំណីបែបហ្នឹង ? ។

លុះត្រីចង្រៃមុជបាត់ទៅ សេចក្តីក្តួងមកទៀត ។ ក្រសារពោល
ថា មកទៀតហើយត្រីក្តួងអ៊ានេះ! ហ្នឹងជាចំណីក្រសាឬ? អញមិន
រវល់ហាមាត់ ចំណីបែបនេះ តែខ្ជិចក៏មិនត្រូវការផង„ ។

ក្រសាប្រកាន់តែថ្នាក់មែបដូច្នេះ រួចក៏ចេះតែដើរ ទៅ ពាល់តែ
រកប្រទះត្រីមួយគ្មានសោះ ។ លុះសេចក្តីស្រេកឃ្លានគ្របសង្កត់ខ្លាំងពេក
រកស៊ីមិនបាន ក្រសារគេងសុទ្ធចិត្តស៊ីខ្លៅ ។

ចូរយើងកុំតាំងខ្លួនជាមនុស្សពិបាកក្រៃពេក អ្នកណាចូលចិត្តនិយម
ច្រើន អ្នកនោះជាមនុស្សឆ្កួតចំផុត ។

ចូរអ្នកច្រយ៉ត្ន កុំមើលងាយអ្វីឲ្យសោះ ពិសេស បើគាលណាអ្នក
យល់ឃើញថា វត្ថុនោះច្រលែលល្មមគុណជាប្រយោជន៍អាត្មាបានហើយ ។

(នៅមានត)

៣- រឿងបឹងអូលីវីយេរ (១)

(តមក)

Le lac des oliviers

រឿងព្រេងជាតិហាន់

Conte de la Nationalité Han

តាំងពីបូកណាកាលយូរណាស់មកហើយ នៅដើងតីមួយ តាមមាត់បឹងអូលីវីយេរ មានយាយចាស់ខ្មែរម្នាក់មានខ្លែលនៅ។ ខ្លែនោះ។ មាតានៃបុត្រនោះ ចាស់ជរាណាស់ទៅហើយ ធ្វើការអ្វីក៏ពុំកើត។ បុត្រនៃយាយចាស់នេះ បានដួលដីមួយកន្លែងពីតុដុតម៉ែកម្មានៅកងកូមិ ហើយក៏ព្យាយាមធ្វើការពីដើមដំរំរហូតដល់ចុងឆ្នាំ។ តែបើទុកជាយ៉ាងណា ក៏នៅតែមានការអត់ឃ្លានជានិរន្តរ៍។

មានកាលមួយថ្ងៃ មាណពជាបុត្រយាយចាស់នោះ មានការឆ្ងល់ខ្លាំងហើយសួរខ្លួនឯងថា : ហេតុដូចម្តេចក៏ខ្ញុំតែងនៅកងបឹងអូលីវីយេរនេះជាខ្មែកហូរជានិច្ច ត្រឡប់ជាខ្មែកតករល្អក់ទៅវិញ ចំណែកខ្លួនឯញ៉ែលខំធ្វើការជានិរន្តរ៍ នៅតែក្រដុនជាប់លាប់ជាកន្លែងយ៉ាង។

១- អូលីវីយេរ (oliver) ជារុក្ខជាតិមួយដែរ ដែលនិយមដាំសម្រាប់ទ្រទេមរឹមទៀតណែ ផ្លែវាមានប្រយោជន៍សម្រាប់ដាក់អាហារឬមានឧបការៈ។ បូរាណពុទ្ធជាតិនេះជាទំនិញសម្បូរនៃបរិភោគណាស់ សន្និភាពនឹងដ៏យូរអង្វែង។

មាណព ក្រោយដែលបានត្រិះរិះដូចខាងលើ ក៏សម្រេចក្នុងចិត្ត ថានឹងយកបញ្ហានេះទៅថ្វាយព្រះអាទិទេពនៃទិសបស្ចិម សូមទ្រង់មេត្តាជួយដោះស្រាយឲ្យបានត្រេះស្រឡះ ។

លុះត្រឹកខ្លឹង មាណពនេះក៏រៀបចំសំពាយ ជាយ ទឹកបំពង់ ហើយតិចារណាថាស្បៀងអាហារល្មមគ្រប់គ្រាន់សម្រាប់មាគ៌ាបរិភោគបានហើយ ក៏រៀបដំណើរទៅទិសបស្ចិម ។

មាណព ដើរតម្រង់ទៅទិសបស្ចិម អស់រយៈវេលាសែសិបប្រាំបួនថ្ងៃៗ តាត់មានមាត់ស្ងួតស្រេកទឹកខះកជាខ្លាំង ។ លុះដល់ថ្ងៃទី ៤៩ តាត់បានដើរទៅចំមុខគេហដ្ឋានមួយយាយចាស់ម្នាក់ហើយសុំទឹកអស្រ័យ ។ យាយចាស់មានចិត្តសប្បុរសក៏ឲ្យទឹកទៅមាណពបរិភោគផ្អែមហើយសួរថា : ចៅឯងបែបប្រញាប់ប្រញាល់ណាស់ ! តើចៅឯងទៅណាមកណា? ។

មាណពតបទៅយាយចាស់វិញថា « សូមជំរាបលោកយាយ ខ្ញុំមានចំណងចង់ទៅមហាមេឃទិសបស្ចិម ។ ខ្ញុំចង់សួរព្រះអាទិទេពថាតួរឲ្យលំទឹកបីដងអូរបីរយហ្មូរដងខ្ចី ម្តេចក៏នៅតែតស៊ូកន្តើយ ហេតុម្តេច ខ្ញុំធ្វើការយប់ថ្ងៃគ្មានឈប់ឈរ នៅតែលំបាកគេកយ៉ាងដូច្នេះ » ។

យាយចាស់តបទៅមាណពថា : នែមាណពអើយ ចូរចៅដួយយាយផង សុំចៅនាំបណ្តាំយាយទៅថ្វាយព្រះអាទិទេពទិសបស្ចិមផងថា « យាយមានឯកញ្ញាអាយុ ១៨ ឆ្នាំហើយ នាងមានប្រាជ្ញា មានរូបឆោម

លោមពណ៌ស្រស់ប្រឹមប្រើយ តែខាងមិនចេះនិយាយ ចូរចៅសួរឱ្យយាយ
ផង ហេតុម្តេចបានជាកូនស្រីយាយមិនចេះនិយាយ » ។

មាណពតបទៅយាយថាស់ថា : « ចាំខ្ញុំសួរព្រះអាទិត្យពេញដួង
លោកយាយ » ។

ក្រោយមាណពកើបដំណើរទៅខាងទិសបស្ចិមអស់រយៈវេលា ៤៨ ថ្ងៃ
តទៅទៀត ។ ពេលសាយណ្ហសម័យនៃថ្ងៃទី ៤៩ មាណពអស់កម្លាំង
ពន់ពេក ។ លុះទៅដល់ផ្ទះតាថស់ម្នាក់ មាណពសុំតាថស់ស្នាក់អា-
ស្រ័យមួយយប់ ។ ក្រោយដែលមាណពបានអង្គុយស្រួលបួលក្តីគេហ
ដ្ឋានហើយ តាថស់សួរមាណពថា : « ចៅ តាសួរចៅ ! ចៅឯងដួច
ជាមកពីប្រទេសឆ្ងាយ . . . តែចៅឯងរកៅណាមកណា បានជាប្រញាប់
ប្រញាល់ដូច្នេះ ? » ។

មាណពតបទៅតាថសវិញ តាមការក្រដួចដែលខ្លួនបានពោលទៅ
កាន់យាយថាស់ខាងលើ ។

តាថស់ឆ្លើយទៅមាណពថា : « ល្អហើយចៅ តែតាសូមផ្តាំទីឯង
ចៅ សូមចៅក្រាបបង្គំទូលសួរព្រះអាទិត្យនៃទិសបស្ចិមដួចតទៅនេះ :
នៅក្នុងសួនតា មានដើមក្រូចពោធិសត្វ មានដើមធំម៉ាមួន មានស្មឹកទៀ
ស្រងាត់ ហេតុដួចម្តេចក៏ពុំមានផ្លែសោះឡើយ » ។

មាណពតបទៅតាវិញថា : « ខ្ញុំជានាក្រាបបង្គំទូលសួរជូនតា » ។

ដល់ព្រឹកស្អែក មាណពបានបន្ទុំដំណើរទៅទៀត ។ មាណពបាន
ទៅដល់ទន្លេមួយធំមានទឹកហូរខ្លាំង ។ ទៅពីនោះគ្មានទូកបម្រុងសោះ
ឡើយ ។ មាណពអង្គុយលើថ្មមាត់ទន្លេ ហើយដកដង្ហើមធំ គិតក្នុងចិត្តថា៖
តើអញត្រូវធ្វើដូចម្តេច? ។ ក្នុងពេលនោះ ស្រាប់តែមានក្រយោបត់ខ្លាំង
ទឹកទន្លេកំពុងជាលេចធំៗ មានឥន្ធនធ្លុះពីលើពពក ។ ទៅក្នុងលេច
គេឃើញនាគមួយខែលមក ។

នាគក៏ស្រែកសួរទៅមាណពថា :

« នាងឯងទៅណាមកណា? » ។

មាណពតបទៅវិញថា : ខ្ញុំមានដំណើរទៅគាន់មហាមេឃទីសុបស្ថិម ។
ខ្ញុំមានបំណងចង់សួរព្រះអាទិទេពថា : (តាមសេចក្តីដូចខាងលើ) ។

នាគតបទៅគាន់មាណពថា : « បើដូច្នេះ ខ្ញុំសូមផ្ទាំងផ្ទើបណ្តាំទៅជា
មួយនាង ចូរនាងយកបណ្តាំខ្ញុំទៅដំកបព្រះអាទិទេពនៃទីសុបស្ថិមផងថា:
ខ្ញុំមិនដែលប្រព្រឹត្តបាបកម្មអ្វីសោះឡើយ ទៅលើមនុស្សក៏គ្មាន សត្វតិរច្ឆាន
ក៏គ្មាន ។ តាំងពី ១០០០ ឆ្នាំមក លុះសព្វថ្ងៃ ខ្ញុំបានប្រព្រឹត្តតែគុណធម៌
ម៉្យាង ហេតុម្តេចក៏ខ្ញុំមិនទាន់មានអំណាចហោះហើរលើអាកាស? » ។

មាណពតបទៅវិញថា : « មិនអីទេបងនាគ សឹមខ្ញុំក្រាបបង្គំទូល
ព្រះអង្គតាមបណ្តាំបង ។

ក្នុងពេលនោះ នាគក៏ឲ្យមាណពឡើងជិះលើខ្នង ហើយហែលទូង

ភាគ៩ខ្ទេដ៏ទៅត្រើយម្ខាង ។

មាណពបន្តដំណើរទៅទៀត ។ ក្រោយដែលបានដើរទៅខាងទិសបស្ចិមអស់រយៈវេលាជាច្រើនថ្ងៃ ស្រាប់តែឃើញមានទីក្រុងមួយមានទំហំភាពល្អណា តែគួរឲ្យពិចពិលរមិលមើល ។ មាណពក្រឡេកទៅឃើញព្រះបរមរាជវាំង ហើយនៅមុខក្លោងទ្វារ មានភាហានចាំនៅទីនោះ ។

មាណពសូមអនុញ្ញាតភាហានឲ្យដួនទៅគាល់ព្រះអាទិទេពនៃទិសបស្ចិម ។ ភាហានក៏ដួនមាណពទៅខាងក្នុង ឃើញព្រះករុណាចាស់មួយព្រះអង្គ មានព្រះកត្រក្តួរជាទីជ្រះថ្លា មានព្រះកេសស្កូវត្រាង ។ មាណពគិតក្នុងចិត្តថា : « ប្រហែលជាព្រះអាទិទេពនៃទិសបស្ចិមទេដឹង ,, ។ ព្រះអាទិទេពទ្រង់ទតទៅឃើញមាណពចូលទៅ គាល់ព្រះអង្គ ក៏មានព្រះរាជឱង្ការសួរថា : “ តើអានាង៦ងមានការណ៍អ្វី បានជាអានាងមក ,, ។

មាណពក៏ក្រាបបង្គំទូលតបចំពោះព្រះអាទិទេពថា :

“ ទូលព្រះបង្គំជាខ្ញុំមកនេះ ដើម្បីនឹងសួរបញ្ហាព្រះអង្គបួនយ៉ាង ,, ។

ព្រះអាទិទេពទ្រង់មានព្រះទេវភ៌ាថា :

យើង៦ចាំស្តាប់មាណព៦ង ។ តែបើអានាង៦ង៦ងដឹង៦ថា យើង៦អនុញ្ញាតឲ្យសួរបញ្ហាចាំង៦នោះបាន ចំពោះតែលេខគ្មានគូគឺ ត្រូវសួរតែបញ្ហាលេខ ១ បញ្ហាលេខ ២ សួរមិនបាន បញ្ហាលេខ ៣ បញ្ហាលេខ ៤ សួរមិនបាន។ បើបញ្ហាមាណព៦ងមានបួន ត្រូវពិចារណាឲ្យហ្មត់ចត់ តើត្រូវចោលបញ្ហាណា ត្រូវសួរបញ្ហាណា ,, ។ (នៅមានត)

សំបុត្រ ទី ១ (១)

សៀវភៅ នៃ ជម្មជាតិ

កាលកូន ខ្ចីៗ ឪពុកនៅជួបជុំគ្នា កូនតែងសាកសួរឪពុកជារឿយ ។ អំពីវត្ថុចាំងឡាយជាច្រើន ហើយឪពុកក៏ឱនទំធ្វើឲ្យគប្បីនឹងសំនួរចាំងនោះ ។ ឥឡូវកូននៅឯស្រុកមុស៊ូរី(Mussoorie) ឯឪពុកនៅឯស្រុកអាឡាហាបាត (Allahabad) យើងពុំអាចនិយាយសាកសួរគ្នាបែបនេះបានទៀតទេ ។ ពេលនេះ ឪពុក ខ្ចីៗ សរសេរផ្ញើរទៅកូនយូរៗ ម្តង ខ្លះរឿងក៏វែងឡាយខ្លី ។ អំពីប្រវត្តិនៃផែនដីរបស់យើង ហើយនឹងប្រទេសចាំងឡាយជាច្រើន ចាំងតួចចាំងធំដែលបែងចែកនៅលើផែនដីនេះ ។ កូនបានអានខ្លះហើយ ខ្លះប្រវត្តិសាស្ត្រអង់គ្លេស នឹងប្រវត្តិសាស្ត្រឥណ្ឌា ។ តែថា ប្រទេសអង់គ្លេសគ្រាន់តែជាកោះមួយដ៏តូចប៉ុណ្ណោះ ហើយប្រទេសឥណ្ឌា គេរាប់ជាមហាប្រទេសមួយក៏ដោយ ក៏គ្រាន់តែជាផ្នែកមួយយ៉ាងតូចនៃផ្ទៃប្រថពីដែរ ។ ប្រសិនបើយើងចង់ដឹងអ្វីមួយអំពីប្រវត្តិនៃពិភពលោកយើងនេះ យើងគប្បីគិតពិចារណាទៅដល់ប្រទេសចាំងអស់ នឹងមនុស្សចាំងអស់ ដែលបានរស់នៅលើពិភពលោកនេះសិន គឺមិនមែនត្រឹមតែស្រុកមួយយ៉ាងតូច ដែលយើងបានកើតនៅនោះឡើយ ។

ឪពុកបារម្ភក្រែង ឪពុកអាចនិយាយច្រាប់កូននៅកន្លងសំបុត្រចាំងនោះ

១—អត្ថបទនេះ ឈ្មោះ ឈន-អៀម បានប្រែមកពីអង់គ្លេស គឺជាសំបុត្រដែលលោកខេរ៉ុ តាយការផ្ញើមន្ត្រីដល់ទៅឲ្យកូនស្រីលោក ។

ជាន់តិចតួចពេក ។ តែឪពុកសង្ឃឹមថាការតិចតួចនេះ នឹងធ្វើឲ្យកូនជាប់ចិត្ត ហើយធ្វើឲ្យកូនគិតពិចារណាដល់ពិភពលោកខាងមួល ហើយនឹងមនុស្សខាងឯណាយដទៃទៀតនៅលើពិភពលោកនេះ ខុសដូចជាបងប្អូនប្រុសស្រីរបស់យើង ។ លុះដល់កូនចំរើនវ័យធំឡើង កូននឹងបានអានឲ្យច្រើនតួនៃផែនដី ហើយនឹងមនុស្សខាងឯណាយនៅលើផែនដីនេះ នៅតាមសៀវភៅខាងឯណាយ កូនមុខជាឃើញរឿងរ៉ាវនេះ មានសារៈសំខាន់ជាងរឿងរ៉ាវប្រលោមលោកឯទៀត ។ ដែលកូនអាចបានអានពុំខាន ។

ពិតមែន កូនដឹងថាផែនដីយើងនេះ មានអាយុចាស់ពេកណាស់ គឺរាប់លានកោដិឆ្នាំមកហើយ ។ ជាយូរលង់មកហើយ ពុំមានមនុស្សប្រុសស្រីរស់នៅលើផែនដីនេះទេ ។ មុនពេលដែលមនុស្សកើតមានឡើង គឺមានតែពួកសត្វប៉ុណ្ណោះ ហើយមុនពួកសត្វកើតមានទៀត គឺជាសម័យមួយដែលពុំមានសត្វមានជីវិតបែបណាមួយ មានអត្ថិភាពនៅលើផែនដីឡើយ ។ នេះគឺជាហេតុមួយដ៏ពិបាកគិតស្មុនឲ្យពិភពលោកយើងនេះ ដែលសត្វខ្លែងពោរពេញទៅដោយមនុស្សសត្វគ្រប់បែបហ៊ាន ទៅជាពុំមានមនុស្សសត្វបិតនៅទៅវិញ។ ប៉ុន្តែ ពួកអ្នកវិទ្យាសាស្ត្រ ហើយនឹងពួកមនុស្សដែលបានសិក្សា ស្រាវជ្រាវ អំពីរឿងរ៉ាវទាំងនេះ មុខជាប្រាប់យើងថា មានសម័យមួយ គឺគ្រាដែលផែនដីត្រៀមខ្លាំងពេក ពុំអាចឲ្យសត្វមានជីវិតណាមួយរស់នៅឯណាបាន ។ ប្រសិនបើយើងមានសៀវភៅ

តំណាងឲ្យរបស់លោកតំណាងនោះ ហើយយើងសិក្សាពិនិត្យទៅថ្មតំណាងឲ្យនឹងសំណល់ធ្លឹងសត្វនានាផង ហើយអាចយើញ ដោយខ្លួនឯង ថារឿងនេះមុខជាពិតដូច្នោះមែន ។

(សម័យនេះ) កូនអានប្រវត្តិសាស្ត្រទៅក្នុងសៀវភៅនានា ។ ប៉ុន្តែតាលតីសម័យព្រេងនាយ តាលដែលមនុស្សមិនទាន់មានអត្ថិភាពពិតប្រាកដនៅឡើយ នោះពុំមានសៀវភៅណាសរសេរទុកទេ ។ តើយើងអាចដឹងថាមានអ្វីខ្លះកើតឡើង ? យើងពុំអាចគ្រាន់តែអង្គុយ ហើយស្មានបង្កើតឡើងនូវរឿងទាំងអស់បានទេ ។ ប៉ើង្វើបែបនេះបាន មុខជាជាប់ចិត្តណាស់ហើយ ព្រោះយើងអាចស្មានបង្កើតឡើងនូវរឿងអ្វីមួយដែលយើងប្រាថ្នា ហើយដូច្នេះ យើងមុខជាអាចបង្កើតបានទូរទៅនិទានតំណាងឲ្យយ៉ាងអស្ចារ្យ ។ ប៉ុន្តែ អំពើបែបនេះ ពុំមែនជាការណ៍ពិតឡើយ ព្រោះវាពុំមែនផ្អែកទៅលើហេតុការណ៍ណាមួយដែលយើងបានយើញឡើយ ។ តែទោះជាយើងពុំមានសៀវភៅតំណាងឲ្យកត់ត្រាទុកក្នុងសម័យដ៏យូរលង់ទោះក៏ដោយ ក៏ឮសំណាងល្អ យើងមានវត្ថុតំណាងឲ្យ ដែលប្រាប់យើងនូវហេតុការណ៍ជាច្រើន ស្ទើរតែល្អដូចជាសៀវភៅដែរ ។ យើងមាន ថ្ម ក្តឹ សម្បុរ ផ្កាយ ខន្ធស្ងឹង ឥលខ្លាច់ សំណល់ធ្លឹងសត្វ ជាដើម ។ តំណាងឲ្យ ។ វត្ថុតំណាងនេះនឹង វត្ថុឯទៀត ។ គឺជាសៀវភៅតំណាងឲ្យនៃប្រវត្តិបរមបុរាណរបស់ផែនដី ។ ហើយមានតាំងពីប្រាកដ

សម្រាប់ឲ្យយល់ច្បាស់នូវប្រវត្តិនេះ តើមិនមែនគ្រាន់តែអានប្រវត្តិនេះនៅក្នុងសៀវភៅរបស់មនុស្សឯទៀត ។ ទេ ប៉ុន្តែត្រូវទៅឲ្យដល់សៀវភៅយ៉ាងធំ នៃធម្មជាតិផ្ទាល់តែម្តង ។ ឪពុកសង្ឃឹមពុកថាកូនមុខតែនឹងចាប់ផ្តើមរៀន តើត្រូវអានប្រវត្តិនេះអំពី ថ្ម ឥដ្ឋ ភ្នំ យ៉ាងដូចម្តេច ក្នុងពេលបច្ចុប្បន្នខ្លួនពុំខាន ។ ចូរកូនគិតស្មានទៅមើលថាតើអំពើនេះធ្វើឲ្យជាប់ចិត្តយ៉ាងណាទៅ? គ្រាប់នៃដុំថ្មតូច ។ ដែលកូនឃើញនៅក្នុងផ្លូវថ្នល់ ឬក៏ទៅដើងភ្នំ អាចជាចំណែកមួយដ៏តូចក្នុងសៀវភៅរបស់ធម្មជាតិបាន ហើយអាចប្រាប់កូនឲ្យដឹងអ្វីមួយបាន បើសិនជាកូនដឹងថាតើត្រូវអានសៀវភៅធម្មជាតិនេះបែបណា ។ ដើម្បីអាចអានភាសាណាមួយបាន ហ៊ិណ្ឌី ឬក៏ អៀរម៉ូ ឬក៏អង់គ្លេស កូនត្រូវតែរៀនព្យញ្ជនៈរបស់ភាសានោះសិន ។ ដូច្នេះកូនក៏ត្រូវតែរៀនព្យញ្ជនៈរបស់ធម្មជាតិដែរ មុនកូនអាចអានប្រវត្តិនៅក្នុងសៀវភៅទាំងឡាយដាក់ថ្មស៊ីលាបានរបស់ធម្មជាតិ ។ ប្រហែលជាក្នុងពេលឥឡូវនេះ កូនដឹងបន្តិចហើយថាតើត្រូវអានសៀវភៅនេះបែបណា ។ បើកូនឃើញដុំត្រួសដ៏ក្តីរលោងតូចមួយយ៉ាងមូលតុំ តើដុំត្រួសនេះមិនបានប្រាប់កូនឲ្យដឹងអ្វីមួយទេឬ? តើហេតុដូចម្តេចបានជាវាមូលតុំ រលើងរលិល ហើយក្តីរលោង គ្មានជ្រួងជ្រាយយ៉ាងនេះ? បើកូនវាយបំបែកដុំថ្មមួយដុំទៅជាបំណែកតូច ។ រឹតបំណែកនិមួយ ។ គ្រាតហើយមានជ្រួងនឹង ប៉ុន្តែស្រួចរលាម ។ ក៏មិនមែនដូចដុំត្រួសរលើងក្តីហើយមូលនោះទេ ។

តើដុំត្រួសនៅជាមួយហើយរលើងក្តីរលោងដោយប្រការដូចម្តេច ? ឥន្ទឹង
ត្រូវប្រតិបត្តិវាដល់កូនឯងពុំបាន បើកូនមានភ្នែកល្អសំពប់មើល មាន
ត្រចៀកល្អសម្រាប់ស្តាប់ ។ វាន់និយាយប្រាប់កូនថា ឥឡូវដើម តាំងតែ
ឥយូរមកហើយ វាជាប់ណែកមួយរបស់ដុំថ្ម ដូចជាប់ណែកដែលកូនឯង
អាចបំបែកពីដុំថ្ម ឬ ដុំសីលាធំមួយសុទ្ធសាធដ៏មានជ្រុងស្រួច ឥឡូវ ខ្លួនជា
ច្រើននោះដែរ ។ ប្រហែលជាវាបិតនៅលើដីនិរភ្នំណាមួយ ។ លុះដល់មាន
ភ្លៀងធ្លាក់មក ទឹកភ្លៀងក៏ហៀរចំលាក់ទៅក្នុងជ្រលងតូច ។ ដែលនាំវា
ទៅដួប ឥឡូវចន្លោះទឹកភ្នំហូរគោញវាប្រមៀលរហូតទាល់តែ វាបានទៅដល់
ស្ទឹងតូចមួយ ។ រួចស្ទឹងតូចក៏ហូរនាំវាទៅកន្លែងទន្លេធំ ។ នៅត្រង់តែខណៈ
ដែលវាប្រមៀលនៅបានស្ទឹង ជ្រុងស្រួចៗរបស់វាក៏សឹកបាត់ហើយឆ្លុតត្រាតតែត្រឹម
ក៏ទៅជារលើង ហើយក្តីរលោង ។ តើវាបានមកជាដុំត្រួសដែលកូនឃើញតាមបែបនេះឯង ។ ស្ទឹងទន្លេ ពុំបានហូរនាំវាទៅទេ ដោយ
ហេតុណាមួយកូនក៏បានឃើញវាទៅៗ បើស្ទឹងទន្លេចេះតែហូរនាំវាទៅទៀត
វាតែតែសឹកតូចទៅៗរហូតដល់ទីបំផុតវាក្លាយទៅជាត្រាប់ឬច្រាច់ ហើយនៅ
ភ្ជុំជាមួយបងប្អូនតាំងឡាយរបស់វាឯទាយឬច្រាច់ ដើម្បីកទៅជាគ្រួយដ៏ល្អ
មួយដែលកុមារតូចៗតាំងឡាយមកលេងហើយតូនធ្វើជាប្រាសាទដ៏ឬច្រាច់ ។

បើប្រសិនដុំត្រួសតូចមួយអាចនិយាយប្រាប់កូនច្រើនដល់ម្ល៉ះ តើ
យើងអាចរៀនអំពីថ្មសីលា ឥឡូវ ក្តីតាំងអស់ ហើយ ឥឡូវអំពីតុតាំងឡាយ
ឯទៀតដែលយើងឃើញនៅជុំវិញយើង បានច្រើនយ៉ាងណាទៅ ?

ទំនៀមទម្លាប់ នៃទេមរជាតិ
ខ្មែរតួរថ្មីឃ្លាត សិក្សាពេញទី ។
ព្រោះទេមរជាតិ ជាជាតិសោភ័
ក្នុងទ្វីបអាស៊ី តាំងពីព្រេងនាយ ។

ប. ព.

ប្រកាសប្រឡងប្រជែងទំនៀមទម្លាប់ខ្មែរ

ក្នុងឆមាសទី ២ ឆ្នាំ ១៩៦៣

នៅឆមាសទី ២ គឺពីខែកក្កដា ដល់ខែធ្នូ ឆ្នាំ ១៩៦៣ ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យត្រូវការជ្រើសរើសយកឯកសារទំនៀមទម្លាប់ខ្មែរ ដោយបើកការប្រឡងប្រជែងពីរមុខ គឺ

១ – អំពីនៀង

២ – អំពីរង្វាស់រង្វាល់

ដូច្នេះ អស់លោក-អ្នកចេះដឹងទាំងឡាយ ជាបុរស ជាស្ត្រី ឬជាបព្វជិត ដែលស្ម័គ្រចិត្តប្រឡង សូមសរសេរតែងវិញ្ញាសា តាមគោលបញ្ជាដូចរៀបរាប់ខាងមុខ ឲ្យការណាទៅក្រុមជំនុំទំនៀមទម្លាប់ខ្មែរ យ៉ាងយូរបំផុតត្រឹមថ្ងៃដាច់ខែធ្នូ ឆ្នាំ ១៩៦៣ ។

ការប្រឡងប្រជែងនេះមានរង្វាន់ដា ៤ ថ្នាក់

ថ្នាក់លេខ ១ . . . ១០០០រ៉ៀល | ថ្នាក់លេខ ៣ . . . . ៦០០រ៉ៀល

ថ្នាក់លេខ ២ . . . ៨០០រ៉ៀល | ថ្នាក់លេខ ៤ . . . . ៤០០រ៉ៀល

បណ្ណាវិញ្ញាសាចំនួនមុខនេះ បើបេក្ខជនម្នាក់ ធ្វើវៅជាក់ប្រឡងចំនួនមុខ ហើយបានល្អចំនួនមុខ អាចបានរង្វាន់ចំនួនមុខ, តែបើស្ត្រីជាក់ប្រឡងចំនួនមុខ សូមសរសេរវិញ្ញាសាន័មួយ ។ លើសៀវភៅសរសេរខ្នាតធំ មានចំនួនទំព័រតិចឬច្រើន តាមសេចក្តីខ្វីឬវែងផ្សេងគ្នា គឺវិញ្ញាសា១ មុខ ជាក់សៀវភៅ ១ កុំជាក់ ២ មុខចូលគ្នា ន័ងកុំសរសេរលើក្រដាសតែមួយ ១ សន្ទឹក ២ សន្ទឹកស្តើង ។ ឡើយ, ហើយសូមសរសេរនាមន័ងលំនៅរបស់ខ្លួនឲ្យច្បាស់លាស់ លើក្រដាស ១ សន្ទឹក ដោយឡែក ជាក់ភ្ជាប់ស្រោមសំបុត្រ ១ ជាមួយន័ងវិញ្ញាសានោះ យកវៅឲ្យផ្ទាល់ខ្លួន កំបាន ធ្វើតាមប៉ុស្តិ៍ក៏បាន ដោយការខ្ចាងសំបុត្រថា:

ពន្ធសាសនបណ្ណាល័យ ក្រុងភ្នំពេញ

(ផ្នែកក្រុមជំនុំទំនៀមទម្លាប់ខ្មែរ)

គោលបញ្ជានៃការប្រឡងប្រជែង

១ – អំពីទៀង:

ខ្ញុំរាយើងន័យមប្រើវៀនគ្រប់គោលក្នុងពាក្យផ្សេង ។ ទើបក្រុម

ជំនុំទំនៀមទម្លាប់ចង់បានសំណុំរឿងអធិប្បាយយ៉ាងតិចស្តាអំពីខឿន ដូចមានសំនួរជាលំនាំខាងក្រោមនេះ៖

ដើមកំណើតខឿន :

តើអ្វីដែលយកមកធ្វើជាខឿន ? គេធ្វើខឿនដូចម្តេច ? មានពុម្ពចាក់ ឬលាយនឹងដែរ ? គេយកក្រមួនមកធ្វើដូចម្តេច ដើម្បីឲ្យងាយរចនាទៅជាខឿន ? ក្រៅអំពីក្រមួន គេអាចប្រើតើអ្វីជំនួសបានឬទេ ? គេយកអំបោះអ៊ីធ្វើជាប្រភេទ ? ការធ្វើខឿនមានត្រណមអ្វីទេ ? ខឿនមានខ្នាតយ៉ាងណាខ្លះ ?

ភាពខឿនផ្សេងៗ គឺឯខឿនណាជាតំណាងអ្វី:

ខ្មែរយើងប្រើខឿនច្រើនយ៉ាង គឺខឿនកយ, ខឿនគោល, ខឿនកល្ប, ខឿនពេលា, ខឿនស្នែងក្របី, ខឿនដើងត្បូង, ខឿនបេះបក,ខឿនកុំព្យែ, ខឿនបង្កិលតាល, ខឿនដំយ, ខឿនវស្សា, ខឿនត្រែង, ខឿនតំភ្លឹង ។ល។ សូមអធិប្បាយអំពីភាពនៃខឿនដូចខាងលើនេះ ទឹងសូមបញ្ជាក់អំពីចម្ងាយ ទំហំ ប្រវែង ព្រមទាំងចំនួនសរសៃអំបោះដែលប្រើធ្វើប្រភេទផង, ចំនួនសរសៃអំបោះតំណាងអ្វី ? តួបណ្តាខឿនទាំងនោះ ខឿនណាតំណាងអ្វី ? ចំនួនខឿនតំណាងអ្វី ?

ការប្រើទៀនក្នុងទំនៀមផ្សេងៗ :

ទៀនណាប្រើក្នុងតំណាក ? សូមអធិប្បាយអំពីទំនៀមផ្សេងៗ ភាក់ងឺដោយទៀនដែលលោកអ្នកបានជ្រាប ។ រៀបអុជទៀន ទឹងតន្តុតទៀន មានទំនៀមធ្វើដូចម្តេច ? ចំពោះទៀនដែលប្រើកងមង្គល ដូចជាទៀនពោល, ទៀនបង្កិលពពិល, ទៀនគោល, ទៀនកល្ប ។ល។ តើមានដំនឿដូចម្តេចខ្លះ បានជាធ្វើ ?

ជាដំបូងមក ក្រុមដំនុំតែងអំពាវនាវសូមឲ្យលោកអ្នកប្រឡងប្រាប់ដើមកំណើតនៃការដែលលោកអ្នកសរសេរតែង តើថាបើលោកអ្នកធ្លាប់បានឃើញ ឬធ្លាប់បានធ្វើដោយខ្លួនឯងក៏សូមបញ្ជាក់តាមដំណើរ ទឹងសូមប្រាប់ថាតើទៀនបែបណា ដែលសព្វថ្ងៃនេះ គេឈប់ប្រើទៅហើយ ។ មួយទៀត សូមនិពាន រឿងត្រូវភាក់ងឺដោយទៀន ឬដោយដើមកំណើតទៀនផង ។

២ – អំពីវង្វាស់វង្វាល់ :

ក្រុមដំនុំចំនៀមទម្លាប់ខ្លះសំណុំរឿងជាច្រើនស្តីអំពីវង្វាស់វង្វាល់ការថ្វាយ ទឹងការចាយប្រាក់កាសជាន់ដើម ។ ដើម្បីកុំឲ្យលេខាបានរៀបរៀបបុពណ្ណសូន្យទៅ, យើងសូមអំពាវនាវដល់អស់លោក

អ្នកដែលមានបងប្អូនដ៏ជូនដីតាចាស់ ។ ដែលនៅចាំរបៀបវាស់វាល់ ថែបបុកណា ឲ្យលោកសួរអស់លោកចាស់ ។ ចាំឯនោះ ហើយសរសេរតែងចូលទៅប្រឡងប្រចាំធមាសទី ៤ នៃឆ្នាំ ១៩៦៣ នេះ ។

ដើម្បីឲ្យងាយដល់អស់លោកអ្នកសរសេរតែង យើងសូមជូនបញ្ជាផ្លាល់នាំដូចខាងក្រោម ៖

រង្វាស់ :

ខ្នែរបុកណាប្រើអ្វីសម្រាប់វាស់សំពត់ អាវ ដីស្រែ-ចំការ ដីកូមិ ? តើលោកអ្នកអាចធៀបរង្វាស់ចាំឯនោះមកនឹងរង្វាស់ម៉ែត្រដែលយើងប្រើសព្វថ្ងៃថ្មានឬទេ ? បើថ្មាន តើប្រវែងប៉ុន្មាន ? ដូចជាថាចំអាមប្រវែងពីដៃណាទៅដៃណា ហៅ ១ ចំអាម ? ១ ចំអាមមានប៉ុន្មានឆ្នាប់ ? អ្វីហៅថាឆ្នាប់ ? អ្វីហៅថា ១ អង្គុលី ? ប៉ុន្មានចំអាមទើបហៅថា ១ ហត្ថ ?

ហត្ថ :

ដូចម្តេចហៅថាហត្ថ ? ១ ហត្ថមានប៉ុន្មានចំអាម ? ហើយ ១ ហត្ថប្រវែងប៉ុន្មានសង្ទីម៉ែត្រ ?

គក់ :

ប្រវែងពីត្រឹមណាទៅត្រឹមណាហៅថាគក់ ? គេប្រើសម្រាប់វាស់អ្វីខ្លះ ?

ក្បាម :

ដូចម្តេចហៅថាក្បាម ? ១ ក្បាមប៉ុន្មានហត្ថ ? យកហត្ថថែប
ណាជាប្រមាណ ? បើគិតជាម៉ែត្រប៉ុន្មានម៉ែត្រជា ១ ក្បាម ?

ទូប :

ដូចម្តេចហៅថាទូប ? ១ ទូបប៉ុន្មានហត្ថ ឬប៉ុន្មានម៉ែត្រ ? រង្វាស់
ដទៃទៀតក្រៅពីនេះដែលជាន់បុកណាធ្លាប់មានប្រើនៅស្រុកលោក
អ្នក ក៏សូមបរិយាយមកផង ។

រង្វាល់ :

បុកណាប្រើអ្វីខ្លះជារង្វាល់ ? តាមដែលយើងធ្លាប់បានដឹងខ្លះ ។
មកគឺ នាឡិ (សម្រាប់រាល់អង្គរ) កន្ត្តាំង-តៅ-ថាំង ។ល។
សូមអធិប្បាយរង្វាល់មួយ ។ ឲ្យបានគ្រប់សព្វ ដូចជាកន្ត្តាំង អ្វី
ដែលហៅថាកន្ត្តាំង ? ១ កន្ត្តាំងមួយទំប៉ុន្មានដោយស្មាន ? រមៀប
រាល់ដូចម្តេច ? កៀស ឬកំពុង ? កន្ត្តាំងគេប្រើរាល់អ្វីខ្លះ ? សូមរៀ
រង្វាល់ឯទៀត ក៏សូមលោកអ្នកអធិប្បាយដូចសំនួរខាងលើនេះដែរ ។
បើរាល់តែកវគេសន្មតយកអ្វីប្រើជាកម្រិត ?

ការប្ដឹង :

ខ្មែរបុកណាមានដញ្ជើងខ្លះ ? ធ្វើអំពីអ្វី ? គេប្រើដញ្ជើងដូចម្តេច

សម្រាប់ថ្លឹងមាសប្រាក់។ ១ តម្លឹងមាស ១០ ១ តម្លឹងរបស់ឯម្នាក់ មួយនេះស្មើគ្នាឬខុសគ្នា ? បុព្វណាគេប្រើជញ្ជីងថ្លឹងអ្វីខ្លះ ? ក្នុងរបៀបការពន្ធដារ ទំនិញរបស់ផ្សេង។ គេយកអ្វីថ្លឹង ? ការលក់ទិញមានរបៀបដូចម្តេច ? គេដឹកនាំទំនិញផ្សេង។ របៀបណា ? គេដំកល់ទំនិញទុកបែបណា ?

ខ្មែរប្រើអ្វីខ្លះសម្រាប់ចាយជាប្រាក់? ប្រាក់ដំនាន់បុព្វណាមានប៉ុន្មានបែប ? បែបដូចម្តេចខ្លះ ? មានតម្លៃដូចម្តេច ? តម្លៃជុំនិមួយ។ ចែកជាតម្លៃកាយប៉ុន្មាន ? កាលជាន់ដើម មានយកវត្ថុអ្វីក្រៅពីសាច់ប្រាក់ធ្វើជាប្រាក់ចាយទេ ? មានប្រើប្រាក់ក្រដាសឬទេ ? បើមានតើដូចម្តេចខ្លះ ? ក្នុងផ្លែកាលណា ? គេទុកជាក់ប្រាក់របៀបណា ?

ជាពិសេស សូមអធិប្បាយអំពីត្រណម ពាក្យស្មោក ពាក្យបណ្តៅឬសុភាសិតបុព្វណា ព្រមទាំងនិទានរឿងត្រង់ទាក់ទងដោយរបស់ទាំងនោះផង។

បណ្តារឿងទាំង ២ មុខ។ គឺខឿន នំនិរង្វាស់រង្វាល់នេះ របស់ឯមួយ។ បើលោកអ្នកអាចគូរជារូបភាពបាន នោះជាការប្រសើរណាស់ដើម្បីឲ្យអ្នកពុំដែលឃើញ ពុំដែលស្គាល់របស់អស់ទាំងនោះ ឬបានស្គាល់ឬបានឃើញផង។

បើលោកអ្នកសរសេររឿងណា, ដើម្បីឲ្យវិញ្ញាសារឿងនោះមាន

ដ៏ស្មុគស្មាញខ្លាំងមានតម្លៃ, ក្រុមដំនុំសូមឲ្យអស់លោកអ្នកតែងបញ្ជាក់ដើម
កំណើតនៃការដែលសរសេរតែងនោះថា ចាប់ដើមពីអ្នកណា ? ឈ្មោះអ្វី?
ធ្វើការបែបអ្វី? នៅស្រុកភូមិណា ? បើចាប់ដើមដោយចាប់យើញគេធ្វើ
ឬឆ្លាប់ចាប់ធ្វើជាលំនូនសូមប្រាប់ផង កុំភ្លេច ខ្លឹមសូមអធិប្បាយសេចក្តី
ផ្សេងៗតែដែលចាត់តែងដោយរឿងទាំង ២ មុខនោះដែលក្រុមដំនុំនឹកតុំ
យើញ តុំចាប់ដាក់សំនួរក្នុងប្រកាសប្រឡងនេះផង ។

ក្រុមដំនុំឆ្ងល់សង្កេតយើញអស់លោកអ្នកប្រឡង ច្រើនតែសរ
សេរតែងសង្ខេបពេក លេបបាត់ការសំខាន់ដែលក្រុមដំនុំត្រូវការអស់ ។
សូមអស់លោកអ្នកកុំភ្លាចវែងឲ្យសោះ សូមធ្វើឲ្យអស់សេចក្តី ព្រោះ
បើការដែលលោកតែងនោះជាការចាំបាច់ ហើយរៀបរាប់ច្បាស់ ។ នោះ
ធ្វើឲ្យក្រុមដំនុំពិនិត្យកែការប្រាកដតុំយើញ ។ ហេតុនេះ សូមអធិប្បាយ
ៗ មួយៗ ឲ្យសព្វគ្រប់ឲ្យអស់ចំណេះ តាមដែលលោកអ្នកចេះចាំ ។

ជាពិសេស ក្រុមដំនុំសូមជំរាបលោកអ្នកស្ម័គ្រចិត្តប្រឡងថា បណ្តា
វិញ្ញាសាទាំង ២ មុខនេះ មុខនីមួយតែងវិញ្ញាសាមុខណា សូមពិនិត្យមើល
តាស្ស្សរបេសក់ក្រុមដំនុំក្នុងវិញ្ញាសាមុខនោះឲ្យមែនទែនឲ្យសព្វគ្រប់ ដើម្បី
កុំឲ្យឃ្លាងសេចក្តីគ្នា ។ ចំពោះការអ្វីដែលខៅធ្ងល់ បើអស់លោកចង់
សរសេរខៅសួរក្រុមដំនុំ ។ នឹងធ្វើយបំភ្លឺសេចក្តីដូនតាមបំណងបាន ។

ក្រុមជំនុំទំនៀមទម្លាប់ស្រុកខ្មែរ

បុណ្យបញ្ចុះសីមាវត្តខ្ពស់ណ្ណាលោម

ក្រុងភ្នំពេញ

ក្នុងឱកាសព្រះអគ្គមហាសន្ធបត្តមក្ក សម្តេចព្រះប្រមុខរដ្ឋជាឪតាឯកភាជ្យជាតិ បានស្តេចយាងទៅជាព្រះរាជាធិបតី ក្នុងពិធីបុណ្យបញ្ចុះសីមាវត្តខ្ពស់ណ្ណាលោមនោះ ។ បុណ្យនេះកំណត់ធ្វើអស់រយៈកាល ៤ ថ្ងៃ ៤ យប់ គឺតាំងពីថ្ងៃទី ១ មិថុនា រហូតដល់ថ្ងៃទី ៤ មិថុនា ឆ្នាំ ១៩៦៣ ។

ថ្ងៃទី ១ ថ្ងៃសៅរ៍ ១០ កើតខែជេស្ឋ (ថ្ងៃទី ១ មិថុនាឆ្នាំ ១៩៦៣)

ថ្ងៃនេះ ជាថ្ងៃចូលពិធីបុណ្យ ចាប់តាំងតាំងពីម៉ោង ៤ រសៀលទៅ ក្រុមពុទ្ធបរិស័ទតាំងបព្វជិត តាំងគ្រហស្ថ ពាក់រយៈពាន់នាក់ ជានិមន្តនីត-អញ្ជើញពីវត្តក្រៅ ទីឯទីក្រុង ត្រង់ចំពារសក្តិសមតាមសមណសារូប ចំ-ណែកឯគ្រហស្ថវិញ ស្ទៀកពាក់តាមមែបជារុចាសក រុចាសិកា មានដៃ-កាន់ទៀនធូបគ្រឿងសក្ការៈបូជា ហើយមានតាំងនាំក្មួនចេះទៅមនយ៉ាង អូអរគឹកកង ប្រកបដោយភក្ត្រប្រឹមប្រើយនឹកសង្ឃឹមថា នឹងបានជួបព្រះចុះ-ធម្មិក ព្រះអគ្គមហាសន្ធបត្តមក្ក ។ ពួកពុទ្ធបរិស័ទមកជួបជុំហើយ ក៏ចាប់ផ្តើមធ្វើពិធីប្រកាសទេវតា នៅមុខមហាចេតីយខ្ពស់ណ្ណាលោម ខាងលិចព្រះវិហារជាកិច្ចផ្តើមពិធីបុណ្យ ។ សេចក្តីប្រកាសទេវតានេះ គឺត្រូវលើលោក ម៉ី-នាង សូត្រប្រកាសដល់ពួកទេវតាថា:

« បពិត្រទេវតាតាំងឡាយ ដែលអាស្រ័យនៅនាព្រះចេតីយធំ ។



ប្រជាពលរដ្ឋនៅទីក្រុងភ្នំពេញព្រមទាំងនៃប្រជាជន ជាពុទ្ធសាសនិក មានចិត្តសប្បុរស ហើយសើចរៃ ចាំបាច់ដំណើរដ្ឋបាលនៃ
ទ្រង់ស្តេចទៅបើកព្រឹត្តិសម្ពោធផ្លូវព្រះវិហារថ្មីវត្តឧណ្ណាលោម កាលពីថ្ងៃទី ១ - ៦ - ៦៣ ។



សម្តេចព្រះមហាសុរោធាធិបតី សង្ឃឹតាយកគណៈបហានិកាយ ធ្វើបដិសណ្ឋារៈ ចំពោះសម្តេចឪ ព្រះប្រមុខរដ្ឋកម្ពុជា នៅពេលដែលទ្រង់
ស្តេចយាងទៅកាន់វត្តឧណ្ណាលោម នៅថ្ងៃទី ១-៦-៦៣ ដើម្បីទ្រង់ជាព្រះរាជាធិបតី ក្នុងទិវាសពើកឥដ្ឋធ្វើសម្ពោធធ្វង ព្រះវិហារឬីវត្តនេះ ។

សម្តេចព្រះឧបយុវរាជ ព្រះអង្គទ្រង់សព្វព្រះរាជហប្ញទ័យ ជ្រួចសុគន្ធភរិជាតិ្តណោតក លើបាទព្រះហស្តស្តាំនៃសម្តេចព្រះសង្ឃនាយក ដើម្បីជានិមិត្តប្លែនៃការវៀរថ្វាយព្រះវិហារប្រគេនព្រះសង្ឃ ប្រើប្រាស់ក្នុងព្រះពុទ្ធសាសនាតទៅ ។

យើងចាំបានថា សម្តេចព្រះមហាសុមេធាធិបតី ព្រះអង្គបានធ្វើនូវអត្ថាធិប្បាយ អំពីជាតកព្រះបាទពិម្ពិសារក្នុងវេលុវនមគធៈ ដែលបានកសាងវត្តប្រគេនព្រះសង្ឃមកជាបឋមដែរ នៃការសាងព្រះវិហារ ថ្វាយសម្តេចទ្រង់ព្រះសណ្តាប់ ។

ព្រះសង្ឃ ១០០ អង្គ ចាប់ចំរែនព្រះបរិត្តតូច្ចមន្ត ។

លុះចប់ព្រះបរិត្តហើយ សម្តេចទ្រង់ប្រគេនទេយ្យទានចំពោះព្រះសង្ឃ ១០៥ អង្គ ដោយមានសហជីវិន ម៉ែន - ឈុំ អនុរដ្ឋលេខាធិការក្រសួងធម្មការ សហជីវិន ភ័យ - ល្នត ប្រធានគណៈកម្មការនាយកនៃពិធីបុណ្យ សហជីវិនប្រធានគណៈកម្មការចាត់ចែងទេយ្យទាន ជួយលើកទេយ្យទានប្រគេនព្រះសង្ឃផង ជាកិច្ចបញ្ចប់បុណ្យនៅថ្ងៃទី ១ ។

ពួកតុន្ដបរិសទ នៅចាំបានក្នុងថ្ងៃ ទី១ នេះថា សម្តេចទ្រង់សព្វព្រះរាជហប្ញទ័យបរិចាគព្រះរាជទ្រព្យផ្ទាល់ព្រះអង្គចំនួន ៣ ម៉ឺនរៀល ចូលជាព្រះរាជកុសល ក្នុងការស្ថាបនាព្រះវិហារថ្មីនេះទឹងវត្តអាកម នឹងព្រះរាជ

ទ្រព្យមួយចំណែកទៀត សំរាប់ប្រគេនព្រះសង្ឃចំរើនព្រះបរិត្តពុទ្ធមន្ត ។ ពិធីនេះ ចប់សព្វគ្រប់ហើយ សម្តេចឧទ្រង់ស្តេចយាងទៅថ្វាយបង្គំព្រះពុទ្ធរូប អង្គធំស្រកាលេញ ដែលដំកល់លើថ្នាក់ទី ៣ នៃព្រះវិហារ ហើយព្រះអង្គទ្រង់ថ្វាយបង្គំព្រះសង្ឃ ទំនិលាពលរដ្ឋកូនចៅព្រះអង្គ និវត្តចូលព្រះបរមរាជវាំង នៅវេលាម៉ោង ៨ យប់ ដោយមានការធ្វើតាវៀកច្ន ថ្វាយជាព្រះរាជកិត្តិយស ដូចពេលដែលស្តេចយាងមកដល់ ។

នៅវេលាម៉ោង ៨ នៃរាត្រីនេះ មានទិមន្តព្រះធម្មកថិកសំដែងព្រះធម្មគោរព បំពេញការកុសល នៅថ្នាក់កណ្តាលនៃព្រះវិហារ មិនដែរប៉ុណ្ណោះ នៅក្នុងរាត្រីនោះ គណៈកម្មការបុណ្យ ចានចាត់ចែងឲ្យមានការសំដែងរបាំ ជូនពុទ្ធសាសនិកជនផង ។

ថ្ងៃទី ២ ថ្ងៃអាទិត្យ ១១ កើត ខែ ឆ្នាំ ជូតិ ពស (ថ្ងៃទី ២ មិថុនា ឆ្នាំ ១៩៦៣)

ពេលព្រឹក អង្គាសយាគូប្រគេនព្រះសង្ឃ ១០០ អង្គ ដែលចំរើនព្រះបរិត្តពីល្ងាច ។

នៅរសៀល ៤ ព្រះកថិកសង្ឃ ១០០អង្គ ជាដែលនោះ ស្វាធ្យាយធម្មពុទ្ធជ័យមង្គល (ភាហ៊ុំ) ទំនិតភេកុដសូត្រ ក្នុងវិហារត្រង់ថ្នាក់កណ្តាល ។ ចំណែកពុទ្ធបរិស័ទជាច្រើនរយនាក់នាក់ ចានប្រកបគ្នាតាមចំណាត្រ ។

នៅម៉ោង ១០-៣០ មានការប្រគេនចង្ហាន់ថ្វាយព្រះសង្ឃ ចំនួន ១០០ អង្គនោះ នៅវិហារឈោបនជ្ឈាន ដោយមានលោក អ៊ឹង-គីមឆន ជាប្រធាននៃគណៈកម្មការចាត់ចែងខាងចង្ហាន់ ជាអ្នករៀបចំ ។

ពេលថ្ងៃរសៀល វេលាម៉ោង ៣ ទិមន្តព្រះធម្មកថិកមួយអង្គគង់វត្តមហាមន្ត្រី ទេសនា គម្ពីរទេសជាតក យ៉ាងសង្ខេប រួចហើយរៀបចំគ្រឿងសក្ការបូជា នៅលើវិហារថ្នាក់ខាងលើ ដើម្បីនឹងអភិសេកព្រះពុទ្ធរូបអង្គធំដែលតំកល់នៅទីនោះ ។

ម៉ោង ៥ ពួកពុទ្ធបរិស័ទ ប្រគេនកេសដួងព្រះតិក្ខុសង្ឃ នៅជុំវិញមហាកុដិ ។

ម៉ោង ៨ យប់ ទិមន្តព្រះសង្ឃ ១០០ អង្គដដែរទៀត ចំរើនព្រះបរិត្តពុទ្ធមន្ត ក្នុងព្រះវិហារថ្នាក់កណ្តាល ។ លុះដល់ម៉ោង ៩ ទើបទិមន្តព្រះមហា អ៊ុក-ម៉ៅ មកពីវត្តជោតនារាម (ចឹងកុក) វែត្រកំពង់ចាម ទេសនា បឋមត្រាស ក្នុងថ្នាក់ខាងលើចង្អស់ ។ តមក ទិមន្តព្រះសង្ឃ ២ អង្គ គង់នៅវត្ត ណ្ណោមតីព្រះធម្មធរ ឡុង-សែម ទីជ្រៃបាត់មុខនៅភ្នំពេញ ញ៉ែល-នាង ស្វាធ្យាយបាលីពុទ្ធាភិសេក ហើយទិមន្តព្រះសង្ឃ ៣០ អង្គ ស្វាធ្យាយធម្មាភិសេកព្រះពុទ្ធរូប ចំណែកពុទ្ធបរិស័ទវិញ បាចសាចផ្កាក្រអូប ។ ទីឯក្រោះព្រំសុគន្ធភីរលើព្រះពុទ្ធរូប ដោយមានលោកអាវុត្រហស្តម្ចាស់សូត្របាលី ព្រមទាំងសំកុយផង ឲ្យពុទ្ធ-

បរិស័ទថាតាមត្រម ។ គ្នា មួយសន្លាក់ម្ខង ។ ថា: ជិយោ ហិ ពុទ្ធស្ស សិរីមតោ អយំ មោរស្ស ប បាបិមតោ បរាជិយោ «ជំនះនេះជាជ័យជំនះនៃព្រះពុទ្ធមានសិរីសួស្តី ! រីឯបរាជ័យជារបស់មារ មានចិត្តបាប !» ព្រះឈ្នះមារហើយ មានចិត្តបាប ចាញ់ហើយ ! ។


នៅរាត្រីយប់ទី ២ នេះ ក៏មានរបាំ ឱ្យពុទ្ធបរិស័ទរីករាយ នៅមាត់ក់-ពង់វត្តខ្ពស់ណ្ហាសោម ដូចយប់ទី ១ ដែរ ។

ថ្ងៃទី ៣-ថ្ងៃបន្ទូ ១២ កើតខែផ្នាំ ជូតិ (ថ្ងៃទី ៣ មិថុនា ឆ្នាំ ១៩៦៣)

នៅវេលាព្រឹក កម្មវិធីបុណ្យ ចាប់តាំងពីម៉ោង ៧ ដល់ម៉ោង ១០-៣០ ដូចថ្ងៃទី ១ ដែរ ។

នៅវេលាម៉ោង ៣ រសៀល ពួកពុទ្ធបរិស័ទ ជួបជុំរៀបចំពិធីសីមា នៅវិហារត្រង់ថ្នាក់ខាងក្រោម ។ ចំណែកតំណូសង្ឃនៅវត្តដដែ ចាន់ទិមន្ត មកកាន់វត្តខ្ពស់ណ្ហាសោម ដើម្បីធ្វើសីមាសង្ឃកម្ម ចំនួន ១.០០០ អង្គ ។ តមក គេប្រគេនកេសជ្ជៈថ្វាយព្រះសង្ឃនៅជុំវិញមហាកុដិ ។

ម៉ោង ៨ យប់ គណៈកម្មការចាត់ចែងបុណ្យ និមន្តព្រះសង្ឃចំនួន ១០០ អង្គ ចំរើនព្រះបរិត្តពុទ្ធមន្តសង្គីប នៅក្នុងវិហារថ្នាក់ខាងក្រោម ។ លុះចប់ព្រះបរិត្ត សម្តេចព្រះមហាសុមេធាធិបតី ជួន - ណាត សង្ឃនាយក មានពុទ្ធដីកាវែកញែកពីរឿសីមាយ៉ាងវែង ក្នុងចំណោមព្រះសង្ឃ ១០០



សម្តេចព្រះនរោត្តម សីហនុ ព្រះប្រមុខរដ្ឋកម្ពុជា អគ្គសាសនូបត្ថម្ភក៍ ទ្រង់កាត់ផ្តាច់ឫសសីមាក្រែ ទម្លាក់នៅក្នុងរណ្តៅ ជាឱកាសដ្ឋាបនៃ
ការបញ្ចុះសីមាព្រះវិហារថ្មីវត្តនន្ទាលោម នៅថ្ងៃទី ៤ - ៦ - ៦៣ ឯអ្នកដែលកាន់កាប់ដីវត្ត គឺសហជីវិន រ៉ាយ ល្អត ប្រធាននៃពុទ្ធិកសមាគមចិនភក្តីលោកមជ្ឈិមណ្ឌលភូមិភាគតម្កុដរង្សី ។

អង្គ គួរឲ្យចាប់អារម្មណ៍ពេកណាស់ ។

បន្ទាប់មកទៀត សម្តេចព្រះអង្គឯង ធ្វើជាវិសុំតាម តង់តណ្ហាលដំទុំ សង្ឃ ១-០០០ អង្គ ហើយសូត្រថាលីថា: អ្ឃំ ភូមិប្បទេសោ វិសុំ គាមោ ហោតុ ។ ព្រះថេរព្រះអង្គ គឺព្រះមុនីកោសល សូរ-ហាយ នំធ្វើព្រះសាសនមុនី កឹម-តូ សូត្រដកថាលីសីមាចាស់ ទៅក្នុងព្រះវិហារ ហើយព្រះសង្ឃទាំងអស់ ចេញមកខាងក្រៅព្រះវិហារ ឈរជាហត្ថបាសក្នុងតាកងដែលគេគួសស ។ លុះតាំងសីមាសង្ឃកម្មរួចហើយ ព្រះសង្ឃនិមន្តទៅកាន់វត្តរៀងព្រះអង្គ ។

យប់នេះ នៅតែមានពិធីសិល្បៈដូចយប់មុនដែរ ។

ថ្ងៃទី ៤-ថ្ងៃអង្គារ ១៣ កើត ខែ ឆ្នាំ ជូតិ (ថ្ងៃទី ៤ ម៉ិថុនា ឆ្នាំ ១៩៦៣

ថ្ងៃទី ៤ នេះ គឺជាថ្ងៃដែលត្រូវធ្វើតាំងបុណ្យ ។ ម៉ោង ៧ ព្រះសង្ឃ ចំនួន ១០០០ អង្គ បានមកជួបជុំ ហើយចំណែកពុទ្ធបរិស័ទវិញ ប្រុងប្រៀបរៀបចំកន្ទេងទុក សំរាប់ដាក់ជាត្រព្រះសង្ឃ ។

ចាប់តាំងពីម៉ោង ៨ កន្លះទៅ នៅក្នុងឥន្ទា មុខវិហារវត្តនុណ្ណាលោម មានការជួបជុំឥស្សរជនជាន់ខ្ពស់ ដែលយើងសង្កេតឃើញដូចអាទិ៍តីសម្តេចជហ្វាកំង ប៉ែន-នុត សហាសដ៏ទៃ ពៅសែនកុសល ប្រធានវង្គសភា

អ្នកអង្គម្ចាស់ នរោត្តម កន្ទុល នាយករដ្ឋមន្ត្រី ឯ-ឧ-សឺន-សាន ទីប្រឹក្សាផ្ទាល់ព្រះអង្គ សមាជិករដ្ឋាភិបាល សហជីវិន ទេព-ផន ព្រះ-រាជប្រតិភូប្រចាំក្រុងភ្នំពេញ សមាជិកខ្ទះនៃសភាតំណាងរាស្ត្រ ព្រមទាំងគណៈកម្មការចាត់ចែងពិធីបុណ្យទំនៀមទម្លាប់ប្រុសស្រី ជាន់ត្រៀមរង់ចាំព្រះរាជដំណើរនៃសម្តេចឥ ដែលព្រះអង្គទ្រង់ស្តេចយាងមក ដើម្បីកាត់ឫសសីមានទីជាក់ជាត្រព្រះសង្ឃ ។

នៅម៉ោង ៩ ព្រឹក សម្តេចសហជីវិនព្រះប្រមុខរដ្ឋ ដោយមាន ឯ-ឧ-តូ-វុន សមាជិកឧត្តមក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក លោកឧត្តមសេនីយ៍ង៉ោ ហ៊ី ទីប្រឹក្សាបច្ចេកទេសផ្ទាល់សម្តេចព្រះប្រមុខរដ្ឋ លោកវរសេនីយ៍ឯក មាស-ហ៊ុល ព្រមទាំងភរជបរិពារដទៃទៀតជាច្រើនផង បានស្តេចយាងដល់វត្តឧណ្ណាលោម ឯក្រុមមាហានទីន្ត្រមាហានក្លែងបានសំដែងគារវកិច្ច ថ្វាយជាព្រះកិត្តិយសតាមទំនៀម ។

នៅពេលសម្តេចយាងចុះពីរថយន្ត ព្រះអង្គបានទទួលការគ្រាបថ្វាយបង្គំពីវរជនជាន់ខ្ពស់ជាច្រើន ហើយទ្រង់ស្តេចយាងលើកំពស់ចូលទៅកន្លែងវិហារជាន់ក្រោមតាមទ្វារខាងត្បូង ដែលមានពាក្យព្រួយបានថ្វាយបុប្ផមាលា ជានិមិត្តរូបនៃការថ្វាយព្រះពរស្វាគមន៍ រួចទ្រង់ស្តេចយាងទៅគ្រាបថ្វាយបង្គំព្រះសង្ឃ មានសម្តេចព្រះសង្ឃនាយកជាប្រធាន ។

លុះសម្តេចឥ ទ្រង់ប្រថាប់សម្រួលព្រះឥរិយាបថរហើយ ទ្រង់



ព្រះធាយាលក្នុងសាងលើ ព័សម្តេចព្រះនរោត្តម សីហនុ ទទួយវាងជាព្រះប្រមុខរដ្ឋកម្ពុជាទ្រង់ឡាយប្រហស្សលេខាលើក្រាំងមាសនៅ
ថ្ងៃទី ២ នៃព្រះរិបារថ្មីវត្តឧណ្ណាលោម កាលពីថ្ងៃទី ៤ - ៦ - ៦៣ ជាថ្ងៃបង្ហើយបុណ្យសម្ពោធនិងបញ្ចុះសីមា ។

ប្រារព្ធកាត់ឫសសីមា តាមសូរតែងជាសញ្ញា នៃការបញ្ចុះសីមាវត្តពុណ្ណាលោមនេះ ។

ព្រះសង្ឃចាំឆ្ងាយ មានសម្តេចព្រះសង្ឃនាយកជាប្រធាន ចាន ស្វាធ្យាយធម៌ដយន្តោ ។ លុះចប់ធម៌ហើយ សម្តេចព្រះសង្ឃនាយក ចានថ្លែងថ្វាយព្រះពរជកុសល ជាពិសេស ថ្វាយចំពោះព្រះវិញ្ញាណក្ខន្ធនៃ សម្តេចព្រះមហាកាញ្ចនកោដ្ឋ ព្រះអតីតព្រះមហាក្សត្រ ដែលទ្រង់ទើបព្រះសុរិណ្ណគត ។

មុនដែលសម្តេចឥត្រមចាំងព្រះពរជបារាព្វាយបង្គំលាព្រះសង្ឃ ព្រះព្រះអង្គទ្រង់ឡាយព្រះហស្តលេខា លើក្រាំងមាស ប្រចាំវិហារវត្តពុណ្ណាលោម ហើយវែនជាខ្នង់ខ្ពស់ចាំងអស់ កំចានចុះហត្ថលេខាជាបន្តបន្ទាប់គ្នាដែរ ។ តមក ព្រះអង្គស្តេចយាងប្រារព្ធដាក់ចាត្រព្រះសង្ឃមួយសង្កាត់ចំនួន ១០០ អង្គ ។ សូមជ្រាបថា ពិធីដាក់ចាត្រនេះ ចែកជា ១០ សង្កាត់ មួយសង្កាត់ ។ មានព្រះសង្ឃ ១០០ អង្គ ឯចង្ហាន់ដាក់ចាត្រ នោះ ចរិបូណិហួសវិស័យ ។

លុះចប់ពិធីដាក់ចាត្រនេះហើយ សម្តេចសហជីវិន ព្រះប្រមុខវង្ស ទ្រង់ថ្លែងសេចក្តីសំណេះសំណាលដ៏ជាទីគាប់ចិត្ត ទៅកាន់ព្រះសង្ឃនិមន្តមកវិស័ទជាភ្ងនថៅព្រះអង្គ ហើយព្រះអង្គទ្រង់ថ្វាយបង្គំលាព្រះសង្ឃ ទីណាសាពុទ្ធបរិស័ទជាភ្ងនថៅ នៅតែទៅកាន់ព្រះពរដំណាក់វិញ ដោយសុវត្ថិភាព ។

សូមជំរាបបញ្ជាក់ថា តាមកម្មវិធីដែលបានគ្រោងទុក ពិធីបុណ្យ
ក្នុងព្រះវិហារ និងបញ្ចុះសីមា នាវត្តទុណ្ណាលោមនេះ មានចំនួនតែ
៣ យប់ ៤ ថ្ងៃប៉ុណ្ណោះទេ តែនៅថ្ងៃបន្ទើយ គឺថ្ងៃទី ៤ មិថុនា
ខាងក្រោយការដាក់ឆ្នាត្រប្រគេនព្រះសង្ឃហើយ សម្តេចឧ ទ្រង់ព្រះបរម
រាជានុញ្ញាតឲ្យបន្តអស់ ១ យប់ ថ្ងៃទី ៤ នេះទៀត ដើម្បីបំពេញសទ្ធា និង
បំពេញការសប្បាយរីករាយ ដល់ពុទ្ធបរិស័ទជាកូនចៅ ដូច្នេះពិធីបុណ្យ
ដ៏ធំនេះ ចែរជាមានរយៈវេលាបួនយប់ បួនថ្ងៃគត់ ។